♣ ♣ ♣

សាមគ្គីបានសុខព្រះពុទ្ធទេសនា
ចូរជាតិខេមរាផ្សះផ្សាទើបជា
ស្រឡាញ់ជាតិខ្មែរត្រូវតែការពារ
ខ្មែរសាមគ្គីគ្នាកម្ពុជាបានសុខ ។

♣ ♣ ♣


**ភិក្ខុវិនយធរោ មហាយិន-នឿន**

**វត្តខ្មែរសាន់តាអាណា**

*2630 N. Grand Ave.*
*Santa Ana, CA 92705*
*(714) 744-2834*
U.S.A.


ព.ស.២៥៥២

**វិសុទ្ធិមគ្គប្រែ**

**ភាគទី ១**

# វិសុទ្ធិមគ្គប្រែ

## ភាគ ទី ១

ប្រែដោយ

សាស្ត្រាចារ្យ ជិត-ជន (ហៅយិន-សុត្រ)

រៀបរៀងដោយ

ភិក្ខុវិនយធរោ មហាយិន-នឿន

* * *


*បោះពុម្ពផ្សាយជាធម្មទានចេញពី*

**វត្តខ្មែរសាន់តាអាណា**

សហរដ្ឋអាមេរិក

*លើកទី១*

ចំនួន ៥,០០០ ក្បាល



*រក្សាសិទ្ធិ*



ព. ស. ២៥៥២

# រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ



**ភិក្ខុវិនយធរោ មហាយិន-នឿន**

*កើត ថ្ងៃទី១០ ខែកក្កដា ១៩៥២*

*ភូមិទួលព្រាំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង*



**សាស្ត្រាចារ្យ ឌិត-ឌន**

*កើត ថ្ងៃទី០៦ ខែ០១ ឆ្នាំ ១៩៣៥*

*នៅភូមិត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ*

រូបកាយ របស់សត្វទាំងឡាយ តែងចាស់គ្រាំគ្រា

ចំណែកឯនាមនិងគោត្រមិនដែលចាស់ជរាឡើយ។

# អារម្ភកថា

(របស់អ្នករៀបរៀង)

សៀវភៅ “បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ” ដែលសាធុជនអ្នកស្រឡាញ់ព្រះធម៌ កំពុងតែអានជាប់នឹងដៃនេះ បានកើតឡើងដោយព្រះរាជយោបល់នៃ សម្ដេចព្រះមហាឃោសានន្ទ (វ៉ា-យ៉ាវ) នៅពេលដែលខ្ញុំ (ភិក្ខុវិនយធរោ មហាយិន-នឿន) បានយកគម្ពីរមង្គលត្ថទីបនីប្រែទាំងបួនភាគ ទៅថ្វាយសម្ដេច នៅវត្តសំពៅមាស ខែវិសាខ ឆ្នាំ កុរ ឆស័ក ព.ស. ២៥៣៩ គឺឆ្នាំ ១៩៩៥ នោះ ។ សម្ដេចទ្រង់បានមានព្រះរាជបន្ទូលថា “សៀវភៅមង្គលត្ថទីបនីប្រែ ទាំង ៤ ភាគនេះ ជួយជាប្រយោជន៍ ដល់ពុទ្ធបរិស័ទខ្មែរយើងបានច្រើនណាស់... បើអាចប្រែគម្ពីរ វិសុទ្ធិមគ្គ ទាំងបីភាគ [១] ដែលនៅជាភាសាបាលី មកជាភាសាសំរាយខ្មែរយើងបានទៀតនោះ គឺជាការប្រសើរណាស់ ព្រោះខ្មែរយើងសព្វថ្ងៃនេះ មានការខ្វះខាតក្បួនច្បាប់ ខាងផ្នែកព្រះពុទ្ធសាសនា ច្រើនណាស់ សូមប្រែនិងរៀបរៀងសៀវភៅ វិសុទ្ធិមគ្គ ទាំងបីភាគ ឲ្យបានជាបន្តទៅទៀត ដើម្បីជួយខ្មែរយើង...” ។

ហេតុនេះ ខ្ញុំក៏បានទទួលថា នឹងប្រែ ហើយរៀបរៀងធ្វើសៀវភៅវិសុទ្ធិមគ្គ នេះ ឲ្យបានសម្រេច សមតាមព្រះរាជយោបល់នៃសម្ដេចព្រះមហាឃោសានន្ទ ។ នៅក្នុងឆ្នាំកុរ ឆស័ក ព.ស ២៥៣៩ ដដែលនោះ ខ្ញុំក៏បានជួបប្រឹក្សា ជាមួយលោកសាស្ត្រាចារ្យជាច្រើនរូប ដែលកំពុងតែបង្រៀនសមណនិស្សិត នៅពុទ្ធិកវិទ្យាល័យ នាទីក្រុងភ្នំពេញ រួមមាន

១- គម្ពីរ វិសុទ្ធិមគ្គទាំងបីភាគ មានលោកអ្នកប្រែពីមុនមកខ្លះៗ ហើយដែរ ប៉ុន្តែមិនបានប្រែឲ្យចប់សព្វគ្រប់ទាំងអស់ទេ ប្រែកាត់ចោលបាលីភាគច្រើន គឺប្រែជ្រើសរើសយកតែសេចក្ដីបែបខ្លីៗ មករៀបរៀងតែប៉ុណ្ណោះឯង ពុំបានចប់សព្វគ្រប់ទេ ។



លោកសាស្ត្រាចារ្យ រស់-សារេវន, លោកសាស្ត្រាចារ្យ ជិត-ជន ហៅ យិន-សូត្រ) និង សាស្ត្រាចារ្យ ទែន-សុខន ជាដើម ដើម្បីរួមដៃគ្នាបកប្រែគម្ពីរ បករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ដែលនៅជាភាសាបាលីមកជាភាសាសម្រាយខ្មែរយើង ឲ្យបានចប់សព្វគ្រប់ទាំងបីភាគ ហើយក៏បានសំរេចគ្នាជាឯកច្ឆ័ន្ទថា ឲ្យលោកសាស្ត្រាចារ្យ ជិត-ជន ទទួលប្រែភាគទី១ លោកសាស្ត្រាចារ្យ រស់-សារេវន ប្រែភាគទី២ [១] និង ឲ្យលោកសាស្ត្រាចារ្យ ទែន-សុខន ទទួលប្រែភាគទី៣ ហើយបានសំរេចឲ្យខ្ញុំជាអ្នកកែសំរួល ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង រៀបរៀង ព្រមទាំងរកនូវបវារិកាដើម្បីបោះពុម្ពផង ។ បន្ទាប់ពីបានប្រឹក្សាគ្នារួចស្រេចហើយ យើងទាំងអស់គ្នា មានសេចក្ដីរំភើបខ្លាំងណាស់ចំពោះកិច្ចការនេះ ។

នៅពេលដែលលោកសាស្ត្រាចារ្យទាំង ៣ បានបកប្រែមកជាភាសាខ្មែរយើងខ្លះៗ ហើយ ក៏បានបញ្ជូននូវសំណៅ ដែលសរសេរជាអក្សរដៃ ទៅឲ្យខ្ញុំ ដើម្បីកែសំរួលផ្ទៀងផ្ទាត់ និងរៀបរៀងជាបណ្ដើរៗ ពេលដែលខ្ញុំបានទទួលសំណៅនោះហើយ ខ្ញុំបានយកទៅពិនិត្យផ្ទៀងផ្ទាត់ ជាមួយនឹងគម្ពីរវិសុទ្ធិមគ្គ ជាភាសាបាលី ដែលព្រះពុទ្ធឃោសាចារ្យ បានរៀបរៀងជាងមួយពាន់ឆ្នាំ កន្លងមកហើយនោះ ដើម្បីកុំឲ្យមានការខុសភ្លាំងភ្លាត់ពីភាសាបាលីដើមនោះ ដោយបានយកចិត្តទុកដាក់បំផុត... (តែបើមានការភ្លាំងភ្លាត់ដោយអចេតនា សូមលោកអ្នកអានជួយកែតម្រូវផង)។

ដូច្នេះ ការដែលលោកសាស្ត្រាចារ្យទាំងនោះ បកប្រែនេះ ខ្ញុំឃើញថា បានប្រែតាមព្រះត្រៃបិដកខ្លះ ប្រែផ្សេងពីព្រះត្រៃបិដកខ្លះ តែសេចក្ដីនឹងអត្ថន័យមិនជាខុសគ្នាទេ ។ លុះខ្ញុំឃើញដូច្នេះ ខ្ញុំក៏បានកែសំរួលឲ្យ

១-សាស្ត្រាចារ្យជិត-ជនប្រែតពីសាស្ត្រាចារ្យរស់-សារេវនពីអនុស្សតិនិទ្ទេសដល់ចប់។

ត្រូវតាមព្រះត្រៃបិដកជាភាសាខ្មែរយើង ហើយខ្ញុំបានដាក់ជាលេខយោង ដើម្បីបញ្ជាក់ប្រាប់គម្ពីរ (ភាគ និង ទំព័រ) ឲ្យបានច្បាស់ និង ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវបន្ថែម សំរាប់សមណនិស្សិតនិងអ្នកបតិបត្តិ ។

ខ្ញុំបានយកសំណៅវិសុទ្ធិមគ្គប្រែ ភាគទី១ ដែលលោកសាស្ត្រាចារ្យ ជិត-ជន បានប្រែហើយនោះ មកកែសំរួល និង រៀបរៀង មុនគេបង្អស់ នៅក្នុងខែមាឃ ព.ស. ២៥៣៩ (១២ មីនា ឆ្នាំ ១៩៩៦) ហើយបាន ចប់សព្វគ្រប់ នៅថ្ងៃច័ន្ទ ៣ កើត ខែផល្គុណ ឆ្នាំជូត អដ្ឋស័ក ព.ស. ២៥៤០ ត្រូវនឹងថ្ងៃទី១០ ខែមីនា ១៩៩៧ ។

បន្ទាប់ពីរៀបរៀងភាគទី១ ចប់ហើយទើបខ្ញុំចាប់ផ្ដើមកែសំរួលផ្ទៀងផ្ទាត់ ភាគទី៣ បន្តទៅទៀត ដែលលោកសាស្ត្រា ទែន-សុខន បានប្រែខ្លះៗហើយ ។ ជាអកុសល គួរឲ្យស្ដាយខ្លាំងណាស់ លោកសាស្ត្រាចារ្យ ទែន-សុខន ប្រែបានពាក់កណ្ដាលតែប៉ុណ្ណោះ លោកក៏បានអនិច្ចកម្មទៅ បន្សល់ទុកនូវភារៈនេះឲ្យទៅលោកសាស្ត្រាចារ្យ នូ-ឌឹម ទទួលប្រែបន្តទៅទៀត តែលោកសាស្ត្រា នូ-ឌឹម ប្រែបានតែបីបួនទំព័រ ក៏ឈប់ទៅវិញ ព្រោះមានការរវល់ខ្លាំងពេក ដូច្នេះភារៈនេះ ត្រូវធ្លាក់មកលើខ្ញុំអ្នករៀបរៀងទៅវិញ ហើយខ្ញុំក៏បានចាប់ផ្ដើមប្រែ... និង បានចប់សព្វគ្រប់នៅថ្ងៃ ពុធ ៨ រោច ខែកត្តិក ឆ្នាំខាល សំរិទ្ធិស័ក ព.ស. ២៥៤២ ត្រូវនឹង ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ។ ហើយបានឲ្យ ភិក្ខុ អៀ-សៅ ជួយវាយចម្លង... តែពុំទាន់បានសំរេចទេ ខ្ញុំត្រូវកែសាជាថ្មីម្ដងទៀត ។

ចំណែកឯសំណៅ វិសុទ្ធិមគ្គប្រែ ភាគទី២ វិញនោះ ភិក្ខុ មហាសម-យស វត្តម៉ាក់ស៊ី នៅប្រទេសបារាំង ទទួលយកទៅកែសំរួល និង រៀបរៀង តែលោករវល់ខ្លាំងពេក ក៏បានប្រគល់មកឲ្យខ្ញុំកែសំរួល និង រៀបរៀង នៅឯប្រទេសសហរដ្ឋអាមេរិកវិញ ខ្ញុំបានទទួលសំណៅវិសុទ្ធិមគ្គ



ភាគទី២ ដែលលោកសាស្ត្រា រស់-សារៈឆន ប្រែនោះ មកចាប់ផ្ដើមកែសំរួល និង រៀបរៀង នៅថ្ងៃច័ន្ទ ៥ កើត ខែភទ្របទ ឆ្នាំច អដ្ឋស័ក ព.ស. ២៥៥០ ត្រូវនឹងថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៦ ហើយបានចប់សព្វគ្រប់ នៅថ្ងៃអង្គារ ៣កើត ខែចេត្រ ឆ្នាំជូត នព្វស័ក ព.ស. ២៥៥១ ត្រូវនឹងថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៨ ។

គម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ដែលក្របានបោះពុម្ពផ្សាយនោះ មកពីរង់ចាំភាគ ទី២ ផង និង ព្រោះពុំទាន់មានថវិកាគ្រប់គ្រាន់ផង ។

ក្នុងការប្រែរៀបរៀងនេះ ខ្ញុំសូមខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះព្រះគុណ ព្រះថេរានុថេរៈ អស់លោកដែលឆ្ងៀវឆ្លាតក្នុងភាសាខ្មែរ និងភាសាបាលី ហើយសូមមេត្តាអនុគ្រោះ ដល់អ្នករៀបរៀងផង ។ ខ្ញុំសូមទទួលនូវការរិះគន់ពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលបានឃើញកំហុសត្រង់កន្លែងណាទីមួយនោះ ហើយផ្ដល់ជាយោបល ដើម្បីនឹងជួយកែលំអគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ឲ្យបានល្អប្រសើរឡើង និង ដើម្បីជួយទ្រទ្រង់នូវអាយុជីវិត នៃព្រះពុទ្ធសាសនា របស់អង្គព្រះសម្មាសម្ពុទ្ធនៃយើង ឲ្យបានរីកចំរើន រុងរឿង រៀងតទៅមុខទៀត ។ សូមអរព្រះគុណ និង សូមអរគុណទុកជាមុន ។

**ភិក្ខុវិនយធរោ មហាយិន-នឿន**

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២

ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៨

## សេចក្ដីថ្លែងអំណរគុណ

ខ្ញុំអ្នករៀបរៀង សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ

-ចំពោះលោកសាស្ត្រាចារ្យទាំងបួនរូប ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ របស់លោក ហើយបានប្រឹងប្រែងប្រែគម្ពីរបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គទាំង ៣ ភាគនេះ ឲ្យបានសម្រេច សមដូចសេចក្ដីប៉ងប្រាថ្នា តាំងតែពីដើមរៀងមក រហូតដល់ទីបញ្ចប់ ។

-ចំពោះភិក្ខុ ប្រាជ្ញ-សារាន និង ភិក្ខុ ហួត-វ៉ៃត ព្រមទាំងសហការីដែលបានជួយយកសំណៅវិសុទ្ធិមគ្គប្រែ អំពីលោកសាស្ត្រាចារ្យ ជិត-ជន មកឲ្យខ្ញុំដើម្បីកែសំរួល និង រៀបរៀង ។

-ចំពោះភិក្ខុ អឿ-សៅ ដែលបានយកចិត្តទុកដាក់ជួយវាយចម្លងគម្ពីរវិសុទ្ធិមគ្គប្រែ ភាគទី៣ និង ចំពោះព្រះមហា សម-យស ភាគ ទី២ ។

-ចំពោះសមណនិស្សិត និង សាស្ត្រាចារ្យមួយចំនួនទៀតជាពិសេសគឺលោកសាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យ អ៊ុំ-ធួន វត្តពោធិវាល ទីរួមខេត្តបាត់ដំបង ដែលត្រូវការគម្ពីរវិសុទ្ធិមគ្គប្រែទាំងបីភាគនេះ ជាងគេហើយទទួចចង់បាន និង ជំរុញ... ឲ្យខ្ញុំប្រញាប់រៀបរៀង ដើម្បីទុកជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាផង និង ដល់សមណនិស្សិត ព្រមទាំងពុទ្ធបរិស័ទផង...ដែលជាហេតុធ្វើឲ្យខ្ញុំរឹងរឹតតែមានកម្លាំងកាយ-ចិត្តខិតខំកែសំរួល និពិត្យផ្ទៀងផ្ទាត់ និង រៀបរៀង ដើម្បីឲ្យបានសំរេចជាគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះឡើង ។

-ចំពោះព្រះថេរានុថេរៈ ព្រមទាំងពុទ្ធបរិស័ទ គ្រប់មជ្ឈដ្ឋានទាំងអស់ដែលបានជួយឧបត្ថម្ភ ក្នុងធម្មទាននេះ ទាំងថវិកា ទាំងកម្លាំងប្រាជ្ញា និងស្មារតី តាំងតែពីដើមមក រហូតដល់គម្ពីរវិសុទ្ធិមគ្គប្រែនេះ ចប់បរិបូរ ។

## ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសព្រះរាជកុសល ដែលកើតពីធម្មទានដ៏ថ្លៃថ្លានេះ ថ្វាយ

-សម្ដេចព្រះមហាឃោសានន្ទ (វ៉ា-យ៉ាវ) សូមទ្រង់សោយនូវព្រះរាជមហាកុសលនេះ សមតាមព្រះរាជហឫទ័យ ។

-សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ ទាំងមហានិកាយ ទាំងធម្មយុត្តដែលទ្រង់សោយនូវព្រះទីវង្គត កន្លងទៅហើយនោះ សូមព្រះអង្គទ្រង់សោយព្រះរាជមហាកុសលនេះ ។

សូមឧទ្ទិសកុសលនៃធម្មទានានិសង្សនេះ ប្រគេន

-ចំពោះព្រះថេរានុថេរៈព្រះសង្ឃសមណនិស្សិតដែលបានបូជាជីវិតដើម្បីព្រះពុទ្ធសាសនា សំរាប់ទុកឲ្យព្រះសង្ឃជំនាន់ក្រោយ បានយកធ្វើជាគំរូដ៏ល្អៗ... សូមបានទទួលបុណ្យកុសលនេះកុំបីខាន ។

-ចំពោះលោកសាស្ត្រាចារ្យ វ៉ែន-សុខន ដែលបានកសាងធម្មទានខិតខំប្រែ គម្ពីរវិសុទ្ធិមគ្គ ភាគទី៣ ទោះជាពុំទាន់បានចប់ចុងចប់ដើម ក៏ដោយ នេះជាស្នាដៃមួយដ៏ល្អ សំរាប់ព្រះពុទ្ធសាសនា... សូមលោកសាស្ត្រាចារ្យបានទទួលនូវកុសលនេះ ហើយបានទៅកើត ក្នុងសុគតិភពសមតាមមនោរថទៅហោង ។

-ចំពោះអ្នកដឹកនាំ ពួកបញ្ញវន្ត អ្នកស្នេហាជាតិ យុវជនយុវតី ប្រជាពលរដ្ឋខ្មែរ គ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានបូជាជីវិត ដើម្បីមាតុភូមិដោយទឹកចិត្តដ៏ស្មោះត្រង់ សូមឲ្យវិញ្ញាណក្ខន្ធអ្នកទាំងនោះបានទទួលនូវកុសលនេះ សូមបានទៅកើត ក្នុងទីសុខទីសួគ៌ កុំបីខានឡើយ ។

សូមប្រគេនមគ្គផលដែលកើតអំពីធម្មទាននេះ ចំពោះព្រះតេជះព្រះគុណ ព្រះថេរានុថេរៈ ព្រះសង្ឃគ្រប់អង្គ ដែលបានជួយឧបត្ថម្ភ ក្នុងការ

*បោះពុម្ពគម្ពីរវិសុទ្ធិមគ្គប្រែ ទាំងបីភាគនេះ ឲ្យបានសំរេចជាស្ថាពរ សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីជាម្លប់ដ៏ត្រជាក់ និង ជាទីពឹងពាក់ពំនាក់អាស្រ័យដល់ពុទ្ធបរិស័ទទាំងឡាយតរៀងទៅ ។*

*សូមញាតិញោម ជាពុទ្ធបរិស័ទ អស់លោក លោកស្រី លោកយាយ លោកតា កុមារ កុមារីទាំងអស់ ដែលបានជួយឧបត្ថម្ភផងដែរនោះ បានទទួលនូវកុសលដែលកើតពីធម្មទាននេះស្មើៗ គ្នា ប្រាថ្នាយ៉ាងណាៗ សូមឲ្យបានសំរេច សមដូចសេចក្ដីប្រាថ្នា ទៅហោង ។*

*សូមជូនបុណ្យកុសលនេះផងដែរ ដល់អ្នកដឹកនាំខ្មែរ គ្រប់ជាន់ថ្នាក់ គ្រប់គណៈបក្សទាំងអស់ សូមដឹកនាំប្រទេសជាតិ ប្រកបដោយជោគជ័យ ដើម្បីប្រយោជន៍សុខ ដល់ប្រជាជនដែលសង្ឃឹមទាំងស្រុងទៅលើមាគ៌ានៃការដឹកនាំដ៏ត្រឹមត្រូវ សុចរិត យុត្តិធម៌ និង សាមគ្គីភាព... ។*

**ខ្មែរសាមគ្គីគ្នា កម្ពុជាបានសុខ !**
**ខ្មែរបែកបាក់គ្នា កម្ពុជាវិនាស !**

*ខ្មែរត្រូវស្រឡាញ់ខ្មែរ*

*ខ្មែរត្រូវថែរក្សាទឹកដីខ្មែរ...កេរពីដូនតាឲ្យបានគង់វង់ល្អ*

**ភិក្ខុវិនយធរោ មហាយិន-នឿន**

វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក

*ថ្ងៃច័ន្ទ ១៥ កើត ខែវិសាខ ឆ្នាំជូត សំរិទ្ធិស័ក ព.ស. ២៥៥២*
*ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ២០០៨*



## ត្រូវស្នេហាជាតិ

ខ្មែរអើយរក្សាកេរមត៌កជាតិ　　កុំឲ្យខូចខាតការពារឲ្យគង់
នាំគ្នាស្ដារឡើងលើកស្ទួយតម្រង់　　កុំឲ្យបាត់បង់រក្សាឲ្យបាន ។

វប្បធម៌ជាតិទំនៀមទំលាប់　　ប្រាសាទក្បួនច្បាប់កេរពីបូរាណ
ជាព្រលឹងជាតិអង្គរថ្កើងថ្កាន　　រក្សាឲ្យបានដើម្បីជាតិរស់ ។

ជួយកសាងជាតិនិងសាសនា　　ឲ្យបានថ្លៃថ្លាដោយចិត្តដ៏ស្មោះ
រួបរួមគ្នាឡើងទាំងសង្ឃគ្រហស្ថ　　លើកស្ទួយសង្គ្រោះព្រលឹងជាតិខ្មែរ ។

ទាំងតូចទាំងធំខេមរាគ្រប់ប្រាណ　　សាមគ្គីឲ្យបានកុំឲ្យបែកបែរ
ខំសាងស្រុកទេសជួយរក្សាថែ　　យើងពូជពង្សខ្មែរត្រូវស្នេហាជាតិ ។

❀ ❦ ❀

**ភិក្ខុវិនយធរោ មហាយិន-នឿន**

## ប្រាសាទសិលា

ប្រាសាទសិលាជាព្រលឹងខ្មែរ ដូនតាពុកម៉ែផ្ដែផ្ដាំទុកថា
ហែអស់កុលបុត្រជាតិខេមរា ជួយថែរក្សាការពារឲ្យគង់ ។

ប្រាសាទនេះហើយជាព្រលឹងជាតិ ចូរខ្មែរខ្មីឃ្មាតរួមគ្នាស្រោចស្រង់
ឲ្យបានស្ថិតស្ថេរតាំងនៅយូរលង់ កុំឲ្យបាត់បង់ព្រលឹងខេមរា ។

ប្រាសាទនាគព័ន្ធព្រះខ័នថ្កុំថ្កើង បាយ័នរុងរឿងបាខែងសង្ហា
បាពួនបន្ទាយក្ដីស្រះស្រង់អស្ចារ្យ បារាយណ៍ទឹកថ្លាបាគងល្អពិត ។

ក្រវ៉ាន់បន្ទាយស្រីល្បីក្នុងលោកា តាសោមថ្លៃថ្លាតាព្រហ្មប្រណិត
អង្គរតូចធំខ្មែរកុំបំភ្លេច ល្អលើសដុំពេជ្រកេរមត៌កខ្មែរ ។

♣ ♣ ♣

**ភិក្ខុវិនយធរោ មហាយិន-នឿន**



## ប្រាសាទព្រះវិហារជាមត៌កខ្មែរ

ប្រាសាទព្រះវិហារជាមត៌កខ្មែរ ឥតមានបែកបែរជារបស់ថៃ
ខ្មែរបានកសាងក្នុងកម្ពុជាដី ខេមរាប្រុសស្រីចាំទុករាល់ថ្ងៃ ។

សតវត្សរ៍ ទី៩ ខ្មែរបានកសាង នេះជាព័ស្តុតាងពុំបានក្រឡៃ
ពេលនោះមិនទាន់មានទេជាតិថៃ មានតែទឹកដីមហានគរ ។

ប្រវត្តិសាស្ត្រយើងជាព័ស្តុតាង ទុកជាសំអាងមិនបានភូតភរ
ទីក្រុងឡាអេ ចារទុកយ៉ាងល្អ ទាំងជួយបន្តការពារឲ្យខ្មែរ ។

ខេមរាតូចធំព្រះសង្ឃគ្រហស្ថ ត្រូវមានចិត្តស្មោះនាំគ្នាជួយថែ
ការពារប្រាសាទព្រះវិហារកេរខ្មែរ កុំឲ្យកែប្រែបានដល់ដៃសៀម ។

❁ ❁

**ភិក្ខុវិនយធរោ (មហាយិន-នឿន)**

*១៣ កើត ខែផល្គុណ ព.ស. ២៥៤៦*

## សាមគ្គីបានសុខ

សូមខេមរជនទាំងប្រុសទាំងស្រី ប្រញាប់ឃ្លាតខ្ចីសាមគ្គីសមគ្គា
ព្រមព្រៀងគ្នាឡើងតម្កើងខេមរា ទើបកម្ពុជារស់មានសេរី ។

បែកបាក់សាមគ្គីគឺមិនប្រសើរ ជាផ្លូវដំណើរដើររកទីក្ស័យ
មិនបានសុខឡើយខ្មែរអើយកើតភ័យ មានទោសពេកក្រៃស្លាប់អស់ខេមរា។

ខ្មែរពិតជាស្លាប់បើបែកសាមគ្គី ដូចហង្សក្បាលពីរដល់ក្តីមរណា
កុំស្លាប់ដូចហង្សកុំបង់រដ្ឋា អាណិតករុណាទឹកដីកម្ពុជា ។

សាមគ្គីបានសុខព្រះពុទ្ធទេសនា ចូរជាតិខេមរាផ្សះផ្សាទើបជា
ស្រឡាញ់ជាតិខ្មែរត្រូវតែការពារ ខ្មែរសាមគ្គីគ្នាកម្ពុជាបានសុខ ។

♣ ♣ ♣

**ភិក្ខុវិនយធរោ មហាយិន-នឿន**

**វត្តខ្មែរសាន់តាអាណា សហរដ្ឋអាមេរិក**



## បណ្ឌិតខាន

ជនបណ្ឌិត ពិតយល់ដឹង ប្រឹងគិតគូរ
ពុំមានថ្ងូរ ប្តូរជីពជន្ម ធន់កិច្ចការ ។
មិនបណ្តោយ ឲ្យកាលហួស ជ្រួសអសារ
តាំងចិន្តា ថ្វាបរិសុទ្ធ ផុតអល់អែក ។
សម្មាកម្ម ចាំជានិច្ច កិច្ចបវរ
ស្មូត្រស្មោះសរ ល្អប្រពៃ ថ្ងៃអនេក ។
ស័ព្ទកម្រ ក្រយល់ដឹង ប្រឹងវែកញែក
ប្រែបែងចែក បែកគំនិត គិតយល់បាន ។
ព្រះមហា [១] ថ្វាព្រះទ័យ លៃពិនិត្យ
យល់យង់ពិត រឹតជ្រះថ្លា ការកល្យាណ ។
ខំរៀបរៀង ផ្ទៀងផ្ទាត់ចប់ សព្វដើមដាន
សំរេចបាន ហានគម្ពីរ វិសុទ្ធិមគ្គ ។

---

(១) ព្រះមហា សំដៅ ព្រះមហាយិន-នឿន
អ្នករៀបរៀងសៀវភៅនេះ

**ឱក-ឌន (យិន-សូត្រ)**

# មាតិកាធម៌

ឈ្មោះធម៌ ទំព័រ
អារម្ភកថា របស់អ្នករៀបរៀង ក
សេចក្តីថ្លែងអំណរគុណ ង
ឧទ្ទិសកថា ច
មាតិកាធម៌ ឌ
ពណ៌នាបញ្ហាព្យាករណ៍ ១
សេចក្តីផ្សេងៗនៃវិសុទ្ធិមគ្គ ៤
សីលនិទ្ទេស ទី១
បញ្ហាកម្ម ៦ យ៉ាង ១៣
អ្វីឈ្មោះថា សីល? ១៣
សំវរៈ ៥ យ៉ាង ១៤
សីលដោយអត្ថដូចម្តេច? ១៥
អ្វីជាលក្ខណៈ, រស, បច្ចុប្បដ្ឋាន, បទដ្ឋាននៃសីល? ១៦
អ្វីជារសរបស់សីល? ១៧
អ្វីជាបច្ចុប្បដ្ឋាន និង បទដ្ឋាននៃសីល? ១៧
សីលមានអានិសង្សដូចម្តេច? ១៨
សីលមានប៉ុន្មានយ៉ាង? ២១
ក្រុមសីល ២ ទី ១ ២៣
ក្រុមសីល ២ ទី ២ ២៣
ក្រុមសីល ២ ទី ៣ ២៥
ក្រុមសីល ២ ទី ៤ ២៥
ក្រុមសីល ២ ទី ៥ ២៥
ក្រុមសីល ២ ទី ៦ ២៦
ក្រុមសីល ២ ទី ៧ ២៧
ក្រុមសីល ៣ ទី ១ ២៨
ក្រុមសីល ៣ ទី ២ ២៩
ក្រុមសីល ៣ ទី ៣ ៣០
ក្រុមសីល ៣ ទី ៤ ៣០
ក្រុមសីល ៣ ទី ៥ ៣១



ឈ្មោះធម៌ ទំព័រ
ក្រុមសីល ៤ ទី ១ ៣២
ក្រុមសីល ៤ ទី ២ ៣៣
ក្រុមសីល ៤ ទី ៣ ៣៣
ក្រុមសីល ៤ ទី ៤ ៣៤
បាដិមោក្ខសំវរសីល ៣៤
ឥន្ទ្រិយសំវរសីល ៣៤
អាជីវបារិសុទ្ធិសីល ៣៥
បច្ចយសន្និសិស្សិតសីល ៣៥
អាចារ និង អនាចារ ៣៦
គោចរ និង អគោចារ ៣៨
គោចរ ៣ យ៉ាង ៤១
ឥន្ទ្រិយសំវរសីល ៤៣
អាជីវបារិសុទ្ធិសីល ៤៨
កុហនានិទ្ទេស ៥១
លបនានិទ្ទេស ៥៧
នេមិត្តិកតានិទ្ទេស ៥៩
និប្បេសិកតានិទ្ទេស ៦១
លាភេន លាភំ និជិ្ឈគឹសនតានិទ្ទេស ៦៣
សាធនៈ (ហេតុឲ្យសីលសម្រេច) ៧៥
រឿងព្រះវង្គីសត្ថេរ ៨០
រឿងព្រះចិត្តគុត្តត្ថេរ ៨១
រឿងព្រះសារីបុត្រ មានអាពាធ ៨៨
បរិភោគ ៤ យ៉ាង ៩២
សុទ្ធិមាន ៤ យ៉ាង ៩៣
ក្រុមសីល ៥ ទី ១ ៩៧
រឿងព្រះមហាសង្ឃរក្ខិតត្ថេរ ១០០
ក្រុមសីល ៥ ទី ២ ១០៤
អ្វីជាសេចក្តីសៅហ្មង និង សេចក្តីផូរផង់នៃសីល? ១០៧
សេចក្តីសៅហ្មងនៃសីល ១០៨

| ឈ្មោះធម៌ | ទំព័រ |
| --- | --- |
| មេថុនសំយោគ ៧ | ១០៩ |
| សេចក្តីផូរផង់នៃសីល | ១១២ |
| ទោសនៃសីលវិបត្តិ | ១១៣ |
| អគ្គក្ខន្ធបរិយាយសូត្រ | ១១៤ |
| អានិសង្សក្នុងសីលសម្បត្តិ ន័យមួយបែបទៀត | ១២២ |
| ធុតង្គនិទ្ទេស ទី ២ | |
| ធុតង្គ ១៣ យ៉ាង | ១២៥ |
| សេចក្តីវិនិច្ឆ័យដោយអត្ថ | ១២៧ |
| សេចក្តីវិនិច្ឆ័យដោយលក្ខណៈជាដើម | ១៣២ |
| វិនិច្ឆ័យដោយការសមាទាន និង វិធីប្រតិបត្តិជាដើម | ១៣២ |
| (១) បំសុកូលិកង្គៈ | ១៣៣ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងបំសុកូលិកង្គៈ | ១៣៣ |
| សំពត់បំសុកូល ២៣ យ៉ាង | ១៣៣ |
| ប្រភេទនៃបំសុកូលិកង្គភិក្ខុ | ១៣៧ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងបំសុកូលិកង្គៈ | ១៣៨ |
| (២) តេចីវរិកង្គៈ | ១៣៩ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងតេចីវរិកង្គៈ | ១៣៩ |
| ប្រភេទនៃតេចីវរិកង្គភិក្ខុ | ១៤០ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងតេចីវរិកង្គៈ | ១៤១ |
| (៣) បិណ្ឌបាតិកង្គៈ | ១៤២ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងបិណ្ឌបាតិកង្គៈ | ១៤២ |
| ភត្ត ១៤ យ៉ាង | ១៤២ |
| ប្រភេទនៃបិណ្ឌបាតិកង្គៈ | ១៤៣ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងបិណ្ឌបាតិកង្គៈ | ១៤៤ |
| (៤) សបទានចារិកង្គៈ | ១៤៦ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងសបទានចារិកង្គៈ | ១៤៦ |
| ប្រភេទនៃសបទានចារិកង្គភិក្ខុ | ១៤៧ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងសបទានចារិកង្គៈ | ១៤៨ |
| (៥) ឯកាសនិកង្គៈ | ១៤៩ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងឯកាសនិកង្គៈ | ១៤៩ |



| ឈ្មោះធម៌ | ទំព័រ |
| --- | --- |
| ប្រភេទនៃឯកាសនិកង្គភិក្ខុ | ១៥០ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងឯកាសនិកង្គៈ | ១៥១ |
| (៦) បត្តបិណ្ឌិកង្គៈ | ១៥២ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងបត្តបិណ្ឌិកង្គៈ | ១៥២ |
| ប្រភេទនៃបត្តបិណ្ឌិកង្គភិក្ខុ | ១៥៣ |
| ការបែកធ្លាយ ក្នុងបត្តបិណ្ឌិកង្គៈ | ១៥៣ |
| អានិសង្ស ក្នុងបត្តបិណ្ឌិកង្គៈ | ១៥៣ |
| (៧) ខលុបច្ឆាភត្តិកង្គៈ | ១៥៤ |
| វិធីសមាទាន និង វិធីប្រតិបត្តិក្នុងខលុបច្ឆាភត្តិកង្គៈ | ១៥៤ |
| ប្រភេទនៃខលុបច្ឆាភត្តិកង្គៈ | ១៥៥ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងខលុបច្ឆាភត្តិកង្គៈ | ១៥៥ |
| (៨) អារញ្ញិកង្គៈ | ១៥៦ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងអារញ្ញិកង្គៈ | ១៥៦ |
| ការកំណត់សេនាសនៈ ក្នុងព្រៃ | ១៥៦ |
| ប្រភេទនៃអារញ្ញិកង្គភិក្ខុ និង ការបែកធ្លាយ | ១៥៩ |
| អានិសង្ស ក្នុងអារញ្ញិកង្គៈ | ១៦០ |
| (៩) រុក្ខមូលិកង្គៈ | ១៦១ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងរុក្ខមូលិកង្គៈ | ១៦១ |
| ប្រភេទនៃរុក្ខមូលិកង្គភិក្ខុ | ១៦២ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងរុក្ខមូលិកង្គៈ | ១៦២ |
| (១០) អព្ភោកាសិកង្គៈ | ១៦៤ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងអព្ភោកាសិកង្គៈ | ១៦៤ |
| ប្រភេទនៃអព្ភោកាសិកង្គភិក្ខុ | ១៦៥ |
| ការបែកធ្លាយ និង អានិសង្ស ក្នុងអព្ភោកាសិកង្គៈ | ១៦៦ |
| (១១) សោសានិកង្គៈ | ១៦៧ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងសោសានិកង្គៈ | ១៦៧ |
| ប្រភេទនៃសោសានិកង្គភិក្ខុ និង ការបែកធ្លាយ | ១៦៨ |
| អានិសង្ស ក្នុងសោសានិកង្គៈ | ១៦៩ |
| (១២) យថាសន្ថតិកង្គៈ | ១៧០ |
| វិធីសមាទាន និង វិធីប្រតិបត្តិ ក្នុងយថាសន្ថតិកង្គៈ | ១៧០ |
| ប្រភេទនៃយថាសន្ថតិកង្គភិក្ខុ | ១៧១ |

ឈ្មោះធម៌ ទំព័រ


ការបែកធ្លាយ និង អានិសង្សក្នុងយថាសន្ថតិកង្គ: ១៧១
(១៣) នេសជ្ជិកង្គ: ១៧៣
វិធីសមាទាន ក្នុងនេសជ្ជិកង្គ: ១៧៣
វិធីប្រតិបត្តិ ក្នុងនេសជ្ជិកង្គ: ១៧៣
ប្រភេទនៃនេសជ្ជិកង្គភិក្ខុ ១៧៣
ការបែកធ្លាយ និង អានិសង្ស ក្នុងនេសជ្ជិកង្គ: ១៧៤
សេចក្តីវិនិច្ឆ័យដោយកុសលត្តិក: ១៧៥
សេចក្តីវិនិច្ឆ័យដោយចំណែកធុតាទិសព្ទ ១៧៦
ធុត: និង ធុតវាទ ១៧៧
ធុតង្គ និង ធុតង្គសេវនា ១៧៩
សេចក្តីវិនិច្ឆ័យដោយសង្ខេប និង ពិស្តារ ១៧៩
កម្មដ្ឋានគ្គហណនិទ្ទេស ទី ៣
បញ្ហាកម្ម ៧ យ៉ាង ១៨៣
លក្ខណ:...កិច្ចជាដើមនៃសមាធិ និង ប្រភេទនៃសមាធិ ១៨៤
ក្រុមសមាធិ ២ ទី ១ ១៨៦
ក្រុមសមាធិ ២ ទី ២ ១៨៦
ក្រុមសមាធិ ២ ទី ៣ ១៨៦
ក្រុមសមាធិ ២ ទី ៤ ១៨៧
ក្រុមសមាធិ ៣ ទី ១ ១៨៧
ក្រុមសមាធិ ៣ ទី ២ ១៨៧
ក្រុមសមាធិ ៣ ទី ៣ ១៨៨
ក្រុមសមាធិ ៣ ទី ៤ ១៨៨
ក្រុមសមាធិ ៤ ទី ១ ១៨៩
ក្រុមសមាធិ ៤ ទី ២ ១៩២
ក្រុមសមាធិ ៤ ទី ៣ ១៩៣
ក្រុមសមាធិ ៤ ទី ៤ ១៩៣
ក្រុមសមាធិ ៤ ទី ៥ ១៩៤
ក្រុមសមាធិ ៤ ទី ៦ ១៩៥
ការចំរើនសមាធិ ១៩៦
បលិពោធ ១០ យ៉ាង ១៩៧




ឈ្មោះធម៌ ទំព័រ


អាវាសបលិពោធ ១៩៨
កុលបលិពោធ ២០១
លាភបលិពោធ ២០៤
គណបលិពោធ ២០៥
កម្មបលិពោធ និង អទ្ធានបលិពោធ ២០៦
ញាតិបលិពោធ ២០៧
អាពាធបលិពោធ ២០៨
គន្ថបលិពោធ ២០៩
ឥទ្ធិបលិពោធ ២១៣
កម្មដ្ឋាន ២ យ៉ាង ២១៣
កល្យាណមិត្ត ២១៥
ចរិយា និង ចរិត ៦ ២២១
ដើមហេតុនៃចរិយា ២២៤
លក្ខណ:នៃចរិត ២២៨
មាតិកានៃលក្ខណ:និង លក្ខណ:នៃឥរិយាបថ ២២៩
លក្ខណ:ដោយកិច្ច ២៣១
លក្ខណ:ដោយការបរិភោគ ២៣២
លក្ខណ:ដោយការឃើញជាដើម ២៣៣
លក្ខណ:ដោយធម្មប្បវត្តិ ២៣៤
សប្បាយ:នៃបុគ្គលដែលជារាគចរិត ២៣៦
សប្បាយ:នៃបុគ្គលដែលជាទោសចរិត ២៣៨
សប្បាយ:នៃបុគ្គលដែលជាមោហចរិត ២៤០
សប្បាយ:នៃបុគ្គលដែលជាសទ្ធាចរិត ២៤១
សប្បាយ:នៃបុគ្គលដែលជាវិតក្កចរិត ២៤១
វិនិច្ឆ័យកម្មដ្ឋាន ដោយអាការ: ១០ ២៤២
សង្ខាតនិទ្ទេស និង កសិណ ១០ ២៤៣
អសុភ ១០ ២៤៣
អនុស្សតិ ១០ និង ព្រហ្មវិហារ ៤ ២៤៤
អារូប្ប ៤ និង ឧបចារប្បនាវហ ២៤៥
ឈានប្បភេទ និង សមតិក្កម ២៤៦

| ឈ្មោះធម៌ | ទំព័រ |
|---|---|
| វឌ្ឍនាវឌ្ឍន | ២៤៧ |
| អារម្មណ | ២៤៨ |
| ភូមិ | ២៥១ |
| គហណ | ២៥២ |
| បច្ចយ និង ចរិយានុកូល | ២៥៣ |
| ការរៀនយកកម្មដ្ឋាន និង ការប្រគល់ខ្លួន | ២៥៥ |
| អជ្ឈាសយធម៌ ៦ យ៉ាង | ២៥៧ |
| **បឋវីកសិណនិទ្ទេស ទី ៤** | |
| វិហារដែលមិនសមគួរ ១៨ យ៉ាង | ២៦៣ |
| វិហារដែលសមគួរ | ២៧១ |
| ការផ្ដាច់បង់នូវបលិពោធតូចៗ | ២៧២ |
| វិត្ថារកថានៃភាវនាវិធី និង បឋវីកសិណ | ២៧៣ |
| ទោសនៃកសិណ ៤ យ៉ាង | ២៧៤ |
| វិធីធ្វើកសិណដែលរំកិលបាន និង រំកិលមិនបាន | ២៧៥ |
| ការផ្សេងគ្នានៃឧគ្គហនិមិត្ត និង បដិភាគនិមិត្ត | ២៧៩ |
| សមាធិ ២ ផ្សេងគ្នា | ២៧៩ |
| វៀរហេតុមិនជាទីសប្បាយ ៧ យ៉ាង | ២៨១ |
| មាតិកានៃអប្បនាកោសល ១០ | ២៨៤ |
| ការធ្វើវត្ថុឲ្យភ្លឺថ្លា | ២៨៥ |
| ការប្រមូលឥន្ទ្រិយ៍ឲ្យស្មើគ្នា | ២៨៦ |
| សតិចាំបាច់ត្រូវមានក្នុងទីទាំងពួង | ២៨៨ |
| ការឈ្លាសក្នុងនិមិត្ត | ២៨៩ |
| ផ្គងចិត្តក្នុងសម័យដែលត្រូវផ្គង | ២៨៩ |
| សង្កត់សង្កិនចិត្តក្នុងសម័យដែលត្រូវសង្កត់សង្កិន | ២៩៨ |
| ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលត្រូវធ្វើឲ្យរីករាយ | ២៩៨ |
| ធ្វើចិត្តឲ្យស្ងួងចុះក្នុងសម័យដែលត្រូវធ្វើឲ្យស្ងួងចុះ | ២៩៩ |
| វៀរចាកបុគ្គលដែលមិនមានចិត្តជាសមាធិ | ២៩៩ |
| សេពគប់បុគ្គលដែលមានចិត្តជាសមាធិ | ២៩៩ |
| បង្អោនចិត្តទៅក្នុងសមាធិនោះ | ៣០០ |
| ឧបមានៃសម្មាវាយាមៈ | ៣០១ |





| ឈ្មោះធម៌ | ទំព័រ |
|---|---|
| វត្ថុកាម និង កិលេសកាម | ៣០៦ |
| បីតិ ៥ យ៉ាង | ៣១៦ |
| បឋមឈាន មានអង្គ ៥ | ៣២១ |
| បឋមជ្ឈាន | ៣២៩ |
| វសី (សេចក្ដីស្ទាត់) ៥ យ៉ាង | ៣៣៧ |
| ទុតិយជ្ឈាន | ៣៤០ |
| តតិយជ្ឈាន | ៣៤៧ |
| ចតុត្ថជ្ឈាន | ៣៦០ |
| បញ្ចកជ្ឈាន | ៣៧០ |
| **សេសកសិណនិទ្ទេស ទី ៥** | |
| អាបោកសិណ | ៣៧៣ |
| តេជោកសិណ | ៣៧៥ |
| នីលកសិណ | ៣៧៧ |
| បីតកសិណ និង លោហិតកសិណ | ៣៧៩ |
| ឱទាតកសិណ | ៣៨០ |
| អាលោកកសិណ | ៣៨១ |
| បរិច្ឆិន្នាកាសកសិណ | ៣៨២ |
| បកិណ្ណកកថា | ៣៨៣ |
| ការប្លែកគ្នានៃកសិណ | ៣៨៥ |
| **អសុភកម្មដ្ឋាននិទ្ទេស ទី ៦** | |
| អសុភ ១០ យ៉ាង | ៣៨៩ |
| ឧទ្ធុមាតកអសុភ និង វនីលកអសុភ | ៣៨៩ |
| វិបុព្វកអសុភ, វិច្ឆិទ្ទកអសុភ និង វិក្ខាយិតកអសុភ | ៣៩០ |
| វិក្ខិត្តកអសុភ និង ហតវិក្ខិត្តកអសុភ | ៣៩១ |
| លោហិតកអសុភ | ៣៩១ |
| បុឡុវកអសុភ និង អដ្ឋិកអសុភ | ៣៩២ |
| (១) វិធីរៀនឧទ្ធុមាតកអសុភកម្មដ្ឋាន | ៣៩២ |
| វិធីទៅពិចារណាអសុភ | ៣៩៥ |
| ទំនៀមក្នុងការមើលអសុភ | ៣៩៧ |
| វត្តក្នុងពេលទៅដល់អសុភ | ៣៩៨ |

| ឈ្មោះធម៌ | ទំព័រ |
|---|---|
| វិធីកំណត់និមិត្តក្នុងអសុភ | ៤០០ |
| កាន់យកនិមិត្តដោយប្រការ ៦ យ៉ាង | ៤០២ |
| កាន់យកនិមិត្តដោយប្រការ ៥ យ៉ាង | ៤០៤ |
| (២) វិនីលកអសុភកម្មដ្ឋាន | ៤១៤ |
| (៣) វិបុព្វកអសុភកម្មដ្ឋាន | ៤១៥ |
| (៤) វិច្ឆិទ្ទកអសុភកម្មដ្ឋាន | ៤១៥ |
| (៥) វិក្ខាយិតកអសុភកម្មដ្ឋាន | ៤១៦ |
| (៦) វិក្ខិតកអសុភកម្មដ្ឋាន | ៤១៦ |
| (៧) ហតវិក្ខិតកអសុភកម្មដ្ឋាន | ៤១៧ |
| (៨) លោហិតកអសុភកម្មដ្ឋាន | ៤១៧ |
| (៩) បុឡុវកអសុភកម្មដ្ឋាន | ៤១៨ |
| (១០) អដ្ឋិកអសុភកម្មដ្ឋាន | ៤១៨ |
| បកិណ្ណកកថា | ៤២២ |
| អសុភ ១០ មានលក្ខណៈតែមួយ | ៤២៥ |
| **ឆអនុស្សតិនិទ្ទេស ទី ៧** | |
| វិនិច្ឆ័យអនុស្សតិ ១០ | ៤៣០ |
| វិធីចំរើនពុទ្ធានុស្សតិ | ៤៣២ |
| អានិសង្សនៃការចំរើនពុទ្ធានុស្សតិ | ៤៦៦ |
| ការចំរើនធម្មានុស្សតិ | ៤៦៧ |
| អានិសង្សនៃការចំរើនធម្មានុស្សតិ | ៤៧៨ |
| ការចំរើនសង្ឃានុស្សតិ | ៤៧៩ |
| អានិសង្សនៃការចំរើនសង្ឃានុស្សតិ | ៤៨៧ |
| ការចំរើនសីលានុស្សតិ | ៤៨៨ |
| អានិសង្សនៃការចំរើនសីលានុស្សតិ | ៤៩០ |
| ការចំរើនចាគានុស្សតិ | ៤៩១ |
| អានិសង្សនៃការចំរើនចាគានុស្សតិ | ៤៩៥ |
| ការចំរើនទេវតានុស្សតិ | ៤៩៦ |
| អានិសង្សនៃការចំរើនទេវតានុស្សតិ | ៤៩៨ |


❁ ❁

## អក្សរសង្ខេប ប្រើក្នុងលេខយោង

| | | | | |
|---|---|---|---|---|
| អភិ. | ធា. | គឺ | អភិធម្មបិដក | ធាតុកថា |
| អភិ. | ប | គឺ | អភិធម្មបិដក | បដ្ឋាន |
| អភិ. | វិ. | គឺ | អភិធម្មបិដក | វិភង្គ |
| អភិ. | សំ. | គឺ | អភិធម្មបិដក | សង្គណិ |
| សុ. | | គឺ | សុត្តន្តបិដក | |
| អំ. | អ. | គឺ | អង្គុត្តរនិកាយ | អដ្ឋកនិបាត |
| អំ. | ឯ. | គឺ | អង្គុត្តរនិកាយ | ឯកនិបាត |
| អំ. | ឯក. | គឺ | អង្គុត្តរនិកាយ | ឯកាទសកនិបាត |
| អំ. | ច. | គឺ | អង្គុត្តរនិកាយ | ចតុក្កនិបាត |
| អំ. | ឆ. | គឺ | អង្គុត្តរនិកាយ | ឆកនិបាត |
| អំ. | តិ. | គឺ | អង្គុត្តរនិកាយ | តិកនិបាត |
| អំ. | ទ. | គឺ | អង្គុត្តរនិកាយ | ទសកនិបាត |
| អំ. | ន. | គឺ | អង្គុត្តរនិកាយ | នវកនិបាត |
| អំ. | ប. | គឺ | អង្គុត្តរនិកាយ | បញ្ចកនិបាត |
| អំ. | ស. | គឺ | អង្គុត្តរនិកាយ | សត្តកនិបាត |
| ខុ. | ឥ. | គឺ | ខុទ្ទកនិកាយ | ឥតិវុត្តកៈ |
| ខុ. | ឧ. | គឺ | ខុទ្ទកនិកាយ | ឧទាន |
| ខុ. | ខុ. | គឺ | ខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| ខុ. | ចុ. | គឺ | ខុទ្ទកនិកាយ | ចុឡនិទ្ទេស |
| ខុ. | ជា. ឯ. | គឺ | ខុទ្ទកនិកាយ | ជាតក ឯកនិបាត |
| ខុ. | ជា. តិ. | គឺ | ខុទ្ទកនិកាយ | ជាតក តិកនិបាត |
| ខុ. | ធម្ម. | គឺ | ខុទ្ទកនិកាយ | ធម្មបទ |
| ខុ. | បដិ. | គឺ | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| ខុ. | មហា. | គឺ | ខុទ្ទកនិកាយ | មហានិទ្ទេស |
| ខុ. | សុ. | គឺ | ខុទ្ទកនិកាយ | សុត្តនិបាត |
| ទី. | បា. | គឺ | ទីឃនិកាយ | បាដិកវគ្គ |
| ទី. | ម. | គឺ | ទីឃនិកាយ | មហាវគ្គ |
| ទី. | សី. | គឺ | ទីឃនិកាយ | សីលក្ខន្ធវគ្គ |
| ម. | ឧ. | គឺ | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| ម. | ម. | គឺ | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| ម. | មូ. | គឺ | មជ្ឈិមនិកាយ | មូលបណ្ណាសក |
| វិ. | ម. | គឺ | វិន័យបិដក | មហាវិភង្គ |
| វិ. | ប. | គឺ | វិន័យបិដក | បរិវារ |
| វិ. | ម. ម. | គឺ | វិន័យបិដក | មហាវិភង្គ មហាខន្ធក |
| សំ. | ខ. | គឺ | សំយុត្តនិកាយ | ខន្ធវារវគ្គ |
| សំ. | និ. | គឺ | សំយុត្តនិកាយ | និទានវគ្គ |
| សំ. | ម. | គឺ | សំយុត្តនិកាយ | មហាវគ្គ |
| សំ. | សគ. | គឺ | សំយុត្តនិកាយ | សគាថវគ្គ |
| សំ. | ស. | គឺ | សំយុត្តនិកាយ | សឡាយតនវគ្គ |

# ឯកសារជំនួយ

១- ព្រះត្រៃបិដកខ្មែរ ។

២- វិសុទ្ធិមគ្គបាលិ ភាគទី ១-២-៣ ។

៣- វិសុទ្ធិមគ្គសង្ខេប អាចារ្យអ៊ុច-រស់ និង អាចារ្យឈឹម-ទូច

៤- សទ្ទានុក្រមបាលី-ខ្មែរ ចេញថ្មី ឆ្នាំ ២៥៥១

៥- បទានុក្រមធម្មបទ ភាគ ១-២-៣ ។

៦- អភិធានប្បទីបិកា មឹង-សេស

៧- វិធីប្រែបាលិ

៨- មង្គលត្ថទីបនីប្រែ ភាគទី ១-២-៣-៤

៩- វចនានុក្រមខ្មែរ ភាគ ១-២ សម្តេចជួន-ណាត

១០- ធាតុប្បទីបិកា

១១- ប្រជុំភាណវារៈបាលី-ប្រែ ពិសេស

១២– សម្ពន្ធមាលា និង ឯកសារផ្សេងៗ មួយចំនួនទៀត ។



# នមស្សការ

*សម្មាសម្ពុទ្ធសត្ថារំ សសទ្ធម្មគុណុត្តមំ*
*អភិវាទិយភាសិស្សំ វិសុទ្ធិមគ្គគម្ពិ (១) រំ ។*
*សចេ អត្ថិ វិរុទ្ធោ មេ វិញ្ញូ និទ្ទុត្តំ មមំ*
*ករតោ ហិ វិរុទ្ធោ សោ អត្ថិ នេវ អកុព្វតោ ។*
*វិរិយស្ស មហន្តស្សា- នុភាវេន ពហុន្ន (២) មេ*
*បុញ្ញានិមេវ សត្តានំ សមិជ្ឈន្តុ សព្វទា ។*

*ខ្ញុំថ្វាយបង្គំសម្ពុទ្ធសត្ថា គុណគាប់ថ្លៃថ្លាប្រសើរឧត្តម*
*រុងរឿងក្លីផ្លេកដោយព្រះសទ្ធម្ម អ្នកទ្រង់សីលសមគឺព្រះសាវ័ក ។*
*បង្គំរួចហើយខ្ញុំសូមប្រែស្រាយ បាលីទាំងឡាយក្នុងវិសុទ្ធិមគ្គ*
*បើមានកំហុសខុសខាតវោតវគ្គ សូមអស់លោកអ្នកប្រាជ្ញឈ្លាសវិះគន់*
*កំហុសតែងមានតែអ្នកធ្វើទេ អ្នកនៅទំនេរគ្មានអ្វីខុសធ្ងន់*
*ខុសត្រង់មិនធ្វើឬខ្ជិលទម្រន់ ខំប្រឹងអត់ធន់អាចសំរេចផល ។*
*ដោយក្តីព្យាយាមនៃខ្ញុំនេះណា សូមអស់សត្តារុងរឿងថ្កើងថ្កល់*
*សំរេចបុណ្យច្រើនចំរើនមានដល់ ទូទាំងសាកលសព្វៗកាលហោង ។*

---

*(១) គម្ពីរំ តែដាក់ គម្ពិរំ ដើម្បីសំរួលដល់ឆន្ទ ។*

*(២) ពហុន្នំ តែដាក់ ពហុន្ន ដើម្បីសំរួលដល់ឆន្ទ (បឋ្យាវត្តឆន្ទ) ។*

ជិត-ជន (នាមដើម យិន-សួត្រ)
សាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

# បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ

## ភាគទី ១

សូមនមស្សការចំពោះព្រះគកវ៌តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

### ពណ៌នាបញ្ហាព្យាករណ៍

(១) នរជនណា ប្រកបដោយសជាតិបញ្ញា តាំងនៅស៊ប់ ក្នុងសីល ចម្រើនសមាធិចិត្ត និង វិបស្សនាបញ្ញា ឈ្មោះថា ជាអ្នកឃើញភ័យ ក្នុងវដ្តសំសារ អ្នកមានព្យាយាមជាគ្រឿងដុតកិលេស អ្នកមានបញ្ញាជាគ្រឿងរក្សានូវខ្លួន, នរជននោះ គប្បីកាប់ឆ្ការនូវព្រៃស្នាប់ គឺតណ្ហានោះបាន [១] ។

*ហេតុនោះ បានជាព្រះភគវ័ត ទ្រង់ត្រាស់ព្រះគាថានេះ ។*

*សួរថា : ហេតុអ្វី? បានជាព្រះភគវ័តត្រាស់ព្រះគាថានេះ ។*

*ឆ្លើយថា: បានឮមកថា ក្នុងចំណែកនៃរាត្រី(មាន)ទេវបុត្រមួយរូប (មាននាម និង គោត្រ មិនប្រាកដ) បានចូលទៅគាល់ព្រះមានព្រះភាគ ព្រះអង្គគង់នៅក្នុងទីក្រុងសាវត្ថី ហើយក្រាបទូលសួរនូវបញ្ហានេះ ដើម្បីដកឡើងនូវសេចក្តីសង្ស័យ របស់ខ្លួនដូច្នេះ ថា :*

បពិត្រព្រះគោតម ពួកសត្វ មានគ្រឿងចាក់ស្រែះ គឺតណ្ហា រឹតឆ្វាក់ឲ្យជាប់ជំពាក់ ទាំងខាងក្នុងទាំងខាងក្រៅ ព្រោះហេតុនោះ ខ្ញុំសូមទូលសួរព្រះអង្គ តើបុគ្គលណាអាចកាប់ឆ្ការ នូវគ្រឿងចាក់ស្រែះនេះបាន [២] ។

*នេះជាសេចក្តីសង្ខេប នៃព្រះគាថានោះ ។ ពាក្យថា “ជដា” នេះ*

*១- សុ. សំ. ភាគទី ២៩ ទំព័រទី ៣៨ ។ ២- សុ. ភាគទី ២៩ ទំព័រទី ៣៣ ។*



*គឺជាឈ្មោះនៃតណ្ហា មានបណ្តាញដូចជាសំណាញ់ ។ មែនពិត តណ្ហានោះ ឈ្មោះថា* ជដា *ព្រោះដូចជាបណ្តាញ ពោលគឺបណ្តាញនៃមែករុក្ខជាតិទាំងឡាយ មានឫស្សីជាដើម ព្រោះអត្ថថា ចាក់ស្រែះ ព្រោះកិរិយាកើតឡើងរឿយៗ ក្នុងអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ដោយអំណាចនៃការកើតឡើង ទាំងខាងក្រោម ទាំងខាងលើ ។*

*ក៏តណ្ហានេះហ្នឹងឯង ទេវបុត្រពោលថា “រឹតឆ្វាក់ទាំងខាងក្នុង ទាំងខាងក្រៅ” ព្រោះកើតឡើង ទាំងក្នុងបរិក្ខារ របស់ខ្លួន និង បរិក្ខាររបស់អ្នកដទៃ ទាំងក្នុងអត្តភាព របស់ខ្លួន និង អត្តភាពអ្នកដទៃ ទាំងក្នុងអាយតនៈខាងក្នុង និង អាយតនៈខាងក្រៅ ។ ពួកសត្វ ត្រូវបណ្តាញ គឺតណ្ហា ដែលកើតឡើងដូច្នេះនោះ ចាក់ស្រែះហើយ ។ អធិប្បាយថា: ពួកសត្វពោលគឺពពួកនៃសត្វនេះទាំងអស់គ្នា ត្រូវបណ្តាញគឺតណ្ហានោះចាក់ស្រែះ គឺរួបរឹត ជេរឆ្វាក់ហើយ ប្រៀបដូចជាពួករុក្ខជាតិ មានឫស្សីជាដើម ត្រូវពួកស្នាប់បន្ទាឫស្សីជាដើម ចាក់ស្រែះ រួបរឹត ជេរឆ្វាក់ដូច្នោះ ។ ក៏ពួកសត្វ ត្រូវបណ្តាញ គឺតណ្ហាចាក់ស្រែះ យ៉ាងនេះហើយ ព្រោះហេតុណា, បពិត្រព្រះគោតម ព្រោះហេតុនោះ ទើបខ្ញុំទូលសួរព្រះអង្គ ។ ពាក្យថា* “តំ តំ គោតម” *សេចក្តីថា ព្រោះហេតុនោះ ទើបខ្ញុំទូលសួរព្រះអង្គ ។ ទេវបុត្រនោះ ហៅព្រះភគវ័ត ថា* “គោតម” *តាមព្រះគោត្រ ។ ពាក្យថា* “កោ ឥមំ វិជដយេ ជដំ” *គឺទេវបុត្រ ទូលសួរថា: អ្នកណាគប្បីកាប់ឆ្ការ គឺថា អ្នកណាអាចដើម្បីនឹងកាប់ឆ្ការ នូវបណ្តាញ គឺតណ្ហានេះ ដែលចាក់ស្រែះនូវត្រៃលោកធាតុហើយ ឋិតនៅយ៉ាងនេះបាន ។*

*ចំណែកព្រះមានព្រះភាគ ព្រះអង្គមានកិរិយាប្រព្រឹត្តិ ដោយព្រះ*

*ញាណមិនមានទើសទាក់ ក្នុងធម៌ទាំងពួង ព្រះអង្គជាទេវតារបស់ពួកទេវតា ជាទេវតាលើសជាងពួកទេវតា ជាព្រះឥន្ទ្រ លើសជាងពួកព្រះឥន្ទ្រ ជាព្រះព្រហ្ម លើសជាងពួកព្រហ្ម ទ្រង់ក្លៀវក្លា ក្នុងចតុវេសារជ្ជ-ញាណ ព្រះអង្គទ្រង់កម្លាំង ១០ មានព្រះញាណ គ្មានធម្មជាតដទៃ មករារាំងបាន ព្រះអង្គមានចក្ខុជុំវិញ ត្រូវទេវបុត្រទូលសួរ ដូច្នេះហើយ កាលនឹងទ្រង់ដោះស្រាយ នូវសេចក្ដីនេះ ដល់ទេវបុត្រនោះ ទើបទ្រង់ត្រាស់ព្រះគាថានេះ ថា :*

នរជន មានប្រាជ្ញា បានតាំងមាំ ក្នុងសីលហើយ ចម្រើននូវសមាធិចិត្ត និង វិបស្សនាបញ្ញា ជាអ្នកមានព្យាយាម ដុតកំដៅកិលេស ប្រកបដោយបារិហារិយប្បញ្ញា ជាអ្នកឃើញភ័យ ក្នុងសង្សារ, បុគ្គលនោះ ទើបកាប់ឆ្ការនូវតណ្ហាជាគ្រឿងចាក់ស្រែះនេះបាន ។

*(២)* ក្នុងកាលឥឡូវនេះ ខ្ញុំឈ្មោះពុទ្ធឃោសាចារ្យ កាលពណ៌នានូវសេចក្ដីដែលផ្សេង ដោយគុណ មានសីល-គុណជាដើម នៃព្រះគាថា ដែលព្រះមានព្រះភាគ ព្រះអង្គស្វែងរកនូវគុណដ៏ធំ សម្ដែងហើយនេះ តាមសមគួរដល់សេចក្ដីពិតនឹងសម្ដែងនូវឧបាយ ជាហេតុបាននូវព្រះនិព្វាន គឺវិសុទ្ធិមគ្គដែលអាស្រ័យន័យនៃទេសនា របស់ព្រះមហាថេរទាំងឡាយ លោកមានប្រក្រតីនៅ ក្នុងមហាវិហារ ជាសេចក្ដីវិនិច្ឆ័យ ដ៏បរិសុទ្ធល្អ ជាគ្រឿងធ្វើ នូវសេចក្ដីរីករាយ ដល់ពួកកុលបុត្រ ជាព្រះយោគី ក្នុង



សាសនានេះ ដែលប្រាថ្នាសេចក្ដីបរិសុទ្ធិ បានបួស ក្នុងសាសនានៃព្រះជិនស្រី ដែលគេបានដោយលំបាកហើយ មិនដឹងនូវផ្លូវត្រង់ជាផ្លូវដ៏ក្សេម ដែលសង្គ្រោះដោយគុណមានសីលគុណជាដើម តាមសមគួរដល់សេចក្ដីពិតដើម្បីសេចក្ដីបរិសុទ្ធិ សូម្បីព្យាយាមក៏ដោយ ក៏មិនបានសំរេចនូវសេចក្ដីបរិសុទ្ធិបានឡើយ, បពិត្រលោកអ្នកសប្បុរសទាំងឡាយ! កាលខ្ញុំសម្ដែង នូវវិសុទ្ធិមគ្គ ដោយគោរព, លោកអ្នកទាំងអស់គ្នា ជាអ្នកប្រាថ្នា នូវសេចក្ដីបរិសុទ្ធិ សូមប្រុងចាំស្ដាប់ នូវវិសុទ្ធិមគ្គនោះ ដោយគោរពចុះ ។

*បទថា “វិសុទ្ធិ” ក្នុងពាក្យថា ខ្ញុំនឹងពោលនូវវិសុទ្ធិមគ្គនោះ បណ្ឌិតគប្បីជ្រាបព្រះនិព្វានដ៏បរិសុទ្ធ ដោយចំណែកមួយ ប្រាសចាកមន្ទិលគ្រប់យ៉ាង, ផ្លូវនៃសេចក្ដីបរិសុទ្ធិនោះ ឈ្មោះថា វិសុទ្ធិមគ្គ, ឧបាយជាគ្រឿងសំរេចនូវព្រះនិព្វាន ព្រះភគវត្រាស់ហៅថា “មគ្គ” អធិប្បាយថា “ខ្ញុំនឹងសម្ដែងវិសុទ្ធិមគ្គនោះ” ។ ក៏វិសុទ្ធិមគ្គនេះនោះ គឺព្រះភគវតទ្រង់ត្រាស់សម្ដែង ដោយអំណាចនៃគុណត្រឹមតែវិបស្សនាប៉ុណ្ណោះ ក្នុងព្រះបាលីខ្លះ ។ សមដូចជាព្រះអង្គត្រាស់ ថា :*

*(៣)* ក្នុងកាលណា បុគ្គលឃើញដោយបញ្ញា ថា “សង្ខារទាំងឡាយទាំងពួង មិនទៀង” ដូច្នេះ ក្នុងកាលណោះ បុគ្គល រមែងនឿយណាយ ក្នុងសេចក្ដីទុក្ខ, នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធិ [១] ។

---

*១- សុ. ខុ. ភាគទី ៥២ ទំព័រទី ៧៩ ។*

*ក្នុងបាលីខ្ទះ ព្រះអង្គទ្រង់ត្រាស់សម្តែង ដោយអំណាចនៃឈាន និង បញ្ញា ។ ដូចជាទ្រង់ត្រាស់ថា :*

ការពិនិត្យ មិនមានដល់បុគ្គលអ្នកមិនមានប្រាជ្ញា, ប្រាជ្ញាមិនមាន ដល់បុគ្គលអ្នកមិនពិនិត្យ, ការពិនិត្យនិងប្រាជ្ញាមានក្នុងបុគ្គលណា, បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន (១) ។

*ក្នុងបាលីខ្ទះ ព្រះអង្គទ្រង់ត្រាស់សម្តែង ដោយអំណាចនៃចេតនាមានកម្មជាដើម ។ សមដូចជាព្រះអង្គ ទ្រង់ត្រាស់ ថា :*

សត្វទាំងឡាយ រមែងបរិសុទ្ធបាន ដោយអដ្ឋង្គិកមគ្គនេះ គឺ កម្មបានដល់មគ្គចេតនា, វិជ្ជា បានដល់សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ, ធម្មៈ បានដល់សម្មាវាយាមៈ, សម្មាសតិ និង សម្មាសមាធិ, សីល បានដល់ សម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈ, ឈ្មោះថា ជីវិតដ៏ឧត្តម មិនមែនបរិសុទ្ធ ដោយគោត្រ ឬ ដោយទ្រព្យទេ (២) ។

*ក្នុងបាលីខ្ទះ ព្រះអង្គទ្រង់ត្រាស់សម្តែង ដោយអំណាចនៃគុណមានសីលជាដើម ។ សមដូចជាព្រះអង្គទ្រង់ត្រាស់ ថា :*

បុគ្គលបរិបូណ៌ដោយសីល មានបញ្ញា មានចិត្តតម្កល់ខ្ជាប់ ដោយប្រពៃ មានព្យាយាមប្រារព្ធហើយ មានចិត្ត

*១- សុ. ខុ. ភាគទី ៥២ ទំព័រ៧៩ ។ ២- សុ. សំ. ភាគទី ២៩ ទំព័រ៨៥ ។*



បញ្ជូនទៅហើយ កាន់ព្រះនិព្វាន សព្វៗ កាល ទើបឆ្លងនូវឱឃៈ ដែលគេឆ្លងបានដោយកម្រ ។

*ក្នុងបាលីខ្ទះ ព្រះអង្គទ្រង់ត្រាស់សម្តែង ដោយអំណាចនៃពោធិបក្ខិយធម៌ មានសតិបដ្ឋានជាដើម ។ សមដូចជាព្រះអង្គទ្រង់ត្រាស់ថា :*

ម្នាលភិក្ខុទាំងឡាយ! សតិបដ្ឋានទាំងឡាយ ៤ នេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីធ្វើនូវព្រះនិព្វាន ឲ្យជាក់ច្បាស់, នេះជាផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង (១) ។

*សូម្បីក្នុងពោធិបក្ខិយធម៌ មានសម្មប្បធានជាដើម ក៏មានន័យដូចគ្នានេះដែរ ។ ប៉ុន្តែក្នុងបញ្ហាព្យាករណ៍នេះ វិសុទ្ធិមគ្គនោះ ព្រះអង្គទ្រង់ត្រាស់សម្តែង ដោយអំណាចត្រៃសិក្ខា មានសីលសិក្ខាជាដើម ។ នេះគឺជាសេចក្តីពណ៌នា ដោយសង្ខេប ក្នុងបញ្ហាព្យាករណ៍នោះ ។*

*(៤) បទ* “សីលេ បតិដ្ឋាយ” *នោះ ប្រែថា ឋិតនៅ ក្នុងសីល ។ ក៏ភិក្ខុ កាលបំពេញសីល ឲ្យបរិបូណ៌ហ្នឹងឯង ទើបព្រះភគវ័ត ហៅថា “ឋិតនៅ ក្នុងសីល” ក្នុងបទថា* “សីលេ បតិដ្ឋាយ” *នោះ ព្រោះហេតុនោះ ទើបមានសេចក្តីអធិប្បាយ ក្នុងបទថា* “សីលេ បតិដ្ឋាយ” *នេះ ដូច្នេះថា “ភិក្ខុ តម្កល់នៅស៊ប់ហើយ ក្នុងសីល ដោយការបំពេញសីលឲ្យបរិបូណ៌” ។ ពាក្យថា* “នរោ” *បានដល់សត្វ ។ បទថា* “សបញ្ញោ” *សេចក្តីថា អ្នកមានបញ្ញា ដោយបញ្ញាដែលមកព្រមនឹងបដិសន្ធិជាត្រៃ*

*១- សុ. ទី. ភាគទី ១៧ ទំព័រទី ២៨៤ ។*

ហេតុ កើតពីកម្ម ។ ពាក្យថា "ចិត្តំ បញ្ញញ្ច ភាវយំ" សេចក្ដីថា ចំរើនសមាធិចិត្ត និង វិបស្សនាចិត្ត ។ មែនពិត ក្នុងបទនេះ សមាធិព្រះភគវត ទ្រង់សម្ដែង ដោយពាក្យជាប្រធាននៃចិត្ត, វិបស្សនា ទ្រង់សម្ដែង ដោយឈ្មោះថា បញ្ញា ។ បទថា "អាតាបី" ប្រែថា អ្នកមានសេចក្ដីព្យាយាម ។ ក៏សេចក្ដីព្យាយាម ព្រះភគវត ទ្រង់ត្រាស់ហៅថា "អាតាបៈ" ព្រោះអត្ថថា ជាហេតុដុតកិលេស ឲ្យក្ដៅសព្វ, សេចក្ដីព្យាយាម ជាហេតុដុតកិលេស ឲ្យក្ដៅសព្វនោះ រមែងមានដល់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា អាតាបី ។ បញ្ញា ព្រះភគវតត្រាស់ហៅថា នេបក្កៈ ត្រង់បទថា "និបកោ" សេចក្ដីថា: ប្រកបព្រម ដោយបញ្ញានោះ ។ មួយទៀត ព្រះភគវត ទ្រង់ត្រាស់សម្ដែងបារិហារិកប្បញ្ញា ដោយបទនេះ ។ ក៏ក្នុងបញ្ហាព្យាករណ៍នេះ បញ្ញា មកអស់វារៈ៣ ដង ។ បណ្ដាបញ្ញាបី ពួកនោះ បញ្ញា ទី១ ឈ្មោះថា សជាតិប្បញ្ញា, បញ្ញាទី ២ ឈ្មោះថា វិបស្សនាបញ្ញា, បញ្ញាទី ៣ ឈ្មោះថា បារិហារិកប្បញ្ញា ដែលជាអ្នកដឹកនាំ ក្នុងកិច្ចគ្រប់យ៉ាង ។

បទថា "ភិក្ខុ" មានវិគ្រោះថា "បុគ្គលណា ឃើញភ័យ ក្នុងវដ្ត-សំសារ បុគ្គលនោះ ទើបឈ្មោះថា ភិក្ខុ" ។ ពាក្យថា "សោ ឥមំ វិជដយេ ជដំ" សេចក្ដីថា ភិក្ខុនោះ គឺអ្នកប្រកបព្រមដោយធម៌ទាំង ៦ ប្រការនេះ គឺដោយសីលនេះ ១ ដោយសមាធិ ដែលព្រះភគវតទ្រង់សម្ដែងដោយប្រធានគឺចិត្តនេះ ១ ដោយបញ្ញា ៣ ប្រការនេះ ១ ដោយសេចក្ដីព្យាយាមជាគ្រឿងដុតកិលេសនេះ ១ ឈរលើផែនដី គឺសីលហើយលើកឡើងនូវកាំបិត គឺវិបស្សនាបញ្ញា ដែលខ្វនសម្លៀងល្អហើយ ដោយថ្ម គឺសមាធិ ដោយដៃ គឺបារិហារិកប្បញ្ញា ដែលកម្លាំង គឺវិរិយៈ



ផ្គងឡើងហើយ គប្បីស្រាយត្រដោះ គឺកាប់ឆ្ការផ្ដួលរំលើង នូវព្រៃស្នាប់ គឺតណ្ហាដែលធ្លាក់ចុះ ក្នុងសន្ដានរបស់ខ្លួន ទាំងអស់នោះបាន មានឧបមាបីដូចជាបុរសឈរនៅលើផែនដី លើកឡើងនូវកាំបិត ដែលខ្វនសម្លៀងល្អហើយ គប្បីកាប់ឆ្ការនូវគុម្ពឫស្សីដ៏ធំ យ៉ាងដូច្នោះឯង ។ ក៏ក្នុងខណៈនៃមគ្គ ភិក្ខុរូបនេះ ឈ្មោះថា កំពុងកាប់ឆ្ការនូវបណ្ដាញ គឺតណ្ហានោះ ។ ក្នុងខណៈនៃផល ភិក្ខុនេះ ឈ្មោះថា កាប់ឆ្ការរួចស្រេចហើយ ជាទក្ខិណេយ្យបុគ្គល ដ៏ប្រសើរ របស់សត្វលោក ព្រមទាំងទេវលោក ។

ព្រោះហេតុនោះ ទើបព្រះភគវត ទ្រង់ត្រាស់ ថា :

> នរជនណា ប្រកបដោយសជាតិបញ្ញា តាំងនៅស៊ប់ ក្នុងសីល ចម្រើនសមាធិចិត្តផង វិបស្សនាចិត្តផង ឈ្មោះថា ជាអ្នកឃើញភ័យ ក្នុងវដ្តសំសារ អ្នកមានព្យាយាមជាគ្រឿងដុតកិលេស អ្នកមានបញ្ញាជាគ្រឿងរក្សានូវខ្លួន, នរជននោះ គប្បីកាប់ឆ្ការនូវព្រៃស្នាប់ គឺតណ្ហា ១០៨ នោះបាន ។

ព្រះយោគីនោះ ព្រះភគវតត្រាស់ ក្នុងគាថានោះថា "ជាអ្នកប្រកបព្រមដោយបញ្ញា" ដោយបញ្ញាណា, កិច្ចដែលព្រះយោគីនោះ ត្រូវធ្វើក្នុងបញ្ញានោះ មិនមានទេ ។ ព្រោះបញ្ញានោះ សំរេចហើយ ដល់ព្រះយោគីនោះ ដោយអានុភាពនៃកម្មដែលមានក្នុងកាលមុន មែនពិត ។ ក៏ប៉ុន្តែព្រះយោគីនោះ ត្រូវតែជាអ្នកធ្វើជាប់បន្តគ្នា មិនឲ្យដាច់ ដោយអំណាចនៃវិរិយៈ និង ជាអ្នកធ្វើដោយការដឹងជាក់ច្បាស់ ដែលព្រះភគវតត្រាស់ហើយ ក្នុងបទទាំងឡាយថា "អាតាបី និបកោ" នេះ ឋិត

នៅស៊ប់ ក្នុងសីលហើយ គប្បីចំរើនសមថៈ និង វិបស្សនា ដែលព្រះភគវតែត្រាស់ហើយដោយអំណាចសមាធិចិត្ត និង វិបស្សនាបញ្ញា ។ ព្រះភគវតែ ទ្រង់សម្ដែងវិសុទ្ធិមគ្គនេះ ដោយប្រធាន គឺសីល សមាធិ និង បញ្ញា ក្នុងព្រះគាថានោះ ។

(៥) មែនពិត សិក្ខា ៣, សាសនា មានលំអ ៣ យ៉ាង, ធម៌ជាឧបនិស្ស័យនៃគុណវិសេស មានវិជ្ជា ៣ ជាដើម, កិរិយាវៀរបង់នូវប្រជុំ ២ នៃផ្លូវអមខាង និង ការសេពនូវសេចក្ដីប្រតិបត្តិជាកណ្ដាល ឧបាយជាគ្រឿងប្រព្រឹត្តិកន្លងសេចក្ដីទុក្ខ មានទុក្ខ ក្នុងអបាយជាដើម ការលះបង់កិលេស ដោយអាការៈ ៣ យ៉ាង, ធម៌ជាសត្រូវ ដល់ទោសទាំងឡាយ មានការប្រព្រឹត្តិកន្លងជាដើម, ការជម្រះនូវសង្កិលេស ៣ យ៉ាង និង ហេតុនៃភាវៈរបស់បុគ្គលមានសោតាបន្នជាដើម ជាធម៌គឺព្រះភគវតែទ្រង់ប្រកាសដោយទេសនាមានប្រមាណប៉ុណ្ណេះ ។ សួរថា ទ្រង់ប្រកាសដោយប្រការដូចម្ដេច? ។ ឆ្លើយថាៈ ក៏ក្នុងបញ្ហាកម្មនេះ អធិសីលសិក្ខា ព្រះភគវតែទ្រង់ប្រកាសដោយសីល, អធិចិត្តសិក្ខា ព្រះអង្គទ្រង់ប្រកាសដោយសមាធិ, អធិប្បញ្ញាសិក្ខា ទ្រង់ប្រកាសដោយបញ្ញា ។ មួយទៀត ភាវៈនៃសាសនា មានលំអបទដើម ក៏ព្រះភគវតែទ្រង់ប្រកាស ដោយសីល ។ មែនពិត សីលទុកជាខាងដើម នៃសាសនា ព្រោះបាលីថាៈ “អ្វីជាខាងដើមនៃកុសលធម៌ទាំងឡាយ និងសីលបរិសុទ្ធ ដោយវិសេស ឬ [១] ” ដូច្នេះ និង ព្រោះព្រះបាលីថា “ការមិនធ្វើនូវអំពើបាបទាំងពួង” ដូច្នេះជាដើម ។ ក៏សីលនោះ ឈ្មោះថា មានលំអ ព្រោះសីលនោះ

១- សុ. សំ. មហាវារ. ភាគទី ៣៨ ទំព័រទី ១១៩ ។



ជាធម្មជាតនាំមកនូវគុណ មានការមិនស្ដាយក្រោយជាដើម ។ ភាវៈនៃសាសនាមានលំអត្រង់បទកណ្ដាល ព្រះអង្គទ្រង់ប្រកាសដោយសមាធិ។ មែនពិត សមាធិ ឈ្មោះថា មានលំអត្រង់បទកណ្ដាល របស់សាសនា ព្រោះព្រះបាលីថា “ការញ៉ាំងកុសលឲ្យដល់ព្រម” ដូច្នេះជាដើម ។

មួយទៀត សមាធិនោះ ឈ្មោះថា មានលំអ ព្រោះសមាធិនោះនាំមកនូវគុណ មានឥទ្ធិវិធីជាដើម ។ ភាវៈនៃសាសនា មានលំអត្រង់ទីបំផុត ព្រះភគវតែទ្រង់ប្រកាសហើយ ដោយបញ្ញា ។ មែនពិត បញ្ញាឈ្មោះថា ទុកជាខាងចុងនៃសាសនា ព្រោះបាលីថា “ការជម្រះចិត្តរបស់ខ្លួន ឲ្យបានផូរផង់, នេះគឺជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ [១] ” និង ព្រោះសាសនា មានបញ្ញា ជាគុណដ៏ប្រសើរលើសលប់ ។ ក៏បញ្ញានោះ ឈ្មោះថា មានលំអ ព្រោះជាហេតុនាំមកនូវតាទិភាព (គឺភាពនឹងន ក្នុងអារម្មណ៍ជាទីប្រាថ្នា និង អារម្មណ៍មិនជាទីប្រាថ្នាទាំងឡាយ ។ សមដូចជាព្រះភគវតែទ្រង់ត្រាស់ ថា :

បណ្ឌិតទាំងឡាយមិនរំភើប ព្រោះពាក្យនិន្ទា និងសរសើរ
ដូចជាភ្នំថ្មតាន់ មិនរំភើប ព្រោះខ្យល់ យ៉ាងដូច្នោះ [២] ។

ឧបនិស្ស័យ នៃភាពរបស់បុគ្គល អ្នកមានវិជ្ជា ៣ ព្រះភគវតែទ្រង់ប្រកាសហើយ ដោយសីលដូចគ្នាដែរ ។ ព្រោះបុគ្គលបានសំរេចវិជ្ជា ៣ ព្រោះអាស្រ័យនូវសីលសម្បត្តិ មិនមែនព្រោះអាស្រ័យហេតុដទៃក្រៅអំពីសីលនោះឡើយ ។ ឧបនិស្ស័យ នៃភាពរបស់បុគ្គលអ្នកមានអភិញ្ញា ៦ ទ្រង់ប្រកាសដោយសមាធិ ។ ព្រោះថា បុគ្គលអ្នកបានសំរេចអភិញ្ញា

១- សុ. ទី. ភាគទី ១៦ ទំព័រ ១០៣ ។ ២- សុ. ខុ. ភាគទី ៥២ ទំព័រ ៣៨ ។

៦ ព្រោះអាស្រ័យសមាធិសម្បទ ពុំមែនព្រោះអាស្រ័យហេតុដទៃក្រៅអំពីសមាធិនោះទេ ។ ឧបនិស្ស័យ នៃកិរិយាចាក់ធ្លុះ ក្នុងបដិសម្ភិទា ទ្រង់ប្រកាសដោយបញ្ញា។ ព្រោះថា បុគ្គលអាស្រ័យបញ្ញាសម្បត្តិ ទើបបានសំរេចបដិសម្ភិទា ៤ មិនមែនបានព្រោះហេតុដទៃឡើយ។ ឯកិរិយាវៀរនូវផ្លូវអមខាង ពោលគឺការព្យាយាម ជាគ្រឿងប្រកបរឿយៗ ក្នុងហេតុប្រកបដោយទីជាទីជាប់នៅនៃសត្វ គឺសេចក្ដីសុខក្នុងកាម ទ្រង់ប្រកាសដោយសីល ។ ការវៀរនូវផ្លូវអមខាង ពោលគឺការព្យាយាម ជាគ្រឿងប្រកបរឿយៗ ក្នុងការញ៉ាំងខ្លួនឲ្យលំបាក ទ្រង់ប្រកាសដោយសមាធិ ។ កិរិយាសេពនូវសេចក្ដីប្រតិបត្តិជាកណ្ដាល ទ្រង់ប្រកាស ដោយបញ្ញា ។ ឧបាយនៃការប្រព្រឹត្តិកន្លងនូវអបាយ ក៏ទ្រង់ប្រកាស ដោយសីល ដូចគ្នាដែរ ។ ឧបាយនៃការប្រព្រឹត្តិកន្លងនូវកាមធាតុ ទ្រង់ប្រកាស ដោយសមាធិ ។ ឧបាយនៃការប្រព្រឹត្តិកន្លងនូវភពទាំងពួង ទ្រង់ប្រកាសដោយបញ្ញា ។ មួយទៀត ការលះបង់កិលេស ដោយអំណាចតទង្គប្បហាន ទ្រង់ប្រកាសហើយ ដោយសីល ។ ការលះបង់កិលេស ដោយអំណាចនៃវិក្ខម្ភនប្បហាន ទ្រង់ប្រកាស ដោយសមាធិ ។ ការលះបង់កិលេស ដោយអំណាចសមុច្ឆេទប្បហាន ទ្រង់ប្រកាស ដោយបញ្ញា ។ ធម៌ដែលជាសឹកសត្រូវដល់ការប្រព្រឹត្តិកន្លង នៃកិលេសទាំងឡាយ ទ្រង់ប្រកាសហើយ ដោយសីលដូចគ្នា ។ ធម៌ដែលជាសត្រូវដល់កិរិយាតាំងឡើងដោយជុំវិញ (ការរួបរុំចិត្ត) នៃកិលេសទាំងឡាយ ទ្រង់ប្រកាស ដោយសមាធិ ។ ធម៌ដែលជាសត្រូវដល់កិរិយាដេកត្រាំនៅរឿយៗនៃកិលេសទាំងឡាយ ព្រះអង្គទ្រង់ប្រកាស ដោយបញ្ញា ។ ចំណែកឯការជម្រះនូវសង្កិលេសគឺទុច្ចរិត ទ្រង់ប្រកាសដោយសីល ។ ការជម្រះនូវសង្កិលេស



គឺតណ្ហា ទ្រង់ប្រកាស ដោយសមាធិ ។ ការជម្រះនូវសង្កិលេស គឺទិដ្ឋិ ទ្រង់ប្រកាស ដោយបញ្ញា ។ ហេតុនៃភាពរបស់បុគ្គលជាព្រះសោតាបន្ន និង ជាព្រះសកិទាគាមី ទ្រង់ប្រកាស ដោយសីលដូចគ្នាដែរ ។ ហេតុនៃភាវៈជាព្រះអនាគាមី ទ្រង់ប្រកាសហើយ ដោយសមាធិ ។ ហេតុនៃភាពជាព្រះអរហន្ត ទ្រង់ប្រកាសហើយ ដោយបញ្ញា ។ ព្រោះថា ព្រះសោតាបន្នបុគ្គល ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ជាអ្នកមានប្រក្រតីបំពេញក្នុងសីលទាំងឡាយ"។ ព្រះសកិទាគាមី ក៏ដូចគ្នាដែរ ។ ចំណែកព្រះអនាគាមី ទ្រង់ត្រាស់ថា "ជាអ្នកមានកិរិយាបំពេញ ក្នុងសមាធិ ជាប្រក្រតី" ។ តែព្រះអរហន្ត ទ្រង់ត្រាស់ថា "ជាអ្នកមានកិរិយាបំពេញក្នុងបញ្ញា" ។

ព្រះមានព្រះភាគ ទ្រង់ប្រកាសគុណទាំងឡាយ ៩ ប្រការនេះ គឺ ត្រៃសិក្ខា ១, សាសនា មានលំអ ៣ យ៉ាង ១, ឧបនិស្ស័យ នៃគុណវិសេស មានភាពជាអ្នកបានវិជ្ជា ៣ ជាដើម ១, ការលះបង់ប្រជុំពីរនៃផ្លូវអមខាង និង ការសេពសេចក្ដីប្រតិបត្តិជាកណ្ដាល ១, ឧបាយជាហេតុប្រព្រឹត្តិកន្លងនូវគតិ មានអបាយជាដើម ១, ការលះបង់កិលេសដោយអាការៈ ៣ យ៉ាង ១, ធម៌ជាសត្រូវដល់ទោស មានការប្រព្រឹត្តិកន្លងជាដើម ១, ការជម្រះនូវសង្កិលេស ៣ យ៉ាង ១, ហេតុនៃភាពរបស់បុគ្គល មានសោតាបន្នបុគ្គលជាដើម ១ និង ទ្រង់ប្រកាសប្រជុំ ៣ នៃគុណបែបនេះដទៃទៀត ដោយធម៌ទេសនា មានប្រមាណប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ។

(សីលនិទ្ទេស)

(៦) ក៏វិសុទ្ធិមគ្គនេះ សូម្បីព្រះមានព្រះភាគ ទ្រង់សម្ដែងហើយ

*ដោយធម៌ជាប្រធាន គឺសីល សមាធិ និង បញ្ញា ដែលសង្គ្រោះដោយគុណជាអនេកយ៉ាងនេះហើយក៏ដោយ ក៏ជាឧបាយគឺព្រះអង្គទ្រង់សម្តែងហើយ ដោយសង្ខេបក្រៃពេក ព្រោះហេតុនោះ វិសុទ្ធិមគ្គនេះ ទើបមិនល្មមគ្រប់គ្រាន់ ដើម្បីជាឧបការៈ ដល់កុលបុត្រទាំងឡាយ ព្រោះហេតុដូច្នោះ ដើម្បីនឹងសម្តែងនូវសេចក្តីពិស្តារ នៃវិសុទ្ធិមគ្គនោះ ទើបមានបញ្ហាកម្មនេះ ប្រារព្ធនូវសីលជាមុន គឺ :*

អ្វីឈ្មោះថា សីល?,

សីល ដោយសេចក្តីថាដូចម្តេច?,

អ្វីជាលក្ខណៈ, ជារស, ជាសេចក្តីប្រាកដ និង អ្វីជាហេតុជាទីតាំង នៃសីលនោះ?,

សីល មានអានិសង្សដូចម្តេច?,

សីលនោះ មានប៉ុន្មានយ៉ាង?,

អ្វីជាសេចក្តីសៅហ្មង និង សេចក្តីផូរផង់នៃសីលនោះ? ។

*នេះជាសេចក្តីដោះស្រាយ ក្នុងបញ្ហាកម្មនោះ ។*

*បញ្ហាកម្មថា* “អ្វីឈ្មោះថាសីល?” *(ឆ្លើយថា) ធម៌ទាំងឡាយ មានចេតនាជាដើម របស់បុគ្គលដែលវៀរចាកបាបកម្ម មានបាណាតិបាត ជាដើមក្តី របស់អ្នកបំពេញវត្តប្រតិបត្តិក្តី ឈ្មោះថា សីល ។ ពាក្យនេះសមដូចព្រះសារីបុត្តត្ថេរ ពោលក្នុងគម្ពីរ ឈ្មោះបដិសម្ភិទាថា “សួរថា: អ្វីឈ្មោះថា សីល? ។ ឆ្លើយថា: ចេតនា ឈ្មោះថា សីល, ចេតសិកឈ្មោះថា សីល, សេចក្តីសង្រួម ឈ្មោះថា សីល, ការមិនប្រព្រឹត្តិកន្លងឈ្មោះថា សីស” ។ ក្នុងសីលទាំងនោះ ចេតនា របស់បុគ្គលអ្នកវៀរចាកអកុសលកម្មមានបាណាតិបាតជាដើមក្តី របស់បុគ្គលអ្នកបំពេញវត្ត*



*ប្រតិបត្តិក្តី ឈ្មោះថា ចេតនាសីល ។ ចេតនា ជាហេតុវៀររបស់បុគ្គលអ្នកដែលវៀរចាកអកុសលកម្ម មានបាណាតិបាតជាដើម ឈ្មោះថា ចេតសិកសីល ។ មួយវិញទៀត ចេតនា ប្រព្រឹត្តទៅ ក្នុងកម្មបថ ៧ របស់បុគ្គលអ្នកលះបង់អកុសលកម្ម មានបាណាតិបាតជាដើម ឈ្មោះថា ចេតនាសីល ។ ធម៌ គឺអនភិជ្ឈា, អព្យាបាទ និង សម្មាទិដ្ឋិ ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ដោយន័យមានជាអាទិ៍ ថា “ភិក្ខុលះបង់នូវអភិជ្ឈា មានចិត្តប្រាសចាកអភិជ្ឈា នៅ” ដូច្នេះ ឈ្មោះថា ចេតសិកសីល ។*

**(សំវរៈ ៥ យ៉ាង)**

*ក្នុងពាក្យថា “សំវរៈ ឈ្មោះថា សីល” នេះ បណ្ឌិត គប្បីជ្រាបសំវរៈ ៥ ប្រការ គឺ បាតិមោក្ខសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។ បណ្តាសំវរៈទាំង ៥ នោះ សំវរៈនេះថា “ភិក្ខុជាអ្នកចូលដល់ហើយជាអ្នកប្រកបព្រមហើយដោយបាតិមោក្ខសំវរៈនេះ” ឈ្មោះថា បាតិមោក្ខសំវរៈ ។ សំវរៈនេះថា “ភិក្ខុ រក្សាចក្ខុន្ទ្រិយ៍ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ៍ ” ឈ្មោះថា សតិសំវរៈ ។ សំវរៈនេះ (ដោយពាក្យ) ថា :*

> ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា: ម្នាលអជិតៈ! ក្រសែនៃ(តណ្ហា)ទាំងឡាយណា មានក្នុងលោក, សតិជាគ្រឿងឃាត់នូវក្រសែទាំងឡាយនោះ, តថាគត ហៅសតិ ថា ជាគ្រឿងបិទបាំងនូវក្រសែទាំងឡាយ, តែក្រស្រែទាំងនោះ អ្នកប្រតិបត្តិ ត្រូវបិទដោយបញ្ញា *ដូច្នេះ*

ឈ្មោះថា ញាណសំវរៈ ។ សូម្បីការសេពនូវបច្ច័យ រមែងដល់នូវការប្រជុំចុះ ក្នុងញាណសំវរៈនេះដែរ ។ ចំណែកសំវរៈ ដែលមកដោយន័យថា "ភិក្ខុ ជាអ្នកអត់ទ្រាំចំពោះត្រជាក់ក្ដៅ" ដូច្នេះជាដើមនេះ ឈ្មោះថា ខន្តិសំវរៈ ។ ឯសំវរៈដែលមក ដោយន័យថា "ភិក្ខុ តែងអត់សង្កត់នូវកាមវិតក្កៈ ដែលកើតឡើងហើយ" ដូច្នេះជាដើមនេះ ឈ្មោះថា វីរិយសំវរៈ ។ សូម្បីអាជីវបារិសុទ្ធិសីល រមែងដល់នូវការប្រជុំចុះ ក្នុងវីរិយសំវរៈនេះដែរ ។ សំវរៈ ៥ ប្រការនេះក្ដី ការវៀរចាកវត្ថុដែលដល់ព្រមរបស់ពួកកុលបុត្រ ដែលភ័យខ្លាចបាបក្ដី, កិរិយាសង្រួម និង ការវៀរទាំងអស់នោះ បណ្ឌិត គប្បីជ្រាបថា សំវរសីល យ៉ាងដូច្នេះ ។ ពាក្យថា "ការមិនប្រព្រឹត្តិកន្លង ឈ្មោះថា សីល" បានដល់ ការមិនប្រព្រឹត្តិកន្លង ដែលប្រព្រឹត្តទៅ ខាងផ្លូវកាយ និង ផ្លូវចិត្ត របស់បុគ្គលអ្នកដែលបានសមាទានសីលហើយ ។ នេះ គឺជាសេចក្ដីដោះស្រាយ នូវបញ្ហាកម្មថា "អ្វីឈ្មោះថា សីល" ជាមុនសិន ។

(អត្ថនៃសីល)

(៧) ការដោះស្រាយក្នុងបទដ៏សេសទាំងឡាយ។ ពាក្យថា "ដែលឈ្មោះថា សីល ព្រោះអត្ថថាដូចម្ដេច?" ។ (ឆ្លើយថា) ដែលឈ្មោះថា សីល ព្រោះអត្ថថា ជាសីលនៈ គឺប្រក្រតី ។ ឈ្មោះថា សីលនៈ នេះគឺជាអ្វី? ។ ដែលឈ្មោះថា សីលនៈ នេះ គឺការតម្កល់នៅស៊ប់ មានសេចក្ដីថា ភាពនៃកម្មទាំងឡាយ មានកាយកម្មជាដើម ជាធម្មជាតមិនរាត់រាយ ដោយអំណាចភាវៈ នៃបុគ្គលជាអ្នកមានសីលល្អ ប្រពៃ ១ ។ គឺការចូលទៅទ្រទ្រង់ទុក អធិប្បាយថាៈ ភាវៈនៃការទ្រទ្រង់ទុក ដោយអំណាចនៃការទ្រទ្រង់ នូវកុសលធម៌ទាំងឡាយ ១ ។ មែនពិត ពួកអ្នក



ប្រាជ្ញ ដែលដឹងនូវលក្ខណៈនៃសព្ទ យល់ព្រមតាមអត្ថទាំង ២ យ៉ាងនេះប៉ុណ្ណោះ ក្នុងបទថា "សីល" នេះ ។ ចំណែកពួកអ្នកប្រាជ្ញដទៃទៀតពណ៌នាសេចក្ដី ក្នុងបទថា សីល នេះ ដោយន័យថា "សីលសព្ទនេះមានសេចក្ដីថា សិរៈ (ខ្ពង់ខ្ពស់), មានសេចក្ដីថា សីសៈ (កំពូល), មានសេចក្ដីថា សីតលៈ (ត្រជាក់), មានសេចក្ដីថា សិវៈ (ក្សេមក្សាន្ត)" ដូច្នេះជាដើមខ្លះ ក៏មាន ។

(លក្ខណៈ, រស, បច្ចុប្បដ្ឋាន, បទដ្ឋាន នៃសីល)

(៨) ឥឡូវនេះ នឹងដោះស្រាយ ក្នុងបញ្ហាកម្មថា "អ្វីជាលក្ខណៈ, ជារស, ជាបច្ចុប្បដ្ឋាន និង ជាបទដ្ឋាន នៃសីលនោះ" ។

> សីលនៈ(ភាពជាប្រក្រតី) ជាលក្ខណៈ របស់សីលនោះ សូម្បីផ្សេងគ្នា ដោយប្រការដ៏ច្រើន ប្រៀបដូចជារបស់មានវិស័យដែលប្រព្រឹត្តទៅ ក្នុងកិរិយាឃើញច្បាស់ ជាលក្ខណៈ របស់រូប ដែលមានប្រការផ្សេងគ្នា ដ៏ច្រើន ក៏យ៉ាងដូច្នោះឯង ។

មែនពិត ភាវៈនៃកិច្ចប្រព្រឹត្តទៅ ក្នុងការឃើញ ឈ្មោះថា ជាលក្ខណៈ របស់រូបាយតនៈ សូម្បីផ្សេងគ្នាដោយប្រការដ៏ច្រើនដែលមានពណ៌ខៀវ និង ពណ៌លឿងជាដើម ព្រោះរូបាយតនៈសូម្បីដែលផ្សេងគ្នាច្រើនប្រការ ដោយប្រភេទនៃពណ៌ មានពណ៌ខៀវជាដើម ក៏មិនប្រព្រឹត្តកន្លងនូវភាពជារបស់មានវិស័យ ដែលគប្បីមើលឃើញទៅបានដែរយ៉ាងណាមិញ, សីលនសព្ទ ដែលបានពោលហើយ ដោយអំណាចនៃការតម្កល់នៅស៊ប់ នៃកម្មទាំងឡាយ មានកាយកម្មជាដើម និង ដោយ

អំណាចនៃការតម្កល់ទុកនូវកុសលធម៌ទាំងឡាយនោះឯង ជាលក្ខណៈរបស់សីល សូម្បីផ្សេងគ្នាច្រើនជាអនេក ដោយប្រភេទនៃធម៌ មានចេតនាជាដើម ព្រោះភាវៈនៃសីល សូម្បីផ្សេងគ្នាដោយប្រការមិនមែនតែមួយ ដោយប្រភេទនៃធម៌មានចេតនាជាដើម មិនកន្លងផុតនូវភាវៈជាទីតម្កល់នៅស៊ប់ និង ភាវៈជាទីតម្កល់ទុកបានដែរ ក៏យ៉ាងដូច្នោះ ។

(រសរបស់សីល)

ចំណែក ភាវៈនៃការកំចាត់បង់ នូវភាពនៃបុគ្គលទ្រុស្តសីល ឬ គុណ គឺកម្មដែលមិនមានទោស លោកហៅថា ឈ្មោះថា ជារស ដោយអត្ថថា ជាកិច្ច និង ជាសម្បត្តិរបស់សីលនោះ ដែលមានលក្ខណៈដូចពោលមកហើយ

ព្រោះហេតុនោះ ឈ្មោះថា សីលនេះ បណ្ឌិត គប្បីជ្រាប ថា "មានកិរិយាកំចាត់បង់ នូវភាពនៃបុគ្គលទ្រុស្តសីល ជារស ដោយរសដែលមានកិច្ចជាអត្ថ មានកម្មដែលមិនមានទោស ជារស ដោយរសដែលមានសម្បត្តិជាអត្ថ" ។ មែនពិត កិច្ចនុ៎ះឯងក្តី សម្បត្តិក្តី លោកហៅថា រស ក្នុងជំនុំបញ្ហាទាំង ៤ មានលក្ខណៈជាដើម ។

(បច្ចុប្បដ្ឋាន និង បទដ្ឋាន)

សីលនេះនោះ ពួកវិញ្ញូជនពណ៌នាថា "មានសេចក្តីស្អាតជាបច្ចុប្បដ្ឋាន (ជាផល) ឱត្តប្បៈ និង ហិរិនុ៎ះឯង ជាបទដ្ឋាន (ជាហេតុជាទីតាំង) នៃសីលនោះ ។

មែនពិត សីលនេះនោះ មានសេចក្តីស្អាត ជាបច្ចុប្បដ្ឋាន ដែល



ព្រះមានព្រះភាគត្រាស់ យ៉ាងនេះថា "សីល មានសេចក្តីស្អាតខាងផ្លូវកាយ, ស្អាតខាងផ្លូវវាចា, ស្អាតខាងផ្លូវចិត្ត [១] " ដូច្នេះ រមែងប្រាកដគឺ រមែងដល់នូវភាព នៃការប្រកាន់យកដោយភាពជាធម្មជាតស្អាត ។

ចំណែកហិរិ និង ឱត្តប្បៈ អ្នកប្រាជ្ញពណ៌នាថា ជាបទដ្ឋាននៃសីលនោះ ។ អធិប្បាយថា: ជាហេតុដ៏ជិត ។ ព្រោះថា កាលបើមានហិរិ និង ឱត្តប្បៈ, សីល រមែងកើតឡើងផង រមែងឋិតនៅផង ។ កាលបើហិរិ និង ឱត្តប្បៈ មិនមានទេ, សីល ក៏មិនកើតឡើង មិនឋិតនៅបានឡើយ ។ លក្ខណៈ, រស, បច្ចុប្បដ្ឋាន និង បទដ្ឋាន របស់សីល បណ្ឌិត គប្បីជ្រាប យ៉ាងនេះឯង ។

(អានិសង្សនៃសីល)

(៩) ពាក្យថា "សីល មានអានិសង្សយ៉ាងដូចម្តេច?" ឆ្លើយថា មានកិរិយាបាននូវគុណជាអនេក មានការមិនក្តៅក្រហាយស្តាយក្រោយជាដើម ជាអានិសង្ស ។ សមដូចជាព្រះភគវតត្រាស់ថា "ម្នាលអានន្ទ ! ក៏សីលទាំងឡាយ ជាកុសល មានការមិនក្តៅក្រហាយជាផល មានការមិនស្តាយក្រោយ ជាអានិសង្ស [២]" ដូច្នេះ, នៅមានពាក្យដទៃទៀត ដែលព្រះអង្គទ្រង់ត្រាស់ថា "ម្នាលគហបតីទាំងឡាយ អានិសង្ស របស់អ្នកមានសីល ដល់ព្រមដោយសីល ៥ យ៉ាងនេះ ។ អានិសង្ស ៥ យ៉ាង តើដូចម្តេចខ្លះ? ។ ម្នាលគហបតីទាំងឡាយ បុគ្គលក្នុងលោកនេះ ជាអ្នកមានសីល បរិបូណ៌ដោយសីល តែងបាននូវគំនរនៃភោគៈដ៏ធំ មានសេចក្តីមិនប្រមាទជាហេតុ, នេះជាអានិសង្ស ទី១ របស់បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល ។

១- សុ. អំ. ភាគទី ៤១ ទំព័រទី ៤២២ ។ ២- សុ. អំ. ភាគទី ៥១ ទំព័រ ២២៣ ។

*ម្នាលគហបតីទាំងឡាយ ពាក្យដទៃនៅមានតទៅទៀត កិត្តិស័ព្ទដ៏ល្អ របស់អ្នកមានសីល បរិបូណ៌ដោយសីល រមែងខ្ចរខ្ចាយទៅ, នេះ គឺជាអានិសង្ស ទី ២ របស់អ្នកមានសីល បរិបូណ៌ដោយសីល ។*

*ម្នាលគហបតីទាំងឡាយ ពាក្យដទៃ នៅមានតទៅទៀត បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល រមែងចូលទៅរកបរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី ជាអ្នកក្លៀវក្លា ជាអ្នកមានមុខមិនសំយុងចុះ (មិនខ្មាស), នេះ គឺជាអានិសង្ស ទី ៣ របស់អ្នកមានសីល បរិបូណ៌ដោយសីល ។*

*ម្នាលគហបតីទាំងឡាយ ពាក្យដទៃ នៅមានទៀត បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល ជាអ្នកមិនវង្វេងធ្វើមរណកាល, នេះគឺជាអានិសង្ស ទី ៤ របស់អ្នកមានសីល បរិបូណ៌ដោយសីល ។*

*ម្នាលគហបតីទាំងឡាយ ពាក្យដទៃ នៅមានទៀត បុគ្គលអ្នកមានសីល បរិបូណ៌ដោយសីល លុះទំលាយកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងចូលទៅកើត ក្នុងសុគតិ, សួគ៌, ទេវលោក, នេះ គឺជាអានិសង្ស ទី ៥ របស់អ្នកមានសីល បរិបូណ៌ដោយសីល [១] ។*

*អានិសង្សសីលមានច្រើនជាអនេក មានភាពជាទីស្រឡាញ់ ជាទីពេញចិត្តជាដើម មានការអស់ទៅនៃអាសវៈជាទីបំផុត ព្រះភគវ័ត ទ្រង់ត្រាស់ដោយន័យជាដើមថា “ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុ ដទៃទៀត គប្បីប្រាថ្នាថា: អាត្មាអញ គប្បីជាទីស្រឡាញ់ ជាទីគាប់ចិត្ត ជាទីគោរព និង ជាទីគួរឲ្យសរសើរ របស់ពួកសព្រហ្មចារី ភិក្ខុនោះ គប្បីជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយចុះ [២] ” ។ សីលមានគុណ*

*១- សុ. ទី. ភាគ ១៦ ទំព័រ ១៨៥ ។ ២- សុ. ម. មូ. ភាគ ២០ ទំព័រ ១០៦ ។*



*និង អានិសង្សច្រើនជាអនេក មានសេចក្តីមិនក្តៅក្រហាយស្តាយក្រោយជាដើម យ៉ាងនេះឯង ។ ន័យមួយទៀត ថា :*

> ទីពឹង(ដទៃ) របស់ពួកកុលបុត្រ ក្នុងសាសនានេះ វៀរចាកសីលណាហើយ មិនមានទេ, អ្នកណា គប្បីពោលនូវការកំណត់នូវអានិសង្ស នៃសីលនោះបាន ។ ទឹកគឺសីល រមែងជម្រះ នូវមន្ទិលណា របស់ពួកសត្វមានជីវិត ក្នុងលោកនេះបាន, ស្ទឹងឈ្មោះគង្គាក្តី, យមុនាក្តី, សរភូក្តី, សរស្សតីក្តី, អចិរវតីក្តី, មហីក្តី, មហានទីក្តី ក៏មិនអាចដើម្បីនឹងជម្រះនូវមន្ទិល របស់ពួកសត្វនោះបានឡើយ, សីលនេះ ដែលបុគ្គលរក្សាបានល្អហើយ ជាអរិយសីល មានសេចក្តីត្រជាក់ត្រជាំក្រៃពេក រមែងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយណា របស់សត្វទាំងឡាយក្នុងលោកនេះបាន, ខ្យល់ទាំងឡាយប្រកបដោយភ្លៀង ក៏រម្ងាប់នូវសេចក្តីក្រវល់ក្រវាលនោះ មិនបានឡើយ, សូម្បីខ្លឹមចន្ទន៍ក្រហម កែវមុក្តា កែវមណី ពន្លឺព្រះច័ន្ទដ៏ស្រទន់ ក៏រម្ងាប់សេចក្តីក្រវល់ក្រវាយនោះមិនបានដែរ ។ ក្លិនឯណា ផ្សាយទៅ ក្នុងទីបណ្តោយខ្យល់ និងក្នុងទីច្រាសខ្យល់ស្មើគ្នា, ក្លិននោះ ស្មើដោយក្លិនគឺសីល នឹងមានឈ្មោះមកអំពីទីណាបាន ។ ទីពឹងដទៃ ជាជណ្តើរឡើងទៅកាន់ឋានសួគ៌ ឬក៏ ជាទ្វារ ក្នុងកិរិយាចូលទៅកាន់នគរ គឺព្រះនិព្វាន ដែលស្មើដោយ

សីល នឹងមានមកអំពីណា ។ ពួកភិក្ខុដែលមានឥន្ទ្រិយ៍សង្រួមហើយ ស្អិតស្អាងហើយ ដោយគ្រឿងស្អិតស្អាង គឺសីល រមែងល្អបាន យ៉ាងណា, ព្រះរាជាទាំងឡាយ ដែលស្អិតស្អាងហើយ ដោយកែវមុក្តា និង កែវមណី ក៏នៅតែមិនល្អបាន យ៉ាងនោះ ។ សីល របស់អ្នកមានសីលទាំងឡាយ រមែងកំចាត់បង់នូវភ័យ មានភ័យអំពីការតិះដៀលខ្លួនជាដើមបាន ដោយប្រការទាំងពួង ទាំងញ៉ាំងកិត្តិស័ព្ទ និង សេចក្តីរីករាយ ឲ្យកើតបានសព្វៗកាល ។ កថាមុខ ដែលសម្តែងនូវអានិសង្ស នៃសីល ដែលជាឫសគល់នៃគុណទាំងឡាយ មានកិរិយាសម្លាប់នូវកម្លាំងនៃទោសទាំងឡាយ បណ្ឌិត គប្បីជ្រាប ដូចដែលបានរៀបរាប់មកនេះឯង ។

## (សីលមានប៉ុន្មានយ៉ាង)

*(១០) ឥឡូវនេះ ជាពាក្យដោះស្រាយ ក្នុងបញ្ហាកម្ម ដែលលោកពោលថា* “ ក៏សីលនោះ មានប៉ុន្មានយ៉ាង? ” *។*

*សីលទាំងអស់នេះឯង មានប្រការ ១ ដោយលក្ខណៈ ជាប្រក្រតីរបស់ខ្លួនមុនសិន, សីល មាន ២ យ៉ាង ដោយអំណាចនៃចារិត្តសីល និង វារិត្តសីល, សីល មាន ២ យ៉ាង ដោយអំណាចនៃអភិសមាចារិក-សីល និង អាទិព្រហ្មចរិយសីល ដោយអំណាចនៃវិរតិសីល និង អវិ-រតិសីល ដោយអំណាចនិស្សិតសីល និង អនិស្សិតសីល ដោយអំណាចនៃកាលបរិយន្តសីល និង អាបាណកោដិកសីល ដោយអំណាច*



*នៃសបរិយន្តសីល និង អបរិយន្តសីល និង ដោយអំណាចលោកិយ-សីល និង លោកុត្តរសីល ក៏ដូច្នោះដែរ ។*

*សីល មាន ៣ យ៉ាង ដោយអំណាចហីនសីល, មជ្ឈិមសីល និង បណីតសីល ។ មួយទៀត សីល មាន ៣ យ៉ាង ដោយអំណាចនៃអត្តាធិបតេយ្យសីល លោកាធិបតេយ្យសីល និង ធម្មាធិបតេយ្យសីល ដោយអំណាចនៃបរាមដ្ឋសីល អបរាមដ្ឋសីល និង បដិបស្សទ្ធិសីល ដោយអំណាចនៃវិសុទ្ធិសីល អវិសុទ្ធិសីល និង វេមតិកសីល ដោយអំណាចនៃសេខសីល អសេខសីល និង នេវសេខានាសេខសីល ក៏ដូចគ្នាដែរ ។*

*សីល មាន ៤ យ៉ាង ដោយអំណាចនៃហានភាគិយសីល ឋិតិ-ភាគិយសីល វិសេសភាគិយសីល និង និព្វេធភាគិយសីល, ដោយអំណាចនៃភិក្ខុសីល ភិក្ខុនីសីល អនុបសម្បន្នសីល និង គហដ្ឋសីល, ដោយអំណាចបកតិសីល អាចារសីល ធម្មតាសីល និង បុព្វហេតុក-សីល និង ដោយអំណាចនៃបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសីល អាជីវបារិសុទ្ធិសីល និង បច្ចយសន្និស្សិតសីល ក៏យ៉ាងនោះដែរ ។*

*សីល មាន ៥ យ៉ាង ដោយអំណាចនៃបារិសុទ្ធិសីល មានបរិយន្តបារិសុទ្ធិសីលជាដើម ។ ដូចពាក្យដែលព្រះសារីបុត្តត្ថេរ ពោលក្នុងគម្ពីរបដិសម្ភិទាថា “សីល មាន ៥ យ៉ាង គឺបរិយន្តបារិសុទ្ធិសីល អបរិយន្តបារិសុទ្ធិសីល បរិបុណ្ណបារិយន្តសីល អបរាមដ្ឋបារិសុទ្ធិសីល បដិបស្សទ្ធិបារិសុទ្ធិសីល [១] ” ។ មួយទៀត មាន ៥ យ៉ាង ដោយអំណាចនៃបហានសីល, វេរមណីសីល, ចេតនាសីល, សំវរសីល និង*

---

*១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ៩៦ ។*

អវីតិក្កមសីល ។ បណ្ដាសីលទាំងនោះ ក្នុងចំណែកសីល មាន ១ យ៉ាង បណ្ឌិតគប្បីជ្រាបសេចក្ដី តាមន័យដែលពោលហើយនោះចុះ ។

(ក្រុមសីល ២ ទី ១)

(១១) បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងចំណែកនៃសីល មាន ២ ប្រការ ។ ការបំពេញសិក្ខាបទដែលព្រះភគវតទ្រង់បញ្ញត្ត ថា “កម្មនេះ គឺអ្នកត្រូវធ្វើ” ឯណា, ការបំពេញ នូវសិក្ខាបទនោះ ឈ្មោះថា ចារិត្តសីល ។ ការមិនធ្វើ នូវសេចក្ដីល្មើសសិក្ខាបទ ដែលព្រះអង្គទ្រង់ហាមឃាត់ហើយថា “កម្មនេះ គឺអ្នកមិនត្រូវធ្វើ” ឯណា, ការមិនធ្វើ សេចក្ដីល្មើសសិក្ខាបទ ដែលព្រះអង្គទ្រង់ហាមឃាត់នោះ ឈ្មោះថា វារិត្តសីល ។ នេះ គឺ ជាសេចក្ដីអធិប្បាយនៃពាក្យ ក្នុងចារិត្តសីល និង វារិត្តសីលនោះ ។ បុគ្គលទាំងឡាយ តែងប្រព្រឹត្តក្នុងសីលនោះ គឺថា ប្រព្រឹត្តដោយភាពជាអ្នកធ្វើឲ្យពេញលេញបរិបូណ៌ ក្នុងសីលទាំងឡាយ ព្រោះហេតុនោះ សីលនោះ ទើបឈ្មោះថា ចារិត្តសីល ។ បុគ្គលទាំងឡាយតែងឃុំគ្រង គឺរក្សានូវសិក្ខាបទ ដែលព្រះភគវត ទ្រង់ហាមឃាត់ហើយ ដោយសីលនោះ ព្រោះហេតុនោះ សីលនោះ ឈ្មោះថា វារិត្តសីល ។ បណ្ដាចារិត្តសីល និង វារិត្តសីល ទាំង ២ យ៉ាងនោះ ចារិត្តសីល សម្រេចអំពីសទ្ធា និង វីរិយៈ, វារិត្តសីល សំរេចអំពីសទ្ធា (តែម្យ៉ាង) ។ សីល មាន ២ យ៉ាង ដោយអំណាចនៃចារិត្តសីល និង វារិត្តសីល យ៉ាងនេះឯង ។

(ក្រុមសីល ២ ទី ២)

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងក្រុមសីល ២ ទី ២ ។ ការប្រព្រឹត្តិស្មើដ៏ខ្ពង់ខ្ពស់ ឈ្មោះថា អភិសមាចារ ។ ការប្រព្រឹត្តិស្មើ ដ៏ខ្ពង់ខ្ពស់



ហ្នឹងឯង ឈ្មោះថា ការប្រកបដោយអភិសមាចារ ។ មួយវិញទៀត សិក្ខាបទ ដែលព្រះភគវតទ្រង់បញ្ញត្ត ប្រារព្ធនូវអភិសមាចារ ឈ្មោះថា អភិសមាចារិកសីល ។ ពាក្យថា អភិសមាចារិកសីលនេះ ជាឈ្មោះនៃសីលដ៏សេសក្រៅពីសីលមានអាជីវៈជាគំរប់ ៨ [1] ។ សីល ឯណា ដែលជាភាវៈខាងដើម នៃមគ្គព្រហ្មចរិយៈ ព្រោះហេតុនោះ សីលនោះ ទើបឈ្មោះថា អាទិព្រហ្មចរិយកសីល ។ ពាក្យថា អាទិព្រហ្មចរិយក-សីលនេះ ជាឈ្មោះនៃអាជីវមដ្ឋកសីល ។ មែនពិត អាជីវមដ្ឋកសីលនោះ ឈ្មោះថាកើតដោយភាពជាខាងដើមនៃមគ្គ ព្រោះភាវៈនៃសីលនោះ ជាគុណគឺបុគ្គលត្រូវជម្រះ ឲ្យស្អាតបរិសុទ្ធ ក្នុងចំណែកជាខាងដើមនុ៎ះឯង ។ ហេតុនោះ ព្រះភគវតត្រាស់ថា “ក៏កាយកម្ម, វចីកម្ម, អាជីវៈរបស់ភិក្ខុនោះ រមែងបរិសុទ្ធល្អ តាំងពីដើមមកម៉្លេះ [2] ” ។ មួយទៀត ពួកសិក្ខាបទណា ដែលព្រះភគវតត្រាស់ថា “ជាសិក្ខាបទតូច និង តូចបន្ទាប់” សិក្ខាបទនេះ ឈ្មោះថា អភិសមាចារិកសីល ។ សិក្ខាបទដ៏សេស ឈ្មោះថា អាទិព្រហ្មចរិយកសីល ។ មួយវិញទៀត សីល ដែលរាប់បញ្ចូល ក្នុងឧភតោវិភង្គ ជាអាទិព្រហ្មចរិយកសីល, ដែលរាប់បញ្ចូល ក្នុងខន្ធកវត្ត ឈ្មោះថា អភិសមាចារិកសីល ។

អាទិព្រហ្មចរិយកសីល សម្រេចព្រម ព្រោះកិរិយាដល់ព្រម នៃអភិសមាចារិកសីលនោះ ។ ព្រោះហេតុនោះ ព្រះភគវតទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ថាបើភិក្ខុនោះ មិនបានបំពេញធម៌ គឺអភិសមា-ចារិកសីលឲ្យបានពេញបរិបូណ៌ហើយ នឹងបំពេញនូវធម៌ គឺអាទិព្រហ្ម-

---

១- សីលមានអាជីវៈជាគំរប់ ៨ បានដល់កុសលកម្មបថ ៧ ដែលជាកាយកម្ម ៣ វចីកម្ម ៤ និង អាជីវបារិសុទ្ធិ ១ ។ ២- ម. ឧ. ភាគទី ២៨ ទំព័រ ៣៨០ ។

ចរិយកសីល ដូច្នេះ, ការប្រព្រឹត្តិនេះ ជាហេតុជាទីតាំងមិនមាន [១] ” ។ សីល មាន ២ យ៉ាង ដោយអំណាច នៃអភិសមាចារិកសីល និង អាទិព្រហ្មចរិយកសីល ដូច្នេះឯង ។

(ក្រុមសីល ២ ទី ៣)

បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងទុកៈ ទី៣ ។ សីល ដែលសម្រេចអំពីការវៀរចាកទោស មានបាណាតិបាតជាដើម ឈ្មោះថា វិរតិសីល ។ សីលដ៏សេសមានចេតនាជាដើម ឈ្មោះថា អវិរតិសីល ។ សីល មាន២ យ៉ាង ដោយអំណាចវិរតិសីល និង អវិរតិសីល ដូច្នេះ ។

(ក្រុមសីល ២ ទី ៤)

បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងទុកៈ ទី ៤ ។ ក្នុងពាក្យថា “និស្ស័យ” បានដល់ និស្ស័យ មាន ២ យ៉ាង គឺៈ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ។ បណ្ដានិស្ស័យទាំង ២ នោះ សីលណា ដែលបុគ្គលប្រាថ្នា នូវសម្បត្តិ ក្នុងភព យ៉ាងនេះ ថា “អាត្មាអញ នឹងបានជាទេវតា ឬ ជាទេវតាណាមួយ ដោយសីលនេះ” ដូច្នេះ ប្រព្រឹត្តទៅ, សីលនេះ ឈ្មោះថាអាស្រ័យដោយតណ្ហា ។ សីលណា ដែលបុគ្គលឲ្យប្រព្រឹត្តទៅ ដោយការយល់ឃើញថាស្អាតថា “អាត្មាអញ ជាអ្នកស្អាតដោយសីល” ដូច្នេះ, សីលនេះ ឈ្មោះថា អាស្រ័យដោយទិដ្ឋិ ។ ចំណែកសីលណា ជាលោកុត្តរៈផង ជាលោកិយៈ តែជាគ្រឿងទំនុកបំរុងលោកុត្តរសីល នោះផង, សីលនេះ ឈ្មោះថា អនិស្សិតសីល ។ សីល ២ យ៉ាង គឺ និស្សិតសីល និង អនិស្សិតសីល យ៉ាងដូច្នេះឯង ។

(ក្រុមសីល ២ ទី ៥)

---

១– សុ. អំ. ប. ភាគទី ៤៩ ទំព័រទី ២៨ ។



បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងទុកៈ ទី៥ ។ សីលដែលបុគ្គលធ្វើការកំណត់កាលសមាទាន ឈ្មោះថា កាលបរិយន្តសីល, សីលដែលបុគ្គលសមាទាន ដរាបដល់អស់ជីវិត ហើយប្រព្រឹត្តទៅ ដរាបដល់អស់ជីវិត ដូច្នោះដែរ ឈ្មោះថា អាបាណកោដិកសីល ។ សីល មាន ២ ប្រការ ដោយអំណាចកាលបរិយន្តសីល និង អាបាណកោដិកសីល យ៉ាងដូច្នេះឯង ។

(ក្រុមសីល ២ ទី ៦)

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងទុកៈ ទី៦ ។ សីលដែលមានការយល់ឃើញ ដោយអំណាចនៃលាភ, យស, ញាតិ, អវយវៈ និង ជីវិត ជាទីបំផុត ឈ្មោះថា សបរិយន្តសីល, សីល ដែលផុយគ្នាអំពីនេះ ឈ្មោះថា អបរិយន្តសីល ។ សមដូចពាក្យដែលព្រះសារីបុត្រ ពោលក្នុងបដិសម្ភិទា ថាៈ “(សួរថា) សីល មានទីបំផុតនោះ តើដូចម្ដេច?, (ឆ្លើយថា) សីល មានលាភជាទីបំផុត ក៏មាន, សីលមានយសជាទីបំផុត ក៏មាន, សីលមានញាតិជាទីបំផុត ក៏មាន, សីលមានអវយវៈជាទីបំផុត ក៏មាន, សីលមានជីវិតជាទីបំផុត ក៏មាន, (សួរថា) សីល មានលាភជាទីបំផុត តើដូចម្ដេច?, (ឆ្លើយថា) បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងសិក្ខាបទ តាមដែលខ្លួនសមាទានហើយយ៉ាងណា ព្រោះលាភជាហេតុ ព្រោះលាភជាបច្ច័យ ព្រោះលាភជាដើមហេតុ, សីល នេះនោះ ឈ្មោះថា លាភបរិយន្តសីល [១] ។ សីលក្រៅអំពីនេះ បណ្ឌិត គប្បី (សម្ដែង) ឲ្យពិស្ដារ ដោយឧបាយនេះឯង ។ សូម្បីក្នុងការវិសជ្ជនាអបរិយន្តសីល ក៏លោកពោលថា “(សួរថា) សីលដែលមិនមានលាភ

---

១– សុ. ខុ. ភាគទី ៦៩ ទំព័រទី ៩៧ ។

ជាទីបំផុតនោះ តើដូចម្តេច?, (ឆ្លើយថា) បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនញុំាំងសូម្បីការគិតឲ្យកើតឡើង ក្នុងការប្រព្រឹត្តិកន្លង នូវសិក្ខាបទតាមដែលខ្លួនបានសមាទានហើយយ៉ាងណា ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះដំណើរនៃលាភ, បុគ្គលនោះ នឹងប្រព្រឹត្តកន្លង (ដោយកាយ, វាចា) ដូចម្តេចកើត, សីលនេះនោះ ឈ្មោះថា មិនមែនមានលាភជាទីបំផុតឡើយ [(១)] ”។ ឯសីលក្រៅអំពីនេះ បណ្ឌិត គប្បី (សម្តែង)ឲ្យពិស្តារ ដោយឧបាយនេះឯង ។ សីលមាន ២ យ៉ាង ដោយអំណាចនៃសបរិយន្តសីល និង អបរិយន្តសីល យ៉ាងដូច្នេះឯង ។

(ក្រុមសីល ២ ធី ៧)

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងទុកៈ ទី ៧ ។ សីល ដែលប្រកបដោយអាសវៈគ្រប់យ៉ាង ឈ្មោះថា លោកិយសីល ។ សីល ដែលមិនមានអាសវៈ ឈ្មោះថា លោកុត្តរសីល ។ បណ្តាសីលទាំង ២ យ៉ាងនោះ លោកិយសីល ជាសីលនាំគុណវិសេសក្នុងភពផង ជាគ្រឿងគាំទ្រនូវការរលាស់ខ្លួនចេញចាកភពផង ។ សមដូចជាព្រះភគវតត្រាស់ថា “វិន័យ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់សំវរៈ, សំវរៈ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់សេចក្តីមិនក្តៅក្រហាយស្តាយក្រោយ, សេចក្តីមិនក្តៅក្រហាយស្តាយក្រោយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់បាមោជ្ជៈ បាមោជ្ជៈ ប្រព្រឹត្តទៅព្រម ដើម្បីប្រយោជន៍ដល់បីតិ, បីតិ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់បស្សទ្ធិ, បស្សទ្ធិ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់សុខៈ, សុខៈប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់សមាធិ, សមាធិប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ, យថាភូតញ្ញាណទស្សនៈ

១– សុ. ខុ. ភាគទី ៦៩ ទំព័រទី ៩៩ ។



ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់និព្វិទា, និព្វិទា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់វិរាគៈ, វិរាគៈ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់វិមុត្តិ, វិមុត្តិ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ, វិមុត្តិញ្ញាណទស្សនៈ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន ជាទីចូលទៅជិតប្រកាន់មិនមាន, កិរិយាពោល (នូវវិន័យ) មានការរួបរួមនេះ ជាប្រយោជន៍, ការប្រឹក្សា (នូវវិន័យ) មានវិន័យនេះជាប្រយោជន៍, ការចូលទៅអង្គុយជិត មានវិន័យនេះជាប្រយោជន៍, ការផ្ទៀងត្រចៀកស្តាប់ មានវិន័យនេះជាប្រយោជន៍, ការរួចស្រឡះនៃចិត្ត ព្រោះមិនប្រកាន់មាំ មានវិន័យនេះជាប្រយោជន៍” ។ លោកុត្តរសីល ជាហេតុនាំមកនូវការរលាស់ខ្លួនចេញចាកភពផង ជាភូមិនៃបច្ចវេក្ខណញ្ញាណផង យ៉ាងនេះឯង ។ បណ្ឌិតគប្បីជ្រាបសីល ២ យ៉ាង ដោយអំណាចលោកិយសីល និង លោកុត្តរសីល ដោយប្រការដូច្នេះ ។

(ក្រុមសីល ៣ ធី ១)

(១២) ក្នុងតិកៈទាំងឡាយ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងតិកៈ ទី១ ដូចតទៅ ។ សីលដែលបុគ្គលឲ្យប្រព្រឹត្តទៅ ដោយឆន្ទៈ ដ៏ថោកទាបក្តី ដោយចិត្ត ដោយវិរិយៈ ដោយវិមំសាដ៏ថោកទាបក្តី ឈ្មោះថា ហីនសីល, សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅ ដោយគុណទាំងឡាយ មានឆន្ទៈជាដើម ជាកណ្តាល ឈ្មោះថា មជ្ឈិមសីល, សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅ ដោយឆន្ទៈដ៏ថ្លៃថ្លា ឈ្មោះថា បណីតសីល, មួយទៀត សីលដែលបុគ្គលសមាទាន ដោយភាពនៃខ្លួនជាអ្នកប្រាថ្នាយស ឈ្មោះថា ហីនសីល ។ សីល ដែលបុគ្គលសមាទាន ព្រោះភាពនៃខ្លួនជាអ្នកប្រាថ្នាផល នៃបុណ្យ ឈ្មោះថា មជ្ឈិមសីល ។ សីល ដែលបុគ្គល

សមាទាន ព្រោះអាស្រ័យនូវភាពជាព្រះអរិយៈ ដោយគិតថា “សីលនេះ អាត្មាអញត្រូវតែធ្វើពិត” ឈ្មោះថា បណីតសីល, មួយទៀត សីល ដែលទោសទាំងឡាយ មានការលើកតម្កើងខ្លួនបន្ទុះបង្អាប់អ្នកដទៃ ចូល ទៅសៅហ្មងហើយ យ៉ាងនេះថា “អាត្មាអញ ជាអ្នកបរិបូណ៌ ដោយ សីល, ឯពួកភិក្ខុដទៃ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក” ដូច្នេះ ឈ្មោះថា ហីនសីល, លោកិយសីល ដែលទោសមិនចូលទៅសៅហ្មង ហើយ ឈ្មោះថា មជ្ឈិមសីល, លោកុត្តរសីល ឈ្មោះថាបណីតសីល។ មួយវិញទៀត សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដើម្បីប្រយោជន៍ ដល់ភព និង ភោគៈ ដោយអំណាចតណ្ហា ឈ្មោះថា ហីនសីល, សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដើម្បីប្រយោជន៍ដល់ការញ៉ាំងខ្លួន ឲ្យ រួចចាកទុក្ខ ឈ្មោះថា មជ្ឈិមសីល, សីល គឺការៈនៃបារមីដែលព្រះ ពោធិសត្វ ឲ្យប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ការញ៉ាំងសព្វសត្វ ឲ្យរួច ចាកទុក្ខ ឈ្មោះថា បណីតសីល ។ បណ្ឌិត គប្បីជ្រាបសីល ៣ យ៉ាង ដោយអំណាចហីនសីល, មជ្ឈិមសីល និង បណីតសីល ដូច្នេះឯង ។

(ក្រុមសីល ៣ ទី ២)

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងតិកៈ ទី ២ ។ សីល ដែលបុគ្គល មានចិត្តធ្ងន់ក្នុងខ្លួន ប្រាថ្នាចង់លះបង់នូវអំពើមិនសមគួរដល់ខ្លួន ប្រព្រឹត្ត ទៅ ដោយសេចក្តីគោរព ក្នុងខ្លួន ឈ្មោះថា អត្តាធិបតេយ្យសីល ។ សីល ដែលបុគ្គលមានចិត្តធ្ងន់ ក្នុងលោក ចង់ចៀសវាងពាក្យតិះដៀល ក្នុងលោក ប្រព្រឹត្តទៅ ដោយសេចក្តីគោរព ក្នុងលោក ឈ្មោះថា លោកាធិបតេយ្យសីល, សីល ដែលបុគ្គលមានចិត្តធ្ងន់ក្នុងធម៌ ចង់បូជា នូវការៈនៃធម៌ជាធំ ប្រព្រឹត្តទៅ ដោយសេចក្តីគោរព ក្នុងព្រះធម៌ ឈ្មោះ



ថា ធម្មាធិបតេយ្យសីល ។ សីលមាន ៣ យ៉ាង ដោយអំណាចនៃសីល មានអត្តាធិបតេយ្យសីលជាដើម យ៉ាងនេះឯង ។

(ក្រុមសីល ៣ ទី ៣)

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យក្នុងតិកៈ ទី៣ ។ សីលណា ដែលលោក ពោលហើយថា “និស្សិតសីល” ក្នុងពួកទី ២, សីលនោះ ឈ្មោះថា បរាមដ្ឋសីល ព្រោះសីលនោះ ត្រូវតណ្ហា និង ទិដ្ឋិ ពាល់ត្រូវហើយ ។ សីល ដែលជាគ្រឿងគាំពារមគ្គ នៃកល្យាណបុថុជ្ជន និង ដែលប្រកប ព្រមដោយមគ្គ នៃសេខបុគ្គលទាំងឡាយ ឈ្មោះថា អបរាមដ្ឋសីល (សីល ដែលតណ្ហា និង ទិដ្ឋិ ពាល់ត្រូវមិនបាន), ចំណែកសីលដែល ប្រកបព្រមដោយផល នៃព្រះសេខបុគ្គល និង ព្រះអសេខបុគ្គលទាំង ឡាយ ឈ្មោះថា បដិប្បស្សទ្ធិសីល ។ សីល មាន ៣ យ៉ាង ដោយ អំណាចនៃសីល មានបរាមដ្ឋសីលជាដើម យ៉ាងនេះឯង ។

(ក្រុមសីល ៣ ទី ៤)

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងតិកៈ ទី៤ ។ សីលណា ដែលភិក្ខុ បំពេញធ្វើមិនឲ្យត្រូវអាបត្តិសោះ ពុំនោះសោតត្រូវហើយ តែបានទៅ បរិវាសកម្ម ឬ សម្តែងអាបត្តិចេញ, សីលនោះ ឈ្មោះថា វិសុទ្ធិសីល, សីលដែលភិក្ខុត្រូវអាបត្តិហើយតែមិនទៅបរិវាសកម្ម ឬ សម្តែងឲ្យបាន ល្អឡើងវិញ ឈ្មោះថា អវិសុទ្ធិសីល, សីល របស់ភិក្ខុអ្នកមានសេចក្តី សង្ស័យក្នុងវត្ថុ (ដែលជាទីកើតអាបត្តិ) ក្តី ក្នុងអាបត្តិក្តី ក្នុងការប្រព្រឹត្តិ ខុស(ដែលគួរឲ្យកើតអាបត្តិ)ក្តី ឈ្មោះថា វេមតិកសីល ។ បណ្តាសីល ទាំងនោះ អវិសុទ្ធិសីល ព្រះយោគីត្រូវជម្រះឲ្យស្អាត ក្នុងវេមតិកសីល មិនត្រូវធ្វើការប្រព្រឹត្តិខុសក្នុងវត្ថុ ត្រូវបន្ទោបង់សេចក្តីសង្ស័យ ឲ្យទាល់

*តែបាន ដូច្នេះ សេចក្ដីសប្បាយ នឹងមានដល់ព្រះយោគីនោះ ។ គប្បីជ្រាបសីល ៣ យ៉ាង ដោយអំណាចនៃសីល មានវិសុទ្ធិសីល និង អវិសុទ្ធិសីលជាដើម យ៉ាងដូច្នេះឯង ។*

(ក្រុមសីល ៣ ទី ៥)

*បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងតិកៈ ទី៥ ។ សីលដែលសម្បយុត្ត ដោយអរិយមគ្គ ៤ និង សាមញ្ញផល ៣ ឈ្មោះថា សេខសីល, សីលដែលសម្បយុត្ត ដោយអរហត្តផល ឈ្មោះថា អសេខសីល, សីលដ៏សេស ឈ្មោះថា នេវសេខានាសេខសីល ។ សីល មាន ៣ យ៉ាង ដោយអំណាចនៃសីល មានសេខសីលជាដើម យ៉ាងដូច្នេះឯង ។*

*ចំណែកក្នុងគម្ពីរបដិសម្ភិទា ព្រះធម្មសេនាបតីសារីបុត្រពោល ថា "ជនទាំងឡាយ ពោលថា: បុគ្គលនេះ មានសេចក្ដីសុខ ជាប្រក្រតី, បុគ្គលនេះ មានទុក្ខជាប្រក្រតី, បុគ្គលនេះ មានជម្លោះជាប្រក្រតី, បុគ្គលនេះ មានការប្រដាប់តាក់តែងជាប្រក្រតី ដូច្នេះ ព្រោះសំដៅយកនូវប្រក្រតីណា, ប្រក្រតីនោះ លោកហៅថា "សីល" របស់សត្វទាំងឡាយនោះៗ ក្នុងលោក ព្រោះហេតុណា, ព្រោះហេតុនោះ សីល ទើបមាន ៣ យ៉ាង គឺ កុសលសីល, អកុសលសីល, អព្យាកតសីល ដោយបរិយាយនោះ" ដូច្នោះ, សីល មាន ៣ យ៉ាង ដោយអំណាចសីលមានកុសលសីលជាដើម យ៉ាងដូច្នេះឯង ។ បណ្ដាសីលទាំង ៣ យ៉ាងនោះ អកុសលសីល មិនសមសូម្បីដោយចំណែកមួយ ក្នុងចំណោមហេតុ មានលក្ខណៈជាដើម នៃសីលដែលខ្ញុំបានប៉ងយកហើយ ក្នុងសេចក្ដីនេះ ហេតុនោះ ទើបមិនបាននាំមកបញ្ចូល ក្នុងនិទ្ទេសនេះទេ ។*

*ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបភាវៈនៃសីលនោះមាន ៣ យ៉ាង*



*តាមន័យដែលខ្ញុំពោលមកហើយហ្នឹងឯង ។*

(ក្រុមសីល ៤ ទី ១)

*(១៣) ក្នុងចតុក្កៈទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យ ក្នុងចតុក្កៈ ទី១*

ភិក្ខុណា ក្នុងសាសនានេះ សេពគប់ពួកជនទ្រុស្ដសីល មិនសេពគប់ពួកជនអ្នកមានសីល ជាអ្នកល្ងង់ខ្លៅ មិនឃើញនូវទោស ក្នុងកិរិយាប្រព្រឹត្តិកន្លងចំពោះវត្ថុ ច្រើនដោយសេចក្ដីត្រិះរិះខុស មិនរក្សានូវឥន្ទ្រិយ៍ទាំងឡាយ, សីល របស់ភិក្ខុមានសភាពបែបនេះនោះ ចាត់ថា ជាសីល ប្រព្រឹត្តទៅ ក្នុងចំណែកនៃសេចក្ដីសាបសូន្យ ។ ចំណែក ភិក្ខុណា ក្នុងព្រះសាសនានេះ ជាអ្នកមានចិត្តត្រេកអររីករាយ ក្នុងសីលសម្បត្តិ មិនញុំាងសេចក្ដីប្រាថ្នាក្នុងចិត្ត ឲ្យកើតឡើង ក្នុងការប្រកបរឿយៗ ក្នុងកម្មដ្ឋាន, សីលនោះ របស់ភិក្ខុរូបនោះ ជាអ្នកត្រេកអរត្រឹមតែសីល មិនប្រឹងប្រែងព្យាយាមឲ្យបានខ្ពស់ តទៅទៀត ជាសីលប្រព្រឹត្តទៅ ក្នុងចំណែកនៃការតាំងនៅ ។ ចំណែក ភិក្ខុរូបណា បរិបូណ៌ដោយសីល ប្រឹងប្រែងព្យាយាម ដើម្បីប្រយោជន៍ ដល់សមាធិ, សីល របស់ភិក្ខុនោះ ជាសីលប្រព្រឹត្តទៅ ក្នុងចំណែក នៃគុណវិសេស ។ ភិក្ខុរូបណា មិនត្រេកអរ ដោយហេតុត្រឹមតែសីល តែងប្រកបរឿយៗ នូវសេចក្ដីនឿយណាយ, សីល របស់ភិក្ខុរូបនោះ ជាសីលប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹង ។

សីល មាន ៤ យ៉ាង ដោយអំណាចនៃសីល មានហានភាគិយ-សីលជាដើម ដោយប្រការដូច្នេះឯង ។

(ក្រុមសីល ៤ ទី ២)

គប្បីជ្រាបវិនិច្ឆ័យ ក្នុងចតុក្កៈ ទី២ តទៅ ។ សិក្ខាបទទាំងឡាយ ដែលព្រះភគវ័ត ទ្រង់ត្រាស់បញ្ញត្ត ប្រារព្ធភិក្ខុទាំងឡាយ និង សិក្ខាបទ ដែលភិក្ខុទាំងនោះ ត្រូវតែរក្សា តាមព្រះបញ្ញត្ត, សីលនេះ ឈ្មោះថា ភិក្ខុសីល, សិក្ខាបទទាំងឡាយ ដែលព្រះភគវ័តទ្រង់ត្រាស់បញ្ញត្តប្រារព្ធ ភិក្ខុនីទាំងឡាយ និង សិក្ខាបទដែលភិក្ខុនីទាំងនោះ ត្រូវតែរក្សាតាម ព្រះបញ្ញត្ត, សីលនេះ ឈ្មោះថា ភិក្ខុនីសីល, សីល ១០ របស់ពួក សាមណេរ និង សាមណេរី ឈ្មោះថា អនុបសម្បន្នសីល, សិក្ខាបទ ទាំង ៥ ដោយអំណាចនៃនិច្ចសីល របស់ពួកឧបាសក និង ឧបាសិកា, ឬ បើមានសេចក្តីឧស្សាហ៍ (ឧបាសក និង ឧបាសិកាត្រូវតែរក្សា) សីល ១០, សីល ៨ ដោយអំណាចនៃអង្គរបស់ឧបោសថ ព្រោះហេតុនោះ សីលនេះ ឈ្មោះថា គហដ្ឋសីល ។ សីល មាន ៤ យ៉ាង ដោយ អំណាចនៃសីល មានភិក្ខុសីលជាដើម យ៉ាងនេះឯង ។

(ក្រុមសីល ៤ ទី ៣)

គប្បីជ្រាបវិនិច្ឆ័យ ក្នុងចតុក្កៈ ទី៣ តទៅនេះ ។ ការមិនប្រព្រឹត្តិ ល្មើស (សីល ៥) របស់ពួកមនុស្សអ្នកនៅ ក្នុងឧត្តរកុរុទ្វីប ឈ្មោះថា ប្រក្រតិសីល, មារយាទ និង ឬកពារៀងៗខ្លួន របស់ត្រកូល, ប្រទេស និង លទ្ធិទាំងឡាយ ឈ្មោះថា អាចារសីល, សីល របស់ព្រះមាតា នៃព្រះពោធិសត្វ ដែលព្រះភគវ័តទ្រង់ត្រាស់ យ៉ាងនេះថា "ម្នាលអានន្ទ នេះ ជាធម្មតា, ព្រះពោធិសត្វ យាងចុះកាន់ព្រះគភ៌ នៃព្រះមាតា ក្នុង



ពេលណា, ក្នុងពេលនោះ ចិត្ត ប្រកបដោយកាមគុណ ក្នុងពួកបុរស មិនកើតឡើងដល់ព្រះមាតា នៃព្រះពោធិសត្វឡើយ (១)" ដូច្នេះ (សីល នេះ) ឈ្មោះថា ធម្មតាសីល, ចំណែកខាងសីលរបស់សត្វដែលបរិសុទ្ធ ទាំងឡាយ មានព្រះមហាកស្សបៈជាដើម និង របស់ព្រះពោធិសត្វ ក្នុង ជាតិទាំងឡាយនោះៗ ឈ្មោះថា បុព្វហេតុកសីល ។ សីល មាន ៤ យ៉ាង ដោយអំណាចនៃសីល មានប្រក្រតិសីលជាដើម យ៉ាងដូច្នេះ ។

(ក្រុមសីល ៤ ទី ៤)

គប្បីជ្រាបវិនិច្ឆ័យ ក្នុងចតុក្កៈ ទី ៤ ដូចតទៅនេះ ។

(បាតិមោក្ខសំវរសីល)

សីលឯណា ដែលព្រះភគវ័តទ្រង់ត្រាស់ យ៉ាងនេះថា "ភិក្ខុ ក្នុង សាសនានេះ ជាអ្នកសង្រួមដោយការសង្រួម ក្នុងបាតិមោក្ខ ជាអ្នក បរិបូណ៌ដោយអាចារៈ និង គោចរៈ នៅ ជាអ្នកឃើញភ័យ ក្នុងទោស ទាំងឡាយ ដែលមានប្រមាណតិចតួច សមាទាន សិក្សា ក្នុងសិក្ខាបទ ទាំងឡាយ (២)" ដូច្នេះ, សីលនេះ ឈ្មោះថា បាតិមោក្ខសំវរសីល ។

(ឥន្ទ្រិយសំវរសីល)

ចំណែកឯ សីលណា ដែលព្រះភគវ័ត ទ្រង់ត្រាស់ថា "ភិក្ខុនោះ ឃើញនូវរូប ដោយចក្ខុ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវ អនុព្យញ្ជនៈ, ពួកធម៌អាក្រក់ ជាអកុសល គឺអភិជ្ឈា និង ទោមនស្ស គប្បីជាប់តាមនូវភិក្ខុនោះ ព្រោះហេតុមិនសង្រួម នូវចក្ខុន្ទ្រីយ៍ណា ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រីយ៍នោះ តែងរក្សានូវចក្ខុន្ទ្រីយ៍ ដល់នូវការ សង្រួមក្នុងចក្ខុន្ទ្រីយ៍, ភិក្ខុនោះ ឮសំឡេង ដោយត្រចៀក ។ល។ ធុំក្លិន

---

១– សុ. ទី. ម. ភាគ ១៦ ទំព័ ២៦ ។ ២– អភិ. វិ. ភាគ ៨១ ទំព័រ ២៨៥ ។

ដោយច្រមុះ ។ល។ ភ្លក្សរស ដោយអណ្តាត ។ល។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ។ល។ ដឹងច្បាស់ធម្មារម្មណ៍ ដោយចិត្ត តែជាអ្នកមិនកាន់យកនូវនិមិត្ត ។ល។ រមែងដល់នូវការសង្រួមក្នុងមនិន្ទ្រីយ៍ [១] ” ដូច្នេះ, សីលនេះ ឈ្មោះថា ឥន្ទ្រិយសំវរសីល ។

(អាជីវបារិសុទ្ធិសីល)

ចំណែកកិរិយាវៀរឯណា ចាកមិច្ឆាជីវៈ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃការប្រព្រឹត្តិល្មើស នូវសិក្ខាបទទាំងឡាយ ដែលព្រះភគវតែទ្រង់ត្រាស់បញ្ញត្ត ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ និងដោយអំណាច នៃបាបធម៌ទាំងឡាយ មានជាអាទិ៍ យ៉ាងនេះ គឺ “ការកុហក ដោយឬក, ការលលោង ដោយវាចា, ភាពជាអ្នកប្រើកលឧបាយ ដោយកាយខ្លះ ដោយវាចាខ្លះ, ភាពជាអ្នកប្រើសំដីជាខ្នោសសំរាប់កោសយកលាភ, ភាពនៃការស្វែងរកលាភ ដោយយកលាភទៅទាក់លាភ” ដូច្នេះ, សីលនេះ ឈ្មោះថា អាជីវបារិសុទ្ធិសីល ។

(បច្ចយសន្និស្សិតសីល)

ការប្រើប្រាស់បច្ច័យ ៤ បរិសុទ្ធ ដោយការពិចារណា ដែលព្រះភគវតែទ្រង់ត្រាស់ ដោយន័យជាដើមថា “ភិក្ខុ ពិចារណា ដោយឧបាយហើយ ទើបប្រើប្រាស់នូវចីវរ ថា គ្រាន់តែដើម្បីការពារត្រជាក់” ដូច្នេះ, សីលនេះ ឈ្មោះថា បច្ចយសន្និស្សិតសីល ។

នេះជាកថាគ្រឿងវិនិច្ឆ័យ ក្នុងសីលទាំងនោះ ព្រមជាមួយនឹងសេចក្តីពណ៌នា តាមលំដាប់បទ ចាប់តាំងអំពីដើមមក ។

បទថា “ឥធ” គឺ ក្នុងសាសនានេះ ។ បទថា “ភិក្ខុ” បានដល់

១- សុ. ម. មូ. ភាគទី ២២ ទំព័រទី ១៨៩ ។



កុលបុត្រដែលបួសដោយសទ្ធា មានរំពាហារគឺខ្លួនបានហើយ យ៉ាងដូច្នេះ ព្រោះភាវៈគឺខ្លួនឃើញភ័យ ក្នុងសង្សារផង ព្រោះជាអ្នកទ្រទ្រង់នូវផ្ទាំងសំពត់ដែលបុគ្គលកាត់ដាច់ហើយផង ។

(១៤) ក្នុងបទថា “បាតិមោក្ខសំវរសំវុតោ” នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ។ សីល ដែលជាសិក្ខាបទ ឈ្មោះថា បាតិមោក្ខ ។ ព្រោះភិក្ខុណា ថែទាំ គឺ រក្សា នូវបាតិមោក្ខសីលនោះ, បាតិមោក្ខសីលនោះញុំាងភិក្ខុនោះ ឲ្យរួចផុត គឺថា ឲ្យរួចរដោះចាកទុក្ខទាំងឡាយ មានទុក្ខក្នុងអបាយជាដើម ព្រោះហេតុនោះ ទើបព្រះភគវតែ ទ្រង់ត្រាស់ហៅថា “បាតិមោក្ខ” ។ ការរាំងប្រយ័ត្ន ឈ្មោះថា ការសង្រួម ។ ពាក្យថា ការសង្រួមនេះ ជាឈ្មោះ នៃការមិនប្រព្រឹត្តិល្មើស ដែលប្រព្រឹត្តទៅក្នុងផ្លូវកាយ និង ផ្លូវវាចា ។ ការសង្រួម គឺបាតិមោក្ខហ្នឹងឯង ឈ្មោះថា បាតិមោក្ខសំវរៈ ។ អធិប្បាយថាៈ ភិក្ខុ សង្រួមហើយ គឺចូលដល់ហើយ ប្រកបព្រមហើយ ដោយគ្រឿងសង្រួម គឺបាតិមោក្ខនោះ ឈ្មោះថា ជាអ្នកសង្រួមហើយ ដោយបាតិមោក្ខសំវរៈ ។ បទថា “វិហរតិ” បានដល់ញុំាងឥរិយាបថ ឲ្យប្រព្រឹត្តទៅ ។

(អាចារៈ និង អនាចារៈ)

សេចក្តីអធិប្បាយ នៃបទទាំងឡាយ មានបទថា “អាចារគោចរ-សម្បន្នោ” ដូច្នេះជាដើម បណ្ឌិត គប្បីជ្រាប តាមន័យដែលមកហើយក្នុងបាលីឯណោះ ។ មែនពិត ពាក្យនេះ ព្រះអដ្ឋកថាចារ្យ ពោលថា : ត្រង់បទថា “អាចារគោចរសម្បន្នោ” មាននិទ្ទេសថា មារយាទ ក៏មាន, ឥតមារយាទ ក៏មាន ។ បណ្តាអាចារៈ និង អនាចារៈ ទាំង ២ យ៉ាងនោះ អនាចារៈ តើដូចម្តេច? ។ ការប្រព្រឹត្តិកន្លង តាមផ្លូវកាយ ការ

ប្រព្រឹត្តិកន្លង តាមផ្លូវវាចា ការប្រព្រឹត្តិកន្លង តាមផ្លូវកាយ និង ការប្រព្រឹត្តិកន្លង តាមផ្លូវវាចា, ការប្រព្រឹត្តិកន្លងនេះ ព្រះភគវតទ្រង់ត្រាស់ហៅថា អនាចារៈ ។ ភាពនៃភិក្ខុជាអ្នកទ្រុស្តសីលទាំងអស់ ឈ្មោះថា អនាចារៈ, ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ចិញ្ចឹមជីវិតដោយការឲ្យឫស្សីខ្លះ ដោយការឲ្យស្លឹកឈើខ្លះ ដោយការឲ្យផ្កាឈើ, ផ្លែឈើ, លំអិតសំរាប់ងូត និង ឈើស្ទន់ខ្លះ ដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួនខ្លះ ដោយភាពជាអ្នកពោល នូវពាក្យឡេះឡោះ (ពិតខ្លះ មិនពិតខ្លះ) ដូចជាសម្លសណ្ដែកបាយខ្លះ ដោយភាពជាអ្នកបី-ព នូវទារកនៃគ្រហស្ថខ្លះ ដោយធ្វើជាជើងសាសន៍ (នាំដំណឹងឲ្យគ្រហស្ថ) ខ្លះ ឬក៏ ដោយការចិញ្ចឹមជីវិតខុស ឯណាមួយ ក្រៅអំពីនេះ ដែលព្រះពុទ្ធទ្រង់តិះដៀលហើយ, ការចិញ្ចឹមជីវិតនេះ ព្រះភគវត ទ្រង់ត្រាស់ហៅថា អនាចារៈ ។

បណ្ដាអាចារៈ និង អនាចារៈ ទាំង ២ នោះ អាចារៈ តើដូចម្ដេច?, ការមិនប្រព្រឹត្តិកន្លង តាមផ្លូវកាយ ការមិនប្រព្រឹត្តិកន្លង តាមផ្លូវវាចា, ការមិនប្រព្រឹត្តិកន្លងតាមផ្លូវកាយ និង កិរិយាមិនប្រព្រឹត្តិកន្លង តាមផ្លូវវាចា, ការមិនប្រព្រឹត្តិកន្លងនេះ ព្រះភគវតទ្រង់ត្រាស់ហៅថា អាចារៈ ។ ការសង្រួម ក្នុងសីលទាំងអស់ ឈ្មោះថា អាចារៈ, ភិក្ខុពួកខ្លះ ក្នុងសាសនានេះ មិនចិញ្ចឹមជីវិត ដោយការឲ្យឫស្សីខ្លះ មិនចិញ្ចឹមជីវិត ដោយការឲ្យស្លឹកឈើខ្លះ មិនចិញ្ចឹមជីវិត ដោយការឲ្យផ្កាឈើ, ផ្លែឈើ, លំអិតសំរាប់ងូត និង ឈើស្ទន់ខ្លះ មិនចិញ្ចឹមជីវិត ដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួនខ្លះ មិនចិញ្ចឹមជីវិត ដោយភាពជាអ្នកពោលនូវពាក្យឡេះឡោះ (ពិតខ្លះមិនពិតខ្លះ) ដូចជាសម្លសណ្ដែកបាយខ្លះ មិនចិញ្ចឹមជីវិត ដោយភាពជាអ្នកបី-ព ទារកនៃគ្រហស្ថខ្លះ មិនចិញ្ចឹមជីវិត



ដោយធ្វើជាជើងសាសន៍ (នាំដំណឹងឲ្យគ្រហស្ថ)ខ្លះ ឬក៏ មិនចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតខុស ឯណាមួយ ក្រៅអំពីនេះ ដែលព្រះពុទ្ធ ទ្រង់តិះដៀល, ការចិញ្ចឹមជីវិតបែបនេះ ហៅថា អាចារៈ ។

(គោចរ និង អគោចរ)

បទថា "គោចរោ" គឺគោចរ មាន អគោចរ មាន, បណ្ដាគោចរ និង អគោចរទាំង ២ នោះ អគោចរ តើដូចម្ដេច? ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកត្រាច់ទៅ ក្នុងទីជាទីនៅនៃស្រីពេស្យា ឬ ឬថា ជាអ្នកត្រាច់ទៅ ក្នុងទីជាទីនៅនៃស្រីមេម៉ាយ, ស្រីក្រមុំចាស់, បណ្ឌក (គឺមនុស្សខ្ទើយ) នាងភិក្ខុនី និង រោងសុរា ជាអ្នកនៅប្រឡូកប្រឡល់ ដោយពួកស្ដេច ពួកមហាមាត្យនៃស្ដេច ពួកតិរ្ថិយ ពួកសាវ័កនៃតិរ្ថិយ ជាអ្នកនៅ ដោយការប្រឡូកប្រឡល់ ជាមួយគ្រហស្ថ ដែលមិនប្រកបដោយការសមគួរ, មួយទៀត ភិក្ខុគប់រាប់រក ចូលទៅអង្គុយជិតនឹងត្រកូលទាំងឡាយ ដែលមិនមានសទ្ធា មិនជ្រះថ្លា ជាអ្នកជេរប្រទេច មិនប្រាថ្នាសេចក្ដីចម្រើន មិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាសេចក្ដីសប្បាយ មិនប្រាថ្នាសេចក្ដីក្សេមចាកយោគៈដល់ពួកភិក្ខុ, ភិក្ខុនី, ឧបាសក,ឧបាសិកា, ការប្រព្រឹត្តិរបស់ភិក្ខុ ដូចបានរៀបរាប់មកនេះ ព្រះភគវតត្រាស់ហៅថា អគោចរ ។

បណ្ដាគោចរ និង អគោចរទាំង ២ នោះ គោចរ តើដូចម្ដេច? ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកមិនត្រាច់ទៅ ក្នុងទីជាទីនៅ នៃស្រីពេស្យា ។លៗ ជាអ្នកមិនត្រាច់ទៅ ក្នុងរោងផឹកសុរា មិននៅប្រឡូកប្រឡល់ ដោយពួកស្ដេច ។លៗ ដោយសាវ័កនៃតិរ្ថិយ ។លៗ ជាអ្នកមិននៅប្រឡូកប្រឡល់ ដោយគ្រហស្ថដែលមិនប្រកប ដោយសេចក្ដីសម

គួរ, មួយទៀត ភិក្ខុសេពគប់ រាប់រក ចូលទៅអង្គុយជិតនឹងត្រកូលទាំងឡាយ ដែលមានសទ្ធាជ្រះថ្លា ដូចជាអណ្តូងទឹក រុងរឿង ដោយសំពត់កាសាវៈ ផ្សព្វផ្សាយ ដោយក្លិនខ្យល់នៃចីវរ របស់ឥសី គឺ ភិក្ខុ និង ភិក្ខុនី ជាអ្នកប្រាថ្នាប្រយោជន៍ ។ល។ ជាអ្នកប្រាថ្នាធម៌ជាគ្រឿងក្សេមចាកយោគៈ ដល់ពួកភិក្ខុ, ភិក្ខុនី, ឧបាសក, ឧបាសិកា, ការប្រព្រឹត្តិរបស់ភិក្ខុនេះ ព្រះភគវតែត្រាស់ហៅថា គោចរ ។ ភិក្ខុណា ជាអ្នកចូលដល់ហើយ ចូលដល់ព្រមហើយ ជាអ្នកចូលទៅជិត ចូលទៅជិតព្រមហើយ ជាអ្នកចូលមកដល់ហើយ ជាអ្នកចូលមកដល់ព្រមហើយ ជាអ្នកប្រកបព្រមហើយ ដោយអាចារៈនេះផង ដោយគោចរៈនេះផង ដោយប្រការដូច្នេះ, ព្រោះហេតុនោះ ភិក្ខុនោះ ព្រះភគវតែត្រាស់ហៅថា "អ្នកប្រកបព្រមហើយ ដោយអាចារៈ និង គោចរៈ" ដូច្នេះ ។

ន័យមួយទៀត បណ្ឌិត គប្បីជ្រាបអាចារៈ និង គោចរៈ តាមន័យនេះ ក្នុងបាតិមោក្ខសីលនិទ្ទេសនេះចុះ ។

(១៥) ក៏អនាចារ មាន ២ យ៉ាង គឺ អនាចារ ប្រព្រឹត្តទៅ តាមផ្លូវកាយ ១ ប្រព្រឹត្តទៅតាមផ្លូវវាចា ១ ។ បណ្តាអនាចារទាំង ២ យ៉ាងនោះ អនាចារ ដែលប្រព្រឹត្តទៅតាមផ្លូវកាយ តើដូចម្តេច? ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ សូម្បីនៅក្នុងទីប្រជុំសង្ឃ ក៏មិនធ្វើសេចក្តីគោរពកោតក្រែង ឈរប្រគៀកប្រគងពួកភិក្ខុចាស់ខ្លះ អង្គុយប្រគៀកប្រគងនឹងពួកភិក្ខុចាស់ខ្លះ, ឈរនៅពីមុខពួកភិក្ខុចាស់ខ្លះ, អង្គុយចំពីមុខពួកភិក្ខុចាស់ខ្លះ, អង្គុយលើអាសនៈខ្ពស់ខ្លះ, អង្គុយទទូរក្បាលខ្លះ, ឈរនិយាយខ្លះ, និយាយវាសដើមដៃខ្លះ, កាលពួកភិក្ខុចាស់ មិនពាក់ស្បែកជើងដើរចង្ក្រម, ខ្លួនក៏ពាក់ស្បែកជើងដើរចង្ក្រម, កាលពួកភិក្ខុចាស់ដើរ



ចង្ក្រមលើទីចង្ក្រមទាប, ខ្លួនចង្ក្រមលើទីចង្ក្រមខ្ពស់, កាលពួកភិក្ខុចាស់ចង្ក្រមលើផែនដី, ខ្លួនចង្ក្រមលើទីចង្ក្រម, ឈរជ្រៀតជ្រែកពួកភិក្ខុចាស់ខ្លះ, អង្គុយជ្រៀតជ្រែកពួកភិក្ខុចាស់ខ្លះ, ហាមពួកភិក្ខុថ្មី ដោយអាសនៈខ្លះ, ដាក់ឧសទៅក្នុងរោងភ្លើង បិទទ្វារ មិនប្រាប់ពួកភិក្ខុចាស់ខ្លះ, ចុះទៅក្នុងកំពង់ទឹក ជ្រៀតជ្រែកពួកភិក្ខុចាស់ខ្លះ, ចុះទៅមុនពួកភិក្ខុចាស់ខ្លះ, ងូតប្រជ្រៀតខ្លះ, ងូតមុនខ្លះ, ឡើងប្រជ្រៀតខ្លះ, ឡើងមុនខ្លះ, ចូលទៅកាន់ចន្លោះផ្ទះ ដើរបៀតប្រជ្រៀតពួកភិក្ខុចាស់ខ្លះ, ដើរខាងមុខខ្លះ, ដើរជៀសទៅខាងមុខ ៗ ពួកភិក្ខុចាស់ខ្លះ, បន្ទប់ទាំងឡាយ របស់ពួកត្រកូលដែលគេលាក់លៀម និង បិទបាំង ដែលជាទីដែលពួកស្ត្រី ក្នុងត្រកូល ពួកកុមារីក្នុងត្រកូលអង្គុយ ក៏ចូលទៅ ក្នុងបន្ទប់នោះ ដោយរហ័ស ប្រមអង្អែលក្បាលក្មេងតូចខ្លះ, អាកប្បកិរិយាបែបនេះ ព្រះភគវតែត្រាស់ហៅថា អនាចារ ប្រព្រឹត្តទៅតាមផ្លូវកាយ ។

បណ្តាអនាចារ ទាំង ២ យ៉ាងនោះ អនាចារ ប្រព្រឹត្តទៅ ក្នុងផ្លូវវាចា តើដូចម្តេច? ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ សូម្បីចូលទៅហើយក្នុងទីប្រជុំសង្ឃ ក៏មិនធ្វើសេចក្តីគោរពកោតក្រែង និយាយធម៌ ដោះស្រាយបញ្ហា សម្តែងបាតិមោក្ខ មិនប្រាប់ពួកភិក្ខុចាស់ខ្លះ, ឈរនិយាយខ្លះ, និយាយវាសដៃខ្លះ, សូម្បីចូលទៅកាន់ចន្លោះផ្ទះ ពោលចចាកអាវកនឹងស្ត្រី ឬ កុមារី យ៉ាងនេះថា "នែស្ត្រីមានឈ្មោះយ៉ាងនេះ នែកុមារីមានគោត្រយ៉ាងនេះ បបរមានឬទេ? បាយមានឬទេ? ខាទនីយៈមានឬទេ? យើងនឹងផឹកអ្វី? នឹងទំពាអ្វី? នឹងឆាន់អ្វី? ឬថា ពួកនាងនឹងឲ្យអ្វីដល់អាត្មា?" ដូច្នេះ, វាចាបែបនេះ ព្រះភគវតែ ត្រាស់ហៅថា អនាចារ ប្រព្រឹត្តទៅតាមផ្លូវវាចា ។ ចំណែកអាចារៈ បណ្ឌិតគប្បីជ្រាប

ដោយអំណាចបដិបក្ខន័យ នៃអនាចារនោះចុះ ។

ន័យមួយវិញទៀត ភិក្ខុ មានសេចក្ដីគោរព មានសេចក្ដីកោតក្រែង បរិបូណ៌ដោយហិរិ និង ឱត្តប្បៈ ស្លៀកល្អត្រឹមត្រូវ ឃ្លុំល្អត្រឹមត្រូវ មានកិរិយាឈានទៅមុខ មានកិរិយាឈានថយក្រោយ មានការសម្លឹងមើល មានកិរិយាមើលជុំវិញ មានកិរិយាបត់អង្គុញ លាតសណ្ដូក ប្រកបដោយសេចក្ដីជ្រះថ្លា មានចក្ខុសំឡឹងចុះក្រោម បរិបូណ៌ដោយឥរិយាបថ មានទ្វារគ្រប់គ្រងហើយ ក្នុងឥរិយាបថទាំងឡាយ ស្គាល់ប្រមាណ ក្នុងភោជន ប្រកបរឿយៗ ក្នុងកិរិយាភ្ញាក់រឭក បរិបូណ៌ដោយសតិ និង សម្បជញ្ញៈ មានសេចក្ដីប្រាថ្នាតិច, សន្ដោស មិនប្រឡូកប្រឡល់ មានសេចក្ដីព្យាយាមប្រារព្ធហើយ ធ្វើសេចក្ដីគោរព ក្នុងអភិសមាចារិកវត្ត ទាំងឡាយ ជាអ្នកច្រើនទៅដោយសេចក្ដីគោរព និង សេចក្ដីកោតក្រែង, កិរិយាប្រព្រឹត្តិបែបនេះ ព្រះភគវតទ្រង់ហៅថា អាចារៈ ។ បណ្ឌិត គប្បីជ្រាបអាចារៈ យ៉ាងនេះមុន ។

(គោចរ ៣ យ៉ាង)

ចំណែក គោចរ វិញ មាន ៣ ប្រការ គឺ ឧបនិស្សយគោចរ ១, អារក្ខគោចរ ១, ឧបនិពន្ធគោចរ ១ ។ បណ្ដាគោចរទាំង ៣ នោះ ឧបនិស្សយគោចរតើដូចម្ដេច? កល្យាណមិត្រជាអ្នកប្រកបព្រមហើយ ដោយគុណ គឺកថាវត្ថុ ១០ យ៉ាង, ភិក្ខុ ស្ដាប់នូវសូត្រ ដែលខ្លួនមិនទាន់បានស្ដាប់ហើយ ព្រោះអាស្រ័យកល្យាណមិត្រណា ញុំាងសូត្រដែលខ្លួនបានស្ដាប់ហើយ ឲ្យផូរផង់ បន្ទោបង់សេចក្ដីសង្ស័យ ធ្វើទិដ្ឋិឲ្យត្រង់ ញុំាងចិត្តឲ្យជ្រះថ្លា ឬ កាលសិក្សាតាមកល្យាណមិត្រណា តែងចំរើន ដោយសទ្ធា ចម្រើនដោយសីល, ដោយសុតៈ, ដោយចាគៈ,



ដោយបញ្ញា, គោចរ គឺកល្យាណមិត្រនេះ ព្រះភគវត ត្រាស់ហៅថា ឧបនិស្សយគោចរ ។

អារក្ខគោចរ តើដូចម្ដេច?, ភិក្ខុ ក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះ ដើរទៅកាន់វិថី មានចក្ខុឱនចុះក្រោម មានប្រក្រតីមើលត្រឹមតែមួយជួរនឹម សង្រួមដើរទៅ មិនរមិលមើលដំរី មិនរមិលមើលសេះ មិនរមិលមើលរថ មិនរមិលមើលអ្នកថ្មើរជើង មិនរមិលមើលស្ត្រី មិនរមិលមើលបុរស មិនរមិលមើលខាងលើ មិនរមិលមើលខាងក្រោម ទាំងមិនរមិលមើលទិសធំ និង ទិសតូច ដើរទៅ, គោចរនេះ ព្រះភគវត ត្រាស់ហៅថា អារក្ខគោចរ ។

ឧបនិពន្ធគោចរ តើដូចម្ដេច? ភិក្ខុ ចូលទៅចងក្រៀកចិត្តទុក ក្នុងធម៌ទាំងឡាយណា, ធម៌ទាំងឡាយនោះ គឺ សតិបដ្ឋាន ៤, ពាក្យនេះ សមដូចព្រះភគវតត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចុះអ្វីទៅ? ជាគោចររបស់ភិក្ខុ, គឺធម៌ដែលជាវិស័យ របស់បិតានៃខ្លួន, ធម៌នេះ គឺអ្វី? គឺ សតិបដ្ឋាន ៤ [១] " ដូច្នេះ, គោចរនេះ ព្រះភគវត ទ្រង់ត្រាស់ហៅថា ឧបនិពន្ធគោចរ ។

ភិក្ខុប្រកបហើយ ប្រកបព្រមហើយ ដោយអាចារៈនេះផង ដោយគោចរនេះផង យ៉ាងដូច្នេះឯង ព្រោះហេតុនោះ ទើបព្រះភគវត ត្រាស់ហៅថា "អ្នកបរិបូណ៌ដោយអាចារៈ និង គោចរៈ" ។

(១៦) បទថា "អណុមត្តេសុ វជ្ជេសុ ភយទស្សាវី" សេចក្ដីថា ភិក្ខុជាអ្នកមានប្រក្រតីឃើញភ័យ ក្នុងទោសទាំងឡាយមានប្រមាណតិចតួច ដែលផ្សេងគ្នា ដោយទោស មានជាអាទិ៍ គឺ សេក្ខិយវត្ត ដែលភិក្ខុ

១- សុ. សំ. មហាវារ. ភាគទី ៣៨ ទំព័រទី ១៨ ។

មិនក្លែងត្រូវហើយ និង ចិត្តុប្បាទ ដែលជាអកុសល ។ បទថា “សមាទាយ សិក្ខតិ សិក្ខាបទេសុ” សេចក្ដីថា សីលឯណាមួយ ដែលខ្លួនត្រូវសិក្សា ក្នុងសិក្ខាបទទាំងឡាយ, ភិក្ខុ សិក្សាកាន់យក នូវសីលទាំងអស់នោះ ដោយល្អប្រពៃ ។

ក៏ក្នុងអធិការ នៃបាតិមោក្ខសំវរសីលនេះ បណ្ឌិត គប្បីជ្រាប ថា “បាតិមោក្ខសំវរសីល ព្រះភគវតទ្រង់សម្ដែងហើយ ដោយទេសនា ជាបុគ្គលាទិដ្ឋាន ដោយហេតុមានប្រមាណប៉ុណ្ណោះ ថា “អ្នកសង្រួមហើយដោយគ្រឿងសង្រួម គឺបាតិមោក្ខ” ដូច្នេះ, ចំណែកខាង ពាក្យថា “អ្នកដល់ព្រមហើយដោយអាចារៈ និង គោចរៈ” ដូច្នេះជាដើម គឺព្រះភគវតទ្រង់ត្រាស់ហើយ ដើម្បីសម្ដែងនូវសេចក្ដីប្រតិបត្តិ ដែលជាផ្លូវបានសម្រេចនៃសីលទាំងពួងនោះ ដល់បុគ្គលអ្នកប្រតិបត្តិ ។

(ឥន្ទ្រិយសំវរសីល)

(១៧) ចំណែកឯ ឥន្ទ្រិយសំវរសីលនេះឯណា ដែលព្រះភគវតត្រាស់សម្ដែងហើយ បន្តបន្ទាប់អំពីបាតិមោក្ខសំវរសីលនោះ ដោយន័យថា “ភិក្ខុនោះ ឃើញរូប ដោយចក្ខុ” ដូច្នេះជាដើម, បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងឥន្ទ្រិយសំវរសីលនោះ ដូចតទៅនេះ ។

បទថា “ភិក្ខុនោះ” បានដល់ភិក្ខុអ្នកឋិតនៅហើយ ក្នុងបាតិមោក្ខ-សំវរសីលនោះ ។ ពាក្យថា “ឃើញរូបដោយចក្ខុ” សេចក្ដីថា ឃើញរូបដោយចក្ខុវិញ្ញាណ ដែលអាចឃើញរូប ព្រោះបានវោហារថា “ចក្ខុ” ដោយអំណាចនៃហេតុ ។ មែនពិត បុរាណាចារ្យ ពោលថា “ចក្ខុ មិនឃើញរូប ព្រោះចក្ខុមិនមានចិត្ត, ឯចិត្ត ក៏មិនឃើញរូប ព្រោះចិត្តមិនមានចក្ខុ, តែកាលបើទ្វារ និង អារម្មណ៍មកផ្ទប់គ្នា, បុគ្គល រមែងឃើញ



រូបដោយចិត្ត ដែលមានចក្ខុបសាទជាទីតាំង, ចំណែកការពោលបែបនេះនុ៎ះ ឈ្មោះថា ការពោលប្រកបដោយសម្ភារៈ ដូចជាក្នុងប្រយោគទាំងឡាយថា បុគ្គលបាញ់(ម្រឹគ)ដោយធ្នូ ដូច្នេះជាដើម ។ ព្រោះហេតុនោះ ពាក្យថា “ឃើញរូបដោយចក្ខុវិញ្ញាណ” នេះនុ៎ះ ជាសេចក្ដីក្នុងពាក្យថា “ឃើញរូប ដោយចក្ខុ” នោះ ។

បទថា “ន និមិត្តគ្គាហី” សេចក្ដីថា ភិក្ខុ មិនកាន់យកនូវនិមិត្តក្នុងស្ត្រី និង បុរស ឬថា និមិត្តដែលជាទីតាំងនៃកិលេស មានសុភនិមិត្តជាដើម ឋិតនៅក្នុងនិមិត្តត្រឹមតែខ្លួនឃើញប៉ុណ្ណោះឯង ។

បទថា “នានុព្យញ្ជនគ្គាហី” សេចក្ដីថា មិនកាន់យកនូវអាការៈផ្សេងដោយអាការៈ មានដៃ, ជើង, ក្បាល, សំណើច, ពាក្យដែលបុរស និង ស្ត្រីពោលចរចាគ្នាទៅវិញទៅមក និង ការក្រឡេកមើលជាដើម ដែលបានវោហារថា “អនុព្យញ្ជនៈ” ព្រោះជាអនុព្យញ្ជនៈ គឺព្រោះជាគ្រឿងធ្វើសេចក្ដីប្រាកដ នៃកិលេសទាំងឡាយ, អាការៈឯណាប្រាកដច្បាស់ ក្នុងសរីរៈនោះ, ក៏កាន់យកនូវអាការៈ មានសក់ជាដើមនោះ (ជាអារម្មណ៍) ដូចព្រះមហាតិស្សត្ថេរ អ្នកនៅក្នុងចេតិយបព៌ត ។

បានឮមកថា កូនប្រសាស្រីនៃត្រកូលម្នាក់ បានឈ្លោះទាស់ទែងជាមួយស្វាមីហើយ ស្អិតស្អាងដោយគ្រឿងប្រដាប់ដ៏ល្អ ដូចជានាងទេវកញ្ញា ចេញពីអនុរាធបុរី តាំងពីព្រឹកព្រហាម ដើរទៅកាន់ផ្ទះនៃញាតិ ក៏បានឃើញព្រះមហាតិស្សត្ថេរនោះ កំពុងនិមន្តមកពីចេតិយបព៌ត (ទៅ) កាន់អនុរាធបុរី ដើម្បីបិណ្ឌបាត ត្រង់ចន្លោះផ្លូវ ជាស្រីមានចិត្ត វាយមាយហើយ សើចយ៉ាងខ្លាំង ។ ឯព្រះថេរៈ ក្រឡេកមើលដោយគិតថា “នេះជាអ្វី?” ក៏បាននូវអសុភសញ្ញា ត្រង់ឆ្អឹងធ្មេញនៃស្រីនោះ ហើយក៏

បានសំរេចអរហត្ត ។

ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលថា :

ព្រះថេរៈ ឃើញឆ្អឹងធ្មេញ របស់ស្ត្រីនោះហើយ ក៏រឭក
ឃើញនូវអសុភសញ្ញា ក្នុងកាលមុន, លោកឈរនៅ
ក្នុងទីនោះដដែល បានសម្រេចព្រះអរហត្តហើយ ។

ចំណែកស្វាមីនៃស្ត្រីនោះ កាលដើរតាមមក បានជួបប្រទះនឹងព្រះថេរៈ ក៏សួរថា "បពិត្រលោកម្ចាស់! តើលោកម្ចាស់ បានឃើញស្ត្រីដែរឬទេ?" ។ ព្រះថេរៈ ប្រាប់បុរសជាស្វាមី របស់ស្ត្រីនោះ ថា :

អាត្មា មិនដឹងច្បាស់ថា ស្ត្រី ឬ បុរសដែលដើរទៅ អំពី
ទីនេះទេ, តែថា រាងឆ្អឹងន៎ុះ កំពុងដើរនៅលើផ្លូវធំ ។

ក្នុងពាក្យថា "យត្វាធិករណមេនំ" ដូច្នេះជាដើម មានវិនិច្ឆ័យថា ធម៌ទាំងឡាយ មានអភិជ្ឈាជាដើមនោះ គប្បីជាប់តាម គឺដេញតាមបុគ្គលនោះ អ្នកមិនសង្រួមចក្ខុន្ទ្រីយ៍ គឺជាអ្នកមានចក្ខុទ្វារមិនបានបិទហើយ នៅដោយសន្ទុះទ្វារ គឺសតិ ព្រោះហេតុណា គឺព្រោះហេតុនៃការមិនសង្រួមចក្ខុន្ទ្រីយ៍ណា ។ បទថា "តស្ស សំវរាយ បដិបជ្ជតិ" សេចក្តីថា ភិក្ខុ ប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ការបិទ នូវចក្ខុន្ទ្រីយ៍នោះ ដោយសន្ទុះទ្វារគឺសតិ ។ ក៏ភិក្ខុ កាលប្រតិបត្តិ យ៉ាងដូច្នេះ ព្រះភគវតត្រាស់ថា "រក្សានូវចក្ខុន្ទ្រីយ៍ខ្លះ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រីយ៍ខ្លះ" ។

ក្នុងពាក្យថា "ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រីយ៍" នោះ បណ្ឌិតគប្បីជ្រាបថាសំវរៈក្តី អសំវរៈក្តី ក្នុងចក្ខុន្ទ្រីយ៍ មិនមាន ក៏ពិតមែនហើយ



ព្រោះសតិក្តី ព្រោះការភ្លេចភ្លាំងសតិក្តី មិនបានអាស្រ័យនូវចក្ខុបសាទកើតឡើងសោះឡើយ, មួយវិញទៀត រូបារម្មណ៍ មកកាន់វង្វង់នៃចក្ខុក្នុងពេលណា, ក្នុងពេលនោះ កាលបើភវង្គកើតឡើង អស់វារៈ ២ ដងហើយ ក៏រលត់ទៅវិញ, មនោធាតុ ដែលជាកិរិយា ញុំាងអាវជ្ជនកិច្ច ឲ្យសម្រេចកើតឡើងហើយរលត់ទៅវិញ, តពីនោះមក ចក្ខុវិញ្ញាណ ញុំាងទស្សនកិច្ច ឲ្យសម្រេច កើតឡើងហើយ ក៏រលត់ទៅវិញ, តពីនោះមក មនោធាតុដែលជាវិបាកញុំាងសម្បដិច្ឆន្នកិច្ចឲ្យសម្រេច កើតឡើងហើយ ក៏រលត់ទៅវិញ, បន្ទាប់មក មនោវិញ្ញាណធាតុ ដែលជាអហេតុកវិបាក ញុំាងសន្តីរណកិច្ច ឲ្យសម្រេច កើតឡើងហើយ ក៏រលត់ទៅវិញ, បន្ទាប់មក មនោវិញ្ញាណធាតុ ដែលជាអហេតុកកិរិយា ញុំាងវោដ្ឋព្វនកិច្ច ឲ្យសម្រេច កើតឡើងហើយ រលត់ទៅវិញ, ក្នុងលំដាប់នោះ ជវនចិត្តរមែងស្ទុះទៅ ។ សំវរៈក្តី អសំវរៈក្តី សូម្បីក្នុងសម័យទាំងឡាយនោះ គឺ ក្នុងភវង្គសម័យ ក៏មិនមាន, បណ្តាសម័យនៃវិថីចិត្ត មានអាវជ្ជនចិត្តជាដើម សម័យណាមួយ ក៏មិនមានសោះឡើយ ។ តែថា ក្នុងខណៈនៃជវនចិត្ត បើភាពនៃបុគ្គលអ្នកទ្រុស្តសីលក្តី, ការភ្លេចភ្លាំងសតិក្តី, ការមិនដឹងក្តី, ការមិនអត់ធន់ក្តី, ការខ្ជិលច្រអូសក្តី កើតឡើង, ការមិនសង្រួម ទើបមាន ។ ក៏ការមិនសង្រួម ដែលមានយ៉ាងនេះនោះ ព្រះភគវតទ្រង់ត្រាស់ថា: "ការមិនសង្រួម ក្នុងចក្ខុន្ទ្រីយ៍" ។ ព្រោះហេតុអ្វី? ។ ព្រោះហេតុថា កាលបើការមិនសង្រួមនោះមាន, សូម្បីទ្វារក៏ជាទ្វារ គឺភិក្ខុ មិនបានគ្រប់គ្រងហើយ, ទាំងភវង្គ ទាំងវិថីចិត្ត មានអាវជ្ជនចិត្តជាដើម គឺភិក្ខុមិនបានគ្រប់គ្រងហើយដែរ ។ ប្រៀបដូចជាអ្វី? ។ ប្រៀបដូចជា កាលបើទ្វារទាំង ៤ ក្នុងក្រុងដែលគេមិនបានបិទ

ហើយ, គេហប្បទេសទាំងឡាយ មានខាងក្នុងផ្ទះ, ខ្លោងទ្វារ និង បន្ទប់ជាដើម ជាប្រទេស គឺគេបិទបាំងល្អហើយ ក៏ពិតមែន, បើទុកជាយ៉ាងនោះក៏ដោយ ទ្រព្យទាំងអស់ខាងក្នុងក្រុង ក៏ឈ្មោះថា គេមិនបានរក្សា មិនបានគ្រប់គ្រងហើយដដែល ព្រោះថា ពួកចោរចូលទៅតាមទ្វារក្រុងហើយ គប្បីធ្វើនូវអំពើ ដែលពួកវាប្រាថ្នានោះ យ៉ាងណាមិញ, កាលបើទោសទាំងឡាយ មានភាពនៃបុគ្គលទ្រុស្តសីលជាដើម កើតឡើងក្នុងជវនចិត្ត, កាលបើការមិនរវាំងប្រយ័ត្ននោះមាន, សូម្បីទ្វារក៏ជាទ្វារ គឺភិក្ខុ មិនបានគ្រប់គ្រងហើយ, ទាំងភវង្គ ទាំងវិថីចិត្ត មានអាវជ្ជនចិត្តជាដើម គឺ ភិក្ខុមិនបានគ្រប់គ្រងហើយ ក៏យ៉ាងនោះដែរ ។ តែថា កាលបើគុណទាំងឡាយ មានសីលជាដើម កើតឡើងហើយ ក្នុងជវនចិត្តនោះ, សូម្បីទ្វារ ក៏ជាទ្វារគឺភិក្ខុគ្រប់គ្រងហើយ ទាំងភវង្គ ទាំងវិថីចិត្ត មានអាវជ្ជនចិត្តជាដើម គឺភិក្ខុគ្រប់គ្រងហើយ ។ ប្រៀបដូចជាអ្វី? ។ ប្រៀបដូចជាកាលបើទ្វារក្រុងទាំងឡាយ គឺគេបិទបាំងល្អហើយ, ទីទាំងឡាយ មានខាងក្នុងផ្ទះជាដើម សូម្បីគេមិនបានបិទបាំងល្អហើយ ក៏ពិតមែន ទុកជាដូច្នោះក៏ដោយ ទ្រព្យទាំងអស់ក្នុងក្រុង ឈ្មោះថា គឺគេបានរក្សា បានគ្រប់គ្រងល្អហើយទាំងស្រុង, ព្រោះថា កាលបើទ្វារក្រុងទាំងឡាយ ដែលគេបានបិទហើយ, ពួកចោរក៏ចូលទៅមិនបានឡើយ យ៉ាងណាមិញ, កាលបើគុណទាំងឡាយមានសីលជាដើម កើតឡើងហើយ ក្នុងជវនចិត្ត, សូម្បីទ្វារ ក៏ជាទ្វារ គឺភិក្ខុគ្រប់គ្រងហើយ, ទាំងភវង្គ ទាំងវិថីចិត្ត មានអាវជ្ជនចិត្តជាដើម គឺភិក្ខុ គ្រប់គ្រងហើយ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ សំវរៈ សូម្បីកើតឡើង ក្នុងខណៈនៃជវនចិត្ត ព្រះភគវតែត្រាស់ថា "ការសង្រួម ក្នុងចក្ខុន្ទ្រីយ៍" ដូច្នេះ ។



ន័យសូម្បីក្នុងប្រយោគទាំងឡាយថា "ឮសំឡេងដោយត្រចៀក" ដូច្នេះជាដើម ក៏ន័យនេះដែរ ។ សីលនេះ បណ្ឌិតគប្បីជ្រាប ដោយសង្ខេបថា: ឈ្មោះថា ឥន្ទ្រិយសំវរសីល ដែលមានការវៀរបង់ នូវការកាន់យកនូវនិមិត្ត ដែលកិលេសជាប់តាមជាដើម ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម ជាលក្ខណៈ ដោយប្រការដូច្នេះឯង ។

## (អាជីវបារិសុទ្ធិសីល)

(១៨) ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាជីវបារិសុទ្ធិសីល ដែលបានពោលហើយ ក្នុងលំដាប់នៃឥន្ទ្រិយសំវរសីល ដូចតទៅ ។

ត្រង់ពាក្យថា "ភិក្ខុប្រព្រឹត្តកន្លងសិក្ខាបទទាំង ៦ ដែលព្រះភគវតែទ្រង់បញ្ញត្តហើយ ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ" សេចក្តីថា សិក្ខាបទទាំង៦ នោះឯណា ដែលព្រះភគវតែត្រាស់បញ្ញត្តយ៉ាងដូច្នេះថា "ភិក្ខុណាប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នា គ្របសង្កត់ហើយ ពោលអួតឧត្តរិមនុស្សធម៌ ដែលមិនមាន(ក្នុងខ្លួន)មិនពិត ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ, ភិក្ខុនោះ ត្រូវអាបត្តិបារាជិក, ភិក្ខុណា ដល់នូវភាពជាអ្នកត្រាច់ទៅ ក្នុងចន្លោះនៃស្ត្រី និង បុរស (គឺធ្វើជាមេអណ្តើកដឹកនាំឲ្យបុរស និង ស្ត្រីបានគ្នាជាប្តីប្រពន្ធ) ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ, ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស, ភិក្ខុណា ប្រាប់ឧត្តរិមនុស្សធម៌ ដល់បុគ្គលណាថា "ភិក្ខុណា នៅក្នុងវត្តរបស់អ្នក, ភិក្ខុនោះជាព្រះអរហន្ត" ដូច្នេះ ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ កាលបើបុគ្គលនោះជឿតាម, ភិក្ខុអ្នកប្រាប់នោះ ត្រូវអាបត្តិថុល្លច្ច័យ, ភិក្ខុណា មិនមានជម្ងឺ ញុំាងបុគ្គលឲ្យសូមភោជន ដ៏ប្រណីត ដើម្បីប្រយោជន៍ ដល់ខ្លួនហើយឆាន់ ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរ នៃ

អាជីវៈ, ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយៈ, ភិក្ខុនីណា មិនមានជម្ងឺ ញ៉ាំង បុគ្គល ឲ្យសូមភោជន ដ៏ប្រណីត ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ, ភិក្ខុនីនោះ ត្រូវអាបត្តិ-បាដិទេសនីយៈ, ភិក្ខុណា មិនមានជម្ងឺ ប្រើគេឲ្យសូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ, ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ" ដូច្នេះ, នេះជាកិរិយាវៀរចាក ការចិញ្ចឹមជីវិតខុស ដែលប្រព្រឹត្តទៅ ដោយអំណាចនៃសិក្ខាបទទាំង ៦ នេះ ។ ក្នុងពាក្យទាំងឡាយ មានពាក្យថា "កុហនា" ជាដើម មានបាលីដូចតទៅនេះ :

ក្នុងបាបធម៌ទាំងនោះ កុហនា តើដូចម្តេច? ។ ការតាំងប្រុងប្រៀប ការតាំង ការតាំងព្រមនូវឥរិយាបថឯណា ការស្រង្គូតស្រងាត់ ភាពនៃការស្រង្គូតស្រងាត់ ការបំភាន់ ការញ៉ាំងទាយកឲ្យភាន់កាំង ភាពនៃការធ្វើទាយកឲ្យភាន់កាំងណា ដោយវិធីកុហក ពោលគឺការសេពបច្ច័យក្តី ដោយកិរិយាខ្សឹបខ្សៀវ ក្នុងទីជិតក្តី របស់ភិក្ខុអ្នកអាស្រ័យនូវលាភ, សក្ការៈ និង កេរ្តិ៍ឈ្មោះ ជាអ្នកប្រាថ្នាដ៏លាមក ជាអ្នកត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ, នេះ លោកហៅថា កុហនា (ការកុហកដោយឫក) ។

បណ្តាបាបធម៌ទាំងនោះ លបនា តើដូចម្តេច? ។ ការបង្អោនចូលមកពោលចំពោះជនដទៃ, ការពោលរួសរាយ, ការពោលឲ្យគេទុកចិត្ត, ការពោលលើក, ការពោលលើកដោយចំណែកគ្រប់យ៉ាង, ការពោលចងជើងក្នុងខាងលើ,ការពោលចងជើងក្នុងខាងលើរឿយៗ, ការនិយាយបញ្ជោរ, ការនិយាយបញ្ជោររឿយៗ, ភាពនៃភិក្ខុ អ្នកមានការពោលចាក់បណ្តោយ, ភាពនៃភិក្ខុជាអ្នកប្រព្រឹត្តបន្ទាបខ្លួន, ភាពនៃភិក្ខុអ្នកមាន



វាចា ដូចជាសម្លស្ល៉ណ្តកបាយ, ភាពនៃភិក្ខុជាអ្នកបី-ព (ទារក) នៃគ្រហស្ថឯណា របស់ភិក្ខុអ្នកអាស្រ័យលាភ, សក្ការៈ និង កេរ្តិ៍ឈ្មោះ ជាអ្នកប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ, នេះ ហៅថា លបនា (ការកុហកដោយវាចា) ។

បណ្តាបាបធម៌ទាំងនោះ នេមិត្តិកតា តើដូចម្តេច? ។ កិរិយាសម្គាល់, អំពើនៃការសម្គាល់, ការពោលបញ្ចិតបញ្ចៀង, អំពើនៃការពោលបញ្ចិតបញ្ចៀង, ការខ្សឹបខ្សៀវ ក្នុងទីជិត, ការពោលជេញជើងណាៗ ចំពោះពួកជនដទៃ របស់ភិក្ខុអ្នកអាស្រ័យនូវលាភ, សក្ការៈ និង កេរ្តិ៍ឈ្មោះ ជាអ្នកប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ, នេះហៅថា នេមិត្តិកតា (ភាពជាអ្នកប្រើឧបាយកល ដោយកាយខ្លះ ដោយវាចាខ្លះ) ។

បណ្តាបាបធម៌ទាំងនោះ និប្បេសិកតា តើដូចម្តេច? ។ ការជេរប្រទេច, ការមើលងាយ, ការតិះដៀល, ការពោលលើក, ការពោលលើកសព្វគ្រប់, ការពោលចំអកឲ្យ, ការពោលចំអកឲ្យខ្លាំងៗ, ការញ៉ាំងទាយកឲ្យដល់, ការញ៉ាំងទាយកឲ្យដល់ព្រម, ការនាំមកនូវទោស, ភាពនៃការពោលពាក្យ ក្នុងទីកំបាំង ដូចជាការស៊ីសាច់ខ្នង របស់ជនដទៃណា ៗ ចំពោះពួកជនដទៃ នៃភិក្ខុអ្នកអាស្រ័យលាភ, សក្ការៈ និង កេរ្តិ៍ឈ្មោះ ជាអ្នកប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ, នេះហៅថា និប្បេសិកតា (ភាពជាអ្នកប្រើសំដីជាខ្នាស សម្រាប់កោសយកលាភ) ។

បណ្តាបាបធម៌ទាំងនោះ ភាពនៃការស្វែងរកលាភ ដោយលាភ តើដូចម្តេច? ។ ភិក្ខុជាអ្នកអាស្រ័យលាភ, សក្ការៈ និង កេរ្តិ៍ឈ្មោះ ជា

អ្នកមានសេចក្តីប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នាំយកអាមិសដែលខ្លួនបានហើយ អំពីផ្ទះនេះទៅក្នុងផ្ទះឯណោះ ឬ នាំយកអាមិសដែលខ្លួនបានហើយ អំពីផ្ទះឯណោះ ទៅក្នុងផ្ទះនេះ, ការស្វែងគឺការស្វែងរក, ការស្វែងរករឿយៗ, ការស្វែងស្វះ, ការស្វះស្វែងនូវអាមិស ដោយអាមិសបែបនេះណាៗ, ការស្វែងរកនេះ លោកហៅថាភាពនៃការស្វែងរកលាភ ដោយលាភ [១] ។

ក៏បណ្ឌិតគប្បីជ្រាបសេចក្តីនៃបាលីនេះ ដូចតទៅនេះ

(កុហនានិទ្ទេស)

(១៩) គប្បីជ្រាបវិនិច្ឆ័យ ក្នុងកុហនានិទ្ទេស ជាមុនសិន ។ បទថា “លាភសក្ការសិលោកសន្និស្សិតស្ស” សេចក្តីថា អ្នកប្រាថ្នា គឺត្រូវការលាភផង សក្ការៈផង កេរ្តិ៍ឈ្មោះផង ។ បទថា “បាបិច្ឆស្ស” គឺជាអ្នកប្រាថ្នាសម្តែងគុណដែលមិនមាន ។ បទថា “ឥច្ឆាបកតស្ស” គឺ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ, អធិប្បាយថា: ត្រូវសេចក្តីប្រទូស្តបៀតបៀនហើយ ។ កុហនវត្ថុ ៣ យ៉ាង មកហើយ ក្នុងមហានិទ្ទេស ដោយអំណាចការសេពនូវបច្ច័យ, ការខ្សឹបខ្សៀវ ក្នុងទីជិត និង អាស្រ័យឥរិយាបថ ព្រោះហេតុណា, ព្រោះហេតុនោះ ដើម្បីសម្តែងនូវកុហនវត្ថុ ៣ យ៉ាងនោះ បន្ទាប់អំពីនេះមក ទើបលោកប្រារព្ធពាក្យមានជាអាទិ៍ ថា “បច្ចយប្បដិសេវនសង្ខាតេន” ដូច្នេះ ។

បណ្តាកុហនវត្ថុទាំង ៣ យ៉ាងនោះ ការញុំាងទាយក ឲ្យជាប់ចិត្តដោយការ- កាលបើទាយកនិមន្តហើយ ដោយបច្ច័យទាំងឡាយ មានចីវរបច្ច័យជាដើម (ខ្លួន) ជាអ្នកត្រូវការ ដោយបច្ច័យនោះ ពិតៗ ប៉ុន្តែ

១- អភិ. វិ. ភាគទី ៨២ ទំព័រទី ១៥៩ ។



ត្រឡប់ជាប្រកែកទៅវិញ ព្រោះអាស្រ័យនូវភាវៈនៃខ្លួន ជាអ្នកប្រាថ្នាលាមកផង ដោយការដឹងនូវពួកគហបតីទាំងនោះ ជាអ្នកមានសទ្ធា តាំងនៅស៊ប់ល្អ ចំពោះខ្លួនហើយ កាលបើពួកគហបតីទាំងនោះ ពោលទទូចថា “លោកម្ចាស់ ជាអ្នកប្រាថ្នាតិចអ្វីម៉្លេះទេ មិនត្រូវការទទួលអ្វីៗ សោះឡើយ, បុណ្យគឺពួកយើងបាន ដោយងាយណាស់ហ្ន៎ គប្បីមានដល់ពួកយើង បើលោកម្ចាស់នេះទទួលវត្ថុអ្វីៗ សូម្បីបន្តិចបន្តួច” ដូច្នេះហើយ ក៏បង្អោនចូលទៅ នូវបច្ច័យទាំងឡាយ មានចីវរជាដើម ដ៏ប្រណីតៗ ដោយឧបាយវិធីផ្សេងៗ ទៀត (ភិក្ខុនោះ) ធ្វើឲ្យប្រាកដនូវភាពដូចជាចង់ឲ្យទាយក អនុគ្រោះខ្លួនគេតែប៉ុណ្ណោះហើយ ទទួលផង ជាហេតុបង្អោនចូលមក (នូវបច្ច័យ) ដោយផ្ទុកទាំងរទេះៗ ចាប់ផ្តើមតាំងពីការប្រកែកនោះមក បណ្ឌិត គប្បីជ្រាប ថា “ជារឿងកុហក ពោលគឺការសេព នូវបច្ច័យ” ។

ដូចជាលោកពោលហើយ ក្នុងមហានិទ្ទេសថា “កុហនវត្ថុ ពោលគឺការសេពបច្ច័យ តើដូចម្តេច? ។ គហបតីទាំងឡាយ ក្នុងលោកនេះនិមន្តភិក្ខុ ដោយចីវរ, បិណ្ឌបាត, សេនាសនៈ, គិលានភេសជ្ជបច្ច័យ និង បរិក្ខារទាំងឡាយ, ភិក្ខុនោះ [១] ជាអ្នកប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ ជាអ្នកមានសេចក្តីត្រូវការដោយចីវរ ។ល។ ប្រកែកបដិសេធ នូវចីវរ ប្រកែកបដិសេធ នូវបិណ្ឌបាត, សេនាសនៈ, គិលានភេសជ្ជបច្ច័យ និង បរិក្ខារទាំងឡាយ ព្រោះអាស្រ័យភាពនៃសេចក្តីចង់បាននូវចីវរ, បិណ្ឌបាត, សេនាសនៈ, គិលានភេសជ្ជបច្ច័យ និង បរិក្ខារទាំងឡាយ ឲ្យបានរឹតតែច្រើនឡើងៗ, ភិក្ខុនោះ ពោល

១- សុ. ខុ. ម. ភាគទី ៦៦ ទំព័រទី ២៨៩ ។

យ៉ាងនេះថា “នឹងមានប្រយោជន៍អ្វី ដោយចីវរ ដែលមានតម្លៃច្រើន ដល់សមណៈ, សមណៈ គប្បីជ្រើសរើសយកនូវសំពត់ដែលគេចោល ហើយ អំពីព្រៃស្មសានក្តី អំពីគំនរសម្រាមក្តី អំពីរានផ្សារក្តី ហើយធ្វើជាសង្ឃាដីទ្រទ្រង់(គ្រង) ព្រោះហេតុណា, ព្រោះហេតុនោះ ជាការសមគួរ, ប្រយោជន៍អ្វី ដោយបិណ្ឌបាតដែលមានតម្លៃច្រើន ដល់សមណៈ, សមណៈ គប្បីចិញ្ចឹមជីវិត ដោយពំនូតបាយដែលខ្លួនបានមក ដោយការស្វែងរក ដោយហេតុណា, ហេតុនោះ ជាការសមគួរ, ប្រយោជន៍អ្វី ដោយសេនាសនៈ ដែលមានតម្លៃច្រើន ដល់សមណៈ, សមណៈ គប្បីជាអ្នកនៅទៀបគល់ឈើ ឬ នៅក្នុងទីវាល ហេតុណា, ហេតុនោះ ជាការគួរ, ប្រយោជន៍អ្វី ដោយគិលានបច្ច័យ និង ភេសជ្ជបរិក្ខារ ដែលមានតម្លៃច្រើន ដល់សមណៈ, សមណៈ គប្បីធ្វើឱសថ ដោយទឹកមូត្រស្អុយ ឬ ដោយលំអិតនៃផ្លែសម៉ ដោយហេតុណា, ហេតុនោះ ជាការសមគួរ” ព្រោះអាស្រ័យនូវហេតុនោះ ភិក្ខុនោះ គ្រងនូវចីវរដែលសៅហ្មង ឆាន់បិណ្ឌបាតដ៏សៅហ្មង ប្រើប្រាស់សេនាសនៈទ្រុឌទ្រោម សេពគិលានបច្ច័យ និង ភេសជ្ជបរិក្ខារដ៏សៅហ្មង, គហបតីទាំងឡាយ ស្គាល់ភិក្ខុនុ៎ះឯង យ៉ាងនេះថា “សមណៈនេះ ជាអ្នកប្រាថ្នាតិច សន្តោស ស្ងប់ស្ងាត់ មិនច្របូកច្របល់ដោយគណៈ មានសេចក្តីព្យាយាមប្រារព្ធហើយ ជាអ្នកពោលនូវធម៌ជាគ្រឿងកំចាត់បង់កិលេស” ដូច្នេះ តែងនិមន្តដោយចីវរ ។ល។ បរិក្ខារទាំងឡាយច្រើនឡើងៗ, ភិក្ខុនោះ ពោលយ៉ាងនេះថា “កុលបុត្រ មានសទ្ធា រមែងបាននូវបុណ្យដ៏ច្រើន ព្រោះភាវៈនៃវត្ថុទាំង ៣ មាននៅចំពោះមុខ, កុលបុត្រ អ្នកមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះសទ្ធាមាននៅចំពោះមុខ, កុលបុត្រ អ្នកមានសទ្ធា រមែងបានបុណ្យ



ច្រើន ព្រោះទេយ្យធម៌មាននៅ ក្នុងទីចំពោះមុខ ។ល។ កុលបុត្រអ្នកមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះទក្ខិណេយ្យបុគ្គលទាំងឡាយមាននៅចំពោះមុខ, អ្នកទាំងឡាយ មានសទ្ធានេះ ពិតមែនផង ទេយ្យ-ធម៌ ក៏មានព្រមគ្នាផង បដិគ្គាហកៈ គឺអាត្មា ក៏មានផង បើអាត្មា នឹងមិនទទួលទេ, កាលបើដូច្នោះ អ្នកទាំងឡាយ នឹងនៅក្រៅស្រឡះចាកបុណ្យ, អាត្មាភាព មិនត្រូវការដោយទេយ្យធម៌នេះទេ, តែថា អាត្មាភាពទទួល ដោយសារតែការអនុគ្រោះដល់អ្នកទាំងឡាយតែប៉ុណ្ណោះ” ដូច្នេះ ព្រោះអាស្រ័យហេតុនោះ ភិក្ខុនោះ ទើបទទួលនូវចីវរយ៉ាងច្រើន ទទួលបិណ្ឌបាត, សេនាសនៈ, ភេសជ្ជបរិក្ខារ យ៉ាងច្រើនៗ, ការមានមុខស្រងូតស្រងាត់, ការមានធ្វើមុខស្រងូតស្រងាត់, ការកុហកដោយបូក, ការញ៉ាំងទាយក ឲ្យភាន់ភាំង, ការបំភាន់ទាយក មានសភាពបែបនេះឯណា, អាកប្បកិរិយាបែបនេះ លោកហៅថា “កុហនវត្ថុ ពោលគឺការសេពនូវបច្ច័យ” ។

ចំណែកការធ្វើឲ្យទាយកភាន់ភាំង ដោយប្រការនោះៗ ដោយវាចាជាហេតុសម្តែង នូវការបានសម្រេចឧត្តរិមនុស្សធម៌ របស់ភិក្ខុអ្នកប្រាថ្នាលាភនោះឯង បណ្ឌិត គប្បីជ្រាបថា “ជារឿងកុហក ពោលគឺការខ្សឹបខ្សៀវ ក្នុងទីជិត” ដូច្នេះ ។ សមដូចជាព្រះអដ្ឋកថាចារ្យពោល ថា “ក្នុងវត្ថុទាំងនោះ រឿងកុហក ពោលគឺការខ្សឹបខ្សៀវក្នុងទីជិត តើដូចម្តេច? ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ មានបំណងដើម្បីឲ្យគេសរសើរ ពោលវាចាដែលប្រកបដោយអរិយធម៌ ដោយគិតថា “កាលបើអាត្មាអញធ្វើយ៉ាងនេះ, ជននឹងសរសើរអាត្មាអញ” ដូច្នេះ ពោលថា “ភិក្ខុណា ទ្រទ្រង់នូវចីវរបែបនេះ,

ភិក្ខុនោះ ជាសមណៈមានស័ក្តិធំ” ពោលថា “ភិក្ខុណា ប្រើប្រាស់បាត្រ, ភាជន៍លោហៈ, ធម្មក្រក, តម្រង, កូនសោ, កាយព័ន្ធ, ស្បែកជើង មានសភាពបែបនេះ, ភិក្ខុនោះ ជាសមណៈមានស័ក្តិធំ” ដូច្នេះ ពោលថា “ព្រះឧបជ្ឈាយ៍, អាចារ្យ, ភិក្ខុ មានឧបជ្ឈាយ៍ស្មើគ្នា, ភិក្ខុ មានអាចារ្យស្មើគ្នា, ភិក្ខុជាមិត្រ, ភិក្ខុជាមិត្រ ធ្លាប់ឃើញ, ភិក្ខុជាមិត្រធ្លាប់ជួបគ្នាម្តងមួយកាល, ភិក្ខុជាសម្លាញ់ មានសភាពបែបនេះៗ របស់ភិក្ខុណា, ភិក្ខុណា នៅក្នុងវត្ត, នៅក្នុងប្រាសាទវែង, ប្រាសាទមូល, ប្រាសាទរលីង, គុហា, រូង, កុដិ, ផ្ទះកំពូល, ប៉ម, រោង, ថែវ, ឧបដ្ឋានសាលា, មណ្ឌប, ទៀបគល់ឈើ មានសភាពបែបនេះៗ, ភិក្ខុនោះ ជាអ្នកមានស័ក្តិធំ” ដូច្នេះ, មួយទៀត ភិក្ខុនោះ មានអាការៈគួរឲ្យខ្ពើមក្រៃពេក មានសភាពជាអ្នកមានមុខ ស្រងូតស្រងាត់ក្រៃពេក ជាអ្នកកុហកក្រៃពេក ជាអ្នកនិយាយប្រចំដែលៗ ស្មើជួសមុខខ្លួនឯង សម្តែងនូវកថា ដ៏ជ្រាលជ្រៅ, កំបាំង, ល្អិត, ជាទីបិទបាំង ដែលប្រកបដោយលោកុត្តរធម៌ និង សុញ្ញតា មានសភាពបែបនោះ ថា “សមណៈរូបនេះ មានប្រក្រតីបាននូវវិហារសមាបត្តិទាំងឡាយនេះ មានសភាពបែបនេះៗ” ដូច្នេះ, ការមានមុខស្រងូតស្រងាត់ ភាពនៃភិក្ខុមានមុខស្រងូតស្រងាត់ ការកុហកដោយឫក ការញ៉ាំងទាយកឲ្យភាន់ភាំង ភាពនៃភិក្ខុ ធ្វើឲ្យទាយកភាន់ភាំង មានសភាពបែបនេះណាៗ, អាកប្បកិរិយាបែបនេះ លោកហៅថា “រឿងកុហក ពោលគឺការខ្សឹបខ្សៀវ ក្នុងទីជិត” ។

ចំណែកការញ៉ាំងទាយកឲ្យភាន់ភាំង ដោយឥរិយាបថ ដែល(ខ្លួន) ធ្វើហើយដើម្បីឲ្យគេសរសើរ របស់ភិក្ខុអ្នកមានសេចក្តីប្រាថ្នាលាមក នោះឯង គប្បីជ្រាបថា “រឿងកុហកអាស្រ័យ ដោយឥរិយាបថ” ។



សមដូចព្រះភគវ័ត ទ្រង់ត្រាស់ថា “កុហនវត្ថុ ពោលគឺឥរិយាបថ តើដូចម្តេច? ។ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ហើយ មានបំណងចង់ឲ្យគេសរសើរ គិតថា “ជននឹងសរសើរអាត្មាអញ យ៉ាងនេះ” ដូច្នេះហើយ ក៏ខិតខំផ្ចិតផ្ចង់ដំណើរ រៀបចំជំហរ បន្ទុយ ដំណេក សង្រួមដើរទៅ សង្រួមឈរនៅ សង្រួមអង្គុយ សង្រួមសម្រេចការសិង ធ្វើហាក់បីដូចជាដើរធ្វើសមាធិ ដូចជាធ្វើសមាធិឈរ ដូចជាអង្គុយធ្វើសមាធិ ធ្វើដូចជាចូលសមាធិសិង, មួយទៀត ជាអ្នកធ្វើដូចជាចូលឈានឲ្យជនគេឃើញ ការតាំង ប្រុងប្រៀប ការតម្កល់ការរៀបចំនូវឥរិយាបថ ការមានមុខស្រងូតស្រងាត់ ភាពនៃភិក្ខុមានមុខស្រងូតស្រងាត់ ការកុហកដោយឫក ការញ៉ាំងទាយកឲ្យភាន់ភាំង ភាពនៃភិក្ខុធ្វើឲ្យទាយកភាន់ភាំងណាៗ, អំពើទាំងអស់នេះ លោកហៅថា “រឿងកុហក ទាក់ទងនឹងការរៀបចំឥរិយាបថ” ។

ក្នុងបាលីនៃកុហនវត្ថុនោះ បទថា “ពោលគឺការសេពនូវបច្ច័យ” សេចក្តីថាៈ (ដោយកុហនវត្ថុ) ដែលបណ្ឌិតរាប់បញ្ចូលព្រមហើយ យ៉ាងនេះថា “ការសេពនូវបច្ច័យ” ដូច្នេះ ឬថា ដោយការសេពនូវបច្ច័យដែលបណ្ឌិត ពោលហើយ ។ បទថា “ដោយការខ្សឹបខ្សៀវក្នុងទីជិត” បានដល់ ដោយការនិយាយក្នុងទីជិត ។ បទថា “ឥរិយាបថស្ស វា” បានដល់ នៃឥរិយាបថទាំង ៤ ។ ការប្រុងប្រៀប តាំងពីដើម ឬ ការប្រុងប្រៀបដោយអើពើ ឈ្មោះថា អដ្ឋបនា ។ អាការៈនៃការប្រុងប្រៀប ឈ្មោះថា ឋបនា ។ ការចាត់ចែង មានពាក្យអធិប្បាយថា ការធ្វើនូវការៈនៃសេចក្តីព្យាយាម ប្រកបដោយសេចក្តីជ្រះថ្លា ឈ្មោះថា សណ្ឋបនា ។ ការធ្វើមុខជូរ មានពាក្យអធិប្បាយថា ការធ្វើមុខស្រងូតស្រងាត់ ដោយ

សម្តែងនូវភាវៈនៃខ្លួនជាអ្នកមានសេចក្តីព្យាយាម យ៉ាងតឹងរឹង ឈ្មោះថា ភាកុដិកា ។ ការធ្វើមុខជូរ ជាប្រក្រតីរបស់ភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា អ្នកមានការធ្វើមុខជូរជាប្រក្រតី ។ ភាវៈនៃភិក្ខុអ្នកមានការធ្វើមុខជូរជាប្រក្រតី ឈ្មោះថា ភាវៈជាអ្នកមានការធ្វើមុខជូរជាប្រក្រតី ។ ការញ៉ាំងទាយកឲ្យភាន់ភាំង ឈ្មោះថា កុហនា ។ ការប្រព្រឹត្តិបោកប្រាស ឈ្មោះថា កុហាយនា ។ ភាវៈនៃបុគ្គលអ្នកមានការប្រព្រឹត្តិបោកប្រាស ឈ្មោះថា កុហិតត្តំ ។

(លបនានិទ្ទេស)

(២០) គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងលបនានិទ្ទេសដូចតទៅនេះ ។ ការដែលភិក្ខុឃើញមនុស្សទាំងឡាយមកកាន់វត្តហើយ និយាយរួសរាយមុនភ្លាម យ៉ាងនេះ ថា “ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយមកហើយដើម្បីប្រយោជន៍អ្វី? មកដើម្បីនិមន្តភិក្ខុទាំងឡាយឬ? ថាបើមានកិច្ចការយ៉ាងនេះ, អ្នកទាំងឡាយចូរទៅចុះ អាត្មា នឹងនាំភិក្ខុទាំងឡាយទៅ តាមក្រោយ” ដូច្នេះ ឈ្មោះថា លបនា ។ មួយទៀត ការដែលភិក្ខុអួតខ្លួនហើយនិយាយរួសរាយ បង្អោនចូលមកកាន់ខ្លួន យ៉ាងនេះថា “អាត្មាឈ្មោះតិស្សៈ, ព្រះរាជា ទ្រង់ជ្រះថ្លាចំពោះអាត្មា, មហាមាត្យ របស់ព្រះរាជា ឯណោះផងៗ ជ្រះថ្លាចំពោះអាត្មា” ដូច្នេះ ឈ្មោះថា អាលបនា ។ ការដែលភិក្ខុត្រូវទាយកសួរហើយ ពោលរួសរាយ មានប្រការដូចបានពោលហើយនុ៎ះឯង ឈ្មោះថា លបនា ។ ការដែលភិក្ខុភ័យខ្លាច ក្នុងការដែលគហបតីទាំងឡាយ នឹងកើតនឿយណាយហើយ និយាយរួសរាយ បើកឱកាសឲ្យ ដោយប្រពៃ ឈ្មោះថា សល្លបនា (និយាយយកចិត្តគេ) ។ ការនិយាយធ្វើឲ្យគេខ្ពស់ឡើង យ៉ាងនេះថា “មហាកុដុម្ពិក៍,



មហានាវិក, មហាទានបតី” ឈ្មោះថា ឧល្លបនា (និយាយលើកគេ) ។ ការនិយាយធ្វើឲ្យគេខ្ពស់ឡើងដោយគ្រប់សព្វ ឈ្មោះថា សមុល្លបនា ។ មានពាក្យអធិប្បាយថា ការនិយាយចង គឺ និយាយសន្ធុញខ្វាំងយ៉ាងនេះថា “ម្នាលឧបាសក និង ឧបាសិកាទាំងឡាយ នៅពេលមុន ក្នុងវេលាដូច្នេះ ពួកអ្នកទាំងឡាយតែងឲ្យទានថ្មី, ឥឡូវនេះ ពួកអ្នកមិនឲ្យទេឬ?” ដូច្នេះ រហូតទាល់តែពួកទាយក ទទួលពាក្យថា “បពិត្រលោកម្ចាស់ ដ៏ចំរើន យើងទាំងឡាយនឹងប្រគេន, តែយើងទាំងឡាយ ពុំទាន់បាននូវឱកាស” ដូច្នេះជាដើម ឈ្មោះថា ឧន្នហា (និយាយចងទុក) ។ មួយទៀត ភិក្ខុ ឃើញឧបាសកកាន់អំពៅ ក៏សួរថា “នែឧបាសក អ្នកយកអំពៅពីណាមក?” ។ ឧបាសកទូលថា “បពិត្រលោកម្ចាស់ដ៏ចំរើន យកអំពីចំការអំពៅ” ។ ភិក្ខុ សួរថា “អំពៅ ក្នុងចំការនោះ មានរសជាតផ្អែមឬ?” ។ ឧបាសកទូលថា “បពិត្រលោកម្ចាស់ដ៏ចំរើន លុះតែលោកម្ចាស់ឆាន់ទើបដឹង” ។ ភិក្ខុពោលថា “ម្នាលឧបាសក និងឧបាសិកាទាំងឡាយ ការនិយាយប្រាប់ថា អ្នកទាំងឡាយ ចូរឲ្យនូវអំពៅដូច្នេះ មិនសមគួរដល់ភិក្ខុទេ” ។ វាចានិយាយចងជើង របស់ភិក្ខុអ្នកនិយាយដោះសារបែបនេះឯណា, វាចាដែលនិយាយចងជើងបែបនោះ ឈ្មោះថា ឧន្នហនា ។ ការនិយាយចងជើងហើយចងទៀតដោយចំណែកសព្វគ្រប់ ឈ្មោះថា សមុន្នហនា ។ បទថា “ឧក្កាបនា” សេចក្តីថា ការនិយាយលើក យ៉ាងនេះថា “ត្រកូលនោះ ស្គាល់អាត្មាច្បាស់ណាស់ បើទេយ្យ-ធម៌ កើតឡើង ក្នុងទីនោះ ត្រកូលនោះ នឹងប្រគេនដល់អាត្មាមិនខាន” ដូច្នេះ ឈ្មោះថា ឧក្កាបនា ។ មានពាក្យអធិប្បាយថា ជាអ្នកនិយាយចង្អុលប្រាប់ ។ ក្នុងបទថា “ឧក្កាបនា” នេះ បណ្ឌិតគប្បីពោលរឿងនាង

តេលកន្ទុរិកា ។ ចំណែកការនិយាយបញ្ជោររឿយៗ ដោយចំណែកសព្វគ្រប់ ឈ្មោះថា សមុក្កាបនា ។ ការមិនរមិលមើលនូវពាក្យសមគួរដល់សេចក្តីពិតត្រង់ ឬ សមគួរដល់ធម៌ហើយ និយាយរឿយៗ ធ្វើឲ្យគេស្រឡាញ់តែប៉ុណ្ណោះ ឈ្មោះថា ភាពនៃភិក្ខុអ្នកពោលនូវពាក្យចាក់បណ្តោយ ។ ការប្រព្រឹត្តិបន្ទាបខ្លួន ការប្រព្រឹត្តិតម្កល់ខ្លួន ខាងក្រោមៗ ឈ្មោះថា ភាពនៃភិក្ខុអ្នកប្រព្រឹត្តបន្ទាបខ្លួន ។ ភាពនៃភិក្ខុអ្នកមានវាចាស្មើ ដោយសម្លសណ្តែកបាយ ឈ្មោះថា មុគ្គសូបតា ។ ប្រៀបដូចជាសណ្តែកបាយដែលបុគ្គលចំអិន, សណ្តែកបាយខ្លះមិនឆ្អិនទេ, តែដែលសេសសល់ឆ្អិន យ៉ាងណា ក្នុងពាក្យរបស់បុគ្គលណា ពាក្យពិត មានត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះឯង ។ ពាក្យដ៏សេស ជាពាក្យឡេះឡោះ ក៏យ៉ាងនោះដែរ, បុគ្គលនេះ លោកឲ្យឈ្មោះថា បុគ្គលប្រៀបដូចជាសម្លសណ្តែកបាយ ។ ភាវៈនៃបុគ្គលដូចជាសម្លសណ្តែកបាយនោះ ឈ្មោះថា មុគ្គសូបតា ។ ភាពនៃភិក្ខុជាអ្នកបី-ព នូវទារក នៃត្រកូល ឈ្មោះថា បារិភដ្យតា ។ អធិប្បាយថា: ក៏ភិក្ខុរូបណា បី-ព គឺទ្រទ្រង់នូវទារកក្នុងត្រកូល ដោយចង្កេះក្តី ដោយ-ក ក្តី ដូចជាមេនំ, អំពើនៃការបី-ពរបស់ភិក្ខុនោះ ឈ្មោះថា បារិភដ្យំ ។ ភាវៈនៃភិក្ខុជាអ្នកបី-ព នូវទារកក្នុងត្រកូល ឈ្មោះថា បារិភដ្យតា យ៉ាងដូច្នេះឯង ។

(នេមិត្តិកតានិទ្ទេស)

(២១) គប្បីជ្រាបសេចក្តីអធិប្បាយ ក្នុងនេមិត្តិកតានិទ្ទេស តទៅ ។ កាយកម្ម និង វចីកម្មណាមួយ ដែលញុំាងសេចក្តីសម្គាល់ ក្នុងការឲ្យបច្ច័យ(ដល់ខ្លួន) ឲ្យកើតដល់ជនដទៃ ឈ្មោះថា និមិត្ត ។ ការដែលភិក្ខុឃើញពួកទាយកកាន់ខាទនីយៈហើយ ដើរទៅ ធ្វើនិមិត្ត ដោយន័យថា



“អ្នកទាំងឡាយបានខាទនីយៈឬ?” ដូច្នេះជាដើម ឈ្មោះថា និមិត្តកម្ម ។ ការនិយាយប្រកបព្រមដោយបច្ច័យ ឈ្មោះថា ឱភាសោ (ការនិយាយបញ្ជិតបញ្ជៀង) ។ ការដែលភិក្ខុឃើញពួកក្មេងឃ្វាលកូនគោហើយ សួរថា “កូនគោទាំងនេះ ជាកូនគោបៅទឹកដោះស្រស់ ឬ ឬថា ជាកូនគោបៅខ្លាញ់?” ដូច្នេះ, កាលបើពួកក្មេងទាំងនោះ ពោលថា “បពិត្រលោកម្ចាស់ កូនគោបៅទឹកដោះស្រស់” ដូច្នេះ, ហើយក៏ធ្វើនូវឱកាស ដោយន័យជាអាទិ៍ យ៉ាងនេះថា “កូនគោទាំងនេះ មិនមែនជាកូនគោបៅទឹកដោះស្រស់ទេ, បើសិនជាកូនគោទាំងឡាយ បៅទឹកដោះស្រស់មែននោះ, ពួកភិក្ខុ គប្បីបានទឹកដោះស្រស់ខ្លះ” រហូតដល់ពួកក្មេងទាំងនោះ ទៅប្រាប់ដល់មាតាបិតា ឲ្យប្រគេនទឹកដោះស្រស់ (ដល់ខ្លួន) ជាដើម ឈ្មោះថា ឱភាសកម្ម ។ ការនិយាយខ្សឹបខ្សៀវធ្វើជិតៗ ឈ្មោះថា ការខ្សឹបខ្សៀវក្នុងទីជិត ។ ឯរឿងភិក្ខុជាជីតុន បណ្ឌិតគប្បីសម្តែងក្នុងបទនេះ ។

បានឮមកថា ភិក្ខុអ្នកចូលទៅកាន់ត្រកូល ត្រូវការឆាន់ ក៏ចូលទៅកាន់ផ្ទះហើយគង់ ។ ស្រីមេផ្ទះឃើញភិក្ខុនោះហើយ មិនចង់ប្រគេន ក៏ពោលថា “អង្ករគ្មានទេ” ដូច្នេះហើយ ធ្វើដូចជាចង់នាំយកអង្ករមក ក៏ដើរទៅកាន់ផ្ទះអ្នកដែលស្និទ្ធស្នាលគ្នា ។ ភិក្ខុ ចូលទៅ ក្នុងបន្ទប់ហើយ ក្រឡេកមើលឃើញ នូវអំពៅនៅក្បែរសន្ទះទ្វារ ឃើញស្ករអំពៅ ក្នុងភាជន៍ ឃើញត្រីងៀតទាំងឡាយ ក្នុងកញ្ច្រោង ឃើញអង្ករ ក្នុងថ្នាំង ឃើញខ្លាញ់ក្នុងក្អម ក៏ចេញមកអង្គុយ ។ ស្រីមេផ្ទះត្រឡប់មកវិញប្រាប់ថា“នាងខ្ញុំមិនបានអង្ករទេ” ។ ភិក្ខុពោលថា: ម្នាលឧបាសិកា អាត្មាបានឃើញនិមិត្តជាមុនស្រេចហើយ ដឹងថា “ថ្ងៃនេះ ភិក្ខានឹងមិនសំរេចទេ” ដូច្នេះ ។ ស្រីមេផ្ទះសួរថា “និមិត្ត ដូចម្តេចទៅ លោកម្ចាស់?” ។ ភិក្ខុ

ពោលថាៈ អាត្មាបានឃើញពស់ ដូចជាអំពៅដែលនាងទុកហើយ នៅក្បែរសន្ទះទ្វារ, អាត្មាកាលក្រឡេកមើល ដោយគិតថា "អាត្មានឹងវាយពស់នោះ" ដូច្នេះ ក៏បានឃើញពពារដូចជាត្រីឆ្អៀត ដែលនាងទុកហើយ ក្នុងកញ្ច្រែងដែលពស់នោះ ត្រូវអាត្មាវាយហើយដោយដុំថ្ម និង ដុំដី ដូចជាដុំស្ករអំពៅដែលនាងទុកហើយ ក្នុងភាជន៍ធ្វើហើយ បានឃើញធ្មេញនៃពស់នោះ ដែលចង់ចឹកដុំដីនោះ ដូចជាអង្ករដែលនៅ ក្នុងថ្នាំង, បានឃើញទឹកមាត់លាយដោយពិស ដែលចេញអំពីមាត់ របស់ពស់នោះ ដែលខឹងហើយ ប្រាកដដូចជាខ្ទាញ់ ដែលនាងទុកដាក់ហើយ ក្នុងក្អម" ។ ស្រីមេផ្ទះ គិតថា "អញ មិនអាចបញ្ឆោតសមណៈត្រងោលនេះបានទេ" ដូច្នេះ ក៏ប្រគេនអំពៅ ដាំបាយ បានប្រគេនហើយ ព្រមទាំងខ្ទាញ់, ស្ករអំពៅ និង ត្រី យ៉ាងដូច្នេះឯង ។ ការខ្សឹបខ្សៀវធ្វើសំឡេង ក្នុងទីជិតយ៉ាងនេះ គប្បីជ្រាបថា "ការខ្សឹបខ្សៀវក្នុងទីជិត" ដូច្នេះ ។ ការនិយាយត្រឡប់ត្រឡិន ធ្វើយ៉ាងណា ឲ្យតែបាននូវបច្ច័យ ឈ្មោះថា បរិកថា ។

(និប្បេសិកតានិទ្ទេស)

(២២) គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិប្បេសិកតានិទ្ទេស ដូចតទៅ ។ ការជេរ ដោយជេរ ១០ យ៉ាង ឈ្មោះថា អក្កោសនា ។ ការនិយាយគ្របសង្កត់ ឈ្មោះថា វម្ភនា ។ ការលើកឡើងនូវទោស ដោយន័យថា "អ្នកនេះ ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា" ដូច្នេះជាដើម ឈ្មោះថា គរហនា ។ ការពោលលើក ដោយវាចាថា "អ្នកទាំងឡាយ កុំនិយាយយ៉ាងនេះ ក្នុងត្រកូលនេះ" ឈ្មោះថា ឧក្ខេបនា ។ ការនិយាយលើកដោយវាចា ធ្វើឲ្យប្រកបដោយវត្ថុ ដោយហេតុ ដោយចំណែកសព្វគ្រប់ ឈ្មោះថា សមុក្ខេបនា ។ ម្យ៉ាងទៀត ការឃើញទាយក មិនឲ្យហើយ



ពោលលើក យ៉ាងដូច្នេះថា "ឱហ្ន៎ លោកទានបតី" ដូច្នេះ ឈ្មោះថា ឧក្ខេបនា ។ ការនិយាយលើក ដោយប្រពៃ យ៉ាងនេះថា "ឱហ្ន៎ លោកមហាទានបតី" ឈ្មោះថា សមុក្ខេបនា ។ ការនិយាយចំអកយ៉ាងនេះថា "ជីវិត របស់អ្នកបរិភោគពូជនេះ តើដូចម្តេចទៅ?" ឈ្មោះថា ខិបនា ។ ការនិយាយចំអកខ្លាំងៗ ដោយវិសេស យ៉ាងនេះថា "ជនណា ឲ្យនូវពាក្យថាៈ មិនមានដល់ពួកជនទាំងពួង អស់កាលជានិច្ច, អ្នកទាំងឡាយពោលនូវជននោះ ថាៈ មិនមែនជាទាយក យ៉ាងដូចម្តេចកើត" ឈ្មោះថា សង្ខិបនា ។ ការញ៉ាំងទាយក ឲ្យដល់នូវភាពមិនមែនជាទាយក ឬ ឲ្យខូចកេរ្តិ៍ឈ្មោះ ឈ្មោះថា បាបនា ។ ការញ៉ាំងទាយក ឲ្យដល់ដោយចំណែកសព្វគ្រប់ ឈ្មោះថា សម្បាបនា ។ ការនាំទោស អំពីផ្ទះទៅកាន់ផ្ទះ អំពីស្រុកទៅកាន់ស្រុក អំពីជនបទទៅកាន់ជនបទ ដោយគិតថា "បុគ្គលនេះ នឹងឲ្យទានដល់អាត្មាអញ ព្រោះភ័យអំពីទោស យ៉ាងនេះ" ឈ្មោះថា អវណ្ណហារិកា ។ ការពោលពាក្យពីរោះ ក្នុងទីចំពោះមុខ ហើយពោលទោស ក្នុងទីកំបាំងមុខ ឈ្មោះថា បរបិដ្ឋិមំសិកតា ។ ព្រោះវាចានុ៎ះ ជាវាចាប្រៀបដូចជា កាលបើបុគ្គលមិនអាច ដើម្បីនឹងក្រឡេកមើលឲ្យចំមុខបាន ទំពាស៊ីនូវសាច់ខ្នង របស់ជនទាំងឡាយ ក្នុងទីកំបាំងមុខ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "បរបិដ្ឋិមំសិកតា" ។ ពាក្យថា "អយំ វុច្ចតិ និប្បេសិកតា" សេចក្តីថា វាចានេះកិន គឺជូតនូវគុណរបស់ជនដទៃ ដូចជាបុគ្គលជូតនូវខ្ទាញ់ដោយបន្ទះឫស្សី ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា ឈ្មោះថា "និប្បេសិកតា" ដូច្នេះ, ម្យ៉ាងវិញទៀត វាចានុ៎ះ ជាវាចាកិនកំទេច គឺលំអិតនូវគុណ របស់ជនដទៃ ស្វែងរកនូវលាភ

ប្រៀបដូចជាបុគ្គល កិនគន្ធជាតហើយ ស្វែងរកនូវក្លិន យ៉ាងដូច្នោះ ព្រោះហេតុណា, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ហៅថា ឈ្មោះថា "និប្បេសិកតា" ដូច្នេះឯង ។

(លាភេន លាភំ និជិគីសនតានិទ្ទេស)

(២៣) គប្បីជ្រាបអត្ថាធិប្បាយ ក្នុងនិទ្ទេស នៃការស្វែងរកលាភ ដោយលាភ ដូចតទៅ ។ ការស្វែងរក ឈ្មោះថា និជិគីសនតា ។ បទថា "ឥតោ លទ្ធំ" គឺបានហើយអំពីផ្ទះនេះ ។ បទថា "អមុត្រ" គឺក្នុងផ្ទះឯណោះ ។ សេចក្តីប្រាថ្នា ឈ្មោះថា ឯដ្ឋិ ។ ការស្វែងរក ឈ្មោះថា គវេដ្ឋិ ។ ការស្វែងរករឿយៗ ឈ្មោះថា បរិយេដ្ឋិ ។ ក៏ក្នុងនិទ្ទេសនេះ បណ្ឌិតគប្បីសម្តែងរឿងភិក្ខុ អ្នកឲ្យភិក្ខាដែលខ្លួនបានហើយៗ តាំងតែពីដើមមក ដល់ពួកទារក ក្នុងត្រកូល ក្នុងផ្ទះនោះៗ លុះបានបបរលាយទឹកដោះស្រស់ហើយទៅ ។ ពាក្យទាំងឡាយ មានពាក្យថា "ឯសនា" ជាដើម ជាពាក្យផ្លាស់ប្តូរគ្នា នៃពាក្យទាំងឡាយ មានពាក្យថា ឯដ្ឋិ ជាដើមនេះឯង ។ ព្រោះហេតុនោះ បណ្ឌិត គប្បីជ្រាបការប្រកប ក្នុងបទទាំងនេះថា: បទថា ឯដ្ឋិ គឺ ឯសនា, បទថា គវេដ្ឋិ គឺ គវេសនា, បទថា បរិយេដ្ឋិ គឺ បរិយេសនា យ៉ាងនេះឯង ។ នេះ គឺជាសេចក្តីអធិប្បាយនៃបាបធម៌ទាំងឡាយ មានកុហនា ជាដើម ។

(២៤) ឥឡូវនេះ ក្នុងបទថា "ឯវមាទីនញ្ច បាបធម្មានំ" ដូច្នេះ បណ្ឌិត គប្បីជ្រាបការកាន់យក នូវបាបធម៌ទាំងឡាយដ៏ច្រើន ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងព្រហ្មជាលសូត្រ ដោយន័យថា "ម្យ៉ាងទៀត ដូចជាពួកសមណព្រាហ្មណ៍ដ៏ចំរើន ពួកខ្លះ ឆាន់នូវភោជន ដែលទាយកឲ្យហើយ ដោយសទ្ធា, សមណព្រាហ្មណ៍ទាំងឡាយនោះ



ចិញ្ចឹមជីវិត ដោយការចិញ្ចឹមជីវិតខុស ដោយតិរច្ឆានវិជ្ជា មានសភាពបែបនេះ ។ តិរច្ឆានវិជ្ជានេះ គឺអ្វីខ្លះ? ។ គឺ ការទាយអវយវៈ, ការទាយនូវនិមិត្ត, ការទាយនូវឧត្បាត (ការធ្លាក់ចុះក្នុងហេតុធំៗ), ការទាយនូវសុបិន, ការទាយលក្ខណៈ, ការទាយសំពត់ដែលត្រូវកណ្តុរកាត់, ការបូជាភ្លើង, ការបូជាវែក" ដូច្នេះជាដើមផង ។

ការចិញ្ចឹមជីវិតខុស ដែលប្រព្រឹត្តទៅ ដោយអំណាចនៃកិរិយាប្រព្រឹត្តិល្មើសសិក្ខាបទទាំង ៦ ដែលព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ ព្រោះអាជីវៈជាហេតុ ទាំងនេះក្តី ដោយអំណាចនៃបាបធម៌ទាំងឡាយមានជាអាទិ៍ យ៉ាងដូច្នេះ គឺ កុហនា, លបនា, នេមិត្តិកតា, និប្បេសិកតា, លាភេន លាភំ និជិគីសនតា ទាំងនេះក្តី ឯណា, ការវៀរចាកមិច្ឆាជីវៈ មានប្រការគ្រប់យ៉ាង ឯណា, ការវៀរចាកកិរិយា ចិញ្ចឹមជីវិតខុសនេះ ឈ្មោះថា អាជីវបារិសុទ្ធិសីល យ៉ាងនេះឯង ។

សេចក្តីនៃពាក្យ ក្នុងអាជីវបារិសុទ្ធិសីលនោះ មានដូចតទៅនេះ ។ ជនទាំងឡាយ អាស្រ័យនូវសភាពនេះ រស់នៅ ហេតុនោះ សភាពនោះ ឈ្មោះថា អាជីវៈ ។ សភាពនោះគឺអ្វី? ។ សភាពនោះគឺសេចក្តីព្យាយាមក្នុងការស្វែងរកនូវបច្ច័យ ។ សេចក្តីបរិសុទ្ធិ ឈ្មោះថា បារិសុទ្ធិ ។ សេចក្តីបរិសុទ្ធិនៃអាជីវៈ ឈ្មោះថា អាជីវបារិសុទ្ធិ ។

(២៥) ឯបច្ចយសន្និស្សិតសីល ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងលំដាប់នៃអាជីវបារិសុទ្ធិសីលនោះឯណា, បណ្ឌិត គប្បីជ្រាបអត្ថាធិប្បាយ ក្នុងបច្ចយសន្និស្សិតសីលនោះ ដូចតទៅនេះ ។

ពាក្យថា "ពិចារណាដោយឧបាយ" សេចក្តីថា ពិចារណា គឺ ដឹងឃើញច្បាស់ ដោយឧបាយ គឺដោយ(ត្រូវ)ផ្លូវ ។ ក៏ការពិចារណាដែល

ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយន័យថា "ដើម្បីការពារ នូវត្រជាក់" ដូច្នេះជាដើម គប្បីជ្រាបថា "ពិចារណា ដោយឧបាយ" ក្នុងបច្ចយសន្និស្សិតសីលនេះ ។ បណ្ដាបទទាំងនោះ បទថា "ចីវរ" បានដល់ បរិក្ខារទាំងឡាយ មានស្បង់ជាដើម បរិក្ខារណាមួយ ។ បទថា "សេព" បានដល់ប្រើប្រាស់ គឺស្លៀក ឬ ឃ្លុំ ។ ពាក្យថា "យាវទេវ" ជាពាក្យនិយមការកំណត់ នូវខេត្តដែននៃប្រយោជន៍ ។ មែនពិត ក្នុងកិរិយាសេពនូវចីវរ របស់ព្រះយោគីមានប្រមាណប៉ុណ្ណេះឯង, នេះគឺអ្វី? ប្រយោជន៍ថា "ដើម្បីការពារ នូវត្រជាក់" ដូច្នេះជាដើម មិនមែនក្រៃលែងជាងនេះទេ ។ ពាក្យថា "ត្រជាក់" បានដល់ នូវត្រជាក់ណាមួយ ដែលកើតឡើងហើយ ដោយអំណាចនៃការកំរើកនូវធាតុ ខាងក្នុង ឬក៏ដោយអំណាចនៃការប្រែប្រួលនូវរដូវខាងក្រៅ ។ ពាក្យថា "ដើម្បីការពារ" គឺដើម្បីកំចាត់បង់ ។ គឺដើម្បីបន្ទោបង់នូវត្រជាក់នោះ ដោយវិធីដែលវាមិនញុំាងអាពាធឲ្យកើតឡើង ក្នុងសរីរៈបាន ។ ព្រោះថា កាលបើសរីរៈ ត្រូវសេចក្ដីត្រជាក់បៀតបៀនហើយ, ភិក្ខុ មានចិត្តរាយមាយ មិនអាចតម្កល់នូវសេចក្ដីព្យាយាម ដោយឧបាយបានឡើយ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់អនុញ្ញាតថា "ភិក្ខុ ត្រូវតែប្រើប្រាស់ចីវរ ដើម្បីការពារនូវត្រជាក់" ។ ន័យនេះ បណ្ឌិត គប្បីជ្រាបក្នុងប្រយោជន៍ទាំងពួង ។ ព្រោះថា ក្នុងអធិការនេះ គ្រប់គ្រាន់ហើយ ។ បទថា "ឧណ្ហស្ស" គឺ នូវកំដៅនៃភ្លើង ។ ចំណែកការកើតព្រម នៃកំដៅនោះ បណ្ឌិត គប្បីជ្រាប ក្នុងកំដៅទាំងឡាយ មានកំដៅភ្លើងព្រៃជាដើម ។ ឯសេចក្ដីវិនិច្ឆ័យ ក្នុងបទថា "ឌំសមកសវាតាតបសរីសបសម្ផស្សានំ" នេះ បណ្ឌិតគប្បីជ្រាប ដូចតទៅ ។ របោម និង រុយទាំងឡាយ ឈ្មោះ



ថា ឌំសៈ ។ ពួកអាចារ្យខ្លះ ពោលថា "រុយក្បាលខៀវ" ដូច្នេះ ក៏មានដែរ ។ មូសទុំះឯង ឈ្មោះថា មកសៈ ។ ខ្យល់ទាំងឡាយផ្សេងដោយខ្យល់មានខ្យល់ប្រកបដោយធូលី និង ខ្យល់មិនមានធូលីជាដើម ឈ្មោះថា ខ្យល់ ។ កំដៅនៃព្រះអាទិត្យ ឈ្មោះថា អាតាបៈ ។ សត្វដែលវារលូន ទៅបានគ្រប់យ៉ាង បានដល់ សត្វដែលមានខ្លួនវែង មានពស់ ជាដើម ឈ្មោះថា សរីសបៈ ។ សម្ផស្សនៃសត្វទាំងឡាយ មានពស់ជាដើមនោះ មាន ២ យ៉ាង គឺសម្ផស្សដែលពស់នោះចឹក១, សម្ផស្សដែលពស់នោះពាល់ត្រូវ១ ។ សម្ផស្សនោះឯង មិនបៀតបៀនភិក្ខុ ដែលឃ្លុំចីវរហើយ អង្គុយទេ ។ ព្រោះហេតុនោះ ក្នុងទីទាំងឡាយ មានសភាពបែបនោះ ភិក្ខុប្រើប្រាស់ចីវរ ដើម្បីការពារនូវសម្ផស្សទាំង២ យ៉ាងនោះ។ ការពោលពាក្យថា "យាវទេវ" នេះម្ដងទៀត ដើម្បីសម្ដែងនូវការកំណត់នូវខេត្តដែន នៃប្រយោជន៍ដែលទៀងទាត់ ។ តាមពិត ការបិទបាំងអវយវៈ ជាហេតុញុំាងសេចក្ដីខ្មាសឲ្យកំរើក ជាប្រយោជន៍ដែលទៀងទាត់ ។ ជួនកាលប្រយោជន៍ទាំងឡាយក្រៅពីនេះ មានក្នុងកាលខ្លះ ។ ក្នុងបទថា "ហិរិកោបិនប្បដិច្ឆាទនំ" នោះ បទថា "ហិរិកោបិនំ" គឺទីចង្អៀតនោះៗ ។ មែនពិត កាលបើអវយវៈណាៗ គឺភិក្ខុបើក, ហិរិរមែងកំរើក គឺរមែងវិនាស, អវយវៈនោះៗ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ហិរិកោបិនំ" ដូច្នេះ ព្រោះជាទីញុំាងសេចក្ដីខ្មាសឲ្យកំរើក។ ចំណែកសេចក្ដីនៃពាក្យថា "ដើម្បីបិទបាំងនូវអវយវៈជាគ្រឿងញុំាងសេចក្ដីខ្មាសឲ្យកំរើក" នោះ គឺដើម្បីបិទបាំងនូវអវយវៈ ជាគ្រឿងញុំាងសេចក្ដីខ្មាសឲ្យកំរើក ។ បាឋៈ ថា "ហិរិកោបិនំ បដិច្ឆាទនត្ថំ" ដូច្នេះ ក៏មានដែរ ។

(២៦) ពាក្យថា "បិណ្ឌបាត" គឺ អាហារណាមួយ ។ ព្រោះថា

អាហារណាមួយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា “បិណ្ឌបាត” ព្រោះអាហារនោះធ្លាក់ចុះហើយ ក្នុងបាត្ររបស់ភិក្ខុ ដោយភាពជាដុំ ។ ម្យ៉ាងទៀត ការធ្លាក់ចុះនៃដុំបាយទាំងឡាយ អធិប្បាយថា ការប្រជុំ គឺការប្រមូលផ្តុំនៃភិក្ខាទាំងឡាយ ដែលភិក្ខុបានហើយ ក្នុងទីនោះៗ ឈ្មោះថា បិណ្ឌបាត ។ បទថា “នេវ ទវាយ” គឺ មិនមែនដើម្បីលេង ដូចជាក្មេងអ្នកស្រុកជាដើមទេ ។ អធិប្បាយថា សេចក្តីសម្គាល់ ក្នុងការលេង ។ បទថា “ន មទាយ” គឺ ដើម្បីសេចក្តីមួម៉ៅ ដូចជាអ្នកចំបាប់ និង អ្នកប្រដាល់ជាដើមក៏ទេ ។ អធិប្បាយថា សេចក្តីសម្គាល់ ដោយសេចក្តីស្រវឹងព្រោះកម្លាំង និង សេចក្តីសម្គាល់ ដោយសេចក្តីស្រវឹងរបស់កូនប្រុស ។ បទថា “ន មណ្ឌនាយ” គឺ ដើម្បីប្រដាប់តាក់តែង ដូចពួកស្រីក្នុងបុរី និង ពួកស្រីពេស្យាជាដើមក៏ទេ។ អធិប្បាយថា សេចក្តីសម្គាល់នូវភាវៈនៃការបញ្ចេញអវយវៈតូច-ធំទាំងឡាយ ។ បទថា “ន វិភូសនាយ” គឺ ដើម្បីស្អិតស្អាង ដូចជាអ្នករបាំ និង អ្នករាំជាដើម ក៏ទេ ។ អធិប្បាយថា សម្គាល់នូវភាវៈនៃស្បែកផូរផង់ ។ មួយវិញទៀត បណ្ឌិតគប្បីជ្រាបថា បណ្តាបទទាំង ៤ នោះ បទថា “នេវ ទវាយ” នេះ ព្រះដ៏មានព្រះភាគ ត្រាស់ហើយ ដើម្បីលះបង់នូវឧបនិស្ស័យនៃមោហៈ ។ បទថា “ន មទាយ” នេះ ព្រះអង្គត្រាស់ហើយ ដើម្បីលះបង់ឧបនិស្ស័យនៃទោសៈ ។ ២ បទថា “ន មណ្ឌនាយ ន វិភូសនាយ” នេះ ទ្រង់ត្រាស់ហើយ ដើម្បីលះបង់នូវឧបនិស្ស័យនៃរាគៈ ។ មួយទៀត ២ បទថា “នេវ ទវាយ ន មទាយ” នេះ ទ្រង់ត្រាស់ហើយ ដើម្បីហាមឃាត់នូវការកើតឡើងនៃសំយោជនៈរបស់ខ្លួន ។ ២ បទថា “ន មណ្ឌនាយ ន វិភូសនាយ” នេះទ្រង់ត្រាស់ហើយ ដើម្បីហាមឃាត់នូវការកើតឡើង



នៃសំយោជនៈរបស់ជនដទៃផង ។ មួយទៀត ការលះបង់នូវសេចក្តីប្រតិបត្តិដែលមិនមែនជាឧបាយនៃប្រាជ្ញា និង ការលះបង់នូវកាមសុខ-ល្លិកានុយោគ ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយ ៤ បទនេះដែរ ។ បទថា “យាវទេវ” គឺមានសេចក្តីអធិប្បាយ ដូចបានពោលមកហើយនុ៎ះឯង ។ បទថា “ឥមស្ស កាយស្ស” គឺ នៃរូបកាយដែលប្រកបដោយមហាភូតរូប ៤ នេះ ។ បទថា “ឋិតិយា” គឺដើម្បីឋិតនៅជាប់តទៅ ។ បទថា “យាបនាយ” គឺដើម្បីមិនកាត់ផ្តាច់នៃការប្រព្រឹត្តិទៅ ឬដើម្បីឋិតនៅ អស់កាលដ៏យូរ ។ មែនពិត ភិក្ខុនេះ សេពនូវបិណ្ឌបាតដើម្បីការតាំងនៅនៃកាយ និង ដើម្បីញុំាងជីវិតិន្ទ្រីយ៍ ឲ្យប្រព្រឹត្តទៅ ដូចជាម្ចាស់នៃផ្ទះដែលចាស់ ប្រើទ្រទល់ទល់ទ្រនូវផ្ទះ និង ដូចជាអ្នករទេះប្រើខ្លាញ់សម្រាប់លាបភ្លៅរទេះដូច្នោះ, មិនមែនដើម្បីលេង, ដើម្បីស្រវឹង, ដើម្បីតាក់តែង និងស្អិតស្អាងទេ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា: ពាក្យថា “ឋិតិ” នេះ គឺជាឈ្មោះ របស់ជីវិតិន្ទ្រីយ៍ ព្រោះហេតុនោះដោយពាក្យមានប្រមាណប៉ុណ្ណេះ ថា “ឥមស្ស កាយស្សឋិតិយា យាបនាយ” ដូច្នេះ ទើបមានពាក្យអធិប្បាយថា “ដើម្បីញុំាងជីវិតិន្ទ្រីយ៍ នៃកាយនេះ ឲ្យប្រព្រឹត្តទៅ” ដូច្នេះ ។

បទថា “វិហឹសុបរតិយា” មានវិនិច្ឆ័យថា សេចក្តីស្រេកឃ្លានឈ្មោះថា វិហឹសា ព្រោះអត្ថថា ធ្វើឲ្យមានជម្ងឺ, មែនពិត ភិក្ខុនេះសេពនូវបិណ្ឌបាត ដើម្បីរម្ងាប់នូវសេចក្តីស្រេកឃ្លាននោះ ដូចជាបុគ្គលអ្នកមានដំបៅលាបថ្នាំរក្សាដំបៅ និង ដូចជាបុគ្គលអ្នកមានជម្ងឺ កាលបើកើតមានអាការៈក្តៅ និង ត្រជាក់ជាដើម ក៏លេបថ្នាំបំបាត់អាការៈនោះដូច្នោះ ។ បទថា “ព្រហ្មចរិយា នុគ្គហាយ” គឺ ដើម្បីអនុគ្រោះ ដល់

សាសនព្រហ្មចរិយៈទាំងអស់ និង មគ្គព្រហ្មចរិយៈផង ។ មែនពិត ភិក្ខុនេះ កាលអាស្រ័យកម្លាំងកាយ ព្រោះការសេពបិណ្ឌបាតជាបច្ច័យ ប្រតិបត្តិដើម្បីកន្លងនូវផ្លូវឆ្ងាយគឺភព ដោយអំណាចនៃការប្រកបរឿយៗ ក្នុងត្រៃសិក្ខា ឈ្មោះថា សេព (នូវបិណ្ឌបាត) ដើម្បីអនុគ្រោះ ដល់ព្រហ្មចរិយៈ ដូចជាគូភរិយាស្វាមី ដែលមានសេចក្តីត្រូវការ ដើម្បីឆ្លងផ្លូវឆ្ងាយ បរិភោគសាច់កូន, ដូចជាបុគ្គលដែលមានសេចក្តីត្រូវការដើម្បីឆ្លងទឹកស៊ីងអាស្រ័យផែ និង បីដូចជាបុគ្គលដែលមានសេចក្តីត្រូវការដើម្បីឆ្លងសមុទ្រ អាស្រ័យនូវនាវា យ៉ាងដូច្នោះឯង ។

ពាក្យថា "ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ" មានសេចក្តីអធិប្បាយថាៈ ភិក្ខុ គិតថា "ដោយប្រការយ៉ាងនេះ គឺដោយការសេព នូវបិណ្ឌបាតនេះ អាត្មាអញ នឹងកំចាត់បង់នូវវេទនាចាស់ ដែលកើតពីសេចក្តីស្រេកឃ្លានផង នឹងមិនញ៉ាំងវេទនាថ្មី ដែលមានការបរិភោគ ហួសប្រមាណជាបច្ច័យ ឲ្យកើតឡើងផង ដូចជាបណ្ឌិតព្រាហ្មណ៍ ឈ្មោះ អាហរហត្ថកៈ, ឈ្មោះ អលំសាដកៈ, ឈ្មោះ តត្ថវដ្ដកៈ, ឈ្មោះ កាកមាសកៈ, ឈ្មោះ ភុត្តវមិតកៈ, ព្រាហ្មណ៍ណាមួយ" ដូច្នេះហើយ សេព (នូវបិណ្ឌបាត) ប្រៀបដូចជាមនុស្សមានជម្ងឺ ប្រើប្រាស់ថ្នាំ យ៉ាងនោះឯង" ដូច្នេះ ។ ន័យមួយទៀត គប្បីជ្រាបអត្ថាធិប្បាយ ក្នុងពាក្យនេះថាៈ វេទនាណា ដែលលោកហៅថា "វេទនាចាស់" ព្រោះអាស្រ័យការបរិភោគនូវរបស់ដែលមិនជាទីសប្បាយ និង បរិភោគហួសប្រមាណក្នុងបច្ចុប្បន្ន កើតឡើងដោយអំណាចនៃកម្មចាស់ជាបច្ច័យ, អាត្មាអញ កាលញ៉ាំងបច្ច័យនៃវេទនាចាស់នោះ ឲ្យវិនាសទៅ ដោយការបរិភោគអាហារ ដែលជាទីសប្បាយ និង បរិភោគតែល្មម



ប្រមាណ ឈ្មោះថា រមែងកំចាត់បង់ នូវវេទនាចាស់នោះបានផង និង វេទនានេះណា ដែលលោកហៅថា "វេទនាថ្មី" ព្រោះអាស្រ័យការសន្សំកម្ម គឺការបរិភោគមិនត្រឹមត្រូវ ដែលខ្លួនធ្វើហើយ ក្នុងកាលឥឡូវនេះ កើតឡើងតទៅ, អាត្មាអញ កាលញ៉ាំងដើមហេតុនៃវេទនាថ្មី មិនឲ្យកើតឡើង ដោយអំណាចការបរិភោគដ៏សមគួរ ឈ្មោះថា មិនញ៉ាំងវេទនាថ្មីនោះ ឲ្យកើតឡើងផង" ដូច្នេះ ។ ក៏ការរួបរួមការបរិភោគដ៏សមគួរ ការលះអត្តកិលមថានុយោគ និង ការមិនលះបង់នូវសេចក្តីសុខដែលប្រកបដោយធម៌ គប្បីជ្រាបថា ព្រះមានព្រះភាគ សម្ដែងហើយ ដោយបាឋៈ ២ យ៉ាងនេះឯង ។

ពាក្យថា "យាត្រា ច មេ ភវិស្សតិ" សេចក្តីថា : ភិក្ខុ គិត ថា "ក៏ដោយការបរិភោគដែលសមគួរ ការទៅ ពោលគឺការធ្វើដំណើរ អស់កាលដ៏យូរ ព្រោះមិនមានសេចក្តីក្រវល់ក្រវាយ ដែលជាទីចូលទៅកាត់ផ្តាច់ នូវជីវិតិន្ទ្រីយ៍ ឬ ដែលជាទីកាច់បំបាក់ នូវឥរិយាបថ នឹងមានដល់អាត្មាអញ, មួយទៀត នឹងមានដល់រាងកាយរបស់អាត្មាអញដែលមានការប្រព្រឹត្តិទៅមិនដាច់ដោយបច្ច័យនេះផង" ហើយសេព(នូវបិណ្ឌបាត) ប្រៀបដូចជាបុគ្គលដែលមានរោគ ប្រើប្រាស់នូវថ្នាំសម្រាប់កែរោគនោះ ដូច្នោះឯង ។

២ បទថា "អនវជ្ជតា ច ផាសុវិហារោ ច" សេចក្តីថា ភិក្ខុ គិតថា "ការមិនមានទោស នឹងមាន ដល់អាត្មាអញ ដោយការវៀរចាកនូវការស្វែងរក, ការទទួល និង ការបរិភោគមិនសមគួរ និង ការនៅសុខសប្បាយ នឹងមានដល់អាត្មាអញ ដោយការបរិភោគដ៏សមគួរ" ដូច្នេះ ។ ន័យមួយទៀតថា "ការមិនមានទោស ដោយការៈ មិនមានទោសផ្សេងៗ

*ដូចជាការមិនត្រេកអរ, ការខ្ជិលច្រអូស, កិរិយាមិតពត់ (អែនអន) និង ការតិះដៀលអំពីវិញ្ញូជនជាដើម ព្រោះបរិភោគរបស់មិនជាទីសប្បាយ និង បរិភោគហួសប្រមាណជាបច្ច័យ នឹងមាន ដល់អាត្មាអញ និង ការនៅជាសុខសប្បាយ ដោយមានកម្លាំងកាយមាំមួន ព្រោះបរិភោគអាហារដែលជាទីសប្បាយ និង បរិភោគអាហារតែល្មមសមគួរជាបច្ច័យ នឹងមានដល់អាត្មាអញ” ដូច្នេះខ្លះ ។ ន័យមួយទៀត ថា “ការមិនមានទោស ព្រោះការលះបង់នូវសេចក្តីសុខ ក្នុងការដេក សេចក្តីសុខ ក្នុងការផ្អែកទ្រេត និង សេចក្តីសុខ ក្នុងការងុយងោកងក់ នឹងមាន ដល់អាត្មាអញ ដោយការវៀរចាកការបរិភោគតាមចំណង់ រហូតដល់ឆ្អែតប៉ោងពោះ និង ការនៅជាសុខសប្បាយ ព្រោះឥរិយាបថទាំង ៤ មានចលនាប្រព្រឹត្តទៅសមប្រកប នឹងមាន ដល់អាត្មាអញ ដោយការបរិភោគអាហារ បន្ថយមកត្រឹមតែ ៤, ៥ ពំនូត” ដូច្នេះខ្លះ ក៏មាន ហើយសេព(នូវបិណ្ឌបាត) ។*

*សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា :*

> ភិក្ខុ ជាព្រះយោគី គប្បីលែងឆាន់ នូវពំនូតទាំងឡាយ ៤, ៥ ពំនូត ហើយផឹកទឹក, ការបរិភោគតែប៉ុណ្ណោះ ល្មមគ្រប់គ្រាន់ហើយ ដើម្បីការនៅជាសុខសប្បាយ ដល់ភិក្ខុដែលមានចិត្តបញ្ជូនទៅហើយកាន់សមាធិ ។

*ការកំណត់នូវប្រយោជន៍ផង កិរិយាប្រតិបត្តិជាកណ្តាលផង គប្បីជ្រាបថា : ព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ដោយបាឋៈត្រឹមតែ ៣ បទនេះឯង ។*

*(២៧) ទីដេក និង ទីអង្គុយ ឈ្មោះថា សេនាសនៈ ។ ក៏ភិក្ខុ សិង*



*ក្នុងទីណាៗ, គឺវិហារក្តី ទីទាំងឡាយមានបង្អាជាដើមក្តី, ទីនោះៗ ឈ្មោះថា សេនៈ, ភិក្ខុអង្គុយ គឺគង់សម្រាក ក្នុងទីណាៗ, ទីនោះៗ ឈ្មោះថា អាសនៈ, ព្រោះរួមពាក្យទាំង ២ នោះ ចូលជាមួយគ្នា ទើបលោកហៅថា* “សេនាសនៈ” *។ ២ បទថា* “ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ” *សេចក្តីថា រដូវហ្នឹងឯង ហៅថា សេចក្តីអន្តរាយ ដែលកើតអំពីរដូវ ព្រោះអត្ថថា បៀតបៀន, (ភិក្ខុ សេពនូវសេនាសនៈ) ដើម្បីបន្ទោបង់នូវសេចក្តីអន្តរាយដែលកើតពីរដូវផង ដើម្បីការត្រេកអរទូទៅ ក្នុងទីជាទីគេចចេញអំពីពួកផង ។ ដូចមានសេចក្តីអធិប្បាយថា “រដូវណា ដែលមិនជាទីសប្បាយ ធ្វើនូវសេចក្តីបៀតបៀន និង សេចក្តីរាយមាយនៃចិត្ត ភិក្ខុ ត្រូវតែបន្ទោបង់ ដោយការសេពនូវសេនាសនៈ ដើម្បីបន្ទោបង់ នូវរដូវនោះផង ដើម្បីសេចក្តីសុខ នៃភាវៈរបស់បុគ្គលតែម្នាក់ឯងផង” ។ មែនពិត ការបន្ទោបង់នូវសេចក្តីអន្តរាយដែលកើតពីរដូវ ព្រះមានព្រះភាគ ត្រាស់ហើយហ្នឹងឯង ដោយពាក្យថា “ដើម្បីការពារនូវត្រជាក់” ដូច្នេះជាដើម ក៏ពិតមែនហើយ ប៉ុន្តែថា បណ្ឌិត គប្បីជ្រាបថា “ព្រះអង្គត្រាស់ពាក្យនេះ ក្នុងការសេពនូវសេនាសនៈនេះទៀត ព្រោះសំដៅយកការបន្ទោបង់ នូវសេចក្តីអន្តរាយ ដែលកើតអំពីរដូវ ដ៏ទៀង ប្រៀបដូចជាពាក្យដែលព្រះអង្គទ្រង់ត្រាស់ ក្នុងការសេពនូវចីវរថា “ការបិទបាំងនូវអវយវៈ ដែលញុំាងសេចក្តីអៀនខ្មាស ឲ្យកម្រើកជាប្រយោជន៍ទៀង, ប្រយោជន៍ទាំងឡាយឯទៀត រមែងមាន ក្នុងកាលខ្លះ” យ៉ាងនោះឯង ។*

*មួយវិញទៀត រដូវ មានប្រការដែលលោកពោលហើយនេះ ក៏គឺរដូវហ្នឹងឯង ។ ឯសេចក្តីអន្តរាយ មាន ២ យ៉ាង គឺ សេចក្តីអន្តរាយ*

ដែលប្រាកដច្បាស់១ សេចក្តីអន្តរាយដែលបិទបាំង១ ។ បណ្តាសេចក្តីអន្តរាយទាំង ២ យ៉ាងនោះ សេចក្តីអន្តរាយទាំងឡាយ មានសេចក្តីអន្តរាយដែលកើតពីសត្វសាហាវ មានសីហៈ និង ខ្លាធំ ជាដើម ហៅថា សេចក្តីអន្តរាយប្រាកដជាក់ច្បាស់, ឯសេចក្តីអន្តរាយទាំងឡាយ មានសេចក្តីអន្តរាយដែលកើតអំពីរាគៈ និង ទោសៈជាដើម ហៅថា សេចក្តីអន្តរាយដែលបិទបាំង ។ សេចក្តីអន្តរាយទាំងនោះ រមែងធ្វើនូវការបៀតបៀនមិនបាន ដោយការមិនគ្រប់គ្រងជុំវិញផង ដោយកិច្ចមានការឃើញរូប ដែលមិនជាទីសប្បាយផង ក្នុងទីសេនាសនៈណា, ភិក្ខុ កាលដឹងហើយ យ៉ាងដូច្នេះ ពិចារណា សេពនូវសេនាសនៈនោះ គប្បីជ្រាប ថា "ពិចារណា ដោយឧបាយហើយ ទើបសេពនូវសេនាសនៈ ។ល។ ដើម្បីបន្ទោបង់នូវសេចក្តីអន្តរាយដែលកើតអំពីរដូវ" ដូច្នេះ ។

(២៨) ក្នុងបទថា "**គិលានប្បច្ចយភេសជ្ជបរិក្ខារំ**" នេះ មានវិនិច្ឆ័យដូចតទៅ ។ ភេសជ្ជៈ ឈ្មោះថា បច្ច័យ ព្រោះអត្ថថា បណ្តេញចេញនូវរោគ, អធិប្បាយថា ព្រោះអត្ថថា ជាគ្រឿងបន្រ្កាបនូវរោគ ។ ពាក្យថា បច្ច័យនេះ គឺជាឈ្មោះ របស់ភេសជ្ជៈ ឯណាមួយ ដែលជាទីសប្បាយ ។ កម្មរបស់ពេទ្យ ឈ្មោះថា **ភេសជ្ជៈ** ព្រោះហេតុថា ភាវៈនៃភេសជ្ជៈ គឺពេទ្យនោះ អនុញ្ញាត្តហើយ ។ ថ្នាំគឺជាបច្ច័យ ដល់អ្នកជំងឺ ឈ្មោះថា គិលានប្បច្ច័យភេសជ្ជៈ ។ អធិប្បាយថាៈ កិច្ចការ របស់ពេទ្យ ដែលជាទីសប្បាយ ដល់អ្នកជំងឺ ណាមួយ ដូចជាប្រេង, ទឹកឃ្មុំ, ស្ករអំពៅជាដើម ។ ចំណែកគ្រឿងបរិវារ ព្រះមានព្រះភាគ ត្រាស់ថា "**បរិក្ខារ**" ក្នុងព្រះបាលីថា "នគរជារបស់ដែលគេបិទបាំងល្អហើយ [១]

១– សុ. អំ. ស. ភាគទី ៤៧ ទំព័រទី ១៩៤ ។



ដោយកំពែងជាគ្រឿងការពារនូវនគរទាំង ៧ " ដូច្នេះជាដើម ។ គ្រឿងអលង្ការ ត្រាស់ហៅថា "បរិក្ខារ" ក្នុងបាលីថា "រថ គឺអរិយមគ្គ មានសីល ជាគ្រឿងពាស មានឈាន ជាភ្លៅ មានសេចក្តីព្យាយាម ជាកង់ [១] " ដូច្នេះជាដើម ។ សម្ភារៈ ក៏ព្រះអង្គត្រាស់ថា "បរិក្ខារ" ក្នុងបាលីថា "បរិក្ខារ សម្រាប់ជីវិតនេះ ណានីមួយ គឺបព្វជិត ត្រូវតែប្រមូលយកមកដោយត្រឹមត្រូវ [២] " ដូច្នេះជាដើម ។ ក៏ក្នុងបទថា "**គិលានប្បច្ចយ-ភេសជ្ជបរិក្ខារោ**" នេះ រមែងគួរទាំងសម្ភារៈទាំងបរិវារ ។ មែនពិត ភេសជ្ជៈជាបច្ច័យដល់អ្នកជំងឺនោះ ឈ្មោះថា ជាបរិវារ (គ្រឿងបិទបាំង) ដល់ជីវិតបានផង ព្រោះរក្សាជីវិត មិនឲ្យចន្លោះ ដល់ការកើតឡើង នៃអាពាធដែលញុំាងជីវិតឲ្យវិនាស, ឈ្មោះថា ជាគ្រឿងគាំទ្រដល់ជីវិតបានផង ព្រោះជាគ្រឿងបណ្តាលធ្វើឲ្យជីវិតប្រព្រឹត្តទៅ បានយឺនយូរ (ទៀតផង) ព្រោះហេតុនោះ ភេសជ្ជៈ ជាបច្ច័យដល់អ្នកជំងឺនោះ លោកហៅថា "បរិក្ខារ" ។ ដូច្នេះ ភេសជ្ជៈជាបច្ច័យដល់អ្នកជំងឺនោះផង ជាគ្រឿងបរិក្ខារផង ព្រោះហេតុនោះ ទើបឈ្មោះថា គិលានប្បច្ចយភេសជ្ជបរិក្ខារ, (ភិក្ខុសេព)នូវគិលានប្បច្ចយភេសជ្ជបរិក្ខារនោះ ។ មានពាក្យអធិប្បាយថា "នូវគ្រឿងគាំទ្រដល់ជីវិតមានប្រេង, ទឹកឃ្មុំ, ស្ករអំពៅជាដើម ដែលគ្រូពេទ្យយល់ព្រមហើយ ដែលជាទីសប្បាយ ដល់អ្នកជំងឺណាមួយ" ។

បទថា "**ឧប្បន្នានំ**" ប្រែថា កើតហើយ មានហើយ កើតឡើងហើយ ។ ក្នុងបទថា "**វេយ្យាពាធិកានំ**" នេះ ការកំរើកធាតុ ឈ្មោះថា **ព្យាពាធ**, ឯរោគទាំងឡាយ មានរោគឃ្លង់, រោគបូស, រោគរលកកែវជាដើម ដែលមានការកំរើកធាតុនោះ ជាសមុដ្ឋាន ឈ្មោះថា **វេយ្យាពាធិកា**

១– សុ. សំ. ភាគទី ៣៧ ទំព័រ ១២ ។ ២– សុ. ម. ភាគទី ២០ ទំព័រ ៣៩៥ ។

(ជារោគប្រកបដោយការបៀតបៀនផ្សេងៗ) ព្រោះភាវៈនៃរោគនោះកើតឡើងហើយដោយការបៀតបៀនផ្សេងៗ ។ វេទនាដែលជាទុក្ខ គឺវេទនាដែលកើតអំពីអកុសលវិបាក ឈ្មោះថា វេទនា ។ នូវវេទនា ដែលប្រកបដោយការបៀតបៀនផ្សេងៗនោះ។ បទថា "អព្យាបជ្ឈបរមតាយ" សេចក្តីថា ដើម្បីជាអ្នកមិនមានសេចក្តីទុក្ខដ៏ក្រៃលែង ។ អធិប្បាយថា: សេចក្តីទុក្ខនោះ (មាន) ដរាបណា, ភិក្ខុ លះបង់សេចក្តីទុក្ខជាកម្មទាំងអស់ ដរាបនោះដែរ ។

សីលដែលមានការពិចារណា ដោយឧបាយនៃប្រាជ្ញា ជាមុនហើយទើបប្រើប្រាស់បច្ច័យ ជាលក្ខណៈនេះ បណ្ឌិត គប្បីជ្រាបថា "ឈ្មោះថាបច្ចយសន្និស្សិតសីល" ដោយសង្ខេប យ៉ាងដូច្នេះ ។ ចំណែកសេចក្តីនៃពាក្យ ក្នុងបទថា "បច្ចយសន្និស្សិតសីល" នេះ ដូចតទៅនេះ ។ ក៏សត្វទាំងឡាយ កាលទទួល អាស្រ័យ គឺបរិភោគ ប្រើប្រាស់នូវបច្ច័យទាំងឡាយ មានចីវរជាដើមនោះហើយ ទើបទៅបាន គឺ ដំណើរទៅបាន បានដល់ ទើបប្រព្រឹត្តទៅបាន ព្រោះហេតុណា ព្រោះហេតុនោះ (បច្ច័យមានចីវរជាដើមនោះ) ទើបលោកហៅថា "បច្ច័យ" ។ សីលណា អាស្រ័យ នូវបច្ច័យទាំងឡាយនោះ ព្រោះហេតុនោះ សីលនោះ ទើបឈ្មោះថា បច្ចយសន្និស្សិតសីល ។

(២៩) គប្បីជ្រាបសាធនៈ (ហេតុឲ្យសម្រេច) ក្នុងសីល ៤ យ៉ាងនេះ ដូចតទៅ ភិក្ខុ គប្បីញុំាងបាតិមោក្ខសំវរសីល ឲ្យដល់ព្រម ដោយសទ្ធា ។ ព្រោះបាតិមោក្ខសំវរសីលនោះ សម្រេចដោយសទ្ធា ព្រោះភាវៈនៃការបញ្ញត្តិសិក្ខាបទ ជាការកន្លងនូវវិស័យនៃព្រះសាវក ។ ពិតមែនហើយ ការត្រាស់ហាមនូវកិរិយាទូលសុំ ឲ្យព្រះអង្គបញ្ញត្តសិក្ខាបទ



ជានិទស្សនៈ ក្នុងបាតិមោក្ខសំវរសីលនេះ ។ ហេតុនោះ បាតិមោក្ខសំវរសីលនោះ ភិក្ខុអ្នកសមាទានសិក្ខាបទ ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តហើយ យ៉ាងណា មិនឲ្យសេសសល់ដោយសទ្ធា ហើយមិនធ្វើនូវការអាឡោះអាល័យ សូម្បីក្នុងជីវិត ត្រូវតែបំពេញឲ្យបរិបូណ៌ ដោយប្រពៃ ។ សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា :

> បក្សីត្រដេវរិច ស៊ូប្រថុយលះបង់ជីវិតរក្សានូវពង យ៉ាងណា មេម្រឹគចាមរី ស៊ូប្រថុយលះបង់ជីវិត រក្សានូវរោមកន្ទុយ យ៉ាងណា កុដុម្ពីក៏មានកូនសំឡាញ់តែមួយ រក្សានូវកូន យ៉ាងណា បុរសមានភ្នែកម្ខាង រក្សានូវភ្នែកមួយ យ៉ាងណា, លោកទាំងឡាយ ចូររក្សានូវសីល របស់ខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តឲ្យណាស់ ចូរប្រកបដោយសេចក្តីគោរព សព្វ ៗ កាល (ឲ្យដូចជាបក្សី ត្រដេវរិចរក្សាពងជាដើម) យ៉ាងដូច្នោះចុះ ។

សូម្បីព្រះតម្រាស់ដទៃទៀត ក៏ព្រះអង្គទ្រង់ត្រាស់ហើយដែរ(ថា) ។ មហាសមុទ្រ ឋិតនៅជាធម្មតា មិនកន្លងហួសច្រាំងទៅបាន យ៉ាងណាមិញ, បពិត្រមហារាជព្រះនាមបហារាទៈ ពួកសាវករបស់តថាគត ក៏យ៉ាងនោះដែរ មិនប្រព្រឹត្តកន្លងសិក្ខាបទនោះ ដែលតថាគតបានបញ្ញត្តហើយ ដល់ពួកសាវក សូម្បីព្រោះហេតុនៃជីវិតឡើយ [១] ។ ក៏ក្នុងសេចក្តីអធិប្បាយនេះ គប្បីជ្រាបរឿងព្រះថេរៈទាំងឡាយ ដែលត្រូវចោរចងហើយ ក្នុងដងព្រៃ (ជាឧទាហរណ៍) ។

---

១- សុ. អំ. អ. ភាគទី ៤៨ ទំព័រទី ៩៣ ។

បានឮមកថា ពួកចោរបានយកវល្លិប្រេងចងផ្តែកព្រះថេរៈ ក្នុងដងព្រៃឈ្មោះមហាវត្តនិ ។ ព្រះថេរៈសិងនៅដដែលនុ៎ះឯង ចំរើនវិបស្សនាអស់ ៧ ថ្ងៃ ក៏បានសម្រេចព្រះអនាគាមិផល ធ្វើមរណកាល ក្នុងទីនោះឯង ហើយបានទៅកើតក្នុងព្រហ្មលោក ។ ចោរទាំងឡាយបានយកវល្លិផោម មកចងផ្តែកព្រះថេរៈដទៃទៀត ក្នុងតម្ពបណ្ណិទ្វីប ។ ព្រះថេរៈនោះកាលបើភ្លើងព្រៃរាលឆេះមកដល់ ក៏មិនផ្តាច់វល្លិសោះឡើយ ផ្តើមចំរើនវិបស្សនា រហូតដល់បានសម្រេចជាព្រះអរហន្តសមសីសី ហើយក៏បរិនិព្វាន ។ ព្រះទីឃភាណកអភយត្ថេរ កាលនិមន្ត ទៅជាមួយនឹងភិក្ខុ ៥០០ អង្គ បានឃើញហើយ ក៏ឲ្យបូជាសរីរៈរបស់ព្រះថេរៈហើយ ឲ្យសាងព្រះចេតិយ (សំរាប់បញ្ចុះអដ្ឋិធាតុ) ។

ព្រោះហេតុនោះហើយ កុលបុត្រអ្នកមានសទ្ធាដទៃទៀត

> កាលជម្រះនូវបាតិមោក្ខ គប្បីស៊ូប្រថុយជីវិត មិនគប្បីទំលាយនូវការសង្រួម ក្នុងសីល ដែលព្រះលោកនាថទ្រង់ត្រាស់បញ្ញត្តហើយ ។

ប្រៀបឧបមាដូចជាបាតិមោក្ខសំវរសីល ភិក្ខុគប្បីឲ្យដល់ព្រមដោយសទ្ធា យ៉ាងណាមិញ, ឥន្ទ្រិយសំវរសីល ក៏ភិក្ខុគប្បីឲ្យដល់ព្រមដោយសតិ ក៏យ៉ាងនោះដែរ ។ មែនពិត ឥន្ទ្រិយសំវរសីលនោះ មានសតិជាគ្រឿងឲ្យសម្រេច ព្រោះឥន្ទ្រីយ៍ទាំងឡាយ ដែលតម្កល់នៅស៊ប់ល្អហើយ ដោយសតិ មិនមែនជាប្រហោង ដែលទោសទាំងឡាយ មានអភិជ្ឈាជាដើម គប្បីចូលមកបានឡើយ ។ ព្រោះហេតុដូច្នោះ ឥន្ទ្រិយ-សំវរសីលនោះ ភិក្ខុកាលរលឹកឃើញ នូវអាទិត្តបរិយាយសូត្រ ដោយ



ន័យថា "ម្នាលភិក្ខុទាំងឡាយ [១] ចក្ខុន្ទ្រីយ៍ដែលភិក្ខុអាលហើយដោយបន្ទះដែកដែលក្តៅហើយ ដែលភ្លើងឆេះសព្វហើយ ដែលភ្លើងឆេះសន្ធោសន្ធៅហើយ មានអណ្តាតភ្លើងតែមួយ ប្រសើរជាង, ចំណែកការកាន់យកនូវនិមិត្ត ដោយអនុព្យញ្ជនៈ ក្នុងរូបទាំងឡាយ ដែលបុគ្គលគប្បីដឹងដោយចក្ខុ មិនប្រសើរសោះឡើយ" ដូច្នេះជាដើមហើយ, កាលបើវិញ្ញាណ ប្រព្រឹត្តទៅតាមទ្វារមានចក្ខុទ្វារជាដើម ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម, ហាមឃាត់នូវកិរិយាកាន់យកមានការកាន់យកនូវនិមិត្តជាដើម ដែលជាផ្លូវ គឺទោសទាំងឡាយ មានអភិជ្ឈាជាដើម គប្បីចូលមកបាន ដោយសតិ ដែលមិនវង្វេងវង្វន់កាន់ប្រឡំ គប្បីធ្វើឲ្យបានសម្រេច ដោយស្រួលបួលចុះ ។

ព្រោះថា កាលបើឥន្ទ្រិយសំវរសីលនោះ គឺភិក្ខុមិនបានធ្វើ ឲ្យសម្រេច យ៉ាងនេះហើយ សូម្បីបាតិមោក្ខសំវរសីល ក៏ជាសីលមិនឋិតនៅយឺនយូរ មិនតាំងនៅអស់កាលដ៏យូរបានឡើយ ប្រៀបដូចជាសន្ទូងដែលគេមិនបានធ្វើរបងហ៊ុមព័ទ្ធហើយ ក៏មិនអាចរស់នៅបានយូរ យ៉ាងដូច្នោះឯង ។ ក៏ភិក្ខុ ដែលមិនធ្វើឥន្ទ្រិយសំវរសីល ឲ្យបានសម្រេចនេះជាអ្នកត្រូវចោរ គឺកិលេសទាំងឡាយបៀតបៀន ដូចជាស្រុកដែលមានទ្វារ បើកចំហ ក៏ត្រូវពួកចោរនាំយកទ្រព្យបុគ្គលដទៃ បៀតបៀនបានយ៉ាងដូច្នោះឯង ។ មួយទៀត រាគៈ រមែងចាក់ទម្លុះនូវចិត្ត របស់ភិក្ខុនោះ ដូចជាតំណក់ទឹកភ្លៀង លេចស្រោចនូវផ្ទះដែលគេប្រក់មិនបានល្អហើយ ក៏យ៉ាងដូច្នោះឯង ។

សមដូចព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា :

---

១- សុ. សំ. ស. ភាគទី ៣៥ ទំព័រទី ៣៨៤ ។

ភិក្ខុ រក្សានូវឥន្ទ្រីយ៍ ក្នុងរូប សំឡេង រស ក្លិន និង ក្នុងផស្សៈទាំងឡាយ ព្រោះថា ទ្វារទាំងឡាយនេះដែលបើកចំហ មិនបានរក្សាហើយ រមែងបៀតបៀន ដូចជាពួកចោរលួចទ្រព្យអ្នកដទៃ បៀតបៀនស្រុក ដែលមានទ្វារបើកចំហចោលដូច្នោះដែរ ។ តំណក់ទឹកភ្លៀង រមែងលេចស្រោច នូវផ្ទះដែលបុគ្គលប្រក់បាំងហើយមិនល្អ យ៉ាងណាមិញ, រាគៈ តែងចាក់ទម្លុះនូវចិត្ត ដែលបុគ្គលមិនបានអប់រំហើយ ក៏យ៉ាងដូច្នោះដែរ ។

តែថា កាលបើឥន្ទ្រិយសំវរសីលនោះ ភិក្ខុធ្វើឲ្យបានសំរេចហើយ សូម្បីបាតិមោក្ខសំវរសីល ក៏ជាសីលឋិតនៅយឺនយូរ ជាសីលតាំងនៅអស់កាលដ៏យូរបាន ប្រៀបដូចសន្ទូង ដែលគេបានធ្វើរបងហ៊ុមព័ទ្ធបានល្អហើយ ក៏អាចរស់នៅបានយូរ យ៉ាងដូច្នោះឯង ។ ក៏ភិក្ខុ ដែលធ្វើឥន្ទ្រិយសំវរសីល ឲ្យបានសម្រេចនេះ ជាអ្នកត្រូវចោរ គឺកិលេសទាំងឡាយបៀតបៀនមិនបាន ដូចជាស្រុកដែលមានទ្វារ បិទបាំងល្អហើយ ក៏ត្រូវពួកចោរនាំយកទ្រព្យបុគ្គលដទៃ បៀតបៀនមិនបាន ក៏យ៉ាងដូច្នោះឯង ។ មួយវិញទៀត រាគៈ រមែងចាក់ទម្លុះនូវចិត្ត របស់ភិក្ខុនោះមិនបាន ប្រៀបដូចជាតំណក់ទឹកភ្លៀង លេចស្រោចមិនបាននូវផ្ទះដែលគេប្រក់បាំងជិតល្អហើយ យ៉ាងដូច្នោះ ។

សមដូចជាព្រះតម្រាស់ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ ថា :

ភិក្ខុ រក្សានូវឥន្ទ្រីយ៍ ក្នុងរូប សំឡេង រស ក្លិន និង ក្នុងផស្សៈទាំងឡាយ ព្រោះថា ទ្វារទាំងឡាយនេះ ដែល



ភិក្ខុបិទរក្សាល្អហើយ រមែងបៀតបៀនមិនបាន ដូចជាពួកចោរលួចទ្រព្យអ្នកដទៃ បៀតបៀនស្រុកដែលមានទ្វារបិទល្អហើយមិនបានដូច្នោះដែរ ។ តំណក់ទឹកភ្លៀងរមែងលេចស្រោចមិនបាន នូវផ្ទះដែលបុគ្គលប្រក់បាំងល្អហើយ យ៉ាងណាមិញ, រាគៈ តែងចាក់ទម្លុះ នូវចិត្តដែលបុគ្គលអប់រំល្អហើយមិនបាន យ៉ាងដូច្នោះដែរ ។

ក៏ទេសនានេះ ជាទេសនាដ៏ឧក្រិដ្ឋក្រៃលែង ។

(៣០) ធម្មតាចិត្តនេះ ជាធម្មជាតប្រព្រឹត្តទៅ យ៉ាងឆាប់រហ័ស ព្រោះហេតុនោះ ឥន្ទ្រិយសំវរៈ ភិក្ខុគប្បីបន្ទោបង់នូវរាគៈ ដែលកើតឡើងហើយ ដោយធ្វើទុកក្នុងចិត្ត នូវអសុភកម្មដ្ឋាន ហើយធ្វើឲ្យដល់ព្រម ដូចព្រះវង្គីសត្ថេរ អ្នកបួសហើយ អស់កាលមិនយូរ ។

(រឿងព្រះវង្គីសត្ថេរ)

បានឮមកថា កាលព្រះថេរៈបួសហើយអស់កាលមិនយូរ ត្រាច់ទៅដើម្បីបិណ្ឌបាត, រាគៈ កើតឡើង ព្រោះឃើញស្ត្រីម្នាក់ ។ ក្នុងគ្រានោះ លោកក៏បានទូលដល់ព្រះអានន្ទ ថា :

ខ្ញុំព្រះករុណា ក្តៅក្រហាយដោយកាមរាគៈ ចិត្ត របស់ខ្ញុំព្រះករុណា តែងរោលរាល បពិត្រព្រះអានន្ទគោតមគោត្រ ដូចជាខ្ញុំព្រះករុណាសូមអង្វរ, សូមលោកម្ចាស់មេត្តាប្រាប់នូវឧបាយជាគ្រឿងរំលត់ នូវសេចក្តីក្តៅរោលរាល ដោយសេចក្តីអនុគ្រោះផងចុះ ។

ព្រះថេរៈ ពោល ថា :

> ចិត្ត របស់លោក តែងរោលរាល ព្រោះវិបល្លាសចាក សញ្ញា, ចូរលោកវៀរឲ្យស្រឡះ នូវសុភនិមិត្ត ដែលជាហេតុនាំឲ្យកើតរាគៈ ចូរលោកអប់រំចិត្ត ឲ្យតាំងនៅបានល្អ ធ្វើឲ្យមានអារម្មណ៍តែមួយ ដោយអសុភសញ្ញា ចូរលោកឃើញនូវសង្ខារទាំងឡាយ ដោយថាជារបស់ដទៃ (មិនទៀងទាត់) ផង ដោយថា ជាទុក្ខផង ដោយថា មិនមែនជារបស់ខ្លួនផង ចូររំលត់នូវរាគៈធំ ឲ្យអស់ទៅ កុំឲ្យជាអ្នក គឺរាគៈដុតរោលរាលញយៗ ឡើយ [១] ។

*ព្រះថេរៈ លុះបន្ទោបង់រាគៈបានហើយ ក៏ត្រាច់ទៅ ដើម្បីបិណ្ឌបាត ។*

*ន័យមួយទៀត ភិក្ខុគប្បីជាអ្នកបំពេញនូវឥន្ទ្រិយសំវរៈ ឲ្យដូចជាព្រះចិត្តគុត្តត្ថេរ អ្នកនៅក្នុងមហាគុហា ឈ្មោះកុរណ្ឌកៈ និង ដូចជាព្រះមហាមិត្តត្ថេរ អ្នកនៅក្នុងចោរកមហាវិហារជាប្រក្រតីផង ។*

(រឿងព្រះចិត្តគុត្តត្ថេរ)

*បានឮមកថា មានរូបគំនូរនៃអភិនិស្រ្កមន៍ របស់ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ជាទីមនោរម្យ នៅក្នុងមហាគុហាឈ្មោះ កុរណ្ឌកៈ ។ ពួកភិក្ខុច្រើនរូប កាលនិមន្តទៅកាន់ទីចារិកនៃសេនាសនៈ ឃើញរូបគំនូរក៏ពោលថា "បពិត្រលោកម្ចាស់ ចិត្តកម្ម ជាទីរីករាយនៃចិត្ត" ។ ព្រះថេរៈ ពោលថា "ម្នាលលោកដ៏មានអាយុទាំងឡាយ កាលដែលខ្ញុំរស់នៅក្នុងគុហា អស់កាលជាង ៦០ ឆ្នាំ មិនដឹងថាៈ រូបគំនូរមាន ឬក៏មិនមានទេ ។ ឥឡូវនេះ ទើបតែថ្ងៃនេះទេ ខ្ញុំទើបនឹងដឹង (ថា មាន)*

*១- សុ. សំ. សគ. ភាគទី ៣០ ទំព័រទី ១៥៨ ។*



*ព្រោះអាស្រ័យលោកទាំងឡាយដែលមានចក្ខុ" ។*

*បានឮមកថា ព្រះថេរៈនៅអស់កាលប្រមាណប៉ុណ្ណោះ មិនធ្លាប់បើកភ្នែកក្រឡេកមើលគុហាទេ ។ ចំណែកខាងក្បែរទ្វារគុហានៃព្រះថេរៈនោះ មានដើមខ្លឹងធំផងដែរ ។ មហានាគព្រឹក្សនោះ ក៏ព្រះថេរៈមិនធ្លាប់ងើយមើលឮដ៏ខាងលើឡើយ ។ ព្រះថេរៈ ទាល់តែឃើញលំអងកេសរ ធ្លាក់លើផែនដី រៀងរាល់ឆ្នាំ ទើបដឹងថា ដើមមហានាគនោះមានផ្កាហើយ ។*

*ព្រះរាជា ទ្រង់ព្រះសណ្ដាប់ នូវគុណសម្បត្តិ របស់ព្រះថេរៈហើយ ទ្រង់មានព្រះបំណងនឹងថ្វាយបង្គំ ទើបទ្រង់បញ្ជូននូវព្រះរាជសារ អស់វារៈ ៣ ដង, កាលបើព្រះថេរៈ មិននិមន្តមក, ទើបទ្រង់ត្រាស់បញ្ជាឲ្យគេចងដោះទាំងឡាយ នៃពួកស្ត្រីដែលមានកូនខ្ចី ក្នុងស្រុកនោះហើយ ទ្រង់បញ្ជាឲ្យរាជអាមាត្យ ប្រថាប់ត្រាថា "ព្រះថេរៈ មិនទាន់និមន្តមក ដរាបណា, ពួកទារក កុំបានឡើយនូវទឹកដោះស្រស់ ដរាបនោះដែរ" ។*

*ព្រះថេរៈ បាននិមន្តទៅកាន់ស្រុកធំហើយ ដើម្បីអនុគ្រោះដល់ពួកទារក ។ ព្រះរាជា ទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ត្រាស់ថា "នែប្រស្ដេងទាំងឡាយ! ពួកអ្នក ចូរទៅនិមន្តឲ្យព្រះថេរៈចូលមកចុះ ខ្ញុំនឹងទទួលនូវសីលទាំងឡាយ" ហើយទ្រង់ត្រាស់ឲ្យពួកអាមាត្យ នាំព្រះថេរៈទៅ ខាងក្នុងនៃព្រះរាជវាំង ទ្រង់ថ្វាយបង្គំព្រះថេរៈហើយ ប្រគេនចង្ហាន់ ឲ្យព្រះថេរៈឆាន់ ទើបត្រាស់ថា "បពិត្រលោកម្ចាស់ដ៏ចំរើន ថ្ងៃនេះ មិនមានឱកាសទេ ខ្ញុំព្រះកុណា នឹងទទួលសីលក្នុងថ្ងៃស្អែក" ដូច្នេះហើយ ទ្រង់កាន់យកបាត្ររបស់ព្រះថេរៈ ជូនទៅបានតែបន្តិចហើយ ទ្រង់ថ្វាយបង្គំត្រឡប់មកវិញ ជាមួយនឹងព្រះនាងទេវី ។ ព្រះរាជា ទ្រង់ថ្វាយបង្គំក្ដី ព្រះនាងទេវី ទ្រង់ថ្វាយបង្គំក្ដី, ព្រះថេរៈ ពោលថា "បពិត្រព្រះមហារាជ*

*សូមទ្រង់មានសេចក្តីសុខចុះ” ។ ថ្ងៃទាំងឡាយ ៧ បានកន្លងទៅហើយយ៉ាងនេះ ។ ភិក្ខុទាំងឡាយសួរថា: បពិត្រលោកម្ចាស់ដ៏ចំរើន ហេតុអ្វីកាលដែលព្រះរាជាថ្វាយបង្គំក្តី ព្រះនាងទេវី ថ្វាយបង្គំក្តី, លោកម្ចាស់ពោល យ៉ាងដូច្នេះ ថា “បពិត្រព្រះមហារាជ! សូមទ្រង់មានសេចក្តីសុខចុះ?” ។ ព្រះថេរៈ ពោលថា “ម្នាលលោកដ៏មានអាយុទាំងឡាយ ខ្ញុំមិនបានធ្វើនូវការកំណត់ថា: ព្រះរាជា ឬ ព្រះនាងទេវី យ៉ាងដូច្នេះទេ” ក្នុងពេលកន្លងទៅបាន ៧ ថ្ងៃ ត្រូវព្រះរាជា បើកឱកាស ឲ្យនិមន្តទៅហើយ ដោយព្រះតម្រាស់ថា “ការនៅក្នុងទីនេះ ពិតជាមានការលំបាកដល់ព្រះថេរៈ” ដូច្នេះហើយ ក៏និមន្តទៅកាន់មហាគុហា ឈ្មោះ កុរណ្ឌកៈ ហើយឡើងកាន់ទីចង្ក្រម ក្នុងចំណែកនៃរាត្រី ។*

*ទេវតា ដែលអាស្រ័យនៅលើដើមខ្នុង បានឈរទ្រោលនូវប្រទីបមានដង ។ ក្នុងគ្រានោះ កម្មដ្ឋាន របស់ព្រះថេរៈ បានបរិសុទ្ធប្រាកដយ៉ាងក្រៃលែង ។ ព្រះថេរៈ មានចិត្តរីករាយ ដោយគិតថា “ព្រោះហេតុអ្វីហ្ន៎! ក្នុងថ្ងៃនេះ កម្មដ្ឋាន របស់អាត្មាអញ ប្រាកដ យ៉ាងក្រៃលែងម្ល៉េះ” ញុំាងភ្នំទាំងមូលឲ្យខ្ទរខ្ទារហើយ ក៏បានសម្រេចព្រះអរហត្ត ក្នុងចន្លោះនៃមជ្ឈិមយាម ។ ហេតុនោះ កុលបុត្រឯទៀត អ្នកប្រាថ្នាប្រយោជន៍*

មិនគប្បីជាអ្នកមានភ្នែករលីមរលោម ដូចជាសត្វស្វានៅ
ក្នុងព្រៃ ដូចជាសត្វម្រឹគភ្ញាក់ផ្អើល ក្នុងព្រៃ និង ដូចជា
កូនក្មេង ដែលមានចិត្តតក់ស្លុតហើយផង គប្បីចោលនូវ
ភ្នែកទាំងឡាយចុះក្រោម ជាអ្នកមានការសំឡឹងមើល
ត្រឹមតែមួយជួរនឹម មិនគប្បីជាអ្នកលុះនូវអំណាច នៃចិត្ត
ដែលរលីមរលោម ដូចជាសត្វស្វាព្រៃឡើយ ។



*មួយទៀត រោគបូសប្រកបដោយពិស កើតឡើង ដល់មាតារបស់ព្រះមហាមិត្តត្ថេរ ។ ចំណែកកូនស្រីរបស់មាតា នៃព្រះថេរៈនោះក៏ជាអ្នកបួសហើយ ក្នុងសំណាក់នៃពួកនាងភិក្ខុនី ។ មាតានោះ និយាយទៅកាន់នាងភិក្ខុនីនោះថា “បពិត្រនាងជាម្ចាស់ ចូរនាងទៅកាន់សំណាក់បង ចូរប្រាប់ថា ខ្ញុំមិនសប្បាយ ហើយនាំយកថ្នាំមក” ។ នាងភិក្ខុនីនោះបានទៅប្រាប់ហើយ ។ ព្រះថេរៈ ពោលថា “ខ្ញុំមិនចេះផ្សំថ្នាំផ្សេងៗមានថ្នាំឫសឈើជាដើមហើយ ចំអិនធ្វើថ្នាំទេ, តែថា ខ្ញុំនឹងប្រាប់នូវថ្នាំដល់នាង, ខ្ញុំបួសហើយ អំពីកាលណា ចាប់ដើមអំពីកាលនោះមក ខ្ញុំមិនធ្លាប់មានចិត្តប្រកប ដោយលោភៈ ហើយទំលាយ នូវឥន្ទ្រីយ៍ទាំងឡាយ រមិលមើលរូបដែលមានចំណែកមិនស្មើគ្នាទេ, ដោយសច្ចវាចានេះ សូមសេចក្តីសប្បាយកើតមាន ដល់មាតារបស់ខ្ញុំ, ចូរនាងទៅ ចូរពោលពាក្យនេះហើយ បបោសអង្អែលសរីរៈនៃឧបាសិកាចុះ” ។ ភិក្ខុនីនោះទៅប្រាប់សេចក្តីនោះហើយ បានធ្វើតាមដែលព្រះថេរៈប្រាប់ ។ ក្នុងខណៈនោះឯង រោគបូសរបស់ឧបាសិកា ក៏រលាយបាត់អស់ហើយ ដូចជាដុំនៃពពុះទឹក ។ ឧបាសិកានោះ ក្រោកឡើងហើយ បានបញ្ចេញនូវវាចា ជាទីរីករាយសប្បាយចិត្ត ថា “បើព្រះសម្មាសម្ពុទ្ធ គប្បីទ្រង់ព្រះធរមាននៅឡើយ ហេតុអ្វី ព្រះអង្គនឹងមិនទ្រង់បបោសអង្អែល នូវព្រះសិរៈ របស់ភិក្ខុ ប្រាកដដូចជាកូន របស់អញ ដោយព្រះហស្ត មានបណ្តាញដ៏វិចិត្រន៎ុះ” ដូច្នេះ ។ ព្រោះហេតុដូច្នោះ*

សូម្បីភិក្ខុដទៃទៀត អ្នកមានសេចក្តីសំគាល់នូវខ្លួនថា ជា
កុលបុត្រ បួសហើយ ក្នុងព្រះសាសនា គប្បីឋិតនៅ ក្នុង
ការសង្រួមឥន្ទ្រីយ៍ដ៏ប្រសើរ ឲ្យដូចជាព្រះមិត្តត្ថេរចុះ ។

ក៏ឥន្ទ្រិយសំវរៈ ភិក្ខុគប្បីឲ្យដល់ព្រមដោយសតិ យ៉ាងណាមិញ, អាជីវបារិសុទ្ធិ ក៏ភិក្ខុ គប្បីឲ្យដល់ព្រម ដោយវីរិយៈ យ៉ាងដូច្នោះដែរ ។ ក៏អាជីវបារិសុទ្ធិនោះ សម្រេចដោយវីរិយៈ ព្រោះថា សេចក្ដីព្យាយាម ដែលភិក្ខុបានប្រារព្ធហើយ ដោយប្រពៃ ជាហេតុឲ្យមានការលះបង់ នូវមិច្ឆាជីវៈ ។ ព្រោះហេតុនោះ អាជីវបារិសុទ្ធិនោះ ភិក្ខុគប្បីលះបង់នូវអនេសនៈ ដែលមិនសមគួរហើយ សេពចំពោះតែបច្ច័យទាំងឡាយ ដែលកើតឡើង ដោយសេចក្ដីបរិសុទ្ធិប៉ុណ្ណោះ វៀរចាកនូវបច្ច័យទាំងឡាយ ដែលកើតឡើង ដោយសេចក្ដីមិនបរិសុទ្ធិ ដែលប្រៀបដូចជាអសិរ្ពិស គប្បីឲ្យដល់ព្រម ដោយការស្វែងរក ដោយប្រពៃ មានការត្រាច់ទៅបិណ្ឌបាតជាដើម ដោយសេចក្ដីព្យាយាម ។

បណ្ដាបច្ច័យដែលកើតឡើងបរិសុទ្ធ និង មិនបរិសុទ្ធទាំង ២ នោះ ក៏បច្ច័យទាំងឡាយដែលកើតឡើងហើយ ដល់ភិក្ខុអ្នកមានធុតង្គ មិនបានរក្សាហើយ អំពីសំណាក់សង្ឃ ឬ អំពីគណៈក្ដី អំពីសំណាក់នៃគ្រហស្ថទាំងឡាយ ដែលជ្រះថ្លាហើយ ដោយគុណទាំងឡាយ មានការសំដែងធម៌ របស់ភិក្ខុនោះក្ដី ឈ្មោះថា បច្ច័យដែលកើតឡើង ដោយសេចក្ដីបរិសុទ្ធិ, ចំណែកឯបច្ច័យទាំងឡាយ ដែលកើតឡើងហើយ ដោយការស្វែងរកទាំងឡាយ មានកិរិយាត្រាច់ទៅបិណ្ឌបាតជាដើម ឈ្មោះថា បច្ច័យដែលកើតឡើង ដោយសេចក្ដីបរិសុទ្ធិ យ៉ាងក្រៃលែង ។

បច្ច័យ ដែលកើតឡើងហើយ ដល់ភិក្ខុអ្នកមានធុតង្គរក្សាហើយ អំពីការស្វែងរកមានកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាតជាដើម និង អំពីសំណាក់នៃជនទាំងឡាយដែលជ្រះថ្លាហើយ ក្នុងធុតង្គគុណ របស់ភិក្ខុនោះ ដោយអនុលោមនូវការកំណត់ធុតង្គ ឈ្មោះថា បច្ច័យដែលកើត



ឡើង ដ៏បរិសុទ្ធ ។ ក៏កាលបើផ្លែសម៉ដែលបុគ្គលត្រាំហើយ ដោយទឹកមូត្រស្អុយ និង វត្ថុដែលមានរសជាតផ្អែម ៤ យ៉ាង កើតឡើងហើយ ដល់ភិក្ខុនោះ ដើម្បីរម្ងាប់នូវព្យាធិណាមួយ ការសមាទានធុតង្គ របស់ភិក្ខុដែលគិតថា "សូម្បីភិក្ខុដទៃ ដែលជាសព្រហ្មចារី នឹងឆាន់នូវវត្ថុមានរសជាតផ្អែម ៤ មុខ" ដូច្នេះ ហើយឆាន់ចំណិត នៃផ្លែសម៉តែម្យ៉ាង ជាការសមាទានដ៏សមគួរ ។ មែនពិត ភិក្ខុរូបនេះ លោកហៅថា "ភិក្ខុអ្នកតាំងនៅ ក្នុងវង្សនៃព្រះអរិយៈដ៏ឧត្ដម" ។

ក៏បច្ច័យទាំងឡាយ មានចីវរបច្ច័យជាដើមនេះឯណា, បណ្ដាបច្ច័យទាំងឡាយនោះ ក្នុងចីវរ និង បិណ្ឌបាត និមិត្តកម្ម, ឱភាសកម្ម, បរិកថា និង វិញ្ញត្តិទាំងឡាយ រមែងមិនសមគួរ ដល់ភិក្ខុគ្រប់រូបដែលកំពុងជម្រះនូវអាជីវៈ, ក៏ប៉ុន្តែ ក្នុងសេនាសនៈ និមិត្តកម្ម, ឱភាសកម្ម និង បរិកថា រមែងសមគួរ ដល់ភិក្ខុអ្នកដែលមិនបានរក្សានូវធុតង្គ ។

បណ្ដានិមិត្តកម្ម, ឱភាសកម្ម, បរិកថា និង វិញ្ញត្តិ ទាំងនោះ កាលបើពួកគ្រហស្ថ ពោល ថា "បពិត្រលោកម្ចាស់ដ៏ចំរើន តើលោកម្ចាស់ធ្វើអ្វី? អ្នកណា ប្រើឲ្យលោកម្ចាស់ធ្វើ?" ដូច្នេះ, ពាក្យតបថា "មិនមានអ្នកណាឲ្យធ្វើទេ" ដូច្នេះ របស់ភិក្ខុ ដែលធ្វើនូវកិច្ចទាំងឡាយ មានការសំអាតផែនដីជាអាទិ៍ ដើម្បីសេនាសនៈ ឈ្មោះថា និមិត្តកម្ម, មួយវិញទៀត ពាក្យឯណាដទៃទៀត ដែលមានសភាពបែបនេះ (ពាក្យនោះ) ឈ្មោះថា និមិត្តកម្ម ។

កាលបើភិក្ខុ ពោលថា "ម្នាលឧបាសក និង ឧបាសិកាទាំងឡាយ អ្នកទាំងឡាយនៅក្នុងទីណា?" ដូច្នេះ, កាលបើឧបាសក និង ឧបាសិកាទូលថា "នៅក្នុងប្រាសាទ លោកម្ចាស់" ដូច្នេះ, ពាក្យដែលភិក្ខុពោល

ហើយថា “ម្នាលឧបាសក និង ឧបាសិកាទាំងឡាយ ចំណែកប្រាសាទមិនសមគួរដល់ភិក្ខុទាំងឡាយទេ” ដូច្នេះ, ឈ្មោះថា ឱភាសកម្ម, ម្យ៉ាងវិញទៀត ពាក្យឯណាដទៃទៀត ដែលមានសភាពបែបនេះ (ពាក្យនោះ) ឈ្មោះថា ឱភាសកម្ម ។

ពាក្យដែលភិក្ខុពោល ថា “សេនាសនៈ នៃភិក្ខុសង្ឃចង្អៀត” ឈ្មោះថា បរិកថា ឬក៏ វាចាជាហេតុពោលណាដទៃទៀត មានសភាពបែបនេះ (វាចាជាហេតុពោលនោះ) ឈ្មោះថា បរិយាយកថា ។

ពាក្យទាំងអស់ហ្នឹងឯង គួរក្នុងភេសជ្ជៈ ។ តែបើភេសជ្ជៈ កើតឡើងហើយ ដោយប្រការដូច្នេះ, កាលបើរោគ ស្ងប់រម្ងាប់ហើយ, ភិក្ខុឆាន់មិនគួរទេ ។ ក្នុងរឿងភេសជ្ជៈដែលកើតឡើងយ៉ាងនេះនោះ ភិក្ខុអ្នកទ្រទ្រង់នូវព្រះវិន័យទាំងឡាយ ពោលថា “ទ្វារ គឺព្រះមានព្រះភាគទ្រង់ត្រាស់ប្រទានឲ្យហើយ, ព្រោះហេតុនោះ ភិក្ខុឆាន់ភេសជ្ជៈគួរ” ដូច្នេះ ។ ចំណែកពួកភិក្ខុអ្នកសិក្សាព្រះសូត្រ ពោលយ៉ាងនេះថា “អាបត្តិ មិនមាន (ដល់ភិក្ខុ) ក៏ពិតមែនហើយ, តែថា ភិក្ខុ ញ៉ាំងអាជីវៈឲ្យកម្រើក, ព្រោះហេតុនោះ ភិក្ខុឆាន់ភេសជ្ជៈ មិនគួរទេ” ។ តែបើភិក្ខុណា មិនធ្វើនូវនិមិត្តកម្ម, ឱភាសកម្ម, បរិកថា និង វិញ្ញត្តិទាំងឡាយ សូម្បីព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ អាស្រ័យនូវគុណមានការប្រាថ្នាតិចជាដើមតែម្យ៉ាង, សូម្បីក្នុងកាលជាទីអស់ទៅនៃជីវិត កើតឡើងប្រាកដហើយក៏ដោយ, ក៏ប្រើប្រាស់នូវបច្ច័យ ដែលកើតឡើងហើយតែប៉ុណ្ណោះ វៀរលែងចាកកម្ម ដែលជាហេតុធ្វើអាជីវៈ ឲ្យកម្រើក មានឱភាសកម្មជាដើម ។ ភិក្ខុរូបនេះ លោកហៅថា “អ្នកប្រព្រឹត្តដូរផង់ក្រៃពេក” ដូចជាព្រះថេរៈ ឈ្មោះសារីបុត្រ យ៉ាងនោះឯង ។



(រឿងព្រះសារីបុត្រមានអាពាធ)

បានឮមកថា លោកដ៏មានអាយុនោះ ចំរើនបវិវេក ក្នុងសម័យមួយ ជាមួយនឹងព្រះមហាមោគ្គល្លានត្ថេរ នៅក្នុងព្រៃមួយ ។ គ្រានោះ ក្នុងថ្ងៃមួយ អាពាធដែលកើតអំពីខ្យល់ ក្នុងពោះកើតឡើងហើយ ដល់ព្រះសារីបុត្រនោះញ៉ាំងទុក្ខដ៏ក្រៃលែងឲ្យកើតឡើង ។ នៅក្នុងពេលល្ងាច ព្រះមហាមោគ្គល្លានត្ថេរ និមន្តទៅកាន់ទីឧបដ្ឋាក របស់លោកដ៏មានអាយុនោះ ឃើញព្រះថេរៈសិងហើយ ក៏សួរដំណឹងនោះហើយសួរ ថា “នៃលោកដ៏មានអាយុ ក្នុងកាលមុនមក សេចក្តីរីករាយសប្បាយ កើតមានហើយ ដល់លោក ដោយហេតុដូចម្តេច?” ។ ព្រះថេរៈ ពោល ថា “ម្នាលលោកដ៏មានអាយុ ក្នុងកាលដែលខ្ញុំនៅជាគ្រហស្ថ មាតាខ្ញុំបានឲ្យនូវបាយាស ដែលចំអិនហើយ ដោយទឹកដោះស្រស់ ៗ មិនលាយដោយទឹក ផ្សំដោយទឹកដោះថ្លា, ទឹកឃ្មុំ, និង ស្ករក្រាមទាំងឡាយ ។ សេចក្តីសប្បាយ បានមានហើយ ដល់ខ្ញុំដោយបាយបាយាសនោះ” ។ ចំណែកឯ ព្រះមហាមោគ្គល្លានត្ថេរ ដ៏មានអាយុនោះ ពោលថា “ម្នាលលោកដ៏មានអាយុ រឿងនោះចូរលើកទុកសិនចុះ, បើបុណ្យរបស់ខ្ញុំ ឬរបស់លោកមាន, បើពិតដូច្នោះមែន យើងនឹងបាន ក្នុងថ្ងៃស្អែក” ។

ចំណែកទេវតា ដែលឋិតនៅលើដើមឈើ ត្រង់ទីបំផុតនៃទីចង្រ្កម ក៏បានឮ នូវពាក្យពោលចរចាគ្នានេះ របស់ព្រះថេរៈទាំងពីរនោះហើយ គិតថា “អញនឹងញ៉ាំងបាយបាយាស ឲ្យកើតឡើងដល់លោកម្ចាស់ ក្នុងថ្ងៃស្អែក” ដូច្នេះហើយ ក៏ទៅកាន់ត្រកូលឧបដ្ឋាក របស់ព្រះថេរៈ ក្នុងខណៈនោះភ្លាមហើយ មួលសរីរៈ របស់កូនប្រុសច្បង ញ៉ាំងសេចក្តីក្តៅក្រហាយ ឲ្យកើតឡើងហើយ ។ គ្រានោះ ទេវតាពោលនូវនិមិត្ត គឺ

កិរិយារក្សា ដល់កូនប្រុសច្បងនោះ ទីងពួកញាតិដែលមកប្រជុំគ្នា ថា : "ប្រសិនបើអ្នកទាំងឡាយ ចាត់ចែងនូវបាយបាយាស មានសភាពបែបនេះ ដល់ព្រះថេរៈ ក្នុងថ្ងៃស្អែក ខ្ញុំនឹងលែង" ។ ពួកញាតិទាំងនោះពោលថា "កាលបើ(ការចាត់ចែងបាយបាយាស) គឺអ្នកមិនបានប្រាប់ក៏ដោយ, ពួកយើង តែងប្រគេនភិក្ខាមិនដាច់ ដល់ព្រះថេរៈទាំងឡាយ" ដូច្នេះហើយ ក្នុងថ្ងៃទី២ ក៏បានចាក់ចែងបាយបាយាស ដែលមានសភាពដូច្នោះ ។ ព្រះមហាមោគ្គល្លានត្ថេរ និមន្តមកតាំងពីព្រឹកព្រលឹម ហើយពោលថា "ម្នាលលោកដ៏មានអាយុ សូមលោកនៅ ក្នុងទីនេះសិនចុះ ទម្រាំតែខ្ញុំត្រាច់ទៅបិណ្ឌបាតហើយ មកវិញ" ដូច្នេះហើយ ក៏ចូលទៅកាន់ស្រុក ។ ពួកមនុស្សទាំងនោះ ទៅទទួលកាន់យកបាត្រ របស់ព្រះថេរៈ បានញ៉ាំងបាត្រ ឲ្យពេញហើយ ដោយបាយបាយាស មានប្រការដូចពោលមកហើយ បានប្រគេនហើយ ។ ព្រះថេរៈ សំដែងនូវអាការៈគឺការនិមន្តទៅ ។ មនុស្សទាំងនោះ ពោលថា "បពិត្រលោកម្ចាស់ ដ៏ចំរើន សូមលោកម្ចាស់និមន្តឆាន់ចុះ យើងខ្ញុំនឹងប្រគេនបាយដទៃទៀតដល់លោកម្ចាស់" និមន្តព្រះថេរៈឆាន់ហើយ ក៏បានប្រគេនបាយបាយាសដាក់ឲ្យពេញក្នុងបាត្រម្តងទៀត ។ ព្រះថេរៈ មកហើយ បង្អោនចូលទៅជិត ពោលថា "ម្នាលសារីបុត្រ ដ៏មានអាយុ ហ៏ចូរលោកឆាន់ទៅ" ។ ចំណែកព្រះថេរៈ ឃើញនូវបាយបាយាសនោះហើយ កាលទឹកគិត ថា "បាយបាយាស ជាទីគាប់ចិត្តក្រៃពេក កើតឡើងហើយ ដោយបការៈដូចម្តេចហ្ន៎?"ដូច្នេះ ទើបបានឃើញមូលហេតុដែលបាយបាយាសនោះកើតឡើងហើយ ក៏ពោលថា "ម្នាលមោគ្គល្លានៈដ៏មានអាយុ! ចូរលោកយកចេញទៅ, បិណ្ឌបាត (នេះ) មិនគួរនឹងឆាន់ទេ" ។ ឯលោកដ៏មាន



អាយុនោះ ទាំងមិនញ៉ាំងចិត្ត ឲ្យកើតឡើងថា "ព្រះសារីបុត្រ មិនឆាន់បិណ្ឌបាត ដែលភិក្ខុប្រាកដដូចជាអាត្មាអញ នាំយកមកហើយ" ដូច្នេះទេ (ក៏)កាន់បាត្រ ត្រង់កណ្តាប់មាត់ ដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះហើយ ក៏ផ្កាប់ក្នុងទីដ៏សមគួរមួយ ។ អាពាធរបស់ព្រះថេរៈ បានជាសះស្បើយហើយ ព្រមជាមួយគ្នានឹងការតម្កល់ទុក នៃបាយបាយាស លើផែនដី ។ តាំងអំពីថ្ងៃនោះមក រហូត ៤៥ ឆ្នាំ អាពាធដូច្នោះ មិនដែលកើតទៀតឡើយ ។

គ្រានោះ ព្រះសារីបុត្រ ពោលទៅកាន់ព្រះមហាមោគ្គល្លានត្ថេរ ថា "ម្នាលអាវុសោ បាយបាយាសដែលកើតឡើង ព្រោះអាស្រ័យនូវការសូម ដោយវាចា មានសភាពមិនគួរដើម្បីឆាន់ សូម្បីកាលបើពោះវៀនធំ ចេញមកត្រាច់ទៅលើផែនដី ក៏ដោយ" ដូច្នេះហើយ ក៏បន្លឺឡើងនូវឧទាននេះ ថា :

ប្រសិនបើខ្ញុំគប្បីឆាន់ នូវមធុបាយាសដែលកើតឡើង
ហើយ ព្រោះការបញ្ចេញ នូវវចីវិញ្ញត្តិ, ការប្រព្រឹត្តិទៅ
មួយអន្លើដោយអាជីវៈ របស់ខ្ញុំ ក៏នឹងត្រូវតិះដៀលហើយ,
ប្រសិនបើពោះវៀនតូច របស់ខ្ញុំ គប្បីចេញទៅខាងក្រៅ
ខ្ញុំក៏នៅតែមិនគប្បីទម្លាយ នូវអាជីវៈជាដាច់ខាត, សូម្បី
លះបង់នូវជីវិត (ក៏ដោយ) ក៏ខ្ញុំនៅតែធ្វើចិត្តរបស់ខ្ញុំ ឲ្យ
ត្រេកអររីករាយបាន, ខ្ញុំវៀរចាកស្រឡះ នូវការស្វែងរក
មិនសមគួរ មួយវិញទៀត ខ្ញុំនឹងមិនធ្វើ នូវអនេសនៈ
ដែលព្រះពុទ្ធទ្រង់ស្អប់ខ្ពើមហើយ ។

មួយទៀត សូម្បីរឿងរបស់ព្រះថេរៈ ឈ្មោះមហាតិស្សៈ ដែលអាស្រ័យនៅទៀបគល់ឈើ អស់កាលដ៏យូរ និង ជាអ្នកឆាន់នូវផ្លែស្វាយ បណ្ឌិត ក៏គួរសំដែង ក្នុងរឿងនេះដែរ ។

> ភិក្ខុអ្នកមានឥន្ទ្រីយ៍សង្រួម បួសដោយសទ្ធា មានប្រាជ្ញា
> ជាគ្រឿងពិចារណាឃើញច្បាស់ មិនគប្បីញ៉ាំងចិត្ត ឲ្យ
> កើតឡើង ក្នុងអនេសនៈឡើយ គប្បីសំអាតអាជីវៈ
> ឲ្យបានបរិសុទ្ធល្អ

ដោយសព្វគ្រប់ យ៉ាងនេះឯង ។

ក៏អាជីវបារិសុទ្ធិ ភិក្ខុ គប្បីឲ្យសម្រេច ដោយសេចក្ដីព្យាយាមយ៉ាងណា, បច្ចយសន្និស្សិតសីល ក៏ភិក្ខុគប្បីឲ្យសម្រេច ដោយបញ្ញាយ៉ាងដូច្នោះដែរ ។ ព្រោះថា បច្ចយសន្និស្សិតសីលនោះ មានបញ្ញាជាហេតុឲ្យសម្រេច ព្រោះភាវៈនៃបុគ្គលអ្នកមានបញ្ញា ជាអ្នកអាចឃើញនូវទោស និង អានិសង្ស ក្នុងបច្ច័យទាំងឡាយ ។ ព្រោះហេតុនោះ បច្ចយសន្និស្សិតសីលនោះ គឺភិក្ខុអ្នកលះបង់នូវការជាប់ជំពាប់ក្នុងបច្ច័យហើយ ពិចារណាដោយបញ្ញា តាមពិធីដែលបានពោលមកហើយ ទើបប្រើប្រាស់នូវបច្ច័យទាំងឡាយ ដែលកើតឡើងហើយដោយធម៌ ដ៏សមគួរ គប្បីឲ្យសម្រេច ។ ក្នុងបច្ចយសន្និស្សិតសីលនោះ ការពិចារណាមាន ២ យ៉ាង គឺ (ពិចារណា) ក្នុងវេលាបាននូវបច្ច័យទាំងឡាយ ១ (ពិចារណា) ក្នុងវេលាប្រើប្រាស់នូវបច្ច័យទាំងឡាយ ១ ។ មែនពិត ការប្រើប្រាស់ របស់ភិក្ខុ អ្នកប្រើប្រាស់ នូវបច្ច័យទាំងឡាយ មានចីវរ-ប្បច្ច័យជាដើម ដែលខ្លួនពិចារណាហើយ ដោយអំណាច នៃធាតុប្បច្-



វេក្ខណៈក្ដី ដោយអំណាចបដិកូលបច្ចវេក្ខណៈក្ដី ទុកដាក់ហើយ សូម្បីក្នុងបដិលាភកាល បន្ទាប់អំពីវេលាដែលបានមកនោះ ក៏មិនមានទោសឡើយ សូម្បីក្នុងវេលាប្រើប្រាស់ ។ នេះ គឺជាសេចក្ដីវិនិច្ឆ័យ ដែលធ្វើសេចក្ដីសន្និដ្ឋាន ក្នុងបរិភោគកាលនោះ ។

(៣១) ក៏ការបរិភោគ មាន ៤ យ៉ាង គឺ : ថេយ្យបរិភោគ ១, ឥណបរិភោគ ១, ទាយជ្ជបរិភោគ ១, សាមិបរិភោគ ១ ។ បណ្ដាការបរិភោគទាំង ៤ នោះ ការបរិភោគ របស់ភិក្ខុទ្រុស្ដសីល អ្នកអង្គុយបរិភោគ សូម្បីក្នុងទីកណ្ដាលនៃព្រះសង្ឃ ឈ្មោះថា ថេយ្យបរិភោគ (បរិភោគដោយលួច) ។ ការបរិភោគ របស់ភិក្ខុអ្នកមានសីល ដែលមិនពិចារណាហើយ ឈ្មោះថា ឥណបរិភោគ (បរិភោគជាបំណុល) ។ ហេតុនោះ ចីវរ ភិក្ខុត្រូវតែពិចារណា រាល់ ៗ ពេលដែលប្រើប្រាស់, បិណ្ឌបាត ភិក្ខុត្រូវពិចារណារាល់ ៗ ពំនូត, ភិក្ខុកាលមិនអាចពិចារណាដោយបការដូច្នោះបានទេ គប្បីពិចារណា ក្នុងកាលមុននៃភត្ត ក្នុងកាលខាងក្រោយនៃភត្ត ក្នុងយាមមុន ក្នុងយាមជាកណ្ដាល និង ក្នុងយាមជាទីបំផុត(ក៏បាន) ។ ថាបើ ភិក្ខុនោះ មិនពិចារណាទេ, អរុណ រះឡើង, ភិក្ខុនោះ ឋិតនៅ ក្នុងទីជាទីបរិភោគនូវបច្ច័យជាបំណុល ។ ចំណែកសេនាសនៈ ភិក្ខុ ត្រូវតែពិចារណា រាល់ ៗ ពេលដែលប្រើប្រាស់ ។ ភាពនៃភិក្ខុអ្នកមានសតិជាបច្ច័យ ក្នុងវេលាទទួលផង ក្នុងវេលាបរិភោគនូវភេសជ្ជៈផង ទើបគួរ ។ កាលបើមានហេតុយ៉ាងនេះ, កាលបើភិក្ខុធ្វើសតិ ក្នុងវេលាទទួលហើយ មិនធ្វើសតិ ក្នុងវេលាបរិភោគប៉ុណ្ណោះ ទើបត្រូវអាបត្តិ, តែកាលបើភិក្ខុមិនបានធ្វើសតិ ក្នុងពេលទទួលទេ ទៅធ្វើសតិ ក្នុងពេលដែលបរិភោគ មិនត្រូវអាបត្តិឡើយ ។

(៣២) ក៏សុទ្ធិ មាន ៤ យ៉ាង គឺ: ទេសនាសុទ្ធិ ១, សំវរសុទ្ធិ ១, បរិយេដ្ឋិសុទ្ធិ ១, បច្ចវេក្ខណសុទ្ធិ ១, ។ បណ្ដាសុទ្ធិ ទាំង ៤ យ៉ាងនោះ បាតិមោក្ខសំវរសីល ឈ្មោះថា ទេសនាសុទ្ធិ ។ ព្រោះថា បាតិ-មោក្ខសំវរសីលនោះ ព្រះមានព្រះភាគ ហៅថា "ទេសនាសុទ្ធិ" ព្រោះបរិសុទ្ធដោយការសំដែង ។ ឥន្ទ្រិយសំវរសីល ឈ្មោះថា សំវរសុទ្ធិ ។ ព្រោះថា ឥន្ទ្រិយសំវរសីលនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា "សំវរសុទ្ធិ" ព្រោះបរិសុទ្ធ ដោយការសង្រួម ដោយតាំងចិត្តថា "អាត្មាអញ នឹងមិនធ្វើយ៉ាងនេះទៀតឡើយ" ។ អាជីវបារិសុទ្ធិសីល ឈ្មោះថា បរិយេដ្ឋិសុទ្ធិ ។ ព្រោះអាជីវបារិសុទ្ធិសីលនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅថា "បរិយេដ្ឋិសុទ្ធិ" ព្រោះបរិសុទ្ធដោយការស្វែងរក នៃភិក្ខុអ្នកលះបង់នូវអនេសនៈ ហើយញ៉ាំងបច្ច័យទាំងឡាយ ឲ្យកើតឡើងដោយធម៌ ដោយសមគួរ ។ បច្ចយបរិភោគសន្និស្សិតសីល ឈ្មោះថា បច្ចវេក្ខណសុទ្ធិ ។ ព្រោះបច្ចយបរិភោគសន្និស្សិតសីលនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា "បច្ចវេក្ខណសុទ្ធិ" ព្រោះបរិសុទ្ធដោយការពិចារណា មានបការៈដូចព្រះអង្គត្រាស់ហើយ ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យ ពោលពាក្យនោះថា "តែមិនត្រូវអាបត្តិ ដល់ភិក្ខុដែលមិនបានធ្វើសតិ ក្នុងពេលទទួលហើយទៅធ្វើសតិ ក្នុងពេលបរិភោគ" ។

(៣៣) ការបរិភោគនូវបច្ច័យរបស់ព្រះសេខបុគ្គល ៧ ពួក ឈ្មោះថា ទាយជ្ជបរិភោគ ។ ព្រោះថា ព្រះសេខបុគ្គល ៧ ពួកនោះ ជាបុត្ររបស់ព្រះមានព្រះភាគ, ព្រោះហេតុនោះ បុត្រទាំងឡាយនោះ ជាអ្នកទទួល នូវបច្ច័យទាំងឡាយ ដែលជារបស់នៃបិតា ប្រើប្រាស់នូវបច្ច័យ



ទាំងឡាយនោះ ។ សួរថា "ក៏បុត្រទាំងឡាយនោះ បរិភោគនូវបច្ច័យទាំងឡាយ របស់ព្រះមានព្រះភាគ ឬ ឬថា បរិភោគនូវបច្ច័យទាំងឡាយរបស់ពួកគ្រហស្ថ?" ។ ឆ្លើយថា "បច្ច័យទាំងឡាយនោះទុកជាគ្រហស្ថទាំងឡាយ ប្រគេនហើយក៏ដោយ ក៏ឈ្មោះថា ជារបស់នៃព្រះដ៏មានព្រះភាគដែរ ព្រោះបច្ច័យទាំងនោះ គឺព្រះដ៏មានព្រះភាគ ទ្រង់បានអនុញ្ញាតហើយ, ព្រោះហេតុនោះ បុត្រទាំងឡាយនោះ បណ្ឌិត គប្បីជ្រាប ថា "បរិភោគនូវបច្ច័យ របស់ព្រះមានព្រះភាគ" ។ ឯធម្មទាយាទសូត្រ ជាគ្រឿងសំរេច ក្នុងអធិការនៃទាយជ្ជបរិភោគនេះ ។ ការបរិភោគ របស់ព្រះខីណាស្រពទាំងឡាយ ឈ្មោះថា សាមិបរិភោគ ។

ព្រោះថា ព្រះខីណាស្រពទាំងឡាយនោះ ឈ្មោះថា ជាម្ចាស់បរិភោគ ព្រោះលោកជាអ្នកកន្លងនូវភាពនៃខ្លួនជាខ្ញុំនៃតណ្ហាបានហើយ។

បណ្ដាការបរិភោគទាំងនេះ សាមិបរិភោគ និង ទាយជ្ជបរិភោគ ទើបគួរ ដល់ភិក្ខុទាំងពួង ។ ចំណែកឥណបរិភោគ មិនគួរទេ ។ វាចាជាហេតុពោល ក្នុងថេយ្យបរិភោគនុ៎ះឯង មិនមានឡើយ ។ ចំណែកឯការបរិភោគ របស់ភិក្ខុអ្នកមានសីល ដែលពិចារណាហើយ នេះឯណា, ការបរិភោគនោះ ឈ្មោះថា ជាការបរិភោគ ដោយភាពជាបច្ច័យមិនមែនជាបំណុល ព្រោះភាវៈនៃបច្ចវេក្ខិតបរិភោគ ជាសត្រូវចំពោះឥណបរិភោគ ឬក៏ ដល់នូវការសង្គ្រោះ ក្នុងទាយជ្ជបរិភោគបានដូចគ្នា ។ ព្រោះថា សូម្បីភិក្ខុអ្នកមានសីល ក៏ព្រះមានព្រះភាគ ត្រាស់ហៅថា "ជាសេខបុគ្គល" បានដែរ ព្រោះលោកប្រកបព្រមដោយសិក្ខានេះ ។ ក៏ក្នុងការបរិភោគទាំងនេះ សាមិបរិភោគ ប្រសើរ ព្រោះហេតុណា, ព្រោះហេតុនោះ បច្ចយសន្និស្សិតសីល ភិក្ខុប្រាថ្នានូវសាមិបរិភោគ ដ៏ប្រសើរ

*នោះ ពិចារណាដោយបច្ចវេក្ខណៈ មានបការៈដូចលោកពោលហើយ បរិភោគ គប្បីឲ្យសម្រេច ។*

*មែនពិត ភិក្ខុកាលធ្វើយ៉ាងនេះ ឈ្មោះថា ជាអ្នកមានកិរិយាធ្វើកិច្ចជាប្រក្រតី ។ ដូចគាថាពន្ធន៍នេះ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ថា*

ភិក្ខុជាសាវក មានប្រាជ្ញាដ៏ប្រសើរ ស្តាប់នូវធម៌ដែលព្រះសុគត ទ្រង់សំដែងហើយ ត្រូវពិចារណា រួចជាមុនហើយ សឹមសេព នូវបិណ្ឌបាត, វិហារ, ទីដេក និង ទីអង្គុយ និង ទឹកសម្រាប់លាងនូវធូលី ដែលជាប់នៅពួដ៏សំពត់សង្ឃាដី, ព្រោះហេតុនោះឯង ភិក្ខុជាអ្នកមិនត្រូវជាប់ជំពាក់ ក្នុងធម៌ទាំងឡាយនេះ គឺក្នុងដុំបាយ, ក្នុងទីដេក និង ទីអង្គុយ និង ក្នុងទឹកសម្រាប់លាងនូវធូលី ដែលជាប់នៅ ពួដ៏សំពត់សង្ឃាដី ដូចជាតំណក់នៃទឹក ដែលមិនជាប់នៅលើស្លឹកឈូក [១] យ៉ាងនោះឯង ។ ភិក្ខុនោះ មានសតិស្មារតី តម្កល់ខ្ជាប់រឿយៗហើយ បាននូវបច្ច័យទាំងឡាយ ព្រោះសេចក្តីអនុគ្រោះអំពីជនដទៃ តាមកាល គប្បីដឹងនូវប្រមាណ ក្នុងវត្ថុដែលខ្លួនគប្បីទំពាស៊ី, ក្នុងវត្ថុដែលខ្លួនគប្បីបរិភោគ និង ក្នុងវត្ថុដែលខ្លួនគប្បីលិទ្ធជញ្ជក់ ប្រៀបដូចជាគ្រូពេទ្យដឹងប្រមាណ ក្នុងកិរិយាដុះឡើងនៃដំបៅ ដោយការលាបថ្នាំ យ៉ាងដូច្នោះ, ភិក្ខុ មិនត្រូវជាប់ចិត្ត ក្នុង

---

*១- សុ. ខុ. សុត្ត. ភាគទី ៥៤ ទំព័រទី ១២៦ ។*



អាហារ ឆាន់អាហារ បំណងឲ្យគ្រាន់តែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដូចជាមាតាបិតាស៊ីនូវសាច់របស់កូន (កំដរអត្តភាព ទាំងទើសទាល់) ក្នុងផ្លូវដែលឆ្ងាយដាច់ស្រយាល, ដូចជាអ្នកបររទេះ លាបនូវខ្លាញ់ភ្លៅរទេះ (សោះតែខានមិនបាន) យ៉ាងដូច្នោះឯង ។

*ក៏ក្នុងភាពជាអ្នកបំពេញជាប្រក្រតី ក្នុងបច្ចយសន្និស្សិតសីលនេះ បណ្ឌិត ត្រូវសំដែងរឿងភាគិនេយ្យសង្ឃរក្ខិតសាមណេរ ។ ព្រោះថាសាមណេរនោះ ពិចារណាដោយប្រពៃហើយទើបឆាន់ ។*

*សមដូចជាពាក្យដែលសាមណេរនោះ ពោលថា :*

ព្រះឧបជ្ឈាយ៍ ប្រាប់ខ្ញុំដែលកំពុងឆាន់ នូវបាយនៃស្រូវសាលីដ៏ត្រជាក់ស្រួល ថា “នែសាមណេរឯង កុំជាអ្នកមិនសង្រួមហើយ ញ៉ាំងអណ្តាតឲ្យឆេះឡើយ” ខ្ញុំបានឮសំដីព្រះឧបជ្ឈាយ៍ហើយ ក៏បាននូវសេចក្តីតក់ស្លុតក្នុងពេលនោះ ខ្ញុំអង្គុយហើយ លើអាសនៈមួយ បានលុះហើយនូវព្រះអរហត្ត ខ្ញុំនោះមានសេចក្តីត្រិះរិះពេញលេញហើយ ដូចជាព្រះចន្ទ ក្នុងថ្ងៃ ១៥ កើត យ៉ាងនោះឯង ជាអ្នកមានអាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីលែងមានទៀតឡើយ ។ ហេតុនោះ សូម្បីបព្វជិតដទៃទៀត កាលប្រាថ្នានូវកិរិយាអស់ទៅនៃសេចក្តីទុក្ខ គប្បីពិចារណា ដោយឧបាយនៃប្រាជ្ញាហើយ សឹមប្រើប្រាស់នូវបច្ច័យទាំងឡាយចុះ ។

សីល មាន ៤ ប្រការ ដោយអំណាចនៃបាតិមោក្ខសំវរសីល ជាដើម យ៉ាងដូច្នេះឯង ។

(ក្រុមសីល ៥ ទី ១)

(៣៤) ក្នុងក្រុមសីល ៥ ទី ១ នៃចំណែកសីល មានប្រការ ៥ បណ្ឌិត គប្បីជ្រាបសេចក្តីអត្ថាធិប្បាយ ដោយអំណាចនៃសីល មាន អនុបសម្បន្នសីលជាដើម ។ មែនពាក្យនេះ ព្រះធម្មសេនាបតីសារីបុត្រ ពោលហើយ ក្នុងបដិសម្ភិទាថា "បរិយន្តបារិសុទ្ធិសីល តើដូចម្តេច? សីល របស់អនុបសម្បន្នទាំងឡាយ អ្នកមានសិក្ខាបទ ជាទីបំផុតនេះ ឈ្មោះថា បរិយន្តបារិសុទ្ធិសីល, អបរិយន្តបារិសុទ្ធិសីល តើដូចម្តេច ? សីល របស់អនុបសម្បន្នទាំងឡាយ អ្នកមានសិក្ខាបទ មិនមានទីបំផុត នេះ ឈ្មោះថា អបរិយន្តបារិសុទ្ធិសីល, បរិបុណ្ណបារិសុទ្ធិសីល តើដូចម្តេច? សីល របស់កល្យាណបុថុជ្ជនទាំងឡាយ អ្នកប្រកបហើយ ក្នុង កុសលធម៌ទាំងឡាយ អ្នកមានកិរិយាធ្វើឲ្យពេញលេញបរិបូណ៌ ក្នុង ទីបំផុត នៃព្រះសេខបុគ្គល មិនជាប់ជំពាក់ ក្នុងរាងកាយ និង ជីវិត មានជីវិតលះបង់ហើយ នេះ ឈ្មោះថា បរិបុណ្ណបារិសុទ្ធិសីល, អបរាមដ្ឋបារិសុទ្ធិសីល តើដូចម្តេច? សីល របស់ព្រះសេខបុគ្គល ៧ ពួកនេះ ឈ្មោះថា អបរាមដ្ឋបារិសុទ្ធិសីល, បដិប្បស្សទ្ធិបារិសុទ្ធិសីល តើដូចម្តេច? ។ សីល របស់ព្រះខីណាស្រពទាំងឡាយ ជាសាវ័ក របស់ព្រះតថាគត, សីល របស់ព្រះបច្ចេកពុទ្ធទាំងឡាយ, សីល របស់ព្រះតថាគត អរហន្ត សម្មាសម្ពុទ្ធទាំងឡាយនេះ ឈ្មោះថា បដិប្បស្សទ្ធិបារិសុទ្ធិសីល" ។

បណ្តាសីលទាំងឡាយនោះ សីល របស់អនុបសម្បន្នទាំងឡាយ



បណ្ឌិត គប្បីជ្រាបថា "សបរិយន្តបារិសុទ្ធិសីល" ព្រោះសីលនោះ មាន ទីបំផុត ដោយអំណាចនៃការរាប់ ។ សីល របស់អនុបសម្បន្នទាំង ឡាយ បណ្ឌិត គប្បីជ្រាបថា "ឈ្មោះថាអបរិយន្តបារិសុទ្ធិសីល" ដូច្នេះ ព្រោះសំដៅយកនូវសបរិយន្តសីល ដោយអំណាចការរាប់ខ្វះ នូវភាព គឺការសមាទាន ដោយអំណាចនៃសីលមិនមានសេសសល់ខ្វះ នូវភាព នៃសីលដែលមិនមែនជាសីល មានការឃើញ ដោយអំណាចនៃលាភ, យស, ញាតិ, អវយវៈ និង ជីវិត ជាទីបំផុត ដូចជាសីល របស់ព្រះ មហាតិស្សត្ថេរអ្នកអាស្រ័យនៅទៀបគល់ឈើអស់កាលមិនយូរ ឆាន់នូវ ផ្លែស្វាយ យ៉ាងនេះ ថា :

> សិក្ខាបទទាំងឡាយដែលជាគ្រឿងសង្រួម និង ជាវិន័យ
> ទាំងនេះ មានចំនួន ប្រាំបួនពាន់កោដិ និង ប៉ែតសិប
> រយកោដិ និង ផ្សេងទៀតហាសិបសែន និង សាមសិប
> ប្រាំមួយផ្សេងៗ ទៀត (រួមត្រូវជាមួយម៉ឺន ប្រាំពីរពាន់
> កោដិ ប្រាំលាន សាមសិបប្រាំមួយ) គឺព្រះសម្ពុទ្ធ ទ្រង់
> ប្រកាសហើយ, ក្នុងវិនយសំវរៈ ព្រះអង្គទ្រង់សំដែង
> ហើយ ដោយប្រធាន គឺសេចក្តីបំព្រួញ ។

ពិតដូច្នោះមែន លោកដ៏មានអាយុអង្គនោះ មិនលះបង់នូវសតិ ជាគ្រឿងរលឹករឿយៗ ដល់ធម៌របស់សប្បុរសនេះ ថា :

> "នរជន គប្បីលះបង់នូវទ្រព្យ ព្រោះហេតុនៃអវយវៈ
> ដ៏ប្រសើរ កាលរក្សានូវជីវិត គប្បីលះបង់នូវអវយវៈ

> កាលរលឹក នូវធម៌រឿយៗ គប្បីលះបង់ទាំងអវយវៈ ទាំងទ្រព្យ ទាំងជីវិត ទាំងអស់ផង” ដូច្នេះ

មិនបានប្រព្រឹត្តកន្លងនូវសិក្ខាបទ សូម្បីក្នុងសេចក្ដីសង្ស័យ ក្នុងជីវិតអាស្រ័យហើយ នូវអបរិយន្តបារិសុទ្ធិសីលនោះឯង ទាំងនៅលើខ្នងនៃឧបាសក បានសម្រេចហើយនូវព្រះអរហត្ត ។

សមដូចជាព្រះមហាតិស្សត្ថេរ ពោលហើយថា :

> ឧបាសករូបនេះ មិនមែនជាបិតា ទាំងមិនមែនជាមាតា មិនមែនជាញាតិ ទាំងមិនមែនជាផៅពង្ស របស់អ្នកទេ គាត់ធ្វើកិច្ច មានសភាពបែបនេះ ព្រោះហេតុ នៃអ្នកមានសីល, (ព្រះថេរៈ) ញុំាងសេចក្ដីសង្វេគតក់ស្លុតឲ្យកើតឡើងហើយ ពិចារណា ដោយឧបាយនៃប្រាជ្ញា ទាំងនៅលើខ្នងនៃឧបាសកនោះ មានចិត្តស្ងប់រម្ងាប់ បានសម្រេចហើយ នូវព្រះអរហត្ត ។

សីល របស់កល្យាណបុថុជ្ជនទាំងឡាយ ដែលប្រាសចាកមន្ទិល សូម្បីគ្រាន់តែញុំាងចិត្តឲ្យកើតឡើង ព្រោះជាសីលដែលបរិសុទ្ធក្រៃពេកហាក់បីដូចជាកែវមណីកើតឯង ដែលបុគ្គលខាត់ហើយ ដោយល្អផងហាក់ដូចជាមាសដែលជាងធ្វើបរិកម្មល្អហើយផង តាំងពីពេលដែលបានឧបសម្បទមក ជាហេតុជាទីតាំងនៃព្រះអរហត្តពិត ព្រោះហេតុនោះទើបព្រះមានព្រះភាគ ត្រាស់ថា “បរិបុណ្ណបារិសុទ្ធិសីល” ដូចជាសីលព្រះមហាសង្ឃរក្ខិតត្ថេរ និង ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ ដូច្នោះឯង ។



(រឿងព្រះមហាសង្ឃរក្ខិតត្ថេរ)

បានឮមកថា ព្រះភិក្ខុសង្ឃ សួរនូវហេតុជាគ្រឿងត្រាស់ដឹង នូវលោកុត្តរធម៌ ចំពោះព្រះមហាសង្ឃរក្ខិតត្ថេរ ដែលមានវស្សា ៦០ កន្លងហើយ សិងនៅលើគ្រែជាដែលទីមរណៈ ។ ព្រះថេរៈ ឆ្លើយតបថា “លោកុត្តរធម៌ របស់ខ្ញុំមិនមានទេ” ។ លំដាប់នោះ ភិក្ខុកម្លោះ ដែលជាឧបដ្ឋាក របស់ព្រះថេរៈនោះ ពោលថា “បពិត្រលោកម្ចាស់ដ៏ចំរើនមនុស្សទាំងឡាយ ប្រមាណ ១២ យោជន៍ ដោយជុំវិញ អង្គុយប្រជុំគ្នាហើយ ដោយគិតថា “លោកម្ចាស់បរិនិព្វានហើយ” ដូច្នេះ, សេចក្ដីស្ដាយក្រោយ របស់មហាជន នឹងមានព្រោះកាលកិរិយាដែលជាបុថុជ្ជនរបស់លោកម្ចាស់” ។ ព្រះថេរៈពោល ថា “ម្នាលអាវុសោ ខ្ញុំមិនបានតាំងផ្ដើមវិបស្សនា ដោយប្រាថ្នា ថា “ខ្ញុំនឹងជួបព្រះដ៏មានព្រះភាគព្រះនាមមេត្តេយ្យ” ដូច្នេះ, បើដូច្នោះ ចូរអ្នកញុំាងខ្ញុំឲ្យអង្គុយហើយ ឲ្យនូវឱកាស” ។ ភិក្ខុកម្លោះនោះ ញុំាងព្រះថេរៈឲ្យគង់ហើយ ក៏ចេញទៅខាងក្រៅ ។ ព្រះថេរៈសម្រេចហើយនូវព្រះអរហត្ត ព្រមជាមួយគ្នានឹងការចេញទៅខាងក្រៅ នៃភិក្ខុកម្លោះនោះឯង បានឲ្យនូវសញ្ញា ដោយម្រាមដៃ ។ ព្រះសង្ឃអង្គុយប្រជុំគ្នាហើយពោលថា “បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ ញុំាងលោកុត្តរធម៌ ឲ្យកើតឡើង ក្នុងសម័យមរណកាល មានសភាពបែបនេះ ឈ្មោះថា បានធ្វើកិច្ចដែលបុគ្គលធ្វើបានដោយកម្រ” ។ ព្រះថេរៈ ពោលថា “ម្នាលអាវុសោទាំងឡាយ អំពើនេះមិនមែន គឺបុគ្គលធ្វើបានដោយកម្រទេ, ម្យ៉ាងទៀត ខ្ញុំនឹងប្រាប់នូវអំពើដែលបុគ្គលធ្វើបានដោយកម្រ ដល់អ្នកទាំងឡាយ, ម្នាលលោកដ៏មានអាយុទាំងឡាយ ចាប់តាំងអំពីពេលដែលខ្ញុំបួសហើយ ខ្ញុំមិន

*នឹកនូវកម្ម ដែលខ្ញុំធ្វើហើយ ដោយការមិនដឹង ព្រោះមិនមានសតិទេ” ។ ចំណែកក្មួយរបស់ព្រះថេរៈនោះ បានសំរេចព្រះអរហត្ត យ៉ាងនេះដែរ ក្នុងកាលមានវស្សា ៥០ ។*

*( ព្រះមានព្រះភាគ ទ្រង់ត្រាស់ ថា : )*

បើបុគ្គលមានសេចក្ដីចេះដឹងតិច ទាំងមិនបានឋិតនៅក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ ដោយហេតុ ២ យ៉ាង គឺ សីល ១ សេចក្ដីចេះដឹង ១ ។

បើបុគ្គលមានសេចក្ដីចេះដឹងតិច តែឋិតនៅខ្ជាប់ខ្ជួនក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ តែដោយសីល, ក៏ប៉ុន្តែសេចក្ដីចេះដឹងមិនបានសម្រេច ដល់បុគ្គលនោះទេ ។

បើបុគ្គលមានសេចក្ដីចេះដឹងច្រើន តែមិនបានឋិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយទេ, អ្នកប្រាជ្ញទាំងឡាយ រមែងតិះដៀលបុគ្គលនោះ តែដោយសីល, តែសេចក្ដីចេះដឹង រមែងសម្រេច ដល់បុគ្គលនោះ ។

បើបុគ្គលមានសេចក្ដីចេះដឹងច្រើន ទាំងឋិតនៅខ្ជាប់ខ្ជួន ក្នុងសីលទាំងឡាយ, អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលនោះ ដោយហេតុ ២ យ៉ាង គឺ សីល ១ សេចក្ដីចេះដឹង ១ ។

អ្នកណា គួរនិន្ទា នូវបុគ្គលអ្នកមានសេចក្ដីចេះដឹង



ច្រើន ទ្រទ្រង់នូវព្រះធម៌ អ្នកមានបញ្ញា ជាពុទ្ធសាវ័កនោះ ដែលដូចជាដុំ នៃមាសជម្ពូនទបាន, សូម្បីទេវតានិង មនុស្សទាំងឡាយ ក៏រមែងសរសើរ នូវបុគ្គលនោះ, សូម្បីព្រហ្ម ក៏សរសើរដែរ [(១)] ។

*ចំណែកខាងសីល របស់សេខបុគ្គលទាំងឡាយ បណ្ឌិត គប្បីជ្រាបថា “អបរាមដ្ឋបារិសុទ្ធិសីល” ព្រោះភាវៈនៃសីលនោះ មិនពាល់ត្រូវហើយ ដោយអំណាចនៃទិដ្ឋិ, មួយវិញទៀត សីលដែលមិនពាល់ត្រូវហើយ ដោយអំណាចនៃកត របស់បុថុជ្ជនទាំងឡាយ គប្បីជ្រាបថា “អបរាមដ្ឋបារិសុទ្ធិសីល” ដូច្នេះ ប្រៀបដូចជាសីល របស់ព្រះកុដុម្ពិយបុត្តតិស្សត្ថេរ ។ សេចក្ដីថា លោកដ៏មានអាយុអង្គនោះ មានបំណងនឹងអាស្រ័យនូវសីលមានសភាពបែបនោះ ហើយឋិតនៅ ក្នុងព្រះអរហត្ត ទើបពោលនឹងមនុស្សអ្នកមានពៀរទាំងឡាយ ថា :*

អាត្មា បំបាក់នូវជើងទាំងពីរហើយ នឹងសង្រួមដល់អ្នកទាំងឡាយ, អាត្មា នឿយណាយធុញទ្រាន់ នូវសេចក្ដីស្លាប់ ប្រកបដោយរាគៈ អាត្មា លុះគិត យ៉ាងនេះហើយ ទើបពិចារណា ដោយឧបាយនៃប្រាជ្ញា, កាលបើព្រះអរុណ រះឡើងហើយ, ក៏បានសម្រេចនូវព្រះអរហត្ត ។

*ព្រះមហាថេរ មួយរូបទៀត មានជំងឺយ៉ាងខ្លាំង មិនអាចឆាន់ នូវអាហារ ដោយដៃខ្លួនឯងបានឡើយ សិងបម្រះននៀលទៅមក នៅលើ*

---

*១- សុ. អំ. ច. ភាគទី ៤២ ទំព័រទី ១៦ ។*

*មូត្រ និង ករីស របស់ខ្លួន ។ ភិក្ខុកម្លោះ មួយរូបទៀត ឃើញនូវព្រះមហាថេរនោះហើយ ពោលថា “ឱ! ជីវិត និង សង្ខារទាំងឡាយ ជាទុក្ខ អ្វីម្ល៉េះទេ” ។ ព្រះមហាថេរ ប្រាប់ភិក្ខុនោះ ថា “ម្នាលលោកដ៏មានអាយុ ខ្ញុំកាលស្លាប់ឥឡូវនេះ គង់បាននូវសម្បត្តិ គឺឋានសួគ៌ សេចក្តីសង្ស័យ ក្នុងជីវិត របស់ខ្ញុំ មិនមានទេ, តែថា ធម្មតាសម្បត្តិ ដែលខ្ញុំត្រូវទម្លាយ នូវសីលនេះហើយ បានមក ក៏ប្រាកដស្មើ ដោយភាពជាគ្រហស្ថ ដែលភិក្ខុលាចាកសិក្ខាបទហើយ បានមកដូច្នោះ” ដូច្នេះហើយ គិតថា “អាត្មាអញនឹងស្លាប់ ជាមួយនឹងសីលឲ្យទាល់តែបាន” ដូច្នេះ សិងនៅដដែល ពិចារណារោគនោះឯង ក៏ដល់នូវព្រះអរហត្ត ហើយព្យាករ ដោយគាថាទាំងនេះ ដល់ភិក្ខុសង្ឃ ថា :*

> កាលខ្ញុំ ត្រូវព្យាធិណាមួយពាល់ត្រូវហើយ គឺរោគបៀតបៀនហើយ ធ្វើឲ្យទ្រុឌទ្រោមយ៉ាងខ្លាំង សាកអសុភនេះនឹងក្រៀមស្ងួត យ៉ាងឆាប់រហ័ស ប្រៀបដូចជាផ្កាដែលបុគ្គលចោលហើយ លើអាចម៍ដី នាកណ្តាលថ្ងៃក្តៅ ឆាប់ក្រៀមស្ងួត យ៉ាងដូច្នោះ, រូបនេះ ជារបស់មិនជាទីពេញចិត្ត តែបុគ្គលពាលពោល ថា ជារបស់ដែលជាទីពេញចិត្ត, រូបនេះ មិនស្អាត តែបុគ្គលពាលសន្មត ថា ជារបស់ដែលល្អស្អាតទៅវិញ, រូបនេះ ពោរពេញទៅដោយសាកសពផ្សេងៗ តែត្រឡប់ទៅជារូប ដែលជាទីពេញចិត្ត ដល់បុគ្គលអ្នកដែលមិនឃើញច្បាស់ (តាមសេចក្តីពិត), សេចក្តីតិះដៀល នូវកាយដែលស្អុយ ឈឺ



> ចាប់ជានិច្ច មានក្លិនមិនល្អ មិនស្អាត មានព្យាធិជាធម្មតា, ពួកសត្វទាំងឡាយ ប្រមាទហើយ ឈ្លក់វង្វេងហើយ ក្នុងកាយស្អុយឯណា, (កាយស្អុយនោះ) ញ៉ាំងមគ្គ ដើម្បីចូលទៅកើត ក្នុងឋានសួគ៌ ឲ្យវិនាស ។

*ចំណែក សីល របស់ព្រះអរិយទាំងឡាយ មានព្រះអរហន្តជាដើម បណ្ឌិត គប្បីជ្រាប ថា* “បដិប្បស្សទ្ធិបារិសុទ្ធិសីល” *ព្រោះការៈនៃសីលនោះ ជាសីលបរិសុទ្ធ ដោយការស្ងប់រម្ងាប់ នូវកិលេសគ្រឿងក្រវល់ក្រវាយទាំងពួង ។ សីល មាន ៥ ប្រការ ដោយអំណាចនៃសីល មានអបរិយន្តបារិសុទ្ធិសីលជាដើម ដោយប្រការដូច្នេះឯង ។*

(ក្រុមសីល ៥ ទី ២)

*(៣៥) ក្នុងបញ្ចកសីល ទី ២ បណ្ឌិត គប្បីជ្រាបសេចក្តីអធិប្បាយ ដោយអំណាចគុណ មានការលះបង់ជាដើម នូវទោសទាំងឡាយ មានបាណាតិបាតជាអាទិ៍ ។ មែនពិត ពាក្យនេះ ព្រះធម្មសេនាបតី-សារីបុត្រ ពោលហើយ ក្នុងបដិសម្ភិទា ថា “សីលទាំងឡាយ ៥ គឺ: ការលះបង់នូវបាណាតិបាត ឈ្មោះថា សីល, ចេតនា ជាគ្រឿងវៀរ ឈ្មោះថា សីល, ចេតនា ឈ្មោះថា សីល, សេចក្តីសង្រួម ឈ្មោះថា សីល, ការមិនប្រព្រឹត្តិកន្លង ឈ្មោះថា សីល ។ ការលះបង់នូវអទិន្នាទាន, កាមេសុមិច្ឆាចារ, មុសាវាទ, ផរុសវាចា, សម្ផប្បលាបៈ, អភិជ្ឈា, ព្យាបាទ, មិច្ឆាទិដ្ឋិ ឈ្មោះថា សីល ។ ការលះបង់នូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ, លះបង់ព្យាបាទ ដោយការមិនព្យាបាទ, លះបង់ថីនមិទ្ធៈ ដោយសេចក្តីសម្គាល់ ក្នុងពន្លឺ, លះបង់នូវឧទ្ធច្ចៈ ដោយការមិនរាយ*

មាយ, លះបង់វិចិកិច្ឆា ដោយការកំណត់នូវធម៌, លះបង់អវិជ្ជា ដោយញាណ, លះបង់អរតិដោយបាមោជ្ជៈ, លះបង់នីវរណៈទាំងឡាយដោយបឋមឈាន, លះបង់វិតក្កៈ និង វិចារៈ ដោយទុតិយឈាន, លះបង់បីតិ ដោយតតិយឈាន, លះបង់សុខ និង ទុក្ខ ដោយចតុត្ថជ្ឈាន, លះបង់រូបសញ្ញា, បដិឃសញ្ញា, នានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ, លះបង់អាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ, លះបង់នូវវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ, លះបង់នូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ, លះបង់នូវនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា, លះបង់នូវសុខសញ្ញា ដោយទុក្ខានុបស្សនា, លះបង់នូវអត្តសញ្ញា ដោយអនត្តានុបស្សនា, លះបង់នូវសេចក្តីត្រេកអរ ដោយនិព្វិទានុបស្សនា, លះបង់នូវរាគៈ ដោយវិរាគានុបស្សនា, លះបង់នូវសមុទយៈ ដោយនិរោធានុបស្សនា, លះបង់នូវភាវៈ នៃចិត្តមិនចង់រួចផុត ដោយមុញ្ចិតុកាម្យតានុបស្សនា, លះបង់សេចក្តីប្រកាន់ ដោយបដិនិស្សគ្គានុបស្សនា, លះបង់នូវឃនសញ្ញា ដោយខយានុបស្សនា, លះបង់នូវកិរិយាចំរើននៃអាយុ ដោយវយានុបស្សនា, លះបង់ធុវសញ្ញា ដោយវិបរិណាមានុបស្សនា, លះបង់នូវកិលេសដែលជានិមិត្ត ដោយអនិមិត្តានុបស្សនា, លះបង់នូវកិលេសដែលជាទីតាំង ដោយអប្បណិហិតានុបស្សនា, លះបង់នូវការប្រកាន់ស្អិត ដោយសុញ្ញតានុបស្សនា, លះបង់ធម៌ជាហេតុនៅអាស្រ័យនៃការប្រកាន់ថា មានខ្លឹមសារ ដោយការឃើញច្បាស់ នូវធម៌ ដោយអធិប្បញ្ញា, លះបង់នូវការប្រកាន់ខ្ជាប់ ដោយសេចក្តីវង្វេងដោយយថាភូតញ្ញាណទស្សនៈ, លះបង់នូវការប្រកាន់ខ្ជាប់ ក្នុងអាល័យ



ដោយអាទីនវានុបស្សនា, លះបង់ការមិនពិចារណា ដោយបដិសង្ខានុបស្សនា, លះបង់ការប្រកាន់ស្អិត ដោយអំណាចនៃការប្រកបព្រមដោយវិវដ្តានុបស្សនា, លះបង់នូវកិលេសទាំងឡាយដែលជាទីតាំងនៃទិដ្ឋិ ដោយសោតាបត្តិមគ្គ, លះបង់នូវកិលេសទាំងឡាយ ដែលគ្រោតគ្រាត ដោយសកទាគាមិមគ្គ, លះបង់នូវកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅព្រមដោយល្អិត ដោយអនាគាមិមគ្គ, លះបង់កិលេសទាំងពួងទាំងឡាយ ដោយអរហត្តមគ្គ ឈ្មោះថា សីល, ការវៀរចាក ឈ្មោះថា សីល, ចេតនា ឈ្មោះថា សីល, សំវរៈ ឈ្មោះថា សីល, ការមិនប្រព្រឹត្តិកន្លង ឈ្មោះថា សីល, សីលទាំងឡាយ មានសភាពបែបនេះ ប្រព្រឹត្តទៅព្រមដើម្បីការមិនក្តៅក្រហាយស្តាយក្រោយនៃចិត្ត ប្រព្រឹត្តទៅដើម្បីបាមោជ្ជៈ ប្រព្រឹត្តទៅព្រមដើម្បីបីតិ ប្រព្រឹត្តទៅព្រមដើម្បីបស្សទ្ធិ ប្រព្រឹត្តទៅដើម្បីសោមនស្ស ប្រព្រឹត្តទៅដើម្បីសេពឲ្យបានច្រើន ប្រព្រឹត្តទៅដើម្បីភាវនា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យបានច្រើន ប្រព្រឹត្តទៅព្រមដើម្បីធម៌ដែលជាគ្រឿងប្រដាប់ ប្រព្រឹត្តទៅដើម្បីគ្រឿងបរិក្ខារ ប្រព្រឹត្តទៅដើម្បីគ្រឿងអែបនែប ប្រព្រឹត្តទៅដើម្បីបំពេញបញ្ញា ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីឧបសមៈ ដើម្បីអភិញ្ញា ដើម្បីការត្រាស់ដឹង ដើម្បីនិព្វាន [១]" ដូច្នេះ ។

ក៏បណ្តាធម៌ទាំង ៥ ប្រការ មានបហានៈជាដើមនោះ ឈ្មោះថា ធម៌ណានីមួយ ដែលលោកហៅថា "បហានៈ" មិនមានទេ លើកលែងត្រឹមតែធម្ម គឺការមិនកើតឡើង នៃទោសទាំងឡាយ មានបាណាតិបាតជាដើម មានប្រការដូចយើងបានពោលហើយតែម្យ៉ាង ។ តែការលះបង់

---

១- សុ. ខុ. បដិ. ភាគទី ៦៩ ទំព័រទី ១០៦ ។

នោះៗ ជាគ្រឿងចូលទៅទ្រទ្រង់ ដោយសេចក្ដីថា ជាគ្រឿងតម្កល់នូវកុសលធម៌នោះៗ ផង និង ជាគ្រឿងរួបរួម ព្រោះកិរិយាធ្វើមិនឲ្យមានភាពរាត់រាយផង ព្រោះហេតុណា, ព្រោះហេតុនោះ (ការលះបង់នោះ) ព្រះមានព្រះភាគត្រាស់ហៅថា "សីល" ព្រោះសេចក្ដីថា ប្រក្រតី (ឫសគល់) ពោលគឺកិរិយាចូលទៅជិត ទ្រទ្រង់ និង កិរិយារួបរួម តាមន័យដែលយើងពោលហើយ ក្នុងខាងដើមនុ៎ះឯង ។ ធម៌ទាំងឡាយ ៤ ក្រៅអំពីនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រោះសំដៅយកការប្រព្រឹត្តិទៅឯង នៃចិត្ត ដោយអំណាចនៃការវៀរចាកទោសនោះ ៗ ផង ដោយអំណាចការសង្រួម(បិទ) នូវទោសនោះៗ ផង ដោយអំណាចនៃចេតនាប្រកបព្រម ដោយវេរមណីសីល និង សំវរសីល ទាំងពីរនោះផង ដោយអំណាចនៃការមិនប្រព្រឹត្តិកន្លង នៃបុគ្គលអ្នកមិនប្រព្រឹត្តកន្លងនូវបាណាតិបាតនោះៗ ផង ។ ចំណែកសេចក្ដីថា ធម៌ ៤ យ៉ាង មានវេរមណីសីលជាដើមនោះ ជាសីល គឺព្រះដ៏មានព្រះភាគ ទ្រង់ប្រកាសហើយ ក្នុងកាលមុននុ៎ះឯង ។ សីល ៥ ប្រការ ដោយអំណាចនៃសីលមានបហានសីលជាដើម យ៉ាងនេះឯង ។

ចំណែកការដោះស្រាយ នូវបញ្ហាទាំងឡាយនេះ ថា "ធម្មជាតអ្វីឈ្មោះថា សីល?, សីល ដោយអត្ថថា ដូចម្ដេច?, ធម្មជាតិអ្វី ជាលក្ខណៈ, ជាកិច្ច, ជាហេតុ និង ជាផល របស់សីលនោះ?, សីល មានអានិសង្សប៉ុន្មានយ៉ាង?, សីលនេះ មានប៉ុន្មានប្រការ?" ដូច្នេះ បានចប់ស្រេចហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

(សេចក្ដីសៅហ្មង និង ផូរផង់នៃសីល)

(៣៦) ចំណែកបញ្ហាកម្មណា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា



ចុះសភាវៈអ្វី ជាសេចក្ដីសៅហ្មង? និង ធម្មជាតអ្វី ជាសេចក្ដីផូរផង់នៃសីលនោះ? ។ យើងនឹងពោល ក្នុងបញ្ហាកម្មនោះ ។ ភាពនៃទោសមានការដាច់ជាដើម ជាសេចក្ដីសៅហ្មងនៃសីល ។ ភាពនៃគុណ មានការមិនដាច់ជាដើម ជាសេចក្ដីផូរផង់នៃសីល ។

(សេចក្ដីសៅហ្មងនៃសីល)

ចំណែកខាងភាពនៃសីលដាច់ជាដើមនោះ គឺលោកសង្គ្រោះហើយ ដោយការបែកធ្លាយ (នៃសីល) ដែលមានលាភ និង យស ជាដើម ជាហេតុ ១ ដោយមេថុនសំយោគ ៧ ប្រការ ១ ។

ពិតដូច្នោះមែន ក្នុងកងនៃអាបត្តិទាំងឡាយ ៧ សិក្ខាបទ ត្រង់ខាងដើមក្ដី ត្រង់ខាងចុងក្ដី របស់ភិក្ខុណា ជាសិក្ខាបទធ្លាយហើយ, សីល របស់ភិក្ខុនោះ ឈ្មោះថា ជាសីលដាច់ (ធ្លុះ) ដូចសំពត់សាកដធ្លុះត្រង់ទីបំផុត(ជាយ), ឯសិក្ខាបទ របស់ភិក្ខុណា ធ្លាយហើយ ត្រង់ទីចំពាក់កណ្ដាល សីល របស់ភិក្ខុនោះ ឈ្មោះថា សីលធ្លុះ ដូចសំពត់សាដកធ្លុះត្រង់កណ្ដាល ។ សិក្ខាបទទាំងឡាយ ២-៣ របស់ភិក្ខុណា ធ្លាយហើយ តាមលំដាប់និងលំដាប់, សីល របស់ភិក្ខុនោះ ឈ្មោះថា សីលពពាល ដូចជាមេគោមានបណ្ដាសម្បុរនៃសរីរៈទាំងឡាយ មានខ្មៅ និង ក្រហមជាដើម សម្បុរណាមួយ ដោយសម្បុរដែលមានចំណែកស្មើប្រាស តាំងឡើងហើយ នៅត្រង់ខ្នងខ្លះ ត្រង់ពោះខ្លះ ។ សិក្ខាបទទាំងឡាយ របស់ភិក្ខុណា ធ្លាយនៅត្រង់ចន្លោះ និងចន្លោះ, សីល របស់ភិក្ខុនោះ ឈ្មោះថា សីលពព្រុស ដូចជាមេគោដែលវិចិត្រហើយ ដោយតំណក់ទឹក មានពណ៌ដែលមានចំណែកស្មើទៅប្រាសហើយត្រង់ចន្លោះៗ ដូច្នោះ ។ ភាវៈនៃសីលដាច់ជាដើម ដោយការបែកធ្លាយ (នៃសីល)

ដែលមានលាភ និង យសជាដើមជាហេតុ រមែងមាន យ៉ាងដូច្នេះឯង ។

(មេថុនសំយោគ ៧)

(ឯការៈនៃសីលដាច់ជាដើម) ដោយអំណាចមេថុនសំយោគ ៧ ប្រការ បណ្ឌិតគប្បីជ្រាប ដូចតទៅនេះ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ហើយ (ក្នុងមេថុនសំយោគនោះថា) :

“ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយប្រពៃ មិនបានប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ (សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ តែថា រមែងត្រេកអរនឹងការដុសខាត់ទួត, ផ្ងូត, ប្របាច់ របស់មាតុគ្រាម, បុគ្គលនោះ រមែងត្រេកអរនឹងការដុសខាត់នោះ រីករាយនឹងការដុសខាត់នោះ និង ដល់នូវសេចក្តីត្រេកអរ ដោយការដុសខាត់ជាដើមនោះ, ម្នាលព្រាហ្មណ៍ នេះឯង ហៅថា ការដាច់ផង ធ្លុះផង ពពាលផង ពព្រុសផង នៃព្រហ្មចរិយធម៌, ម្នាលព្រាហ្មណ៍ បុគ្គលនេះ តថាគតហៅថា បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានបរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ រមែងមិនរួចផុតចាកជាតិ, ជរា និង មរណៈ, សោកៈ, បរិទេវៈ, ទុក្ខៈ, ទោមនស្សៈ, ឧបាយាសៈ, តថាគត ហៅថា គេរមែងមិនរួចចាកទុក្ខបានឡើយ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយប្រពៃ រមែងមិនប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ (សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ ទាំងមិនត្រេកអរនឹងការដុសខាត់ ។ល។ នៃមាតុគ្រាមទេ តែថារមែងនៅចំអកឡកឡឺយសើចក្អាកក្អាយជាមួយនឹង



មាតុគ្រាម, បុគ្គលនោះ រមែងត្រេកអរ ដោយការនៅចំអកឡកឡឺយ ជាដើមនោះ ។ល។ តថាគតហៅថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ។ល។ មិនបានប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ(សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ ទាំងមិនត្រេកអរនឹងការដុសខាត់ ។ល។ ទាំងមិនចំអកឡកឡឺយ សើចក្អាកក្អាយជាមួយនឹងមាតុគ្រាមទេ, តែថា រមែងនៅមៀងមៀង នូវភ្នែកដោយភ្នែក ចំពោះមាតុគ្រាម, បុគ្គលនោះរមែងត្រេកអរ នឹងការមៀងមៀងនូវភ្នែក ដោយភ្នែកនោះ ។ល។ តថាគតហៅថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ។ល។ មិនបានប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ(សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ ទាំងមិនត្រេកអរនឹងការដុសខាត់នៃមាតុគ្រាមទេ ទាំងមិនចំអកឡកឡឺយ សើចក្អាកក្អាយជាមួយនឹងមាតុគ្រាមទេ, ទាំងមិននៅមៀងមៀង ។ល។ ចំពោះមាតុគ្រាមទេ ។ តែថា បុគ្គលនោះ រមែងស្តាប់នូវសំឡេងនៃមាតុគ្រាម ដែលកាលសេចក្តីនិយាយក្តី ច្រៀងក្តី យំក្តី ខាងក្រៅជញ្ជាំង ឬ ខាងក្រៅកំពែង, បុគ្គលនោះ រមែងត្រេកអរ ដោយការស្តាប់សំឡេងជាដើមនោះ ។ល។ តថាគត ហៅថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ។ល។ មិនបានប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ(សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ ទាំងមិនត្រេកអរនឹងការដុសខាត់នៃមាតុគ្រាមទេ ទាំងមិនចំអកឡកឡឺយ សើចក្អាកក្អាយ

ជាមួយនឹងមាតុគ្រាមទេ, ទាំងមិននៅមៀងដៀង ។ល។ ចំពោះមាតុគ្រាមទេ, ទាំងមិនស្តាប់នូវសំឡេងនៃមាតុគ្រាម ដែលកាលយំក្តី ។ល។ តែថា បុគ្គលនោះ រមែងរលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេង ជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើម, បុគ្គលនោះ រមែងត្រេកអរនឹងការធ្លាប់បានសើច ជាមួយនឹងមាតុគ្រាមជាដើមនោះ ។ល។ តថាគត ហៅថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ។ល។ មិនបានប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ (សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ ។ល។ ទាំងមិនរលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេង ជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើមទេ, តែថា បុគ្គលនោះ រមែងឃើញនូវគហបតី ឬក៏ គហបតិបុត្រ ដែលស្កប់ស្កល់ មូលមិត្រ មានគេបម្រើដោយកាមគុណ ៥, បុគ្គលនោះ រមែងត្រេកអរនឹងការឃើញនូវគហបតី ឬ គហបតិបុត្រ ដែលស្កប់ស្កល់ មូលមិត្រ មានគេបម្រើ ដោយកាមគុណ ៥ នោះ ។ល។ តថាគត ហៅថា គេរមែងមិនរួចផុតចាកទុក្ខបានឡើយ ។

ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬ ជាព្រាហ្មណ៍ ។ល។ មិនបានប៉ះពាល់ចំពោះការប៉ះពាល់ ដោយបុគ្គលពីរៗ (សេពមេថុន) មួយអន្លើដោយមាតុគ្រាមទេ ។ល។ ទាំងមិនរលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេង ជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើមទេ, ទាំងមិនឃើញនូវគហបតី ឬក៏ គហបតិបុត្រ ។ល។ ដែលមានគេបម្រើដោយកាមគុណ ៥ ទេ, តែថា



បុគ្គលនោះ រមែងប្រព្រឹត្តនូវព្រហ្មចរិយធម៌ ដើម្បីប្រាថ្នានូវទេពនិកាយណាមួយថា "អញសូមឲ្យបានជាទេវតា ទោះជាទេវតាណាមួយ ដោយសីលនេះផង ដោយវត្តនេះផង ដោយតបៈនេះផង ដោយព្រហ្មចរិយធម៌នេះផង" ដូច្នេះ, បុគ្គលនោះ រមែងត្រេកអរនឹងធម៌នោះ រមែងរីករាយនឹងធម៌នោះ និង ដល់នូវសេចក្តីត្រេកអរ ចំពោះធម៌នោះ, ម្នាលព្រាហ្មណ៍ សូម្បីសេចក្តីត្រេកអរ ដើម្បីចង់កើតជាទេវតានេះ ក៏ហៅថា ការដាច់ផង, ធ្លុះផង, ពពាលផង, ពព្រុសផង នៃព្រហ្មចរិយធម៌ (១) " ដូច្នេះឯង ។

ការៈនៃសីល មានសីលដាច់ជាដើម បណ្ឌិត គប្បីជ្រាបថា "ព្រះមានព្រះភាគ ទ្រង់សង្គ្រោះហើយ ដោយការបែកធ្លាយ (នៃសីល) ដែលមានលាភ និង យសជាដើមជាហេតុ ១ ដោយមេថុនសំយោគ ៧ ប្រការ ១" ដូចបានពោលមកហើយ ។

(សេចក្តីផូរផង់នៃសីល)

ចំណែកខាងការៈនៃសីល មានសីលមិនដាច់ជាដើម លោករួបរួមហើយ ដោយការមិនបែកធ្លាយនូវសិក្ខាបទទាំងឡាយ ដោយប្រការទាំងពួង ១ ដោយការសំដែង នូវអាបត្តិទាំងឡាយដែលធ្លាយហើយ ដែលខ្លួនគប្បីសំដែងបាន ១ ដោយការមិនមាននៃមេថុនសំយោគ ៧ ប្រការ ១ ដោយសេចក្តីល្អដទៃទៀត គឺ ដោយកិរិយាមិនកើតឡើងនៃបាបធម៌ទាំងឡាយមានជាអាទិ៍ គឺៈ កោធៈ, ឧបនាហៈ, មក្ខៈ, បលាសៈ, ឥស្សា, មច្ឆរិយៈ, មាយា, សាថេយ្យៈ, ថម្ភៈ, សារម្ភៈ, មានះ, អតិមានះ, មទៈ, បមាទៈ ជាដើម ១ ដោយការកើតឡើងនៃគុណទាំងឡាយ មាន

---

១- សុ. អំ. ស. ភាគទី ៤៧ ទំព័រទី ១០១ ។

អប្បិច្ឆតាគុណ, សន្តុដ្ឋិតាគុណ និង សល្លេខតាគុណជាដើម ១ ។

មែនពិត សីលទាំងឡាយឯណា ដែលភិក្ខុមិនធ្វើឲ្យបែកធ្លាយហើយ ដើម្បីប្រយោជន៍ ដល់ទោសទាំងឡាយ មានលាភជាដើមក្តី ទុកជាភិក្ខុធ្វើឲ្យបែកធ្លាយហើយ ព្រោះទោស គឺសេចក្តីប្រមាទ តែបានសំដែងហើយក្តី ដែលមេថុនសំយោគទាំងឡាយ ឬ បាបធម៌ទាំងឡាយ មានកោធៈ និង ឧបនាហៈជាដើម មិនបានចូលទៅបៀតបៀនហើយក្តី, សីលទាំងឡាយនោះ លោកហៅថា សីលមិនដាច់, សីលមិនធ្លុះ, សីលមិនពពាល, សីលមិនពព្រុស ដោយប្រការទាំងពួង ។ ក៏សីលទាំងឡាយនោះឯង ឈ្មោះថា ជាសីលរួចខ្លួន ព្រោះការធ្វើនូវភាពជាអ្នករួចខ្លួន, ឈ្មោះថា សីល គឺអ្នកប្រាជ្ញសរសើរហើយ ព្រោះភាវៈនៃសីលនោះ គឺអ្នកប្រាជ្ញទាំងឡាយសរសើរហើយ, ឈ្មោះថា ជាសីលមិនប៉ះពាល់ហើយ ព្រោះភាវៈនៃសីលនោះ គឺតណ្ហា និង ទិដ្ឋិទាំងឡាយមិនបានប៉ះពាល់ត្រូវហើយ និង ឈ្មោះថា ជាសីល ប្រព្រឹត្តទៅព្រមដើម្បីសមាធិ ព្រោះញុំាងឧបចារសមាធិ ឬ អប្បនាសមាធិ ឲ្យប្រព្រឹត្តទៅបានស្រួល ។ ហេតុនោះ ភាវៈនៃសីលជាសីលមិនដាច់ជាដើមនុ៎ះ បណ្ឌិតគប្បីជ្រាបថា ជាសេចក្តីផូរផង់នៃសីលទាំងនោះ ។ ក៏សេចក្តីផូរផង់នេះនុ៎ះ រមែងសម្រេច ដោយអាការៈ ២ គឺៈ ដោយការឃើញទោសនៃសីលវិបត្តិ ១ ដោយការឃើញអានិសង្សនៃសីលសម្បត្តិ ១ ។

### (ទោសនៃសីលវិបត្តិ)

បណ្តាទោស និង អានិសង្សទាំងពីរនោះ ចំណែកទោស នៃសីលវិបត្តិ បណ្ឌិត គប្បីឃើញតាមន័យ ក្នុងសុត្តន្តបិដកជាដើម យ៉ាងនេះ ថា "ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ នៃសីលវិបត្តិ របស់បុគ្គលអ្នក



ទ្រុស្តសីលនេះ មាន ៥ យ៉ាង [១]" ។ ន័យមួយទៀត បុគ្គលទ្រុស្តសីល ព្រោះហេតុនៃខ្លួនទ្រុស្តសីល រមែងមិនជាទីគាប់ចិត្តនៃទេវតា និង មនុស្សទាំងឡាយ ជាអ្នកគឺសព្រហ្មចារីបុគ្គលទាំងឡាយ មិនគួរប្រៀនប្រដៅ ជាអ្នកមានសេចក្តីទុក្ខ និមិត្តពាក្យតិះដៀល ដោយភាពជាអ្នកទ្រុស្តសីល ជាអ្នកមានសេចក្តីក្តៅក្រហាយស្តាយក្រោយ និមិត្តពាក្យសរសើរ ចំពោះអ្នកមានសីលទាំងឡាយ មិនតែប៉ុណ្ណោះ ព្រោះភាពជាអ្នកទ្រុស្តសីលនោះ បុគ្គលនោះ ជាអ្នកមានសម្បុរអាក្រក់, ម្យ៉ាងវិញទៀត ឈ្មោះថា ជាអ្នកមានសម្ផស្សគ្រោតគ្រាត ព្រោះនាំសេចក្តីទុក្ខ ក្នុងអបាយ មកឲ្យដល់ពួកជនទាំងឡាយ ដែលដល់នូវទិដ្ឋានុគតិរបស់បុគ្គលនោះ អស់រាត្រីកាលដ៏យូរ ឈ្មោះថា ជាអ្នកមានតម្លៃថោក ព្រោះធ្វើនូវភាព នៃការមិនមានផលច្រើន ដល់ពួកទាយកទាំងឡាយ ដែលខ្លួនទទួលនូវទេយ្យធម៌ (របស់ពួកគេ) យកមក ដូចជាសំពត់សាជកដែលគេត្បាញហើយ ដោយសម្បកធ្មៃ ដែលជាសំពត់មានពណ៌អាក្រក់ មានសម្ផស្សមិនល្អ និង មានតម្លៃថោក ដូច្នោះឯង ជាអ្នកគឺគេសំអាតបានដោយកម្រ ដូចជារណ្តៅនៃលាមក ដែលត្រាំនៅ អស់កាលជាច្រើនឆ្នាំ ជាអ្នកនៅខាងក្រៅស្រឡះ ចាកប្រយោជន៍ទាំងពីរ ដូចជាឧសដែលបុគ្គលដុតសាកសព (ប្រើការមិនបាន) ដូច្នោះ ទុកជាប្តេជ្ញានូវភាពនៃខ្លួនថា ជាភិក្ខុ ក៏មិនមែនជាភិក្ខុដដែល ដូចជាសត្វលាឈ្មោលដើរតាមហ្វូងគោ (មិនក្លាយទៅជាគោបានឡើយ) ជាអ្នកមានសេចក្តីតក់ស្លុតជានិច្ច ដូចជាបុរសដែលមានពៀរចំពោះបុគ្គលជាទូទៅ ជាអ្នកមិនគួរនៅរួមជាមួយ ដូចជាសាកសព សូម្បីប្រកបដោយគុណ មានសុតៈ

---

១- សុ. អំ. ប. ភាគទី ៩៥ ទំព័រទី ២៨៧ ។

ជាដើម ក៏ជាអ្នកមិនគួរដល់នូវការបូជា នៃសព្រហ្មចារីបុគ្គលទាំងឡាយឡើយ ដូចជាភ្លើង ក្នុងព្រៃស្មសាន មិនគួរដល់ការបូជា របស់ពួកព្រាហ្មណ៍ ជាអ្នកអភ័ព្វ ក្នុងការបានសំរេច នូវគុណវិសេស ដូចមនុស្សខ្វាក់ភ្នែក អភ័ព្វ ក្នុងការឃើញនូវរូប ជាអ្នកមិនមានសេចក្តីសង្ឃឹម ក្នុងព្រះសទ្ធម្ម ដូចកុមារនៃជនចណ្ឌាល មិនមានសេចក្តីសង្ឃឹម ក្នុងរាជ-សម្បត្តិ បើទុកជាសំគាល់(ខ្លួន)ថា "អាត្មាអញ ជាអ្នកមានសេចក្តីសុខ" ដូច្នេះ ក៏ឈ្មោះថា ជាអ្នកដល់ហើយនូវសេចក្តីទុក្ខពិត ព្រោះភាវៈនៃខ្លួនជាអ្នកមានចំណែកនៃសេចក្តីទុក្ខ ដែលព្រះដ៏មានព្រះភាគ ត្រាស់ហើយក្នុងអគ្គិក្ខន្ធបរិយាយសូត្រ ។

ពិតដូច្នោះមែន ព្រះមានព្រះភាគ ព្រះអង្គជាអ្នកឃើញផលនៃកម្មជាក់ច្បាស់ ដោយប្រការទាំងពួង កាលទ្រង់សំដែងនូវសេចក្តីទុក្ខដ៏ខ្លោចផ្សាក្រៃពេក អាចក្នុងកិរិយាញុំាងសេចក្តីក្តៅក្រហាយ ក្នុងហឫទ័យ ឲ្យកើតឡើងហើយ ញុំាងកិរិយាក្អួតនៃលោហិតដ៏ក្តៅ ឲ្យប្រព្រឹត្តទៅ ដោយត្រឹមតែការនឹករលឹក នូវហេតុនោះរឿយ ៗ ជាបច្ច័យ ដល់បុគ្គលដែលទ្រុស្តសីលទាំងឡាយ អ្នកមានចិត្តត្រេកអរីករាយនឹងសេចក្តីសុខ ក្នុងការបរិភោគនូវកាមគុណ ៥ និង ក្នុងសាមីចិកម្ម មានការថ្វាយបង្គំ និងការរាប់អានជាដើម ទើបទ្រង់ត្រាស់ ថា :

"ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញគំនរភ្លើងធំ ឯណោះដែលកំពុងឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅដែរឬ?" ។ ភិក្ខុទាំងឡាយទូលថា "ព្រះករុណាព្រះអង្គ" ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះថា ដូចម្តេច?, ភិក្ខុចូលទៅអង្គុយ ឬ ដេកឱបគំនរភ្លើងធំឯណោះ ដែលកំពុងឆេះ ភ្លឺប្រាល



រន្ទាល សន្ធោសន្ធៅហើយ និង ភិក្ខុអង្គុយ ឬ ដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃ និង ជើងដ៏ទន់ល្វាសល្វន់ តើអំពើណា ប្រសើរជាង?" ។

ភិក្ខុទាំងឡាយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអង្គុយ ឬ ដេកឱបខត្តិយកញ្ញាក្តី ព្រាហ្មណកញ្ញាក្តី គហបតិកញ្ញាក្តី ដែលមានដៃនិងជើងដ៏ទន់ល្វាសល្វន់នុ៎ះ ប្រសើរជាង, បពិត្រព្រះអង្គដ៏ចម្រើន ឯភិក្ខុអង្គុយ ឬ ដេកឱបគំនរភ្លើងធំឯណោះ ដែលកំពុងឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅនុ៎ះ ជាទុក្ខលំបាកពិត" ។

ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគត ប្រាប់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតពន្យល់អ្នកទាំងឡាយ ភិក្ខុអង្គុយ ឬ ដេកឱបគំនរភ្លើងធំឯណោះ ។បេ។ អំពើនុ៎ះឯង ប្រសើរជាង, ភិក្ខុទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត ដែលគួររលឹកដោយសេចក្តីរង្កៀស បិទបាំងអំពើអាក្រក់ មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថា ជាសមណៈ មិនមែនព្រហ្មចារី តែប្តេជ្ញាខ្លួនថា ជាព្រហ្មចារីស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ ជាបុគ្គលមានចិត្តជ្រោកជ្រាកនោះ, ដំណើរនោះ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះ ដល់នូវសេចក្តីស្លាប់ ឬ សេចក្តីទុក្ខស្ទើរតែស្លាប់ ព្រោះតែអង្គុយ ឬ ដេកឱបគំនរភ្លើងនោះ (តែប៉ុណ្ណោះ) ដល់បែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏មិនទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះតែអង្គុយ ឬ ដេកឱបគំនរភ្លើងធំនោះឡើយ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកទ្រុស្តសីលនោះ ជាអ្នកមានធម៌ដ៏អាក្រក់ មានមារយាទមិនស្អាត ដែលគួររលឹក ដោយសេចក្តីរង្កៀស បិទបាំងនូវអំពើអាក្រក់ មិនមែនជា

សមណៈ តែប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី តែប្តេជ្ញាថា ជាព្រហ្មចារី ជាអ្នកស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ មានចិត្តជ្រោកជ្រាក អន្តុយ ឬ ដេកឱបខត្តិយកញ្ញាក្តី ។ល។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះឯង នាំឲ្យភិក្ខុនោះ បានសេចក្តីវិនាស សេចក្តីទុក្ខ អស់កាលយូរ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីស្លាប់ទៅ រមែងទៅកើត ក្នុងអបាយ, ទុគ្គតិ, វិនិបាត, នរក (តទៅទៀត)" ។

ព្រះមានព្រះភាគ លុះទ្រង់សំដែងនូវទុក្ខ មានការបរិភោគ នូវកាមគុណ ៥ ដែលប្រតិព័ទ្ធ ក្នុងស្ត្រីជាបច្ច័យ ដោយសេចក្តីប្រៀបធៀប ដោយគំនរភ្លើង យ៉ាងនេះហើយ ទើបទ្រង់សំដែងនូវទុក្ខ ដែលមានការថ្វាយបង្គំ ការធ្វើអញ្ជលិកម្ម ការប្រើប្រាស់ចីវរ បិណ្ឌបាត គ្រែ តាំង និង វិហារជាបច្ច័យ ដោយសេចក្តីប្រៀបធៀប ដោយខ្សែជាវិការៈនៃកន្ទុយសត្វ លំពែងដ៏មុត បន្ទះដែក ដុំដែក គ្រែដែក តាំងដែក និងខ្ទះដែក ទាំងឡាយនេះ ដោយឧបាយដូចគ្នានេះ ថា :

"ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះ ថាដូចម្តេច? បុរសមានកម្លាំង គប្បីរុំក្ងួតនូវស្មងទាំងពីរ ដោយខ្សែកន្ទុយសត្វយ៉ាងជាប់ ខ្សែនោះ ក៏មុតស្បែកសម្បុរថ្ងៃ លុះមុតស្បែកសម្បុរថ្ងៃហើយ ក៏មុតស្បែកខាងក្នុង លុះមុតស្បែកខាងក្នុងហើយ ក៏មុតសាច់ លុះមុតសាច់ហើយ ក៏មុតសរសៃ លុះមុតសរសៃហើយក៏មុតឆ្អឹង លុះមុតឆ្អឹងហើយ ក៏ចុចជាប់ទៅនឹងខួរក្នុងឆ្អឹង, ភិក្ខុ ត្រេកអរនឹងកិរិយាថ្វាយបង្គំ របស់ខត្តិយមហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏ គហបតិមហាសាលទាំងឡាយ (ទាំងពីរនេះ) តើណាប្រសើរជាង ? ។ល។



ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះ ថាដូចម្តេច? បើបុរសមានកម្លាំង ពួយនឹងលំពែងដ៏មុត ដែលគេលាបដោយប្រេង ចំដើមទ្រូង, ភិក្ខុ ត្រេកអរនឹងអញ្ជលិកម្ម របស់ខត្តិយ-មហាសាលទាំងឡាយ ឬ ព្រាហ្មណមហាសាលទាំងឡាយ ឬក៏គហបតិមហាសាលទាំងឡាយ តើណា ប្រសើរជាង ? ។ល។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះ ថាដូចម្តេច ? បើបុរសមានកម្លាំង ស្រោបកាយ ដោយបន្ទះដែក ដ៏ក្តៅដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ, ភិក្ខុ ប្រើប្រាស់នូវចីវរ របស់ខត្តិយមហាសាលទាំងឡាយ ។ល។ ដែលគេឲ្យដោយសទ្ធា តើណា ប្រសើរជាង ? ។ល។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះ ថាដូចម្តេច ? បុរសមានកម្លាំង បើកមាត់ ដោយសណ្ឌាសដែក ដ៏ក្តៅដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅហើយ ដាក់នូវដុំទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងតែឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅក្នុងមាត់, ដុំទង់ដែងនោះ គប្បីរលាកបបូរមាត់ របស់បុរសនោះផងរលាកមាត់ផង រលាកអណ្តាតផង រលាក-កផង រលាកទ្រូងផងរលួយទាំងពោះវៀនធំ និង ពោះវៀនតូច ធ្លាក់របូតទៅ ខាងក្រោមផង, ភិក្ខុឆាន់នូវបិណ្ឌបាត របស់ខត្តិយមហាសាលទាំងឡាយ ។ល។ ដែលគេឲ្យដោយសទ្ធា តើណា ប្រសើរជាង ? ។ល។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះ ថាដូចម្តេច ? បុរសមានកម្លាំង ចាប់ (បុរសឯទៀត) ត្រង់ក្បាល ឬត្រង់-ក ហើយទន្គិចឲ្យអង្គុយ ឬ ឲ្យដេកលើគ្រែដែក ឬ តាំងដែកដ៏ក្តៅ

ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ, ភិក្ខុ ប្រើប្រាស់នូវគ្រែ ឬ តាំង របស់ខត្តិយមហាសាលទាំងឡាយ ។ល។ ដែលគេឲ្យដោយសទ្ធា តើណា ប្រសើរជាង? ។ល។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្ដីនោះ ថា ដូចម្ដេច? បុរសមានកម្លាំង ចាប់ (នូវបុរសឯទៀត) យួរជើង (ទាំងពីរ) ឡើងលើ ឲ្យក្បាលសំយុងចុះក្រោម ហើយបោះទៅ ក្នុងខ្ទះទង់ដែងក៏ក្ដៅ ដែលភ្លើងកំពុងឆេះ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ, កាលបុរសនោះ កំពុងតែឆេះពុះផុល ក្នុងខ្ទះទង់ដែងនោះ អណ្ដែតឡើងមកលើម្ដងលិចចុះទៅក្រោមម្ដង ទៅទទឹងម្ដង, ភិក្ខុ ប្រើប្រាស់នូវវិហារ របស់ខត្តិយមហាសាលទាំងឡាយ ។ល។ ដែលគេឲ្យដោយសទ្ធា តើណា ប្រសើរជាង ? ។ល។ បុរសនោះ រមែងចូលទៅកើត ។ល។ (១) ” ដូច្នេះឯង ។

ព្រោះហេតុនោះ បណ្ឌិត គប្បីជ្រាបកិរិយាឃើញទោស ក្នុងសីលវិបត្តិ ដោយការពិចារណា ដោយន័យមានជាអាទិ៍យ៉ាងនេះ ថា :

សេចក្ដីសុខក្នុងកាម មានផលជាទុក្ខ ក្រហល់ក្រហាយ
ដ៏ក្រៃលែងជាងទុក្ខ ដែលកើតពីការឱបនូវគំនរនៃភ្លើង
កាលបើបុគ្គល មានសីលធ្លាយហើយ មិនព្រមលះបង់
ចេញទេ តើសេចក្ដីសុខ នឹងមានមកអំពីទីណា ។

សេចក្ដីសុខ ក្នុងកិរិយាទទួលគ្រេកអរ នូវការក្រាប
ថ្វាយបង្គំ នឹងមានដូចម្ដេចកើត ដល់បុគ្គលដែលមាន
សីលវិបត្តិ អ្នកមានចំណែក ដោយទុក្ខដ៏ក្រៃលែង ជាង

១- សុ. អំ. ស. ភាគទី ៤៧ ទំព័រទី ២៣៣ ។



ទុក្ខ ដែលកើតអំពីកិរិយាក្ដួត ឬ ពួតនូវស្មង ដោយខ្សែ
ដែលបុគ្គលត្របាញ់ ដោយរោមកន្ទុយសត្វដ៏មាំ ? ។

សេចក្ដីសុខ ក្នុងការទទួលគ្រេកអរ នូវអញ្ជលិកម្ម
នៃបុគ្គលអ្នកមានសទ្ធាទាំងឡាយ ឯណា ដែលជាហេតុ
នៃសេចក្ដីទុក្ខ ដ៏ក្រៃលែងជាងសេចក្ដីទុក្ខ ដែលកើតអំពី
ការប្រហារដោយលំពែង សេចក្ដីសុខនោះនឹងមានដល់
បុគ្គលដែលមិនមានសីលបាន យ៉ាងដូចម្ដេចកើត ? ។

សម្ផស្ស នៃបន្ទះដែក ដ៏ឆ្អិនឆ្អៅទាំងឡាយ នៅក្នុង
នរក ដែលបុគ្គល(ទ្រុស្តសីល) មិនសង្រួមហើយ គប្បី
សោយ អស់កាលយ៉ាងយូរ ដោយសេចក្ដីសុខឯណា,
សេចក្ដីសុខ ក្នុងការប្រើប្រាស់ចីវរនោះ នឹងមានដល់
បុគ្គលអ្នកមិនបានសង្រួមហើយ ដូចម្ដេចកើត ? ។

បិណ្ឌបាត បើទុកជាមានរសជាត ដ៏ឆ្ងាញ់ពិសា ក៏
ប្រៀបបាននឹងថ្នាំពិស ដ៏ក្លៀវក្លា ដល់បុគ្គលដែលមិន
មានសីល ដែលនឹងត្រូវទៅលេបដុំដែកទាំងឡាយ ដែល
ភ្លើងឆេះច្រាលឆ្អៅ អស់កាលដ៏យូរអង្វែង ។

កិរិយាប្រើប្រាស់នូវគ្រែ និង តាំង របស់បុគ្គលអ្នក
មិនមានសីល បើទុកជាសន្មតថាជាសុខ ក៏គង់ដល់នូវ
សេចក្ដីទុក្ខពិត ព្រោះថា បុគ្គលនោះ នឹងត្រូវឲ្យគ្រែ និង
តាំង ដែលជាវិការនៃដែក ដ៏ឆ្អិនឆ្អៅ ដែលជាទុក្ខទាំង
ឡាយ បៀតបៀន អស់កាលដ៏យូរ ។

សេចក្ដីត្រេកអរ ដោយការនៅអាស្រ័យ ក្នុងវិហារ ដែលគេឲ្យ ដោយសទ្ធា បែបណា នឹងមាន ដល់បុគ្គល ដែលទ្រុស្ដសីល បើបុគ្គលនោះ មុខជានឹងត្រូវទៅនៅ អាស្រ័យ ក្នុងកណ្ដាលនៃខ្ទះដែក ដែលភ្លើងនរក ឆេះឆាប សន្ធោសន្ធៅដដែល ? ។

ព្រះលោកនាថ ជាបរមគ្រូនៃសត្វលោក កាលទ្រង់ត្រាស់តិះដៀល នូវបុគ្គលទ្រុស្ដសីល ឯណា ថា “ជាអ្នកមានសមាចារ គួរនឹកឃើញរង្កៀវចិត្ត ជាអ្នកមានជាតិដូចជាសំរាម (ជាំកខ្វិកកខ្វក់) មានចិត្តទទឹកសើម ដោយរាគៈ ជាបុគ្គលលាមក និង ជាអ្នកស្អុយ ខាងក្នុងផង” ដូច្នេះ, ឆ្ងៃយ! ជីវិត របស់បុគ្គលដែលទ្រុស្ដសីល ឥតប្រាជ្ញា មិនមែនជាសមណៈ តែលបទ្រទ្រង់នូវភេទ របស់ជនជាសមណៈនោះ រស់នៅគ្រាន់តែកំដរ នូវសំបក នៃអត្តភាពទទេ ដែលកិលេសចូលទៅកំចាត់បង់ ជីករំលើងសីលអស់ហើយ ។

សប្បុរសទាំងឡាយ ជាអ្នកមានសីល ក្នុងលោកនេះ តែងចៀសវាង នូវបុគ្គលដែលទ្រុស្ដសីល ឯណា ដូចជាបុគ្គលអ្នកពេញចិត្តខាងប្រដាប់តាក់តែងរាងកាយ តែងចៀសវាងលាមក និង សាកសព ក៏ដូច្នោះដែរ, ជីវិតរបស់បុគ្គលទ្រុស្ដសីលនោះ នឹងរស់នៅបែបណា? ។

បុគ្គលដែលទ្រុស្ដសីលនោះ មិនផុតចាកភ័យទាំងពួង



បានឡើយ តែផុតស្រឡះហើយចាកសេចក្ដីសុខ ក្នុងអធិគមធម៌ទាំងអស់ មានទ្វារចូលទៅកាន់ស្ថានសួគ៌បិទជិតឈឹងអស់ហើយ មានតែឡើងទៅកាន់ផ្លូវសំរាប់ទៅកាន់អបាយ តែម្យ៉ាងគត់ ។

បុគ្គលដទៃ បែបណាសោត ដែលគួរកើតសេចក្ដីករុណា ដល់ជនដែលប្រកបដោយករុណាគុណ ដែលស្មើដោយបុគ្គលទ្រុស្ដសីល ? ទោសក្នុងភាពនៃបុគ្គលដែលទ្រុស្ដសីល មានច្រើនប្រការ ដូចពោលមកនេះ”

*និង ការឃើញ នូវអានិសង្ស ក្នុងសីលសម្បត្តិ បណ្ឌិត ក៏គប្បីឃើញ ដោយន័យដែលផ្ទុយគ្នាអំពីបការៈ ដែលយើងបានពោលហើយ ។*

**ន័យមួយវិញទៀត**

សីលរបស់ភិក្ខុណា ជាសីលបរិសុទ្ធ មិនមានមន្ទិល ការទ្រទ្រង់បាត្រ និង ចីវរ របស់ភិក្ខុនោះ ជាទីនាំមកនូវសេចក្ដីជ្រះថ្លា ទាំងបព្វជ្ជា របស់ភិក្ខុនោះ ក៏មានផល ។

ភ័យ មានភ័យអំពីការតិះដៀលខ្លួនជាដើម មិនដែលធ្លាក់ចុះកាន់ហឫទ័យ របស់ភិក្ខុ ដែលមានសីលបរិសុទ្ធ ឡើយ ហាក់បីដូចជាព្រះអាទិត្យ ដែលមិនដែលធ្លាក់ចុះមកកាន់ទីងងឹត យ៉ាងនោះឯង ។

ភិក្ខុអ្នកមានសីល កាលល្អក្នុងព្រៃគឺតបៈ រមែងល្អ ដោយការដល់ព្រមនៃសីល ដូចព្រះច័ន្ទល្អ នាកណ្ដាលនៃស្រទាប់មេឃ ដោយសម្បត្តិនៃរស្មីដូច្នោះ ។

ត្រឹមតែក្លិនកាយ របស់ភិក្ខុដែលមានសីល ក៏អាចធ្វើនូវសេចក្ដីរីករាយចិត្ត ដល់ទេវតាទាំងឡាយ បានទៅហើយ នឹងពោលទៅដូចម្ដេច ដល់ក្លិននៃសីលសោត ។

ក្លិនរបស់សីល រមែងគ្របសង្កត់នូវសម្បត្តិ នៃគន្ធជាតទាំងឡាយទាំងពួងបាន តែងផ្សាយទៅកាន់ទិសទាំងដប់ មិនមានទើសទាក់ឡើយ ។

សក្ការៈ ដែលទាយកធ្វើហើយ ក្នុងបុគ្គលដែលមានសីល បើទុកណាជាបន្តិចបន្តួច ក៏គង់មានផលច្រើន ព្រោះថា បុគ្គលអ្នកមានសីល ចាត់ទុកថា ជាភាជនៈសម្រាប់តំកល់នូវគ្រឿងបូជា និង សក្ការៈ ។

អាសវធម៌ទាំងឡាយ ដែលមានកិរិយាសម្លាប់ និងកិរិយាចងជាដើម ក្នុងបច្ចុប្បន្ន មិនអាចបៀតបៀន នូវបុគ្គលដែលមានសីលបានឡើយ មិនត្រឹមតែប៉ុណ្ណោះសោត បុគ្គលអ្នកមានសីល តែងជីករំលើងនូវឫសគល់នៃសេចក្ដីទុក្ខ នៅក្នុងបរលោកនាយទាំងឡាយ ។

សម្បត្តិ ក្នុងឋានមនុស្សក្ដី សម្បត្តិក្នុងឋានទេវតាក្ដី កាលបើបុគ្គលដែលមានសីលបរិបូណ៌ ត្រូវការចង់បានហើយ សម្បត្តិទាំងអស់នោះមិនជាក្រីក្រសោះឡើយ ។

ម្យ៉ាងទៀត និព្វានសម្បត្តិ នេះឯណា ដែលជាគុណជាតិស្ងប់កន្លង (មិនមានការក្រហល់ក្រហាយ ដោយកិលេស) ចិត្ត របស់ភិក្ខុ ដែលមានសីលបរិបូណ៌ ក៏



រមែង តែស្ទុះទៅរឿយ ៗ កាន់និព្វានសម្បត្តិនោះឯង ។

ព្រះយោគាវចរកុលបុត្រ ជាបណ្ឌិត គប្បីចំរើននូវអានិសង្ស ដ៏ដេរដាស ដោយអាការៈជាអនេក ក្នុងសីលដែលជាឫសគល់ នៃសម្បត្តិទាំងពួង ឲ្យវិសេសឡើងតាមន័យដែលបានពោលហើយ យ៉ាងនេះឯង ។

*ព្រោះថា កាលបើបណ្ឌិត សំដែងសីលឲ្យច្បាស់លាស់ យ៉ាងនេះហើយ ចិត្ត រមែងងាកចេញអំពីសីលវិបត្តិហើយ ជាធម្មជាតទោរទន់ទៅកាន់សីលសម្បត្តិ ។ ព្រោះហេតុនោះ ភិក្ខុ ឃើញទោស ក្នុងសីលវិបត្តិនេះ និង អានិសង្ស ក្នុងសីលសម្បត្តិនេះ ដូចបានពោលហើយ គប្បីជម្រះសីល ឲ្យបានបរិសុទ្ធផូរផង់ ដោយសេចក្ដីប្រឹងប្រែងគ្រប់ប្រការ ។*

*ឯសីល ក្នុងវិសុទ្ធិមគ្គ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយធម៌ជាប្រធាន គឺ* សីល, សមាធិ, បញ្ញា *ដោយគាថានេះ ថា :* “**សីលេ បតិដ្ឋាយ នរោ សបញ្ញោ**” *ដូច្នេះ គឺខ្ញុំសំដែងមុនគេហើយ ដោយសេចក្ដីអត្ថាធិប្បាយមានប្រមាណប៉ុណ្ណោះឯង ។*

*បរិច្ឆេទ ទី១ ឈ្មោះសីលនិទ្ទេស*
*ក្នុងគម្ពីរវិសុទ្ធិមគ្គ គឺខ្ញុំរចនាហើយ ដើម្បីប្រយោជន៍*
*ដល់ការញ៉ាំងសាធុជនឲ្យរីករាយ ដោយប្រការដូច្នេះ ។*

❈ ❦ ❈

រៀបរៀង ចប់ដោយបរិបូណ៌
នៅថ្ងៃអង្គារ ៨ រោច ខែទុតិយាសាឍ ឆ្នាំកុរ អដ្ឋស័ក ព.ស. ២៥៣៩
ត្រូវនឹងថ្ងៃទី៦ ខែសីហា គ.ស. ១៩៩៦
វេលាម៉ោង ៣ កន្លះ ល្ងាច

*(៣៧) ឥឡូវនេះ សេចក្ដីផូរផង់នៃសីល មានប្រការគឺយើងពោលហើយ រមែងមាន ដោយគុណទាំងឡាយ មានអប្បិច្ឆិតាគុណ និង សន្តុដ្ឋិតាគុណជាដើមឯណា ព្រះយោគីអ្នកមានសីលសមាទានហើយ គប្បីធ្វើការសមាទាននូវធុតង្គ (ជាបន្តទៅទៀត) ដើម្បីញ៉ាំងគុណទាំងឡាយនោះ ឲ្យបានសម្រេច ព្រោះថា កាលបើធ្វើយ៉ាងនេះ សីលផង របស់ព្រះយោគីនោះ មានមន្ទិលគឺខ្ទួនលាងហើយ ដោយទឹកគឺគុណ មានសេចក្ដីប្រាថ្នាតិច, សេចក្ដីសន្តោស, សេចក្ដីជុសខាត់, សេចក្ដីស្ងប់ស្ងាត់, ការមិនសន្សំ, ការប្រារព្ធសេចក្ដីព្យាយាម និង គុណមានការចិញ្ចឹមងាយជាដើម នឹងជាសីលបរិសុទ្ធល្អ វត្តទាំងឡាយផង របស់ព្រះយោគីនោះ ក៏នឹងបានសម្រេច, (ព្រះយោគី) អ្នកមានសមាចារទាំងពួងបរិសុទ្ធ ដោយគុណគឺសីល និង វត្តដែលមិនមានទោស យ៉ាងដូច្នេះហើយ នឹងជាអ្នកឈ្មោះថា តម្កល់នៅស៊ប់ហើយ ក្នុងវង្សនៃព្រះអរិយៈ ៣ ប្រការ ដែលមានក្នុងកាលមុន ជាអ្នកគួរដល់កិរិយាបានសម្រេច នូវអរិយវង្ស ទី៤ ពោលគឺភាពនៃខ្ទួនមានភាវនា ជាទីមកត្រេកអរ ហេតុណា, ហេតុនោះ យើងនឹងប្រារព្ធ (ផ្ដើម) នូវធុតង្គកថា (ដូចតទៅ) ។*

*មែនពិត ព្រះមានព្រះភាគ ទ្រង់ត្រាស់អនុញ្ញាតធុតង្គទាំងឡាយ ១៣ យ៉ាង ដល់កុលបុត្រទាំងឡាយដែលមានលោកាមិសលះបង់ហើយ អ្នកមិនអាឡោះអាល័យ ក្នុងកាយ និង ជីវិត អ្នកប្រាថ្នា ដើម្បីញ៉ាំងអនុលោមប្បដិបទា ឲ្យសម្រេចតែម្យ៉ាង ។ ធុតង្គ ទាំង ១៣ យ៉ាងនេះ គឺអ្វីខ្លះ? ។ ធុតង្គទាំង ១៣ នោះ គឺ :*

១- បំសុកូលិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយាទ្រទ្រង់នូវសំពត់បំសុកូលជាប្រក្រតី,*



២- តេចីវរិកង្គៈ *អង្គរបស់ភិក្ខុអ្នកមានតែត្រៃចីវរ ជាប្រក្រតី,*

៣- បិណ្ឌបាតិកង្គៈ *អង្គរបស់ភិក្ខុអ្នកមានកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាត ជាប្រក្រតី,*

៤- សបទានចារិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយាត្រាច់ទៅដើម្បីបិណ្ឌបាត រៀងតាមលំដាប់ផ្ទះ ជាប្រក្រតី,*

៥- ឯកាសនិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគ នូវភោជន តែក្នុងអាសនៈ ១ ជាប្រក្រតី,*

៦- បត្តបិណ្ឌិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយាបរិភោគ នូវភោជន តែក្នុងបាត្រ ជាប្រក្រតី,*

៧- ខលុបច្ឆាភត្តិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយាមិនឆាន់នូវបច្ឆាភត្ត ជាប្រក្រតី,*

៨- អារញ្ញិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅតែក្នុងព្រៃ ជាប្រក្រតី,*

៩- រុក្ខមូលិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យទៀបគល់ឈើ ជាប្រក្រតី,*

១០- អព្ភោកាសិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងទីវាល ជាប្រក្រតី,*

១១- សោសានិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅអាស្រ័យក្នុងព្រៃស្មសាន ជាប្រក្រតី,*

១២- យថាសន្ថតិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅ តែក្នុងទីសេនាសនៈ ដែលសង្ឃសំដែងឲ្យ ជាប្រក្រតី,*

១៣- នេសជ្ជិកង្គៈ *អង្គរបស់ភិក្ខុ អ្នកមានកិរិយានៅ ដោយការ*

*អង្គុយជាប្រក្រតី ។*

សេចក្តីវិនិច្ឆ័យ ក្នុងធុតង្គនោះ បណ្ឌិតគប្បីជ្រាប ដោយអត្ថវិគ្គហៈ ១ ដោយអាការៈទាំងឡាយ មានលក្ខណៈជាដើម ១ ដោយការសមាទាន ១ ដោយវិធី ១ ដោយប្រភេទ ១ ដោយការបែកធ្លាយ ១ ដោយអានិសង្ស នៃធុតង្គនោះៗ ១ ដោយកុសលត្តិកៈ ១ ដោយការវែកញែកគុណមានធុតង្គគុណជាដើម ១ ដោយសង្ខេប និងដោយពិស្តារ ១ ។

(វិនិច្ឆ័យដោយអត្ថ)

*បណ្តាបទទាំងនោះ នឹងវិនិច្ឆ័យ ដោយអត្ថវិគ្គហៈ ជាមុន, ចីវរឯណា ប្រៀបដូចជា គឺបុគ្គលគួរខ្ពើម ដូចជាអាចម៍ដី ក្នុងទីនោះៗ ព្រោះការៈនៃចីវរនោះ បិតនៅលើអាចម៍ដីទាំងឡាយ ក្នុងទីទាំងឡាយ មានផ្លូវថ្នល់, ព្រៃស្មសាន, គំនរសំរាមជាដើម ទីណាមួយ, ហេតុនោះ ចីវរនោះ ឈ្មោះថា បំសុកូល ។ម្យ៉ាងទៀត ចីវរណា ដល់នូវភាពគឺបុគ្គលគួរខ្ពើម ដូចអាចម៍ដី ព្រោះហេតុនោះ ចីវរនោះ ឈ្មោះថា បំសុកូល ។ អធិប្បាយថា “ចីវរនោះ ដល់នូវភាពគឺបុគ្គលគប្បីខ្ពើមដូចជាអាចម៍ដី” ។ ការទ្រទ្រង់ចីវរ ដែលបុគ្គលគួរខ្ពើមដូចជាអាចម៍ដី មានអត្ថវិគ្គហៈ បានហើយ យ៉ាងនេះ ឈ្មោះថា សំពត់បំសុកូល ។ សំពត់បំសុកូល ជាប្រក្រតីនៃភិក្ខុនេះ ហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា មានសំពត់បំសុកូលជាប្រក្រតី ។ អង្គនៃភិក្ខុអ្នកមានសំពត់បំសុកូល ជាប្រក្រតី ឈ្មោះថា អង្គ នៃភិក្ខុអ្នកមានសំពត់បំសុកូល ជាប្រក្រតី ។ ហេតុ លោកហៅថា*



*“អង្គ” ។ ហេតុនោះ បណ្ឌិត គប្បីជ្រាបថា “ភិក្ខុនោះ ជាអ្នកមានសំពត់បំសុកូលជាប្រក្រតី ដោយការសមាទានណា, ពាក្យថា អង្គនុ៎ះ ជាឈ្មោះ នៃការសមាទាននោះ” ។ ដោយន័យដូចគ្នានេះដែរ ចីវរ ៣ ពោលគឺ សង្ឃាដី, ចីវរ, ស្បង់ ជាប្រក្រតី នៃភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា មានចីវរ ៣ ជាប្រក្រតី ។ អង្គនៃភិក្ខុ អ្នកមានចីវរ ៣ ជាប្រក្រតី ឈ្មោះថា អង្គនៃភិក្ខុអ្នកមានចីវរ ៣ ជាប្រក្រតី ។*

*ឯការធ្លាក់ចុះនូវដុំ នៃអាមិសទាំងឡាយ ពោលគឺភិក្ខា ហេតុនោះ ឈ្មោះថា* បិណ្ឌបាត *។ (មួយទៀត) ការធ្លាក់ចុះនៃដុំបាយទាំងឡាយ ដែលជនទាំងឡាយដទៃ ឲ្យហើយ ហេតុនោះ ឈ្មោះថា បិណ្ឌបាត ។ អធិប្បាយថា “ការធ្លាក់ចុះ ក្នុងបាត្រ នៃដុំបាយទាំងឡាយ ដែលពួកជនដទៃឲ្យហើយ” ។ ភិក្ខុណា ស្វែងរក គឺចូលទៅរកត្រកូលនោះៗ ស្វែងរកនូវបិណ្ឌបាតនោះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកស្វែងរកនូវបិណ្ឌបាត ។ ម្យ៉ាងទៀត ការធ្លាក់ទៅ ដើម្បីបិណ្ឌបាតជាវត្ត របស់ភិក្ខុនេះ ហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកត្រាច់ទៅដើម្បីបិណ្ឌបាតជាវត្ត ។ ពាក្យថា “ការធ្លាក់ទៅ” សេចក្តីថា ការត្រាច់ទៅ ។ ភិក្ខុអ្នកត្រាច់ទៅ ដើម្បីដុំបាយជាវត្តហ្នឹងឯង ឈ្មោះថា ភិក្ខុអ្នកត្រាច់ទៅ ដើម្បីដុំបាយជាវត្ត ។ អង្គនៃភិក្ខុអ្នកត្រាច់ទៅ ដើម្បីដុំបាយជាវត្ត ឈ្មោះថា អង្គនៃភិក្ខុអ្នកត្រាច់ទៅ ដើម្បីដុំបាយជាវត្ត ។*

*ការដាច់ លោកហៅថា* ទានៈ *។ ការទៅប្រាសចាកការដាច់ ឈ្មោះថា* អបទានៈ *។ អធិប្បាយថា “ការមិនដាច់” ។ ការត្រាច់ទៅឯណា ប្រព្រឹត្តទៅមួយអន្លើ ដោយការមិនដាច់ ការត្រាច់ទៅនោះ ឈ្មោះថា* សបទានៈ *។ អធិប្បាយថា “ការត្រាច់ទៅប្រាសចាកការ*

ដាច់ គឺការត្រាច់ទៅ តាមលំដាប់នៃផ្ទះ” ដូច្នេះ ។ កិរិយាត្រាច់ទៅ មួយអន្លើដោយការប្រាសចាកការដាច់នេះ ជាប្រក្រតី របស់ភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានការត្រាច់ទៅកាន់លំដាប់នៃផ្ទះជាប្រក្រតី។ ភិក្ខុអ្នកមានការត្រាច់ទៅកាន់លំដាប់នៃផ្ទះជាប្រក្រតីហ្នឹងឯង ឈ្មោះថា ភិក្ខុអ្នកមានកិរិយាត្រាច់ទៅកាន់លំដាប់នៃផ្ទះជាប្រក្រតី, អង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅ កាន់លំដាប់ផ្ទះជាប្រក្រតីនោះ ឈ្មោះថា អង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅ កាន់លំដាប់ផ្ទះជាប្រក្រតី ។

ការឆាន់ ក្នុងអាសនៈតែមួយ ឈ្មោះថា ឯកាសនៈ ។ ការឆាន់ក្នុងអាសនៈតែមួយនោះជាប្រក្រតី របស់ភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានការឆាន់ ក្នុងអាសនៈមួយជាប្រក្រតី ។ អង្គនៃភិក្ខុអ្នកមានការឆាន់ ក្នុងអាសនៈមួយ ជាប្រក្រតីនោះ ឈ្មោះថា អង្គនៃភិក្ខុអ្នកមានការឆាន់ ក្នុងអាសនៈមួយជាប្រក្រតី ។

ដុំបាយ ក្នុងបាត្រតែមួយប៉ុណ្ណោះ ព្រោះភាជនៈ ទី២ គឺភិក្ខុឃាត់ហើយ ឈ្មោះថា ដុំបាយក្នុងបាត្រ ។ ឥឡូវនេះ ព្រោះធ្វើនូវសេចក្តីសំគាល់នូវដុំបាយ ក្នុងបាត្រ ក្នុងកាលជាទីទទួលនូវដុំបាយ ក្នុងបាត្រ, ដុំបាយក្នុងបាត្រ ជាប្រក្រតី របស់ភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានដុំបាយក្នុងបាត្រ ជាប្រក្រតី ។ អង្គ នៃភិក្ខុអ្នកមានដុំបាយក្នុងបាត្រ ជាប្រក្រតី របស់ភិក្ខុនោះ ឈ្មោះថា អង្គនៃភិក្ខុអ្នកមានដុំបាយក្នុងបាត្រ ជាប្រក្រតី ។

ពាក្យថា “ខលុ” ជានិបាត(ប្រព្រឹត្តទៅ) ក្នុងអត្ថថា ហាមឃាត់ ។ ភត្ត ដែលភិក្ខុជាអ្នកហាមឃាត់ហើយបានមក ក្នុងកាលជាខាងក្រោយ ឈ្មោះថា បច្ឆាភត្ត ។ ការឆាន់នូវបច្ឆាភត្តនោះ ក៏ឈ្មោះថាបច្ឆាភត្តដែរ ។



ព្រោះធ្វើសេចក្តីសំគាល់ដល់ការឆាន់នូវបច្ឆាភត្ត ក្នុងបច្ឆាភត្តភោជននោះ កិរិយាឆាន់នូវបច្ឆាភត្ត ជាប្រក្រតី របស់ភិក្ខុនេះ ហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា បច្ឆាភត្តិកៈ ។ ភិក្ខុអ្នកមិនមានកិរិយាឆាន់នូវបច្ឆាភត្តជាប្រក្រតី ឈ្មោះថា ភិក្ខុអ្នកមិនមានកិរិយាឆាន់ភត្តដែលខ្លួនហាមឃាត់ហើយ បានមក ក្នុងកាលជាខាងក្រោយជាប្រក្រតី ។ ពាក្យថា “បច្ឆាភត្ត” នេះ ជាឈ្មោះនៃអតិរិត្តភោជន ដែលហាមឃាត់ហើយ ដោយអំណាចនៃកិរិយាសមាទាន ។ ចំណែកក្នុងអដ្ឋកថា លោកពោល ថា “សត្វស្លាបមួយក្បាល ឈ្មោះខលុ សត្វស្លាបនោះ ពាំនូវផ្លែឈើបានហើយ កាលបើផ្លែឈើនោះ ជ្រុះធ្លាក់ហើយ ក៏មិនស៊ីផ្លែឈើដទៃទៀតទេ, ភិក្ខុនេះ ដូចជាសត្វស្លាបនោះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានកិរិយាមិនឆាន់ នូវបច្ឆាភត្ត ជាប្រក្រតី ដូចជាសត្វស្លាប ឈ្មោះខលុ ។ អង្គនៃភិក្ខុជាខលុបច្ឆាភត្តិកៈនោះ ឈ្មោះថា ខលុបច្ឆាភត្តិកង្គៈ ។

ការនៅក្នុងព្រៃ ឈ្មោះថា អរញ្ញៈ ។ ការនៅ ក្នុងព្រៃនោះ ជាប្រក្រតី របស់ភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានកិរិយានៅ ក្នុងព្រៃជាប្រក្រតី ។ អង្គ នៃភិក្ខុអ្នកមានកិរិយានៅ ក្នុងព្រៃជាប្រក្រតីនោះ ឈ្មោះថា អារញ្ញិកង្គៈ ។

ការនៅទៀបគល់ឈើ ឈ្មោះថា រុក្ខមូល ។ ការនៅទៀបគល់ឈើនោះ របស់ភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានការនៅទៀបគល់ឈើជាប្រក្រតី ។ អង្គ នៃភិក្ខុអ្នកមានការនៅទៀបគល់ឈើ ជាប្រក្រតីនោះ ឈ្មោះថា រុក្ខមូលិកង្គៈ ។

ន័យសូម្បីក្នុងអព្ភោកាសិកង្គៈ និង សោសានិកង្គៈ ក៏ន័យដូចនេះដែរ ។

សេនាសនៈ ដែលភិក្ខុក្រាលហើយ យ៉ាងណាទុំះឯង ឈ្មោះថា

សេនាសនៈដែលភិក្ខុក្រាលហើយយ៉ាងណា ។ ពាក្យថា "យថាសន្ថតៈ" នេះ គឺជាឈ្មោះនៃសេនាសនៈ ដែលភិក្ខុជាសេនាសនបញ្ញាបកៈ សំដែងហើយ ជាដំបូង យ៉ាងនេះថា "សេនាសនៈនេះ ត្រូវបានដល់លោក" ដូច្នេះ។ ការនៅលើសេនាសនៈ ដែលគេក្រាលហើយយ៉ាងណានោះ ជាប្រក្រតី របស់ភិក្ខុនេះ ព្រោះហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានកិរិយានៅលើសេនាសនៈ ដែលគេក្រាលហើយយ៉ាងណា ជាប្រក្រតី ។ អង្គ នៃភិក្ខុអ្នកមានកិរិយានៅលើសេនាសនៈ ដែលគេក្រាលហើយយ៉ាងណា ជាប្រក្រតីនោះ ឈ្មោះថា យថាសន្ថតិកង្គៈ ។

ការឃាត់នូវការដេកហើយ នៅដោយការអង្គុយ ជាប្រក្រតី របស់ភិក្ខុនេះ ហេតុនោះ (ភិក្ខុនោះ) ឈ្មោះថា អ្នកមានការឃាត់ នូវការដេកហើយ នៅដោយការអង្គុយជាប្រក្រតី ។ អង្គ នៃភិក្ខុអ្នកមានការឃាត់នូវការដេកហើយ នៅដោយការអង្គុយ ជាប្រក្រតីនោះ ឈ្មោះថា នេសជ្ជិកង្គៈ ។

ចំណែកអង្គទាំងអស់ហ្នឹងឯង ឈ្មោះថា ធុតង្គ ព្រោះជាអង្គរបស់ភិក្ខុដែលឈ្មោះថា ធុតៈ (អ្នកកំចាត់បង់នូវកិលេស) ព្រោះភាវៈជាអ្នកកំចាត់បង់នូវកិលេស ដោយការសមាទាននោះៗ ។ ម្យ៉ាងទៀត ឈ្មោះថា ធុតង្គ ព្រោះមានញាណដែលបានវោហារថា "ធុតៈ" ព្រោះជាគ្រឿងកំចាត់បង់នូវកិលេសជាអង្គ ។ ម្យ៉ាងវិញទៀត អង្គទាំងឡាយនោះ ឈ្មោះថា ធុតៈ ព្រោះកំចាត់បង់នូវធម៌ដែលជាសឹកសត្រូវទាំងឡាយបានផង ជាអង្គនៃការប្រតិបត្តិផង ព្រោះហេតុនោះ ទើបឈ្មោះថា ធុតង្គ ។ បណ្ឌិត គប្បីដឹងច្បាស់សេចក្តីវិនិច្ឆ័យ ដោយអត្ថវិគ្គហៈ ក្នុងពាក្យថា ធុតង្គនេះ យ៉ាងនេះ ជាមុនសិនចុះ ។



(វិនិច្ឆ័យដោយលក្ខណៈជាដើម)

ក៏ធុតង្គទាំងអស់នេះឯង មានចេតនាជាគ្រឿងសមាទាន ជាលក្ខណៈ ។ សមដូចជាពាក្យដែលលោកបានពោលថា "អ្នកណាសមាទាន, អ្នកនោះ បានដល់ បុគ្គល, បុគ្គលសមាទាន ដោយធម៌ណា ធម៌ទាំងឡាយនោះ បានដល់ ចិត្ត និង ចេតសិក, ចេតនាជាគ្រឿងសមាទាន ណា ការសមាទាននោះ ឈ្មោះថា ធុតង្គ, (វចីបយោគ) ហាមឃាត់នូវកិច្ចណា, កិច្ចនោះ ឈ្មោះថា វត្ថុ " ។ មួយទៀត ធុតង្គទាំងអស់ហ្នឹងឯង មានការកំចាត់បង់សេចក្តីល្មោភ ជាកិច្ច, មានសេចក្តីមិនលោភ ជាហេតុ, មានធម៌ដ៏ប្រសើរ, មានភាពជាអ្នកប្រាថ្នាតិច ជាដើម ជាផល ។ បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ដោយអាការៈទាំងឡាយ មានលក្ខណៈជាដើម ក្នុងធុតង្គនិទ្ទេសនេះយ៉ាងនេះ ។

(វិនិច្ឆ័យដោយការសមាទាន និង វិធីជាដើម)

(៣៨) ចំណែកសេចក្តីវិនិច្ឆ័យ ក្នុងបទទាំង ៥ មានបទជាដើម ថា "សមាទានវិធានតោ" ដូច្នេះ បណ្ឌិត គប្បីជ្រាប ដូចតទៅ ។ ធុតង្គទាំងឡាយទាំងពួងហ្នឹងឯង, កាលព្រះដ៏មានព្រះភាគ ទ្រង់ធរមាននៅឡើយ, ភិក្ខុត្រូវសមាទាន ក្នុងសំណាក់នៃព្រះមានព្រះភាគពិត, កាលបើព្រះមានព្រះភាគទ្រង់បរិនិព្វានទៅហើយ, ភិក្ខុត្រូវសមាទាន ក្នុងសំណាក់នៃព្រះមហាសាវក, កាលបើព្រះមហាសាវកនោះមិនមានទេ, ភិក្ខុត្រូវសមាទាន ក្នុងសំណាក់នៃព្រះខីណាស្រព, ព្រះអនាគាមី, ព្រះសកទាគាមី, ព្រះសោតាបន្ន, ព្រះថេរៈអ្នកទ្រទ្រង់នូវព្រះត្រៃបិដក, ព្រះថេរៈអ្នកទ្រទ្រង់បិដកពីរ, ព្រះថេរៈអ្នកទ្រទ្រង់បិដកមួយ, ព្រះថេរៈអ្នកផ្ទៀងផ្ទាត់និកាយមួយ, ព្រះអដ្ឋកថាចារ្យ, កាលបើព្រះអដ្ឋកថាចារ្យនោះ មិនមានទេ, ភិក្ខុ

ត្រូវសមាទាន ក្នុងសំណាក់នៃភិក្ខុអ្នកទ្រទ្រង់នូវធុតង្គ, តែបើភិក្ខុអ្នកទ្រទ្រង់នូវធុតង្គនោះ មិនមានទេ, ភិក្ខុត្រូវបោសលានព្រះចេតិយ អង្គុយប្រហោងហើយ ពោលសមាទានឲ្យដូចជាពោលសមាទាន ក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធដូច្នោះ។ មួយទៀត សូម្បីភិក្ខុសមាទានដោយខ្លួនឯងក៏បានដូចគ្នាពិត ។ ក៏ក្នុងការសមាទាន ដោយខ្លួនឯងនេះ ត្រូវសំដែងរឿងនៃសេចក្តីប្រាថ្នាតិច ក្នុងធុតង្គ របស់ព្រះថេរៈជាបង នៃព្រះថេរៈដែលត្រូវជាបងប្អូននឹងគ្នាពីរនាក់ ក្នុងចេតិយបព៌ត ។ នេះជាពាក្យដែលពោលដោយទូទៅ ជាដំបូងសិន ។ ឥឡូវនេះ យើងនឹងពណ៌នា នូវការសមាទាន, វិធី, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ទាំងឡាយនៃធុតង្គមួយ ៗ (ដូចតទៅនេះ) :

### ១- បំសុកូលិកង្គ:

### (វិធីសមាទាន ក្នុងបំសុកូលិកង្គ:)

*(៣៩) ជាបឋម បំសុកូលិកង្គធុតង្គ គឺជាធុតង្គ ដែលភិក្ខុត្រូវសមាទាន ដោយពាក្យទាំងពីរនេះ ពាក្យណាមួយ ថា “ខ្ញុំ ហាមឃាត់នូវគហបតិទានចីវរ, ខ្ញុំ សមាទាននូវបំសុកូលិកធុតង្គ” ដូច្នេះ ។ នេះជាការសមាទាន ក្នុងបំសុកូលិកង្គធុតង្គនេះ ជាដំបូង ។*

### (វិធីក្នុងបំសុកូលិកង្គ:)

*ក៏ព្រះយោគីនោះ អ្នកមានធុតង្គសមាទានហើយ យ៉ាងនេះ ត្រូវទទួលយកនូវចីវរ (សំពត់) ទាំងឡាយនេះ ចីវរណាមួយ គឺ :*

១- សោសានិកៈ *សំពត់ដែលធ្លាក់ក្នុងព្រៃស្មសាន,*

២- បាបណិកៈ *សំពត់ដែលធ្លាក់ចុះទៀបរានផ្សារ,*

៣- រថិយចោឡៈ *សំពត់ដែលគេបោះចោលត្រង់ផ្លូវរថ,*



៤- សង្ការចោឡៈ *សំពត់ដែលគេចោលលើគំនរសំរាម,*

៥- សោត្ថិយៈ *សំពត់ដែលគេជូតនូវមន្ទិលនៃគភ៌,*

៦- នហានចោឡៈ *សំពត់ដែលពេទ្យបណ្តេញកូត យកទៅទទូរគ្របអ្នកជំងឺ លិចទាំងក្បាលផ្ងូតទឹកហើយចោល,*

៧- តិត្ថចោឡៈ *សំពត់ដែលគេចោលនៅក្បែរកំពង់ងូតទឹក,*

៨- គតប្បច្ចាគតៈ *សំពត់ដែលអ្នកទៅកាន់ទីស្មសានចោល,*

៩- អគ្គិទឌ្ឍៈ *សំពត់ដែលត្រូវភ្លើងឆេះហើយគេចោល,*

១០- គោខាយិតៈ *សំពត់ដែលគោអង្កៀមស៊ីហើយគេចោល,*

១១- ឧបចិកាខាយិតៈ *សំពត់ដែលកណ្តៀរកោរ,*

១២- ឧន្ទូរខាយិតៈ *សំពត់ដែលកណ្តុរកាត់ហើយគេចោល,*

១៣- អន្តច្ឆិន្នៈ *សំពត់ដែលដាច់រេចត្រង់រឹម,*

១៤- ទសច្ឆិន្នៈ *សំពត់ដែលរេចត្រង់ជាយ,*

១៥- ធជាហដៈ *សំពត់ដែលគេចងធ្វើទង់នៅក្នុងទីចម្បាំង,*

១៦- ថូបចីវរៈ *សំពត់ដែលគេរុំព័ទ្ធជំបូកធ្វើពលិកម្ម,*

១៧- សមណចីវរៈ *សំពត់របស់សមណៈ,*

១៨- អាភិសេកិកៈ *សំពត់ដែលគេចោលត្រង់ទីរាជាភិសេក,*

១៩- ឥទ្ធិមយៈ *សំពត់ដែលសម្រេចដោយឫទ្ធិ,*

២០- បន្ថិកៈ *សំពត់ដែលជ្រុះនៅកណ្តាលផ្លូវ,*

២១- វាតាហដៈ *សំពត់ដែលខ្យល់កួចរសាត់យកទៅឆ្ងាយ,*

២២- ទេវទត្តិយៈ *សំពត់ដែលទេវតាផ្តល់ឲ្យ,*

២៣- សាមុទ្ទិយៈ *សំពត់ដែលរលកសមុទ្រផាត់មកលើគោក,*

*ហើយហែកសាច់សំពត់ ដែលពុកផុយចោលហើយ បោកគក់ជម្រះ*

សាច់សំពត់ដែលនៅមាំមួន ធ្វើជាចីពរ ផ្លាស់គហបតិចីវរចាស់ ចេញហើយប្រើប្រាស់ចុះ ។

បណ្តាសំពត់ទាំងនោះ សំពត់ដែលធ្លាក់ចុះក្នុងទីស្មសាន ឈ្មោះថា សោសានិកៈ ។ សំពត់ដែលធ្លាក់ចុះហើយ ត្រង់មាត់ទ្វាររានផ្សារ ឈ្មោះថា បាបណិកៈ ។ សំពត់ដែលបុគ្គលត្រូវការ ដោយបុណ្យទាំងឡាយ ចោលនៅត្រង់ផ្លូវរថ តាមចន្លោះ នៃបង្អួច ឈ្មោះថា រថិយចោឡៈ ។ សំពត់ដែលគេចោលនៅលើទីសំរាម ឈ្មោះថា សង្ការចោឡៈ ។ សំពត់ដែលគេជូតមន្ទិលគ៌ភហើយចោល ឈ្មោះថា សោត្ថិយៈ ។ បានឮមកថា មាតា របស់អាមាត្យ ឈ្មោះតិស្សៈ ឲ្យគេយកសំពត់ ថ្លៃមួយសែន ជូតមន្ទិលនៃគ៌ភហើយ ឲ្យគេ(យកទៅចោលត្រង់ផ្លូវ ឈ្មោះតាលវេឡិ ដោយគិត ថា “ពួកភិក្ខុ អ្នកមានកិរិយាទ្រទ្រង់ នូវសំពត់បំសុកូល ជាប្រក្រតី នឹងកាន់យក” ។ ភិក្ខុទាំងឡាយ កាន់យក ដើម្បី (ប៉ះ) សំពត់ដែលចាស់(រហែក)តែម្យ៉ាង ។ ជនទាំងឡាយដែលពួកគ្រូខ្មោច ឲ្យផ្ងូតទឹកព្រមទាំងក្បាលហើយ ចោលសំពត់ ណានីមួយ ដើរទៅ ដោយការសំគាល់ ថា “សំពត់នោះ គឺជាសំពត់កាលកណ្ណី” សំពត់នោះ ឈ្មោះថា នហានចោឡៈ ។ កំណាត់សំពត់ចាស់ៗ ដែលគេចោលហើយត្រង់កំពង់សម្រាប់ងូតទឹក ឈ្មោះថា តិត្ថចោឡៈ ។ ពួកមនុស្សទៅកាន់ទីស្មសាន ត្រឡប់មកវិញ ងូតទឹកស្រេចហើយ ក៏ចោលសំពត់ណា សំពត់នោះ ឈ្មោះថា គតប្បច្ចាគតៈ ។ សំពត់ដែលត្រូវភ្លើងឆេះ(ខ្វះ)ហើយ ឈ្មោះថា អគ្គិទឍ្ឍៈ ។ មនុស្សទាំងឡាយ តែងចោលនូវសំពត់នោះផងដែរ។ សំពត់ទាំងឡាយ មានសំពត់ដែលគោអង្កៀមជាដើម ប្រាកដហើយមែនពិត ។ ព្រោះថា មនុស្សទាំងឡាយ តែងចោលនូវសំពត់បែបនោះ ។



សំពត់ដែលមនុស្សទាំងឡាយ កាលឡើងជិះនាវា ចងជាទង់ជ័យហើយ ទើបឡើង ឈ្មោះថា ធជាហដៈ ។ ការដែលភិក្ខុកាន់យកនូវសំពត់នោះ កាលបើផុតកន្ទុយភ្នែក នៃមនុស្សទាំងនោះហើយ ក៏សមគួរ ។ សូម្បីសំពត់ណា ដែលគេចងជាទង់ហើយ ទុកក្នុងទីចម្បាំង, ក្នុងពេលដែលទាហានទាំងពីរបក្សទៅហើយ ភិក្ខុកាន់យកនូវសំពត់នោះក៏គួរ ។ សំពត់ដែលគេរុំព័ទ្ធជុំបូកហើយ ធ្វើពលិកម្ម ឈ្មោះថា ថូបចីវរៈ ។ សំពត់ដែលជារបស់ភិក្ខុផងគ្នា ឈ្មោះថា សមណចីវរៈ ។ សំពត់ដែលគេចោលក្នុងទីរាជាភិសេក ឈ្មោះថា អាភិសេកិកៈ ។ ចីវរ របស់ឯហិភិក្ខុ ឈ្មោះថា ឥទ្ធិមយៈ ។ សំពត់ដែលធ្លាក់ចុះ ក្បែរចន្លោះផ្លូវ ឈ្មោះថា បន្ថិកៈ ។ ក៏សំពត់ណា ដែលធ្លាក់ព្រោះសេចក្តីភ្លេចភ្លាំងសតិ នៃម្ចាស់ទាំងឡាយ, សំពត់នោះ ភិក្ខុត្រូវរក្សាបន្តិចសិនហើយ ចាំកាន់យក ។ សំពត់ដែលខ្យល់បក់ផាត់ ឲ្យធ្លាក់ចុះក្នុងទីឆ្ងាយ ឈ្មោះថា វាតាហដៈ ។ ក៏ការដែលភិក្ខុមិនឃើញម្ចាស់ទាំងឡាយ កាន់យកសំពត់នោះ ក៏គួរ ។ សំពត់ ឯណា ដែលទេវតាទាំងឡាយឲ្យហើយ ដូចជាសំពត់ដែលនាងលាជទេវធីតា ប្រគេនដល់ព្រះអនុរុទ្ធត្ថេរដូច្នោះ, សំពត់នោះ ឈ្មោះថា ទេវទត្តិយៈ ។ សំពត់ ដែលរលកនៃសមុទ្រទាំងឡាយ ផាត់ឲ្យអណ្តែតឡើងមកលើគោក ឈ្មោះថា សាមុទ្ទិយៈ ។

ចំណែកសំពត់ណា ដែលពួកទាយកប្រគេនហើយ ដោយពាក្យថា “យើងទាំងឡាយប្រគេនដល់សង្ឃ” ដូច្នេះក្តី ដែលភិក្ខុទាំងឡាយ កាលត្រាច់ទៅ ដើម្បីសូមកំណាត់សំពត់ បានមកហើយក្តី, សំពត់នោះ មិនឈ្មោះថា សំពត់បំសុកូលទេ ។ សូម្បីក្នុងសំពត់ ដែលភិក្ខុផងគ្នា ឲ្យក៏បណ្ឌិត គប្បីជ្រាបដែរ ។ សំពត់ណា ដែលភិក្ខុអ្នកចែកចីវរ ចែកឲ្យ

តាមលំដាប់វស្សាក្តី ជាចីវរប្រចាំសេនាសនៈក្តី, សំពត់នោះ មិនឈ្មោះថា សំពត់បំសុកូលទេ, សំពត់ដែលភិក្ខុជាចីវរភាជកៈ មិនបានឲ្យហើយនុ៎ះឯង ទើបឈ្មោះថា សំពត់បំសុកូល ។ សូម្បីក្នុងសំពត់បំសុកូលដូច្នោះ សំពត់ណា ដែលពួកទាយក ទុកហើយទៀបទីជិតជើងរបស់ភិក្ខុ, តែភិក្ខុនោះ ទុកប្រគេន លើដៃរបស់បំសុកូលិកភិក្ខុ, សំពត់នោះ ឈ្មោះថា បរិសុទ្ធតែម្ខាង ។ សំពត់ណា ដែលពួកទាយក ទុកប្រគេនហើយលើដៃរបស់ភិក្ខុ, តែថា ភិក្ខុនោះ ដាក់ទៀបទីជិតជើង, សូម្បីសំពត់នោះ ក៏ឈ្មោះថា ឯកតោសុទ្ធិកៈដែរ ។ សំពត់ណា ដែលទាយក ដាក់ប្រគេនហើយ នៅក្បែរទីជិតជើងនៃភិក្ខុ, ទាំងភិក្ខុនោះ ក៏ប្រគេន (ដល់បំសុកូលិកភិក្ខុ) ដោយទំនងដូចគ្នាដែរ, សំពត់នោះ ឈ្មោះថា ឧភតោសុទ្ធិកៈ (បរិសុទ្ធទាំងពីរខាង) ។ សំពត់ណា ដែលភិក្ខុបានមក ព្រោះទាយកដាក់ក្នុងដៃហើយ ភិក្ខុនោះ ដាក់ក្នុងដៃ(នៃបំសុកូលិកភិក្ខុ) ដូចគ្នា, សំពត់នោះ ឈ្មោះថា ចីវរមិនឧក្រិដ្ឋ ។ បំសុកូលិកភិក្ខុ គួរដឹងប្រភេទនៃសំពត់បំសុកូលនេះ ដោយប្រការដូច្នេះហើយ ប្រើប្រាស់ចីវរចុះ ។ នេះ គឺជាពិធី (ប្រតិបត្តិ) ក្នុងបំសុកូលិកង្គៈនេះ ។

(ប្រភេទនៃបំសុកូលិកភិក្ខុ)

ឯប្រភេទ បណ្ឌិត គប្បីជ្រាប ដូចតទៅ។ បំសុកូលិកភិក្ខុ មាន ៣ ពួក គឺ ថ្នាក់ឧក្រិដ្ឋ, ថ្នាក់មជ្ឈិម, ថ្នាក់ទាប ។ បណ្តាបំសុកូលិកភិក្ខុទាំង ៣ ពួកនោះ ភិក្ខុដែលកាន់យកតែសំពត់ដែលធ្លាក់ ក្នុងទីស្មសានប៉ុណ្ណោះ ឈ្មោះថា ថ្នាក់ឧក្រិដ្ឋ ។ ភិក្ខុអ្នកទទួលយក នូវសំពត់ដែលគេទុកហើយ ដោយគិតថា "បព្វជិត នឹងទទួលយក" ដូច្នេះ ឈ្មោះថា ថ្នាក់មជ្ឈិម ។ ភិក្ខុ អ្នកទទួលនូវសំពត់ ដែលគេដាក់ប្រគេន ក្បែរទីជិត



នៃជើង ឈ្មោះថា ថ្នាក់មុទុ (ថ្នាក់ទាប) ។

(ការបែកធ្លាយ ក្នុងបំសុកូលិកង្គៈ)

ធុតង្គ របស់បំសុកូលិកភិក្ខុទាំង ៣ ពួកនោះ ពួកណានីមួយក៏ដោយ រមែងបែកធ្លាយ ក្នុងខណៈដែលភិក្ខុត្រេកអរ នូវសំពត់ដែលគ្រហស្ថទាំងឡាយប្រគេនហើយ តាមសេចក្តីពេញចិត្តរបស់ខ្លួន ។ នេះជាការបែកធ្លាយ ក្នុងបំសុកូលិកង្គៈនុ៎ះ ។

(អានិសង្ស ក្នុងបំសុកូលិកង្គៈ)

ចំណែកអានិសង្ស បណ្ឌិត គប្បីជ្រាប ដូចតទៅ គឺ : (១) កើតមានសេចក្តីប្រតិបត្តិ ដែលសមគួរដល់និស្ស័យ ព្រោះបាលីថា "បព្វជ្ជាអាស្រ័យនូវបំសុកូលចីវរ" ដូច្នេះ, (២) បានឋិតនៅក្នុងអរិយវង្សទីមួយ, (៣) ភាពមិនមានការព្រួយ ព្រោះការរក្សា, (៤) ភាពជាអ្នកមិនមានការប្រព្រឹត្តិវិការ ដោយបុគ្គលដទៃ, (៥) មិនមានការភ័យខ្លាច ព្រោះចោរភ័យ, (៦) មិនមានតណ្ហា ក្នុងការប្រើប្រាស់, (៧) មានបរិក្ខារសមគួរដល់សមណៈ, (៨) មានបច្ច័យ តាមដែលព្រះមានព្រះភាគត្រាស់សរសើរហើយថា "សំពត់ទាំងនេះ មានតម្លៃតិចផង, ជារបស់ដែលរកបាន ដោយងាយស្រួលផង, ជារបស់ដែលមិនមានទោសផង" ដូច្នេះ, (៩) ភាពជាអ្នកនាំមក នូវសេចក្តីជ្រះថ្លា, (១០) ការសម្រេចផលនៃអប្បិច្ឆតាគុណជាដើម, (១១) ការចំរើនឡើង នូវសម្មាបដិបត្តិ, (១២) ធ្វើឲ្យបច្ឆាជន យកជាតម្រាប់តាម ។

(អវសានគាថា ក្នុងបំសុកូលិកង្គៈ)

ព្រះយោគី អ្នកទ្រទ្រង់នូវបំសុកូលចីវរ រមែងល្អក្នុងការ

សម្លាប់មារ និង សេនាមារ ដូចជាក្សត្រដែលមានគ្រឿងក្រោះចងហើយល្អ ក្នុងទីចម្បាំងដូច្នោះឯង ។ អម្បាលតែព្រះសម្ពុទ្ធ ដែលជាបរមគ្រូរបស់សត្វលោក ម្ដេចគង់ព្រះអង្គលះបង់ នូវសំពត់ទាំងឡាយដ៏ថ្លៃថ្លា មានសំពត់ដែលគេនាំមក អំពីដែនកាសីជាដើមហើយ មកទ្រទ្រង់នូវបំសុកូលចីវរណា, ចុះភិក្ខុអង្គណាសោត ក៏មិនទ្រទ្រង់ នូវបំសុកូលចីវរនោះបាន ? ព្រោះហេតុនោះ ព្រះយោគាវចរភិក្ខុ កាលរលឹកឃើញនូវពាក្យប្ដេជ្ញា របស់ខ្លួន ក៏គប្បីជាអ្នកត្រេកអរ ក្នុងបំសុកូលចីវរ ដ៏សមគួរដល់សេចក្ដីព្យាយាមចុះ ។

*នេះ ជាការពណ៌នា ក្នុងពិធីសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងបំសុកូលិកង្គៈ ជាដំបូង ។*

## ២- តេចីវរិកង្គៈ

### (វិធីសមាទាន ក្នុងតេចីវរិកង្គៈ)

*(៤០) ក៏ក្នុងលំដាប់ នៃបំសុកូលិកង្គៈនោះ អង្គនៃភិក្ខុអ្នកទ្រទ្រង់នូវចីវរ ៣ ជាអង្គគឺភិក្ខុត្រូវសមាទាន ដោយពាក្យទាំងឡាយនេះ ពាក្យណាមួយថា “ខ្ញុំ ហាមឃាត់នូវចីវរជាគម្រប់ ៤, ខ្ញុំ សមាទាន នូវអង្គនៃភិក្ខុអ្នកទ្រទ្រង់នូវចីវរ ៣ ” ដូច្នេះ ។*

### (ពិធីក្នុងតេចីវរិកង្គៈ)

*ក៏ភិក្ខុអ្នកទ្រទ្រង់នូវចីវរបើនោះ បានសំពត់ដើម្បីចីវរ មិនអាចដើម្បីធ្វើ ព្រោះសេចក្ដីមិនសប្បាយក្ដី មិនបាននូវកម្ម គឺការវាស់វែងក្ដី គ្រឿងឧបករណ៍ទាំងឡាយ មានម្ជុលជាដើម វត្ថុឯណាមួយក្ដី មិនគ្រប់គ្រាន់ដរាបណា, ត្រូវទុក ដរាបនោះ ។ ទោសព្រោះបច្ច័យនៃសំពត់ដែលភិក្ខុទុកហើយ មិនមានទេ ។ តែថា ការដែលភិក្ខុទុកតាំងតែពីពេលដែលខ្លួនជ្រលក់ហើយ មិនគួរឡើយ ។ ភិក្ខុអ្នកទ្រទ្រង់នូវចីវរបើនោះ ឈ្មោះថា* ធុតង្គចោរ *។ នេះជាវិធាននៃតេចីវរិកង្គៈនោះ ។*



### (ប្រភេទនៃតេចីវរិកភិក្ខុ)

*បើពោលដោយប្រភេទ តេចីវរិកភិក្ខុនេះ មាន ៣ ពួក ។ បណ្ដា ៣ ពួកនោះ ភិក្ខុថ្នាក់ឧក្រិដ្ឋ ក្នុងពេលជ្រលក់ គប្បីជ្រលក់ស្បង់មុន ឬ ចីវរមុន ក៏បាន រួចស្លៀកស្បង់ ឬ ចីវរនោះហើយ ជ្រលក់ចីវរក្រៅពីនេះ ។ ភិក្ខុ ត្រូវឃ្លុំចីវរនោះហើយ ជ្រលក់សង្ឃាដី ។ តែការដែលភិក្ខុស្លៀកសង្ឃាដី មិនគួរឡើយ ។ នេះ គឺជាវត្ត ក្នុងសេនាសនៈ ទីបំផុតនៃស្រុក ចំពោះតែតេចីវរិកភិក្ខុនេះ ។ ចំណែកខាងអារញ្ញិកភិក្ខុ ទោះបីបោកគក់ជ្រលក់ចីវរទាំងពីរដំណាលគ្នា ក៏បាន។ តែថា ភិក្ខុត្រូវអង្គុយ ក្នុងទីជិតឲ្យល្មមតែឃើញមនុស្សណាមួយ ដើរមក អាចនឹងទាញសំពត់កាសាវៈមកគ្របលើខ្លួនបាន ។ តាមធម្មតា ភិក្ខុ អ្នកថ្នាក់មធ្យម បើមានសំពត់កាសាវៈសំរាប់ជ្រលក់ ក្នុងរោងសំរាប់ជ្រលក់, ការដែលភិក្ខុស្លៀក ឬ ដណ្ដប់ចីវរនោះហើយ ធ្វើនូវកម្ម គឺការជ្រលក់ទើបគួរ ។ សម្រាប់ភិក្ខុថ្នាក់អន់ ទោះបីស្លៀក ឬ ដណ្ដប់នូវចីវរទាំងឡាយ របស់ភិក្ខុផងគ្នាហើយធ្វើកម្ម គឺការជ្រលក់ ក៏គួរ ។ សូម្បីសំពត់កម្រាល ដែលមាននៅក្នុងរោងជ្រលក់នោះ ក៏សមគួរ ដល់ភិក្ខុថ្នាក់អន់នោះ ។ តែថា ការដែលភិក្ខុថ្នាក់អន់ រក្សាទុក ក៏មិនគួរ ។ ទោះបីភិក្ខុថ្នាក់អន់ ប្រើប្រាស់សូម្បីចីវរ របស់ពួកភិក្ខុផងគ្នា បន្តបន្ទាប់គ្នា ក៏មិនគួរ ។ ក៏ប៉ុន្តែ បើ*

តេចីវរិកភិក្ខុ នឹងបង្កើនសំពត់អង្សកៃមួយមកទៀត គម្រប់ ៤ ក៏បាន ។ ប៉ុន្តែសំពត់អង្សកៃនោះ ត្រូវមានទទឹង ១ ចំអាម, បណ្តោយ ៣ ហត្ថ តែប៉ុណ្ណោះ ទើបសមគួរ ។

(ការបែកធ្លាយ ក្នុងតេចីវរិកង្គ:)

ក៏ធុតង្គ របស់តេចីវរិកភិក្ខុទាំងបីនេះ រមែងបែកធ្លាយ ក្នុងខណៈដែលខ្លួនត្រេកអរហើយ ចំពោះចីវរជាគម្រប់ ៤ នុ៎ះឯង ។ នេះគឺជាការបែកធ្លាយ ក្នុងតេចីវរិកង្គ:នេះ ។

(អានិសង្ស ក្នុងតេចីវរិកង្គ:)

ចំណែកអានិសង្ស មានដូចតទៅនេះ, គុណទាំងឡាយ មានជាអាទិ៍យ៉ាងនេះ គឺ: (១) ភិក្ខុអ្នកទ្រទ្រង់នូវចីវរ ៣ ឈ្មោះថា ជាអ្នកមានសេចក្តីសន្តោស ដោយចីវរល្មមតែរក្សានូវកាយបាន, (២) ដោយសេចក្តីសន្តោសនោះ ភិក្ខុនោះ កាន់យកតែ (ចីវរបី) ត្រាច់ទៅ ហាក់ដូចជាសត្វបក្សី, (៣) ភាពជាអ្នកមានសេចក្តីប្រារព្ធតិច, (៤) ការវៀរបង់នូវការសន្សំទុកនូវសំពត់, (៥) ភាពជាអ្នកប្រព្រឹត្តស្រាល, (៦) កិរិយាលះបង់នូវសេចក្តីល្មោភហួសកំរិត ក្នុងអតិរេកចីវរ, (៧) ភាពជាអ្នកធ្វើនូវប្រមាណ ក្នុងចីវរដែលគួរ, (៨) ភាពជាអ្នកប្រព្រឹត្តក្បឹល ឬ ពង្រេចនូវកិលេសឲ្យស្តើងចុះ, (៩) កិរិយាសម្រេចនូវគុណទាំងឡាយ មានអប្បិច្ឆតាគុណជាដើម រមែងសំរេច (ដល់ភិក្ខុនោះ) ។

(អវសានគាថា ក្នុងតេចីវរិកង្គ:)

ព្រះយោគី ជាអ្នកប្រាជ្ញ ដឹងនូវរសនៃសេចក្តីសុខ ដែល
កើតអំពីសេចក្តីសន្តោស លះបង់នូវសេចក្តីចំណង់ ក្នុង
សំពត់ដែលលើសកំណត់ វៀរបង់ការសន្សំទុក ជាអ្នក



ទ្រទ្រង់តែចីវរបី, ព្រោះហេតុនោះ ព្រះយោគីដ៏ប្រសើរ
អ្នកមានប្រាថ្នា ដើម្បីត្រាច់ទៅជាសុខ ក៏ត្រូវឲ្យមានតែ
ចីវរ ៣ ជាប់ទៅជាមួយ ហាក់បីដូចជាសត្វបក្សី ដែល
ត្រាច់ទៅ មានតែស្លាប ជាប់ទៅជាមួយនឹងខ្លួនដូច្នោះ
គប្បីធ្វើសេចក្តីត្រេកអរ ក្នុងចីវរដែលមានកំណត់ ។

នេះ ជាការពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងតេចីវរិកង្គ: ។

៣- បិណ្ឌបាតិកង្គ:

(វិធីសមាទានក្នុងបិណ្ឌបាតិកង្គ:)

(៤១) សូម្បីបិណ្ឌបាតិកង្គ: ក៏ជាធុតង្គដែលភិក្ខុត្រូវសមាទានដោយពាក្យទាំង ២ ម៉ាត់នេះ ពាក្យឯណានីមួយ ថា "ខ្ញុំ ហាមឃាត់នូវអតិរេកលាភ, ខ្ញុំសមាទាននូវបិណ្ឌបាតិកង្គធុតង្គ" ដូច្នេះ ។

(វិធីក្នុងបិណ្ឌបាតិកង្គ:)

ក៏ភិក្ខុអ្នកមានកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាតជាវត្តនោះ មិនត្រូវត្រេកអរនឹងភត្តទាំង ១៤ យ៉ាងនេះ គឺ :

១- សង្ឃភត្ត ភត្តដែលគេប្រគេនចំពោះសង្ឃ,

២- ឧទ្ទេសភត្ត ភត្តដែលគេឧទ្ទិសយកភិក្ខុ ១ អង្គក្តី ២ អង្គក្តី អំពីសំណាក់សង្ឃហើយប្រគេន,

៣- និមន្តនភត្ត ភត្តដែលគេនិមន្តភិក្ខុយកទៅប្រគេន,

៤- សលាកភត្ត ភត្តដែលគេប្រគេនតាមស្លាក,

៥- បក្ខិកភត្ត ភត្តដែលគេប្រគេនក្នុង ១ បក្ខ តែ ១ ថ្ងៃ,

៦- ឧបោសថិកភត្ត  ភត្តដែលគេប្រគេនរាល់ៗថ្ងៃឧបោសថ,

៧- បាដិបទិកភត្ត  ភត្តដែលគេកំណត់ប្រគេន តែក្នុងថ្ងៃដើម នៃបក្ខ គឺ ថ្ងៃ ១ កើត ឬ ១ រោច,

៨- អាគន្តុកភត្ត  ភត្តដែលគេប្រគេន ដល់ភិក្ខុអាគន្តុកៈ,

៩- គមិកភត្ត  ភត្តដែលគេប្រគេនដល់ភិក្ខុរៀបដើរផ្លូវឆ្ងាយ,

១០- គិលានភត្ត  ភត្តដែលគេប្រគេនដល់ភិក្ខុដែលមានជំងឺ,

១១- គិលានុបដ្ឋាកភត្ត  ភត្តដែលគេប្រគេនដល់ភិក្ខុ ដែលថែរក្សាភិក្ខុអ្នកមានជំងឺ,

១២- វិហារភត្ត  ភត្តដែលគេប្រគេនចំពោះវត្ត ឬ កុដិ,

១៣- ធុរភត្ត  ភត្តដែលគេតំកល់ទុកក្នុងផ្ទះហើយប្រគេន,

១៤- វារភត្ត  ភត្តដែលគេដាក់វេនគ្នាប្រគេន ។

តែថា បើភត្តទាំងឡាយណា ជាភត្តដែលទាយកមិនពោល ដោយន័យជាដើម ថា “សូមលោកម្ចាស់ទាំងឡាយ ទទួលនូវសង្ឃភត្ត” ដូច្នេះ, ហើយពោលថា “សូមព្រះសង្ឃ ទទួលភិក្ខាក្នុងផ្ទះ នៃយើងទាំងឡាយ សូម្បីលោកម្ចាស់ទាំងឡាយ ក៏សូមទទួលភិក្ខា” ដូច្នេះ ហើយប្រគេន, ភិក្ខុជាបិណ្ឌបាតិកៈ ត្រេកអរនឹងភត្តទាំងនោះ ក៏គួរ ។ សលាកភត្តដែលមិនប្រឡំដោយអាមិស (ដែលកើតឡើង) អំពីសង្ឃក្តី ភត្តដែលទាយកចំអិន ក្នុងវត្តក្តី រមែងសមគួរមែនពិត ។ នេះ គឺ ជាវិធាននៃបិណ្ឌបាតិកភិក្ខុនេះ ។

(ប្រភេទនៃបិណ្ឌបាតិកភិក្ខុ)

បើពោលតាមប្រភេទ បិណ្ឌបាតិកភិក្ខុ នេះឯង មាន ៣ ពួក ។ បណ្តាបិណ្ឌបាតិកភិក្ខុ ទាំង ៣ ពួកនោះ បិណ្ឌបាតិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ



ទទួលភិក្ខា ដែលទាយកនាំមកពីខាងមុខក្តី ពីខាងក្រោយក្តី ឈរនៅទៀបទ្វារនៃផ្ទះ របស់បុគ្គលដទៃហើយ ឲ្យបាត្រទៅពួកទាយកដែលនៅចាំទទួលយកទៅ (ដាក់ភិក្ខា)ក្តី ទទួលភិក្ខា ដែលទាយកនាំមកប្រគេនក្នុងពេលត្រឡប់មកវិញក្តី (ក៏បាន) តែភិក្ខុអង្គុយហើយ ទទួលភិក្ខាក្នុងថ្ងៃនោះមិនបានទេ ។ បិណ្ឌបាតិកភិក្ខុ ថ្នាក់កណ្តាល ទុកជាអង្គុយចុះហើយ ក៏គង់ទទួលបាន ក្នុងថ្ងៃនោះ តែបើទទួលនិមន្តទុកដល់ទៅថ្ងៃស្អែកទៀតពុំបានសោះឡើយ។ បិណ្ឌបាតិកភិក្ខុ ថ្នាក់អន់ ទោះបីទទួលចង្ហាន់ ដើម្បីទុកឆាន់ដល់ទៅថ្ងៃស្អែក ឬ ខានស្អែកទៀតក៏បាន ។ ភិក្ខុជាបិណ្ឌបាតិកៈទាំង ២ ពួកនោះ មិនបាននូវសេចក្តីសុខ ដោយកិរិយានៅតាមទំនើងចិត្តរបស់ខ្លួនទេ ។ មានតែភិក្ខុថ្នាក់ឧក្រិដ្ឋទេ ទើបបាន ។ ដំណាលមកថា ក្នុងស្រុកមួយ មានអរិយវង្ស ។ បិណ្ឌបាតិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ និយាយទៅកាន់ពួកបិណ្ឌបាតិកភិក្ខុ ក្រៅនេះ ថា “ម្នាលលោកដ៏មានអាយុទាំងឡាយ មកពួកយើងទៅស្តាប់ធម៌” ។ បណ្តាភិក្ខុទាំងពីររូបនោះ ភិក្ខុមួយរូប និយាយថា “បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា ជាអ្នកត្រូវមនុស្សម្នាក់ ឲ្យអង្គុយហើយ” ។ ភិក្ខុ មួយរូបទៀត និយាយថា “បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា ទទួលចង្ហាន់មនុស្សម្នាក់ ដើម្បីឆាន់ ក្នុងថ្ងៃស្អែកដែរ” ។ កាលបើមានហេតុយ៉ាងនេះ, ភិក្ខុ ទាំងពីររូបនោះ បានសាបសូន្យហើយ ។ ឯបិណ្ឌបាតិកភិក្ខុថ្នាក់ឧក្រិដ្ឋ មួយរូបទៀត ត្រាច់ទៅបិណ្ឌបាត តាំងពីព្រលឹមស្រាងហើយ សោយនូវរសនៃព្រះធម៌ ។

(ការបែកធ្លាយ ក្នុងបិណ្ឌបាតិកង្គៈ)

ឯធុតង្គ របស់បិណ្ឌបាតិកង្គភិក្ខុទាំងបី ពួកនេះឯង រមែងបែកធ្លាយ

ក្នុងខណៈដែលខ្លួនត្រេកអរ នូវអតិរេកលាភ មានសង្ឃភត្ត ជាដើម ។ នេះជាការបែកធ្លាយ ក្នុងបិណ្ឌបាតិកង្គធុតង្គ ។

(អានិសង្សក្នុងបិណ្ឌបាតិកង្គ:)

ចំណែកអានិសង្សវិញ ដូចតទៅនេះ គឺ (១) សភាពជាអ្នកមានសេចក្តីប្រតិបត្តិ សមគួរដល់និស្ស័យ ព្រោះបាលីថា "បព្វជ្ជាអាស្រ័យការបរិភោគនូវពំនូតបាយ ដែលស្វែងរកដោយកម្លាំងស្មង" ដូច្នេះ, (២) កិរិយាតាំកល់នៅ ក្នុងអរិយវង្សទីពីរ, (៣) ភាពជាអ្នកមិនមានកិរិយាប្រព្រឹត្តិជាប់ដោយបុគ្គលដទៃ, (៤) ភាពជាអ្នកមានបច្ច័យ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សរសើរ ថា "ភោជនទាំងនោះ មានតម្លៃតិចផង ភិក្ខុរកបានដោយងាយផង មិនមានទោសផង" ដូច្នេះ, (៥) ភាព នៃកិរិយាញាំញីនូវសេចក្តីខ្ជិលច្រអូស (៦) ភាពជាអ្នកមានការចិញ្ចឹមជីវិតបរិសុទ្ធស្អាត, (៧) កិរិយាបំពេញនូវសេចក្តីប្រតិបត្តិ ក្នុងសេខិយវត្ត, (៨) ភាពជាអ្នកមិនបាច់ចិញ្ចឹមអ្នកដទៃ, (៩) ការធ្វើនូវសេចក្តីអនុគ្រោះដល់ជនដទៃ, (១០) ការលះបង់នូវមានះ, (១១) កិរិយាហាមឃាត់នូវចំណង់ក្នុងរស(នៃភោជន), (១២) ភាពជាអ្នកមិនមានអាបត្តិ ដោយគណភោជនសិក្ខាបទ បរម្បរភោជនសិក្ខាបទ និង ចារិត្តសិក្ខាបទ (១៣) ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរ ដល់អប្បិច្ឆតាគុណ ជាដើម, (១៤) កិរិយាបង្កើននូវសម្មាបដិបត្តិ, (១៥) កិរិយាអនុគ្រោះដល់ប្រជុំជនជំនាន់ក្រោយ ។

(អវសានគាថា ក្នុងបិណ្ឌបាតិកង្គ:)

ព្រះយោគី អ្នកមានសេចក្តីត្រេកអរដោយស្មើៗ ក្នុង
ដុំបាយដែលគេធ្វើឲ្យជាពំនូតៗ មានកិរិយាចិញ្ចឹមជីវិត



មិនជាប់ ដោយបុគ្គលដទៃ លះបង់សេចក្តីលោភ ក្នុង
អាហារបានហើយ តែងត្រាច់ទៅបាន ក្នុងទិសទាំង ៤
រមែងបន្ទោបង់នូវសេចក្តីខ្ជិលច្រអូស អាជីវៈរបស់លោក
សោត ក៏បរិសុទ្ធស្អាត, ព្រោះហេតុនោះឯង ភិក្ខុ អ្នក
មានប្រាជ្ញាល្អ មិនគប្បីមើលងាយ នូវដំណើរដែលត្រាច់
ទៅដើម្បីភិក្ខាឡើយ ។

ព្រោះថា ពួកទេវតា តែងស្រឡាញ់ ចំពោះភិក្ខុអ្នក
មានការត្រាច់ទៅ ដើម្បីបិណ្ឌបាតជាប្រក្រតី ចិញ្ចឹម
តែខ្លួន មិនចិញ្ចឹមនូវបុគ្គលដទៃ មានសភាពបែបនេះ
តែថា ពួកទេវតា តែងមិនស្រឡាញ់ ចំពោះភិក្ខុដែល
អាស្រ័យលាភ និង សេចក្តីសរសើរឡើយ ។

នេះ គឺជាការពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងបិណ្ឌបាតិកង្គ: ។

៤– សបទានចារិកង្គ:

(វិធីសមាទានក្នុងសបទានចារិកង្គ:)

(៤២) ឯអង្គ នៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅ តាមលំដាប់ច្រក ជាប្រក្រតី ជាអង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ យ៉ាង នេះ ពាក្យណាមួយ ថា "ខ្ញុំហាមឃាត់នូវការប្រព្រឹត្តិលោភលន់, ខ្ញុំសមាទានអង្គនៃភិក្ខុអ្នកមានកិរិយាត្រាច់ទៅតាមលំដាប់ច្រក ជាប្រក្រតី" ដូច្នេះ ។

(វិធីក្នុងសបទានចារិកង្គ:)

ក៏សបទានចារិកភិក្ខុនោះ ត្រូវឈរទៀបទ្វារនៃស្រុក ហើយគប្បី

កំណត់មើលការមិនមានអន្តរាយ ។ សេចក្តីអន្តរាយ រមែងមាននៅត្រង់ប្រក ឬ ស្រុកឯណាមួយ ។ ការដែលភិក្ខុលះបង់ប្រក និង ស្រុកនោះហើយត្រាច់ទៅទីដទៃទៀត ទើបគួរ ។ ភិក្ខុ មិនបាននូវភោជនបន្តិចបន្តួចទៀបទ្វារផ្ទះឯណាក្តី ក្នុងប្រកក្តី ក្នុងស្រុកក្តី ភិក្ខុត្រូវធ្វើឲ្យជាសញ្ញា ថាមិនមែនជាស្រុកហើយ គប្បីត្រាច់ទៅទីដទៃ ។ ភិក្ខុ បាននូវភោជនតិចតួច ក្នុងទីណា ការដែលភិក្ខុលះបង់ទីនោះហើយទៅ មិនគួរឡើយ ។ តែថា ភិក្ខុនេះ គប្បីចូលទៅមុនវេលា ព្រោះថា បើធ្វើដូច្នេះ ភិក្ខុនេះអាចលះបង់កន្លែង ដែលមិនជាទីសប្បាយហើយ ទៅក្នុងទីដទៃទៀត ។ បើមានមនុស្សគេធ្វើទាន ក្នុងវត្ត ឬ មកកណ្តាលផ្លូវ ទទួលយកបាត្រហើយ ប្រគេនបិណ្ឌបាត ដល់ភិក្ខុនោះ, ការដែលភិក្ខុនោះ ទទួលក៏គួរ ។ មួយវិញទៀត សបទានចារិកភិក្ខុនេះ កាលកំពុងដើរទៅ កាន់ផ្លូវក៏ដោយមិនត្រូវត្រាច់ទៅរំលងស្រុក ដែលដល់ព្រមហើយ ក្នុងវេលាត្រាច់ទៅដើម្បីភិក្ខាឡើយ។ សបទានចារិកភិក្ខុនេះ ទោះបីមិនបានភិក្ខាក្តី បានតិចតួចក្តី ក៏ត្រូវតែត្រាច់ទៅ តាមលំដាប់នៃផ្ទះ ក្នុងស្រុកនោះ ។ នេះ គឺជាវិធាននៃសបទានចារិកង្គៈនេះ ។

(ប្រភេទនៃសបទានចារិកភិក្ខុ)

បើពោលតាមប្រភេទ សបទានចារិកភិក្ខុនេះឯង មាន ៣ ពួក ។ បណ្តាទាំង ៣ ពួកនោះ សបទានចារិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ មិនទទួល នូវចង្ហាន់ដែលគេនាំយកមកហើយ អំពីខាងមុខផង នូវចង្ហាន់ដែលទាយកនាំមកហើយ អំពីខាងក្រោយផង នូវចង្ហាន់ដែលទាយក នាំមក



ប្រគេន ក្នុងវេលាត្រឡប់មកវិញផង មានតែលះបង់បាត្រទៀបទ្វារផ្ទះនៃជនដទៃ ។ មែនពិត ក្នុងធុតង្គនេះ សបទានចារិកភិក្ខុ អ្នកប្រាកដស្មើដោយព្រះមហាកស្សបត្ថេរ មិនមានឡើយ ។ ឯកន្លែងដែលព្រះមហា-កស្សបត្ថេរនោះ លះបង់បាត្រ រមែងប្រាកដ ។ ភិក្ខុថ្នាក់កណ្តាល រមែងទទួលចង្ហាន់ ដែលទាយកនាំមកហើយពីខាងមុខផង ពីខាងក្រោយផងនូវចង្ហាន់ដែលទាយកនាំមកហើយ ក្នុងវេលាត្រឡប់មកវិញផង លះបង់បាត្រនៅទៀបទ្វារផ្ទះជនដទៃផង ។ ប៉ុន្តែសបទានចារិកភិក្ខុនេះ មិនអង្គុយរង់ចាំភិក្ខា ។ សបទានចារិកភិក្ខុនោះ ឈ្មោះថា ប្រព្រឹត្តតាមបិណ្ឌបាតិកភិក្ខុថ្នាក់ឧក្រិដ្ឋ ។ សបទានចារិកភិក្ខុ ថ្នាក់អន់ អង្គុយរង់ចាំ (ភិក្ខា) ក្នុងថ្ងៃនោះបាន ។

(ការបែកធ្លាយ ក្នុងសបទានចារិកង្គៈ)

ក៏ធុតង្គ នៃសបទានចារិកភិក្ខុទាំង ៣ ពួកនេះ កាលបើមានការត្រាច់ទៅដើម្បីបិណ្ឌបាត ដោយសេចក្តីលោភលន់កើតឡើង ក៏រមែងបែកធ្លាយ ។ នេះ ជាការបែកធ្លាយ ក្នុងសបទានចារិកង្គធុតង្គនេះ ។

(អានិសង្ស ក្នុងសបទានចារិកង្គៈ)

ឯអានិសង្សដូច្នេះ គឺ (១) ភាពជាបុគ្គលថ្មីថ្មោង អស់កាលជានិច្ចក្នុងត្រកូលទាំងឡាយ, (២) ភាពជាបុគ្គលល្អ ប្រៀបដូចជាព្រះច័ន្ទ, (៣) ការលះបង់មច្ឆរិយៈ ក្នុងត្រកូល, (៤) ភាពជាអ្នកមានសេចក្តីអនុគ្រោះដ៏ស្មោះស្មើ, (៥) មិនមានទោស ក្នុងការចូលទៅកាន់ត្រកូល, (៦) ការមិនទទួលត្រេកអរ នូវពាក្យដែលគេហៅរក ដោយការនិមន្ត, (៧) ភាពជាអ្នកមិនមានសេចក្តីត្រូវការ ដោយអាហារដែលគេនាំមកឲ្យ, (៨) ភាពជាអ្នកមានការប្រព្រឹត្តិ សមគួរដល់អប្បិច្ឆតាគុណជាដើម ។

(អវសានគាថា ក្នុងសបទានចារិកង្គៈ)

សបទានចារិកភិក្ខុ ក្នុងសាសនានេះ ជាបុគ្គលល្អ ប្រៀប
ដូចព្រះច័ន្ទ ជាបុគ្គលថ្មោងថ្មីជានិច្ច ក្នុងត្រកូលទាំងឡាយ
ជាអ្នកមិនកំណាញ់ ជាអ្នកមានសេចក្ដីអនុគ្រោះស្មើ ដល់
ត្រកូលទាំងពួង ជាអ្នករួចស្រឡះ ចាកទោសដែលកើត
ឡើង ដល់កុលុប្បកភិក្ខុ ព្រោះហេតុនោះ ភិក្ខុជាអ្នកប្រាជ្ញ
កាលប្រាថ្នាចង់ត្រាច់ទៅលើផែនដី តាមទំនើងចិត្ត ត្រូវតែ
លះបង់ នូវកិរិយាត្រាច់ទៅ ដើម្បីបិណ្ឌបាត តាមភាព
ដែលល្មោភ ត្រូវមានចក្ខុសំឡឹងចុះក្រោម ត្រូវក្រឡេក
មើល តែត្រឹមមួយជួរនឹម គប្បីប្រព្រឹត្តនូវអង្គ នៃភិក្ខុអ្នក
មានការត្រាច់ទៅបិណ្ឌបាត តាមលំដាប់ច្រកចុះ ។

*នេះ ជាសេចក្ដីពណ៌នា នូវវិធាននៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងសបទានចារិកង្គធុតង្គ ។*

## ៥- ឯកាសនិកង្គៈ

(វិធីសមាទាន ក្នុងឯកាសនិកង្គៈ)

*(៤៣) ឯកាសនិកង្គធុតង្គវិញ ជាធុតង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ នេះ ពាក្យណាមួយថា “ខ្ញុំ ហាមឃាត់ការបរិភោគភោជន លើអាសនៈផ្សេង ៗ, ខ្ញុំ សមាទាននូវអង្គ នៃភិក្ខុអ្នកមានការបរិភោគភោជន តែលើអាសនៈ ១ ជាប្រក្រតី” ។*

(វិធីក្នុងឯកាសនិកង្គៈ)

*ក៏ឯកាសនិកភិក្ខុនោះ កាលបើអង្គុយនៅ លើអាសនសាលា មិនត្រូវអង្គុយ លើថេរាសនៈឡើយ ត្រូវតែកំណត់នូវអាសនៈ ដ៏សមគួរ*



*ថា “អាសនៈនេះ នឹងត្រូវបានដល់អាត្មាអញ” ដូច្នេះហើយ សឹមអង្គុយ, បើខ្លួនឆាន់ភោជនមិនទាន់រួច, អាចារ្យ ឬ ព្រះឧបជ្ឈាយ៍ និមន្តមកដល់, ភិក្ខុ ក្រោកទៅធ្វើវត្ត ទើបគួរ ។ ចំណែកព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់បិដកបី ពោលថា “ភិក្ខុ ត្រូវរក្សាអាសនៈ ឬ គប្បីរក្សាភោជន, ប៉ុន្តែភិក្ខុរូបនេះ មានភោជនពុំទាន់ហើយ, ព្រោះហេតុនោះ ភិក្ខុ ចូរធ្វើនូវវត្ត តែចូរកុំឆាន់ភោជនឡើយ” ដូច្នេះ ។ នេះ គឺជាវិធាន នៃឯកាសនិកង្គភិក្ខុនេះ ។*

(ប្រភេទនៃឯកាសនិកភិក្ខុ)

*បើពោលដោយប្រភេទ ឯកាសនិកភិក្ខុនេះ មាន ៣ ពួក ។ បណ្ដាភិក្ខុទាំង ៣ ពួកនេះ ឯកាសនិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ, ភោជន មានតិចក្ដីច្រើនក្ដី, ភិក្ខុនោះ លូកដៃចូលក្នុងភោជនណា មិនបានកាន់យកភោជនដទៃក្រៅអំពីភោជននោះទេ ។ តែបើមនុស្សទាំងឡាយ គេគិតឃើញថា “ព្រះថេរៈនេះ មិនឆាន់វត្ថុអ្វីបន្តិចបន្តួចទេ” ដូច្នេះហើយ នាំយកវត្ថុទាំងឡាយ មានទឹកដោះថ្លាជាដើម មកប្រគេន, វត្ថុទាំងអស់នោះ គួរដើម្បីប្រើប្រាស់ជាភេសជ្ជៈតែប៉ុណ្ណោះ, មិនគួរ ដើម្បីប្រើប្រាស់ជាអាហារទេ។ ឯកាសនិកភិក្ខុថ្នាក់កណ្ដាល, បើភត្ត ក្នុងបាត្រមិនទាន់អស់ ដរាបណា, តែងបានដើម្បីទទួលនូវភោជនដទៃ ដរាបនោះ ។ ព្រោះថា ភិក្ខុរូបនេះ ឈ្មោះថា ជាអ្នកមានភោជនជាទីបំផុត។ ឯកាសនិកភិក្ខុថ្នាក់អន់ បើមិនទាន់ក្រោកចាកអាសនៈ ដរាបណា តែងបានដើម្បីនឹងឆាន់ ដរាបនោះ ។ ព្រោះថា ឯកាសនិកភិក្ខុនោះ ឈ្មោះថា ឧទកបរិយន្តិកៈ (ជាអ្នកមានទឹកក្នុងទីបំផុត) ក៏បាន ព្រោះថា បើមិនទាន់ទទួលទឹកលាងបាត្រ ដរាបណា នៅឆាន់បាន ដរាបនោះ ឈ្មោះថា អាសនបរិយន្តិកៈ(ជាអ្នកមានអាសនៈ*

ជាទីបំផុត) ក៏បាន ព្រោះថា បើមិនទាន់ក្រោកចាកពីអាសនៈ ដរាបណាទេ នៅឆាន់បាន ដរាបនោះ ។

(ការបែកធ្លាយ ក្នុងឯកាសនិកង្គៈ)

ក៏ធុតង្គនៃឯកាសនិកភិក្ខុទាំង ៣ នោះ រមែងបែកធ្លាយ ក្នុងខណៈដែលភិក្ខុនោះ ឆាន់នូវភោជន លើអាសនៈផ្សេង ៗ ។ នេះ គឺ ជាការបែកធ្លាយ ក្នុងឯកាសនិកង្គភិក្ខុនេះ ។

(អានិសង្ស ក្នុងឯកាសនិកង្គៈ)

ចំណែកឯអានិសង្ស ដូចតទៅនេះ គឺ : (១) ភាពជាអ្នកមានអាពាធតិច, (២) ភាពជាអ្នករស់នៅមិនលំបាក គឺមិនមានសេចក្ដីទុក្ខ (៣) ការក្រោកឡើងយ៉ាងរហ័ស, (៤) មានកម្លាំងពលំ, (៥) ការនៅជាសុខសប្បាយ, (៦) មិនត្រូវអាបត្តិ ព្រោះអនតិរិត្តសិក្ខាបទ ជាបច្ច័យ, (៧) កិរិយាបន្ទោបង់ នូវសេចក្ដីចំណង់ក្នុងរស, (៨) ភាពជាអ្នកមានការប្រព្រឹត្តិដ៏សមគួរ ដល់គុណមានអប្បិច្ឆតាគុណជាដើម ។

(អវសានគាថា ក្នុងឯកាសនិកង្គៈ)

រោគទាំងឡាយ ដែលមានការបរិភោគភោជន ជាបច្ច័យ
មិនបៀតបៀននូវព្រះយោគី អ្នកត្រេកអរ ក្នុងការបរិភោគ
ភោជន តែលើអាសនៈ ១ ជាអ្នកមិនល្មោភ ក្នុងរស មិន
ញុំាងការងាររបស់ខ្លួនឲ្យសាបសូន្យ, ព្រោះហេតុនោះ ព្រះ
យោគីអ្នកមានចិត្តស្អាតបរិសុទ្ធ គប្បីញុំាងសេចក្ដីត្រេកអរ
ឲ្យកើត ក្នុងការបរិភោគភោជន តែលើអាសនៈ ១ ដែល
ជាហេតុនៃការនៅជាសុខសប្បាយ ដែលភិក្ខុអ្នកត្រេកអរ
ក្នុងសល្លេខគុណដ៏ស្អាត ចូលទៅជិតសេពហើយ ។



នេះ ជាសេចក្ដីពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងឯកាសនិកង្គធុតង្គ ។

## ៦- បត្តបិណ្ឌិកង្គៈ

(វិធីសមាទានក្នុងបត្តបិណ្ឌិកង្គៈ)

(៤៤) ឯបត្តបិណ្ឌិកង្គធុតង្គ ជាធុតង្គដែលភិក្ខុសមាទានហើយដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា "ខ្ញុំ ហាមឃាត់នូវភាជនៈជាគម្រប់ពីរ, ខ្ញុំ សមាទាននូវអង្គ នៃភិក្ខុអ្នកមានការបរិភោគនូវភោជនតែក្នុងបាត្រ ជាប្រក្រតី" ដូច្នេះ ។

(វិធីក្នុងបត្តបិណ្ឌិកង្គៈ)

ក៏បត្តបិណ្ឌិកភិក្ខុនោះ ក្នុងពេលហុតបបរ កាលបើបានម្ហូបក្រៀមដាក់ក្នុងភាជនៈហើយ ត្រូវឆាន់ម្ហូបក្រៀមមុន ក៏បាន ឬ ហុតបបរ មុន ក៏បាន ។ តែបើភិក្ខុ ដាក់ម្ហូបក្រៀម ក្នុងបបរ, កាលបើទាយកដាក់ម្ហូបក្រៀម មានប្រហុកជាដើមចូលទៅ, បបរជារបស់ដែលគេគួរខ្ពើម ។ តែប្រសិនបើភិក្ខុអ្នកឆាន់ បេះធ្វើឲ្យទៅជារបស់មិនគួរខ្ពើមទៅវិញហើយ ឆាន់ទើបគួរ ។ ព្រោះហេតុនោះ ពាក្យថា របស់ដែលបុគ្គលមិនគួរខ្ពើមនេះ លោកពោល សំដៅយកម្ហូបក្រៀម ដែលមានសភាពបែបនោះ ។ ឯវត្ថុណា មានទឹកឃ្មុំ និង ស្ករក្រាមជាដើម ជារបស់ដែលមិនគួរខ្ពើម, ភិក្ខុ ត្រូវដាក់វត្ថុនោះ ។ តែភិក្ខុកាលទទួល ត្រូវតែទទួល ឲ្យគួរដល់ប្រមាណ ។ ការដែលបត្តបិណ្ឌិកភិក្ខុ កាន់នូវបន្លែស្រស់ មើមដំឡូងឆាន់នឹងដៃ ទើបគួរ ។ តែបើមិនធ្វើដូច្នោះទេ ត្រូវដាក់ទៅ ក្នុងបាត្រតែម្យ៉ាង ។ តែព្រោះហាមភាជនៈទីពីរ វត្ថុដទៃ សូម្បីតែស្លឹកឈើ ក៏មិនគួរឡើយ ។ នេះជាវិធាននៃបត្តបិណ្ឌិកភិក្ខុនេះ ។

(ប្រភេទនៃបត្តបិណ្ឌិកភិក្ខុ)

បើពោលតាមប្រភេទ បត្តបិណ្ឌិកភិក្ខុនេះឯង មាន ៣ ពួក ។ បណ្ដាបត្តបិណ្ឌិកភិក្ខុ ៣ ពួកនោះ ចំពោះបត្តបិណ្ឌិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ នឹងរើសសំរាមចោលក៏មិនគួរ វៀរលែងតែវេលាដែលឆាន់អំពៅ ។ កុំថាដល់ទៅម្ហូប សូម្បីតែបំបែកដុំបាយ សាច់ត្រី និង នំទាំងឡាយហើយឆាន់ ក៏មិនគួរ ។ ចំពោះភិក្ខុ ថ្នាក់កណ្ដាល បំបែកដោយដៃម្ខាងហើយឆាន់ក៏គួរ ។ ភិក្ខុ ថ្នាក់កណ្ដាលនេះ ឈ្មោះថា ហត្ថយោគី (អ្នកប្រកបដោយដៃ) ។ ចំណែកភិក្ខុ ថ្នាក់អន់ ឈ្មោះថា បត្តយោគី (អ្នកប្រកបដោយបាត្រ) ។ ចំពោះបត្តបិណ្ឌិកភិក្ខុ ថ្នាក់អន់នោះ ភោជនណា អាចដាក់ចូលទៅ ក្នុងបាត្របាន ក៏អាចដើម្បីបំបែកនូវភោជននោះ ដោយដៃ ឬ ខាំ ទំពា ដោយធ្មេញហើយ ឆាន់បានទាំងអស់ ។

(ការបែកធ្លាយ ក្នុងបត្តបិណ្ឌិកង្គៈ)

ក៏ធុតង្គ របស់បត្តបិណ្ឌិកភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយ ក្នុងខណៈដែលភិក្ខុទាំង ៣ នោះ ត្រេកអរនូវភាជនៈ ជាគម្រប់ពីរ ។ នេះ ជាការបែកធ្លាយ ក្នុងបត្តបិណ្ឌិកង្គៈនេះ ។

(អានិសង្ស ក្នុងបត្តបិណ្ឌិកង្គៈ)

ចំណែកអានិសង្សវិញ ដូចតទៅនេះ គឺៈ (១) ការបន្ទន់នូវចំណង់ ក្នុងភោជនដែលមានរសផ្សេង ៗ, (២) ការលះបង់នូវសេចក្ដីប្រាថ្នា ដ៏លើសលប់, (៣) ភាពជាអ្នកឃើញប្រមាណនៃប្រយោជន៍ ក្នុងអាហារ, (៤) មិនមានសេចក្ដីលំបាក ព្រោះរក្សាទុកនូវភាជន៍ មានថាសជាដើម, (៥) ភាពជាអ្នកមិនបរិភោគ មានចិត្តរាយមាយជាប្រក្រតី, (៦) ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។



(អវសានគាថា ក្នុងបត្តបិណ្ឌិកង្គៈ)

ព្រះយោគី អ្នកមានវត្តដ៏ល្អ មានចក្ខុសំឡឹងចុះក្រោម
លះបង់នូវសេចក្ដីរាយមាយ ក្នុងភាជនៈផ្សេងៗ ទុកដូច
ជាជីករំលើង នូវឫសទាំងឡាយ នៃសេចក្ដីចំណង់ ក្នុង
រស ជាអ្នកមានចិត្តល្អស្អាត ទ្រទ្រង់នូវសេចក្ដីសន្ដោស
ហាក់ដូចជាទ្រទ្រង់នូវរូបកាយ របស់ខ្លួន បត្តបិណ្ឌិកភិក្ខុ
ឯទៀត អង្គណាសោត ក៏នឹងគប្បីបរិភោគអាហារ (ក្នុង
ភាជនៈផ្សេងៗ បាន) ។

នេះ ជាសេចក្ដីពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងបត្តបិណ្ឌិកង្គធុតង្គនេះ ។

៧- ខលុបច្ឆាភត្តិកង្គៈ

(វិធីសមាទានក្នុងខលុបច្ឆាភត្តិកង្គៈ)

(៤៥) សូម្បីខលុបច្ឆាភត្តិកង្គៈ ក៏ជាធុតង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា “ខ្ញុំ ហាមឃាត់ការបរិភោគនូវអតិរិត្តភោជន (ភោជនដ៏សល់) ខ្ញុំ សមាទាននូវអង្គ នៃភិក្ខុអ្នកមានការមិនបរិភោគនូវភត្តដែលខ្លួនមានភោជន ហាមរួចហើយ ទើបបានមកក្នុងកាលជាខាងក្រោយ ជាប្រក្រតី” ដូច្នេះ ។

(វិធីក្នុងខលុបច្ឆាភត្តិកង្គៈ)

ក៏ខលុបច្ឆាភត្តិកភិក្ខុនោះ ហាមភោជនរួចហើយ មិនត្រូវឲ្យគេធ្វើភោជន ជាកប្បិយៈហើយ បរិភោគទៀតឡើយ ។ នេះ គឺជាវិធាន នៃខលុបច្ឆាភត្តិកភិក្ខុនុ៎ះ ។

(ប្រភេទនៃខលុបច្ឆាភត្តិកភិក្ខុ)

*បើពោលទៅតាមប្រភេទ ខលុបច្ឆាភត្តិកភិក្ខុនេះ មាន ៣ ពួក ។ បណ្ដាទាំង ៣ ពួកនោះ ខលុបច្ឆាភត្តិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ, ព្រោះហេតុដែលឈ្មោះថា ការហាមឃាត់ ក្នុងដុំបាយជាដំបូង មិនមាន, ប៉ុន្តែកាលបើដុំបាយ ជាដំបូងនោះ គឺលោកកំពុងតែលេបចូលទៅ (ហើយហាមឃាត់) ភោជនដទៃ ទើបឈ្មោះថា ហាមឃាត់, ព្រោះហេតុនោះ ភិក្ខុថ្នាក់ឧក្រិដ្ឋនោះ ឈ្មោះថា ហាមភោជន យ៉ាងនេះហើយ ក៏លេបដុំបាយជាដំបូងហួសចូលទៅហើយ មិនឆាន់ដុំបាយជាគម្រប់ ២ ។ ភិក្ខុ ថ្នាក់កណ្ដាលហាមហើយ ក្នុងភោជនណា ឆាន់តែភោជននោះប៉ុណ្ណោះ ។ ភិក្ខុថ្នាក់អន់មិនទាន់ក្រោកចាកអាសនៈ ដរាបណា ក៏នៅឆាន់បាន ដរាបនោះ ។*

(ការបែកធ្លាយ ក្នុងខលុបច្ឆាភត្តិកង្គៈ)

*ធុតង្គ របស់ខលុបច្ឆាភត្តិកភិក្ខុទាំង ៣ ពួកនេះ បែកធ្លាយ ក្នុងខណៈដែលភិក្ខុទាំង ៣ ពួកនោះ ហាមហើយ ឲ្យគេធ្វើ ជាកប្បិយៈហើយឆាន់ ។ នេះជាការបែកធ្លាយ ក្នុងខលុបច្ឆាភត្តិកង្គៈនុ៎ះ ។*

(អានិសង្ស ក្នុងខលុបច្ឆាភត្តិកង្គៈ)

*ចំណែកអានិសង្សវិញ ដូចតទៅនេះគឺ (១) ភាពជាអ្នកឆ្ងាយចាកអាបត្តិ ដែលត្រូវព្រោះការឆាន់នូវអនតិរិត្តភោជន, (២) មិនមាននៃភាពជាអ្នកមានអាហារចើសពោះ (ចាក់ប្រាស), (៣) ភាពជាអ្នកមិនសន្សំអាមិស, (៤) មិនមានការស្វែងរកម្ដងទៀត, (៥) ភាពជាអ្នកមានការប្រព្រឹត្តិសមគួរ ដល់ធុតង្គគុណទាំងឡាយ មានអប្បិច្ឆតាគុណជាដើម ។*

(អវសានគាថា ក្នុងខលុបច្ឆាភត្តិកង្គៈ)

ព្រះយោគី អ្នកមានប្រាជ្ញា ជាអ្នករក្សាខលុបច្ឆាភត្តិកង្គៈ



មិនដល់នូវសេចក្ដីលំបាក ព្រោះការស្វែងរកបច្ច័យ មិន
ធ្វើនូវកិរិយាសន្សំទុក លះបង់នូវភាពជាអ្នកមានអាហារ
ចើសពោះបាន, ព្រោះហេតុនោះ ព្រះយោគីអ្នកមានប្រាជ្ញា
ដើម្បីកំចាត់បង់ នូវទោសទាំងឡាយ គប្បីគប់រកនូវធុតង្គ
ដែលព្រះសុគត ទ្រង់ត្រាស់សរសើរថា ជាធម្មជាតញ៉ាំង
សេចក្ដីចំរើន ដោយគុណ មានការសន្ដោសជាដើម
ឲ្យកើតព្រមនេះចុះ ។

*នេះ ជាសេចក្ដីពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងខលុបច្ឆាភត្តិកង្គៈ ។*

## ៨- អារញ្ញិកង្គៈ

(វិធីសមាទាន ក្នុងអារញ្ញិកង្គៈ)

*(៤៦) ចំណែកអារញ្ញិកង្គៈជាធុតង្គដែលភិក្ខុសមាទានហើយដោយពាក្យទាំង ២ នេះ ពាក្យឯណាមួយ ថា “ខ្ញុំ ហាមឃាត់នូវសេនាសនៈជិតស្រុក, ខ្ញុំសមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅក្នុងព្រៃជាប្រក្រតី” ។*

(វិធីក្នុងអារញ្ញិកង្គៈ)

*ក៏អារញ្ញិកភិក្ខុនោះ ត្រូវលះបង់ នូវសេនាសនៈ ជិតស្រុកហើយញ៉ាំងអរុណឲ្យរះឡើង ក្នុងព្រៃ ។*

(កំណត់សេនាសនៈក្នុងព្រៃ)

*ក្នុងពាក្យទាំងនោះ ស្រុកជាមួយនឹងឧបចារៈនុ៎ះឯង ឈ្មោះថាសេនាសនៈជិតស្រុក ។ ស្រុកឯណានីមួយ មានតែខ្ទមមួយក្ដី ច្រើនក្ដី*

មានរបងព័ទ្ធជុំវិញក្តី មិនមានក្តី មានមនុស្សអាស្រ័យនៅក្តី មិនមានក្តី ឈ្មោះថា ស្រុក, ដោយហោចទៅ សូម្បីឈ្នួញរទេះណាមួយ ទៅសំចត នៅជាង ៤ ខែ ក៏ឈ្មោះថា ស្រុកដែរ ។ ចំពោះស្រុកដែលមានរបងព័ទ្ធ ជុំវិញ បើមានសសរខឿន ២ ដូចជាអនុរាធបុរី ការធ្លាក់ចុះនៃដុំដី របស់បុរសដែលមានកម្លាំងយ៉ាងមធ្យម ដែលឈរនៅត្រង់សសរខឿន មាន នៅត្រង់ចន្លោះខាងក្នុង ឈ្មោះថា ឧបចារៈនៃស្រុក ។ ព្រះវិន័យធរទាំងឡាយ ពោលថា "ឯលក្ខណៈ នៃស្រុកនោះ បានដល់ទីខាងក្នុង នៃទីជាទីធ្លាក់ចុះនៃដុំដី ដែលបុគ្គលចោលទៅហើយ ដូចជាពួកមនុស្សក្មេង ៗ កាលនឹងសំដែងនូវកម្លាំង របស់ខ្លួន លានូវដើមដៃហើយ ចោលដុំដីទៅដូច្នោះឯង" ។ ចំណែក ពួកលោកអ្នកដែលទ្រទ្រង់ព្រះសូត្រ ពោលថា "ខាងក្នុងនៃទីដែលជាទីធ្លាក់ចុះ នៃដុំដីដែលគេចោលហើយ ដោយទំនងនៃការដេញក្អែក ឈ្មោះថា លេឌ្ឌុបាត" ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងផ្ទះដែលគេមិនបានធ្វើរបងព័ទ្ធ (ដូចតទៅ) មាតុគ្រាម ឈរក្បែរទ្វារផ្ទះ ចុងបំផុតគេទាំងអស់ យកភាជនៈ ជះទឹកទៅដល់ទីណា, ទីដែលទឹកធ្លាក់ទៅនោះ ឈ្មោះថា ឧបចារៈ នៃផ្ទះ ។ ការធ្លាក់ចុះនៃដុំដីមួយដុំ ដោយន័យដែលលោកពោលហើយអំពីឧបចារៈនៃផ្ទះនោះ ឈ្មោះថា ស្រុក ។ លេឌ្ឌុបាតទី ២ ឈ្មោះថា ឧបចារៈនៃស្រុក ។ ចំណែកព្រៃ បើពោលតាមព្រះវិន័យជាមុន ព្រះឧបាលិត្ថេរពោលហើយថា "ទីទាំងអស់ទុ៎ះ លើកលែងតែស្រុក និង ឧបចារៈនៃស្រុកចេញប៉ុណ្ណោះ ឈ្មោះថា ព្រៃ" ដូច្នេះ ។ បើពោលទៅតាមព្រះអភិធម្ម លោកពោលថា "ទីទាំងអស់ ចេញទៅខាងក្រៅ អំពីសសរគោលទុ៎ះ ឈ្មោះថា ព្រៃ" ។ ប៉ុន្តែលក្ខណៈដែលលោកបានពោលហើយ



ដោយបរិយាយក្នុងព្រះសូត្រថា "ទីសេនាសនៈ ដែលមានចម្ងាយ ៥០០ ធ្នូ យ៉ាងតិចបំផុត ឈ្មោះថា សេនាសនៈដែលតាំងនៅក្នុងព្រៃ, នេះជាលក្ខណៈ ក្នុងពាក្យថា ព្រៃនេះ ។ សេនាសនៈ ដែលតាំងនៅ ក្នុងព្រៃនោះ ចំពោះស្រុកដែលគេបានធ្វើរបងព័ទ្ធហើយ ភិក្ខុ អ្នកមានកិរិយានៅក្នុងព្រៃជាវត្ត គប្បីវាស់ ចាប់តាំងអំពីសសរគោលទៅ ដោយធ្នូ របស់អាចារ្យដែលទាញជំឡើងហើយ, ចំពោះស្រុក ដែលគេមិនបានធ្វើរបងព័ទ្ធហើយ គប្បីវាស់ ចាប់ដើមអំពីការធ្លាក់ចុះ នៃដុំដីជាដំបូង រហូតទៅទល់គ្នានឹងរបងព្រះវិហារ ។ ព្រះអដ្ឋកថាចារ្យពោល ក្នុងអដ្ឋកថានៃព្រះវិន័យទាំងឡាយថា "តែប្រសិនបើវិហារមិនបានធ្វើរបងព័ទ្ធ, សេនាសនៈដំបូងគេបង្អស់ក្តី សាលាភត្តក្តី កន្លែងប្រជុំ ទៀងទាត់ក្តី ដើមពោធិក្តី ចេតិយក្តី ឯណានីមួយ បើនៅឆ្ងាយ ពីសេនាសនៈ, ភិក្ខុ គប្បីធ្វើទីនោះឲ្យជាខេត្តកំណត់ហើយវាស់ចុះ ។

ឯក្នុងអដ្ឋកថាមជ្ឈិមនិកាយ លោកពោល ថា "អារញ្ញិកភិក្ខុ គប្បីលើកវាស់នូវឧបចារៈនៃវិហារ ត្រង់ចន្លោះនៃលេឌ្ឌុបាតទាំង ២ ឲ្យដូចជាឧបចារៈនៃស្រុកដូច្នោះ"។ នេះជាប្រមាណក្នុងវិធីវាស់ទុ៎ះ ។ ប្រសិនបើមានស្រុកនៅជិត ភិក្ខុដែលនៅក្នុងវត្ត ឮសំឡេងពួកមនុស្ស តែមិនអាចនឹងដើរត្រង់ទៅបាន ព្រោះមានភ្នំ និង ស្ទឹងជាដើម ខណ្ឌហើយនៅត្រង់ចន្លោះ, ផ្លូវឯណា ជាផ្លូវប្រក្រតី របស់អ្នកស្រុកនោះ, ប្រសិនបើផ្លូវនោះ គឺជនទាំងឡាយគប្បីសញ្ចរតាមនាវា, អារញ្ញិកភិក្ខុ គប្បីកំណត់យកទីប្រវែង ៥០០ ធ្នូ តាមផ្លូវនោះចុះ ។ តែអារញ្ញិកភិក្ខុ ណា បិទផ្លូវតាមចន្លោះនោះៗ ដើម្បីញ៉ាំងអង្គនៃស្រុកជិតឲ្យដល់ព្រម, អារញ្ញិក-ភិក្ខុនេះ ឈ្មោះថា ធុតង្គចោរ ។ តែប្រសិនបើព្រះឧបជ្ឈាយ៍ ឬ អាចារ្យ

របស់អារញ្ញិកភិក្ខុនោះ មានអាពាធ, ភិក្ខុនោះ មិនបានសេចក្ដីសប្បាយក្នុងព្រៃ គប្បីនាំឧបជ្ឈាយ៍ ឬ អាចារ្យនោះ ទៅកាន់ទីសេនាសនៈ ជិតស្រុកហើយបំរើចុះ ។ តែថា អារញ្ញិកភិក្ខុ ត្រូវចេញអំពីព្រឹកព្រហាម ត្រូវឲ្យអរុណ រះឡើង ក្នុងទីប្រកបដោយអង្គ ។ ថាបើក្នុងពេលដែល អរុណ រះឡើង អាពាធរបស់ឧបជ្ឈាយ៍ ឬ អាចារ្យទាំងនោះ រឹតតែខ្លាំងឡើង, អារញ្ញិកភិក្ខុ ត្រូវធ្វើកិច្ច ដើម្បីឧបជ្ឈាយ៍ និង អាចារ្យទាំងនោះវិញចុះ ។ អារញ្ញិកភិក្ខុ មិនត្រូវជាអ្នកស្អាតស្អំបរិសុទ្ធ ក្នុងធុតង្គ តែម្យ៉ាងនោះទេ ។ នេះជាវិធាន នៃអារញ្ញិកង្គធុតង្គទុំះ ។

(ប្រភេទនៃអារញ្ញិកភិក្ខុ)

បើពោលតាមប្រភេទ អារញ្ញិកភិក្ខុនេះឯង មាន ៣ ពួក ។ បណ្ដា ៣ ពួកនោះ អារញ្ញិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ គប្បីញុំាងអរុណ ឲ្យរះឡើង ក្នុងព្រៃ អស់កាលទាំងពួង ។ អារញ្ញិកភិក្ខុ ថ្នាក់មធ្យម រមែងបាន ដើម្បីនៅ ក្នុងសេនាសនៈជិតស្រុក អស់រដូវភ្លៀង ៤ ខែ ។ ចំណែកខាង អារញ្ញិកភិក្ខុ អ្នកថ្នាក់អន់ រមែងបាន ដើម្បីនៅ អស់រវាង ៤ ខែ ក្នុងហេមន្តរដូវ តទៅទៀតក៏បាន ។

(ការបែកធ្លាយក្នុងអារញ្ញិកង្គ:)

ក៏កាលអារញ្ញិកភិក្ខុទាំង ៣ ពួកនេះ មកអំពីព្រៃ ក្នុងពេលដែលខ្លួនបានកំណត់ហើយយ៉ាងណា ស្ដាប់ធម៌ ក្នុងទីសេនាសនៈ ជិតស្រុក, កាលបើអរុណ រះឡើងហើយ, ធុតង្គ មិនបែកធ្លាយទេ ។ កាលបើ អារញ្ញិកភិក្ខុ ស្ដាប់ធម៌ហើយទៅ, សូម្បីអរុណ រះឡើង ត្រង់ចន្លោះផ្លូវក៏ដោយ ធុតង្គ ក៏មិនបែកធ្លាយដែរ ។ តែថា កាលបើព្រះធម្មកថិក ក្រោកឡើងហើយ (ឈប់ទេសនា), បើអារញ្ញិកភិក្ខុ គិតថា "ពួកយើង



សិងមួយភ្លែតសិន សឹមទៅ" ដូច្នេះហើយ ក៏សិងលក់ទៅ, អរុណ ក៏រះឡើង ឬក៏ ញុំាងអរុណ ឲ្យរះឡើង ក្នុងទីសេនាសនៈ ជិតស្រុក តាមសេចក្ដីពេញចិត្តរបស់ខ្លួន, ធុតង្គ បែកធ្លាយ ។ នេះ ជាការបែកធ្លាយ ក្នុងអារញ្ញិកង្គធុតង្គទុំះ ។

(អានិសង្ស ក្នុងអារញ្ញិកង្គ:)

ចំណែកអានិសង្សវិញ ដូច្នេះ គឺ (១) អារញ្ញិកភិក្ខុ កាលធ្វើទុកក្នុងចិត្តនូវសេចក្ដីសំគាល់ថា ព្រៃ ជាអ្នកសមគួរ ដើម្បីបាននូវសមាធិដែលខ្លួនមិនទាន់បាននៅឡើយផង, (២) ជាអ្នកគួរដើម្បីរក្សាទុក នូវសមាធិ ដែលខ្លួនបានរួចហើយផង, (៣) សូម្បីព្រះសាស្ដា ក៏ទ្រង់ពេញព្រះហឫទ័យ ចំពោះភិក្ខុនោះ ។ សមដូចជាព្រះអង្គត្រាស់ថា "ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគត ជាអ្នកមានចិត្តត្រេកអរ ដោយកិរិយានៅក្នុងព្រៃរបស់ភិក្ខុនោះ [១] "ដូច្នេះ ។ (៤) អន្តរាយទាំងឡាយមានរូបដែលមិនជាទីសប្បាយជាដើម រមែងគ្របសង្កត់ចិត្ត របស់ភិក្ខុអ្នកមានកិរិយានៅ ក្នុងទីសេនាសនៈស្ងាត់ ជាប្រក្រតីនោះ មិនបានទេ, (៥) អារញ្ញិកភិក្ខុនោះ ជាអ្នកមិនមានសេចក្ដីតក់ស្លុតទេ, (៦) រមែងលះបង់នូវសេចក្ដីត្រេកអរ ក្នុងជីវិតបាន, (៧) រមែងបានសោយនូវរស នៃសេចក្ដីសុខដែលកើតពីវិវេក, (៨) សូម្បីភាពជាអ្នកទ្រទ្រង់នូវសំពត់បំសុកូលជាដើម ក៏រមែងសមគួរ ដល់អារញ្ញិកភិក្ខុ អ្នកមានប្រក្រតីនៅក្នុងព្រៃជាវត្តទុំះផង ។

(អវសានគាថា ក្នុងអារញ្ញិកង្គ:)

ព្រះយោគី អ្នកមានចិត្តស្ងប់ស្ងាត់ មិនច្រឡូកច្រឡំដោយ

---

១- សុ. អំ. អ. ភាគទី ៤៨ ទំព័រទី ៣៦២ ។

ពួក ត្រេកអរតែក្នុងទីសេនាសនៈ ដែលស្ងាត់ ញ៉ាំងព្រះហឫទ័យ របស់ព្រះលោកនាថ ឲ្យទ្រង់ព្រះអំណរបាន ដោយកិរិយានៅ ក្នុងព្រៃ អាស្រ័យនៅ ក្នុងព្រៃតែម្នាក់ឯង រមែងបាននូវសេចក្ដីសុខ ឯណា សូម្បីទេវតាទាំងឡាយ ព្រមទាំងព្រះឥន្ទ្រ ក៏មិនបានសោយ នូវរសនៃសេចក្ដីសុខបែបនោះឡើយ ។ ក៏អារញ្ញិកភិក្ខុ នេះឯង កាលបើបានទ្រទ្រង់ នូវសំពត់បំសុកូល ទុកដូចជាគ្រឿងក្រោះថែមទៀត ចូលទៅកាន់ទីសង្គ្រាម ពោលគឺព្រៃ យកធុតង្គដ៏សេសសល់ជាយោធា ជាអ្នកអាច ដើម្បីនឹងច្បាំងឈ្នះមារ ព្រមទាំងពាហនៈបាន មិនយឺតយូរឡើយ ហេតុនោះ ភិក្ខុដែលជាបណ្ឌិត គប្បីធ្វើនូវសេចក្ដីត្រេកអរ ក្នុងកិរិយានៅ ក្នុងព្រៃចុះ ។

*នេះ ជាសេចក្ដីពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងអារញ្ញិកង្គៈ ។*

**៩- រុក្ខមូលិកង្គៈ**

**(វិធីសមាទាន ក្នុងរុក្ខមូលិកង្គៈ)**

*(៤៧) សូម្បីរុក្ខមូលិកង្គៈ ក៏ជាធុតង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា “ខ្ញុំ ហាមឃាត់សេនាសនៈដែលគេប្រក់ដោយដម្បូល, ខ្ញុំ សមាទានអង្គ នៃភិក្ខុអ្នកមានកិរិយានៅអាស្រ័យទៀបគល់ឈើជាប្រក្រតី” ដូច្នេះ ។*

**(វិធីក្នុងរុក្ខមូលិកង្គៈ)**



*ក៏រុក្ខមូលិកភិក្ខុនោះ គប្បីវៀរនូវដើមឈើទាំងឡាយនេះ គឺ : ដើមឈើដែលឋិតនៅ ត្រង់ព្រំដែន, ដើមឈើដែលគេគោរពបូជា, ដើមឈើដែលមានជ័រ, ដើមឈើដែលមានផ្លែ, ដើមឈើដែលមានផ្កា, ដើមឈើដែលមានពួកសត្វប្រជៀវនៅអាស្រ័យ, ដើមឈើដែលមានប្រហោង, ដើមឈើដែលដុះនៅចំកណ្ដាលវត្តហើយ គប្បីកំណត់យក នូវដើមឈើដែលឋិតនៅក្នុងទីបំផុតនៃវត្តចុះ ។ នេះ គឺជាវិធាននៃរុក្ខមូលិកង្គៈនុ៎ះ ។*

**(ប្រភេទនៃរុក្ខមូលិកភិក្ខុ)**

*បើពោលតាមប្រភេទ សូម្បីរុក្ខមូលិកភិក្ខុនេះ ក៏មាន ៣ ពួក ។ បណ្ដា ៣ ពួកនោះ រុក្ខមូលិកភិក្ខុថ្នាក់ឧក្រិដ្ឋ ប្រកាន់យកដើមឈើ តាមសេចក្ដីពេញចិត្ត របស់ខ្លួនហើយ ឲ្យគេបោសប្រាសឲ្យ មិនបានឡើយ, ត្រូវបោសតែកំញ៉មស្លឹកឈើទុំ ដែលជ្រុះមក ដោយជើងហើយ គប្បីនៅចុះ ។ រុក្ខមូលិកភិក្ខុថ្នាក់កណ្ដាល បើប្រើមនុស្សដែលដើរមកដល់ទីនោះ ឲ្យបោសប្រាសឲ្យបាន ។ រុក្ខមូលិកភិក្ខុ ថ្នាក់អន់ ទោះបីហៅមនុស្សរក្សាវត្ត និង សាមណេរទាំងឡាយមក ប្រើឲ្យជម្រះធ្វើទីនោះឲ្យស្មើហើយ ឲ្យរោយរាយដីខ្សាច់ ធ្វើរបងព័ទ្ធ ឲ្យប្រកបទ្វាររួចស្រេចហើយសឹមនៅចុះ។ តែក្នុងថ្ងៃដែលពួកមនុស្សធ្វើបុណ្យឆ្លង រុក្ខមូលិកភិក្ខុ មិនត្រូវអង្គុយនៅ ក្នុងទីនោះឡើយ ត្រូវតែចេញទៅ អង្គុយនៅក្នុងទីឯទៀត ដែលជាទីបិទបាំង ។*

**(ការបែកធ្លាយ ក្នុងរុក្ខមូលិកង្គៈ)**

*ឯធុតង្គ របស់រុក្ខមូលិកភិក្ខុទាំង ៣ ពួកនេះឯង តែងបែកធ្លាយ ក្នុងខណៈដែលភិក្ខុទាំងនេះ សំរេចការនៅ ក្នុងទីលំនៅដែលគេប្រក់បាំងហើយ ។ ព្រះថេរៈ អ្នកពោលគម្ពីរអង្គុត្តរនិកាយ ពោលថា : “ធុតង្គ*

បែកធ្លាយ ក្នុងពេលត្រឹមតែរុក្ខមូលិកភិក្ខុដឹងហើយ ញុំាងអរុណ ឲ្យរះឡើង ក្នុងទីដែលគេប្រក់បាំងហើយ" ។ នេះ ជាការបែកធ្លាយ ក្នុងរុក្ខមូលិកង្គធុតង្គនុ៎ះ ។

(អានិសង្ស ក្នុងរុក្ខមូលិកង្គ:)

ចំណែកអានិសង្សវិញ ដូច្នេះ គឺ (១) សភាពជាអ្នកមានសេចក្ដីប្រតិបត្តិដ៏សមគួរដល់និស្ស័យ ព្រោះបាលីថា "បព្វជ្ជា ត្រូវអាស្រ័យនូវទីសេនាសនៈទ្បេបគល់ឈើ" ដូច្នេះ, (២) ភាពជាអ្នកមានបច្ច័យ ដែលព្រះមានព្រះភាគ ត្រាស់សរសើរហើយ ថា " វត្ថុទាំងនេះ ជារបស់តិចផង រកបានដោយងាយផង មិនមានទោសផង " ដូច្នេះ, (៣) ភាពនៃការញុំាងអនិច្ចសញ្ញា ឲ្យកើតឡើងបាន ដោយបានឃើញ នូវការប្រែប្រួលនៃស្លឹកឈើរឿយៗ, (៤) មិនមានសេចក្ដីកំណាញ់ក្នុងសេនាសនៈនិង ភាពជាអ្នកត្រេកអរ ក្នុងការងារ, (៥) ភាពជាអ្នកមានការនៅរួមជាមួយនឹងពួកទេវតា, (៦) ភាពជាអ្នកមានការប្រព្រឹត្តិសមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

(អវសានគាថា ក្នុងរុក្ខមូលិកង្គ:)

ទីនៅអាស្រ័យ របស់ភិក្ខុអ្នកស្ងប់ស្ងាត់ ដែលព្រះពុទ្ធ
ជាឆ្នើម ទ្រង់ត្រាស់សរសើរហើយផង ទ្រង់ត្រាស់ ថា
ជានិស្ស័យ (របស់បព្វជិត) ផង ឲ្យស្មើដោយគល់ឈើ
នឹងមានមកអំពីណា? ព្រោះថា ភិក្ខុដែលមានវត្ត ដ៏ល្អ
កាលនៅអាស្រ័យ ទ្បេបគល់ឈើ ដ៏ស្ងប់ស្ងាត់ ជាទី
កំចាត់បង់ នូវសេចក្ដីកំណាញ់ ក្នុងទីអាវាស ជាទីដែល



ទេវតាថែរក្សាហើយ កាលឃើញនូវស្លឹកឈើទាំងឡាយ
ដែលក្រហមទុំក្រៃពេកផង ខៀវផង លឿងផង ដែល
ជ្រុះធ្លាក់ហើយ រមែងបន្ទោបង់បាន នូវសេចក្ដីសំគាល់ ថា
ជារបស់ទៀងទាត់ ព្រោះហេតុនុ៎ះឯង ភិក្ខុអ្នកមានប្រាជ្ញា
ឃើញច្បាស់ មិនត្រូវមើលងាយនូវគល់ឈើ ដែលជាទី
ស្ងប់ស្ងាត់ ជាកេរ្តិ៍ដំណែលរបស់ព្រះពុទ្ធ ជាទីលំនៅរបស់
លោកអ្នកដែលត្រេកអរក្រៃលែង ក្នុងភាវនាឡើយ ។

នេះ ជាសេចក្ដីពណ៌នា នូវវិធាន នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងរុក្ខមូលិកង្គ: ។

## ១០- អព្ភោកាសិកង្គ:

(វិធីសមាទាន ក្នុងអព្ភោកាសិកង្គ:)

(៤៨) សូម្បីអព្ភោកាសិកង្គ: ក៏ជាធុតង្គដែលភិក្ខុសមាទានហើយដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា "ខ្ញុំ ហាមឃាត់នូវទីសេនា-សនៈ ដែលគេប្រក់បាំងហើយផង ទីសេនាសនៈទៀបគល់ឈើផង, ខ្ញុំសមាទានអង្គនៃភិក្ខុអ្នកនៅអាស្រ័យក្នុងទីវាលស្រឡះជាប្រក្រតី"ដូច្នេះ។

(វិធីក្នុងអព្ភោកាសិកង្គ:)

ក៏កិរិយាចូលទៅកាន់រោងឧបោសថ ដើម្បីស្ដាប់ព្រះធម៌ក្ដី ដើម្បីប្រយោជន៍ដល់ការធ្វើឧបោសថកម្មក្ដី រមែងគួរ ដល់អព្ភោកាសិកភិក្ខុនោះ ។ បើអព្ភោកាសិកភិក្ខុ ចូលទៅហើយ ភ្លៀងបង្អុរចុះមក, កាលបើភ្លៀងកំពុងតែបង្អុរចុះមក, អព្ភោកាសិកភិក្ខុ កុំអាលចេញទៅ ត្រូវចេញទៅ ក្នុងពេលរាំងភ្លៀង ។ ការដែលអព្ភោកាសិកភិក្ខុនោះ ចូលទៅ

កាន់រោងឆាន់ ឬ រោងភ្លើង ហើយធ្វើវត្តក្តី (ចូលទៅ) បម្រើនូវភិក្ខុ ជាថេរៈទាំងឡាយ ដោយអាហារក្នុងរោងឆាន់ក្តី កាលរៀនដោយខ្លួនឯង ឬ បង្រៀនគេ ចូលទៅកាន់ទីសេនាសនៈ ដែលគេប្រក់បាំងក្តី ការដែលអព្ភោកាសិកភិក្ខុ ជញ្ជូនគ្រឿងសេនាសនៈ មានគ្រែ និង តាំងជាដើម ដែលគេទុកដាក់មិនល្អ នៅខាងក្រៅ ឲ្យចូលទៅ ខាងក្នុងក្តី ទើបគួរ ។ បើអព្ភោកាសិកភិក្ខុ ដើរទៅតាមផ្លូវ មានកាន់យកគ្រឿងបរិក្ខារ របស់ពួកភិក្ខុចាស់ទៅហើយ ទទួលមានភ្លៀង បើនឹងចូលទៅកាន់សាលា ដែលឋិតនៅកណ្តាលផ្លូវក៏បាន ។ បើមិនបានកាន់គ្រឿងបរិក្ខារអ្វីៗ ទេ, អព្ភោកាសិកភិក្ខុនឹងដើរចូលទៅ យ៉ាងប្រញាប់ប្រញាល់ ដោយគិត ថា "អាត្មាអញ នឹងនៅក្នុងសាលា" ដូច្នេះ មិនគួរទេ ។ តែត្រូវដើរចូលទៅ តាមដំណើរជាប្រក្រតី ហើយឈរនៅ រហូតទាល់តែភ្លៀងរាំង សឹមដើរទៅ ។ នេះ គឺជាវិធាន នៃអព្ភោកាសិកភិក្ខុនុ៎ះ ។ ឯសេចក្តីពន្យល់ នៃរុក្ខមូលិកភិក្ខុ ក៏ដូចសេចក្តីពន្យល់នេះដែរ ។

(ប្រភេទនៃអព្ភោកាសិកភិក្ខុ)

បើពោលតាមប្រភេទ អព្ភោកាសិកភិក្ខុនេះ មាន ៣ ពួក ។ បណ្តា ៣ ពួកនោះ ចំពោះអព្ភោកាសិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ នឹងចូលទៅនៅផ្អែកអាស្រ័យដើមឈើ ភ្នំ ឬក៏ ផ្ទះពុំបានឡើយ, ត្រូវតែធ្វើខ្ទមជាវិការនៃចីវរ នៅក្នុងទីវាលស្រឡះតែម្យ៉ាង ។ ចំពោះភិក្ខុ ថ្នាក់កណ្តាល នឹងចូលទៅនៅអាស្រ័យដើមឈើ, ភ្នំ និង ផ្ទះបាន កុំតែចូលទៅនៅឰដ៏ខាងក្នុង ។ ចំពោះភិក្ខុថ្នាក់អន់ ញកភ្នំដែលគេមិនបានបិទបាំងហើយក្តី ជំរំធ្វើដោយមែកឈើក្តី បារាំដែលធ្វើដោយសំពត់សាដកក្តី ខ្ទមដែលពួកអ្នកចាំស្រែជាដើម បោះបង់ចោលហើយ ក្នុងទីនោះក្តី បើនឹងចូលទៅជ្រកបាន ។



(ការបែកធ្លាយ ក្នុងអព្ភោកាសិកង្គៈ)

ក៏ធុតង្គ របស់អព្ភោកាសិកភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយ ក្នុងខណៈដែលភិក្ខុទាំងនុ៎ះ ចូលទៅកាន់ទីប្រក់បាំង និង គល់ឈើ ដើម្បីនឹងនៅ ។ ព្រះអង្គុត្តរភាណកត្ថេរទាំងឡាយ ពោលថា "ធុតង្គ រមែងបែកធ្លាយ ក្នុងពេលត្រឹមតែខ្លួនដឹងហើយ បណ្តាយឲ្យអរុណ រះឡើង ក្នុងទីដែលគេប្រក់បាំង និង គល់ឈើនោះ" ។ នេះ គឺជាការបែកធ្លាយ ក្នុងអព្ភោកាសិកង្គធុតង្គនុ៎ះ ។

(អានិសង្ស ក្នុងអព្ភោកាសិកង្គៈ)

ចំណែកអានិសង្សវិញ ដូច្នេះ គឺ : (១) កិរិយាផ្តាច់បង់នូវសេចក្តីកង្វល់ ក្នុងអាវាស, (២) កិរិយាបន្ទោបង់ចោលនូវថីនមិទ្ធៈ, (៣) ភាពជាអ្នកមិនទទាក់ទទាម ដោយទីលំនៅ ដែលសមគួរដល់ពាក្យសរសើរ ថា "ភិក្ខុទាំងឡាយ ជាអ្នកនៅមិនជាប់ជំពាក់នឹងទីកន្លែង ត្រាច់ទៅ មិនកំណត់ទីលំនៅ ដូចជាសត្វម្រឹគទាំងឡាយ [១]" ដូច្នេះ, (៤) ភាពជាអ្នកត្រាច់ទៅកាន់ទិសទាំងបួន, (៥) ភាពជាអ្នកមានកិរិយាប្រព្រឹត្តិ ដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

(អវសានគាថា ក្នុងអព្ភោកាសិកង្គៈ)

ព្រះយោគាវចរភិក្ខុ កាលនៅ ក្នុងទីវាលស្រឡះ ដែល
រកបានដោយងាយ ជាទីសមគួរ ដល់ភាវៈនៃបុគ្គលដែល
មិនមានផ្ទះ ដែលមានកែវមណី គឺដារាជាពិដាន មាន
ប្រទីបគឺព្រះច័ន្ទ សំរាប់អុចបំភ្លឺ មានចិត្ត (មិនជាប់ជំពាក់
នឹងទីលំនៅ) ដូចជាសត្វម្រឹគ បន្ទោបង់ នូវថីនមិទ្ធៈបាន

---

១- សុ. សំ. សគ. ភាគទី ៣០ ទំព័រទី ១៨៩ ។

អាស្រ័យ នូវភាពជាអ្នកត្រេកអរ ក្នុងភាវនា រមែងបាន ទទួលនូវសេចក្ដីរីករាយ ក្នុងរស នៃសេចក្ដីស្ងប់ស្ងាត់ មិនមានយឺតយូរឡើយ ព្រោះហេតុណា, ព្រោះហេតុនោះ ឯង ព្រះយោគី អ្នកមានបញ្ញា គប្បីជាអ្នកត្រេកអរ ក្នុងទីវាលស្រឡះចុះ ។

*នេះ គឺជាសេចក្ដីពណ៌នា នូវវិធី នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងអព្ភោកាសិកង្គធុតង្គ ។*

## ១១- សោសានិកង្គ:

### (វិធីសមាទាន ក្នុងសោសានិកង្គ:)

*(៤៩) សូម្បីសោសានិកង្គ: ក៏ជាធុតង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា "ខ្ញុំ ហាមឃាត់នូវទីដែលមិនមែនជាទីស្មសាន, ខ្ញុំ សមាទាននូវអង្គ នៃភិក្ខុអ្នកមានកិរិយានៅអាស្រ័យ ក្នុងទីស្មសាន ជាប្រក្រតី" ដូច្នេះ ។*

### (វិធីក្នុងសោសានិកង្គ:)

*ក៏មនុស្សទាំងឡាយ កាលកសាងស្រុក កំណត់នូវទីណាមួយ ថា "ទីនេះ ជាទីស្មសាន" ដូច្នេះ សោសានិកភិក្ខុនោះ មិនត្រូវនៅ ក្នុងទីនោះទេ ។ ព្រោះថា ទីនោះ កាលបើសាកសពគេមិនទាន់បានដុត, ក៏មិនទាន់ឈ្មោះថា ជាទីស្មសានទេ ។ តែថា ចាប់តាំងពីពេលដែលគេដុតសាកសពហើយ បើសិនគេបោះបង់ទីនោះចោល អស់រយៈពេល ១២ ឆ្នាំក៏ដោយ ក៏ឈ្មោះថា ទីស្មសានដដែល ។*

*ក៏ភិក្ខុអ្នកនៅ ក្នុងទីស្មសាននោះ មិនត្រូវប្រើឲ្យគេធ្វើទីទាំងឡាយ*



*មានទីចង្ក្រម និង មណ្ឌបជាដើម តាក់តែងគ្រែ និង តាំង តម្កល់នូវទឹកសម្រាប់ឆាន់ និង ទឹកសម្រាប់ប្រើប្រាស់ (ទើង) មិនត្រូវបង្រៀនធម៌ឡើយ ។ ព្រោះថា ធុតង្គនេះ មានទម្ងន់ពេកណាស់ ។ ព្រោះហេតុនោះ ដើម្បីការពារដល់សេចក្ដីអន្តរាយ ដែលកើតឡើង សោសានិកភិក្ខុ មិនត្រូវជាអ្នកធ្វេសប្រហែស ត្រូវតែពិតទូលដល់សង្ឃត្ថេរ ឬក៏ មន្ត្រីរាជស្រុកឲ្យបានដឹងហើយសឹមចូលនៅចុះ ។ កាលដើរចង្ក្រមត្រូវតែក្រឡេកកន្ទុយភ្នែក ឈ្មៀងមើលទៅកន្លែងសាកសព ទើបចង្ក្រម ។ សូម្បីកាលដើរចូលទៅកាន់ទីស្មសាន ត្រូវតែជៀសវាងផ្លូវធំ ហើយដើរទៅ តាមផ្លូវខាងក្រៅចុះ ។ ក្នុងវេលាថ្ងៃ ត្រូវកំណត់អារម្មណ៍ ឲ្យបានជាស្រេច ។ ព្រោះថា កាលបើសោសានិកភិក្ខុនោះ កំណត់ទុកដូច្នេះហើយ, នោះនឹងមិនមានរឿងដែលនាំឲ្យមានការភ័យខ្លាច ក្នុងពេលយប់ឡើយ ។ បើពួកអមនុស្សដើរស្រែក ក្នុងពេលយប់ មិនត្រូវប្រហារ ដោយវត្ថុអ្វីមួយឡើយ ។ មិនត្រូវខានទៅកាន់ទីស្មសាន ក្នុងថ្ងៃ ណានីមួយឲ្យសោះ ។ ព្រះអង្គុត្តរភាណកត្ថេរ ពោលថា "សោសានិកភិក្ខុ ញុំាំងមជ្ឈិមយាមឲ្យអស់ទៅ ក្នុងទីស្មសានហើយត្រឡប់មកវិញ នៅក្នុងបច្ឆិមយាមបាន" ។ មិនត្រូវឆាន់ល្ង, ម្សៅ, កត្តដែលលាយ ដោយសណ្ដែករាជមាស, ត្រី, សាច់, និង បង្អែមដែលលាយដោយទឹកដោះស្រស់, ប្រេង, ស្ករអំពៅជាដើម ដែលជាចំណូលរបស់អមនុស្សទាំងឡាយឡើយ។ មិនត្រូវចូលទៅកាន់ផ្ទះ នៃត្រកូលឡើយ ។ នេះ គឺជាវិធាននៃសោសានិកង្គ:នុ៎ះ ។*

### (ប្រភេទនៃសោសានិកភិក្ខុ)

*បើពោលតាមប្រភេទ សោសានិកភិក្ខុនេះ មាន ៣ ពួក ។ បណ្ដាភិក្ខុទាំងបី ពួកនោះ សោសានិកភិក្ខុថ្នាក់ឧក្រិដ្ឋ គប្បីនៅតែក្នុងទីស្មសាន*

ដែលមានគេដុត (ឬកប់) សាកសពជានិច្ច មានសាកសពដែលគេចោលជាប់មិនដាច់ មានមនុស្សទៅយំស្រែកជានិច្ចប៉ុណ្ណោះ ។ ចំពោះភិក្ខុថ្នាក់កណ្ដាល បណ្ដាហេតុទាំង ៣ យ៉ាងនោះ ឲ្យតែទីស្មសាន ឯណា មានហេតុណាមួយ ក៏គួរនៅបាន ។ ភិក្ខុ ថ្នាក់អន់ ក្នុងទីគ្រាន់តែដល់ នូវលក្ខណៈជាទីស្មសាន ក៏គួរនៅបាន តាមន័យដែលពោលហើយ ។

**(ការបែកធ្លាយ ក្នុងសោសានិកង្គ:)**

ធុតង្គ របស់ភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយ ព្រោះសម្រេចការនៅក្នុងទីដែលមិនមែនជាទីស្មសាន។ ព្រះអង្គុត្តរភាណកត្ថេរ ពោលថា "ធុតង្គ រមែងបែកធ្លាយ ក្នុងថ្ងៃ ដែលភិក្ខុនោះ មិនបានទៅកាន់ទីស្មសាន" ដូច្នេះ ។ នេះគឺជាការបែកធ្លាយ ក្នុងសោសានិកង្គៈនុ៎ះ ។

**(អានិសង្ស ក្នុងសោសានិកង្គ:)**

ចំណែកអានិសង្ស មានដូច្នេះ គឺ: (១) កិរិយាបាននូវមរណស្សតិ, (២) ភាពជាអ្នកនៅ ដោយសេចក្ដីមិនប្រមាទ, (៣) កិរិយាបាននូវអសុភនិមិត្ត, (៤) បន្ទោបង់នូវកាមរាគៈ, (៥) កិរិយាឃើញនូវសភាពនៃរាងកាយរឿយ ៗ, (៦) ភាពជាអ្នកមានសេចក្ដីសង្វេគច្រើន, (៧) កិរិយាលះបង់នូវសេចក្ដីស្រវឹង ដោយភាពដែលមិនមានរោគជាដើម, (៨) ភាពជាអ្នកអត់ទ្រាំនូវភ័យ ដែលគួរស្បើមបាន, (៩) ភាពជាអ្នកគួរឲ្យអមនុស្សទាំងឡាយគោរព និង កោតសរសើរ, (១០) ភាពជាអ្នកមានកិរិយាប្រព្រឹត្តិដ៏សមគួរ ដល់អប្បិច្ឆតាគុណជាដើម ។

**(អវសានគាថា ក្នុងសោសានិកង្គ:)**

ក៏ដោយអានុភាព នៃកិរិយានឹករលឹកនូវសេចក្ដីស្លាប់ ជា
រឿយៗ ទោសដែលកើត ព្រោះសេចក្ដីប្រមាទទាំងឡាយ



រមែងមិនប៉ះពាល់ នូវសោសានិកភិក្ខុ សូម្បីអ្នកចូលកាន់
និទ្រាហើយ, មិនត្រឹមតែប៉ុណ្ណោះ ចិត្ត របស់ភិក្ខុនោះ
សោត កាលបើបានឃើញ នូវសាកសពទាំងឡាយ មុខ
ជាមិនលុះទៅ ក្នុងអំណាចនៃកាមរាគៈ មានតែដល់នូវ
សេចក្ដីសង្វេគ យ៉ាងធំទូលាយ មិនមែនដល់នូវសេចក្ដី
ស្រវឹងឡើយ ទាំងព្យាយាម ខ្នះខ្នែង ស្វែងរកតែសេចក្ដី
រំលត់ទុក្ខ ដោយប្រពៃ ព្រោះហេតុនោះ ព្រះយោគី អ្នក
មានចិត្តបង្អោនចូលទៅរកព្រះនិព្វាន គប្បីសេពនូវសោ-
សានិកង្គធុតង្គចុះ ព្រោះជាធម្មជាត នាំគុណដ៏ច្រើន ជា
អនេក មកប្រគល់ឲ្យ ។

នេះ គឺជាសេចក្ដីពណ៌នា នូវវិធី នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងសោសានិកង្គធុតង្គ ។

## ១២- យថាសន្ថតិកង្គ:

**(វិធីសមាទាន ក្នុងយថាសន្ថតិកង្គៈ)**

(៥០) សូម្បី យថាសន្ថតិកង្គៈ ក៏ជាធុតង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា "ខ្ញុំ ហាមឃាត់នូវភាពដែលល្មោភ ក្នុងសេនាសនៈ, ខ្ញុំ សមាទានអង្គនៃភិក្ខុអ្នកមានកិរិយានៅក្នុងសេនាសនៈ តាមដែលសង្ឃសំដែងឲ្យ ជាប្រក្រតី" ។

**(វិធីក្នុងយថាសន្ថតិកង្គ:)**

ក៏ យថាសន្ថតិកភិក្ខុ នោះ បើភិក្ខុដែលសង្ឃ ចាត់ឲ្យជាអ្នកចែកនូវទីសេនាសនៈ បានប្រគល់ទីសេនាសនៈ បែបណាឲ្យ ដោយពាក្យថា

*“សេនាសនៈនេះ ត្រូវបានដល់អ្នក” ដូច្នេះ ត្រូវតែត្រេកអរ ដោយទីសេនាសនៈនោះប៉ុណ្ណោះ ។ មិនត្រូវធ្វើឲ្យភិក្ខុដទៃទៀត ផ្លាស់ទីលំនៅឡើយ ។ នេះ គឺជាវិធី នៃយថាសន្ថតិកង្គធុតង្គនុ៎ះ ។*

(ប្រភេទនៃយថាសន្ថតិកភិក្ខុ)

*បើពោលតាមប្រភេទ យថាសន្ថតិកភិក្ខុ នេះឯង មាន ៣ ពួក ។ បណ្ដាភិក្ខុ ៣ ពួកនោះ យថាសន្ថតិកភិក្ខុ ថ្នាក់ឧក្រិដ្ឋ មិនបានដើម្បីនឹងសួរនូវសេនាសនៈ ដែលត្រូវបានដល់ខ្លួន ថា “នៅឆ្ងាយ ឬក៏ នៅជិតពេក, ជាទីសេនាសនៈ ដែលអមនុស្ស និង ទីយជាតជាដើមបៀតបៀនឬទេ, ឬថា ក្ដៅ ឬក៏ ត្រជាក់” ដូច្នេះឡើយ ។ ភិក្ខុថ្នាក់កណ្ដាល បើនឹងសួរបាន កុំតែដើរទៅរមិលមើល ។ ភិក្ខុ ថ្នាក់អន់ ទៅត្រួតពិនិត្យមើល តែបើទីសេនាសនៈនោះ ខ្លួនមិនពេញចិត្តទេ នឹងជ្រើសយកសេនាសនៈដទៃទៀតក៏បាន ។*

(ការបែកធ្លាយ ក្នុងយថាសន្ថតិកង្គៈ)

*ក៏ធុតង្គ របស់ភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយ ក្នុងពេលត្រឹមតែកើតសេចក្ដីលោភលន់ ក្នុងទីសេនាសនៈ ។ នេះ គឺជាការបែកធ្លាយ ក្នុងយថាសន្ថតិកង្គធុតង្គនុ៎ះ ។*

(អានិសង្ស ក្នុងយថាសន្ថតិកង្គៈ)

*ចំណែកអានិសង្ស ដូច្នេះ គឺ (១) បានឈ្មោះថា ធ្វើតាមព្រះឱវាទដែលព្រះសាស្ដាត្រាស់សំដែង ថា* “ទីសេនាសនៈណា ដែលខ្លួនបានមកហើយ ភិក្ខុគប្បីត្រេកអរ ដោយទីសេនាសនៈនោះចុះ [១] ” *ដូច្នេះ, (២) ភាពជាអ្នកស្វែងរកនូវប្រយោជន៍ ឲ្យដល់សព្រហ្មចារីភិក្ខុផងគ្នា,*

*១– សុ. ខុ. ជា. ឯ. ភាគទី ៥៨ ទំព័រទី ៦០ ។*



*(៣) កិរិយាលះបង់ នូវសេចក្ដីកំណត់ថា ថោកថយ និង ថ្កើនថ្កានបាន, (៤) កិរិយាលះបង់ នូវសេចក្ដីត្រេកអរ និង សេចក្ដីពិរោធបាន, (៥) កិរិយាបិទនូវទ្វារនៃសេចក្ដីប្រាថ្នាដ៏ក្រៃលែង, (៦) ភាពជាអ្នកមានការប្រព្រឹត្តិសមគួរ ដល់ធុតង្គគុណទាំងឡាយ មានអប្បិច្ឆតាគុណជាដើម ។*

(អវសានគាថា ក្នុងយថាសន្ថតិកង្គៈ)

ព្រះយោគី អ្នកសន្ដោស ដោយសេនាសនៈ តាមដែលខ្លួនបានហើយ ជាអ្នកនៅតែក្នុងទីសេនាសនៈ ដែលសង្ឃសំដែលឲ្យ មិនរើស (សេនាសនៈដ៏ថ្លៃថ្លា ឬក៏ថោកទាប) រមែងរស់នៅយ៉ាងសុខសប្បាយ សូម្បីលើកម្រាល ដែលជាវិការៈ នៃស្មៅទាំងឡាយ លើទីសេនាសនៈ ដ៏ល្អប្រសើរ ក៏លោកមិនត្រេកអរដែរ បើទុកជាបានទីសេនាសនៈ ដ៏ថោកទាប ក៏លោកមិនក្រោធខឹងសោះឡើយ, លោក រមែងជួយអនុគ្រោះ ដល់ពួកសព្រហ្មចារីភិក្ខុផងគ្នា ដែលទើបនឹងបួសថ្មី ដោយប្រយោជន៍, ហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញា គប្បីប្រកបរឿយៗ នូវភាពជាអ្នកត្រេកអរ តែក្នុងទីសេនាសនៈ ដែលសង្ឃសំដែងឲ្យ ជាប្រពៃណី របស់ពួកព្រះអរិយៈ ដែលព្រះពុទ្ធជាអ្នកប្រាជ្ញ ដ៏ឆ្នើម ទ្រង់បានត្រាស់សរសើរហើយ ។

*នេះ គឺជាសេចក្ដីពណ៌នា នូវវិធី នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងយថាសន្ថតិកង្គធុតង្គ ។*

## ១៣- នេសជ្ជិកង្គៈ

### (វិធីសមាទាន ក្នុងនេសជ្ជិកង្គៈ)

(៥១) *សូម្បីនេសជ្ជិកង្គៈ ក៏ជាធុតង្គដែលភិក្ខុសមាទានហើយ ដោយពាក្យទាំង ២ នេះ ពាក្យណាមួយ ថា "ខ្ញុំ ហាមឃាត់នូវឥរិយាបថដេក, ខ្ញុំ សមាទាននូវអង្គ នៃភិក្ខុអ្នកមានកិរិយាសម្រេច នូវឥរិយាបថអង្គុយជាប្រក្រតី" ដូច្នេះ ។*

### (វិធីក្នុងនេសជ្ជិកង្គៈ)

*ក៏នេសជ្ជិកភិក្ខុនោះ ក្នុងយាម ៣ នៃរាត្រី គប្បីក្រោកឡើង ដើរចង្ក្រម អស់យាម ១ ។ ព្រោះថា ក្នុងឥរិយាបថទាំងឡាយ នឹងដេកតែម្យ៉ាង មិនបានឡើយ ។ នេះជាវិធីនៃនេសជ្ជិកង្គធុតង្គនុ៎ះ ។*

### (ប្រភេទនៃនេសជ្ជិកភិក្ខុ)

*បើពោលតាមប្រភេទ នេសជ្ជិកភិក្ខុនេះឯង មាន ៣ ពួក ។ បណ្តាទាំង ៣ ពួកនោះ ចំពោះនេសជ្ជិកភិក្ខុថ្នាក់ឧក្រិដ្ឋ ទីបង្អែក សំពត់សំរាប់ត្របោម សំពត់សម្រាប់ប្រតោង មិនគួរទាំងអស់ ។ ចំពោះភិក្ខុ ថ្នាក់មធ្យម វត្ថុទាំង ៣ នេះ (ប្រើប្រាស់) វត្ថុណាមួយ ក៏បាន ។ ចំពោះភិក្ខុថ្នាក់អន់ ទីបង្អែកក្តី សំពត់សំរាប់ត្របោមក្តី សំពត់សម្រាប់ប្រតោងក្តី ខ្នើយក្តី កៅអីមានអង្គ ៥ ក្តី កៅអីមានអង្គ ៧ ក្តី ប្រើប្រាស់បានទាំងអស់ ។ កៅអីដែលគេធ្វើមានបង្អែកនៅខាងក្រោយ ឈ្មោះថា បញ្ចង្គៈ ។ កៅអីដែលគេធ្វើ មានបង្អែកខាងក្រោយ និង មានក្អាក់ដៃអមសងខាង ឈ្មោះថា សត្តង្គៈ ។ បានឮមកថា ពួកមនុស្ស បានធ្វើកៅអីសត្តង្គៈនោះ (ប្រគេន) ព្រះចូឡាភយត្ថេរ អ្នកចេះព្រះត្រៃបិដក ។ ព្រះថេរៈបានសំរេចជាព្រះអនាគាមី បរិនិព្វានហើយ ។*



### (ការបែកធ្លាយ ក្នុងនេសជ្ជិកង្គៈ)

*ក៏ធុតង្គ របស់ភិក្ខុទាំង ៣ នេះឯង រមែងបែកធ្លាយ ក្នុងខណៈគ្រាន់តែភិក្ខុទាំងនេះ សម្រេចការសិង ។ នេះ គឺជាការបែកធ្លាយ ក្នុងនេសជ្ជិកង្គធុតង្គនេះ ។*

### (អានិសង្ស ក្នុងនេសជ្ជិកង្គៈ)

*ចំណែកអានិសង្សវិញ ដូច្នេះ គឺ : (១) កិរិយាកាត់ផ្តាច់នូវកំនួចរបស់ចិត្ត ដែលលោកពោលថា "ភិក្ខុ ជាអ្នកប្រកបរឿយៗ នូវសេចក្តីសុខ ក្នុងការដេក សេចក្តីសុខ ក្នុងការផ្អែក សេចក្តីសុខ ក្នុងការដេកលក់ [១] " ដូច្នេះ, (២) ភាពនៃឥរិយាបថជាទីសប្បាយ ដល់ការប្រកបនូវសេចក្តីព្យាយាម ក្នុងកម្មដ្ឋានទាំងពួង, (៣) ភាពជាអ្នកមានឥរិយាបថ ជាទីនាំមកនូវសេចក្តីជ្រះថ្លា, (៤) ភាពដ៏សមគួរដល់អ្នកប្រារព្ធសេចក្តីព្យាយាម, (៥) កិរិយាបង្កើននូវសម្មាបដិបត្តិ ។*

### (អវសានគាថា ក្នុងនេសជ្ជិកង្គៈ)

ព្រះយោគី អ្នកអង្គុយពត់ភ្នែន តម្រង់កាយឲ្យត្រង់ រមែង
ញ៉ាំងហឫទ័យនៃមារឲ្យកម្រើកបាន, ភិក្ខុអ្នកមានសេចក្តី
ព្យាយាមប្រារព្ធហើយ លះបង់នូវកិរិយាដេកជាសុខ នូវ
កិរិយាលក់ជាសុខ ត្រេកអរ តែក្នុងឥរិយាបថអង្គុយ
ញ៉ាំងព្រៃគឺតបធម៌ ឲ្យភ្លឺស្វាងរុងរឿង រមែងបាននូវបីតិ
និង សុខដែលមិនមានអាមិស ព្រោះហេតុណា, ព្រោះ
ហេតុនោះ ភិក្ខុអ្នកមានប្រាជ្ញា គប្បីបំពេញឲ្យបានល្អ នូវ
ធុតង្គវត្ត ឈ្មោះ នេសជ្ជិកៈចុះ ។

---

*១- សុ. ម. មូ. ភាគទី ២០ ទំព័រទី ៣៨៦ ។*

*នេះ ជាសេចក្ដីពណ៌នា នូវវិធី នៃការសមាទាន, ប្រភេទ, ការបែកធ្លាយ និង អានិសង្ស ក្នុងនេសជ្ជិកង្គធុតង្គ ។*

**(វិនិច្ឆ័យដោយកុសលត្តិកៈ)**

*(៥២) តទៅនេះ ជាការពណ៌នា ដោយអំណាចគាថានេះ ថា :*

បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ដោយកុសលត្តិកៈ ១
ដោយចំណែកសព្ទ មានធុតង្គជាដើម ១ ដោយសេចក្ដី
សង្ខេប និង សេចក្ដីពិស្ដារ ១ ” ។

*បណ្ដាបទទាំងនោះ បទថា “ដោយកុសលត្តិកៈ” សេចក្ដីថា ក៏ធុតង្គទាំងអស់នុ៎ះឯង ជាកុសល ក៏មាន ជាអព្យាក្រឹត ក៏មាន ដោយអំណាចនៃអ្នករក្សាដែលជាព្រះសេខៈ បុថុជ្ជន និង ព្រះខីណាស្រពទាំងឡាយ, ធុតង្គដែលជាអកុសល មិនមានទេ ។ ចំណែកបុគ្គលណា គប្បី ពោល ថា “ធុតង្គសូម្បីជាអកុសលក៏មាន” ដូច្នេះ ព្រោះព្រះបាលីជា អាទិ៍ថា* “ភិក្ខុ អ្នកមានសេចក្ដីប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាលាមកគ្របសង្កត់ហើយ ជាអារញ្ញិកៈ [1] ” *ដូច្នេះ, បុគ្គលនោះ ត្រូវគេតវ៉ាថា យើងមិនបានពោល ថា “ភិក្ខុមានចិត្តជាអកុសល រមែងមិនទៅក្នុងព្រៃ” ដូច្នេះ, ព្រោះថា កិរិយានៅក្នុងព្រៃរបស់ភិក្ខុណាមាន, ភិក្ខុនោះ ក៏ឈ្មោះថា ជាអារញ្ញិកៈ ហើយអារញ្ញិកភិក្ខុនោះសោត គប្បីជាអ្នកមានសេចក្ដីប្រាថ្នាលាមក ក៏មាន ជាអ្នកមានសេចក្ដីប្រាថ្នាតិច ក៏មាន, ក៏ពាក្យនេះ លោកបានពោលហើយថា “អង្គទាំងឡាយនេះ ឈ្មោះថា* ធុតង្គ *ព្រោះជាអង្គ របស់ភិក្ខុអ្នកឈ្មោះថា* ធុតៈ *ព្រោះជាអ្នកកំចាត់នូវកិលេសបាន*

*១- សុ. អំ. ប. ភាគទី ៩៥ ទំព័រទី ១៨៣ ។*



*ដោយកិរិយាសមាទាននោះ ៗ, មយ៉ាងទៀត ឈ្មោះថា ធុតង្គ ព្រោះមានញាណ ដែលបានវោហារ ថា “ធុតៈ ព្រោះជាគ្រឿងកំចាត់កិលេសជាអង្គ” ដូច្នេះ, មួយទៀតសោត អង្គទាំងនោះ ឈ្មោះថា ធុតៈ ព្រោះកំចាត់នូវទោស ដែលជាសឹកសត្រូវផង ជាអង្គនៃសេចក្ដីប្រតិបត្តិផង ព្រោះហេតុនោះឯង ទើបបាន ឈ្មោះថា “ធុតង្គ” ដូច្នេះឯង, អង្គទាំងឡាយនេះ គប្បីមានដល់បុគ្គលណា បុគ្គលនោះ អ្នកណាទៅ នឹងឈ្មោះថា ជាអ្នកកំចាត់កិលេសបានដោយអកុសល មិនមានផង, ធុតង្គ លោកគប្បីហៅថា ធុតង្គ ព្រោះធ្វើអកុសលនោះ ឲ្យជាអង្គនៃកិលេសទាំងឡាយណា អកុសល នឹងកំចាត់នូវកិលេសនោះឯណាមួយ មិនបានផង, អកុសលកំចាត់បដិបក្ខទោស មានសេចក្ដីលោភលន់ ក្នុងចីវរជាដើម មិនបានផង, ជាអង្គនៃសេចក្ដីប្រតិបត្តិ មិនបានផង, ព្រោះហេតុនោះ ពាក្យថា “ធុតង្គ ជាអកុសល មិនមាន” ដូច្នេះនេះ គឺលោកពោលល្អហើយ, ឯធុតង្គ របស់ភិក្ខុទាំងឡាយណា រួចផុតស្រឡះពីកុសលត្តិកៈ, ធុតង្គ របស់ភិក្ខុទាំងឡាយនោះ ដោយសេចក្ដី ក៏មិនមានពិត ។ របស់ដែលមិនមាន នឹងឈ្មោះថា ជាធុតង្គ ព្រោះកំចាត់បង់នូវអ្វី, សូម្បីសេចក្ដីខុសផ្សេងពីបាលីថា “ប្រព្រឹត្តសមាទាន នូវធុតគុណទាំងឡាយ” ដូច្នេះ ក៏រមែងត្រូវដល់ភិក្ខុទាំងឡាយនោះ, ព្រោះហេតុនោះ ពាក្យរបស់ភិក្ខុទាំងនោះ មិនត្រូវកាន់យកឡើយ ។ នេះ គឺជាសេចក្ដីពណ៌នា ដោយកុសលត្តិកៈ ជាបឋម ។*

**(វិនិច្ឆ័យដោយចំណែកធុតាទិសព្ទ)**

*ក្នុងពាក្យថា “ដោយចំណែកនៃសព្ទ មានធុតង្គសព្ទជាដើម” នោះ បណ្ឌិត គប្បីជ្រាបធុតៈ, គប្បីជ្រាបធុតវាទៈ, គប្បីជ្រាបធុតធម៌ទាំង*

ឡាយ, គប្បីជ្រាបធុតង្គទាំងឡាយ, គប្បីជ្រាបការសេពធុតង្គទាំងឡាយ ថា ជាទីសប្បាយ ដល់បុគ្គលណា ។

(ធុតៈ)

បណ្តាបទទាំងនោះ បទថា "ធុតៈ" បានដល់ បុគ្គលអ្នកកំចាត់បង់កិលេសបានហើយ ឬ ធម៌ដែលជាគ្រឿងកំចាត់បង់នូវកិលេស ។

(ធុតវាទៈ)

ចំណែកក្នុងបទ ថា "ធុតវាទ" នេះ បណ្ឌិត គប្បីជ្រាបថា បុគ្គលជាធុតៈ តែមិនមែនជាធុតវាទ ក៏មាន, បុគ្គលមិនមែនជាធុតៈ តែជាធុត-វាទ ក៏មាន, បុគ្គលទាំងមិនមែនជាធុតៈ ទាំងមិនមែនជាធុតវាទ ក៏មាន, បុគ្គលទាំងជាធុតៈ ទាំងជាធុតវាទក៏មាន ។ បណ្តាបុគ្គលទាំង៤ ពួកនោះ បុគ្គលណា កំចាត់បង់នូវកិលេសទាំងឡាយ របស់ខ្លួន ដោយធុតង្គ, តែមិនអប់រំទូន្មានអ្នកដទៃ ដោយធុតង្គ ប្រៀបដូចព្រះថេរៈ ឈ្មោះពាកុលៈ, បុគ្គលនេះ ឈ្មោះថា ធុតៈតែមិនមែនជាធុតវាទ ។ សមដូចជាពាក្យដែលលោកពោលថា "បុគ្គលដែលជាធុតៈ តែ មិនមែនជាធុតវាទនេះនុ៎ះ ស្រេចតែភិក្ខុពាកុលត្ថេរដ៏មានអាយុ" ។ ចំណែកបុគ្គលណា មិនកំចាត់បង់នូវកិលេសទាំងឡាយ របស់ខ្លួន ដោយធុតង្គ, អប់រំទូន្មាននូវពួកជនដទៃ ដោយធុតង្គតែម្យ៉ាង ដូចជាព្រះឧបនន្ទត្ថេរ, បុគ្គលនេះ មិនមែនជាធុតៈ តែជាធុតវាទ ។ សមដូចជាលោកពោលថា "បុគ្គលដែលមិនមែនជា ធុតៈ តែជាធុតវាទនេះនុ៎ះ ស្រេចតែព្រះឧបនន្ទសក្យបុត្រ ដ៏មានអាយុ" ។ បុគ្គលណា ដាច់ទាំង ២ យ៉ាង ដូចជាព្រះលោលុទាយី, បុគ្គលនេះ មិនមែនទាំងធុតៈ មិនមែនទាំងធុតវាទ ។ សមដូចជាលោកពោលថា "បុគ្គលដែលមិនមែនជាធុតៈ មិនមែនជាធុតវាទនេះនុ៎ះ ស្រេច



តែព្រះលោលុទាយី ដ៏មានអាយុ" ។ ចំណែកបុគ្គលណា ដល់ព្រមទាំង ២ យ៉ាង ដូចជាព្រះធម្មសេនាបតី, បុគ្គលនេះ ឈ្មោះថា ជាធុតៈផង ជាធុតវាទផង ។ ដូចលោកពោលហើយ ថា "បុគ្គលដែលជាធុតៈផង ជាធុតវាទផង នេះនុ៎ះ ស្រេចតែព្រះសារីបុត្រដ៏មានអាយុ" ដូច្នេះ ។

(ធុតធម៌)

ពាក្យថា "បណ្ឌិតគប្បីជ្រាបធុតធម៌ទាំងឡាយ" នុ៎ះ មានសេចក្តីវិនិច្ឆ័យថា: ធម៌ទាំងឡាយ ៥ យ៉ាង ដែលជាបរិវារ របស់ធុតង្គចេតនានេះ គឺ ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច, ភាពជាអ្នកសន្តោស, ភាពជាអ្នកប្រព្រឹត្តជុសខាត់កិលេស, ភាពជាអ្នកស្ងប់ស្ងាត់, ភាពជាអ្នកដឹងថារបស់នេះមានប្រយោជន៍ ឈ្មោះថា ធុតធម៌ ព្រោះព្រះបាលីថា "ភិក្ខុជាអ្នកមានកិរិយានៅ ក្នុងព្រៃជាប្រក្រតី ព្រោះអាស្រ័យនូវសេចក្តីប្រាថ្នាតិច" ដូច្នេះជាដើម ។ បណ្តាធម៌ទាំងនោះ អប្បិច្ឆតា និង សន្តុដ្ឋិតា រាប់បញ្ចូល ក្នុងអលោភៈ, សល្លេខតា និង បវិវេកតា រាប់ចូល ក្នុងធម៌ទាំង ២ យ៉ាង គឺ អលោភៈ និង អមោហៈ ។ ឥទមត្ថិតា បានដល់ញាណនុ៎ះឯង ។ ក្នុងអលោភៈ និង អមោហៈធម៌ទាំង ២ យ៉ាងនោះ ភិក្ខុអ្នកសមាទានធុតង្គ រមែងកំចាត់បង់នូវលោភៈ ក្នុងវត្ថុដែលត្រូវហាមឃាត់ទាំងឡាយ ដោយអលោភៈ កំចាត់បង់មោហៈ ដែលបិទបាំង នូវទោស ក្នុងវត្ថុដែលត្រូវហាមឃាត់ទាំងនោះនុ៎ះឯង ដោយអមោហៈ ។ មួយទៀត ភិក្ខុអ្នកសមាទានធុតង្គ រមែងកំចាត់បង់នូវកាមសុខានុយោគ ដែលប្រព្រឹត្តទៅ ដោយប្រធាន គឺការសេព នូវបច្ច័យទាំងឡាយដែលព្រះមានព្រះភាគទ្រង់បានអនុញ្ញាតហើយ ដោយអលោភៈ, កំចាត់បង់នូវអត្តកិលមថានុយោគ ដែលប្រព្រឹត្តទៅ ដោយប្រធាន គឺកិរិយាជុស

ខាត់ដីក្រៃលែង ក្នុងធុតង្គទាំងឡាយ ដោយអមោហៈ, ព្រោះហេតុនោះ ធម៌ទាំងឡាយ ៥ ប្រការនេះ បណ្ឌិតគប្បីជ្រាបថា ជាធុតធម៌ ។

(ធុតង្គៈ)

ពាក្យថា "គប្បីជ្រាបធុតង្គទាំងឡាយ" សេចក្ដីថាៈ បណ្ឌិត គប្បីជ្រាបធុតង្គទាំង ១៣ យ៉ាង គឺៈ បំសុកូលិកង្គៈ ។ល។ នេសជ្ជិកង្គៈ ។ ធុតង្គទាំងឡាយនោះ លោកបានពោលស្រេចហើយ ទាំងដោយអត្ថ ទាំងដោយបកិណ្ណកៈ មានលក្ខណៈជាដើម ។

(ធុតង្គសេវនា)

ពាក្យថា "ការសេពធុតង្គជាទីសប្បាយដល់បុគ្គលណា" ឆ្លើយថា ការសេពធុតង្គ ជាទីសប្បាយដល់បុគ្គលដែលជារាគចរិត និង បុគ្គលដែលជាមោហចរិត ។ ព្រោះហេតុអ្វី? ព្រោះការសេពធុតង្គ ជាការប្រតិបត្តិលំបាកផង ជាការរស់នៅយ៉ាងតឹងតែងផង ។ ក៏រាគៈ រមែងស្ងប់រម្ងាប់ ព្រោះអាស្រ័យទុក្ខាបដិបទា, មោហៈ គឺបុគ្គលអ្នកមិនប្រមាទហើយ រមែងលះបង់បាន ព្រោះអាស្រ័យសល្លេខបដិបត្តិ, មួយទៀត ក្នុងធុតង្គទាំងនេះ ការសេពអារញ្ញិកង្គៈ និង រុក្ខមូលិកង្គៈជាទីសប្បាយដល់បុគ្គលដែលមានទោសចរិតពិត។ ព្រោះថា កាលបើបុគ្គលដែលមានទោសចរិតនោះ គឺមិនមានអ្នកណាមួយ មកបៀតបៀន អាស្រ័យនៅក្នុងព្រៃ និង ក្រោមគល់ឈើហ្នឹងឯង សូម្បីទោសៈ ក៏រមែងស្ងប់រម្ងាប់ដែរ ។ នេះជាការពណ៌នា ដោយចំណែកនៃធុតង្គសព្វជាដើម ។

(វិនិច្ឆ័យដោយសង្ខេប និង ពិស្តារ)

ពាក្យថា "ដោយសង្ខេប និង ដោយពិស្តារ" នេះ មានវិនិច្ឆ័យថាៈ ក៏ធុតង្គទាំងនេះ ដោយសង្ខេប មានត្រឹមតែ ៨ ប៉ុណ្ណោះ គឺ ចាត់ជាអង្គ



ដែលជាប្រធាន ៣ ជាអង្គដែលមិនច្រឡំគ្នា ៥ ។ បណ្ដាអង្គទាំង៨ នោះ អង្គ ៣ នេះ គឺៈ សបទានចារិកង្គៈ, ឯកាសនិកង្គៈ, អព្ភោកាសិកង្គៈ ជាអង្គដែលជាប្រធាន ។ ព្រោះថា កាលភិក្ខុរក្សាសបទានចារិកង្គៈ ក៏ត្រូវតែរក្សាបិណ្ឌបាតិកង្គៈផងដែរ ។ ក៏បើភិក្ខុរក្សាឯកាសនិកង្គៈ សូម្បីបិណ្ឌបាតិកង្គៈ និង ខលុបច្ឆាភត្តិកង្គៈ ក៏ឈ្មោះថា ត្រូវរក្សាយ៉ាងល្អប្រសើរផង ។ កាលបើភិក្ខុរក្សាអព្ភោកាសិកង្គៈ នឹងមានអ្វី ឈ្មោះថាត្រូវរក្សា ក្នុងរុក្ខមូលិកង្គៈ និង យថាសន្ថតិកង្គៈនុ៎ះ ។ ដូច្នេះ ធុតង្គទើបមានត្រឹមតែ ៨ ប៉ុណ្ណោះ គឺ : អង្គដែលជាប្រធាននេះ ៣ និង អង្គដែលមិនច្រឡំគ្នា ៥ នេះ គឺៈ អារញ្ញិកង្គៈ, បំសុកូលិកង្គៈ, តេចីវរិកង្គៈ, នេសជ្ជិកង្គៈ, សោសានិកង្គៈ ។

ដោយសង្ខេប មួយទៀត មានត្រឹមតែ ៤ យ៉ាងប៉ុណ្ណោះ ដូច្នេះ គឺ ទាក់ទងដោយចីវរ ២, ទាក់ទងដោយបិណ្ឌបាត ៥, ទាក់ទងដោយសេនាសនៈ ៥, ទាក់ទងដោយសេចក្ដីព្យាយាម ១ ។ បណ្ដាធុតង្គទាំង ៤ យ៉ាងនោះ នេសជ្ជិកង្គៈ ជាអង្គប្រកបព្រមដោយវីរិយៈ ។ ធុតង្គទាំងឡាយក្រៅអំពីនេះ ប្រាកដច្បាស់អស់ហើយ ។

ដោយសង្ខេប មួយទៀត ធុតង្គទាំងអស់នុ៎ះឯង មាន ២ យ៉ាង ដោយអំណាចនៃទីអាស្រ័យ គឺៈ អាស្រ័យនូវបច្ច័យ ១២, អាស្រ័យសេចក្ដីព្យាយាម ១ ។ សូម្បីដែលចាត់ជាអង្គដែលគួរសេព និង មិនគួរសេព ក៏មាន ២ យ៉ាង ដូចគ្នាដែរ ។ ក៏កាលបើភិក្ខុណា សេពនូវធុតង្គ, កម្មដ្ឋាន រមែងចំរើន, ភិក្ខុនោះ គប្បីសេព ។ កាលបើភិក្ខុណា សេព, កម្មដ្ឋាន រមែងសាបសូន្យ, ភិក្ខុនោះមិនគប្បីសេពទេ។ ចំណែកភិក្ខុណា កាលសេពក្ដី មិនសេពក្ដី, កម្មដ្ឋាន ចេះតែចំរើនឡើង មិនសាបសូន្យ,

ភិក្ខុនោះឯង បើនឹងអនុគ្រោះ ដល់ប្រជុំជនជំនាន់ក្រោយ ត្រូវតែសេព ។ សូម្បីភិក្ខុណា សេពក្តី មិនសេពក្តី, កម្មដ្ឋាន ក៏នៅតែមិនចំរើនឡើង, ភិក្ខុនោះឯង ត្រូវតែសេពដូចគ្នា ដើម្បីជាវាសនា តទៅអនាគត ។ ធុតង្គ មាន ២ យ៉ាង ក៏មាន គឺធុតង្គដែលគួរសេព ១, ធុតង្គដែលមិនគួរសេព ១ ដូច្នេះឯង ។

សូម្បីក្នុងអដ្ឋកថាទាំងឡាយ ក៏លោកពោលថា "ធុតង្គទាំងពួងនុ៎ះឯង មានត្រឹមតែ ១ ដោយសំដៅយកត្រង់ចេតនា ព្រោះចេតនា ក្នុងការសមាទានធុតង្គ ដូចគ្នាតែមួយទេ" ។ អាចារ្យពួកខ្លះ ពោលថា : "ចេតនា យ៉ាងណា, ធុតង្គ ក៏យ៉ាងនោះដែរ" ។

ចំណែកដោយពិស្តារ ធុតង្គ មាន ៤២ យ៉ាង គឺៈ ចំពោះភិក្ខុ មាន ១៣, ភិក្ខុនី មាន ៨, សាមណេរ ១២, សិក្ខមានា និង សាមណេរី ៧, ឧបាសក និង ឧបាសិកា មាន ២ ។ ប្រសិនបើទីស្មសាន ដល់ព្រមជាអារញ្ញិកង្គៈ មាននៅ ក្នុងទីវាលស្រឡះ, សូម្បីតែភិក្ខុមួយរូប ក៏អាចដើម្បីបរិភោគនូវធុតង្គបានគ្រប់ទាំងអស់ ដោយវេលាតែមួយ។ ចំណែកចំពោះពួកនាងភិក្ខុនី អារញ្ញិកង្គៈ និង ខលុបច្ឆាភត្តិកង្គៈ ទាំង ២ យ៉ាង ព្រះអង្គទ្រង់ហាម ដោយសិក្ខាបទ ជាមួយគ្នា ។ អង្គទាំង ៣ នេះ គឺៈ អព្ភោកាសិកង្គៈ, រុក្ខមូលិកង្គៈ, សោសានិកង្គៈ ជាអង្គដែលនាងភិក្ខុនីរក្សាបានដោយលំបាក ។ ព្រោះថា ការនៅក្នុងព្រៃ ប្រាសចាកសំឡាញ់ហើយ រមែងមិនគួរដល់នាងភិក្ខុនីឡើយ ។ ក៏ក្នុងទីកន្លែងបែបនោះ ស្ត្រីដែលជាសំឡាញ់មានឆន្ទៈស្មើគ្នា រកបានដោយក្រ ។ ប្រសិនបើរកបាន ក៏មិនរួចផុតអំពីការនៅប្រឡូកប្រឡំគ្នាដែរ ។ បើយ៉ាងដូច្នោះ ភិក្ខុនីគប្បីសេពធុតង្គ ដើម្បីប្រយោជន៍ណា, ប្រយោជន៍នោះ ក៏មិនសម្រេច ដល់



ភិក្ខុនីនោះឡើយ ។ គប្បីជ្រាបថាៈ ធុតង្គ របស់ពួកភិក្ខុនី បន្ថយចុះមក ៥ ទើបនៅសល់ត្រឹមតែ ៨ ព្រោះភាវៈដែលមិនអាចបរិភោគបាន យ៉ាងនេះឯង ។ មួយវិញទៀត បណ្តាធុតង្គដូចបានពោលមកហើយ លើកលែងតែតេចីវរិកង្គៈចេញទៅ ធុតង្គដែលសេសសល់ ១២ យ៉ាង គប្បីជ្រាបថា ជាអង្គ របស់សាមណេរទាំងឡាយ, ៧ ជាអង្គ របស់ពួកនាងសិក្ខមានា និង សាមណេរី ។ ចំណែកឯ ពួកឧបាសក និង ឧបាសិកា មានធុតង្គ ២ គឺៈ ឯកាសនិកង្គៈ ១, បត្តបិណ្ឌិកង្គៈ ១ ព្រោះហេតុនេះ ធុតង្គទាំង ២ នេះ ប៉ុណ្ណោះ ជាធុតង្គ ដ៏សមគួរផង អាចនឹងបរិភោគបានផង ។ ដោយពិស្តារ ធុតង្គ មាន ៤២ ដូច្នេះឯង ។ នេះ គឺជាការពណ៌នា ដោយសង្ខេប និង ពិស្តារ ។

ក៏ការពណ៌នាអំពីធុតង្គដែលជាវត្ត គឺភិក្ខុត្រូវសមាទាន ដើម្បីញុំាងគុណទាំងឡាយ មានសេចក្តីប្រាថ្នាតិច និង សន្តោសជាដើម ដែលជាគ្រឿងផូរផង់ នៃសីល មានប្រការដូចបានពោលមកហើយ ឲ្យដល់ព្រមក្នុងវិសុទ្ធិមគ្គ ដែលព្រះអង្គសំដែងហើយដោយប្រធាន គឺសីល, សមាធិ និង បញ្ញា ដោយគាថានេះថា "សីលេ បតិដ្ឋាយ នរោ សបញ្ញោ" ដូច្នេះ គឺលោកបានពោលហើយ ដោយកថាមគ្គ មានប្រមាណប៉ុណ្ណោះឯង ។

បរិច្ឆេទ ទី២ ឈ្មោះធុតង្គនិទ្ទេស
ក្នុងវិសុទ្ធិមគ្គ ដែលខ្ញុំរចនាហើយ
ដើម្បីប្រយោជន៍ដល់បាមោជ្ជៈនៃសាធុជន ដូច្នេះឯង

❀ ❀

រៀបរៀងចប់ ថ្ងៃ ១៤ កើត ខែស្រាពណ៍ ឆ្នាំជូត អដ្ឋស័ក ព.ស.២៥៣៩
ត្រូវនឹងថ្ងៃអង្គារ ទី២៧ ខែសីហា ១៩៩៦

(៥៣) ឥឡូវនេះ យោគាវចរកុលបុត្រ អ្នកឋិតនៅស៊ប់ហើយក្នុងសីលនេះ ដែលផូរផង់ ដោយគុណទាំងឡាយ មានភាពជាអ្នកប្រាថ្នាតិចជាដើម ដែលខ្លួនបានធ្វើឲ្យដល់ព្រមហើយ ដោយការរក្សា នូវធុតង្គយ៉ាងដូច្នេះហើយ គប្បីចំរើនសមាធិ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយ ដោយប្រធាន គឺចិត្ត តាមព្រះបាលីថា “**សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ**” ដូច្នេះជាដើម, ប៉ុន្តែសមាធិនោះ មិនមែនធ្វើបាន ដោយងាយទេ សូម្បីត្រឹមតែយល់ដឹង, នឹងចាំបាច់ទៅពោលធ្វើអ្វី ដល់ការចំរើនទុំះ ព្រោះព្រះមានព្រះភាគត្រាស់សំដែងហើយ ដោយសង្ខេបក្រៃពេកណាស់ ព្រោះហេតុណា, ព្រោះហេតុនោះ ដើម្បីនឹងសំដែងនូវសេចក្ដីពិស្ដារ និង ន័យនៃការចំរើន នៃសមាធិនោះ ទើបមានបញ្ហាកម្ម ដូចតទៅនេះ គឺ :

(១) អ្វីជាសមាធិ?,

(២) សមាធិ ដោយសេចក្ដីថា ដូចម្ដេច?,

(៣) អ្វីជាលក្ខណៈ, ជារស, ជាសេចក្ដីប្រាកដ និង ជាហេតុ ជាទីតាំង នៃសមាធិនោះ?,

(៤) សមាធិ មានប៉ុន្មានយ៉ាង?,

(៥) អ្វីជាគ្រឿងសៅហ្មង និង អ្វីជាសេចក្ដីផូរផង់នៃសមាធិនោះ?,

(៦) សមាធិ គប្បីចំរើនបាន យ៉ាងដូចម្ដេច?,

(៧) អ្វីជាអានិសង្ស នៃការចំរើនសមាធិ? ។

ក្នុងបញ្ហាកម្មនោះ មានការវិសជ្ជនា ដូចតទៅនេះ ។

ពាក្យថា “អ្វីជាសមាធិ?” ឆ្លើយថា : សមាធិ មានច្រើនយ៉ាង



ច្រើនប្រការផ្សេងៗណាស់ ។ ការវិសជ្ជនានូវសមាធិទាំងអស់នោះប្រាថ្នាធ្វើឲ្យប្រាកដជាក់ច្បាស់ គប្បីញុាំងសេចក្ដីប៉ងប្រាថ្នាទុំះឯង ឲ្យសម្រេចមិនបានឡើយ និង ថែមទាំងប្រព្រឹត្តទៅ ដើម្បីសេចក្ដីរាយមាយលើសដើមទៅទៀត, ព្រោះហេតុនោះ យើងទាំងឡាយ ពោលសំដៅយកសេចក្ដីប៉ងប្រាថ្នាទុំះឯង ក្នុងទីនេះថា: ភាពមានអារម្មណ៍តែមួយ នៃចិត្តដែលជាកុសល ឈ្មោះថា សមាធិ ដូច្នេះ ។

(អត្ថនៃសមាធិ)

ពាក្យថា “សមាធិ ដោយអត្ថថាដូចម្ដេច?” ឆ្លើយថា: ឈ្មោះថា សមាធិ ព្រោះអត្ថថា តាំងនៅស៊ប់ ។ សួរថា: ឈ្មោះថា ការតាំងនៅស៊ប់នេះ តើដូចម្ដេច? ។ ឆ្លើយថា: ឈ្មោះថា ការតាំងនៅស៊ប់នេះ គឺការតាំងនៅខ្ជាប់ អធិប្បាយថា: ការឋិតនៅស្មាំស្មើផង ដោយត្រឹមត្រូវផង នៃចិត្ត និង ចេតសិកទាំងឡាយ ក្នុងអារម្មណ៍តែមួយ ។ ហេតុនោះគប្បីជ្រាបថា “ចិត្ត និង ចេតសិកទាំងឡាយ ជាធម្មជាតមិនរាយមាយ និង មិនរសាត់អណ្តែតអណ្តូង ឋិតនៅស្មាំស្មើផង ត្រឹមត្រូវផង ក្នុងអារម្មណ៍តែមួយ ដោយអានុភាព នៃធម៌ណា, ការឋិតនៅ នៃចិត្ត និង ចេតសិកទាំងឡាយ ដោយអានុភាព នៃធម៌នោះនេះ ឈ្មោះថា ការតាំងនៅស៊ប់” ដូច្នេះ ។

(លក្ខណៈ, កិច្ច...នៃសមាធិ)

ចំណែកក្នុងពាក្យថា “អ្វីជាលក្ខណៈ, កិច្ច, ផល និង ជាហេតុនៃសមាធិនោះ” ដូច្នេះនេះ មានពាក្យឆ្លើយថា: សមាធិ មានការមិនរាយមាយចិត្ត ជាលក្ខណៈ, មានការកំចាត់ នូវសេចក្ដីអណ្តែតអណ្តូងជាកិច្ច, មានកិរិយាមិនញាប់ញ័រ ជាផល, ចំណែកឯហេតុនៃសមាធិនោះ

គឺសេចក្ដីសុខ ដោយព្រះបាលី ថា "ចិត្ត របស់បុគ្គលដែលមានសេចក្ដីសុខ រមែងតាំងនៅខ្ជាប់" ដូច្នេះ ។

(ប្រភេទនៃសមាធិ)

(៥៤) ពាក្យថា "សមាធិ មានប៉ុន្មានយ៉ាង?" ឆ្លើយថា: ដំបូងដោយលក្ខណ: គឺការមិនរាយមាយចិត្ត សមាធិ ទើបមានតែមួយ, មាន ២ យ៉ាង ដោយអំណាចនៃឧបចារសមាធិ និង អប្បនាសមាធិ, មាន ២ យ៉ាង ដោយអំណាចលោកិយសមាធិ និង លោកុត្តរសមាធិ ក៏ដូច្នោះដែរ, មាន ២ យ៉ាង ដោយអំណាចនៃសមាធិ ដែលប្រកបដោយបីតិ និង សមាធិដែលមិនប្រកបដោយបីតិ និង ដោយអំណាចសុខសហគត: និង ឧបេក្ខាសហគត: ក៏ដូច្នោះដែរ, សមាធិ មាន ៣ យ៉ាង ដោយអំណាចនៃសមាធិដែលអន់ថយ, កណ្ដាល និងប្រណីត, មាន ៣ យ៉ាង ដោយអំណាចនៃសមាធិ ដែលមានវិតក្ក: និង មានវិចារ:ជាដើម ដោយអំណាចនៃសមាធិ មានសមាធិដែលប្រកបព្រម ដោយបីតិជាដើម និង ដោយអំណាចនៃគុណានុភាពដែលជាបរិត្ត:, មហគ្គត: និង អប្បមាណ: ក៏ដូច្នោះដែរ, សមាធិ មាន ៤ យ៉ាង ដោយអំណាចនៃសេចក្ដីប្រតិបត្តិ និង ការយល់ដឹង មានទុក្ខាបដិបទា ទន្ធាភិញ្ញាសមាធិជាដើម ដោយអំណាចនៃអានុភាព និង អារម្មណ៍ មានបរិត្តបរិត្តារម្មណសមាធិជាដើម ដោយអំណាចនៃអង្គ នៃចតុកជ្ឈាន ដោយអំណាចនៃផ្នែក មានបហានភាគិយសមាធិជាដើម ដោយអំណាចភូមិ មានកាមាវចរសមាធិជាដើម និង ដោយអំណាចឥទ្ធិបាទ ដែលជាអធិបតី ក៏យ៉ាងដូច្នោះដែរ, សមាធិ មាន ៥ យ៉ាង ដោយអំណាចនៃអង្គ នៃបញ្ចកឈាន ក្នុងបញ្ចកន័យ ។ ក្នុងសមាធិទាំងនោះ សមាធិមានចំណែកតែ១ មានសេចក្ដីពាក់ព័ន្ធនៃពិត។



(ក្រុមសមាធិ ២ ទី ១)

(៥៥) បណ្ឌិត គប្បីជ្រាបសេចក្ដីអធិប្បាយ ក្នុងសមាធិ ដែលមានចំណែក ២ ដូចតទៅនេះ ។ ឯកគ្គតា នៃចិត្ត ដែលព្រះយោគី បានហើយ ដោយអំណាច នៃធម៌ទាំងឡាយនេះ គឺ: អនុស្សតិដ្ឋាន ៦, មរណស្សតិ, ឧបសមានុស្សតិ, អាហារេបដិកូលសញ្ញា, ចតុធាតុវវដ្ឋាន, និង ឯកគ្គតា ក្នុងចំណែកខាងដើម នៃអប្បនាសមាធិ ទាំងឡាយណា, ឯកគ្គតានេះ ជាឧបចារសមាធិ, ចំណែក ឯកគ្គតា ក្នុងលំដាប់ នៃបរិកម្ម ឯណា ព្រោះព្រះបាលីថា "បរិកម្ម នៃបឋមឈាន ជាបច្ច័យ ដោយជាអនន្តរបច្ច័យនៃបឋមឈាន [1]" ដូច្នេះជាដើម, ឯកគ្គតានេះ ឈ្មោះថា អប្បនាសមាធិ ដោយប្រការដូច្នេះ ។ សមាធិ មាន ២ យ៉ាង ដោយអំណាចនៃឧបចារសមាធិ និង អប្បនាសមាធិផង យ៉ាងដូច្នេះឯង ។

(ក្រុមសមាធិ ២ ទី ២)

សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ២ ទី២ ដូចតទៅនេះ ។ ឯកគ្គតា នៃចិត្ត ដែលជាកុសល ក្នុងភូមិទាំង ៣ ជាលោកិយសមាធិ, ឯកគ្គតា ដែលសម្បយុត្តហើយ ដោយអរិយមគ្គ ជាលោកុត្តរសមាធិ ។ សមាធិ មាន ២ យ៉ាង ដោយអំណាចលោកិយ: និង លោកុត្តរ: យ៉ាងនេះឯង។

(ក្រុមសមាធិ ២ ទី ៣)

សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ២ ទី៣ ដូចតទៅនេះ ។ ឯកគ្គតា ក្នុងឈានទាំង ២ ក្នុងចតុក្កន័យ ក្នុងឈានទាំង ៣ ក្នុងបញ្ចកន័យ ជាសមាធិ ប្រកបដោយបីតិ, ឯកគ្គតា ក្នុងឈានទាំងឡាយ ២ ដ៏សេស ជាសមាធិ មិនប្រកបដោយបីតិ, តែឧបចារសមាធិ ជាសមាធិ ប្រកប

---

១- អភិ. ប. ភាគទី ៩៨ ទំព័រទី ២៨៦ ។

ដោយបីតិ (និង) មិនប្រកបដោយបីតិ ។ សមាធិ មាន ២ យ៉ាង ដោយអំណាច នៃសប្បីតិកៈ និង និប្បីតិកៈ យ៉ាងនេះឯង ។

(ក្រុមសមាធិ ២ ទី ៤)

សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ២ ទី៤ ដូចតទៅនេះ ។ ឯកគ្គតា ក្នុងឈានទាំង ៣ ក្នុងចតុក្កន័យ ក្នុងឈានទាំង ៤ ក្នុងបញ្ចកន័យ ជាសមាធិ ប្រកបព្រមដោយសុខ, ឯកគ្គតា ក្នុងឈានទាំងឡាយដ៏សេស ជាសមាធិ ប្រកបព្រមដោយឧបេក្ខា, តែឧបចារសមាធិ ជាសមាធិ ប្រកបព្រមដោយសុខ (និង) ប្រកបព្រមដោយឧបេក្ខា ។ សមាធិ មាន ២ យ៉ាង ដោយអំណាចនៃសុខសហគតៈ និង ឧបេក្ខាសហគតៈ ដោយប្រការដូច្នេះឯង ។

(ក្រុមសមាធិ ៣ ទី ១)

(៥៦) ក៏ក្នុងក្រុមសមាធិទាំងឡាយ ៣ សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៣ ទី ១ ដូចតទៅ ។ សមាធិ ដែលបុគ្គលគ្រាន់តែបានហើយ ជាសមាធិ ដ៏អន់ថយ, សមាធិ ដែលបុគ្គលបានអប់រំហើយ មិនទាន់បានល្អប្រសើរ ជាសមាធិ ថ្នាក់កណ្ដាល, សមាធិ ដែលបុគ្គលបានអប់រំល្អប្រសើរហើយ ជាសមាធិប្រណីត ។ សមាធិ មាន ៣ យ៉ាង ដោយអំណាចសមាធិ ដ៏អន់ថយ មធ្យម និង ដ៏ប្រណីត យ៉ាងនេះឯង ។

(ក្រុមសមាធិ ៣ ទី ២)

សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៣ ទី ២ ដូចតទៅនេះ ។ សមាធិ ក្នុងបឋមឈាន មួយអន្លើដោយឧបចារសមាធិ ជាសមាធិ ដែលប្រកបដោយវិតក្កៈ និង វិចារៈ, សមាធិ ក្នុងទុតិយឈាន ក្នុងបញ្ចកន័យ ជាអវិតក្កៈ និង វិចារមត្តសមាធិ គឺជាសមាធិ ដែលមិនមានវិតក្កៈ មានតែ



វិចារៈ, ក៏បុគ្គលណា ឃើញទោសត្រឹមតែក្នុងវិតក្កៈប៉ុណ្ណោះ មិនឃើញទោស ក្នុងវិចារៈ ប្រាថ្នាត្រឹមតែការលះបង់ នូវវិតក្កៈតែម្យ៉ាង កន្លងនូវបឋមឈាន, បុគ្គលនោះ រមែងបាននូវសមាធិ ដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈ, ពាក្យថា “សមាធិ ក្នុងទុតិយឈាន ក្នុងបញ្ចកន័យ ជាអវិតក្កវិចារមត្តសមាធិ” ដូច្នេះនុ៎ះ គឺខ្ញុំពោលហើយសំដៅយកនូវសមាធិរបស់បុគ្គលនោះ ។ ចំណែក ឯកគ្គតា ក្នុងឈានទាំងឡាយ ៣ ក្នុងចតុក្កន័យ មានទុតិយឈានជាដើម និង ក្នុងបញ្ចកន័យ មានតតិយ-ឈានជាដើម ជាសមាធិដែលមិនមានទាំងវិតក្កៈ មិនមានទាំងវិចារៈ ។ សមាធិ មាន ៣ យ៉ាង ដោយអំណាចនៃអង្គ គឺវិតក្កៈ វិចារៈ មានសវិតក្កៈ និង សវិចារៈ ជាដើម យ៉ាងដូច្នេះឯង ។

(ក្រុមសមាធិ ៣ ទី ៣)

សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៣ ទី៣ ដូចតទៅនេះ ។ ឯកគ្គតា ក្នុងឈានទាំងឡាយ ២ ខាងដើម ក្នុងចតុក្កន័យ និង ក្នុងឈានទាំង ៣ ខាងដើមក្នុងបញ្ចកន័យ ជាសមាធិដែលប្រកបព្រមដោយបីតិ។ ឯកគ្គតា ក្នុងតតិយឈាន និង ក្នុងចតុត្ថឈាន ក្នុងចតុក្កន័យ និង ក្នុងបញ្ចក-ន័យទាំងនោះឯង គឺជាសមាធិដែលប្រកបព្រមដោយសុខ ។ ឯកគ្គតា ក្នុងឈានជាទីបំផុត ជាសមាធិដែលប្រកប ដោយឧបេក្ខា, តែឧបចារសមាធិ ជាសមាធិ ដែលប្រកបព្រមដោយបីតិ និង សុខខ្លះ ប្រកបដោយឧបេក្ខាខ្លះ ។ សមាធិ មាន ៣ យ៉ាង ដោយអំណាចសមាធិ មានបីតិសហគតសមាធិជាដើម ដូច្នេះឯង ។

(ក្រុមសមាធិ ៣ ទី ៤)

សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៣ ទី៤ ដូចតទៅនេះ ។ ឯកគ្គតា

ក្នុងឧបចារភូមិ ជាសមាធិមានគុណដ៏តិច, ឯកគ្គតា ក្នុងរូបាវចរ និង អរូបាវចរ(ភូមិ) ដែលជាកុសល ជាសមាធិដែលមានគុណដ៏ធំ, ឯកគ្គតា ដែលសម្បយុត្ត ដោយអរិយមគ្គ ជាសមាធិ ដែលមានគុណប្រមាណ មិនបាន ។ សមាធិ មាន ៣ យ៉ាង ដោយអំណាចនៃគុណ មានបរិត្តៈ មហគ្គតៈ និង អប្បមាណៈ ។

(ក្រុម សមាធិ ៤ ទី ១)

(៥៧) សេចក្ដីវិនិច្ឆ័យ ក្នុងក្រុមសមាធិទាំងឡាយ ៤ ក្នុងក្រុម សមាធិ៤ ទី១ ដូចតទៅ ។ សមាធិដែលមានការប្រតិបត្តិលំបាក ក៏មាន, មានការត្រាស់ដឹងយឺតយូរ ក៏មាន, សមាធិ មានការប្រតិបត្តិលំបាក ក៏មាន តែមានការត្រាស់ដឹងឆាប់រហ័សក៏មាន, សមាធិ មានការប្រតិបត្តិ ស្រួល ក៏មាន, មានការត្រាស់ដឹងយឺតយូរ ក៏មាន, សមាធិ មានការ ប្រតិបត្តិស្រួលក៏មាន ប៉ុន្តែមានការត្រាស់ដឹងឆាប់រហ័ស ក៏មាន ដូច្នេះ ឯង ។ ក្នុងពាក្យថា បដិបទា និង អភិញ្ញានោះ ការចំរើនសមាធិ ដែល ប្រព្រឹត្តទៅចាប់តាំងពីការប្រមូលនូវចិត្ត ឲ្យយាងចុះក្នុងកម្មដ្ឋាន ជាដំបូង រហូតដល់ឧបចារៈ នៃឈាននោះៗ កើតឡើង ហៅថា “បដិបទា” ។ ចំណែក បញ្ញា ដែលប្រព្រឹត្តទៅចាប់តាំងអំពីឧបចារៈ រហូតដល់អប្បនា លោកហៅថា “អភិញ្ញា” ។ ក៏បដិបទានេះនុ៎ះ រមែងជាការលំបាក គឺជា ការក្រ អធិប្បាយថា ចំរើនមិនបានស្រួល ដល់បុគ្គលពួកខ្លះ ព្រោះត្រូវ ធម៌ដែលជាសឹកសត្រូវមាននីវណធម៌ជាដើម ក្របួច ប្រមូល រួបរឹត ។ (តែ) រមែងជាការស្រួល ដល់បុគ្គលពួកខ្លះ ព្រោះមិនមានធម៌ ដែលជា សឹកសត្រូវមាននីវរណធម៌ ជាដើមនោះរួបរឹត ។ ឯអភិញ្ញា រមែងជា ការយឺត គឺយូរ មិនប្រព្រឹត្តទៅ យ៉ាងឆាប់រហ័សដល់បុគ្គលពួកខ្លះ, (តែ)



ជាការឆាប់រហ័ស គឺមិនយឺតយូរ ប្រព្រឹត្តទៅ យ៉ាងឆាប់រហ័ស ដល់ បុគ្គលពួកខ្លះ ។

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងបដិបទា និង អភិញ្ញាទាំងនោះ ដូច តទៅៈ ខ្ញុំនឹងពណ៌នានូវរបស់ដែលជាទីសប្បាយ និង របស់ដែលមិន ជាទីសប្បាយ នូវបុព្វកិច្ចទាំងឡាយ មានការកាត់នូវបលិពោធជាដើម និង នូវអប្បនាកោសលទាំងឡាយឯណាព្ធដ៏ខាងមុខ, បណ្ដារបស់ដែល ជាសប្បាយ និង ជាអសប្បាយជាដើមនោះ ព្រះយោគី រូបណា ជាអ្នក សេពនូវរបស់ដែលជាអសប្បាយ, បដិបទា របស់ព្រះយោគីនោះ ជា បដិបទាប្រព្រឹត្តទៅដោយលំបាកផង ការត្រាស់ដឹង របស់ព្រះយោគីនោះ ក៏យឺតយូរផង ។ បដិបទា របស់ព្រះយោគីដែលសេពនូវរបស់ដែលជា សប្បាយ ជាបដិបទាប្រព្រឹត្តទៅ ដោយស្រួលផង ការត្រាស់ដឹង របស់ ព្រះយោគីនោះ ក៏ឆាប់រហ័សផង ។ ចំណែក ព្រះយោគីរូបណា សេព នូវរបស់ដែលជាអសប្បាយ ក្នុងកាលជាខាងដើមហើយ ជាអ្នកសេព នូវរបស់ដែលជាសប្បាយ ក្នុងកាលក្រោយមក ឬ សេពនូវរបស់ដែល ជាសប្បាយ ក្នុងកាលជាខាងដើមហើយ ជាអ្នកសេពនូវរបស់ដែលជា អសប្បាយ ក្នុងកាលក្រោយមក, បដិបទា និងអភិញ្ញា របស់ព្រះយោគី រូបនោះ បណ្ឌិត គប្បីជ្រាបថា ជារបស់ច្របូកច្របល់គ្នា ។ ក៏មានន័យ ដូចគ្នានោះដែរ បដិបទា របស់ព្រះយោគីដែលមិនបានញុំាងបុព្វកិច្ច មាន ការកាត់នូវបលិពោធជាដើម ឲ្យសម្រេចហើយ មកប្រកបនូវភាវនា ជា បដិបទាប្រព្រឹត្តទៅដោយលំបាក, ដោយន័យដែលផ្ទុយពីគ្នា ជាបដិបទា ប្រព្រឹត្តទៅ ដោយស្រួល ។ ចំណែកឯ អភិញ្ញា របស់ព្រះយោគីដែល មិនបានញុំាងអប្បនាកោសលទាំងឡាយឲ្យសម្រេច ជាធម្មជាតិយឺតយូរ

អភិញ្ញា របស់ព្រះយោគីដែលញ៉ាំងអប្បនាកោសល ឲ្យសម្រេច ជាធម្មជាតិឆាប់រហ័ស។ម្យ៉ាងទៀត ប្រភេទនៃបដិបទា និង អភិញ្ញាទាំងឡាយនោះ បណ្ឌិតគប្បីជ្រាប ដោយអំណាចតណ្ហា និង អវិជ្ជា និង ដោយអំណាចនៃការសន្សំអប់រំមក ក្នុងសមថៈ និង វិបស្សនាផង ។ មែនពិតបដិបទា របស់ព្រះយោគី ដែលត្រូវតណ្ហាគ្របសង្កត់ គឺជាបដិបទា ដ៏លំបាក, បដិបទា របស់ព្រះយោគី ដែលមិនត្រូវតណ្ហាគ្របសង្កត់ ជាបដិបទាប្រព្រឹត្តទៅស្រួល ។ ឯអភិញ្ញា របស់ព្រះយោគី ដែលត្រូវអវិជ្ជាគ្របសង្កត់ គឺជាធម្មជាតិយឺតយូរ, របស់ព្រះយោគី ដែលមិនត្រូវអវិជ្ជាគ្របសង្កត់ ជាធម្មជាតិប្រព្រឹត្តទៅឆាប់រហ័ស។ ចំណែកព្រះយោគីរូបណា មិនបានធ្វើការសន្សំអប់រំមក ក្នុងសមថៈ, បដិបទា របស់ព្រះយោគីរូបនោះ ជាបដិបទាប្រព្រឹត្តទៅ ដោយលំបាក, របស់ព្រះយោគីដែលបានធ្វើការសន្សំអប់រំមក ជាបដិបទាប្រព្រឹត្តទៅ ដោយស្រួល ។ ចំណែកព្រះយោគីណា មិនបានធ្វើការសន្សំអប់រំ ក្នុងវិបស្សនា, អភិញ្ញារបស់ព្រះយោគីនោះ ជាធម្មជាតិយឺតយូរ, របស់ព្រះយោគីដែលបានធ្វើការសន្សំអប់រំមក ជាធម្មជាតិឆាប់រហ័ស ។ មួយទៀត បណ្ឌិត គប្បីជ្រាបប្រភេទនៃបដិបទា និង អភិញ្ញាទាំងនោះ ដោយអំណាចនៃកិលេសនិង ឥន្ទ្រីយ៍ផងចុះ ។ ពិតមែនដូច្នោះ បដិបទា របស់បុគ្គលដែលមានកិលេសខ្លាំងក្លា តែមានឥន្ទ្រីយ៍ទន់ខ្សោយ ជាបដិបទាប្រព្រឹត្តទៅ ដោយលំបាកផង ទាំងអភិញ្ញា ក៏ជាធម្មជាតិយឺតយូរផង, ចំណែកឯ អភិញ្ញារបស់បុគ្គលអ្នកមានឥន្ទ្រីយ៍ខ្លាំងក្លា ជាធម្មជាតិឆាប់រហ័ស ។ ឯបដិបទារបស់បុគ្គលដែលមានកិលេសទន់ខ្សោយ និង មានឥន្ទ្រីយ៍ទន់ខ្សោយជាបដិបទាប្រព្រឹត្តទៅ ដោយស្រួល, ប៉ុន្តែ អភិញ្ញា ជាធម្មជាតិយឺតយូរ,



ចំណែកអភិញ្ញា របស់បុគ្គលដែលមានឥន្ទ្រីយ៍ខ្លាំងក្លា ជាធម្មជាតិ ឆាប់រហ័ស ដោយប្រការដូច្នេះ ។ ក្នុងបដិបទា និង អភិញ្ញាទាំងនេះ បុគ្គលណា ដល់នូវសមាធិ ដោយបដិបទាដ៏លំបាក និង ដោយអភិញ្ញាដ៏យឺតយូរ, សមាធិនោះ របស់បុគ្គលនោះ លោកហៅថា “បដិបទាប្រព្រឹត្តទៅដោយលំបាក (ទាំង) ការត្រាស់ដឹងក៏យឺតយូរ” យ៉ាងដូច្នេះឯង។ សូម្បីក្នុងសមាធិ ៣ ដ៏សេស ក៏ន័យដូចគ្នានេះដែរ ។ សមាធិ មាន ៤ យ៉ាងដោយអំណាចនៃការប្រតិបត្តិ និង ការត្រាស់ដឹង មានទុក្ខាបដិបទាទន្ធាភិញ្ញាសមាធិជាដើម ដោយប្រការដូច្នេះឯង ។

(ក្រុមសមាធិ ៤ ទី ២)

សេចក្តីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៤ ទី២ ដូចតទៅនេះ ។ គប្បីជ្រាបថា សមាធិ មានសភាពតូចឆ្មារផង ទាំងមានអារម្មណ៍តូចឆ្មារផងក៏មាន, សមាធិមានសភាពតូចឆ្មារផង តែមានអារម្មណ៍ប្រមាណមិនបានក៏មាន, សមាធិ មានសភាពរកប្រមាណមិនបាន តែមានអារម្មណ៍ តូចឆ្មារ ក៏មាន, សមាធិ មានសភាពរកប្រមាណមិនបានផង ទាំងមានអារម្មណ៍ រកប្រមាណមិនបានផង ក៏មាន ។ ក្នុងសមាធិ ទាំង ៤ នោះសមាធិណា មិនស្ទាត់ជំនាញ មិនអាចដើម្បីនឹងជាបច្ច័យ នៃឈានថ្នាក់ខ្ពស់បាន, សមាធិនេះ ជាសមាធិមានសភាពតូចឆ្មារ ។ ចំណែកសមាធិណា ប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមិនរីកចំរើន, សមាធិនេះ ជាសមាធិមានអារម្មណ៍ដ៏តូចឆ្មារ ។ សមាធិ ឯណា មានការស្ទាត់ជំនាញ ដែលព្រះយោគី បានអប់រំល្អហើយ រមែងអាចដើម្បីជាបច្ច័យ នៃឈានថ្នាក់ខ្ពស់បាន, សមាធិនេះ ជាសមាធិមានសភាពប្រមាណមិនបាន, មួយទៀត សមាធិណា ប្រព្រឹត្តទៅ ក្នុងអារម្មណ៍ដែលរីកចំរើន, សមាធិនេះ

មានអារម្មណ៍ រកប្រមាណមិនបាន ។ ចំណែកឯ ន័យនៃសមាធិ ដែលប្រឫកប្រឫល់គ្នា បណ្ឌិត គប្បីជ្រាប ក្នុងសមាធិ ដែលប្រឫកប្រឫល់គ្នា តាមលក្ខណៈ ដែលបានពោលរួចមកហើយ យ៉ាងនេះឯង ។ សមាធិ មាន ៤ យ៉ាង ដោយអំណាចនៃគុណ និង អារម្មណ៍ មានបរិត្តបរិត្តារម្មណសមាធិជាដើម ដូច្នេះឯង ។

(ក្រុមសមាធិ ៤ ទី ៣)

សេចក្តីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៤ ទី៣ មានដូចតទៅនេះ ។ បឋមឈាន មានអង្គ ៥ គឺ វិតក្កៈ, វិចារៈ, បីតិ, សុខៈ និង សមាធិ ដែលបង្ក្រាបនូវនីវរណៈបានហើយ, បន្ទាប់ពីនោះ ទុតិយឈាន វិតក្កៈ និង វិចារៈ ស្ងប់រម្ងាប់ មានអង្គ ៣, បន្ទាប់អំពីនោះ តតិយឈាន មានបីតិបាត់បង់ទៅ នៅសល់អង្គ ២, បន្ទាប់អំពីនោះ ចតុត្ថឈាន លះបង់នូវសុខៈចេញ នៅសល់អង្គ ២ ដោយអំណាចនៃសមាធិ ដែលប្រកបព្រម ដោយឧបេក្ខាវេទនា ។ សមាធិ មាន ៤ យ៉ាង ដែលជាអង្គ នៃឈានទាំងឡាយ ៤ នេះ ដូច្នេះឯង, សមាធិ មាន ៤ យ៉ាង ដោយអំណាចអង្គរបស់ចតុក្កឈាន យ៉ាងនេះឯង ។

(ក្រុមសមាធិ ៤ ទី ៤)

សេចក្តីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៤ ទី៤ ដូចតទៅនេះ ។ សមាធិ ដែលប្រព្រឹត្តទៅខាងផ្លូវវិនាសក៏មាន, ប្រព្រឹត្តទៅខាងផ្លូវឋិតនៅក៏មាន, ប្រព្រឹត្តទៅខាងផ្លូវវិសេស ក៏មាន, ប្រព្រឹត្តទៅខាងផ្លូវត្រាស់ដឹងអរិយសច្ច ក៏មាន ។ ក្នុងសមាធិទាំង ៤ នោះ ភាវៈនៃសមាធិ ជាហានភាគិយៈ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃការប្រព្រឹត្តិផ្ទុះឡើង នៃធម៌ ដែលជាសឹកសត្រូវ, ភាវៈនៃសមាធិជាឋិតិភាគិយៈ គប្បីជ្រាប ដោយ



អំណាចនៃការតម្កល់នៅ នៃសតិដែលជាសភាវៈដ៏សមគួរ ដល់សមាធិនោះ, ភាវៈនៃសមាធិ ជាវិសេសភាគិយៈ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃកិរិយាបានសំរេច នូវធម៌ដ៏វិសេសខ្ពស់ឡើងទៅៗ និង ភាវៈនៃសមាធិ ជានិព្វេធភាគិយៈ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃកិរិយាផ្ទុះផ្ដាលឡើងនៃសញ្ញា និង មនសិការ ដែលប្រព្រឹត្តទៅព្រម ដោយនិព្វិទា ។ សមដូចជាលោក ពោលហើយថា: “ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបព្រមដោយកាម រមែងជាស់តឿន នូវបុគ្គលដែលបានបឋមជ្ឈាន ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ, សតិ ដែលមានសភាពដ៏សមគួរដល់បញ្ញានោះ រមែងតាំងនៅស្មើ ឈ្មោះថា បញ្ញា មានចំណែកនៃការតាំងនៅ, ការធ្វើទុកក្នុងចិត្ត ដោយសញ្ញា មិនប្រកបដោយវិតក្កៈ រមែងជាស់តឿន(នូវបុគ្គលដែលបានបឋមជ្ឈាននោះ) ឈ្មោះថា បញ្ញាមានចំណែកនៃសេចក្តីវិសេស, ការធ្វើទុកក្នុងចិត្តដោយសញ្ញា ដែលប្រកបដោយនិព្វិទា ប្រកបដោយវិរាគៈ រមែងជាស់តឿន (នូវបុគ្គលដែលបាននូវបឋមជ្ឈាននោះ) ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីនឿយណាយ [១] ” យ៉ាងដូច្នេះឯង ។ សូម្បីសមាធិ ដែលសម្បយុត្តហើយ ដោយបញ្ញានោះ ក៏មាន ៤ ។ សមាធិ មាន ៤ យ៉ាង ដោយអំណាចនៃសមាធិ មានហានភាគិយសមាធិ ជាដើម ដូច្នេះឯង ។

(ក្រុមសមាធិ ៤ ទី ៥)

សេចក្តីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៤ ទី៥ ដូចតទៅនេះ ។ សមាធិទាំងឡាយ ៤ យ៉ាងនេះ គឺ: សមាធិដែលជាកាមាវចរ, សមាធិដែលជារូបាវចរ, សមាធិដែលជាអរូបាវចរ, សមាធិដែលមិនរាប់បញ្ចូល ក្នុងភូមិទាំង ៣ នោះ គឺជាលោកុត្តរៈ ។ ក្នុងសមាធិទាំងនោះ ឯកគ្គតា ថ្នាក់

---

១- អភិ. វិ. ភាគទី ៨២ ទំព័រទី ១០៨ ។

ឧបចារៈទាំងពួង ឈ្មោះថា ជាកាមាវចរសមាធិ, ឯកគ្គតា ផ្នែកខាងកុសលចិត្ត មានរូបាវចរចិត្តជាដើម ឈ្មោះថា ជាសមាធិ ៣ យ៉ាង ក្រៅអំពីនេះ ។ សមាធិ មាន ៤ យ៉ាង ដោយអំណាចនៃភូមិ មានកាមាវចរសមាធិជាដើម យ៉ាងនេះឯង ។

(ក្រុមសមាធិ ៤ ទី ៦)

សេចក្តីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៤ ទី៦ ដូចតទៅនេះ ។ ប្រសិនបើភិក្ខុធ្វើសេចក្តីពេញចិត្ត ឲ្យជាធំ រមែងបាននូវសមាធិ បាននូវភាវៈនៃចិត្តមានអារម្មណ៍តែមួយ, សមាធិនេះ ហៅថា ឆន្ទសមាធិ, បើភិក្ខុធ្វើនូវវីរិយៈឲ្យជាធំ រមែងបាននូវសមាធិ បាននូវភាវៈនៃចិត្តមានអារម្មណ៍តែមួយ, សមាធិនេះ ហៅថា វីរិយសមាធិ, បើភិក្ខុធ្វើ នូវចិត្តឲ្យជាធំ រមែងបាននូវសមាធិ បាននូវភាវៈនៃចិត្តមានអារម្មណ៍តែមួយ, សមាធិនេះ លោកហៅថា ចិត្តសមាធិ, បើភិក្ខុធ្វើវីមំសាឲ្យជាធំ រមែងបាននូវសមាធិ បាននូវភាវៈនៃចិត្តមានអារម្មណ៍តែមួយ, សមាធិ នេះ ហៅថា វីមំសាសមាធិ [(១)], សមាធិ មាន ៤ យ៉ាង ដោយអំណាចនៃឥទ្ធិបាទដែលជាអធិបតីជាដើម យ៉ាងដូច្នេះឯង ។

(៥៨) សេចក្តីវិនិច្ឆ័យ ក្នុងក្រុមសមាធិ ៥ ដូចតទៅនេះ ។ បណ្ឌិតគប្បីជ្រាបឈានទាំងឡាយ ៥ ព្រោះបែងចែកជាពីរ ដោយវិធីយ៉ាងនេះគឺ: ទុតិយឈានណា ដែលលោកពោលហើយ ក្នុងចតុក្កន័យ ទុតិយ-ឈាននោះ (បែង)ជាទុតិយឈាន ព្រោះកន្លងត្រឹមតែវិតក្កៈ, ជាតតិយ-ឈាន ព្រោះកន្លងទាំងវិតក្កៈ ទាំងវិចារៈ, សមាធិដែលជាអង្គ នៃឈានទាំង ៥ នោះ ទើបជាសមាធិ ៥ យ៉ាងដូច្នេះ, បណ្ឌិត គប្បីជ្រាបភាវៈ

១- អភិ. វិ. ភាគទី ៨១ ទំព័រទី ១៨៧ ។



នៃសមាធិ មាន ៥ ដោយអំណាចអង្គ នៃបញ្ចកឈាន យ៉ាងនេះឯង ។

(៥៩) ក៏ពាក្យឆ្លើយ ក្នុងបញ្ហាកម្មថា "អ្វី ជាសេចក្តីសៅហ្មង និងអ្វីជាសេចក្តីផូរផង់ របស់សមាធិនោះ ?" ដូច្នេះនេះ គឺលោកបានពោលហើយ ក្នុងវិភង្គនុ៎ះឯង ។ មែនពិត ក្នុងវិភង្គនោះ លោកបានពោលហើយថា ធម៌ដែលជាចំណែកនៃសេចក្តីសាបសូន្យ ឈ្មោះថា សេចក្តីសៅហ្មង, ធម៌ដែលជាចំណែកនៃសេចក្តីវិសេស ឈ្មោះថា សេចក្តីផូរផង់ ។ ក្នុងធម៌ទាំង ២ យ៉ាងនោះ បណ្ឌិតគប្បីជ្រាបហានភាគិយធម៌តាមន័យនេះថា "ការធ្វើទុកក្នុងចិត្តដោយសញ្ញា ប្រកបដោយកាមរមែងជាស់តឿននូវបុគ្គលអ្នកបានបឋមឈាន, ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីសាបសូន្យ [(១)] " ។ វិសេសភាគិយធម៌ បណ្ឌិតគប្បីជ្រាបតាមន័យនេះថា "ការធ្វើទុកក្នុងចិត្ត ដោយសញ្ញា មិនប្រកបដោយវិតក្កៈ រមែងជាស់តឿន... ឈ្មោះថា បញ្ញា មានចំណែកនៃសេចក្តីវិសេស" ។

(ការចំរើនសមាធិ)

(៦០) ឯពាក្យឆ្លើយ ក្នុងបញ្ហាកម្មថា "សមាធិនោះ គប្បីចំរើនយ៉ាងដូចម្តេច?" នេះ បណ្ឌិត គប្បីជ្រាប ដូចតទៅ ។ សមាធិ ឯណាដែលសម្បយុត្តហើយដោយអរិយមគ្គ គឺខ្ញុំពោលហើយ មុនដំបូង ក្នុងទុក្កសមាធិ មានជាអាទិ៍ថា "សមាធិនេះ មាន ២ យ៉ាង ដោយអំណាចនៃលោកិយៈ និង លោកុត្តរៈ" ដូច្នេះ, ន័យក្នុងការចំរើន នូវអរិយមគ្គ-សមាធិនោះ លោកសង្គ្រោះ ដោយន័យ នៃការចំរើននូវបញ្ញានុ៎ះឯង ។ ព្រោះថា កាលបើបញ្ញា គឺបុគ្គលចំរើនហើយ, អរិយមគ្គសមាធិនោះក៏ឈ្មោះថា គឺបុគ្គលចំរើនហើយ ដោយពិត ។ ព្រោះហេតុនោះ យើង

១- អភិ. វិ. ភាគទី ៨២ ទំព័រទី ១០៤ ។

*និងមិនពោលសំដៅយកនូវអរិយមគ្គសមាធិនោះ ដោយឡែកៗ អ្វីទៀត ថា "អរិយមគ្គសមាធិនោះ គប្បីចំរើនយ៉ាងនេះៗ"ដូច្នេះឡើយ។ ចំណែក សមាធិដែលជាលោកិយៈនេះឯណា, សមាធិដែលជាលោកិយៈនោះ គឺ ព្រះយោគីគប្បីញុំាងសីលទាំងឡាយ ឲ្យបានបរិសុទ្ធស្អាត ដោយន័យ ដែលបានពោលហើយ ឋិតនៅ ក្នុងសីលដែលបរិសុទ្ធស្អាតហើយ, បណ្ដាបលិពោធទាំង ១០ យ៉ាង បលិពោធណានីមួយ មានដល់ព្រះ យោគាវចរនោះ, កាត់ផ្ដាច់នូវបលិពោធនោះចោលហើយ ចូលទៅរក លោកអ្នកដែលឲ្យនូវកម្មដ្ឋាន ដែលជាកល្យាណមិត្រដ៏ល្អ រៀនយកនូវ កម្មដ្ឋានណាមួយ ក្នុងចំណោមកម្មដ្ឋានទាំង ៤០ ដែលសមគួរ ដល់ ចរិយារបស់ខ្លួន លះបង់នូវវិហារ ដែលមិនសមគួរដល់ការចំរើនសមាធិ ហើយ នៅក្នុងវិហារ ដ៏សមគួរ កាត់ផ្ដាច់នូវសេចក្ដីកង្វល់តូចតាច ឲ្យ អស់ហើយ គប្បីជាអ្នកមិនញុំាងភាវនាវិធីឲ្យសាបសូន្យ ចំរើន(សមាធិ) ចុះ ។ នេះ ជាសេចក្ដីសង្ខេប ក្នុងការចំរើននូវសមាធិនោះ ។ ចំណែក សេចក្ដីពិស្ដារវិញ មានរៀបរាប់ដូចតទៅនេះ ។*

**(បលិពោធ ១០)**

*ពាក្យឯណា ដែលលោកបានពោលទុកហើយ, សេចក្ដីវិនិច្ឆ័យ ក្នុងពាក្យថា "បណ្ដាបលិពោធទាំងឡាយ ១០ យ៉ាង បលិពោធ ឯណា មួយ មានដល់ព្រះយោគាវចរនោះ កាត់ផ្ដាច់នូវបលិពោធនោះ" ដូច្នេះ នេះ បណ្ឌិតគប្បីជ្រាបជាមុន ។*

គ្រឿងកង្វល់ទាំងឡាយនោះ មាន ១០ យ៉ាង គឺ អាវាស,
ត្រកូល, លាភ, គណៈ និង ការងារជាគម្រប់ ៥, ការធ្វើ
ដំណើរ, ញាតិ, អាពាធ, ការសិក្សារៀនសូត្រ និង ឫទ្ធិ ។



*គ្រឿងកង្វល់ទាំង១០ យ៉ាងនេះឯង ឈ្មោះថា* បលិពោធ *។ បណ្ដា បលិពោធទាំង ១០ យ៉ាងនោះ អាវាសនុ៎ះឯង ឈ្មោះថា សេចក្ដីកង្វល់ ដោយអាវាស ។ ន័យក្នុងបលិពោធក្រៅអំពីនេះ មានត្រកូលជាដើម ក៏មានន័យដូចគ្នានេះដែរ ។*

*សេចក្ដីអធិប្បាយ ក្នុងបលិពោធ ១០ នោះ គប្បីជ្រាបដូចតទៅ :*

**(អាវាសបលិពោធ)**

*សូម្បីបន្ទប់មួយ ក៏ហៅថា អាវាស, សូម្បីបរិវេណមួយ ក៏ហៅថា អាវាស, សូម្បីសង្ឃារាមទាំងមូល ក៏ហៅថា អាវាសដែរ ។ អាវាស នេះនោះ មិនមែនជាបលិពោធ ដល់ភិក្ខុគ្រប់ៗ រូបឡើយ ។ ក៏ភិក្ខុណា ដល់នូវការខ្វល់ខ្វាយ ក្នុងកិច្ចការផ្សេងៗ មានការសាងសាងជាដើម ក្នុង អាវាសនោះក្ដី ជាអ្នកមានការសន្សំរបស់របរជាច្រើន ក្នុងអាវាសនោះក្ដី ជាអ្នកមានសេចក្ដីអាល័យ មានចិត្តជាប់ជំពាក់ ក្នុងអាវាសនោះ ដោយ ហេតុការណ៍ណាមួយក្ដី, អាវាសនោះ ទើបជាទីបលិពោធ ដល់ភិក្ខុរូប នោះមែន ។ មិនមែនជាទីបលិពោធ ដល់ភិក្ខុក្រៅអំពីនេះឡើយ ។*

*រឿងនេះ ជានិទស្សនៈ ក្នុងភាវៈនៃអាវាសមិនជាទីបលិពោធនោះ។ មានរឿងដំណាលថា: កុលបុត្រ ២ នាក់ ចេញអំពីអនុរាធបុរី ទៅ ដោយលំដាប់ហើយ បានបួស ក្នុងវត្តថូបារាម ។ បណ្ដាបព្វជិតទាំង ២ នោះ បព្វជិតមួយរូប រៀនមាតិកា ២ បានយ៉ាងស្ទាត់ជំនាញ ជាអ្នកមាន វស្សាគ្រប់ ៥ បវារណាហើយ ទៅកាន់ជនបទ ឈ្មោះបាចីនខណ្ឌរាជី ។ ភិក្ខុមួយរូបទៀត គង់នៅក្នុងថូបារាមនោះឯង ។ ភិក្ខុដែលទៅកាន់ជនបទ ឈ្មោះបាចីនខណ្ឌរាជី នៅក្នុងទីនោះ យ៉ាងយូរ បានជាព្រះថេរៈហើយ គិត ថា "ទីនេះ ជាទីដ៏សមគួរ ដល់ការនៅសម្ងំ, ណ្ហើយចុះ អាត្មាអញ*

នឹងប្រាប់ នូវរឿងនោះ ដល់ភិក្ខុដែលជាមិត្រសំឡាញ់ផង” ដូច្នេះហើយ ក៏ចេញពីទីនោះ ទៅដល់ថូបារាម ដោយលំដាប់ ។ ព្រះថេរៈដែលមានវស្សាស្មើគ្នា ឃើញព្រះថេរៈនោះ កំពុងដើរចូលមកទុំ៎ឯង ទើបទៅរកទទួលដំណើរហើយកាន់យកបាត្រ និង ចីពរហើយបានធ្វើវត្តប្រតិបត្តិ ។ ព្រះថេរៈដែលជាអាគន្តុកៈ បានចូលទៅកាន់ទីសេនាសនៈហើយ គិតថា “សំឡាញ់របស់អាត្មាអញ នឹងយកនូវសប្បិ ឬ ទឹកអំពៅ ឬក៏ ទឹកបានៈមកឲ្យឥឡូវនេះ ព្រោះសំឡាញ់នេះ មកនៅក្នុងនគរនេះ យូរហើយ” ។ ព្រះអាគន្តុកត្ថេរនោះ មិនបានវត្ថុអ្វីឡើយ រហូតដល់យប់ លុះព្រឹកឡើង ទើបគិតថា “ពេលនេះ សំឡាញ់ របស់អញ នឹងបញ្ជូននូវយាគូ និង វត្ថុដែលគួរឆាន់ ដែលពួកឧបដ្ឋាកនាំយកមកប្រគេន” ។ ព្រះអាគន្តុកត្ថេរនោះ មិនបានឃើញនូវយាគូ និង វត្ថុដែលគួរឆាន់ ដែលខ្លួនបានគិតនោះឡើយ ទើបគិតថា “ឈ្មោះថា របស់ដែលគេយកមកប្រគេន មិនមានទេ, កាលបើព្រះថេរៈ ដែលជាសំឡាញ់របស់អញ ចូលទៅ(បិណ្ឌបាត្រ) ប្រហែលជាពួកឧបដ្ឋាក ប្រគេនទេដឹង?” ដូច្នេះហើយ ក៏ចូលទៅទីក្រុង (ដើម្បីបិណ្ឌបាត្រ) ជាមួយព្រះថេរៈនោះ តាំងតែពីព្រលឹម ។ ព្រះថេរៈទាំងពីររូបនោះ ត្រាច់ទៅលើថ្នល់តែមួយ បាននូវយាគូត្រឹមតែមួយវែក ក៏អង្គុយ ហុតលើអាសនសាលា ។ លំដាប់នោះ ភិក្ខុអាគន្តុកៈ គិតថា “យាគូប្រចាំ ឃើញថា មិនមាន, ក្នុងវេលាឆាន់ភត្តនេះឯង មនុស្សទាំងឡាយ នឹងប្រគេនភត្តដ៏ប្រណីត” ដូច្នេះ ។ សូម្បីក្នុងវេលាឆាន់ភត្តនោះ ព្រះអាគន្តុកត្ថេរក្រៅនេះ ឆាន់នូវអាហារដែលត្រាច់ទៅបិណ្ឌបាត្រ បានមកទុំ៎ឯងហើយ ក៏បានសួរថា “បពិត្រលោកដ៏ចម្រើន! តើលោកញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅយ៉ាងនេះ អស់កាលទាំងពួងឬ?” ។ ព្រះថេរៈ



ឆ្លើយថា “ត្រូវហើយ លោកដ៏មានអាយុ” ។ ភិក្ខុអាគន្តុកត្ថេរ ពោលថា “បពិត្រលោកដ៏ចំរើន ជនបទឈ្មោះបាចីនខណ្ឌរាជីជាកន្លែងមានសេចក្ដីសុខ, ពួកយើងនឹងទៅ(នៅ) ក្នុងទីនោះចុះ” ។ ព្រះថេរៈ (ទទួលហើយ) ក៏ចេញពីនគរតាមទ្វារទិសទក្សិណ ដើរទៅកាន់ផ្លូវនៃស្រុកជាងធ្វើឆ្នាំង ។ ព្រះថេរៈក្រៅនេះ ពោលថា “បពិត្រលោកដ៏ចម្រើន ចុះហេតុអ្វី បានជាលោកដើរទៅកាន់ផ្លូវនេះ?” ។ ព្រះថេរៈ ពោលថា “ម្នាលលោកដ៏មានអាយុ លោកបានពណ៌នា នូវជនបទ ឈ្មោះបាចីនខណ្ឌរាជី មិនមែនទេឬ?” ។ ភិក្ខុអាគន្តុកត្ថេរ ពោលថា “បពិត្រលោកដ៏ចំរើន ក្នុងទីដែលលោកគង់នៅ អស់កាលប្រមាណប៉ុណ្ណោះនេះ តើមិនមានអតិរេកបរិក្ខារអ្វីខ្លះទេឬ?” ។ ព្រះថេរៈ ពោលថា “ម្នាលអាវុសោ ត្រូវហើយ, គ្រែ និង តាំង គឺជារបស់សង្ឃ, ខ្ញុំ បានប្រមូល ទុកដាក់វា ត្រឹមត្រូវហើយ, របស់អ្វីៗ ឯទៀតគ្មានទេ”។ ព្រះអាគន្តុកត្ថេរ ពោលថា “បពិត្រលោកដ៏ចម្រើន! តែឈើច្រត់ និង បំពង់ប្រេង, ស្បែកជើង, ស្រោមបាត្ររបស់ខ្ញុំ នៅមានក្នុងទីនោះឯង” ។ ព្រះថេរៈ ពោលថា “ម្នាលអាវុសោ លោកនៅ អស់ពេលមួយថ្ងៃ ទុកដាក់របស់ មានប្រមាណប៉ុណ្ណោះឬ?” ដូច្នេះ ។ ព្រះអាគន្តុកត្ថេរ ពោលថា “បពិត្រលោកដ៏ចំរើន ពិតមែនហើយ” ។ ព្រះអាគន្តុកត្ថេរនោះមានចិត្តជ្រះថ្លា ថ្វាយបង្គំព្រះថេរៈហើយ ទើបពោលថា “បពិត្រលោកដ៏ចំរើន ចំពោះភិក្ខុទាំងឡាយ ដូចជាលោកម្ចាស់ ការរស់នៅក្នុងព្រៃទុំ៎ឯង រមែងប្រព្រឹត្តទៅបាន ក្នុងទីគ្រប់កន្លែង, ថូបារាម ជាទីកន្លែងបញ្ចុះព្រះធាតុព្រះពុទ្ធទាំងឡាយ ៤ ព្រះអង្គ, លោកម្ចាស់ បានស្ដាប់ធម៌ដែលជាទីសប្បាយ ក្នុងលោហប្រាសាទ, បានឃើញមហាចេតិយ និង បានឃើញព្រះថេរៈ រមែងប្រព្រឹត្តទៅ ដូចជា

ពុទ្ធកាល, សូមលោកម្ចាស់ មេត្តាគង់នៅ ក្នុងបូបារាមនេះចុះ” ដូច្នេះ ហើយ ក្នុងថ្ងៃ ទី៣ ក៏បានកាន់បាត្រ និង ចីវរ ទៅតែខ្លួនប៉ុណ្ណោះឯង ។ អាវាស រមែងមិនជាទីបលិពោធ ដល់ភិក្ខុដូចនេះឡើយ ។

(កុលបលិពោធ)

(៦១) ត្រកូលញាតិក្តី ត្រកូលឧបដ្ឋាកក្តី ឈ្មោះថា ត្រកូល ។ មែនពិត សូម្បីត្រកូលនៃឧបដ្ឋាក ក៏រមែងជាបលិពោធ ចំពោះភិក្ខុពួកខ្លះ ដែលនៅប្របូកប្របល់ ដោយន័យថា “បើពួកឧបដ្ឋាក មានសេចក្តីសុខ, អាត្មាអញ ក៏មានសេចក្តីសុខដែរ” ដូច្នេះជាដើម។ ភិក្ខុនោះ ព្រាត់ពីពួកមនុស្សក្នុងត្រកូល សូម្បីទៅកាន់វត្តជិតខាង ដើម្បីស្តាប់ធម៌ក៏មិនបាន ។ សូម្បីមាតាបិតា ក៏មិនជាបលិពោធ ចំពោះភិក្ខុណាមួយឡើយ ដូចជាភិក្ខុកម្លោះដែលត្រូវជាក្មួយ របស់ព្រះតិស្សត្ថេរ ដែលអាស្រ័យនៅ ក្នុងកោរន្ទកវិហារ យ៉ាងនោះឯង ។

បានឮមកថា: ភិក្ខុកម្លោះនោះ បានទៅកាន់រោហណជនបទ ដើម្បីរៀនបាលី ។ ចំណែកឧបាសិកាដែលត្រូវជាប្អូនស្រីរបស់ព្រះថេរៈ បានសួរនូវពត៌មាន របស់ភិក្ខុកម្លោះនោះ នឹងព្រះថេរៈគ្រប់ៗ ពេលវេលា ។ ព្រះថេរៈ គិតថា “អាត្មាអញ នឹងនាំភិក្ខុកម្លោះមក ក្នុងថ្ងៃមួយ” ហើយ ក៏បានដើរ មានមុខឆ្ពោះទៅកាន់រោហណជនបទ ។ ឯភិក្ខុកម្លោះ គិតថា “អាត្មាអញ នៅក្នុងទីនេះ ក៏យូរហើយ ឥឡូវនេះ អាត្មាអញ នឹងទៅជួបព្រះឧបជ្ឈាយ៍ និង ដឹងពត៌មាន របស់ឧបាសិកាហើយ ចាំវិលមកវិញ” ដូច្នេះហើយ ក៏បានចេញពីរោហណជនបទ ។ លោកទាំងពីររូបនោះបាន មកជួបគ្នា នៅត្រង់មាត់ទន្លេ។ ភិក្ខុកម្លោះនោះ បានធ្វើវត្តចំពោះព្រះថេរៈ ក្បែរគល់ឈើមួយដើម ត្រូវព្រះថេរៈ សួរថា “តើលោកទៅទីណា? ”



ដូច្នេះហើយ ក៏បានប្រាប់រឿងរ៉ាវនោះ(ដល់ព្រះថេរៈ) ។ ព្រះថេរៈ ពោលថា “លោកបានធ្វើកម្មល្អហើយ, សូម្បីឧបាសិកា ក៏ដណ្តឹងសួរមិនឈប់ដែរ, ចំណែកខ្ញុំសោត ក៏បានមកហើយ ដើម្បីប្រយោជន៍នេះដែរ, ចូរលោកទៅចុះ, ចំណែកខ្ញុំនឹងនៅចាំវស្សានេះ ក្នុងទីនេះឯង” ដូច្នេះហើយ បញ្ជូនភិក្ខុកម្លោះនោះទៅហើយ ។ ភិក្ខុកម្លោះនោះ បានទៅដល់វត្តនោះ ក្នុងថ្ងៃចូលវស្សានុ៎ះឯង ។ សូម្បីសេនាសនៈ ដែលញោមប្រុស របស់លោក ឲ្យគេកសាងហើយនុ៎ះឯង ក៏បានដល់ភិក្ខុកម្លោះនោះ ។

គ្រានោះ ក្នុងថ្ងៃទី ២ ញោមប្រុសរបស់ភិក្ខុនោះ មកហើយ សួរថា “បពិត្រព្រះគុណម្ចាស់ សេនាសនៈ របស់ញោម តើបានដល់ភិក្ខុអង្គណា?” លុះបានឮថា “បានដល់ភិក្ខុកម្លោះ ដែលជាអាគន្តុកៈ” ដូច្នេះ ក៏ចូលទៅរកភិក្ខុនោះ ថ្វាយបង្គំហើយ ទើបពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន វត្តរមែងមានដល់ភិក្ខុដែលចូលចាំវស្សា ក្នុងទីសេនាសនៈ របស់ខ្ញុំព្រះករុណា” ។ ភិក្ខុកម្លោះនោះ សួរថា “ម្នាលឧបាសក តើវត្តដូចម្តេចទៅ?” ។ ឧបាសកនោះ ទូលថា “វត្តនោះ គឺព្រះគុណម្ចាស់ត្រូវទទួលភិក្ខា តែក្នុងផ្ទះ របស់ញោមប៉ុណ្ណោះ រហូតអស់ ៣ ខែ លុះដល់បវារណាហើយ ក្នុងពេលនិមន្តទៅត្រូវតែលា” ដូច្នេះ ។ ភិក្ខុកម្លោះនោះ ទទួលហើយ ដោយតុណ្ហីភាព ។ ចំណែក ឧបាសក ទៅផ្ទះហើយប្រាប់ថា “ព្រះគុណម្ចាស់អាគន្តុកៈមួយអង្គ បានចូលចាំវស្សា ក្នុងអាវាសរបស់យើង, យើងត្រូវឧបដ្ឋាកដោយគោរព” ដូច្នេះ ។ ឧបាសិកា ទទួលថា “សាធុ” ហើយក៏បានចាត់ចែងខាទនីយៈ ភោជនីយៈ ដ៏ប្រណីតៗ ។ ចំណែកភិក្ខុកម្លោះ ក្នុងវេលាឆាន់ភត្ត ក៏បានទៅកាន់ផ្ទះនៃញាតិ ។ មិនមានអ្នកណាម្នាក់ ចាំ (ស្គាល់) ភិក្ខុកម្លោះនោះបានឡើយ ។ ភិក្ខុនោះ

ឆាន់នូវបិណ្ឌបាត ក្នុងផ្ទះនោះ ចាំវស្សា រហូត ៣ ខែហើយ ក៏លាថា “អាត្មាភាព នឹង (ចំរើនពរលា) ទៅ” ។

គ្រានោះ ពួកញាតិ របស់ភិក្ខុនោះ សូមអង្វរ ថា “បពិត្រព្រះគុណម្ចាស់ ដល់ថ្ងៃស្អែក ចាំនិមន្តទៅចុះ” លុះដល់ថ្ងៃទី ២ ក៏បានអង្គាសភិក្ខុនោះ ក្នុងផ្ទះនុ៎ះឯង ចាក់ប្រេងពេញបំពង់ហើយ ប្រគេននូវស្ករអំពៅមួយដុំ និង សំពត់សាដក ៩ ហត្ថ ទូលថា “បពិត្រព្រះគុណម្ចាស់ ដ៏ចំរើន សូមព្រះគុណម្ចាស់ និមន្តទៅចុះ” ។ ភិក្ខុនោះ ធ្វើអនុមោទនាស្រេចហើយ ក៏ដើរមានមុខឆ្ពោះទៅកាន់រោហណជនបទ ។

ឯឧបជ្ឈាយ៍ របស់ភិក្ខុនោះ បវារណាហើយមកកាន់ផ្លូវជួបគ្នា បានជួបភិក្ខុនោះ ក្នុងទីដែលធ្លាប់ជួបគ្នា ក្នុងកាលមុននុ៎ះឯង ។ ភិក្ខុនោះ ថ្វាយបង្គំ នូវព្រះថេរៈហើយ ក៏បានធ្វើវត្តចំពោះព្រះថេរៈ នៅក្បែរគល់ឈើមួយដើម ។ គ្រានោះ ព្រះថេរៈ សួរភិក្ខុនោះ ថា “នែលោកដ៏មានមុខល្អ តើលោកបានជួបឧបាសក និង ឧបាសិកា របស់លោកហើយឬនៅ?” ។ លោកទូលថា “បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណា បានជួបហើយ” ដូច្នេះ ក៏បានទូលរឿងរ៉ាវទាំងអស់ឲ្យព្រះថេរៈជ្រាបហើយ យកប្រេងនោះ លាបជើងព្រះថេរៈ យកស្ករអំពៅ ធ្វើជាទឹកបានៈ ប្រគេនសំពត់សាដកនោះឯងដល់ព្រះថេរៈភ្លាម ថ្វាយបង្គំព្រះថេរៈហើយ ក៏ទូលថា “បពិត្រព្រះអង្គដ៏ចំរើន រោហណជនបទប៉ុណ្ណោះ ជាទីសប្បាយ ដល់ខ្ញុំព្រះករុណា” ដូច្នេះ និមន្តទៅហើយ ។ ឯព្រះថេរៈ ក៏មកកាន់វត្តវិញហើយ ក្នុងថ្ងៃទី ២ ក៏បានចូលទៅកាន់ស្រុកកោរន្ទកគ្រាម ។

ចំណែកឧបាសិកា សង្ឃឹមថា “លោកបង របស់អាត្មាអញ នឹងនាំលោកកូន របស់ខ្លួនមក ក្នុងពេលឥឡូវនេះ” ហើយ ឈរវង់ចាំមើល



ផ្លូវគ្រប់ៗ ពេល ។ ឧបាសិកានោះ ឃើញព្រះថេរៈនិមន្តមកតែមួយអង្គឯងគត់ ក៏គិតស្មានថា “ប្រហែលជាលោកកូន របស់អញស្លាប់បាត់ទៅហើយ បានជាព្រះថេរៈនេះ និមន្តមកតែមួយអង្គប៉ុណ្ណោះ” ។ ឧបាសិកានោះ ស្រែកយំខ្សឹកខ្សួល បម្រះនរទៀល នៅក្បែរបាទមូល របស់ព្រះថេរៈ ។ ព្រះថេរៈ នឹកគិតថា “ភិក្ខុកម្លោះ មិនឲ្យអ្នកណាស្គាល់ខ្លួនទេព្រោះភាវៈជាអ្នកមានសេចក្តីប្រាថ្នាតិច បានទៅហើយ មិនមែនទេឬ?” ដូច្នេះហើយ ក៏ធ្វើឲ្យឧបាសិកានោះសប្បាយចិត្ត ប្រាប់រឿងរ៉ាវទាំងអស់ឲ្យដឹង បាននាំយកនូវសំពត់សាដកនោះ ចេញមកអំពីស្រោមបាត្រ មកបង្ហាញហើយ ។ ឧបាសិកា ជ្រះថ្លាហើយ បែរមុខឆ្ពោះទៅទិស ដែលលោកកូនទៅ ឱនដើមទ្រូង ក្រាបទមស្ការហើយ ពោលថា “ព្រះមានព្រះភាគ ដូចជាទ្រង់ធ្វើ នូវភិក្ខុដែលដូចជាលោកកូន របស់អញ ឲ្យជាកាយសក្ខី (ជាសាក្សី) ហើយតើហ្ន៎! ទ្រង់សំដែង នូវរថវិនីតប្បដិបទា, នាលកប្បដិបទា, តុវដ្តកប្បដិបទា និង មហាអរិយវំសប្បដិបទា ដែលសំដែងនូវភាពជាអ្នកសន្តោស ក្នុងបច្ច័យ ៤ និង ភាពជាអ្នកត្រេកអរក្នុងភាវនា, គួរឲ្យសរសើរមែន! ភិក្ខុរូបនេះ សូម្បីឆាន់នៅក្នុងផ្ទះ របស់ម្តាយបង្កើត អស់រយៈពេល ៣ ខែ ក៏មិនប្រាប់ថាៈ អាត្មា ជាកូនរបស់ញោម, ញោមជាមាតា របស់អាត្មាឡើយ, ឱហ្ន៎! មនុស្ស ដ៏អស្ចារ្យមែន” ដូច្នេះ ។ ចំពោះភិក្ខុដែលមានសភាពបែបនេះ សូម្បីមាតា និង បិតា ក៏មិនជាបលិពោធឡើយ, មិនចាំបាច់ពោលធ្វើអ្វី ដល់ទៅត្រកូលឧបដ្ឋាកដទៃ ដោយប្រការដូច្នេះឯង ។

(លាភបលិពោធ)

(៦២) បច្ច័យទាំងឡាយ ៤ ឈ្មោះថា លាភ ។ សួរថា : បច្ច័យ

ទាំង ៤ នោះ ជាបលិពោធ ដូចម្តេចទៅ? ។ ឆ្លើយថាៈ ក៏ក្នុងទីកន្លែងដែលភិក្ខុអ្នកមានបុណ្យទៅហើយៗ ពួកមនុស្ស តែងប្រគេនបច្ច័យទាំងឡាយដែលមានគ្រឿងបរិវារដ៏ច្រើន ។ ភិក្ខុនោះ រវល់តែធ្វើអនុមោទនា រវល់តែសំដែងធម៌ ដល់ពួកមនុស្សទាំងនោះ មិនបានឱកាសនឹងធ្វើនូវសមណធម៌ឡើយ ។ ចាប់តាំងពីអរុណរះឡើង រហូតដល់បឋមយាម ភិក្ខុនោះ ប្រឡូកប្រឡល់តែជាមួយនឹងមនុស្ស មិនដែលបានដាច់ឡើយ ។ ក្នុងវេលាទៀបភ្លឺទៀតសោត ពួកភិក្ខុ អ្នកមានកិរិយាប្រព្រឹត្តិបិណ្ឌបាត្រជាវត្ត ដែលជាអ្នកចង់បានបច្ច័យច្រើន ក៏មកទូលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ឧបាសក, ឧបាសិកា, អាមាត្យ, បុត្ររបស់អាមាត្យ, ធីតារបស់អាមាត្យ ឈ្មោះនោះៗ ប្រាថ្នាចង់ឃើញលោកម្ចាស់” ។ ភិក្ខុនោះពោលថា “ម្នាលអាវុសោ ចូរអ្នកជួយយកបាត្រ និង ចីវរផង” ជាអ្នករៀបចំបំរុងនឹងទៅតែម្តង ជាអ្នកខ្វល់ខ្វាយជានិច្ច ។ បច្ច័យទាំងឡាយនោះ រមែងជាបលិពោធ ដល់ភិក្ខុនុ៎ះឯង ។ ភិក្ខុនោះ ត្រូវតែលះបោលនូវគណៈហើយ ត្រាច់ទៅតែម្នាក់ឯង ក្នុងទីកន្លែងដែលពួកមនុស្សគេមិនស្គាល់ខ្លួន ។ ធ្វើយ៉ាងនេះ ទើបភិក្ខុនោះ កាត់បលិពោធនោះបាន ។

(គណបលិពោធ)

(៦៣) ពួកភិក្ខុដែលរៀនព្រះសូត្រក្តី ពួកភិក្ខុដែលរៀនព្រះអភិធម្មក្តី ឈ្មោះថា គណៈ ។ ភិក្ខុឯណា រវល់ឲ្យឧទ្ទេសខ្លះ បរិបុច្ឆាខ្លះ ដល់គណៈនោះ រមែងមិនបានឱកាស ដើម្បីនឹងធ្វើសមណធម៌ឡើយ, គណៈរមែងជាបលិពោធដល់ភិក្ខុនោះ ។ បលិពោធនោះ ភិក្ខុនោះត្រូវកាត់ផ្តាច់ដូចតទៅនេះ ។ បើការងារ របស់ភិក្ខុទាំងនោះ ជាការងារ(ធ្វើ) រួចហើយជាច្រើន, ការងារបន្តិចបន្តួចមាននៅសល់, ភិក្ខុនោះ ត្រូវធ្វើការងារនោះ



ឲ្យរួចស្រេចហើយ ចាំចូលទៅព្រៃ ។ បើសិនការងារធ្វើរួចតែបន្តិច នៅសល់ការងារ យ៉ាងច្រើន, ភិក្ខុនោះ កុំទៅឲ្យហួសពីមួយយោជន៍ ត្រូវចូលទៅរកគណវាចកដទៃ ក្នុងទីខាងក្នុង នៃកំណត់ ១ យោជន៍ ហើយពោលថា “សូមលោកដ៏មានអាយុ ជួយសង្គ្រោះភិក្ខុទាំងនេះ ដោយសង្គហវិធី មានឧទ្ទេសជាដើមផង” ។ កាលបើមិនបាន ដូចពោលមកនេះទេ គប្បីពោលថា “ម្នាលអាវុសោទាំងឡាយ! កិច្ចការម្យ៉ាង របស់ខ្ញុំមាន, អ្នកទាំងឡាយ ចូរទៅកាន់ទីកន្លែង តាមសប្បាយចុះ” ដូច្នេះ គប្បីលះបង់គណៈហើយ ធ្វើការងាររបស់ខ្លួន ។

(កម្មបលិពោធ)

(៦៤) នវកម្ម ឈ្មោះថា ការងារ ។ ភិក្ខុអ្នកធ្វើ នូវនវកម្មនោះត្រូវដឹងឧបករណ៍ ដែលអ្នកធ្វើការ មានជាងឈើជាដើម បានហើយ ឬមិនទាន់បានហើយ, ត្រូវខ្វល់ខ្វាយ ចំពោះការងារ ដែលជាងធ្វើរួចហើយនិង មិនទាន់ធ្វើរួចហើយ, ភិក្ខុអ្នកធ្វើនវកម្ម តែងមានបលិពោធសព្វបែបយ៉ាងដូច្នេះឯង ។ សូម្បីបលិពោធនោះ ភិក្ខុ គប្បីកាត់ ដូចតទៅនេះ ។ បើការងារមានសល់តិច ត្រូវធ្វើឲ្យរួចស្រេចឲ្យហើយ ។ បើសិនជាការងារនៅសល់ច្រើន, បើជានវកម្ម របស់សង្ឃ ត្រូវតែប្រគល់ឲ្យទៅ ដល់សង្ឃ ឬក៏ ដល់ពួកភិក្ខុអ្នកទទួលនូវភារៈ, បើជានវកម្ម របស់ផ្ទាល់ខ្លួនគប្បីប្រគល់ឲ្យ ដល់ពួកបុគ្គលអ្នកទទួលភារៈ របស់ខ្លួន ។ បើមិនបានពួកភិក្ខុអ្នកទទួលភារៈ យ៉ាងដូច្នោះទេ គប្បីលះបង់ ឲ្យដល់សង្ឃហើយទើបទៅចុះ ។

(អទ្ធានបលិពោធ)

(៦៥) ការធ្វើដំណើរ ឈ្មោះថា អទ្ធានៈ ។ ក៏បព្វជ្ជាបេក្ខៈ របស់

ភិក្ខុណា មានក្នុងទីណា ឬក៏ បច្ច័យណាមួយ ដែលភិក្ខុណា គប្បីបានក្នុងទីណា ។ បើភិក្ខុនោះ មិនបាននូវបព្វជ្ជាបេក្ខៈ និង បច្ច័យនោះទេ ក៏មិនអាចអត់ទ្រាំបានឡើយ ។ ធម្មតាចិត្ត គិតនឹងទៅ សូម្បីរបស់ភិក្ខុអ្នកចូលទៅកាន់ព្រៃហើយ ធ្វើសមណធម៌ ក៏ជាធម្មជាតដែលបុគ្គលគប្បីបន្ទោបង់បាន ដោយលំបាក ។ ព្រោះហេតុនោះ ភិក្ខុនោះ គប្បីពិចារណាកិច្ចការនោះ ឲ្យបានស្រេចហើយ ចាំធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងសមណធម៌ចុះ ។

(ញាតិបលិពោធ)

(៦៦) ពួកជនដែលត្រូវស្គាល់គ្នា មានជាអាទិ៍ យ៉ាងនេះ គឺ ក្នុងវត្ត អាចារ្យ, ព្រះឧបជ្ឈាយ៍, សទ្ធិវិហារិក, អន្តេវាសិក, ភិក្ខុអ្នករួមព្រះឧបជ្ឈាយ៍, ភិក្ខុអ្នករួមអាចារ្យ, ក្នុងផ្ទះ មាតា, បិតា, បងប្អូនស្រី, បងប្អូនប្រុស ឈ្មោះថា ញាតិ ។ បុគ្គលទាំងឡាយ មានអាចារ្យ ជាដើមនោះ កើតមានជម្ងឺ ទើបជាបលិពោធ ដល់ភិក្ខុនេះ ។ ព្រោះហេតុនោះ បលិពោធនោះ ភិក្ខុនោះ គប្បីកាត់ផ្ដាច់ ដោយការឧបដ្ឋាកហើយ ធ្វើបុគ្គលទាំងនោះ (ឲ្យជាសះស្បើយ) ជាប្រក្រតីឡើងវិញ ។

បណ្ដាបុគ្គលទាំងនោះ ដំបូង ព្រះឧបជ្ឈាយ៍ មានអាពាធ, បើព្រះឧបជ្ឈាយ៍ មិនជាសះស្បើយឆាប់ទេ, ភិក្ខុ គប្បីថែទាំលោក រហូតអស់មួយជីវិត ។ ព្រះបព្វជ្ជាចារ្យ, ព្រះឧបសម្បទាចារ្យ, សទ្ធិវិហារិក, អន្តេវាសិក ដែលខ្លួនបានឧបសម្បទ និង បានបំបួសឲ្យ និង ភិក្ខុអ្នករួមព្រះឧបជ្ឈាយ៍ជាមួយគ្នា ក៏គប្បីទំនុកបំរុង យ៉ាងនោះដែរ ។ ចំណែកព្រះនិស្សយាចារ្យ, ព្រះឧទ្ទេសាចារ្យ, និស្សយន្តេវាសិក, ឧទ្ទេសន្តេវាសិក និង ភិក្ខុអ្នករួមអាចារ្យផងគ្នា គប្បីទំនុកបំរុង ដរាបដល់និស្ស័យ



និង ឧទ្ទេស មិនទាន់ដាច់ ។ បើអាច ក៏គួរទំនុកបំរុង ឲ្យបានលើសនោះថែមទៀត ដោយពិត ។

ចំពោះមាតាបិតា គប្បីទំនុកបំរុង ឲ្យដូចជាព្រះឧបជ្ឈាយ៍ចុះ ។ មែនពិត បើជាមាតាបិតាទាំងនោះ ជាអ្នកឋិតនៅ ក្នុងរាជសម្បត្តិ, ហើយគាត់ប្រាថ្នានូវការទំនុកបំរុងអំពីបុត្រ, ភិក្ខុ គប្បីធ្វើឲ្យបាន ។ មួយទៀត មាតាបិតាទាំងនោះ មិនមានថ្នាំរក្សារោគ, ភិក្ខុ គប្បីឲ្យថ្នាំដែលជារបស់ខ្លួន, បើថ្នាំរបស់ខ្លួន មិនមានទេ, ភិក្ខុគប្បីទៅស្វែងរកមកដោយភិក្ខាចារ ហើយឲ្យ (ដល់មាតាបិតា) ទាល់តែបាន ។

តែចំពោះបងប្អូនប្រុស-ស្រីទាំងឡាយវិញ ភិក្ខុ គប្បីផ្សំថ្នាំ ដែលជារបស់ពួកគេទាំងនោះឯង ហើយឲ្យ (ដល់ពួកគេ) ។ បើថ្នាំដែលជារបស់ពួកគេទាំងនោះ មិនមានទេ, ភិក្ខុ គប្បីឲ្យថ្នាំដែលជារបស់ខ្លួន ជារបស់ឲ្យខ្ចី, ក្រោយមក បើបាន គប្បីទទួលយក បើមិនបានទេ មិនត្រូវទារឡើយ ។ ភិក្ខុ មិនគួរធ្វើថ្នាំ មិនគួរឲ្យថ្នាំដល់ស្វាមីរបស់បងប្អូនស្រី ដែលមិនមែនជាញាតិឡើយ ។ តែភិក្ខុ គប្បីឲ្យ ដល់បងប្អូនស្រី ប្រាប់ថា "ចូរអ្នកឲ្យ ដល់ស្វាមីរបស់អ្នកចុះ" ។ សូម្បីក្នុងកិរិយា របស់បងប្អូនប្រុស ក៏មានន័យដូចគ្នានេះដែរ ។ ចំណែកឯបុត្រទាំងឡាយ របស់ជនទាំងនោះ ក៏ជាញាតិ របស់ភិក្ខុនេះ ដោយពិត ព្រោះហេតុនោះ ភិក្ខុផ្សំថ្នាំ ឲ្យដល់បុត្រទាំងឡាយ របស់ជនទាំងនោះ ក៏គួរ ។

(អាពាធបលិពោធ)

(៦៧) រោគឯណាមួយ ឈ្មោះថា **អាពាធ** ។ រោគនោះ កាលបៀតបៀន ទើបឈ្មោះថា ជាបលិពោធ ។ ព្រោះហេតុនោះ ភិក្ខុ គប្បីកាត់ ដោយការធ្វើថ្នាំ ។ តែសូម្បីកាលបើភិក្ខុ ធ្វើថ្នាំរក្សា ពីរ បី ថ្ងៃ,

រោគ ក៏នៅតែមិនជាស្បើយ, ភិក្ខុ គប្បីតិះដៀលនូវអត្តភាព ថា "ខ្ញុំមិនមែនជាខ្ញុំបម្រើ មិនមែនជាកូនឈ្នួល របស់អ្នកឡើយ, ក៏ខ្ញុំ ចិញ្ចឹមអ្នកនេះឯង ទើបបានទទួលសេចក្តីទុក្ខ ក្នុងសំសារវដ្ដ ដែលបុគ្គលមិនដឹងទីបំផុត" ដូច្នេះហើយ គប្បីធ្វើសមណធម៌ ។

(គន្ថបលិពោធ)

(៦៨) ការថែរក្សានូវព្រះបរិយត្តិ ឈ្មោះថា គន្ថៈ ។ ការរក្សាគ្រប់គ្រងនូវព្រះបរិយត្តិនោះ រមែងជាបលិពោធ ដល់ភិក្ខុអ្នកខ្វល់ខ្វាយជាប់ជានិច្ច ដោយការស្វាធ្យាយជាដើម ។ មិនជាបលិពោធ ដល់ភិក្ខុក្រៅអំពីនេះឡើយ ។ ក្នុងការៈនៃគន្ថៈ មិនជាទីបលិពោធ ដល់ភិក្ខុអ្នកមិនខ្វល់ខ្វាយនោះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ។

មានរឿងដំណាលថា ព្រះទេវត្ថេរ អ្នកសូត្រគម្ពីរមជ្ឈិមនិកាយ ទៅកាន់សំណាក់ របស់ព្រះទេវត្ថេរ ដែលអាស្រ័យនៅមលយជនបទ ហើយសុំរៀនកម្មដ្ឋាន ។ ព្រះថេរៈសួរថា "ម្នាលអាវុសោ តើអ្នកដល់ថ្នាក់ណាហើយ ក្នុងព្រះបរិយត្តិ?" ។ ព្រះមជ្ឈិមភាណកៈ ឆ្លើយថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! ខ្ញុំចេះចាំមជ្ឈិមនិកាយ ស្ទាត់ជំនាញ" ។ ព្រះថេរៈពោលថា "ម្នាលអាវុសោ ធម្មតាមជ្ឈិមនិកាយនោះ បុគ្គលរក្សាបានដោយលំបាក, កាលបើបុគ្គលស្វាធ្យាយ នូវមូលបណ្ណាសកៈ, មជ្ឈិមបណ្ណាសកៈ នឹងមក, កាលបើស្វាធ្យាយមជ្ឈិមបណ្ណាសកៈនោះ ឧបរិបណ្ណាសកៈ ក៏នឹងមក, កម្មដ្ឋាន របស់អ្នកនឹងមានមកពីណា?" ។ ព្រះមជ្ឈិមភាណកៈ ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា បានកម្មដ្ឋាន ក្នុងសំណាក់ របស់ព្រះគុណម្ចាស់ហើយ នឹងមិនក្រឡេកមើលទៀតឡើយ" ដូច្នេះហើយ ក៏រៀននូវកម្មដ្ឋាន មិនធ្វើនូវ



ការស្វាធ្យាយ រហូតដល់ទៅ ១៩ ឆ្នាំ ក្នុងឆ្នាំទី ២០ ក៏បានសម្រេចព្រះអរហត្ត ហើយពោលប្រាប់ ដល់ពួកភិក្ខុដែលមក ដើម្បីស្វាធ្យាយ ថា "ម្នាលអាវុសោ កាលបើខ្ញុំមិនក្រឡេកមើលព្រះបរិយត្តិ រហូតដល់ទៅ ២០ ឆ្នាំ តែខ្ញុំបានធ្វើការសន្សំ ក្នុងព្រះបរិយត្តិនោះហើយ, អ្នកទាំងឡាយ ចូរចាប់ផ្តើមចុះ" ដូច្នេះ លោកមិនដែលមានសេចក្តីងឿងឆ្ងល់សង្ស័យសូម្បីក្នុងព្យញ្ជនៈមួយឡើយ តាំងតែអំពីដើម រហូតដល់ចប់ ។

សូម្បីព្រះនាគត្ថេរ ដែលនៅអាស្រ័យ ក្នុងករុន្ទិយគិរី លះបង់នូវព្រះបរិយត្តិ រហូតដល់ទៅ ១៨ ឆ្នាំហើយ បានសំដែងនូវធាតុកថា ដល់ភិក្ខុទាំងឡាយ ។ កាលភិក្ខុទាំងឡាយនោះ ផ្ទៀងផ្ទាត់ជាមួយនឹងព្រះគាមវាសិកត្ថេរទាំងឡាយ សូម្បីតែបញ្ហាមួយដែលមកហើយ ខុសលំដាប់ ក៏មិនមានសោះឡើយ ។

សូម្បីក្នុងមហាវិហារ ព្រះថេរៈ ឈ្មោះចូឡាភ័យ ដែលចេះចាំនូវព្រះត្រៃបិដក មិនបានរៀនអដ្ឋកថាឡើយ ហើយបានឲ្យបុគ្គលវាយស្គរសុវណ្ណភេរី ប្រកាសថា "ខ្ញុំនឹងបកប្រែនូវព្រះត្រៃបិដក ក្នុងវង្វង់នៃបញ្ចនិកាយ" ដូច្នេះ ។ ភិក្ខុសង្ឃ ពោលថា "បានសិក្សាអំពីអាចារ្យណាមក ព្រះចូឡាភយត្ថេរ ចូរប្រាប់តែការសិក្សាអំពីអាចារ្យ របស់ខ្លួនចុះ, ពួកយើងនឹងមិនឲ្យពោលក្រៅពីនេះឡើយ" ។ សូម្បីព្រះឧបជ្ឈាយ៍ក៏បានសាកសួរព្រះចូឡាភយត្ថេរនោះ ដែលមកឧបដ្ឋាកខ្លួន ថា "ម្នាលអាវុសោ តើអ្នកឲ្យគេវាយស្គរប្រកាសមែនឬ?" ។ ព្រះចូឡាភយត្ថេរទូលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន មែនហើយ" ។ ព្រះឧបជ្ឈាយ៍សួរទៀតថា "ព្រោះហេតុអ្វី?" ។ ព្រះថេរៈ ទូលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណានឹងប្រែព្រះបរិយត្តិ" ។ ព្រះឧបជ្ឈាយ៍ សួរថា

“ម្នាលអភ័យដ៏មានអាយុ អាចារ្យទាំងឡាយ ពោលនូវបទនេះថា ដូចម្តេច?” ។ ព្រះថេរៈ ឆ្លើយតបថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ពោលយ៉ាងដូច្នេះ” ។ ព្រះឧបជ្ឈាយ៍ ក្លែងពោលបដិសេធ ដោយសំឡេងថា “ហឺៗ” ។ ព្រះចូឡាភយត្ថេរនោះ បានឆ្លើយតប ដោយបរិយាយផ្សេងៗទៀតថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ពោលយ៉ាងដូច្នេះៗ” អស់វារៈបីដង ។ ព្រះថេរៈ ក៏បានពោលបដិសេធ ដោយសំឡេងថា “ហឺៗទាំងអស់” ហើយពោលថា “នែលោកមានអាយុ ផ្លូវដែលអ្នកពោលហើយជាបឋមនុ៎ះឯង ជាអាចរិយមគ្គ តែព្រោះអ្នក មិនបានរៀនផ្ទាល់មាត់អំពីអាចារ្យ ទើបមិនអាចដើម្បីនឹងបញ្ជាក់ថា: អាចារ្យទាំងឡាយ ពោលយ៉ាងនេះ, ចូរអ្នកទៅចុះ, ចូរអ្នកស្តាប់ ក្នុងសំណាក់នៃអាចារ្យ របស់ខ្លួនចុះ” ។ ព្រះចូឡាភយត្ថេរ សួរថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំនឹងទៅក្នុងទីណា?” ។ ព្រះឧបជ្ឈាយ៍ ប្រាប់ថា “ព្រះថេរៈឈ្មោះមហាធម្មរក្ខិតៈ ជាអ្នកឆ្លាត ក្នុងព្រះបរិយត្តិគ្រប់យ៉ាង អាស្រ័យនៅ ក្នុងវិហារឈ្មោះ តុលាធារបព៌ត ក្នុងរោហណជនបទ ខាងមាត់ច្រាំង នៃទន្លេគង្គាឯណោះ, ចូរអ្នកទៅកាន់សំណាក់ នៃព្រះមហាធម្មរក្ខិតៈនោះចុះ” ។

ព្រះចូឡាភយត្ថេរ ទទួលព្រមថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ប្រពៃហើយ” ថ្វាយបង្គំព្រះថេរៈហើយ ក៏បានទៅកាន់សំណាក់ នៃព្រះថេរៈ ព្រមជាមួយភិក្ខុ ៥០០ រូប ថ្វាយបង្គំហើយ ទើបអង្គុយ ។ ព្រះថេរៈ សួរថា “តើអ្នកមកព្រោះហេតុអ្វី?” ។ ព្រះចូឡាភយត្ថេរ ឆ្លើយថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំមកដើម្បីស្តាប់ធម៌”។ ព្រះថេរៈ ពោលថា “ម្នាលអភ័យដ៏មានអាយុ ភិក្ខុទាំងឡាយ មកសួរខ្ញុំ ក្នុងទីឃនិកាយនិង មជ្ឈិមនិកាយ មួយដងមួយកាល ឯព្រះសូត្រ ដ៏សេស ខ្ញុំមិនដែល



បានមើលមក ៣០ ឆ្នាំហើយ, ណ្ហើយចុះ ក្នុងវេលាយប់ ចូរអ្នកបកប្រែ ក្នុងសំណាក់ខ្ញុំ ក្នុងពេលថ្ងៃ ខ្ញុំ នឹងសំដែងប្រាប់ដល់អ្នក” ។ ព្រះចូឡាភយត្ថេរនោះ ទទួលថា “សាធុ ភន្តេ” ដូច្នេះហើយ បានធ្វើយ៉ាងដូច្នោះឯង ។ ពួកអ្នកស្រុក ឲ្យបុគ្គលធ្វើមហាមណ្ឌបត្រង់មាត់ទ្វារ នៃបរិវេណ ហើយមកស្តាប់ធម៌រៀងរាល់ថ្ងៃ ។ ព្រះថេរៈ យកព្រះសូត្រដែលព្រះចូឡាភយត្ថេរបកប្រែ ក្នុងពេលយប់ មកសំដែង ក្នុងពេលថ្ងៃ ញុំាងព្រះសូត្រឲ្យចប់ ដោយលំដាប់ហើយ ទើបអង្គុយលើកន្ទេល ក្បែរសំណាក់នៃព្រះអភយត្ថេរហើយ ពោលថា “ម្នាលអ្នកដ៏មានអាយុ ចូរអ្នកបង្រៀននូវកម្មដ្ឋានដល់ខ្ញុំ” ។ ព្រះចូឡាភយត្ថេរ ពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន តើព្រះគុណម្ចាស់ពោលនូវអ្វីទៅ? (បើ) កម្មដ្ឋាននោះ ខ្ញុំបានស្តាប់ហើយ ក្នុងសំណាក់ព្រះគុណម្ចាស់នុ៎ះឯង មិនមែនទេឬ?, ខ្ញុំនឹងប្រាប់កម្មដ្ឋានអ្វីទៅ ដែលព្រះគុណម្ចាស់មិនទាន់ចេះនោះ?” ។ លំដាប់នោះ ព្រះថេរៈ ពោលនឹងព្រះចូឡាភយត្ថេរ ថា “ម្នាលអាវុសោ ឈ្មោះថា ផ្លូវម្យ៉ាង របស់បុគ្គលអ្នកទៅដល់ហើយនុ៎ះឯង” ។ បានដឹងមកថា ក្នុងពេលនោះ ព្រះអភយត្ថេរ ជាព្រះសោតាបន្ន ។

គ្រានោះ ព្រះចូឡាភយត្ថេរ ឲ្យនូវកម្មដ្ឋាន ដល់ព្រះថេរៈនោះហើយ ទើបមកបកប្រែធម៌ ក្នុងលោហប្រាសាទ បានស្តាប់ដំណឹង ថា “ព្រះថេរៈបរិនិព្វានហើយ” ដូច្នេះ លុះបានឮហើយ ក៏ពោលថា “ម្នាលអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយ នាំយកចីវរមក” ដូច្នេះ គ្រងចីវរហើយពោលសរសើរព្រះថេរៈថា “ម្នាលអាវុសោទាំងឡាយ អរហត្តមគ្គសមគួរហើយ ដល់អាចារ្យរបស់ពួកយើង, ម្នាលអាវុសោទាំងឡាយ! អាចារ្យរបស់យើង ជាមនុស្សត្រង់ ជាអាជានីយបុគ្គល អាចារ្យរបស់

យើងនោះ សុខចិត្តអង្គុយលើកន្ទេល ក្បែរសំណាក់ នៃធម្មន្តេវាសិក របស់ខ្លួន ហើយពោលថា "ចូរអ្នកប្រាប់នូវកម្មដ្ឋាន ដល់ខ្ញុំផង" ដូច្នេះ, ម្នាលអាវុសោទាំងឡាយ អរហត្តមគ្គ សមគួរហើយដល់ព្រះថេរៈ" ។

គន្ថៈ មិនជាទីបលិពោធ ដល់ភិក្ខុទាំងឡាយបែបនេះឯង ។

(ឥទ្ធិបលិពោធ)

(៦៩) ឫទ្ធិ ដែលជារបស់បុថុជ្ជន ឈ្មោះថា ឫទ្ធិ ។ ក៏ឫទ្ធិ ដែលជារបស់បុថុជ្ជននោះ ជារបស់ដែលរក្សាបានដោយលំបាក ដូចជាទារកដែលនៅដេកផ្ងារ និង ដូចជាស្រូវដ៏ខ្ចី រមែងបែកធ្លាយ ដោយហេតុមានត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ។ ក៏ឫទ្ធិនោះ រមែងជាបលិពោធ ដល់វិបស្សនា មិនជាបលិពោធ ដល់សមាធិទេ ព្រោះឫទ្ធិនោះ បុគ្គលបានសមាធិហើយ ទើបសម្រេច ។ ព្រោះហេតុនោះឯង ឥទ្ធិបលិពោធ ព្រះយោគាវចរ អ្នកប្រាថ្នាវិបស្សនា គប្បីកាត់ផ្តាច់, បលិពោធក្រៅអំពីនេះ ព្រះយោគាវចរ អ្នកប្រាថ្នាសមថៈ គប្បីកាត់ផ្តាច់ ។

សេចក្តីពិស្តារ ក្នុងបលិពោធកថានេះ បណ្ឌិត គប្បីជ្រាបជាមុន ។

(៧០) ចំណែកក្នុងពាក្យថា "ចូរទៅរកព្រះយោគី អ្នកឲ្យនូវកម្មដ្ឋានដែលជាកល្យាណមិត្រ" ដូច្នេះនេះ មានវិនិច្ឆ័យ ដូចតទៅ :

(កម្មដ្ឋាន ២ យ៉ាង)

កម្មដ្ឋាន មាន ២ យ៉ាង គឺ : សព្វត្ថកកម្មដ្ឋាន ១ បារិហារិយ-កម្មដ្ឋាន ១ ។ ក្នុងកម្មដ្ឋានទាំង ២ យ៉ាងនោះ (កម្មដ្ឋានគឺ) មេត្តា ក្នុងបុគ្គលទាំងឡាយ មានពួកភិក្ខុជាដើម ក្តី (កម្មដ្ឋានគឺ) មរណស្សតិ ក្តី ឈ្មោះថា សព្វត្ថកកម្មដ្ឋាន ។ អាចារ្យពួកខ្លះ ពោលថា "អសុភសញ្ញា ឈ្មោះថា សព្វត្ថកកម្មដ្ឋាន" ដូច្នេះក៏មាន ។ មែនពិត មេត្តា ជាបឋម



គឺភិក្ខុអ្នកបំពេញកម្មដ្ឋាន គប្បីកំណត់ពួកភិក្ខុនោះជាមុនហើយសឹមចំរើនក្នុងពួកភិក្ខុដែលនៅ ក្នុងសីមា ដោយន័យថា "សូមឲ្យភិក្ខុទាំងឡាយដែលនៅក្នុងសីមា មានសេចក្តីសុខ កុំបីបៀតបៀនគ្នាឡើយ" បន្ទាប់ពីនោះ គប្បីចំរើន ក្នុងពួកទេវតាដែលនៅក្នុងសីមា តអំពីនោះមក គប្បីចំរើន ក្នុងពួកឥស្សរជន ក្នុងគោចរគ្រាម បន្ទាប់មក គប្បីចំរើន ក្នុងមនុស្ស ក្នុងគោចរគ្រាមនោះ រហូតដល់សព្វសត្វទាំងឡាយ ។ ក៏ព្រោះ (ចំរើន)មេត្តា ក្នុងភិក្ខុសង្ឃ ភិក្ខុនោះ រមែងធ្វើឲ្យភិក្ខុទាំងឡាយ ដែលនៅរួមជាមួយគ្នា កើតមានចិត្តទន់ ។ កាលបើដូច្នោះ ភិក្ខុទាំងឡាយនោះជាអ្នកមានការនៅរួមជាសុខ ដល់ភិក្ខុនោះ ។ ព្រោះ (ចំរើន)មេត្តា ក្នុងពួកទេវតា ដែលអាស្រ័យនៅ ក្នុងសីមានោះ ភិក្ខុនោះ ជាអ្នកគឺទេវតាទាំងឡាយ ដែលមានចិត្តគឺមេត្តានោះ ធ្វើឲ្យទោរទន់ហើយ រក្សាឃុំគ្រងល្អហើយ ដោយការរក្សាដែលប្រកបដោយធម៌ ។ ព្រោះ (ចំរើន)មេត្តា ក្នុងឥស្សរជន ក្នុងគោចរគ្រាម ភិក្ខុនោះ ជាអ្នកគឺឥស្សរជនទាំងឡាយដែលមានសន្តានចិត្ត គឺមេត្តានោះ ធ្វើឲ្យទន់ហើយ ថែរក្សាការពារ យ៉ាងល្អហើយ ដោយការថែរក្សាដែលប្រកបដោយធម៌ ។ ព្រោះ(ចំរើន)មេត្តា ក្នុងមនុស្សទាំងឡាយ ក្នុងគោចរគ្រាមនោះ ភិក្ខុនោះ ជាអ្នកគឺមនុស្សទាំងឡាយនោះ ដែលមានចិត្តគឺមេត្តានោះ ធ្វើឲ្យជ្រះថ្លាហើយ មិនមើលងាយហើយ រមែងត្រាច់ទៅ ។ ព្រោះ (ចំរើន)មេត្តា ក្នុងសត្វទាំងឡាយទាំងពួង ភិក្ខុនោះ ជាអ្នកមានកិរិយាត្រាច់ទៅ មិនត្រូវគេរាំងស្ទះ ក្នុងទីទាំងពួង ។ ម្យ៉ាងទៀត ដោយមរណស្សតិ ភិក្ខុនោះ កាលគិត ថា "អាត្មាអញ គឺពិតជានឹងស្លាប់" ដូច្នេះ នឹងលះបង់នូវអនេសនៈហើយ ជាអ្នកមានសេចក្តីសង្វេគ រីកចំរើនខ្ពស់ឡើង ៗ ជាអ្នកមានការប្រព្រឹត្តិ

មិនធូរថយ ។ មួយទៀត កាលបើភិក្ខុនោះ មានចិត្តសន្សំអប់រំ ក្នុងអសុភសញ្ញាហើយ អារម្មណ៍ទាំងឡាយសូម្បីជាទិព្វ ក៏នឹងមិនគ្របសង្កត់នូវចិត្ត (របស់ភិក្ខុនោះ) ដោយអំណាចនៃសេចក្ដីលោភលន់ ។

ដូចបានពណ៌នាមកនេះឯង កម្មដ្ឋាន ៣ មាន មេត្តាកម្មដ្ឋាន ជាដើម ទើបលោកហៅថា "សព្វត្ថកកម្មដ្ឋាន" ព្រោះជាកម្មដ្ឋាន ដែលបុគ្គលគប្បីត្រូវការ គឺគប្បីប្រាថ្នាក្នុងភាវនានុយោគទាំងពួង ព្រោះភាវៈជាកម្មដ្ឋានដែលមានឧបការច្រើនផង ព្រោះជាទីតាំងនៃការផ្សារ គឺកិរិយាតាមប្រកបរឿយៗ ដែលយោគភាវនា ត្រូវការហើយផង ។ ចំណែកកម្មដ្ឋានឯណា ក្នុងកម្មដ្ឋានទាំង ៤០ សមគួរ ដល់ចរិយា របស់ភិក្ខុណា, កម្មដ្ឋាននោះ របស់ភិក្ខុនោះ លោកហៅថា "បារិហារិយកម្មដ្ឋាន" ព្រោះជាកម្មដ្ឋាន ដែលភិក្ខុនោះ ត្រូវតែរក្សា ជាប់ជានិច្ច និង ព្រោះជាបទដ្ឋាននៃភាវនាកម្មខ្ពស់ឡើង ៗ របស់ភិក្ខុនោះផង ។

ភិក្ខុរូបណា ឲ្យនូវកម្មដ្ឋានទាំង ២ យ៉ាងនេះ ដូចបានពោលហើយ, ភិក្ខុរូបនេះ ឈ្មោះថា ជាអ្នកឲ្យនូវកម្មដ្ឋាន, ព្រះយោគាវចរ គប្បីចូលទៅរកភិក្ខុអ្នកឲ្យកម្មដ្ឋាននោះ ។

(កល្យាណមិត្រ)

ពាក្យថា "ជាកល្យាណមិត្រ" គឺមិត្រដែលល្អ អ្នកឋិតនៅហើយក្នុងផ្នែកនៃសេចក្ដីចំរើន ប្រកបដោយប្រយោជន៍សុខតែម្យ៉ាង ជាអ្នកប្រកបព្រមហើយ ដោយគុណមានជាអាទិ៍ យ៉ាងដូច្នេះ គឺ :

ជាអ្នកគួរស្រឡាញ់ ១ គួរគោរព ១ គួរសរសើរ ១
ជាអ្នកពោល ១ ជាអ្នកអត់ធន់នូវពាក្យ ១ ជាអ្នក



តែងនូវកថា(ធម៌)ដ៏ជ្រាលជ្រៅ ១ មិនដឹកនាំ(បុគ្គល
ដទៃ) ក្នុងទីដែលមិនគួរ ១ ។

ក៏ព្រោះព្រះពុទ្ធវចនៈថា "ម្នាលអានន្ទ! ពិតមែន សត្វទាំងឡាយជាអ្នកមានជាតិជាធម្មតា អាស្រ័យតថាគតដែលជាកល្យាណមិត្រហើយ រមែងរួចផុតអំពីជាតិបាន [១] " ដូច្នេះជាដើម ព្រះសម្មាសម្ពុទ្ធនុ៎ះឯង ជាកល្យាណមិត្រ ប្រកបព្រមដោយអាការៈទាំងពួង ។ ព្រោះហេតុនោះ កាលព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ធរមាននៅឡើយ, កម្មដ្ឋានដែលបុគ្គលរៀនហើយ ក្នុងសំណាក់នៃព្រះមានព្រះភាគអង្គនោះ តែប៉ុណ្ណោះ ជាកម្មដ្ឋានដែលបុគ្គលរៀនល្អហើយ តែកាលបើព្រះអង្គ ទ្រង់បរិនិព្វានទៅហើយ បណ្ដាព្រះមហាសាវកទាំង៨០ ព្រះមហាសាវកអង្គណា មានជីវិតរស់នៅ, ភិក្ខុ នឹងរៀនកម្មដ្ឋាន ក្នុងសំណាក់នៃព្រះមហាសាវកអង្គនោះ ក៏គួរ, សូម្បីព្រះមហាសាវកអង្គនោះ មិនមានទេ, ខ្លួនជាអ្នកប្រាថ្នាចង់រៀនកម្មដ្ឋានណាមួយ ក៏គប្បីរៀន ក្នុងសំណាក់នៃព្រះខីណាស្រព ដែលជាអ្នកញ៉ាំងចតុក្កឈាន និង បញ្ចកឈាន ឲ្យកើត ដោយអំណាចកម្មដ្ឋាន ដែលខ្លួនត្រូវការនោះឯង ចំរើនវិបស្សនា ដែលមានឈាននោះ ជាបទដ្ឋានហើយ សម្រេចនូវការអស់ទៅនៃអាសវៈ ។

សួរថា "ក៏ព្រះខីណាស្រព ប្រកាសនូវខ្លួនថា អាត្មាអញ ជាព្រះខីណាស្រពឬ? " ។ ឆ្លើយថា "នឹងពោលធ្វើអ្វី ព្រោះព្រះខីណាស្រពដឹងនូវភាវៈនៃភិក្ខុនោះ ធ្វើពិតហើយ ទើបប្រកាស, ព្រះអស្សគុត្តត្ថេរដឹងថា "កម្មដ្ឋាន គឺភិក្ខុនេះ ប្រារព្ធហើយ ភិក្ខុនេះ ជាអ្នកធ្វើពិត" ដូច្នេះ

---

១- សុ. សំ. សគ. ភាគទី ២៩ ទំព័រទី ២៣៩ ។

ហើយ ក្រាលផ្ទាំងស្បែកលើអាកាស អង្គុយពត់ភ្នែនលើផ្ទាំងស្បែកនោះ ហើយ ប្រាប់នូវកម្មដ្ឋាន មិនមែនទេឬ?” ។ ព្រោះហេតុនោះ បើព្រះយោគាវចរ បាននូវព្រះខីណាស្រព ក៏ការបាននោះ ជាការល្អហើយ, បើមិនបានទេ គប្បីកាន់យក ក្នុងសំណាក់នៃព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន បុថុជ្ជន អ្នកបានឈាន ភិក្ខុអ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកទ្រទ្រង់បិដកពីរ អ្នកទ្រទ្រង់បិដកមួយ ចុះតាមលំដាប់ៗមក, សូម្បីកាលបើភិក្ខុអ្នកទ្រទ្រង់បិដកមួយ មិនមានទេ, ភិក្ខុឯណា ជាអ្នកស្ទាត់ជំនាញសូម្បីនិកាយមួយ ព្រមទាំងអដ្ឋកថា និង ភិក្ខុនោះ ខ្លួនឯង ជាអ្នកមានការអៀនខ្មាស គប្បីកាន់យក (កម្មដ្ឋាន) ក្នុងសំណាក់នៃភិក្ខុអង្គនោះ ។ ព្រោះថា ភិក្ខុបែបនេះ ជាអ្នកទ្រទ្រង់នូវបែបបទ ជាអ្នកតាមរក្សានូវវង្សត្រកូល ជាអ្នកថែរក្សាប្រពៃណី ជាអាចារ្យ ជាអ្នកជឿតាមមតិ របស់អាចារ្យ ជាអ្នកមិនយកតាមអត្តនោម័តិ ។ ព្រោះហេតុនោះឯង ទើបព្រះបោរាណកត្ថេរទាំងឡាយ បានពោលហើយ ៣ ដង ថា “ភិក្ខុលជ្ជី នឹងរក្សា, ភិក្ខុលជ្ជី នឹងរក្សា, ភិក្ខុលជ្ជី នឹងរក្សា” ដូច្នេះ ។

ក៏ក្នុងការឲ្យកម្មដ្ឋាននេះ ភិក្ខុមានព្រះខីណាស្រពជាដើម ដែលបានពោលមកហើយ ពួដ៏ខាងដើម រមែងប្រាប់បានតែផ្លូវដែលខ្លួនបានសំរេចហើយប៉ុណ្ណោះឯង ។ ចំណែកឯ ភិក្ខុជាពហុស្សូត ព្រោះភាវៈនៃខ្លួនជាអ្នកចូលទៅរកអាចារ្យនោះៗហើយ ញ៉ាំងឧគ្គហៈ(ការរៀន) និង បរិបុច្ឆា (ការសាកសួរ) ឲ្យជ្រះស្រឡះហើយ កំណត់នូវព្រះសូត្រ និង ហេតុការណ៍ អំពីទីនេះខ្វះ ទីនោះខ្វះ ប្រកបឲ្យទៅជាទីសប្បាយ ឬ មិនជាទីសប្បាយ សំដែងផ្លូវដ៏ធំទូលាយ ហើយប្រាប់នូវកម្មដ្ឋាន ប្រៀបដូចជាមហាហត្ថី ដែលដើរចូលទៅ ក្នុងទីព្រៃដែលស៊ុបទ្រុប យ៉ាងនោះឯង ។



ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីចូលទៅរកភិក្ខុ ដែលជាអ្នកឲ្យកម្មដ្ឋាន ជាកល្យាណមិត្របែបនោះ ធ្វើវត្តបតិបត្តិ ដល់ភិក្ខុនោះហើយ គប្បីរៀនយកកម្មដ្ឋាន ។ បើព្រះយោគាវចរ បានភិក្ខុអ្នកឲ្យនូវកម្មដ្ឋាន ដែលជាកល្យាណមិត្រនោះ ក្នុងវត្តជាមួយគ្នានុ៎ះឯង ការបានយ៉ាងនោះ ជាការល្អហើយ, បើមិនបានទេ, ភិក្ខុ អ្នកឲ្យកម្មដ្ឋាននោះ អាស្រ័យនៅក្នុងទីណា ព្រះយោគាវចរ គប្បីទៅ ក្នុងទីនោះចុះ ។ ក៏កាលបើនឹងទៅ មិនត្រូវពាក់ស្បែកជើងដោយជើងដែលលាងដុសជម្រះហើយ បាំងឆ័ត្រ ប្រើឲ្យគេកាន់យកនូវគ្រឿងប្រើប្រាស់ មានបំពង់ ប្រេង និង ភេសជ្ជៈ មានទឹកឃ្មុំ និង ស្ករអំពៅជាដើម មានអន្តេវាសិក ចោមរោមហើយដើរទៅ, តែគប្បីបំពេញគមិកវត្ត ហើយកាន់យកបាត្រ និង ចីវររបស់ខ្លួន ដោយខ្លួនឯងតែម្តង ចូលទៅកាន់វត្តណាៗ ក្នុងចន្លោះផ្លូវ ធ្វើវត្តប្រតិបត្តិ ក្នុងទីទាំងពួង ជាអ្នកមានបរិក្ខារដ៏ស្រាល មានការប្រព្រឹត្តិដុសជម្រះ យ៉ាងក្រៃលែងត្រាច់ទៅ ។ កាលចូលទៅដល់វត្តនោះ គប្បីញ៉ាំងបុគ្គលឲ្យធ្វើឈើជម្រះធ្មេញ ជាកប្បិយៈ ក្នុងចន្លោះផ្លូវនុ៎ះឯងហើយ កាន់ចូលទៅ ។ មួយទៀត មិនគួរចូលទៅកាន់បរិវេណផ្សេងទៀត ដោយគិតថា “អញ នឹងសម្រាក ធ្វើនូវសរីរកិច្ច មានលាង និង លាបជើងជាដើម បន្តិចសិនហើយ ចាំចូលទៅរកសំណាក់អាចារ្យ” ។ សួរថា “ព្រោះហេតុអ្វី?” ។ ឆ្លើយថា “ព្រោះថាភិក្ខុទាំងឡាយដែលជាវិសភាគ របស់អាចារ្យនោះ គប្បីមាន ក្នុងបរិវេណនោះ, ភិក្ខុទាំងនោះ សួរហេតុនៃការមកហើយ គប្បីប្រកាសនូវទោសរបស់អាចារ្យហើយ ពោលថា “វិនាសហើយលោកអើយ! បើលោកមកកាន់សំណាក់អាចារ្យនោះ” ហើយគប្បីញ៉ាំងសេចក្តីក្តៅក្រហាយ ឲ្យកើតឡើង, ភិក្ខុនោះ គប្បីវិលវិញ

ចាកទីនោះ ព្រោះហេតុណា, ព្រោះហេតុនោះ ភិក្ខុ គប្បីសួរទីលំនៅរបស់អាចារ្យហើយ សឹមទៅត្រង់ ក្នុងទីនោះតែម្តង ។

បើអាចារ្យក្មេងជាង មិនគួរត្រេកអរនឹងសាមីចិកម្ម មានការទទួលយកបាត្រ និង ចីវរជាដើមឡើយ ។ បើអាចារ្យចាស់ជាង, ទៅដល់ហើយ គប្បីថ្វាយបង្គំអាចារ្យហើយឈរ ។ បើអាចារ្យពោលថា "ម្នាលលោកដ៏មានអាយុ ចូរលោកដាក់បាត្រនិងចីវរចុះ" ហើយគប្បីដាក់ចុះ ។ បើអាចារ្យពោលថា "និមន្តឆាន់ទឹក" ដូច្នេះហើយ បើប្រាថ្នា ត្រូវឆាន់ ។ អាចារ្យពោលថា "ចូរលាងជើង" មិនត្រូវលាងជើងជាមុនទេ ។ ព្រោះថា បើអាចារ្យ ត្រូវទៅដងទឹកមក ក៏ជាការមិនសមគួរឡើយ ។ តែបើអាចារ្យប្រាប់ថា "ម្នាលអាវុសោ ចូរលាងចុះ ទឹកនោះ ខ្ញុំមិនបានដងមកទេ គឺពួកភិក្ខុដទៃទេដែលដងមក" ហើយ គប្បីទៅអង្គុយ ក្នុងទីដែលអាចារ្យ មើលមិនឃើញ ទោះបីជាទីទំនេរ ដែលមានគ្រឿងបិទបាំង ឬទីវាលដូច្នោះ ឬក៏ ទីក្បែរៗ នៃវិហារក៏បាន ហើយលាងជើងចុះ ។ បើអាចារ្យនាំយកបំពង់ប្រេងមក គប្បីក្រោកឡើង យកដៃទាំងពីរទទួលដោយគោរព ។ ព្រោះបើភិក្ខុ មិនទទួលបំពង់ប្រេងនោះទេ អាចារ្យនឹងកើតមានចិត្តគិតផ្សេងថា "ភិក្ខុនេះ ញុំាងកិរិយាគប់រកឲ្យកំរើក ចាប់តាំងពីពេលនេះ ពិតមែន" ។ តែលុះទទួលយកហើយ មិនត្រូវលាបជើងមុនភ្លាមៗ ទេ ។ ព្រោះថា ប្រេងនោះ ជាប្រេងសំរាប់លាបខ្លួន របស់អាចារ្យ នឹងទៅជាការដែលមិនសមគួរ ។ ហេតុនោះ ភិក្ខុ គប្បីលាបក្បាលមុនហើយ ចាំលាបនូវអវយវៈ មាន-ក ជាដើម ។ តែបើអាចារ្យពោលថា "ម្នាលអាវុសោ! ប្រេងនេះ ជាប្រេងសម្រាប់ ប្រើប្រាស់បានគ្រប់យ៉ាង ចូរអ្នកលាបជើង ក៏បាន" ដូច្នេះ ត្រូវដាក់លើក្បាលបន្តិច



ហើយ តមក ត្រូវលាបជើងហើយ ពោលថា "បពិត្រព្រះគុណម្ចាស់ ដ៏ចំរើន ខ្ញុំនឹងទុកដាក់នូវបំពង់ប្រេងនេះ" បើអាចារ្យទទួល គប្បីប្រគេន ។ ភិក្ខុមិនត្រូវ(ប្រញាប់) ពោលយ៉ាងនេះថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើនសូមព្រះគុណម្ចាស់ មេត្តាប្រាប់កម្មដ្ឋានដល់ខ្ញុំ" ចាប់តាំងពីថ្ងៃដែលមកដល់ ។ តែចាប់ពីថ្ងៃទី ២ ទៅ បើឧបដ្ឋាកជាប្រចាំ របស់អាចារ្យមាន គប្បីសូមឧបដ្ឋាកនោះ ហើយធ្វើវត្ត ។ បើសូមហើយ ឧបដ្ឋាកនោះមិនឲ្យទេ បើបានឱកាសភ្លាម គប្បីធ្វើ ។ ក៏កាលនឹងធ្វើ គប្បីប្រគេនឈើជម្រះធ្មេញ ៣ យ៉ាង គឺ ខ្នាតតូច, ខ្នាតកណ្តាល និង ខ្នាតធំ ។ ទឹកសំរាប់លាងមុខ និង ទឹកសំរាប់ងូត គប្បីត្រៀមទុកទាំង ២ យ៉ាង គឺៈ ទឹកត្រជាក់ ទឹកក្តៅ ។ អាចារ្យប្រើនូវឈើជម្រះធ្មេញ និង ទឹកណាមួយ រហូត ៣ ថ្ងៃ បន្ទាប់ពីនោះ គប្បីប្រគេនឈើជម្រះធ្មេញ និង ទឹកដូច្នោះឯង ជាប់ជានិច្ច ។ កាលបើអាចារ្យមិនរើស ប្រើណាមួយក៏បាន គប្បីប្រគេនតាមតែបានមក ។ នឹងពោលច្រើនធ្វើអ្វី ។ វត្តដ៏ប្រពៃ គឺព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ ក្នុងមហាខន្ធកៈ ថា "ម្នាលភិក្ខុទាំងឡាយ អន្តេវាសិក គប្បីធ្វើវត្តដ៏ប្រពៃ ចំពោះអាចារ្យ, នេះ ជាការធ្វើវត្តប្រពៃក្នុងរឿងនោះ គឺ អន្តេវាសិក គប្បីក្រោកឡើង អំពីព្រលឹមតែម្តង ដោះស្បែកជើងចេញ គ្រងចីពរឆៀងស្មាម្ខាងហើយ ប្រគេនឈើជម្រះធ្មេញ ប្រគេនទឹកលាងមុខ ក្រាលអាសនៈឲ្យ បើយាគូមាន គប្បីលាងភាជនៈហើយប្រគេនយាគូ" ដូច្នេះជាដើម នោះឯណា, គប្បីធ្វើសម្មាវត្តទាំងអស់នោះចុះ ។

សិស្ស ញុំាងអាចារ្យឲ្យត្រេកអរ ដោយវត្តសម្បត្តិ យ៉ាងនេះ, ក្នុងវេលាល្ងាច អាចារ្យឲ្យទៅវិញ ដោយប្រាប់ ថា "ចូរអ្នក ទៅចុះ" ថ្វាយ

បន្តិំហើយសឹមទៅ ។ អាចារ្យនោះ សួរថា “តើអ្នកមក ដើម្បីអ្វី?” ក្នុងពេលណា, ក្នុងពេលនោះ ត្រូវប្រាប់ហេតុការណ៍ដែលមក ។ បើសិនអាចារ្យនោះ មិនសួរទេ តែអាចារ្យ ត្រេកអរនឹងវត្តប្រតិបត្តិ, កាលបើកន្លង ១០ ថ្ងៃ ឬ មួយបក្ស ទៅហើយ ក្នុងថ្ងៃមួយ សូម្បីអាចារ្យបានអនុញ្ញាតហើយ ក៏មិនគួរទៅ ឲ្យលោកធ្វើឱកាសហើយ ចាំប្រាប់ហេតុនៃការមក ។ ឬក៏ ទៅខុសវេលា ត្រូវអាចារ្យ សួរថា “តើអ្នកមក ដើម្បីអ្វី?” គប្បីប្រាប់ ។ បើអាចារ្យនោះ ប្រាប់ថា “ចូរអ្នកមកអំពីព្រឹកបន្តិច” ត្រូវតែមកអំពីព្រលឹមតែម្តង ។ តែបើក្នុងពេលនោះ ពោះរបស់ភិក្ខុនោះ ត្រូវរោគថ្លើមបៀតបៀនក្តី អាហារមិនរលាយ ព្រោះធាតុភ្លើងតិចពេកក្តី រោគ ឯណាមួយដទៃទៀត បៀតបៀនក្តី, គប្បីប្រាប់នូវរោគនោះ តាមសភាពពិត ប្រាប់នូវវេលាដែលជាទីសប្បាយ របស់ខ្លួនហើយ ត្រូវចូលទៅរក ក្នុងពេលនោះ ។ ព្រោះថា នៅក្នុងវេលាដែលមិនសប្បាយ សូម្បីតែអាចារ្យ ប្រាប់កម្មដ្ឋានឲ្យ ក៏មិនអាចធ្វើទុក ក្នុងចិត្តបានដែរ ។ នេះ ជាសេចក្តីពិស្តារ ក្នុងពាក្យថា “ចូលទៅរកអាចារ្យ អ្នកឲ្យកម្មដ្ឋានដែលជាកល្យាណមិត្រ” នោះ ។

(ចរិយា និង ចរិត ៦)

(៧១) ឥឡូវនេះ បណ្ឌិត គប្បីជ្រាបសេចក្តីពិស្តារ ក្នុងពាក្យថា “កម្មដ្ឋាន ដែលសមគួរដល់ចរិយារបស់ខ្លួន” ដូចតទៅនេះ ។

ពាក្យថា “ចរិយា” បានដល់ ចរិយា ៦ គឺ : រាគចរិយា, ទោស-ចរិយា, មោហចរិយា, សទ្ធាចរិយា, ពុទ្ធិចរិយា, វិតក្កចរិយា ។ ប៉ុន្តែអាចារ្យពួកខ្លះ ប្រាថ្នាយកចរិយា ១៤ ព្រមទាំងចរិយា ៨ នេះ គឺ : ដោយការប្រឡូកប្រឡាក់គ្នា និង ដោយការរួបរួមគ្នា នៃវត្ថុ ៣ ខាងដើម



មានរាគៈជាដើម បានដល់ចរិយា ៤ ដទៃទៀត នៃវត្ថុ ៣ ខាងចុង មានសទ្ធាជាដើម បានដល់ ចរិយា ៤ ដទៃទៀត ក៏ដូចគ្នា ។ តែបើពោលប្រភេទ យ៉ាងដូច្នេះ ចរិយា រមែងមានច្រើនជាអនេក ព្រោះធ្វើការបូករួម ដោយវត្ថុ ៣ ខាងដើម មានរាគៈជាដើម ចូលជាមួយគ្នានឹងវត្ថុ ៣ ខាងចុង មានសទ្ធាជាដើម, ព្រោះហេតុនោះ គប្បីជ្រាបចរិយាតែ ៦ ប៉ុណ្ណោះ ដោយសង្ខេប ។

ពាក្យថា “ចរិយា បកតិ ឧស្សន្នតា” ដោយអត្ថ មានន័យ តែមួយ ។ ដោយអំណាចនៃចរិយាទាំង ៦ នោះ បុគ្គលក៏មាន ៦ ដូចគ្នាដែរ គឺ: បុគ្គលដែលជារាគចរិត, បុគ្គលដែលជាទោសចរិត, បុគ្គលដែលជាមោហចរតិ, បុគ្គលដែលជាសទ្ធាចរិត, បុគ្គលដែលជាពុទ្ធិចរិត, បុគ្គលដែលជាវិតក្កចរិត ។ ព្រោះហេតុដែលក្នុងបុគ្គលទាំង ៦ ពួកនោះ បុគ្គលដែលជារាគចរិត ក្នុងពេលប្រព្រឹត្តកុសល រមែងមានសទ្ធាដ៏ខ្លាំងក្លា ព្រោះសទ្ធា មានគុណដែលនៅជិតក្បែរនឹងរាគៈ ។ មែនពិត ក្នុងផ្នែកខាងអកុសល រាគៈ មានទោសដ៏ជិតស្និទ្ធ មិនមានសៅហ្មង យ៉ាងណាមិញ, ក្នុងផ្នែកកុសល សទ្ធា ក៏ជាគុណដែលស្រស់ប្រិមប្រិយ មិនសៅហ្មង យ៉ាងនោះដែរ ។ រាគៈ ស្វែងរកនូវវត្ថុកាម យ៉ាងណា, សទ្ធាក៏ស្វែងរកគុណមានសីលជាដើម យ៉ាងនោះដែរ ។ រាគៈ រមែងមិនលះបង់ចោលនូវរបស់ដែលមិនមែនជាប្រយោជន៍ យ៉ាងណាមិញ, សទ្ធាក៏មិនលះបង់ចោលនូវរបស់ដែលជាប្រយោជន៍ យ៉ាងនោះដែរ, ព្រោះហេតុនោះ បុគ្គលដែលជាសទ្ធាចរិត ទើបមានចំណែកស្មើគ្នានឹងបុគ្គលដែលជារាគចរិត ។

ចំណែកបុគ្គលដែលជាទោសចរិត ក្នុងពេលប្រព្រឹត្តកុសល រមែង

មានបញ្ញាដ៏ខ្លាំងក្លា ព្រោះបញ្ញាមានគុណនៅជិតនឹងទោសៈ ។ មែនពិត ក្នុងផ្នែកអកុសល ទោសៈ ជាទោសដែលមិនមានសេចក្ដីស្រឡាញ់ មិនជាប់ជំពាក់នូវអារម្មណ៍ យ៉ាងណាមិញ, ក្នុងផ្នែកកុសល បញ្ញា ក៏ជាគុណដែលមិនមានស្នេហា មិនជាប់ជំពាក់នូវអារម្មណ៍ យ៉ាងនោះដែរ ។ មួយទៀត ទោសៈ រមែងស្វែករកតែទោសដែលមិនពិត យ៉ាងណាមិញ, បញ្ញា រមែងស្វែងរកតែទោសដែលពិតប៉ុណ្ណោះ យ៉ាងនោះដែរ។ ទោសៈ រមែងប្រព្រឹត្តទៅ ដោយអាការដែលមិនអើពើចំពោះសត្វ យ៉ាងណា, បញ្ញា រមែងប្រព្រឹត្តទៅ ដោយអាការមិនអើពើចំពោះសង្ខារ យ៉ាងនោះដែរ, ព្រោះហេតុនោះ បុគ្គលដែលជាពុទ្ធិចរិត ទើបមានចំណែកស្មើគ្នានឹងបុគ្គលដែលជាទោសចរិត ។

ឯបុគ្គលដែលជាមោហចរិត កាលព្យាយាមធ្វើនូវកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង, វិតក្កៈទាំងឡាយ ដែលធ្វើសេចក្ដីអន្តរាយ រមែងកើតឡើង ដោយច្រើន ព្រោះវិតក្កៈ មានលក្ខណៈនៅជិតគ្នានឹងមោហៈ ។ មែនពិត មោហៈ មិនតាំងនៅស៊ប់ហើយ ព្រោះវង្វេងវង្វាន់កាន់កាំងហើយ យ៉ាងណា, វិតក្កៈ ក៏មិនឈប់នៅស្ងៀមបាន ព្រោះវល់តែគិតត្រិះរិះ ច្រើនប្រការផ្សេងៗ ក៏យ៉ាងនោះដែរ ។ មួយទៀត មោហៈ ជាទោសដែលញាប់ញ័រ ព្រោះភាវៈនៃចិត្តមិនតាំងនៅរឹងមាំល្អ យ៉ាងណា, វិតក្កៈ ជាធម្មជាតកម្រើកញាប់ញ័រ ព្រោះមានការគិតឆាប់រហ័ស យ៉ាងនោះដែរ, ព្រោះហេតុនោះ បុគ្គលដែលជាវិតក្កចរិត ទើបមានចំណែកស្មើគ្នា នឹងបុគ្គលដែលជាមោហចរិត ។

អាចារ្យពួកខ្លះ បានពោលថា “ចរិយា មាន ៣ យ៉ាង ផ្សេងទៀត ដោយអំណាចនៃតណ្ហា, មានះ និង ទិដ្ឋិ” ។ បណ្ដាបី យ៉ាងនោះ តណ្ហា



គឺ រាគៈនុ៎ះឯង, ចំណែកមានះ ក៏សម្បយុត្ត ដោយរាគៈនោះ ព្រោះហេតុនោះ តណ្ហា និង មានះទាំង ២ នោះ ក៏មិនរួចផុតអំពីរាគចរិយា ។ ចំណែកឯ ទិដ្ឋិចរិយា រមែងទៅតាមមោហចរិយានុ៎ះឯង ព្រោះទិដ្ឋិ មានមោហៈជាដើមហេតុ ។

(៧២) សួរថា “ក៏ចរិយាទាំងនេះនោះ មានអ្វីជាដើមហេតុ? និង គប្បីដឹងបាន ដូចម្ដេចថា: បុគ្គលនេះ ជាអ្នកមានរាគចរិត, បុគ្គលនេះជាអ្នកមានចរិតណាមួយ ក្នុងចរិតទាំងឡាយ មានទោសចរិត ជាដើម ? និង អ្វីដែលជាទីសប្បាយដល់បុគ្គលដែលមានចរិតបែបណា?” ដូច្នេះ ។

**(ដើមហេតុនៃចរិយា)**

បណ្ដាចរិយាទាំង ៦ នោះ នឹងឆ្លើយចរិយា ៣ ខាងដើម ជាមុន អាចារ្យពួកខ្លះ ពោលថា “ចរិយាទាំងឡាយ ៣ ខាងដើមនោះ មាន អាចិណ្ណកម្ម ក្នុងភពមុន ជាដើមហេតុ ១ មានធាតុ និង ទោស ជាដើមហេតុ ១” ដូច្នេះ ។

បានឮមកថា បុគ្គលអ្នកច្រើនដោយបយោគ ដែលជាទីប្រាថ្នា និង កម្មដែលល្អមកអំពីកាលមុនក្ដី មនុស្សដែលច្យុតមកពីឋានសួគ៌ ហើយមកកើត ក្នុងមនុស្សលោកនេះក្ដី ជាបុគ្គលដែលមានរាគចរិត, បុគ្គលអ្នកច្រើនដោយកម្ម ដែលជាពៀរវេរា គឺកាប់គេ, វាយគេ, សម្លាប់គេ និង ចាប់ចងគេក្នុងកាលមុនក្ដី បុគ្គលដែលច្យុតមកពីនរក និង កំណើតពស់ ហើយមកកើត ក្នុងមនុស្សលោកនេះក្ដី ជាបុគ្គលដែលមានទោស-ចរិត ។ បុគ្គលដែលច្រើនដោយការផឹកទឹកស្រវឹង និង ជាអ្នកលះបង់ចោលនូវការស្ដាប់ និង ការសាកសួរ ក្នុងកាលមុនក្ដី បុគ្គលដែលច្យុតអំពីកំណើត នៃសត្វតិរច្ឆាន ហើយមកកើត នៅក្នុងមនុស្សលោកនេះក្ដី

ជាបុគ្គលដែលមានមោហចរិត, ព្រោះហេតុនេះឯង ទើបលោក ពោលថា "ចរិយាទាំង៣ មានអាចិណ្ណកម្ម ក្នុងភពមុន ជាដើមហេតុ" ដូច្នេះឯង ។

ម្យ៉ាងទៀត បុគ្គលដែលជាមោហចរិត ព្រោះធាតុ ២ យ៉ាង គឺ បឋវីធាតុ ១ អាបោធាតុ ១ ដុះដាលឡើង, បុគ្គលដែលជាទោសចរិត ព្រោះធាតុទាំង ២ ក្រៅអំពីនេះដុះដាលឡើង ។ បុគ្គល ដែលជារាគចរិត ព្រោះធាតុទាំងពួងស្មើគ្នា យ៉ាងដូច្នេះ ១, ក្នុងទោសទាំងឡាយ បុគ្គល ដែលច្រើនដោយស្លេស្ម ជាអ្នកមានរាគចរិត, បុគ្គល ដែលច្រើនដោយខ្យល់ ជាអ្នកមានមោហចរិត, ឬក៏ បុគ្គល ដែលច្រើនដោយស្លេស្ម ជាអ្នកមានមោហចរិត, បុគ្គលដែលច្រើនដោយខ្យល់ ជាអ្នកមានរាគចរិត យ៉ាងដូច្នេះ ១, ដូចបានពោលមកនេះឯង ទើបលោក ពោលថា "ចរិតទាំង ៣ ខាងដើម មានធាតុ និង ទោស ជាដើមហេតុ" ដូច្នេះ ។

ព្រោះហេតុថា បណ្ដាបុគ្គលទាំងនោះ សូម្បីបុគ្គលទាំងឡាយ អ្នកច្រើនដោយបយោគ ដែលជាទីប្រាថ្នា និង កម្មដែលល្អ (មានមក) ក្នុងកាលមុនក្ដី សូម្បីមនុស្សដែលច្យុតមកអំពីឋានសួគ៌ ហើយមកកើត ក្នុងមនុស្សលោកនេះក្ដី មិនមែនសុទ្ធតែជាបុគ្គលរាគចរិតទាំងអស់ទុំះទេ ឬក៏ បុគ្គលទាំងឡាយក្រៅពីនេះ ក៏មិនមែនជាអ្នកមានទោសចរិត និង មោហចរិតគ្រប់ៗ គ្នាដែរ ។ ក៏ធម្មតាការកំណត់ចរិយា ដោយការដុះឡើង នៃធាតុទាំងឡាយ តាមន័យដែលបានពោលមកហើយនោះ មិនមានទេ និង ក្នុងការកំណត់ចរិយា ដោយទោស គឺលោកបានពោលហើយ តែ ២ យ៉ាង គឺ រាគចរិត និង មោហចរិតប៉ុណ្ណោះ, សូម្បីពាក្យដែលបានពោលមកនោះ ពាក្យខាងដើម និង ពាក្យខាងចុង ជាពាក្យខុសគ្នា មែនពិត, ចំណែក ក្នុងចរិយាទាំងឡាយ មានសទ្ធាជាដើម លោកមិនបានពោល



សូម្បីតែដើមហេតុ នៃចរិយាមួយឡើយ ព្រោះហេតុនោះ ពាក្យទាំងអស់នោះឯង ជាពាក្យដែលលោកមិនបានកំណត់ហើយ ។

ចំណែកឯសេចក្ដីនេះ ជាសេចក្ដីវិនិច្ឆ័យ ទៅតាមមតិ នៃព្រះអដ្ឋកថាចារ្យទាំងឡាយ ក្នុងបញ្ហានេះ ថា "ចរិយាទាំងឡាយ មានអ្វីជាដើមហេតុ?" ដូច្នេះ ។

ពិតដូច្នោះ ក្នុងឧស្សទកិត្តនៈ លោកបានពោលពាក្យនេះមកហើយថា "សត្វទាំងឡាយនេះ ដោយនិយាម (កំណត់) នៃហេតុ ក្នុងកាលមុន ជាអ្នកក្រាស់ដោយលោភៈក៏មាន ជាអ្នកក្រាស់ដោយទោសៈ ក៏មាន ជាអ្នកក្រាស់ដោយមោហៈ ក៏មាន ជាអ្នកច្រើនដោយអលោភៈ ក៏មាន ជាអ្នកច្រើនដោយអទោសៈ ក៏មាន ជាអ្នកច្រើនដោយអមោហៈ ក៏មាន, មែនពិត ក្នុងខណៈដែលព្យាយាមធ្វើកម្ម បុគ្គលណា មានលោភៈដ៏ខ្លាំងក្លា មានអលោភៈទន់ខ្សោយ មានអទោសៈ និង អមោហៈខ្លាំងក្លា មានទោសៈ និង មោហៈទន់ខ្សោយ អលោភៈដ៏ទន់ខ្សោយ របស់បុគ្គលនោះ មិនអាចដើម្បីគ្របសង្កត់ នូវលោភៈបានទេ តែអទោសៈ និង អមោហៈខ្លាំងក្លា អាចគ្របសង្កត់ នូវទោសៈ និង មោហៈបាន ព្រោះហេតុនោះ បុគ្គលនោះ កើតមកហើយ ដោយអំណាចនៃបដិសន្ធិ ដែលកម្មនោះផ្ដល់ឲ្យហើយ ជាបុគ្គលល្មោភ (តែ) ជាបុគ្គលដែលមានចិត្តត្រជាក់ មិនក្រោធខឹង មានបញ្ញា មានញាណដូចជាពេជ្រ ។ ចំណែកបុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ និង ទោសៈ ដ៏មានកម្លាំង មានអលោភៈ និង អទោសៈ ដ៏ទន់ខ្សោយ តែមានអមោហៈខ្លាំងក្លា មានមោហៈ ទន់ខ្សោយ, បុគ្គលនោះ ដោយន័យមុនទុំះឯង ជាបុគ្គលល្មោភផង ជាបុគ្គលក្រោធខឹងផង តែជាបុគ្គលឆ្លាត មានញាណ ដូចជាពេជ្រ

ប្រៀបដូចជាព្រះទត្តាភយត្ថេរ យ៉ាងនោះឯង, បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ និង មោហៈដ៏មានកម្លាំង ក្រៅអំពីនេះ ទន់ខ្សោយ, បុគ្គលនោះ ដោយន័យមុនទុំះឯង ជាបុគ្គលល្មោភផង ជាបុគ្គលល្ងង់ខ្លៅផង តែជាបុគ្គលមានចិត្តត្រជាក់ មិនក្រោធខឹង, មានន័យដូចគ្នានោះដែរ បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានលោភៈ, ទោសៈ និង មោហៈទាំង ៣ យ៉ាង មានកម្លាំងខ្លាំង មានអលោភៈជាដើម ទន់ខ្សោយ, បុគ្គលនោះ ដោយន័យមុនទុំះឯង ជាបុគ្គលល្មោភផង ជាបុគ្គលក្រេវក្រោធផង ជាបុគ្គលវង្វេងផង, ប៉ុន្តែបុគ្គលឯណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ, ទោសៈ និង មោហៈ មានកម្លាំងខ្លាំងក្លា ក្រៅអំពីនេះទន់ខ្សោយ, បុគ្គលនោះ ដោយន័យមុនទុំះឯង ជាអ្នកមិនល្មោភ និង មានកិលេសតិចតួច សូម្បីឃើញអារម្មណ៍ដែលជាទិព្វ ក៏មិនញាប់ញ័រ តែជាបុគ្គលក្រេវក្រោធ និង មានបញ្ញាល្ងង់ខ្លៅ, បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ, អទោសៈ និង មោហៈ មានកម្លាំងខ្លាំង ក្រៅអំពីនេះទន់ខ្សោយ, បុគ្គលនោះ ដោយន័យមុនទុំះឯង ជាអ្នកមិនលោភលន់ផង មានចិត្តត្រជាក់ផង តែជាបុគ្គលល្ងង់ខ្លៅ, ដោយន័យដូចគ្នានោះដែរ បុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈ, ទោសៈ និង អមោហៈ មានកម្លាំងខ្លាំងក្លា ក្រៅអំពីនេះ ទន់ខ្សោយ, បុគ្គលនោះ ដោយន័យមុនទុំះឯង ជាអ្នកមិនលោភលន់ផង មានបញ្ញាផង តែជាបុគ្គលឆេវឆាវ មានសេចក្តីក្រោធ, ឯបុគ្គលណា ក្នុងខណៈព្យាយាមធ្វើកម្ម មានអលោភៈជាដើម ទាំង ៣ យ៉ាង មានកម្លាំងខ្លាំងក្លា ផ្ទុកអកុសលមានលោភៈជាដើម ទន់ខ្សោយ, បុគ្គលនោះ ជាអ្នកមិនល្មោភផង មិនក្រេវក្រោធផង មានបញ្ញាផង ដូចជាព្រះ



មហាសង្ឃរក្ខិតត្ថេរ យ៉ាងនោះឯង ។

ក៏ក្នុងឧស្សទកិត្តនៈនេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅៈ បុគ្គលណា លោកហៅថា ជាអ្នកល្មោភ, បុគ្គលនេះ ជាអ្នកមានរាគចរិត ។ ចំណែកបុគ្គលដែលហៅថា ជាអ្នកក្រេវក្រោធ និង ជាអ្នកល្ងង់ខ្លៅ បានដល់បុគ្គលអ្នកមានទោសចរិត និង អ្នកដែលមានមោហចរិត ។ ដែលលោកហៅថា អ្នកមានបញ្ញា បានដល់បុគ្គលដែលមានពុទ្ធិចរិត។ បុគ្គលដែលហៅថា ជាអ្នកមិនលោភ និង មិនក្រេវក្រោធ បានដល់ បុគ្គលដែលជាសទ្ធាចរិត ព្រោះបុគ្គលដែលមិនលោភលន់ និង មិនក្រេវក្រោធនោះ ជាអ្នកមានសេចក្តីជ្រះថ្លា ជាប្រក្រតី ។

មួយទៀត គប្បីជ្រាបថា “បដិសន្ធិជនកកម្ម ដែលមានបុព្វហេតុទាំងឡាយ មានលោភៈជាដើមឯណាមួយ ជាគ្រឿងចោមរោម ដល់គ្នានឹងគ្នា ជាដើមហេតុនៃចរិយាទាំងឡាយ ដោយន័យយ៉ាងនេះថា “បុគ្គលដែលកើតមកហើយ ព្រោះកម្មដែលមានអមោហៈ ជាគ្រឿងបរិវារ ជាបុគ្គលដែលមានពុទ្ធិចរិត យ៉ាងណា, បុគ្គលដែលកើតមក ព្រោះកម្មដែលមានសទ្ធាដ៏ខ្លាំងក្លាជាគ្រឿងបរិវារ ជាអ្នកមានសទ្ធាចរិត ។ បុគ្គលដែលកើតមកហើយ ព្រោះកម្មដែលមានកាមវិតក្កៈជាដើម ជាគ្រឿងបរិវារ គឺជាអ្នកមានវិតក្កចរិត ។ បុគ្គលដែលកើតមកហើយ ព្រោះកម្មដែលមានលោភៈជាដើម លាយឡំគ្នា ជាគ្រឿងបរិវារ គឺជាបុគ្គលដែលមានចរិតលាយឡំគ្នា” ដោយប្រការដូច្នេះឯង ។

(លក្ខណៈនៃចរិត)

(៧៣) ចំណែកពាក្យណា ដែលលោកពោលហើយថា “និង គប្បីជ្រាបបាន យ៉ាងដូចម្តេច ថា : បុគ្គលនេះ ជាអ្នកមានរាគចរិត” ដូច្នេះជា

ដើម, គប្បីជ្រាបន័យ ក្នុងពាក្យនោះ ដូចតទៅនេះ :

(មាតិកានៃលក្ខណៈ)

បណ្ឌិត គប្បីសំដែងចរិយាទាំងឡាយ ដោយឥរិយាបថ
ដោយកិច្ច ដោយការបរិភោគ ដោយអាការៈមានការ
មើលជាដើម និង ដោយការប្រព្រឹត្តិទៅនៃធម៌ទាំងឡាយ ។

(លក្ខណៈដោយឥរិយាបថ)

ក្នុងពាក្យថា "ដោយឥរិយាបថ" គប្បីជ្រាបន័យ ដូចតទៅនេះ :

ក៏បុគ្គលដែលជាអ្នករាគចរិត កាលធ្វើដំណើរទៅ ដោយដំណើរជាប្រក្រតី រមែងធ្វើដំណើរទៅ ដោយអាការដែលគួរជាទីស្រឡាញ់ ដាក់ជើងរាងថ្នមៗ ដាក់ជើងទ្រង់ស្មើៗ លើកជើងក៏ទ្រង់ស្មើៗ ។ ឯផ្ទៃបាទជើង របស់បុគ្គលនោះ ផតខូងត្រង់កណ្ដាល ។

បុគ្គលដែលជាទោសចរិត ដើរទៅដូចជាកកាយដី ដោយចុងម្រាម ដាក់ជើងទ្រង់រហ័ស លើកជើងក៏ទ្រង់រហ័ស ។ ដានជើង របស់បុគ្គលនោះ ជាដានជើងធ្ងន់ជ្រៅទៅខាងមុខ ។

បុគ្គលដែលជាមោហចរិត ដើរដំណើរទ្រង់រឡេមរឡាម ដាក់ជើងដូចជាទ្រង់ភ័យ លើកជើង ក៏ទ្រង់ដូចជាភ័យដែរ ។ ដានជើង របស់បុគ្គលនោះ ជាដានជើងធ្ងន់ខាងក្រោយ ។

មែនពិត ក្នុងរឿងនៃមាគណ្ឌិយសូត្រ នាងព្រាហ្មណី ក៏បានពោលពាក្យជាគាថាព័ន្ធនេះ ថា :

ក៏ដានជើង របស់បុគ្គលដែលជារាគចរិត ជាដានជើង
ផតត្រង់កណ្ដាល, ដានជើង របស់បុគ្គលដែលជាទោស



ចរិត ជាដានជើងធ្ងន់ជ្រៅទៅខាងមុខ, ដានជើង របស់
បុគ្គលដែលជាមោហចរិត ជាដានជើងធ្ងន់ទៅខាង
ក្រោយ, តែដានជើងដូច្នេះនេះ ជាដានជើងរបស់បុគ្គល
ដែលមានដំបូល ពោលគឺកិលេសបើកហើយ ។

សូម្បីការឈរ របស់បុគ្គលដែលជារាគចរិត មានអាការទីមទួនសុភាពរៀបរយគួរជាទីជ្រះថ្លា, ការឈរ របស់បុគ្គលដែលជាទោសចរិត មានអាការទ្រង់រឹង, ការឈរ របស់បុគ្គលដែលជាមោហចរិត មានអាការទ្រង់វឹកវរខ្វឹខ្វា ។ សូម្បីក្នុងកិរិយាអង្គុយ ក៏មានន័យដូចនេះដែរ ។

ឯបុគ្គលដែលជារាគចរិត មិនប្រញាប់ប្រញាល់ រណ្ដូងរណាង រៀបចំតាក់តែងទីដំណេកស្រួលបួលហើយសន្សឹមៗដេក ប្រមូលនូវអវយវៈតូចធំឲ្យមូលគ្នាហើយ ទើបប្រះខ្លួនដេក ដោយអាការដែលគួរឲ្យជ្រះថ្លា, មួយទៀត កាលត្រូវគេដាស់ឲ្យក្រោក ក៏មិនក្រោកយ៉ាងប្រញាប់ប្រញាល់ ឲ្យ (និយាយ) ពាក្យតបវិញទ្រង់ស្រទន់ ដូចជាបុគ្គលដែលមានសេចក្ដីរង្កៀសសង្ស័យហើយ ។

បុគ្គល ដែលជាទោសចរិត រៀបចំទីដំណេកតូងតាង ព្រូសប្រះតាមតែបាន ប្រះខ្លួនដេកខ្ទាំង ដេកចងចិញ្ចើម ធ្វើមុខក្រញូវ, មួយទៀត កាលត្រូវគេដាស់ឲ្យក្រោក ក៏ក្រោកយ៉ាងប្រញាប់ ឲ្យពាក្យឆ្លើយតបទ្រង់ដូចជាក្រោធខឹង ។

បុគ្គលមោហចរិត រៀបចំដំណេកមានសណ្ឋានមិនល្អ ប្រះខ្លួនដេកច្រើនប្រផេងប្រផាង ច្រើនដេកផ្កាប់មុខ, មួយទៀត កាលត្រូវគេដាស់ឲ្យក្រោក ច្រើនធ្វើសំឡេងថ្ងូរហ៊ុះៗ ក្រោកឡើងយឺត ។

ក៏ព្រោះបុគ្គល ៣ ខាងចុង មានបុគ្គលដែលជាសទ្ធាចរិត ជាដើម ជាបុគ្គលដែលមានចំណែកស្មើគ្នានឹងបុគ្គល ៣ ខាងដើម មានបុគ្គលដែលជារាគចរិតជាដើម ព្រោះហេតុនោះ ឥរិយាបថ សូម្បីនៃបុគ្គល ៣ ខាងចុង មានបុគ្គលដែលជាសទ្ធាចរិតជាដើមនោះ ក៏មានន័យដូចគ្នានេះដែរ ។ បណ្ឌិត គប្បីសំដែងចរិយាទាំងឡាយ ដោយឥរិយាបថ ជាមុន តាមន័យដែលបានពោលមកនេះឯង ។

(លក្ខណៈដោយកិច្ច)

គប្បីជ្រាបន័យ ក្នុងពាក្យថា “ដោយកិច្ច” ដូចតទៅ : ក៏ក្នុងកិច្ចទាំងឡាយ មានការបោសសំអាតជាដើម បុគ្គលដែលជារាគចរិត ចាប់អំបោសហើយ មិនប្រញិបប្រញាប់ មិនពង្រាយខ្សាច់ ឲ្យខ្ចាតខ្ចាត់ខ្ចាយ បោសបានស្អាតស្មើល្អ ដូចជាក្រាលរបៀបនៃផ្កាឈើភ្ញីង ។

បុគ្គលទោសចរិត ចាប់អំបោសរាងមាំទាំ ទ្រង់ប្រញិបប្រញាប់ ធ្វើដីខ្សាច់ឲ្យពូនឡើងទាំងសងខាង មានសំឡេងបោសខ្លាំង បោសបានស្អាតល្អ តែមិនស្មើ ។

បុគ្គលដែលជាមោហចរិត ចាប់អំបោសរាងធូរខ្សុយ គ្រវាសទៅគ្រវាសមក បោសមិនបានស្អាត មិនបានរាបស្មើ ។

ក៏ក្នុងការបោសសំអាត មានឥរិយាបថ យ៉ាងណាមិញ, ក្នុងកិច្ចទាំងពួងទាំងឡាយ សូម្បីមានការបោក និង ការជ្រលក់ចីពរជាដើម ក៏មានឥរិយាបថ ដូច្នោះដែរ ។

បុគ្គលដែលជារាគចរិត ច្រើនធ្វើកិច្ចការល្អិតម៉ត់ចត់ ល្អត្រឹមត្រូវ និង ធ្វើដោយគោរព ។ បុគ្គលដែលជាទោសចរិត ធ្វើការងាររាងមាំទាំ រឹងប៉ឹង តែមិនរៀបរយល្អ ។ បុគ្គលដែលជាមោហចរិត ជាអ្នកធ្វើ



ការងារច្រើនមិនម៉ត់ចត់ ស្មុគស្មាញមិនរៀបរយ និង មិនចេះចប់ ។ ក៏សូម្បីការគ្រងចីពរ របស់បុគ្គលដែលជារាគចរិត ក៏មិនតឹងពេក មិនធូរពេក ជាបរិមណ្ឌលគួរជាទីជ្រះថ្លា ។ ការគ្រងចីវរ របស់បុគ្គលដែលជាទោសចរិត រាងតឹងពេក និង មិនជាបរិមណ្ឌល ។ ការគ្រងចីពរ របស់បុគ្គលដែលជាមោហចរិត រាងធូរ រយីករយាកខ្ជីខ្ជា ។ សូម្បីបុគ្គលទាំងឡាយ ៣ ខាងចុង មានបុគ្គលដែលជាសទ្ធាចរិតជាដើម ក៏គប្បីជ្រាបតាមទំនងនៃបុគ្គលទាំងឡាយ ៣ ខាងដើម មានបុគ្គលដែលជារាគចរិតជាដើមនោះឯង ព្រោះជាអ្នកប្រហាក់ប្រហែលគ្នានឹងបុគ្គលទាំងនោះ ។ បណ្ឌិត គប្បីសំដែងចរិយាទាំងឡាយ ដោយកិច្ច យ៉ាងដូច្នេះឯង ។

(លក្ខណៈដោយការបរិភោគ)

ក្នុងពាក្យថា “ដោយការបរិភោគ” មានន័យ ដូចតទៅនេះ : បុគ្គលដែលជារាគចរិត ច្រើនពេញចិត្តបរិភោគនូវភោជនស្និទ្ធ (ជាទីពេញចិត្ត) និង បង្អែម ។ ក៏កាលនឹងបរិភោគ ធ្វើពំនូតបាយ ឲ្យជាបរិមណ្ឌល មិនឲ្យធំហួសពេក ជាអ្នកស្គាល់រសជាត បរិភោគមិនប្រញិបប្រញាប់ បានវត្ថុអ្វីបន្តិចបន្តួចដែលល្អ ក៏ឆាប់ត្រេកអរ ។

បុគ្គលទោសចរិត ច្រើនពេញចិត្តបរិភោគនូវភោជនដែលសៅហ្មង និង ម្ជូរ ។ ក៏កាលនឹងបរិភោគ ធ្វើពំនូតបាយឲ្យទូញថ្ពាល់ ជាអ្នកមិនស្គាល់នូវរសជាត បរិភោគប្រញិបប្រញាប់ បានវត្ថុអ្វីបន្តិចបន្តួច ដែលមិនល្អ ក៏ឆាប់តូចចិត្ត ។

បុគ្គលដែលជាមោហចរិត ជាអ្នកបរិភោគភោជន មិនទៀងទាត់ ក៏កាលនឹងបរិភោគ ធ្វើនូវពំនូតបាយឲ្យតូច មិនជាបរិមណ្ឌល ចោលគ្រាប់បាយ រោយរាយក្នុងភាជនៈ ធ្វើឲ្យប្រឡាក់មាត់ មានចិត្តរាយមាយ

បរិភោគ គិតពីនេះពីនោះបណ្តើរ ។ សូម្បីបុគ្គលទាំងឡាយ ៣ ខាងចុង មានបុគ្គលដែលជាសទ្ធាចរិតជាដើម ក៏គប្បីជ្រាប តាមទំនងនៃបុគ្គលទាំងឡាយ ៣ ខាងដើម មានបុគ្គលដែលជារាគចរិតជាដើមនោះឯង ព្រោះជាអ្នកប្រហាក់ប្រហែលគ្នានឹងបុគ្គលទាំងនោះ ។ បណ្ឌិត គប្បីសំដែងចរិយា ដោយការបរិភោគ យ៉ាងដូច្នេះ ។

(លក្ខណៈដោយការឃើញជាដើម)

ក្នុងពាក្យថា "ដោយអាការមានការឃើញជាដើម" មានន័យ ដូចតទៅនេះ : បុគ្គលដែលជារាគចរិត ឃើញរូបដែលជាទីរីករាយចិត្ត សូម្បីតែបន្តិចបន្តួច ក៏ខំសំឡឹងមើល អស់កាលយ៉ាងយូរ ដូចជាកើតសេចក្តីព្រឺព្រួច ឆាប់ជាប់ចិត្ត ក្នុងគុណតែបន្តិចបន្តួច មិនសូវប្រកាន់ទោសគេ ទោះបីពិតក៏ដោយ កាលនឹងចេញដើរទៅ ក៏ជាអ្នកមិនប្រាថ្នានឹងចេញទៅឡើយ ចេញទៅទាំងសេចក្តីអាឡោះអាល័យ ។

បុគ្គលដែលជាទោសចរិត ឃើញរូបដែលមិនជាទីរីករាយចិត្ត សូម្បីបន្តិចបន្តួច ក៏សំឡឹងមើលមិនបានយូរ ដូចជាលំបាកណាស់ ឆាប់អាក់អន់ចិត្ត ក្នុងទោសសូម្បីតែបន្តិចបន្តួច មិនសូវជាទទួលយកគុណសូម្បីពិតក៏ដោយ កាលនឹងចេញដើរទៅ ក៏ជាអ្នកប្រាថ្នានឹងចេញទៅភ្លាមៗ ចេញទៅទាំងមិនមានសេចក្តីអាឡោះអាល័យ ។

បុគ្គលដែលជាមោហចរិត ឃើញរូបឯណាមួយហើយ ច្រើនតែបណ្តោយទៅតាមគេ ឮគេនិន្ទា ក៏និន្ទាតាម ឮគេសរសើរ ក៏សរសើរតាម តែបើខ្លួនម្នាក់ឯង ច្រើនជាអ្នកព្រងើយៗ ព្រោះឧបេក្ខាដែលល្ងង់ខ្លៅ ។ សូម្បីក្នុងអាការទាំងឡាយ មានការស្តាប់សំឡេងជាដើម ក៏មានន័យដូចនេះដែរ ។



ចំណែកបុគ្គលទាំងឡាយបី ខាងចុង មានបុគ្គលដែលជាសទ្ធាចរិតជាដើម ក៏គប្បីជ្រាប តាមទំនងនៃបុគ្គលទាំងឡាយ ៣ ខាងដើម មានបុគ្គលដែលជារាគចរិតជាដើមនោះឯង ព្រោះជាអ្នកប្រហាក់ប្រហែលគ្នានឹងបុគ្គលទាំងនោះ ។ បណ្ឌិត គប្បីសំដែងចរិយា ដោយការឃើញរូបជាដើម យ៉ាងដូច្នេះឯង ។

(លក្ខណៈដោយធម្មប្បវត្តិ)

ក្នុងពាក្យថា "និងដោយការប្រព្រឹត្តិទៅនៃធម៌នុ៎ះឯង" មានន័យដូចតទៅនេះ: ក៏ធម៌ទាំងឡាយ គឺ: មាយា, ភាពជាអ្នកអួតអាង, ការប្រកាន់ខ្លួន, ភាពជាអ្នកប្រាថ្នាលាមក, ភាពជាអ្នកប្រាថ្នាធំ, ភាពជាអ្នកមិនសន្តោស, ការក្រអឺតក្រទម, ភាពជាអ្នកឆ្មើងឆ្មៃ យ៉ាងនេះជាដើម រមែងប្រព្រឹត្តទៅយ៉ាងច្រើន ដល់បុគ្គលដែលជារាគចរិត ។

ធម៌ទាំងឡាយ គឺ: សេចក្តីក្រោធ, ការចងក្រោធទុក, លុបគុណគេ, លើកកំពស់ស្មើនឹងគេ, ប្រណែន, កំណាញ់យ៉ាងនេះជាដើម រមែងប្រព្រឹត្តទៅជាច្រើន ដល់បុគ្គលដែលជាទោសចរិត ។

ធម៌ទាំងឡាយ គឺ: សេចក្តីរួញរា, សេចក្តីរាយមាយ, សេចក្តីអណ្តែតអណ្តូង, សេចក្តីក្តៅក្រហាយ, សេចក្តីសង្ស័យ, ការប្រកាន់ត្រង់ណា មាំត្រង់ណោះ, ការលះបង់បានដោយក្រ យ៉ាងនេះជាដើម រមែងប្រព្រឹត្តទៅយ៉ាងច្រើន ដល់បុគ្គលដែលជាមោហចរិត ។

ធម៌ទាំងឡាយ គឺ ភាពជាអ្នកមានចាគៈលះរួចហើយ, ភាពជាអ្នកចង់ឃើញនូវព្រះអរិយ, ភាពជាអ្នកចង់ស្តាប់ធម៌, ភាពជាអ្នកច្រើនដោយសេចក្តីរីករាយ, ភាពជាអ្នកមិនអួតអាង, ភាពជាអ្នកមិនមានមាយា, ជ្រះថ្លា ក្នុងហេតុដែលគួរជ្រះថ្លា យ៉ាងនេះជាដើម រមែងប្រព្រឹត្ត

ទៅយ៉ាងច្រើន ដល់បុគ្គលដែលជាសទ្ធាចរិត ។

ធម៌ទាំងឡាយ គឺៈ ជាអ្នកដែលគេប្រដៅងាយ, ភាពជាអ្នកមានកល្យាណមិត្រ, ភាពជាអ្នកស្គាល់ប្រមាណ ក្នុងការបរិភោគ, មានសតិ និង សម្បជញ្ញៈ, ជាអ្នកភ្ញាក់រឭករឿយៗ, សង្វេគក្នុងហេតុ ដែលគួរសង្វេគ, កាលកើតសេចក្ដីសង្វេគច្រើន តាំងទុកនូវសេចក្ដីព្យាយាម ដោយឧបាយនៃប្រាជ្ញា យ៉ាងនេះជាដើម រមែងប្រព្រឹត្តទៅ យ៉ាងច្រើន ដល់បុគ្គលដែលជាពុទ្ធិចរិត ។

ធម៌ទាំងឡាយ គឺៈ ភាពជាអ្នកនិយាយច្រើនជាងធ្វើ, ភាពជាអ្នកត្រេកអរក្នុងពួក, ភាពជាអ្នកមិនត្រេកអរ ក្នុងការសាងកុសល, ភាពជាអ្នកកាន់ការមិនចំពោះ, ពេលយប់បែកគំនិតហុយដូចផ្សែង, ពេលថ្ងៃចាត់ការក្ដៅដូចភ្លើងឆេះ, គំនិតរើរួសរេច្ឆា យ៉ាងនេះជាដើម រមែងប្រព្រឹត្តទៅ យ៉ាងច្រើន ដល់បុគ្គលដែលជាវិតក្កចរិត ។

បណ្ឌិតគប្បីសំដែងចរិយា ដោយធម្មប្បវត្តិ យ៉ាងនេះឯង ។ តែព្រោះថា វិធីសំដែងនូវចរិយានេះ មិនបានមកក្នុងបាលី មិនបានមកក្នុងអដ្ឋកថា ដោយអាការទាំងពួង, ខ្ញុំពោលហើយ តាមលំអាននៃមតិរបស់អាចារ្យតែម្យ៉ាង ហេតុនោះ បណ្ឌិត មិនគួរជឿតាម ដោយយកជាសារៈឡើយ ។ ព្រោះថា សូម្បីបុគ្គលទាំងឡាយ មានបុគ្គលដែលជាទោសចរិតជាដើម ជាអ្នកនៅដោយសេចក្ដីមិនប្រមាទ ក៏មិនអាចដើម្បីនឹងធ្វើនូវអ្វីផ្សេងៗ មានឥរិយាបថជាដើម ដែលបានពោលមកហើយ ចំពោះបុគ្គលដែលជារាគចរិតបានឡើយ ។ មួយទៀត អាការទាំងឡាយមានឥរិយាបថជាដើម ដែលមានលក្ខណៈផ្សេងៗ គ្នា នឹងកើតឡើង ដល់បុគ្គលដែលមានចរិត ប្របូកប្របល់គ្នាតែម្នាក់ឯង មិនបានឡើយ ។



ឯវិធីសំដែងចរិតនេះណា ដែលពោលមកហើយ ក្នុងអដ្ឋកថាទាំងឡាយ, វិធីសំដែងចរិយានោះឯង បណ្ឌិត គប្បីជឿ ដោយយកជាសារៈបាន ។

សមដូចជាលោក ពោលទុកហើយថា “អាចារ្យ អ្នកដែលបាននូវចេតោបរិយញ្ញាណ ស្គាល់នូវចរិយាហើយ ទើបប្រាប់កម្មដ្ឋាន, អាចារ្យដែលមិនបាននូវចេតោបរិយញ្ញាណក្រៅនេះ គប្បីសាកសួរអន្តេវាសិក” ដូច្នេះ ។ ហេតុនោះ នឹងសំគាល់ដឹងបានថាៈ បុគ្គលនេះ ជាអ្នកមានរាគចរិត បុគ្គលនោះ ជាអ្នកមានចរិតណាមួយ បណ្ដាចរិតទាំងឡាយមានទោសចរិតជាដើម ក៏ព្រោះចេតោបរិយញ្ញាណ ឬក៏ ព្រោះសាកសួរនូវបុគ្គលនោះហើយ ទើបនឹងដឹងបាន ដូច្នេះឯង ។

(៧៤) ឯសេចក្ដីវិនិច្ឆ័យ ក្នុងបញ្ហាកម្មនេះថា **“និងអ្វីទៅជាទីសប្បាយដល់បុគ្គលដែលមានចរិតបែបណា?”** ដូច្នេះ បណ្ឌិតគប្បីជ្រាបដូចតទៅនេះ :

**(សប្បាយៈ នៃបុគ្គលមានរាគចរិត)**

ចំពោះបុគ្គលរាគចរិត ជាដំបូង សេនាសនៈ គឺជាទីសេនាសនៈដែលលើកជាទីតាំង ដែលមិនទាន់ជម្រះលាងហើយ សេនាសនៈ ដែលនៅជាប់នឹងផែនដី ញកភ្នំ ដែលមិនទាន់បានតាក់តែងហើយ បណ្ដាទីសេនាសនៈទាំងឡាយ មានកុដិធ្វើពីស្មៅ និង សាលាធ្វើពីស្លឹកជាដើម សេនាសនៈណានីមួយ សេនាសនៈ ដែលប្រឡាក់ទៅដោយល្អងធូលីពោរពេញទៅដោយអាចម៍ប្រជៀវ ពុកបាក់បែក ខ្ពស់ហួសពេក ឬក៏ទាបហួសពេក សោះកក្រោះ មានភ័យ មានផ្លូវដើរមិនស្អាត និង មិនរាបស្មើ ក្នុងទីសេនាសនៈឯណា សូម្បីគ្រែ និង តាំង ក៏រខេករខាកសម្បុរអាក្រក់ ពោរពេញទៅដោយសត្វសង្កើច កាលបើបុគ្គលឃើញ

សេនាសនៈណាមួយប៉ុណ្ណោះ ក៏កើតសេចក្ដីខ្ពើមរអើម, សេនាសនៈដូច្នោះ ជាសប្បាយៈ,

សំពត់ស្លៀកពាក់(ស្បង់ចីវរ) មានជាយដាច់ដាចហើយ រោយរាយទៅដោយសរសៃអំបោះ រយីងរយូង រណែងរណោង ដូចជានំអំបែង មានសម្ផស្សគគ្រាតគគ្រើម ដូចជាសំពត់រនាំង សៅហ្មង ធ្ងន់ ប្រើប្រាស់លំបាក ជាសប្បាយៈ,

សូម្បីបាត្រ គឺជាបាត្រដី មានពណ៌អាក្រក់ ឬក៏ ជាបាត្រដែកដែលធ្ងុះដោយស្នៀត និង ធ្ងន់ធ្ងន់ មានទ្រង់ទ្រាយអាក្រក់ គួរឲ្យខ្ពើម ដូចជាអំបែងក្បាល រមែងសមគួរ,

សូម្បីផ្លូវភិក្ខាចារ ក៏ជាផ្លូវដែលមិនជាទីពេញចិត្ត មិនជិតពីភូមិស្រុក ជាផ្លូវមិនរាបស្មើ រមែងសមគួរ,

សូម្បីស្រុកភូមិ នៃភិក្ខាចារ ជាស្រុកភូមិដែលពួកភិក្ខុត្រាច់ទៅ ដូចជាមិនមានមនុស្សឃើញ ជាស្រុកភូមិដែលពួកមនុស្សទាំងឡាយ និមន្តភិក្ខុដែលមិនបានភិក្ខា សូម្បីក្នុងត្រកូលមួយហើយ ក៏ចេញទៅ ឲ្យចូលទៅកាន់រោងឆាន់ ដោយពាក្យថា “បពិត្រព្រះគុណម្ចាស់ដ៏ចំរើន សូមព្រះគុណម្ចាស់និមន្តមក(ទីនេះ)” ដូច្នេះ ថ្វាយយាគូ និងភត្តហើយ កាលនឹងទៅ ក៏ទៅមិនបែរមើល ដូចគៀងគោញី បញ្ចូលក្រោល ហើយទៅមិនខ្វីបែរមើល, ផ្លូវភិក្ខាចារដូច្នោះ គួរ,

សូម្បីពួកមនុស្សដែលអង្គាស ជាពួកខ្ញុំបម្រើ ឬក៏ ពួកកម្មករ មានស្បែកអាក្រក់ មិនគួរគេយគន់ សំពត់ស្លៀកពាក់សៅហ្មង មានក្លិនស្អុយគួរខ្ពើមណាស់ អង្គាសដោយអាការៈមិនកោតក្រែង ដូចជាចោលយាគូ និង ភត្តដូច្នោះឯង, ពួកមនុស្ស ដែលអង្គាសដូច្នោះ ជាសប្បាយៈ,



សូម្បីយាគូ, ភត្ត និង របស់ដែលគួរឆាន់ សៅហ្មង ពណ៌អាក្រក់ សម្រេចដោយអបរណ្ណជាត មានស្រងែ, ស្រូវគែលលក និង ចុងអង្ករ ជាដើម គ្រឿងសម្ភប្រកបដោយទឹកដោះជូរ, ទឹកជ្រក់ និង អន្ទក់ដែលចាស់ៗ (អន្ទក់សល់) យ៉ាងណាមួយ ក៏បានដែរ គ្រាន់តែបំពេញពោះតែម្យ៉ាង រមែងសមគួរ,

សូម្បីឥរិយាបថ នៃបុគ្គលដែលជារាគចរិតនោះ ជាការឈរ ឬក៏ចង្ក្រម រមែងសមគួរ,

អារម្មណ៍ ក៏គឺបណ្ដាវណ្ណកសិណ មាននីលកសិណជាដើម យ៉ាងណាមួយ មានពណ៌មិនស្អាត រមែងសមគួរ, នេះ គឺជាសប្បាយ របស់បុគ្គលដែលជារាគចរិត ដោយប្រការដូច្នេះឯង ។

(សប្បាយៈ នៃបុគ្គលទោសចរិត)

ចំពោះបុគ្គលដែលជាទោសចរិត សេនាសនៈ ជាទីសេនាសនៈដែលមិនខ្ពស់ពេក មិនទាបពេក បរិបូណ៌ដោយម្លប់ និង ទឹក មានជញ្ជាំង, សសរ និង ជណ្ដើរល្អសមរម្យ មានការតាក់តែង ដោយឈើមានផ្កា និង វល្លិ យ៉ាងល្អរៀបរយ ស្រស់បំព្រង ដោយចិត្តកម្ម មានគំរូផ្សេងៗ គ្នា មានផ្ទៃនៃភូមិភាគរាបស្មើ, ស្និទ្ធ និង ទន់ ប្រដាប់តាក់តែងពិដាន ដោយកម្រងផ្កា និង សំពត់ មានពណ៌ដ៏វិចិត្រ មានកម្រាលគ្រែ និង តាំងដ៏ល្អស្អាត គួរជាទីរីករាយ ដែលបុគ្គលក្រាលទុកល្អហើយ មានផ្កាឈើ គ្រឿងអប់ និង គ្រឿងក្រអូប ដាក់ទុកដើម្បីអប់ក្លិន ក្នុងទីនោះៗ ដូចជាវិមាននៃព្រហ្ម, សេនាសនៈណាមួយ គ្រាន់តែឃើញភ្លាម ក៏ញ៉ាំងបីតិ និង ប្រាមោជ្ជៈឲ្យកើត, សេនាសនៈបែបនេះ ជាសប្បាយៈ,

ចំណែកឯផ្លូវដើរ នៃសេនាសនៈនោះ ជាផ្លូវដែលជៀសផុតអំពី

អន្តរាយគ្រប់បែបយ៉ាង មានផ្ទៃរាបស្មើល្អ ប្រដាប់តាក់តែងហើយ,

ឯគ្រឿងបរិក្ខារ សំរាប់សេនាសនៈ ក្នុងសេនាសនៈនោះ គួរតែកុំឲ្យមានច្រើនពេក គឺមានត្រឹមតែគ្រែ និង តាំងតែមួយប៉ុណ្ណោះ ក៏គួរ ដើម្បីកាត់ផ្តាច់នូវទីអាស្រ័យ របស់ពួកសត្វកណ្តូប, សង្កើច, ពស់ និង កណ្តុរជាដើម,

សូម្បីគ្រឿងសំលៀកពំពាក់ របស់បុគ្គលដែលជាទោសចរិតនោះ សមគួរជាសំពត់ណាៗ មួយ បណ្តាសំពត់ក្រចៅ, សំពត់សោមារៈ, សំពត់សូត្រ, សំពត់ធ្វើពីកប្បាស, និង សំពត់សម្បកឈើ ដែលមានសាច់ម៉ត់ល្អជាដើម ដែលល្អប្រណីត, (នឹងយក) សំពត់នោះៗ (ធ្វើ) ជាចីវរមួយជាន់ ឬក៏ ពីរជាន់ ក៏ដោយ ជាចីវរស្រាល ជ្រលក់បានល្អ មានពណ៌ល្អបរិសុទ្ធ ដោយសមគួរដល់សមណៈ,

សូម្បីបាត្រ ក៏គួរជាបាត្រដែក មានទ្រង់ទ្រាយយ៉ាងល្អ ដូចជាពពុះទឹក រលីងស្រិល មិនមានប្រេះ ដូចជាកែវមណី អប់ក្លិនយ៉ាងល្អ មានពណ៌ស្អាតបរិសុទ្ធ ដោយសមគួរដល់សមណៈ,

ផ្លូវភិក្ខាចារ គួរជាផ្លូវដែលផុតអំពីអន្តរាយ រាបស្មើ គួរជាទីរីករាយចិត្ត មិនឆ្ងាយពេក មិនជិតពេកអំពីភូមិស្រុក,

សូម្បីភិក្ខាចារគ្រាម ក៏គួរជាទីដែលមនុស្សទាំងឡាយ ត្រេកអរ ថា “ព្រះគុណម្ចាស់ដ៏ចំរើន នឹងមកក្នុងពេលនេះ” ដូច្នេះហើយ ឲ្យគេក្រាលអាសនៈ ក្នុងទីដែលបុគ្គលស្រោចទឹក និង បោសសំអាតរួចហើយ ក៏ទៅទទួលយកបាត្រ និមន្តឲ្យចូលផ្ទះ ឲ្យគង់លើអាសនៈ ដែលគេបានក្រាលហើយ អង្គាសដោយដៃខ្លួនឯង ដោយគោរព,

ចំណែកឯបុគ្គលដែលអង្គាស ជាបុគ្គលដែលមានរូបរាងស្អាត គួរ



ជាទីជ្រះថ្លា ឲ្យងូតទឹក ដុសលាងស្អាតល្អហើយ ក្រអូបឈ្ងុយឈ្ងប់ទៅដោយក្លិនធូបអប់ និង ផ្កាឈើ ប្រដាប់តាក់តែងកាយ ដោយសំពត់ និង គ្រឿងអាភរណៈ មានពណ៌ផ្សេងៗ និង ល្អស្អាត ដែលជាទីពេញចិត្ត ធ្វើការអង្គាស ដោយសេចក្តីគោរពដូច្នោះ ជាទីសប្បាយ ដល់បុគ្គលដែលជាទោសចរិត,

សូម្បីយាគូ ភត្ត និង របស់ដែលគួរទំពា ក៏គួរជារបស់ដែលដល់ព្រមដោយពណ៌, ក្លិន និង រស មានឱជារសឆ្ងាញ់ គួរជាទីពេញចិត្ត ដ៏ល្អប្រណីត គ្រប់បែបយ៉ាង មានតាមសេចក្តីត្រូវការ,

សូម្បីឥរិយាបថ របស់បុគ្គលដែលជាទោសចរិតនោះ ក៏គួរជាឥរិយាបថដេក ឬក៏ ទីអង្គុយ,

សូម្បីអារម្មណ៍ ក៏គួរជាកសិណណាមួយ បណ្តាវណ្ណកសិណ មាននីលកសិណជាដើម ដែលមានពណ៌ល្អបរិសុទ្ធស្អាត ដូច្នេះឯង ។

នេះ គឺជាទីសប្បាយ របស់បុគ្គលដែលជាទោសចរិត ។

(សប្បាយៈ នៃបុគ្គលមោហចរិត)

ចំពោះបុគ្គលដែលជាមោហចរិត សេនាសនៈក៏គួរជាទីសេនាសនៈ ដែលមានមុខឆ្ពោះទៅរកទិស មិនចង្អៀតពេក ជាទីដែលទិសទាំងឡាយប្រាកដ បើកចំហ សំរាប់បុគ្គលដែលអង្គុយ, ទីចង្ក្រម គួរក្នុងឥរិយាបថទាំងឡាយ, ចំណែកអារម្មណ៍ របស់បុគ្គលដែលជាមោហចរិតនោះ មិនគួរជាកសិណតូច មានខ្នាតប៉ុនចង្អេរ ឬក៏ ប៉ុនចាន ។ ព្រោះថា ក្នុងឱកាសដែលចង្អៀត ចិត្ត នឹងដល់នូវសេចក្តីវង្វេង រឹតតែច្រើនឡើង ព្រោះហេតុនោះ គួរជាកសិណ ដែលមានខ្នាតទូលាយ ជាកសិណដែលធំ ។ សប្បាយៈដ៏សេស ក៏ដូចជាសប្បាយៈ ដែលបានពោលមកហើយ

នៃបុគ្គលដែលជាទោសចរិត យ៉ាងដូច្នេះឯង, នេះជាសប្បាយៈនៃបុគ្គលដែលជាមោហចរិត ។

(សប្បាយៈ នៃបុគ្គលសទ្ធាចរិត)

វិធីដែលបានពោលហើយ ក្នុងបុគ្គលដែលជាទោសចរិតទាំងអស់ ក៏ជាសប្បាយៈ នៃបុគ្គលដែលជាសទ្ធាចរិត និង ក្នុងអារម្មណ៍ទាំងឡាយ សូម្បីអនុស្សតិកម្មដ្ឋាន ក៏គួរដល់បុគ្គលដែលជាសទ្ធាចរិតនោះផងដែរ ។

ពាក្យដែលគួរពោលថា "ក្នុងវត្ថុទាំងឡាយមានសេនាសនៈជាដើម វត្ថុឈ្មោះនេះ មិនជាទីសប្បាយនៃបុគ្គលដែលជាពុទ្ធិចរិត" មិនមានទេ ។

(សប្បាយៈ នៃបុគ្គលវិតក្កចរិត)

សម្រាប់បុគ្គលវិតក្កចរិត ទីសេនាសនៈ មិនគួរជាទីសេនាសនៈ ដែលបើកចំហ មានមុខឆ្ពោះទៅកាន់ទិស ជាទីដែលសួនច្បារ, ព្រៃឈើ និង ស្រះបោក្ខរណី ដែលជាទីរីករាយចិត្ត តាមលំដាប់នៃស្រុក, និគម និង ជនបទ និង ភ្នំដែលមានពណ៌ខៀវស្រងាត់ ប្រាកដដល់បុគ្គលដែលអង្គុយហើយ។ ព្រោះទីសេនាសនៈនុ៎ះ ជាបច្ច័យនៃការត្រាច់ទៅនៃវិតក្កដោយពិត ។ ព្រោះហេតុនោះ បុគ្គលដែលជាវិតក្កចរិត គួរនៅក្បែរមាត់ប្រកដែលជ្រៅ ក្នុងសេនាសនៈ ដែលមានព្រៃបិទបាំង ដូចជាញកនៃពោះដំរី, គុហាព្រះមហិន្ទ ។

សូម្បីអារម្មណ៍ របស់បុគ្គលដែលជាវិតក្កចរិតនោះ ក៏មិនគួរជាកសិណ ធំទូលាយពេកទេ ។ ព្រោះកសិណដូច្នោះ ជាបច្ច័យដល់ការត្រាច់រង្គាត់ទៅ ដោយអំណាចនៃវិតក្កៈ ។ ប៉ុន្តែគួរជាកសិណដែលមានខ្នាតតូច ។ សប្បាយៈដ៏សេស ក៏ដូចជាសប្បាយៈដែលបានពោលមកហើយ សម្រាប់បុគ្គលដែលជារាគចរិតនុ៎ះដែរ ។ នេះ គឺជាសប្បាយៈ



របស់បុគ្គលដែលជាវិតក្កចរិត ។

សេចក្តីអធិប្បាយនេះ ជាសេចក្តីពិស្តារ នៃចរិយាដែលមកហើយ ក្នុងពាក្យនេះថា "កម្មដ្ឋាន ដែលសមគួរ ដល់ចរិយារបស់ខ្លួន" ដោយការកំណត់ប្រភេទ, ដើមហេតុ, វិធីប្រាប់ និង វត្ថុដែលជាទីសប្បាយ ។

តែកម្មដ្ឋាន ដែលសមគួរដល់ចរិយា ខ្ញុំមិនទាន់ធ្វើ ឲ្យជាក់ច្បាស់ហើយ ដោយអាការទាំងពួងជាមុនឡើយ ។ ព្រោះកម្មដ្ឋាននោះ នឹងមកប្រាកដច្បាស់ ដោយខ្លួនឯងពិត ក្នុងសេចក្តីពិស្តារ នៃបទមាតិកាដែលនឹងពោលជាលំដាប់ ។ ហេតុនោះ ក្នុងពាក្យដែលខ្ញុំពោលហើយថា "កាន់យកនូវកម្មដ្ឋានណាមួយ ក្នុងកម្មដ្ឋានទាំង ៤០" ដូច្នេះនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុងកម្មដ្ឋាន ដោយអាការៈទាំង ១០ នេះ ជាមុន គឺ :

១- សង្ខាតនិទ្ទេស ដោយដឹងការសំដែងចំនួននៃកម្មដ្ឋាន,
២- ឧបចារប្បនាវហ ដោយដឹងកម្មដ្ឋានដែលនាំមកនូវឧបចារជ្ឈាន និង កម្មដ្ឋានដែលនាំមកនូវអប្បនាឈាន,
៣- ឈានប្បភេទ ដោយដឹងប្រភេទរបស់ឈាន,
៤- សមតិក្កម ដោយដឹងវិធីប្រព្រឹត្តិកន្លងរបស់កម្មដ្ឋាន,
៥- វឌ្ឍនាវឌ្ឍន ដោយដឹងកម្មដ្ឋានដែលសមគួរដល់ការចំរើនថែម និង មិនគួរចំរើនថែម,
៦- អារម្មណ ដោយដឹងអារម្មណ៍របស់កម្មដ្ឋាន,
៧- ភូមិ ដោយដឹងភូមិរបស់កម្មដ្ឋាន,
៨- គហណ ដោយដឹងកិច្ចដែលត្រូវរៀនយកកម្មដ្ឋាន,
៩- បច្ចយ ដោយដឹងបច្ច័យរបស់កម្មដ្ឋាន,
១០- ចរិយានុកូល ដោយដឹងកម្មដ្ឋានដែលសមគួរដល់ចរិយា ។

(សទ្ធាគនិទ្ទេស)

(៧៥) ក្នុងបទមាតិកាទាំងនោះ បទថា “ដោយដឹងការសំដែងចំនួននៃកម្មដ្ឋាន” មានវិនិច្ឆ័យ ដូចតទៅនេះ : ក៏ពាក្យថា “ក្នុងកម្មដ្ឋានទាំង ៤០” នេះ គឺខ្ញុំពោលហើយ, ក្នុងពាក្យនោះ កម្មដ្ឋានទាំងឡាយ ៤០ នេះ គឺ កសិណ ១០, អសុភ ១០, អនុស្សតិ ១០, ព្រហ្មវិហារ ៤, អារូប្ប ៤, សញ្ញា ១, វវដ្ឋាន ១ ។

ក្នុងកម្មដ្ឋានទាំងឡាយនោះ កសិណទាំងឡាយ ១០ គឺ :

(១) បឋវីកសិណ យកដីធ្វើជាវង់កសិណ,

(២) អាបោកសិណ យកទឹកធ្វើជាកសិណ,

(៣) តេជោកសិណ យកភ្លើងធ្វើជាកសិណ,

(៤) វាយោកសិណ យកខ្យល់ធ្វើជាកសិណ,

(៥) នីលកសិណ យកវត្ថុមានពណ៌ខៀវធ្វើជាកសិណ,

(៦) បីតកសិណ យកវត្ថុមានពណ៌លឿងធ្វើជាកសិណ,

(៧) លោហិតកសិណ យកវត្ថុពណ៌ក្រហមធ្វើជាកសិណ,

(៨) ឱទាតកសិណ យកវត្ថុមានពណ៌-ស ធ្វើជាកសិណ,

(៩) អាលោកកសិណ យកពន្លឺធ្វើជាកសិណ,

(១០) បរិច្ឆិន្នាកាសកសិណ យកអាកាសដែលកំណត់ជាកសិណ ។

**អសុភទាំងឡាយ ១០ គឺ**

(១) ឧទ្ធុមាតក អសុភ ហើមពោរប៉ោងឡើង,

(២) វិនីលក អសុភ ហើមមានពណ៌ខៀវដោយច្រើន,

(៣) វិបុព្វក អសុភ ហើមមានខ្ទុះហូរទៅ ក្នុងខាងលើ-ក្រោម,



(៤) វិច្ឆិទ្ទក អសុភដែលគេកាត់ដាច់ពាក់កណ្ដាលខ្លួន,

(៥) វិក្ខាយិតក អសុភដែលសត្វខាំកកេរស៊ីរលុះរលួយ,

(៦) វិក្ខិត្តក អសុភដែលគេកាត់ដាច់ចេញពីគ្នាជាកំណាត់ៗ,

(៧) ហតវិក្ខិត្តក អសុភដែលគេកាប់សាប់មានស្នាមសាំរវាម,

(៨) លោហិតក អសុភដែលមានឈាមហូរស្រោចស្រព,

(៩) បុឡុវក អសុភដែលមានដង្កូវចុះហូរចេញតាមទ្វារទាំង៩,

(១០) អដ្ឋិក អសុភដែលមានតែរាងឆ្អឹងរាត់រាយខ្ចាត់ខ្ចាយ ។

**អនុស្សតិទាំងឡាយ ១០ នេះ គឺ**

(១) ពុទ្ធានុស្សតិ ការរឭករឿយៗមានពុទ្ធគុណជាអារម្មណ៍,

(២) ធម្មានុស្សតិ ការរឭករឿយៗមានធម្មគុណជាអារម្មណ៍,

(៣) សង្ឃានុស្សតិ ការរឭករឿយៗមានសង្ឃគុណជាអារម្មណ៍,

(៤) សីលានុស្សតិ ការរឭករឿយៗមានសីលគុណជាអារម្មណ៍,

(៥) ចាគានុស្សតិ ការរឭករឿយៗមានចាគគុណជាអារម្មណ៍,

(៦) ទេវតានុស្សតិ ការរឭករឿយៗមានសទ្ធាទិគុណ របស់ទេវតា និង សទ្ធាទិគុណ របស់ខ្លួនជាអារម្មណ៍,

(៧) មរណានុស្សតិ ការរឭករឿយៗដល់មរណៈជាអារម្មណ៍,

(៨) កាយគតាសតិ ការរឭកតាំងចុះក្នុងកាយជាអារម្មណ៍,

(៩) អានាបាណស្សតិ ការរឭកខ្យល់ចេញចូលជាអារម្មណ៍,

(១០) ឧបសមានុស្សតិ ការរឭករឿយៗនូវព្រះនិព្វានជាអារម្មណ៍ ។

**ព្រហ្មវិហារ ៤ នេះ គឺ**

(១) មេត្តា ផ្សាយមេត្តា ដល់សព្វសត្វទាំងពួង,

(២) ករុណា ផ្សាយករុណាដល់សព្វសត្វទាំងពួង,

(៣) មុទិតា ផ្សាយមុទិតាដល់សព្វសត្វទាំងពួង,

(៤) ឧបេក្ខា ផ្សាយឧបេក្ខាដល់សព្វសត្វទាំងពួង,

អារូប្ប ៤ នេះ គឺ

(១) អាកាសានញ្ចាយតន យកអាកាសក្នុងបដិភាគនិមិត្តដែលកើតអំពីកសិណ ៩ វៀរលែងតែអាកាសកសិណចេញ ដែលមិនមានទីបំផុត មកជាអារម្មណ៍,

(២) វិញ្ញាណញ្ចាយតន ស្រាវយកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅ មិនមានទីបំផុត មកជាអារម្មណ៍,

(៣) អាកិញ្ចញ្ញាយតន កំណត់យកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅ មិនមានកង្វល់តិចតួច មកជាអារម្មណ៍,

(៤) នេវសញ្ញានាសញ្ញាយតន កំណត់យកសេចក្ដីល្អិត របស់អរូប-វិញ្ញាណទី ៣ ដែលមានស្មើរតែនឹងមិនមាន មកជាអារម្មណ៍ ។

អាហារេបដិកូលសញ្ញា ដែលព្រះយោគាវចរពិចារណាអាហារដោយបដិកូល ឈ្មោះថា សញ្ញា ១ ។ ចតុធាតុវវដ្ឋាន ដែលព្រះយោគាវចរ ពិចារណាកំណត់ធាតុ ៤ ឈ្មោះថា វវដ្ឋាន ១ ។

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយសង្ខាតនិទ្ទេស យ៉ាងនេះឯង ។

(ឧបចារប្បនាវហ)

ពាក្យថា “ដោយដឹងកម្មដ្ឋាន ដែលនាំមកនូវឧបចារជ្ឈាន និងកម្មដ្ឋានដែលនាំមកនូវអប្បនាឈាន” មានវិនិច្ឆ័យ ដូចតទៅ : ក៏ក្នុងកម្មដ្ឋានទាំងឡាយនោះ កម្មដ្ឋានទាំង ១០ នេះ គឺ អនុស្សតិ លើកលែង



តែកាយគតាសតិ និង អានាបានស្សតិចេញ នៅសល់ ៨, អាហារេបដិកូលសញ្ញា ១, ចតុធាតុវវដ្ឋាន ១ នេះប៉ុណ្ណោះ ជាកម្មដ្ឋាននាំមកនូវត្រឹមតែឧបចារជ្ឈាន, កម្មដ្ឋានដ៏សេស ជាកម្មដ្ឋាននាំមកនូវអប្បនាឈាន ។

បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងកម្មដ្ឋានដែលនាំមកនូវត្រឹមតែឧបចារជ្ឈាន និង អប្បនាឈាន យ៉ាងដូច្នេះឯង ។

(ឈានប្បភេទ)

ពាក្យថា “ដោយដឹងប្រភេទរបស់ឈាន” មានវិនិច្ឆ័យថា: ក៏ក្នុងកម្មដ្ឋានទាំង ២ យ៉ាង ដូចបានពោលមកហើយនោះ បណ្ដាកម្មដ្ឋានដែលនាំមក នូវអប្បនាឈាន កសិណ ១០ ព្រមទាំងអានាបានស្សតិ ជាចតុក្កជ្ឈានិក ចំរើនឲ្យកើតឈានបានគ្រប់ ៤ ។ អសុភ ១០ ព្រមទាំងកាយគតាសតិ ជាបឋមជ្ឈានិក ចំរើនឲ្យកើតឈានបានត្រឹមតែបឋមជ្ឈាន ។ ព្រហ្មវិហារ ៣ ខាងដើម ជាតិកជ្ឈានិក ចំរើនឲ្យកើតឈានបានត្រឹមតែ ៣ ។ ព្រហ្មវិហារ ទី ៤ និង អារូប្ប ៤ ជាចតុត្ថជ្ឈានិក ប្រព្រឹត្តទៅ ក្នុងចតុត្ថជ្ឈាន ។ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យដោយដឹងប្រភេទរបស់ឈាន យ៉ាងដូច្នេះឯង ។

(សមតិក្កម)

បទថា “ដោយដឹងវិធីប្រព្រឹត្តិកន្លងរបស់កម្មដ្ឋាន” មានវិនិច្ឆ័យថាការប្រព្រឹត្តិកន្លង មាន ២ យ៉ាង គឺ: ការប្រព្រឹត្តិកន្លងនូវអង្គ ១ ការប្រព្រឹត្តិកន្លងនូវអារម្មណ៍ ១ ។ ក្នុងការប្រព្រឹត្តិកន្លងទាំង ២ នោះ ការប្រព្រឹត្តិកន្លងអង្គ រមែងមាន ក្នុងកម្មដ្ឋានទាំងឡាយដែលជាតិកជ្ឈានិក និង ចតុក្កជ្ឈានិកទាំងពួង ព្រោះឈានទាំងឡាយថ្នាក់ខ្ពស់ មានទុតិយ-ឈានជាដើម ព្រះយោគាវចរត្រូវតែកន្លង នូវអង្គឈានទាំងឡាយ មាន

វិតក្កៈ និង វិចារៈ ជាដើមហើយ ទើបបានសំរេច ក្នុងអារម្មណ៍ទាំងឡាយនោះឯង ។ ក្នុងព្រហ្មវិហារ ទី៤ ក៏យ៉ាងដូច្នោះ ។ ព្រោះសូម្បីព្រហ្មវិហារ ទី៤ នោះ ព្រះយោគាវចរ ក៏ត្រូវតែកន្លង នូវសោមនស្សហើយ ទើបបានសម្រេច ក្នុងអារម្មណ៍នៃព្រហ្មវិហារ ៣ ខាងដើម មានមេត្តាជាដើមនុ៎ះឯង ។ ចំណែកការប្រព្រឹត្តិកន្លងនូវអារម្មណ៍ រមែងមានក្នុងអារូប្ប ៤ ។ ព្រោះអាកាសានញ្ចាយតនៈ ព្រះយោគាវចរ ត្រូវតែកន្លង នូវអារម្មណ៍ណាមួយ បណ្តាកសិណ ៩ ខាងដើមហើយ ទើបសម្រេចបាន ។ ក៏អារូប្បខាងដើម មាន វិញ្ញាណញ្ចាយតនៈជាដើម ព្រះយោគាវចរ ត្រូវតែកន្លងនូវអារម្មណ៍ទាំងឡាយ មានអាកាសជាដើមហើយ ទើបសម្រេចបាន ។ ក្នុងកម្មដ្ឋាន ដ៏សេស ការប្រព្រឹត្តិកន្លងមិនមានទេ ។ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងវិធីប្រព្រឹត្តិកន្លង នៃកម្មដ្ឋាន យ៉ាងដូច្នេះឯង ។

(ខឌ្ឍនាខឌ្ឍន)

(៧៦) បទថា “ដោយដឹងកម្មដ្ឋាន ដែលគួរដល់ការចំរើនថែម និងមិនគួរដល់ការចំរើនថែម” មានវិនិច្ឆ័យថា : ក្នុងកម្មដ្ឋានទាំង ៤០ នេះ កសិណ ១០ ប៉ុណ្ណោះ ព្រះយោគាវចរ គួរចំរើនបន្ថែម ។ ព្រោះព្រះយោគាវចរ ផ្សាយដោយកសិណ របូតឱកាសត្រឹមណា, ឮដ៏ខាងក្នុងឱកាសត្រឹមនោះ ព្រះយោគាវចរនោះ អាចស្តាប់សំឡេងឮ ដោយទិព្វ-សោតធាតុ ឃើញរូប ដោយទិព្វចក្ខុ និង ដឹងចិត្ត របស់សត្វដទៃ ដោយចិត្តបាន ។ ឯកាយគតាសតិ និង អសុភទាំងឡាយ ព្រះយោគាវចរ មិនគួរចំរើនថែមទេ ។ ព្រោះហេតុអ្វី? ។ ព្រោះកាយគតាសតិ និង អសុភនោះត្រូវកំណត់ហើយដោយឱកាស និង មិនមានអានិសង្សផង ។



ក៏ភាវៈនៃកម្មដ្ឋានទាំងនោះ ត្រូវកំណត់ហើយ ដោយឱកាសនេះនោះ នឹងមានប្រាកដ ដោយភាវនាន័យ។ ក៏កាលបើព្រះយោគាវចរចំរើនកម្មដ្ឋានទាំងនោះ បន្ថែមហើយ គំនរនៃសាកសពតែប៉ុណ្ណោះឯង រមែងចំរើន ។ អានិសង្សប្រន្តិចបន្តួចមិនមានទេ ។ មែនពិត ពាក្យនេះ ព្រះសោបាកត្ថេរពោលហើយ ក្នុងសោបាកប្បញ្ហាព្យាករណ៍ថា “បពិត្រព្រះមានព្រះភាគ រូបសញ្ញា ប្រាកដច្បាស់, អដ្ឋិកសញ្ញា មិនប្រាកដច្បាស់” ដូច្នេះ ។ ក៏ក្នុងសញ្ញាទាំង ២ នោះ រូបសញ្ញា លោកពោលហើយថាៈ ប្រាកដច្បាស់ ដោយអំណាចនៃការចំរើនឡើង នៃនិមិត្ត ។ អដ្ឋិកសញ្ញា លោកពោលថាៈ មិនប្រាកដច្បាស់ ដោយអំណាចនៃការមិនចំរើនឡើង (នៃនិមិត្ត) ។ ឯពាក្យនេះឯណា ដែលព្រះថេរៈ ពោលហើយថា “ខ្ញុំព្រះករុណា បានផ្សាយទៅដោយអដ្ឋិកសញ្ញា ពេញផែនដីនេះទាំងមូល” ដូច្នេះ, ពាក្យនោះ ព្រះថេរៈ ពោលហើយ ដោយអំណាចនៃអាការដែលប្រាកដឡើងដល់ខ្លួនលោកដែលជាអ្នកបាន ។ ដូចជាក្នុងកាលនៃព្រះបាទធម្មាសោក សត្វករវិក ឃើញស្រមោលរបស់ខ្លួន ក្នុងជញ្ជាំងនៃកញ្ចក់ ដោយជុំវិញ ក៏សម្គាល់ថាៈ ស្រមោលរបស់ខ្លួន ជាសត្វករវិក ក្នុងទិសទាំងពួង ទើបបញ្ចេញសំឡេងយ៉ាងពីរោះ យ៉ាងណាមិញ, សូម្បីព្រះថេរៈ ក៏យ៉ាងដូច្នោះដែរ ព្រោះភាវៈជាអ្នកជំនាញក្នុងអដ្ឋិកសញ្ញា ឃើញនូវនិមិត្តដែលប្រាកដឡើង ក្នុងទិសទាំងពួង ក៏គិតថា “ប្រឹថពីទាំងមូល ពោរពេញទៅដោយអដ្ឋិ” ដូច្នេះឯង ។

សួរថា : បើយ៉ាងដូច្នោះ ភាវៈនៃអសុភឈានទាំងឡាយ ជាអប្បមាណារម្មណ៍ ឯណា ដែលលោកពោលហើយ, នោះ មិនខុសទេឬ? ។ ឆ្លើយថាៈ ក៏ភាវៈនៃអសុភឈាន ជាអប្បមាណារម្មណ៍នោះ

មិនខុសទេ ព្រោះព្រះយោគាវចរខ្លះ កាន់យកនិមិត្ត ក្នុងឧទ្ធុមាតកអសុភ ឬ ក្នុងអដ្ឋិកអសុភដែលធំ, ព្រះយោគាវចរពួកខ្លះ ក៏កាន់យកនិមិត្ត ក្នុងអសុភនោះ ៗ ដែលតូច ៗ ដោយបរិយាយនេះ, ឈាន របស់ព្រះយោគាវចរពួកខ្លះ ជាបរិត្តារម្មណ៍, ឈាន របស់ព្រះយោគាវចរពួកខ្លះ ជាអប្បមាណារម្មណ៍ ។ មួយទៀត ព្រះយោគាវចរ រូបណា មិនឃើញទោស ក្នុងការចំរើនបន្ថែម នូវអសុភនិមិត្តនោះ ក៏ចំរើនថែម, លោកពោលសំដៅយកឈាន របស់ព្រះយោគាវចរនោះ ថា: អសុភឈាន ជាអប្បមាណារម្មណ៍ ។ ប៉ុន្តែមិនគួរចំរើនថែម ព្រោះមិនមានអានិសង្ស ដូច្នេះឯង ។ សូម្បីកម្មដ្ឋាន ដ៏សេស ក៏មិនគួរចំរើនថែម ដូចជាកាយ-គតាសតិ និង អសុភទាំងនុ៎ះ យ៉ាងនោះឯង ។

សួរថា: ព្រោះហេតុអ្វី? ។ ឆ្លើយថា: ព្រោះក្នុងកម្មដ្ឋាន ដ៏សេស ទាំងនោះ ដំបូង បើព្រះយោគាវចរ ចំរើនថែមនូវអានាបាននិមិត្ត, គំនរខ្យល់តែប៉ុណ្ណោះ រមែងចំរើន និង អានាបាននិមិត្តនោះ ក៏ត្រូវកំណត់ហើយ ដោយឱកាស ។ អានាបាននិមិត្ត គឺព្រះយោគាវចរ មិនគួរចំរើនថែម ព្រោះមានទោសផង ព្រោះត្រូវបានកំណត់ហើយផង ។

ព្រហ្មវិហារ ក៏មានសត្វជាអារម្មណ៍ ។ កាលបើព្រះយោគាវចរ ចំរើនថែមនូវនិមិត្ត នៃព្រហ្មវិហារទាំងនោះ, ក៏គំនរសត្វតែប៉ុណ្ណោះ គប្បីចំរើន ។ តែប្រយោជន៍ ដោយការចំរើនគំនរសត្វនោះ ក៏មិនមានទេ ។ ព្រោះហេតុនោះ សូម្បីព្រហ្មវិហារនិមិត្តនោះ ក៏មិនគួរចំរើន ។ ចំណែកពាក្យបាលី ដែលលោកពោលហើយ ថា "ភិក្ខុ មានចិត្តប្រកប ដោយមេត្តា ផ្សាយទៅកាន់ទិសមួយ" ដូច្នេះជាដើមនោះ លោកពោលហើយ ដោយអំណាចនៃការប្រកាន់យក ។ មែនពិត ព្រះយោគាវចរ កំណត់



យកនូវសត្វទាំងឡាយ ក្នុងទិស ១ ចំរើនទៅដោយលំដាប់ មានវត្តមួយវត្តពីរជាដើម ហៅថា "ផ្សាយទៅកាន់ទិសមួយ" មិនមែនជាអ្នកចំរើនថែមនូវនិមិត្តទេ ។ ក៏បដិភាគនិមិត្ត ដែលព្រះយោគាវចរ ចំរើននោះឯង មិនមានទេ ក្នុងព្រហ្មវិហារភាវនានេះ ។ ចំណែកភាវៈដែលជាបរិត្តា-រម្មណ៍ និង អប្បមាណារម្មណ៍ ក្នុងព្រហ្មវិហារនេះ បណ្ឌិត គប្បីជ្រាបដោយអំណាចនៃការកំណត់យកនុ៎ះឯង ។

សូម្បីក្នុងអារម្មណ៍នៃអារូបទាំងឡាយ អាកាស ក៏មិនគួរចំរើនថែម ព្រោះធ្វើឲ្យកសិណរបើកឡើង។ មែនពិត អាកាសនោះ ព្រះយោគាវចរ គប្បីធ្វើទុកក្នុងចិត្ត ដោយអំណាចការទៅប្រាសនៃកសិណប៉ុណ្ណោះឯង ។ កាលបើចំរើនឲ្យច្រើនជាងនោះ ក៏គ្មានប្រយោជន៍អ្វីឡើយ ។ វិញ្ញាណ ក៏មិនគួរចំរើនថែម ព្រោះជាសភាវធម៌ ។ មែនពិត អ្នកណា ក៏មិនអាចធ្វើសភាវធម៌ឲ្យចំរើនបានឡើយ ។ ការទៅប្រាសនៃវិញ្ញាណ ក៏មិនគួរចំរើនថែម ព្រោះគ្រាន់តែជាសេចក្ដីមិនប្រាកដនៃវិញ្ញាណ ។ អារម្មណ៍នៃនេវសញ្ញានាសញ្ញាយតនៈ ក៏មិនគួរចំរើនថែម ព្រោះជាសភាវធម៌ដូចគ្នាដែរ ។

កម្មដ្ឋាន ដ៏សេស ក៏មិនគួរចំរើនថែម ព្រោះមិនមាននិមិត្ត ។ មែនពិត បដិភាគនិមិត្ត ឈ្មោះថា ជានិមិត្តគួរចំរើនដោយពិត, តែអារម្មណ៍នៃអនុស្សតិទាំងឡាយ មានពុទ្ធានុស្សតិជាដើម មិនមែនជាបដិភាគនិមិត្តទេ ។ ហេតុនោះ អនុស្សតិកម្មដ្ឋាននោះ ទើបមិនគួរចំរើនថែមឡើយ ។ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងកម្មដ្ឋានដែលគួរដល់ការចំរើនថែម និង មិនគួរដល់ការចំរើនថែម យ៉ាងដូច្នេះឯង ។

(៧៧) បទថា "ដោយដឹងអារម្មណ៍ របស់កម្មដ្ឋាន" មានវិនិច្ឆ័យ

(អារម្មណ៍)

ថា : ក៏ក្នុងកម្មដ្ឋានទាំង ៤០ នេះ កម្មដ្ឋាន ២២ នេះ គឺ កសិណ ១០, អសុភ ១០, អានាបានស្សតិ ១, កាយគតាសតិ ១ មានអារម្មណ៍ ជាបដិភាគនិមិត្តបាន ។ កម្មដ្ឋាន ក្រៅអំពីនេះ (១៨) មានអារម្មណ៍ ជាបដិភាគនិមិត្តមិនបានឡើយ ។ ដោយន័យនោះ កម្មដ្ឋាន ១២ នេះ គឺៈ ក្នុងអនុស្សតិ ១០ អនុស្សតិ ៨ ដ៏សេស លើកលែតែអានាបានស្សតិ និង កាយគតាសតិចេញ និង អាហារបដិកូលសញ្ញា១ ចតុធាតុវវដ្ឋាន១ វិញ្ញាណញ្ចាយតនៈ១ នេវសញ្ញានាសញ្ញាយតនៈ១ កាន់យកសភាវធម៌មកជាអារម្មណ៍ ។ កម្មដ្ឋានទាំង ២២ នេះ គឺ កសិណ១០, អសុភ ១០, អានាបានស្សតិ ១, កាយគតាសតិ ១ កាន់យកនិមិត្ត មកជាអារម្មណ៍ ។ កម្មដ្ឋាន ក្រៅអំពីនេះ ៦ (គឺៈ ព្រហ្មវិហារ ៤, អាកាសានញ្ចាយតនៈ ១, អាកិញ្ចញ្ញាយតនៈ១) កាន់យកអារម្មណ៍ ដែលគួរពោលកំណត់មិនបាន, មួយទៀត កម្មដ្ឋាន ៨ នេះ គឺៈ វិបុព្វកអសុភ ១, លោហិតកអសុភ ១, បុឡុវកអសុភ ១, អានាបានស្សតិ ១, អាបោកសិណ ១, តេជោ-កសិណ ១, វាយោកសិណ ១ មណ្ឌលរស្មី នៃព្រះអាទិត្យជាដើម ដែលជាអារម្មណ៍ ក្នុងអាលោកកសិណ ១ (មុនកើតបដិភាគនិមិត្ត) មានអារម្មណ៍ញ័រ ។ តែអារម្មណ៍កម្រើកទាំងនោះឯង រមែងមាន ក្នុងកាលជាខាងដើម ។ តែដល់បដិភាគនិមិត្ត ក៏មានអារម្មណ៍ស្ងប់មិនកម្រើក ។ កម្មដ្ឋាន សល់ក្រៅអំពីនេះ មានអារម្មណ៍ស្ងប់ ឥតកម្រើក ។ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងអារម្មណ៍ របស់កម្មដ្ឋាន យ៉ាងដូច្នេះ ។

(ភូមិ)

(៧៨) បទថា "ដោយដឹងភូមិ របស់កម្មដ្ឋាន" មានវិនិច្ឆ័យ ថា :



ក៏បណ្តាកម្មដ្ឋាន ៤០ នេះ កម្មដ្ឋាន ១២ នេះ គឺ អសុភ ១០, កាយ-គតាសតិ ១, អាហារបដិកូលសញ្ញា ១ ប្រព្រឹត្តទៅ ក្នុងទេវលោកមិនបាន ។ កម្មដ្ឋាន ១៣ នេះ គឺៈ កម្មដ្ឋាន ១២ នោះ និង អានាបាន-ស្សតិ ប្រព្រឹត្តទៅ ក្នុងព្រហ្មលោកមិនបាន ។ តែកម្មដ្ឋានដទៃ វៀរលែងតែអារូប្ប ៤ ប្រព្រឹត្តទៅ ក្នុងអរូបភពមិនបាន ។ ឯកម្មដ្ឋាន ទាំងអស់ (៤០) ប្រព្រឹត្តទៅ ក្នុងមនុស្សលោកបាន ។ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងភូមិ របស់កម្មដ្ឋាន យ៉ាងដូច្នេះឯង ។

(គហណ)

បទថា "ដោយដឹងកិច្ច ដែលត្រូវរៀនយកកម្មដ្ឋាន" មានវិនិច្ឆ័យថាៈ ក៏សេចក្តីវិនិច្ឆ័យ ក្នុងបទនេះ បណ្ឌិតគប្បីជ្រាប ដោយការកាន់យកតាមនិមិត្ត ដែលមើលឃើញ, តាមដែលខ្យល់ប៉ះពាល់ត្រូវ និង តាមដែលបានស្តាប់ឮ ។ ក្នុងផ្លូវទាំង ៣ នោះ កម្មដ្ឋានទាំង ១៩ នេះ គឺៈ កសិណដ៏សេស៩ លើកលែងតែវាយោកសិណចេញ, អសុភ១០ គប្បីកាន់យកតាមនិមិត្តដែលឃើញ ។ មានសេចក្តីថា មុនដំបូង ត្រូវមើលដោយចក្ខុហើយ ទើបកាន់យកនិមិត្ត នៃកម្មដ្ឋានទាំងនោះ ។ ក្នុងកាយ-គតាសតិ អារម្មណ៍ របស់កាយគតាសតិនោះ ត្រូវកាន់យកតាមនិមិត្តដែលមើលឃើញ និង តាមដែលបានស្តាប់ឮ យ៉ាងដូច្នេះ គឺៈ ត្រង់តចបញ្ចកៈ ត្រូវរៀនយក តាមនិមិត្តដែលមើលឃើញ, សល់អំពីនោះត្រូវរៀនយក តាមដែលស្តាប់ឮ ។ អានាបានស្សតិ ត្រូវរៀនយក តាមខ្យល់ដែលពាល់ត្រូវ ។ វាយោកសិណ ត្រូវរៀនយក តាមនិមិត្តដែលមើលឃើញ និង តាមខ្យល់ដែលពាល់ត្រូវ ។ កម្មដ្ឋាន ដែលសល់អំពីនេះ ១៨ ត្រូវរៀនយក តាមដែលបានស្តាប់មក ។ តែក្នុងកម្មដ្ឋាន ៤០

នេះ កម្មដ្ឋានទាំងនេះ គឺៈ ឧបេក្ខាព្រហ្មវិហារ ១ អារុប្ប ៤ គឺព្រះយោគាវចរកុលបុត្រ ដែលជាអាទិកម្មិកៈ មិនត្រូវរៀនឡើយ ត្រូវរៀនតែកម្មដ្ឋាន ៣៥ ក្រៅអំពីនេះ ។ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងកិច្ច ដែលត្រូវរៀនយកនូវកម្មដ្ឋាន យ៉ាងនេះឯង ។

(បច្ច័យ)

បទថា "ដោយដឹងបច្ច័យ របស់កម្មដ្ឋាន" មានវិនិច្ឆ័យថា ក្នុងកម្មដ្ឋានទាំងនេះ កសិណ ដ៏សេស ៩ លើកលែងតែអាកាសកសិណចេញទៅ រមែងជាបច្ច័យនៃអារុប្បទាំងឡាយ ។ កសិណទាំង ១០ ជាបច្ច័យនៃអភិញ្ញាទាំងឡាយ ។ ព្រហ្មវិហារ ៣ ជាបច្ច័យ នៃព្រហ្មវិហារទី៤ ។ អារុប្បថ្នាក់ទាបៗ ជាបច្ច័យដល់អារុប្បថ្នាក់លើៗ។ នេវសញ្ញា-នាសញ្ញាយតនៈ ជាបច្ច័យដល់និរោធសមាបត្តិ ។ កម្មដ្ឋានគ្រប់ទាំង ៤០ ជាបច្ច័យឲ្យព្រះវីណាស្រេព នៅជាសុខ ក្នុងបច្ចុប្បន្ន ដល់នូវវិបស្សនា និង ដល់ភពសម្បត្តិ ដូច្នេះឯង ។

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ដោយដឹងបច្ច័យ របស់កម្មដ្ឋាន ដូច្នេះ ។

(ចរិយានុកូល)

បទថា "ដោយដឹងកម្មដ្ឋាន ដែលគួរដល់ចរិយា" មានវិនិច្ឆ័យ ថាៈ ក៏សេចក្តីវិនិច្ឆ័យ ក្នុងបទនេះ បណ្ឌិត គប្បីជ្រាប ដោយសមគួរ ដល់ចរិយាទាំងឡាយ ។ តើកម្មដ្ឋាន ដែលសមគួរដល់ចរិយានេះ យ៉ាងដូចម្តេច? ។ ជាដំបូង ក្នុងកម្មដ្ឋានទាំង ៤០ នោះ កម្មដ្ឋាន ១១ គឺៈ អសុភ ១០, កាយគតាសតិ ១ ជាកម្មដ្ឋាន សមគួរដល់បុគ្គលដែលជារាគចរិត, កម្មដ្ឋាន ៨ គឺ ព្រហ្មវិហារ ៤, វណ្ណកសិណ ៤ សមគួរ ដល់បុគ្គលដែលជាទោសចរិត ។ អានាបានស្សតិកម្មដ្ឋាន តែមួយប៉ុណ្ណោះ សមគួរ



ដល់បុគ្គលដែលជាមោហចរិត និង បុគ្គលដែលជាវិតក្កចរិត។ អនុស្សតិ ៦ ខាងដើម សមគួរ ដល់បុគ្គលដែលជាសទ្ធាចរិត ។ កម្មដ្ឋាន ៤ គឺ មរណស្សតិ ១, ឧបសមានុស្សតិ ១, ចតុធាតុវវដ្ឋាន ១, អាហារបដិកូលសញ្ញា ១ សមគួរដល់បុគ្គលដែលជាពុទ្ធិចរិត ។ កសិណដ៏សេសសល់ និង អារុប្ប ៤ សមគួរដល់បុគ្គលគ្រប់ចរិតទាំងអស់ ។ តែក្នុងកសិណទាំងឡាយ កសិណឯណាមួយ ដែលជាបរិត្តារម្មណ៍ កសិណនោះ សមគួរ ដល់បុគ្គលដែលជាវិតក្កចរិត, ដែលជាអប្បមាណារម្មណ៍ សមគួរដល់បុគ្គលដែលជាមោហចរិត ។ ក្នុងកម្មដ្ឋាននោះ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ដោយដឹងកម្មដ្ឋានដែលសមគួរដល់ចរិយា យ៉ាងនេះឯង ។

ក៏ពាក្យនេះទាំងអស់លោកពោលហើយ ដោយអំណាចនៃកម្មដ្ឋានដែលជាសឹកសត្រូវដោយត្រង់ និង ដោយអំណាចនៃកម្មដ្ឋាន ដែលជាទីសប្បាយ ដ៏ក្រៃលែងផង ។ តែឈ្មោះថា កុសលភាវនា ដែលមិនបានគ្របសង្កត់ នូវទោសទាំងឡាយមានរាគៈជាដើម ឬ ដែលមិនមែនជាឧបការៈ ដល់គុណទាំងឡាយ មានសទ្ធាជាដើម មិនមាន ។ មែនពិតពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ ក្នុងមេឃិយសូត្រ ថា "ធម៌ទាំងឡាយ ៤ ប្រការ គឺអ្នកគប្បីចំរើន ឲ្យបានប្រសើរឡើង គឺ អសុភទាំងឡាយ គឺអ្នកគប្បីចំរើន ដើម្បីលះបង់នូវរាគៈ, មេត្តា អ្នកគប្បីចំរើនដើម្បីលះបង់នូវព្យាបាទ, អានាបានស្សតិ អ្នកគប្បីចំរើន ដើម្បីផ្តាច់បង់នូវវិតក្កៈ, អនិច្ចសញ្ញា គឺអ្នកគប្បីចំរើន ដើម្បីគាស់រំលើងអស្មិមានៈ" ដូច្នេះ ។ សូម្បីក្នុងរាហុលសូត្រ ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់កម្មដ្ឋាន ៧ ដល់ព្រះរាហុលតែម្នាក់ឯងគត់ ដោយន័យជាអាទិ៍ថា "ម្នាលរាហុល ចូរអ្នកចំរើនមេត្តាភាវនា" ដូច្នេះ ។ ព្រោះហេតុនោះ បណ្ឌិត មិនគួរតាំង

ចិត្តជឿ ក្នុងហេតុត្រឹមតែពាក្យពោល ត្រូវតែស្វែងរកសេចក្តីអធិប្បាយ ក្នុងទីទាំងពួងផង ។ នេះ គឺជាសេចក្តីវិនិច្ឆ័យ ក្នុងកម្មដ្ឋានកថា ក្នុងបទថា "រៀនយកកម្មដ្ឋាន" នុ៎ះ ។

(ការរៀនយកកម្មដ្ឋាន)

(៧៩) ក៏ការសំដែងនូវសេចក្តី នៃបទថា "រៀនយក" នេះ មានដូចតទៅនេះ ។ ព្រះយោគីនោះ គប្បីចូលទៅរកកល្យាណមិត្រ មានប្រការដូចបានពោលមកហើយ តាមន័យដែលលោកពោលហើយ ក្នុងពាក្យថា "ចូលទៅរកកល្យាណមិត្រ អ្នកឲ្យនូវកម្មដ្ឋាន" ដូច្នេះ ហើយប្រគល់ខ្លួន ចំពោះព្រះមានព្រះភាគ ឬក៏ ចំពោះអាចារ្យ ជាអ្នកមានអធ្យាស្រ័យ ដល់ព្រមហើយ និង ជាអ្នកមានអធិមុត្តិ ដល់ព្រមហើយ សុំកម្មដ្ឋានចុះ ។

(ការប្រគល់ខ្លួន)

ក្នុងការប្រគល់ខ្លួននោះ ព្រះយោគី គប្បីប្រគល់ខ្លួន ចំពោះព្រះមានព្រះភាគព្រះពុទ្ធជាម្ចាស់ យ៉ាងដូច្នេះ ថា "ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជាមិ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះករុណា សូមលះបង់នូវអត្តភាពនេះ ចំពោះព្រះអង្គ" ដូច្នេះ ។ ក៏ភិក្ខុ កាលមិនប្រគល់ខ្លួនយ៉ាងនេះទេ នៅក្នុងសេនាសនៈទាំងឡាយដែលស្ងាត់ កាលបើអារម្មណ៍ដែលគួរឲ្យភ័យខ្លាច មកជួបគ្នាហើយ ក៏មិនអាចអត់ទ្រាំនៅបានទេ នឹងស្ទុះចុះទៅកាន់ស្រុក ជាអ្នកប្រឡូកប្រឡល់ ដោយគ្រហស្ថ ដល់នូវការស្វែងរកមិនសមគួរ គប្បីដល់នូវសេចក្តីមិនចំរើន និង វិនាស ។ ប៉ុន្តែកាលបើភិក្ខុនោះ បានប្រគល់ខ្លួនហើយ, កាលបើអារម្មណ៍ដែលគួរឲ្យភ័យខ្លាច មកជួបគ្នាហើយ ភ័យក៏មិនកើតឡើង ។ មួយទៀត កាលបើ



ភិក្ខុនោះ ពិចារណាឃើញថា "នែបណ្ឌិត អ្នកបានប្រគល់ខ្លួន ចំពោះព្រះពុទ្ធ ក្នុងថ្ងៃមុនហើយ មិនមែនទេឬ" ដូច្នេះ សេចក្តីសោមនស្ស ក៏នឹងកើតឡើងភ្លាម ។ ប្រៀបដូចជាសំពត់ ក្នុងដែនកាសី របស់បុរស ជាសំពត់មានតម្លៃច្រើន, កាលបើសំពត់នោះ ត្រូវកណ្តុរ ឬ កន្លាត កកេរហើយ, សេចក្តីតូចចិត្ត ក៏នឹងកើតឡើងដល់បុរសនោះ, តែបើបុរសនោះគប្បីប្រគេនសំពត់កាសីនោះ ដល់ភិក្ខុ ដែលមិនមានចីវរ តមក សេចក្តីរីករាយចិត្តនុ៎ះឯង គប្បីកើតឡើងដល់បុរសនោះ ព្រោះឃើញសំពត់នោះត្រូវភិក្ខុរូបនោះ កាត់ធ្វើជាកំណាត់តូច-ធំ មានឧបមាយ៉ាងណា, បណ្ឌិតគប្បីជ្រាបសេចក្តីឧបមេយ្យនេះ ក៏យ៉ាងនោះដែរ ។

សូម្បីភិក្ខុ ប្រគល់ខ្លួនចំពោះអាចារ្យ ក៏ត្រូវពោលថា "ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន ខ្ញុំព្រះករុណា សូមប្រគល់ខ្លួន ចំពោះព្រះគុណម្ចាស់" ដូច្នេះ ។ ក៏ភិក្ខុ ដែលមិនបានប្រគល់ខ្លួន យ៉ាងនេះទេ ជាអ្នកគឺអាចារ្យ គប្បីគម្រាមមិនបានខ្លះ ជាអ្នកគឺអាចារ្យ ប្រដៅបានដោយក្រ មិនធ្វើតាមឱវាទខ្លះ ជាអ្នកដែលទៅតាមអំពើចិត្ត របស់ខ្លួន មិនទាន់លាអាចារ្យផង ក៏ទៅក្នុងទីដែលខ្លួនប្រាថ្នាខ្លះ, អាចារ្យមិនសង្គ្រោះនូវភិក្ខុរូបនោះ ដោយអាមិសខ្លះ ដោយធម៌ខ្លះ ទាំងមិនឲ្យសិក្សានូវការសិក្សាដែលមានអាថ៌កំបាំងស្មុគស្មាញ ។ ភិក្ខុនោះ កាលមិនបាននូវសេចក្តីសង្គ្រោះ ២ យ៉ាងនេះទេ ឈ្មោះថាមិនបានទីពឹង ក្នុងព្រះសាសនា មិនយូរប៉ុន្មានទេ ក៏នឹងដល់នូវភាពជាអ្នកទ្រុស្តសីល ឬក៏ ភាពជាគ្រហស្ថ ។ តែភិក្ខុអ្នកដែលបានប្រគល់ខ្លួនហើយ នឹងមិនជាអ្នកដែលអាចារ្យ គប្បីគម្រាមមិនបាន មិនជាអ្នកដែលទៅតាមអំពើចិត្ត ជាអ្នកដែលគេប្រដៅបានដោយងាយ ជាអ្នកមានការ

ប្រព្រឹត្តិមួយអន្លើដោយអាចារ្យជាក់ស្តែង ។ ភិក្ខុនោះ កាលបានសេចក្តីសង្គ្រោះទាំង ២ យ៉ាង អំពីអាចារ្យ រមែងបានដល់នូវសេចក្តីរីកចំរើនដុះដាល លូតលាស់ ក្នុងព្រះសាសនា ដូចជាអន្តេវាសិក នៃព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ យ៉ាងនោះឯង ។

មានរឿងមកថា ភិក្ខុ ៣ រូប និមន្តមកកាន់សំណាក់ព្រះថេរៈ ។ បណ្តាភិក្ខុទាំង ៣ រូបនោះ ភិក្ខុមួយរូប ពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើពោលថា: ដើម្បីប្រយោជន៍ ដល់ព្រះគុណម្ចាស់ ដូច្នេះហើយ ខ្ញុំព្រះករុណា អាចនឹងធ្លាក់ចុះទៅក្នុងជ្រោះដែលមានប្រវែង ១០០ នៃបុរសបាន" ដូច្នេះ ។ ភិក្ខុទីពីរ បានពោលថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើពោលថា: ដើម្បីប្រយោជន៍ ដល់ព្រះគុណម្ចាស់ ដូច្នេះហើយ ខ្ញុំព្រះករុណា កាលត្រដុសនូវអត្តភាពនេះ ចាប់តាំងអំពីក្តោលជើងមក លើខ្នងនៃថ្មដា អាចនឹងឲ្យអស់ទៅ មិនមានសេសសល់បាន" ដូច្នេះ ។ ភិក្ខុទី ៣ បានពោល ថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន កាលបើពោលថា: ដើម្បីប្រយោជន៍ ដល់ព្រះគុណម្ចាស់ ដូច្នេះហើយ ខ្ញុំព្រះករុណា អាចនឹងអត់សង្កត់ នូវខ្យល់អស្សាសៈ និងបស្សាសៈ ហើយធ្វើកាលកិរិយាបាន" ដូច្នេះ ។ ព្រះថេរៈ គិតថា "ភិក្ខុទាំងបីរូបនេះ ជាភព្វបុគ្គលដោយពិត" ដូច្នេះហើយ ទើបប្រាប់កម្មដ្ឋាន ។ ភិក្ខុទាំងនោះ ឋិតនៅក្នុងឱវាទ របស់ព្រះថេរៈនោះហើយ ក៏បានសម្រេចព្រះអរហត្តទាំង ៣ រូប ។ នេះ គឺជាអានិសង្ស ក្នុងការប្រគល់ខ្លួន ។ ព្រោះហេតុនោះ ទើបខ្ញុំពោលថា "គប្បីប្រគល់ខ្លួន ចំពោះព្រះមានព្រះភាគ ព្រះពុទ្ធជាម្ចាស់ ឬក៏ ចំពោះអាចារ្យ" ដូច្នេះ ។

**(អជ្ឈាសយធម៌ ៦ យ៉ាង)**



(៨០) ចំណែកក្នុងពាក្យថា **"ជាអ្នកមានអជ្ឈាស្រ័យ ដល់ព្រមហើយ និង ជាអ្នកមានអធិមុត្តិ ដល់ព្រមហើយ"** នេះ មានវិនិច្ឆ័យថា: ព្រះយោគីនោះ ត្រូវមានអជ្ឈាស្រ័យដល់ព្រមហើយ ដោយអាការ ៦ ដោយអំណាចគុណធម៌មានអលោភៈជាដើម ។ ក៏ព្រះយោគី ដែលមានអជ្ឈាស្រ័យដល់ព្រមហើយយ៉ាងនេះ រមែងបានដល់នូវបណ្តាធម៌គ្រឿងត្រាស់ដឹង ៣ យ៉ាង ធម៌គ្រឿងត្រាស់ដឹង ឯណាមួយ ។ ដូចជាលោកពោលហើយថា: ក៏អជ្ឈាស្រ័យទាំងឡាយ ៦ របស់ព្រះពោធិសត្វទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីអប់រំបន្ទុំនូវធម៌ជាគ្រឿងត្រាស់ដឹង គឺ: ព្រះពោធិសត្វទាំងឡាយ ជាអ្នកមានអជ្ឈាស្រ័យមិនលោភលន់ ជាអ្នកឃើញទោស ក្នុងសេចក្តីលោភជាប្រក្រតី ១, ព្រះពោធិសត្វទាំងឡាយ ជាអ្នកមានអជ្ឈាស្រ័យមិនប្រទូស្ត ជាអ្នកឃើញនូវទោស ក្នុងសេចក្តីប្រទូស្តជាប្រក្រតី ១, ព្រះពោធិសត្វទាំងឡាយ ជាអ្នកមានអជ្ឈាស្រ័យមិនវង្វេង ជាអ្នកឃើញនូវទោស ក្នុងសេចក្តីវង្វេងជាប្រក្រតី ១, ព្រះពោធិសត្វទាំងឡាយ ជាអ្នកមានអជ្ឈាស្រ័យ ក្នុងការចេញចាកកាម ជាអ្នកឃើញទោស ក្នុងការនៅគ្រប់គ្រងផ្ទះជាប្រក្រតី ១, ព្រះពោធិសត្វទាំងឡាយ ជាអ្នកមានអជ្ឈាស្រ័យពេញចិត្ត ក្នុងសេចក្តីស្ងាត់ ជាអ្នកឃើញនូវទោស ក្នុងការនៅប្រឡូកប្រឡល់ ដោយពួកជាប្រក្រតី ១, ព្រះពោធិសត្វទាំងឡាយ ជាអ្នកមានអជ្ឈាស្រ័យពេញចិត្ត ក្នុងការរលាស់ខ្លួនចេញចាកភព ជាអ្នកឃើញនូវទោស ក្នុងដំណើរទៅកាន់ភពទាំងពួងជាប្រក្រតី ១ ។

ពិតមែនហើយ បុគ្គលទាំងឡាយណា ជាព្រះសោតាបន្ន ជាព្រះសកទាគាមី ជាព្រះអនាគាមី ជាព្រះខីណាស្រព ជាព្រះបច្ចេកពុទ្ធ និង

ជាព្រះសម្មាសម្ពុទ្ធ ដែលមានមក ក្នុងអតីត អនាគត និង បច្ចុប្បន្ន, បុគ្គលទាំងឡាយទាំងពួងនោះ បានដល់នូវគុណវិសេស ដែលខ្លួនគប្បីបានសម្រេច ដោយអាការទាំង ៦ នេះឯង ។ ព្រោះហេតុដូច្នោះ ព្រះយោគី គួរជាអ្នកមានអជ្ឈាស្រ័យប្រកបព្រមហើយ ដោយអាការទាំង ៦ ប្រការនេះ ។ មួយទៀត ព្រះយោគី គួរជាអ្នកដល់ព្រមហើយដោយអធិមុត្តិ ដោយភាពជាអ្នកមានចិត្តបង្អោនចូលទៅ ក្នុងធម៌នោះ ។ អធិប្បាយថា: គប្បីជាអ្នកមានចិត្តបង្អោនចូលទៅ ក្នុងសមាធិ, ជាអ្នកធ្ងន់ ក្នុងសមាធិ, ជាអ្នកឈោងទៅរកសមាធិ, ជាអ្នកមានចិត្តបង្អោនចូលទៅ ក្នុងព្រះនិព្វាន, ជាអ្នកធ្ងន់ ក្នុងព្រះនិព្វាន និង ជាអ្នកឈោងទៅរកព្រះនិព្វាន ។

ក៏ចរិយា របស់ព្រះយោគីនោះ ដែលជាអ្នកមានអជ្ឈាស្រ័យ និង អធិមុត្តិដល់ព្រមហើយ យ៉ាងដូច្នេះ សូមនូវកម្មដ្ឋាន, អាចារ្យដែលជាអ្នកបាននូវចេតោបរិយញ្ញាណ ពិនិត្យមើលវារៈចិត្តហើយគប្បីដឹងបាន ។ អាចារ្យក្រៅនេះ ត្រូវសួរ ដោយន័យជាអាទិ៍ យ៉ាងដូច្នេះថា "តើអ្នកមានចរិតដូចម្ដេច? ឬ ធម៌យ៉ាងដូចម្ដេច ប្រព្រឹត្តទៅ ជាច្រើនដល់អ្នក? ឬថា កាលបើអ្នកធ្វើទុកក្នុងចិត្ត តើកម្មដ្ឋានអ្វីជាទីសប្បាយដល់អ្នក? ឬក៏ ចិត្តរបស់អ្នកបង្អោនចូលទៅ ក្នុងកម្មដ្ឋានមួយណា?" ដូច្នេះ ទើបដឹងបាន ។ លុះអាចារ្យដឹង ដូច្នេះហើយ គប្បីប្រាប់កម្មដ្ឋានដ៏សមគួរ ដល់ចរិយា ។ ក៏កាលនឹងប្រាប់ ត្រូវប្រាប់ដោយវិធី ៣ យ៉ាង គឺ: (១) ចំពោះបុគ្គលដែលរៀនកម្មដ្ឋាន តាមប្រក្រតី គប្បីឲ្យអន្ទុយធ្វើការស្វាធ្យាយ មួយដងពីរដង ហើយសឹមឲ្យ, (២) ចំពោះបុគ្គលដែលនៅ ក្នុងសំណាក់ ត្រូវ



ប្រាប់គ្រប់ខណៈ ដែលបានមកហើយៗ, (៣) ចំពោះបុគ្គលដែលរៀនហើយប្រាថ្នាចង់ទៅទីដទៃទៀត គប្បីប្រាប់កុំឲ្យខ្លីពេកកុំឲ្យពិស្ដារពេក ។

ក្នុងចំណោមកម្មដ្ឋានទាំងនោះ ជាដំបូង កាលនឹងប្រាប់នូវកម្មដ្ឋានគឺ បឋវីកសិណ ត្រូវប្រាប់អាការ ៩ នេះ គឺ ទោស របស់កសិណ ៤, ការធ្វើកសិណ, ភាវនាន័យ របស់កសិណ ដែលធ្វើហើយ, និមិត្ត ២, សមាធិ ២, សប្បាយៈ និង អសប្បាយៈ ៧, អប្បនាកោសល ១០, ភាពប្រព្រឹត្តិស្មើនៃវីរិយៈ, វិធីចំរើនអប្បនា ។ សូម្បីក្នុងកម្មដ្ឋានដ៏សេសក៏ត្រូវប្រាប់រឿងដ៏សមគួរ ដល់កម្មដ្ឋាននោះៗ ។ វិធីទាំងអស់នោះ នឹងមានប្រាកដ ក្នុងភាវនាវិធី នៃកម្មដ្ឋានទាំងនោះ ។

ក៏កាលបើអាចារ្យប្រាប់កម្មដ្ឋានយ៉ាងនេះ ព្រះយោគីនោះគប្បីស្ដាប់ចាប់យកនិមិត្តឲ្យបាន ។ ពាក្យថា "ចាប់យកនិមិត្ត" នេះ មានសេចក្ដីថា "ចូលទៅចងភ្ជាប់នូវអាការនោះៗ យ៉ាងដូច្នេះថា: នេះ ជាបទខាងក្រោម, នេះ ជាបទខាងលើ, នេះ ជាសេចក្ដីនៃបទនោះ, នេះ ជាសេចក្ដីអធិប្បាយ, នេះ ជាពាក្យឧបមា" ដូច្នេះ ។ ព្រោះថា កាលបើព្រះយោគីស្ដាប់ដោយគោរព ចាប់យកនិមិត្តបាន យ៉ាងនេះហើយ ឈ្មោះថា រៀនយកកម្មដ្ឋានបានយ៉ាងល្អហើយ ។ ក្រោយមក ការបាននូវគុណវិសេសនឹងសម្រេចដល់ព្រះយោគីនោះ ព្រោះអាស្រ័យនូវកម្មដ្ឋាន ដែលខ្លួនបានរៀនល្អហើយនោះ,មិនបានសម្រេច ដល់បុគ្គលដទៃក្រៅពីនេះឡើយ ។ នេះ ជាពាក្យសំដែង នូវសេចក្ដីនៃបទ ថា "រៀនយក" នេះ ។

បទទាំងឡាយនេះ ថា "ចូលទៅរកកល្យាណមិត្រហើយ រៀនយកកម្មដ្ឋានឯណាមួយ ក្នុងចំណោមកម្មដ្ឋាន ៤០ ដែលសមគួរ ដល់

ចរិយារបស់ខ្លួន” ដូច្នេះ ជាបទដែលខ្ញុំ(បានធ្វើ) ឲ្យពិស្តារហើយ ដោយអាការទាំងពួង ដោយកថាមគ្គ មានប្រមាណប៉ុណ្ណោះឯង ៕

បរិច្ឆេទ ទី៣ ឈ្មោះ កម្មដ្ឋានគ្គហណនិទ្ទេស
ក្នុងអធិការនៃសមាធិភាវនា ក្នុងគម្ពីរវិសុទ្ធិមគ្គ
ដែលខ្ញុំរចនាហើយ ដើម្បីប្រយោជន៍ដល់បាមោជ្ជៈនៃសាធុជន
ដោយប្រការយ៉ាងនេះឯង ៕

♣ ♣

រៀបរៀងចប់ ថ្ងៃអង្គារ ១២ រោច ខែភទ្របទ ព.ស. ២៥៣៩
ត្រូវនឹងថ្ងៃទី ៨ តុលា ១៩៩៦
ម៉ោង ៣:២០ នាទី ល្ងាច



(៨១) ឥឡូវនេះ បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យដែលខ្ញុំបាននោលហើយនេះថា “ព្រះយោគី អ្នកលះបង់នូវវិហារ ដែលមិនសមគួរដល់ការចំរើនសមាធិចោលហើយ អាស្រ័យនៅ ក្នុងវិហារដែលសមគួរ” ដូចតទៅនេះ :

ជាដំបូង កាលព្រះយោគីរូបណា អាស្រ័យនៅក្នុងវិហារ ១ ជាមួយនឹងអាចារ្យ មានសេចក្តីសុខសប្បាយ, ព្រះយោគីរូបនោះ កាលជម្រះនូវកម្មដ្ឋាន ក៏គួរអាស្រ័យនៅ ក្នុងវិហារនោះឯងចុះ, បើមិនមានសេចក្តីសុខសប្បាយ ក្នុងវិហារនោះទេ, វិហារដទៃទៀត ដែលជាទីសប្បាយ មាននៅក្នុងទីប្រវែង ១ គាវុត ឬ កន្លះយោជន៍ ឬក៏សូម្បីត្រឹមតែមួយយោជន៍ក៏ដោយ ក៏គួរអាស្រ័យនៅក្នុងវិហារនោះចុះ ៕ ព្រោះថាកាលបើអាស្រ័យនៅ យ៉ាងដូច្នេះ, កាលបើមានសេចក្តីសង្ស័យ ឬ កើតមានសេចក្តីភ្លេចភ្លាំងសតិ ក្នុងកម្មដ្ឋានផ្នែកណាមួយហើយ នឹងបានធ្វើវត្ត ក្នុងវិហារ តាំងអំពីព្រឹកព្រលឹមហើយត្រាច់ទៅបិណ្ឌបាត ក្នុងចន្លោះផ្លូវ ទៅដល់ទីលំនៅរបស់អាចារ្យ ក្នុងពេលឆាន់ភត្តកិច្ចរួចហើយ ជម្រះនូវកម្មដ្ឋាន ក្នុងសំណាក់អាចារ្យ ក្នុងថ្ងៃនោះ លុះដល់ព្រឹកឡើង ថ្វាយបង្គំអាចារ្យ ចេញទៅបិណ្ឌបាត ក្នុងចន្លោះផ្លូវ កាលមិនទាន់ហត់នឿយទេ ក៏អាចមកកាន់ទីលំនៅ របស់ខ្លួនបាន ៕ ចំណែកព្រះយោគីរូបណាមិនបាននូវទីកន្លែងដែលសុខសប្បាយ សូម្បីក្នុងទីប្រមាណមួយយោជន៍, ព្រះយោគីនោះ ត្រូវកាត់ទីដែលពកដុំ (ទើរទាក់) ទាំងអស់ ក្នុងកម្មដ្ឋានចេញហើយ ធ្វើកម្មដ្ឋាន ដែលជាប់ទាក់ទងនឹងការពិចារណា ដែលមានសេចក្តីល្អបរិសុទ្ធហើយ ទៅឲ្យឆ្ងាយ លះបង់នូវវិហារដែលមិនសមគួរ

ដល់ការចំរើនសមាធិចោលហើយ អាស្រ័យនៅក្នុងវិហារដ៏សមគួរចុះ ។

(វិហារដែលមិនសមគួរ)

ក្នុងវិហារដែលមិនសមគួរ និង វិហារដែលសមគួរទាំង ២ យ៉ាង នោះ វិហារដែលប្រកបហើយ ដោយទោស ១៨ ប្រការ ទោសណាមួយ ឈ្មោះថា វិហារដែលមិនសមគួរ ។

ក្នុងសេចក្ដីនោះ ទោសទាំងឡាយ ១៨ ប្រការនេះ គឺ :

(១) មហន្តត្តំ វិហារធំ,

(២) នវត្តំ វិហារទើបកសាងថ្មី,

(៣) ជិណ្ណត្តំ វិហារចាស់បាក់បែក,

(៤) បន្ថសន្និស្សិតត្តំ វិហារនៅក្បែរផ្លូវថ្នល់,

(៥) សោណ្ឌី វិហារមានត្រពាំងទឹក,

(៦) បណ្ណំ វិហារសម្បូរដោយស្លឹកឈើបន្លែ,

(៧) បុប្ផំ វិហារសម្បូរដោយផ្កាឈើ,

(៨) ផលំ វិហារសម្បូរដោយផ្លែឈើ,

(៩) បត្ថនីយតា វិហារដែលគេត្រូវការចុះចូលច្រើន,

(១០) នគរសន្និស្សិតតា វិហារដែលនៅក្នុងទីក្រុង,

(១១) ទារុសន្និស្សិតតា វិហារដែលនៅក្បែព្រៃឈើឧស,

(១២) ខេត្តសន្និស្សិតតា វិហារដែលអាស្រ័យនៅក្បែរស្រែ,

(១៣) វិសភាគានំ បុគ្គលានំ អត្ថិតា វិហារដែលមានបុគ្គលខុសប្លែកផ្សេងពីគ្នា,

(១៤) បដ្ដនសន្និស្សិតតា វិហារដែលនៅក្បែរកំពង់ចំណត,



(១៥) បច្ចន្តសន្និស្សិតតា វិហារដែលនៅក្នុងបច្ចន្តគ្រាម,

(១៦) រជ្ជសីមន្តរសន្និស្សិតតា វិហារដែលនៅក្នុងចន្លោះព្រំដែន,

(១៧) អសប្បាយតា វិហារដែលមិនជាទីសប្បាយ,

(១៨) កល្យាណមិត្តានំ អលាភោ វិហារដែលរកកល្យាណមិត្រមិនបាន ។

វិហារ ដែលប្រកបហើយ ដោយទោស ១៨ ប្រការនេះ ទោសណាមួយ ឈ្មោះថា វិហារមិនសមគួរ, ព្រះយោគី មិនត្រូវនៅក្នុងវិហារនោះទេ ។ ព្រោះហេតុអ្វី? ។

(មហន្តត្តំ)

ជាដំបូង ក្នុងវិហារធំ ភិក្ខុទាំងឡាយច្រើនរូប មានឆន្ទៈផ្សេងៗ គ្នា រួមប្រជុំគ្នា ។ ភិក្ខុទាំងនោះ មិនធ្វើវត្តដល់គ្នានឹងគ្នា ព្រោះភាពជាអ្នកមានការខុសចិត្តគំនិតគ្នា ។ ទីបរិវេណទាំងឡាយ មានទីលានដើមពោធិ៍ជាដើម ជាទីដែលមិនបានបោសហើយ, ទឹកសំរាប់ឆាន់ និង ទឹកសំរាប់ប្រើប្រាស់ ក៏មិនបានតាំងទុកឡើយ ។ ក្នុងវិហារនោះ ភិក្ខុនេះ គិតថា “អញ នឹងត្រាច់ទៅបិណ្ឌបាត ក្នុងគោចរគ្រាម” ដូច្នេះ ក៏កាន់បាត្រ និង ចីវរចេញទៅ បើឃើញកិច្ចវត្តដែលមិនទាន់ធ្វើ ឬក៏ ពាងទឹកឆាន់ ក៏ទទេ, កាលបើដូច្នោះ កិច្ចវត្តនោះ ជាកិច្ចវត្តដែលភិក្ខុនោះត្រូវធ្វើ, ទឹកសម្រាប់ឆាន់ ក៏ភិក្ខុនោះ ត្រូវដងដាក់ទុក ។ កាលភិក្ខុ មិនធ្វើត្រូវអាបត្តិ ព្រោះវត្តភេទ ។ កាលបើភិក្ខុនោះធ្វើកិច្ចវត្តនោះ វេលាក៏កន្លងទៅ ។ ភិក្ខុនោះចូលទៅ(ផ្ទះ)ថ្ងៃហួស កាលបើភិក្ខា អស់ហើយ ក៏មិនបានវត្ថុអ្វីឡើយ ។ សូម្បីភិក្ខុនោះ ជាអ្នកគេចចេញពីពួកហើយសម្ងំនៅ ក៏នឹងរាយមាយចិត្ត ដោយសំឡេងគឹកកង របស់សាមណេរ និង ភិក្ខុកម្លោះទាំងឡាយ និង

ដោយអំពើគឺការបៀតបៀនទាំងឡាយ ។ តែក្នុងមហាវិហារណា កិច្ចវត្ត ទាំងអស់ជាកិច្ចវត្តដែលគេធ្វើហើយ, សូម្បីការរំខានដទៃទៀត ក៏មិនមាន ក្នុងវិហារបែបនេះ សូម្បីជាវិហារធំ ភិក្ខុក៏គួរនៅបាន ។

(នវត្តំ)

ក្នុងវិហារថ្មី ការកសាងមានច្រើន ។ បុគ្គលទាំងឡាយ តែងលើក ទោសនូវភិក្ខុដែលមិនធ្វើ(នវកម្ម) ។ តែក្នុងវិហារថ្មីណា ភិក្ខុទាំងឡាយ ប្រាប់ថា "សូមលោកដ៏មានអាយុ ធ្វើសមណធម៌ចុះ យើងនឹងធ្វើនូវ នវកម្ម" ដូច្នេះ, ក្នុងវិហារថ្មីដូច្នេះ ភិក្ខុគួរនៅអាស្រ័យបាន ។

(ជិណ្ណត្តំ)

ចំណែកឯក្នុងវិហារចាស់ របស់របរដែលត្រូវថែទាំ មានច្រើន ។ ដោយហោចទៅ ភិក្ខុដែលមិនថែទាំសូម្បីត្រឹមតែសេនាសនៈ របស់ខ្លួន ភិក្ខុទាំងឡាយ ក៏លើកទោសដែរ ។ កាលបើភិក្ខុ (រវល់) តែរក្សាថែទាំ (សេនាសនៈនោះ), កម្មដ្ឋាន ក៏សាបសូន្យទៅ ។

(បន្ថសន្និស្សិតត្តំ)

ក្នុងវិហារដែលនៅក្បែរផ្លូវថ្នល់ គឺវិហារដែលនៅក្បែរផ្លូវធំ ភិក្ខុ អាគន្តុកៈទាំងឡាយ តែងមកប្រជុំគ្នា ទាំងថ្ងៃទាំងយប់ ។ កាលបើភិក្ខុ ទាំងនោះ មកក្នុងវេលាវិកាល ភិក្ខុត្រូវតែឲ្យសេនាសនៈ របស់ខ្លួនហើយ ទៅនៅអាស្រ័យក្រោមគល់ឈើ ឬក៏ លើផ្ទាំងនៃថ្មដា, សូម្បីដល់ស្អែក ឡើង ក៏នៅតែធ្វើដូច្នោះដដែល ព្រោះហេតុនេះ ឱកាស (ធ្វើ) កម្មដ្ឋាន ក៏មិនមាន ។ តែក្នុងវិហារដែលនៅក្បែរផ្លូវថ្នល់ណា សេចក្តីចង្អៀត ដោយ អាគន្តុកភិក្ខុបែបនេះមិនមានទេ, ភិក្ខុគួរនៅអាស្រ័យ ក្នុងវិហារដែលឋិត នៅក្បែរផ្លូវថ្នល់នោះបាន ។



(សោណ្ឌី)

ស្រះបោក្ខរណី ដែលមានថ្មដា ឈ្មោះថា ត្រពាំងទឹក, ក្នុងវិហារ ដែលមានត្រពាំងទឹកនោះ មហាជន តែងមកដងទឹកសំរាប់ផឹក ។ ពួក អន្តេវាសិកនៃព្រះថេរៈ ក្នុងរាជត្រកូល ដែលនៅអាស្រ័យ ក្នុងវត្ត ក្នុង ទីក្រុង នឹងមកដើម្បីប្រយោជន៍ដល់ការជ្រលក់ ។ កាលបើភិក្ខុទាំងនោះ សួរនូវគ្រឿងប្រើប្រាស់មានភាជនៈ, ឧស និង ស្នូកជាដើម, ភិក្ខុត្រូវតែ បង្ហាញប្រាប់ ថា : ក្នុងទីឯណោះ និង ក្នុងទីឯណោះ ។ ការជួយខ្វល់ ខ្វាយជានិច្ច នឹងមាន រហូតគ្រប់ពេលវេលា យ៉ាងដូច្នេះ ។

(បណ្ណំ)

ក្នុងវិហារណា មានស្លឹកឈើដែលជាបន្លែមានប្រការផ្សេងៗ កាល បើព្រះយោគីនោះ សូម្បីរៀនកម្មដ្ឋានហើយ អង្គុយសម្រាក នៅក្នុង វេលាថ្ងៃ ក្នុងវិហារនោះ, ពួកស្ត្រីដែលបេះបន្លែ នឹងមកច្រៀងបណ្តើរ បេះស្លឹកឈើបន្លែបណ្តើរ នៅក្នុងទីជិតៗ រមែងធ្វើអន្តរាយ ដល់កម្មដ្ឋាន ដោយការរំខាន ដោយសំឡេងដែលជាវិសភាគ ។

(បុប្ផំ)

ចំណែកក្នុងវិហារឯណា មានគុម្ពឈើមានផ្កា មានប្រការផ្សេងៗ មានផ្ការីកស្គុសស្គាយល្អ, សូម្បីក្នុងវិហារនោះ ក៏មានសេចក្តីអន្តរាយ យ៉ាងដូច្នោះបានដែរ ។

(ផលំ)

ក្នុងវិហារណា មានផ្លែឈើមានប្រការផ្សេងៗ ដូចជាផ្លែស្វាយ, ផ្លែ ជម្ពូ, ផ្លែខ្នុរជាដើម, ក្នុងវិហារនោះ មនុស្សអ្នកត្រូវការផ្លែឈើទាំងឡាយ នឹងមកសូម, កាលបើព្រះយោគី មិនឲ្យទេ, ពួកគេនឹងក្រោធខឹង ឬក៏

នឹងបេះយក ដោយធ្វើតាមកម្លាំង ។ ក្នុងវេលាល្ងាច ភិក្ខុនោះ ដើរចង្ក្រមត្រង់កណ្តាលវិហារ ឃើញមនុស្សទាំងនោះហើយ សួរថា “នែឧបាសក និង ឧបាសិកាទាំងឡាយ ព្រោះហេតុអ្វី ពួកអ្នកធ្វើយ៉ាងនេះ?” ដូច្នេះហើយ មនុស្សទាំងនោះ នឹងជេរស្តី តាមតែអំពើចិត្ត ទាំងព្យាយាមដើម្បីមិនឲ្យភិក្ខុនោះ អាស្រ័យនៅថែមទៀត ។

(បដ្ឋនីយតា)

ឯភិក្ខុដែលនៅ ក្នុងវិហារដែលគេត្រូវការចុះចូលច្រើន គឺវិហារដែលលោកតែងតាំងឲ្យ ដូចជាទក្ខិណាគិរីវិហារ, ហត្ថិកុច្ឆិវិហារ, ចេតិយគិរីវិហារ និង ចិត្តលបព្វតវិហារ មនុស្សទាំងឡាយលើកតម្កើងសរសើរថា “ភិក្ខុនេះ ជាព្រះអរហន្ត” ដូច្នេះហើយ ប្រាថ្នានឹងថ្វាយបង្គំ ក៏ហូរមកចុះចូល ដោយជុំវិញ ព្រោះហេតុនោះ សេចក្តីសុខ ទើបមិនមាន ដល់ភិក្ខុនោះ ។ តែវិហារនោះ ជាទីសប្បាយដល់ព្រះយោគីណា, ព្រះយោគីនោះ ត្រូវទៅក្នុងទីដទៃ ក្នុងវេលាថ្ងៃ, ក្នុងវេលាយប់ គួរទៅនៅចុះ ។

(នគរសន្និស្សិតតា)

ក្នុងវិហារដែលនៅក្នុងទីក្រុង វិសភាគារម្មណ៍ទាំងឡាយ តែងមកកាន់នូវផ្លូវ(នៃចក្ខុជាដើម), សូម្បីពួកនាងកុម្ភទាសី ក៏ដើរមក ប៉ះទង្គិចគ្នានឹងក្អមទឹកទាំងឡាយ មិនព្រមជៀសបើកផ្លូវឲ្យដែរ, សូម្បីពួកមនុស្សដែលជាឥស្សរជន ក៏មកបាំងរាំងនន អង្គុយនៅត្រង់កណ្តាលវិហារ ។

(ទារុសន្និស្សិតតា)

ចំណែកក្នុងវិហារ ដែលនៅក្បែរព្រៃឈើឧស គឺក្នុងវិហារដែលមានឈើឧស និង ដើមឈើសម្រាប់ប្រើធ្វើគ្រឿងផ្ទះ មនុស្សអ្នករកឧសទាំងឡាយ នឹងធ្វើសេចក្តីមិនសប្បាយ ដូចជាពួកអ្នកបេះបន្លែ និង អ្នក



បេះផ្កាឈើដូចបានពោលហើយ ក្នុងរឿងខាងដើម ។ មនុស្សទាំងឡាយគិតគ្នាថា “ពួកយើងនឹងកាត់ដើមឈើទាំងឡាយ ដែលមាននៅក្នុងវិហារមកធ្វើជាផ្ទះ” ដូច្នេះហើយ ក៏នាំគ្នាមកកាត់, បើពេលល្ងាច ព្រះយោគីចេញមកអំពីខ្ទម សម្រាប់បំពេញសេចក្តីព្យាយាម ដើរចង្ក្រម នៅត្រង់កណ្តាលវិហារឃើញមនុស្សទាំងនោះហើយពោលថា “នែឧបាសក និងឧបាសិកាទាំងឡាយ ព្រោះហេតុអ្វី បានជាពួកអ្នកធ្វើយ៉ាងនេះ?” ដូច្នេះ, មនុស្សទាំងនោះ នឹងជេរប្រទេច តាមតែចិត្តប្រាថ្នា នឹងព្យាយាមមិនឲ្យព្រះយោគីនោះនៅថែមទៀត ។

(ខេត្តសន្និស្សិតតា)

ឯវិហារណា មាននៅក្បែរទីស្រែ ព័ទ្ធជុំវិញដោយស្រែទាំងឡាយក្នុងវិហារនោះ ពួកមនុស្ស ធ្វើលានបញ្ជាន់ស្រូវ នៅត្រង់កណ្តាលវត្តនុ៎ះឯង ហាលស្រូវនៅចំពីមុខវត្ត នឹងធ្វើសេចក្តីមិនសប្បាយដទៃទៀត ជាច្រើន ។ សូម្បីក្នុងវិហារណា មានភោគសម្បត្តិ របស់សង្ឃជាច្រើន, ពួកអារាមិកជន ហាមហ្វូងគោ នៃត្រកូលទាំងឡាយ ទប់ផ្លូវទឹក, ពួកមនុស្សកាន់ទងស្រូវ ទៅបង្ហាញដល់ព្រះសង្ឃថា “សូមលោកម្ចាស់ទាំងឡាយ មើលនូវការងាររបស់ញោមវត្ត នៃលោកម្ចាស់ទាំងឡាយផងចុះ” ដូច្នេះ, ព្រោះហេតុនោះ ព្រះយោគីនោះ ត្រូវតែទៅកាន់ទ្វារនៃព្រះរាជវាំង និង ទ្វារផ្ទះនៃរាជមហាអាមាត្យ, សូម្បីវិហារ ដែលមានភោគសម្បត្តិរបស់សង្ឃដ៏ច្រើននេះ ក៏សង្គ្រោះចូលជាមួយនឹងវិហារ ដែលនៅក្បែរ ទីស្រែ បានដូចគ្នាដែរ ។

(វិសភាគានំ បុគ្គលានំ អត្ថិតា)

ពាក្យថា “ភាវៈនៃវិហារ ដែលមានបុគ្គលខុសប្លែកអំពីគ្នា” មាន

*វិនិច្ឆ័យថា: ក្នុងវិហារណា ភិក្ខុទាំងឡាយដែលជាវិសភាគ គឺដែលជាសឹកសត្រូវដល់គ្នានឹងគ្នា នៅអាស្រ័យ, ភិក្ខុទាំងឡាយណា ធ្វើការឈ្លោះទាស់ទែងនឹងគ្នា ត្រូវព្រះយោគី ហាមប្រាមថា "បពិត្រលោកអ្នកដ៏ចំរើនទាំងឡាយ សូមលោកទាំងឡាយ កុំធ្វើយ៉ាងនេះអី" ដូច្នេះ ភិក្ខុទាំងនោះ នឹងជាអ្នកពោលតប ថា "តាំងអំពីពេលដែលភិក្ខុអ្នកប្រព្រឹត្តបំសុកូលជាវត្តនេះមក (នៅ) ពួកយើងជាអ្នកវិនាសហើយ" ដូច្នេះ ។*

(បដ្ដនសន្និស្សិតតា)

*ឯវិហារណា នៅជាប់នឹងកំពង់ទឹក ឬ កំពង់ផ្លូវគោក, ក្នុងវិហារនោះ ពួកមនុស្សដែលមករឿយៗ តាមនាវា និង តាមរទេះទាំងឡាយ រមែងបៀតបៀន ធ្វើសេចក្ដីមិនសប្បាយ ដោយពាក្យថា "សូមលោកទាំងឡាយ ឲ្យនូវឱកាស ឲ្យនូវទឹកផឹក ឲ្យនូវអំបិល" ។*

(បច្ចន្តសន្និស្សិតតា)

*ចំណែកក្នុងវិហារ ដែលនៅជាប់នឹងជាយដែន មនុស្សទាំងឡាយជាអ្នកមិនជ្រះថ្លាហើយ ក្នុងព្រះរតនត្រៃមានព្រះពុទ្ធជាដើម ។*

(រជ្ជសីមន្តរសន្និស្សិតតា)

*ក្នុងវិហារដែលនៅចន្លោះព្រំដែន រាជភ័យនឹងមាន ។ ព្រោះថា ព្រះរាជាមួយអង្គ ទ្រង់ត្រាស់ថា "ទឹកន្លែងនេះ មិនទាន់បានប្រព្រឹត្តទៅ ក្នុងអំណាចរបស់អញ" ដូច្នេះហើយ ក៏វាយយកទីកន្លែងនោះ ។ ឯព្រះរាជាមួយអង្គផ្សេងទៀត ទ្រង់ត្រាស់ថា "ទីកន្លែងនេះ មិនទាន់ធ្លាក់មក លើអំណាចរបស់អញ" ដូច្នេះហើយ ក៏វាយយកទីកន្លែងនោះ ។ ក្នុងវិហារនោះ ភិក្ខុនេះ ពេលខ្លះ ត្រាច់ទៅក្នុងដែនដីព្រះរាជាអង្គនេះ, ពេលខ្លះក៏ត្រាច់ទៅ ក្នុងដែនដី នៃព្រះរាជាអង្គដទៃទៀត ។ កាលបើដូច្នោះ អ្នក*



*រាជការទាំងឡាយ សម្គាល់ថា "ភិក្ខុរូបនេះ ជាចារបុរស" ដូច្នេះ នឹងធ្វើឲ្យដល់នូវសេចក្ដីវិនាសអន្តរាយ ។*

(អសប្បាយតា)

*ពាក្យថា* "ភាវៈនៃវិហារដែលមិនជាទីសប្បាយ" *មានវិនិច្ឆ័យ ថា: ភាវៈនៃវិហារ ឈ្មោះថា មិនជាទីសប្បាយ ព្រោះជាទីដែលប្រមូលផ្ដុំនូវវិសភាគារម្មណ៍មានរូបជាដើម ឬ ព្រោះជាទីដែលអមនុស្សហួងហែងហើយ ។ ក្នុងវិហារនោះ មានរឿងនេះ (ជាឧទាហរណ៍) ។*

*មានរឿងដំណាលមកថា ព្រះថេរៈមួយអង្គអាស្រ័យនៅក្នុងព្រៃ ។ គ្រានោះ នាងយក្ខិនីមួយ ឈរច្រៀងនៅក្បែរទ្វារបណ្ណសាលា របស់ព្រះថេរៈនោះ ។ ព្រះថេរៈនោះចេញមកឈរនៅត្រង់មាត់ទ្វារ ។ នាងយក្ខិនីនោះ មកច្រៀងនៅត្រង់ដើមទីចង្ក្រមន៍ ។ ព្រះថេរៈ បានទៅកាន់ដើមនៃទីចង្ក្រមន៍ ។ នាងយក្ខិនីនោះ ក៏ទៅឈរច្រៀងនៅត្រង់មាត់ជ្រោះជ្រៅប្រវែងមួយរយជួរនៃបុរស ។ ព្រះថេរៈ ក៏ត្រឡប់មកវិញ ។ ពេលនោះនាងយក្ខិនីនោះ ក៏ប្រញាប់មកចាប់ព្រះថេរៈនោះ ហើយស្រែកថា "នៃវើយ មនុស្សដូចជាអ្នកឯង យើងមិនមែនស៊ីតែម្នាក់ពីរនាក់ទេ" ដូច្នេះ ។*

(កល្យាណមិត្តានំ អលាភោ)

*ពាក្យថា* "វិហារដែលរកកល្យាណមិត្រមិនបាន" *សេចក្ដីថា ក្នុងវិហារណា ព្រះយោគី មិនអាចរកអាចារ្យ ឬ ភិក្ខុដែលស្មើនឹងអាចារ្យ ព្រះឧបជ្ឈាយ៍ ឬក៏ ភិក្ខុដែលស្មើនឹងព្រះឧបជ្ឈាយ៍ ដែលជាកល្យាណមិត្របានទេ, ការមិនបាន នូវកល្យាណមិត្រនោះ ក្នុងវិហារនោះ មានទោសធំមែនពិត ។*

*វិហារ ដែលប្រកបព្រមហើយ ដោយទោសទាំង ១៨ ប្រការនេះ*

ទោសណាមួយ បណ្ឌិត គប្បីជ្រាបថា វិហារដែលមិនសមគួរ ។

មែនពិត ក្នុងអដ្ឋកថាទាំងឡាយ លោកពោលគាថាព័ន្ធនេះ ថា :

> បណ្ឌិតដឹងនូវទីទាំងឡាយ ១៨ យ៉ាងនេះ គឺអាវាសដែលធំ ១, អាវាសដែលថ្មី ១, អាវាសដែលចាស់គ្រាំគ្រា ១, អាវាសដែលនៅក្បែរផ្លូវ ១, អាវាសដែលមានត្រពាំងទឹក ១, អាវាសដែលមានស្លឹកឈើបន្លែ ១, អាវាសដែលមានផ្កាឈើ ១, អាវាសដែលមានឈើមានផ្លែ១, អាវាសដែលមនុស្សចុះចូល ១, អាវាសដែលនៅក្នុងទីក្រុង ១, អាវាសដែលនៅក្បែរព្រៃឈើឱស ១, អាវាសដែលនៅក្បែរស្រែ ១, អាវាសដែលមានភិក្ខុខុសផ្សេងអំពីគ្នា ១, អាវាសដែលនៅក្បែរកំពង់ទឹក ១, អាវាសដែលនៅក្នុងបច្ចន្តគ្រាម ១, អាវាសដែលនៅ ក្នុងចន្លោះព្រំដែន ១, អាវាសដែលមិនជាទីសប្បាយ ១, អាវាសដែលរកមិត្រមិនបាន ១ ដូច្នេះហើយ គប្បីជៀសវាងឲ្យបានឆ្ងាយ ដូចជាបុគ្គលជៀសវាងផ្លូវ ដែលមានភ័យចំពោះមុខ យ៉ាងដូច្នោះឯង ។

(វិហារដែលសមគួរ)

ចំណែកវិហារណា ប្រកបដោយអង្គ ៥ មានវិហារដែលមិនឆ្ងាយពេក មិនជិតពេក អំពីគោចរគ្រាមជាដើម, វិហារនេះ ឈ្មោះថា វិហារដែលសមគួរ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក៏សេនាសនៈប្រកបដោយអង្គ ៥ តើយ៉ាងដូច



ម្ដេច? ម្នាលភិក្ខុទាំងឡាយ សេនាសនៈក្នុងសាសនានេះ ជាសេនាសនៈដែលមិនឆ្ងាយពេក មិនជិតពេក ដើរទៅមកស្រួល ពេលថ្ងៃ មិនច្រឡូកច្រឡំ ពេលយប់ ស្ងាត់ មិនមានឮសូរសំឡេង ស្រែកជជែកគ្នា ប្រាសចាកសម្ផស្សនៃរបោម, មូស, ខ្យល់, កំដៅថ្ងៃ, និង ពស់តូច ពស់ធំ, ក៏បើភិក្ខុនៅក្នុងសេនាសនៈនោះ, ចីវរ, បិណ្ឌបាត, សេនាសនៈ និងគិលានបច្ចយភេសជ្ជបរិក្ខារទាំងឡាយ រមែងកើតឡើងដោយមិនលំបាកឡើយ ។ មួយទៀត ភិក្ខុទាំងឡាយ ដែលជាព្រះថេរៈ ជាពហុស្សូតស្ទាត់ជំនាញក្នុងព្រះបរិយត្តិ ទ្រទ្រង់ធម៌ទ្រទ្រង់ព្រះវិន័យ ទ្រទ្រង់មាតិការមែងនៅ ក្នុងសេនាសនៈនោះ, ភិក្ខុ ចូលទៅរកព្រះថេរៈទាំងនោះ តាមកាលដ៏សមគួរហើយ សាកសួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចំរើន បទនេះ តើដូចម្ដេច? សេចក្ដីនៃបទនេះ តើដូចម្ដេច?" ដូច្នេះ, ព្រះថេរៈ ដ៏មានអាយុទាំងនោះ រមែងបើកបង្ហាញ នូវធម៌ដែលមិនទាន់បានបើកបង្ហាញ រមែងធ្វើធម៌ដែលជ្រាលជ្រៅ ឲ្យរាក់មកវិញ និង បន្ទោបង់នូវសេចក្ដីសង្ស័យ ក្នុងធម៌ទាំងឡាយ ដែលគួរឲ្យសង្ស័យមានច្រើន ជាអនេក, ម្នាលភិក្ខុទាំងឡាយ សេនាសនៈ ប្រកបដោយអង្គ ៥ យ៉ាងដូច្នេះឯង" ។ នេះជាសេចក្ដីពិស្ដារ ក្នុងពាក្យនេះថា "លះបង់នូវវិហារដែលមិនសមគួរ ដល់ការចំរើនសមាធិ ហើយនៅអាស្រ័យ ក្នុងវិហារដែលសមគួរ" ដូច្នេះ ។

(ការផ្ដាច់បង់បលិពោធតូចៗ)

ត្រង់ដែលថា "ត្រូវផ្ដាច់បង់នូវបលិពោធតូចៗ" នេះ បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ដូចតទៅ: ព្រះយោគីដែលនៅអាស្រ័យ ក្នុងវិហារដ៏សមគួរ យ៉ាងនេះ គប្បីផ្ដាច់បង់បលិពោធទាំងឡាយតូចៗ ដែលមាន

ដល់ខ្លួនទាំងនោះចោលឲ្យអស់ ។ បលិពោធតូចៗនោះ តើដូចម្តេចខ្លះ?។ គឺ: សក់វែង, ក្រចកវែង, រោមវែង ត្រូវកាត់ចេញ, ត្រូវធ្វើឲ្យមាំ ឬ ធ្វើការប៉ះ ក្នុងចីវរដែលចាស់គ្រាំគ្រាទាំងឡាយ ឬក៏ ត្រូវជ្រលក់ចីវរដែលសៅហ្មងឲ្យហើយ, បើក្នុងបាត្រមានប្រេះ ត្រូវដុតចេញ, សេនាសនៈមានគ្រែ និង តាំងជាដើម ត្រូវជម្រះឲ្យបានស្អាតល្អ ។ នេះ ជាសេចក្តីពិស្តារ ក្នុងពាក្យថា “ត្រូវផ្តាច់បង់នូវបលិពោធតូចៗ” នេះ ។

(វិត្ថារកថានៃភាវនាវិធី)

(៨២) ការពណ៌នានេះ ជាការពណ៌នាយ៉ាងពិស្តារ ក្នុងពាក្យដែលថា “ព្រះយោគី មិនត្រូវញ៉ាំងភាវនាវិធីទាំងពួង ឲ្យសាបសូន្យ ចំរើនសមាធិចុះ” នេះ ដោយអំណាចកម្មដ្ឋានទាំងពួង ចាប់តាំងពីបឋវីកសិណជាដើមឡើងទៅ ក្នុងពេលឥឡូវនេះ ។

(បឋវីកសិណ)

សេចក្តីពិស្តារថា ភិក្ខុដែលបានផ្តាច់បង់បលិពោធតូចៗ យ៉ាងនេះស្រេចហើយ ត្រឡប់មកពីបិណ្ឌបាតហើយ ក្រោយពេលភត្តកិច្ច បន្ទោបង់នូវការស្រវឹងហាល់ ក្នុងអាហារហើយ អង្គុយឲ្យបានសប្បាយ ក្នុងឱកាសដែលស្ងប់ស្ងាត់ គប្បីកាន់យកនិមិត្ត ក្នុងដីដែលបានធ្វើទុកហើយ ឬក៏ មិនបានធ្វើទុកហើយក៏បាន ។ មែនពិត ពាក្យនេះ លោកបានពោលហើយថា “ព្រះយោគាវចរ អ្នករៀនយកបឋវីកសិណ រមែងកាន់យកនិមិត្ត ក្នុងដីដែលបានធ្វើទុកហើយ ឬ មិនបានធ្វើទុកហើយ ជាដីដែលមានទីបំផុត មិនមែនមិនមានទីបំផុត មានកំណត់មិនមែនមិនមានកំណត់ មានរាងមូល មិនមែនមិនមានរាងមូល មានទីបំផុតដោយជុំវិញ មិនមែនមិនមានទីបំផុត ដោយជុំវិញ មានទំហំប៉ុនចង្អេរ ឬក៏ មានទំហំប៉ុនចាន,



ភិក្ខុនោះ ធ្វើនិមិត្តនោះ ឲ្យបាននៅជាប់ល្អ ពិចារណាឲ្យបានល្អ កំណត់ចំណាំ ឲ្យបានត្រឹមត្រូវ, ភិក្ខុនោះ លុះធ្វើនិមិត្តនោះ ឲ្យបាននៅជាប់ល្អហើយ ពិចារណា កំណត់ឲ្យបានល្អ ត្រឹមត្រូវហើយ ជាអ្នកឃើញនូវអានិសង្ស ជាអ្នកមានសេចក្តីសម្គាល់ ថា ជារតនៈ ហើយ ចាប់ផ្តើមនូវសេចក្តីកោតក្រែង ប្រព្រឹត្តស្រឡាញ់ ចូលចិត្ត ចងចិត្តឲ្យជាប់ ក្នុងអារម្មណ៍នោះ ដោយជឿច្បាស់ ថា “អាត្មាអញ នឹងរួចផុតអំពីជរា និងមរណៈ ដោយបដិបទានេះមែនពិត” ដូច្នេះ, ភិក្ខុនោះ ស្ងាត់ចាកកាមទាំងឡាយមែនពិត ។ល។ សំរេចចូលដល់បឋមឈានហើយ” ដូច្នេះឯង ។

ព្រះយោគាវចរ ឯណា ធ្លាប់បួសក្នុងព្រះសាសនា ឬក៏ បួសជាតាបសឥសី ញ៉ាំងចតុក្កជ្ឈាន ឬ បញ្ចកជ្ឈាន ឲ្យកើតឡើងហើយ ក្នុងបឋវីកសិណ សូម្បីក្នុងអតីតភព, និមិត្ត ក្នុងដីដែលមិនបានធ្វើទុកហើយ ក្នុងពាក្យដែលលោកបានពោលហើយនោះ គឺក្នុងទីដែលគេបានភ្ជួរហើយ ឬក៏ ក្នុងមណ្ឌលនៃទីលានបញ្ជាន់ស្រូវ រមែងកើតឡើង ដល់ព្រះយោគាវចរនោះ ដែលជាអ្នកមានបុណ្យបរិបូណ៌ហើយដោយឧបនិស្ស័យដូចជាព្រះមល្លកត្ថេរ យ៉ាងដូច្នោះ ។

បានឮមកថា កាលបើលោកដ៏មានអាយុអង្គនោះ ក្រឡេកមើលទី(ស្រែ)ដែលគេភ្ជួរហើយ, និមិត្ត ទំហំប៉ុនទី(ស្រែ)នោះ ក៏បានកើតឡើង។ ព្រះថេរៈនោះ ពង្រីកនិមិត្តនោះ ញ៉ាំងបញ្ចកជ្ឈាន ឲ្យកើតឡើង ចំរើនវិបស្សនា ដែលមានឈានជាបទដ្ឋានហើយ ក៏បានសំរេចព្រះអរហត្ត ។

ចំណែកព្រះយោគាវចរណា ជាអ្នកមិនបានធ្វើបុញ្ញាធិការទុក យ៉ាងនេះទេ, ព្រះយោគាវចរនោះ មិនគួរធ្វើកម្មដ្ឋានវិធី ដែលខ្លួនបានរៀនហើយ ក្នុងសំណាក់នៃអាចារ្យ ឲ្យខុសក្បាត់ឡើយ វៀរចាកទោស នៃ

កសិណ ៤ ប្រការចេញ គប្បីធ្វើកសិណចុះ ។ ក៏ទោសនៃបឋវីកសិណ មាន ៤ ប្រការ ដោយអំណាចនៃការលាយឡំដោយដី មានពណ៌ខៀវ, ដីពណ៌លឿង, ដីពណ៌ក្រហម និង ដីពណ៌-ស ។ ព្រោះហេតុនោះ ព្រះយោគាវចរ មិនត្រូវយកដីស្អិត ដែលមានពណ៌លាយដោយពណ៌ខៀវជាដើម គប្បីធ្វើកសិណ ដោយដីស្អិតដែលមានពណ៌ដូចជាពណ៌ នៃព្រះអរុណ ដូចជាដីស្អិត ក្នុងផ្ទៃនៃទន្លេគង្គា ។ ក៏កសិណនោះឯង មិនត្រូវធ្វើក្នុងទីជាទីត្រាច់ទៅ នៃអនុបសម្បន្នទាំងឡាយ មានសាមណេរជាដើម នៅចំកណ្ដាលវិហារឡើយ ។ តែគួរធ្វើ ក្នុងទីដែលបិទបាំង ត្រង់ជាយដែននៃវិហារ ក្នុងញកភ្នំ ឬក៏ ក្នុងបណ្ណសាលា ធ្វើឲ្យទៅជារបស់ដែលរំកិលបាន ឬក៏ ធ្វើឲ្យនៅជាប់នឹងកន្លែងនោះ ក៏បាន ។

(**វិធីធ្វើកសិណដែលរំកិលបាន**)

ក្នុងវង់កសិណទាំង២ យ៉ាងនោះ វង់កសិណដែលរំកិលបាន គប្បីចងនូវកំណាត់សំពត់ចាស់ កំណាត់ស្បែក ឬក៏ កំណាត់កន្ទេល ភ្ជាប់នឹងបង្គោលឈើ ៤ ហើយយកដីដែលបានរើសយកឫសស្មៅ, ដុំក្រួស និងដីខ្សាច់ចេញអស់ហើយ ប្របាច់ល្អហើយ មកលាបធ្វើជាវង់មូល មានទំហំ ដូចបានពោលមកហើយ នៅលើកំណាត់សំពត់ កំណាត់ស្បែក និង កំណាត់កន្ទេលដែលបានចងទុកនោះ ។ វង់កសិណដែលរំកិលបាន នោះក្នុងពេលបរិកម្ម ត្រូវក្រាលឲ្យរាបលើផែនដីហើយសំឡឹងមើលចុះ។

(**វិធីធ្វើកសិណដែលនៅនឹងកន្លែង**)

វង់កសិណ ដែលនៅជាប់នឹងកន្លែងនោះ ត្រូវបោះបង្គោលទាំងឡាយ ក្នុងផែនដី ដោយអាការដូចជាត្របកឈូកហើយ យកវល្លិទាំងឡាយ មកចងផ្អោបស្រេចហើយធ្វើចុះ ។ បើសិនជាដីនោះ មិនគ្រប់



គ្រាន់ទេ ត្រូវយករបស់ដទៃដាក់ខាងក្រោមហើយ ធ្វើវង់កសិណ ឲ្យមានរាងមូលប្រវែង ទទឹង ១ ចំអាម ៤ ធ្នាប់ ដោយដីដែលមានពណ៌ ដូចជាព្រះអរុណ ដែលបានលាងស្អាតល្អហើយពូន់ខាងលើ ។ មែនពិត ពាក្យថា “មានទំហំប៉ុនចង្អេរ ឬ មានទំហំប៉ុនចាន” លោកពោលសំដៅយកនូវប្រមាណ ១ ចំអាម ៤ ធ្នាប់នុ៎ះឯង ។ ចំណែកពាក្យថា “ជាដីដែលមានទីបំផុត មិនមែនជាដីដែលមិនមានទីបំផុត” ដូច្នេះជាដើម លោកពោលហើយ ដើម្បីប្រយោជន៍ដល់ការកំណត់បឋវីនិមិត្តនោះ ។ ព្រោះហេតុនោះ ព្រះយោគាវចរកុលបុត្រ ធ្វើវង់កសិណ ឲ្យបានជាខ្នាត មានប្រមាណ ដូចបានពោលមកនេះហើយ ញ៉ាំងពណ៌ដែលមានចំណែកមិនស្មើ ឲ្យកើតឡើង ដោយស្នាបព្រាបាយអដែលធ្វើពីឈើ ។ ព្រោះហេតុនោះ ព្រះយោគាវចរ មិនត្រូវយកស្នាបព្រាបាយអនោះ ត្រូវយកស្នាបព្រាធ្វើពីថ្ម ត្រដុសធ្វើ ឲ្យបានរាបស្មើ ដូចជាផ្ទៃនៃស្គរ បោសទីកន្លែងនោះ ទៅងូតទឹកហើយ ត្រូវមកវិញ អង្គុយលើតាំងដែលបានរៀបចំល្អស្រេចហើយ មានជើងកំពស់ ១ ចំអាម ៤ ធ្នាប់ ដែលខ្លួនបានរៀបទុកហើយ ក្នុងទីកន្លែងដែលមានចន្លោះ ២ ហត្ថ ១ ចំអាម អំពីមណ្ឌលកសិណ ។ ព្រោះថា បើព្រះយោគី អង្គុយឆ្ងាយជាងនោះ កសិណ នឹងមិនប្រាកដឡើយ ។ បើអង្គុយនៅជិតជាងនោះ ទោស របស់កសិណនឹងប្រាកដច្បាស់ ។ មួយទៀត ព្រះយោគីអង្គុយខ្ពស់ពេក នឹងត្រូវឱនក សំឡឹងមើល ។ អង្គុយទាបពេក ក្បាលជង្គង់នឹងឈឺ ។ ព្រោះហេតុនោះ ព្រះយោគីត្រូវអង្គុយ តាមន័យដែលបានពោលមកហើយតែម្យ៉ាងហើយ ពិចារណាទោស ក្នុងកាមទាំងឡាយ ដោយន័យមានជាអាទិ៍ថា “កាមទាំងឡាយ មានសេចក្ដីត្រេកអរ មានប្រមាណតិច” ដូច្នេះ កើត

សេចក្តីពេញចិត្ត ក្នុងនេក្ខម្មៈ ដែលជាគ្រឿងរលាស់ខ្លួនចេញចាកកាម ជាឧបាយកន្លងផុតពីសេចក្តីទុក្ខទាំងពួងបាន ញ៉ាំងបីតិ និង បាមោជ្ជៈ ឲ្យកើតឡើង ដោយកិរិយារឭកដល់គុណរបស់ព្រះពុទ្ធ, ព្រះធម៌ និង ព្រះសង្ឃហើយ មានសេចក្តីគោរពកើតឡើង ក្នុងសេចក្តីប្រតិបត្តិ ដោយគិតថា "ឥឡូវនេះ នេក្ខម្មប្បដិបទា នេះនោះ គឺជាផ្លូវដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះសាវក រាល់ព្រះអង្គ តែងបានប្រតិបត្តិមកហើយ" ដូច្នេះហើយ ត្រូវញ៉ាំងសេចក្តីឧស្សាហ៍ ឲ្យកើតឡើង ដោយនឹកសង្ឃឹមថា "អញ មុខជានឹងបានចំណែកនៃរស នៃសេចក្តីសុខ ក្នុងវិវេក ដោយសេចក្តីប្រតិបត្តិនេះ មិនខានឡើយ" ដូច្នេះ ទើបបើកភ្នែកឡើង ដោយអាការដ៏សមគួរ កាន់យកនូវនិមិត្តហើយគប្បីចំរើន ។ ព្រោះថា អ្នកប្រឹងបើកភ្នែកសំឡឹងមើល ភ្នែក នឹងរោយលំបាកផង មណ្ឌលកសិណ នឹងប្រាកដហួសពេកផង ។ ដោយវិធីនោះ និមិត្ត នឹងមិនកើតឡើងដល់ព្រះយោគីនោះឡើយ ។ ព្រះយោគី ដែលបើកភ្នែកព្រឹមៗ សំឡឹងមើល, វង់ (កសិណ)នឹងមិនប្រាកដ, ឯចិត្តសោត ក៏ជាធម្មជាតរួញរាទៅផង, សូម្បីដោយវិធីយ៉ាងនេះ និមិត្តក៏មិនកើតឡើងបានដែរ ។ ហេតុនោះ ព្រះយោគី ត្រូវបើកភ្នែកមើល ដោយអាការសមគួរ ដូចជាមើលស្រមោលមុខ ក្នុងផ្ទៃនៃកញ្ចក់ យ៉ាងនោះឯង ហើយគប្បីកំណត់យកនិមិត្ត ចំរើនចុះ ។ ព្រះយោគី មិនត្រូវពិចារណាពណ៌នៃកសិណទេ ។ ព្រះយោគី មិនត្រូវធ្វើទុកក្នុងចិត្តនូវលក្ខណៈទេ ។ តែថា នឹងលះបង់ពណ៌ចោល ក៏មិនបាន ត្រូវធ្វើពណ៌ ឲ្យជារបស់ស្មើគ្នានឹងនិស្ស័យ តាំងចិត្តនៅ ក្នុងបណ្ណត្តិធម៌ ហើយធ្វើទុកក្នុងចិត្ត ដោយអំណាចនៃឧស្សន្នវោហារ ។ ព្រះយោគី ប្រាជ្ញាឈ្មោះផែនដីណាមួយ បណ្តាឈ្មោះផែនដីទាំងឡាយ



ដូចជាបឋវី, មហី, មេទនី, ភូមិ, វសុធា, វសុន្ធរា ដូច្នេះជាដើម, ផែនដីឈ្មោះណា សមគួរដល់សញ្ញា របស់ព្រះយោគីនោះ, ឈ្មោះនោះ ព្រះយោគីគប្បីពោល ។ តែថា ឈ្មោះនេះឯងថា "បឋវី" ដូច្នេះ ជាឈ្មោះប្រាកដ ។ ព្រោះហេតុនោះ ព្រះយោគីត្រូវភាវនាថា "បឋវីបឋវី" ដោយអំណាចនៃឈ្មោះដែលប្រាកដចុះ ។ ព្រះយោគី ត្រូវបើកភ្នែកពិចារណាតាមកាល ត្រូវធ្មេចភ្នែកពិចារណា តាមកាល ។ ដរាបណា ឧគ្គហនិមិត្ត មិនទាន់កើតឡើង ព្រះយោគីគប្បីភាវនា តាមន័យនោះឯង ដរាបនោះ សូម្បីអស់កាល ១០០ ដងក្តី ១០០០ ដងក្តី សូម្បីច្រើនដងជាងនោះក្តី។ កាលបើព្រះយោគីនោះចំរើនយ៉ាងដូច្នេះ ពេលណា ព្រះយោគីធ្មេចភ្នែកហើយ នឹកនិមិត្តមកកាន់រង្វង់នៃចក្ខុ ដូចជាក្នុងពេលដែលបើកភ្នែកមើល ក្នុងពេលនោះ ឧគ្គហនិមិត្ត ឈ្មោះថា កើតហើយ ។ ចាប់ដើមតាំងអំពីឧគ្គហនិមិត្តនោះ កើតហើយ ព្រះយោគី មិនត្រូវអង្គុយ ក្នុងទីនោះទេ ។ ត្រូវចូលទៅកាន់ទីនៅ របស់ខ្លួន ហើយអង្គុយ ចំរើនក្នុងទីនោះ ។ មួយទៀត ព្រះយោគីនោះ គប្បីប្រាថ្នាស្បែកជើងមានជាន់ ១ និង ឈើច្រត់ចាស់ ដើម្បីកំចាត់បង់ នូវការយឺតយូរ ដោយការលាងជើង ។ លំដាប់នោះ ថាបើ សមាធិ នៅខ្ចី វិនាសទៅ ដោយហេតុមិនជាទីសប្បាយណាមួយ, ព្រះយោគីនេះ ត្រូវពាក់ស្បែកជើង កាន់ឈើច្រត់ចាស់ ទៅកន្លែងនោះ កាន់យកនូវនិមិត្តហើយ មកអង្គុយចំរើន ឲ្យបានស្រួលបួល ត្រូវប្រមូល (និមិត្ត) មកជារឿយៗ ត្រូវធ្វើឲ្យជានិមមិត្ត ដែលខ្លួននាំមកហើយ ដោយសេចក្តីត្រិះរិះ ដែលខ្លួននាំមកហើយ ដោយសេចក្តីត្រិះរិះវិសេស ។ កាលបើព្រះយោគីនោះ ធ្វើយ៉ាងនេះ, នីវរណៈទាំងឡាយ នឹងស្ងប់, កិលេសទាំងឡាយ នឹងស្ងប់ស្ងាត់ ដោយលំដាប់, ចិត្ត នឹង

តម្កល់នៅមាំ ដោយឧបចារសមាធិ, បដិភាគនិមិត្ត ក៏កើតឡើង ។

(ការផ្សេងគ្នានៃឧគ្គហនិមិត្ត និង បដិភាគនិមិត្ត)

នេះជាសេចក្តីផ្សេងគ្នានៃឧគ្គហនិមិត្ត ដែលពោលមកខាងដើម និង បដិភាគនិមត្តនេះ ក្នុងពាក្យដែលបានពោលមកហើយនោះ ។

ក្នុងឧគ្គហនិមិត្ត ទោស របស់កសិណ រមែងប្រាកដ ។ បដិភាគ-និមិត្ត ហាក់ដូចជាទំលាយ នូវឧគ្គហនិមិត្ត ចេញមកប្រាកដឡើង ដូចជានិមិត្តដែលបរិសុទ្ធល្អ ជាងឧគ្គហនិមិត្តនោះ ១០០ ដង ១.០០០ ដង ដូចជាផ្ទាំងនៃកញ្ចក់ដែលបុគ្គលយកចេញអំពីស្រោម ដូចជាសម្បកនៃស័ង្ខ ដែលបុគ្គលដុសខាត់ល្អហើយ ដូចជាមណ្ឌលនៃព្រះច័ន្ទ ដែលចេញអំពីចន្លោះ នៃពពក ដូចជាហ្វូងសត្វកុក ខាងមុខពពក ។ តែថា និមិត្តនោះ ជារបស់ដែលមិនមានពណ៌ មិនមានសណ្ឋានមែនពិត ។ ក៏ប្រសិនបើ បដិភាគនិមិត្តនោះ គប្បីជានិមិត្តបែបនេះ, ជានិមិត្ត គឺព្រះយោគីគប្បីដឹងច្បាស់ដោយចក្ខុ ជារបស់គ្រោតគ្រាត ចូលដល់ការពិចារណា គឺត្រៃ-លក្ខណ៍ គ្របសង្កត់ហើយ ។ តែថាបដិភាគនិមិត្តនេះ មិនមែនបែបនោះទេ ។ តាមពិត បដិភាគនិមិត្តនេះ កើតពីសញ្ញាហ្នឹងឯង ត្រឹមតែអាការៈដែលប្រាកដឡើង ដល់ព្រះយោគីអ្នកដែលបាននូវសមាធិប៉ុណ្ណោះឯង ។ ចំណែកនីវរណៈទាំងឡាយ ត្រូវសមាធិ ញាំញីហើយមែនពិត, កិលេសទាំងឡាយ ក៏ស្ងប់ស្ងាត់ហើយដែរ ចាប់ដើមតាំងតែអំពីបដិភាគនិមិត្តនោះ កើតឡើងហើយ ។ ចិត្ត ជាធម្មជាតតាំងនៅមាំល្អហើយ ដោយឧបចារសមាធិ ដោយពិត ។

(សមាធិ ២ ផ្សេងគ្នា)

ក៏សមាធិមានពីរប្រការ គឺឧបចារសមាធិ ១ អប្បនាសមាធិ ១ ។



ចិត្ត តែងតាំងនៅមាំ ដោយអាការៈទាំងឡាយ ២ ក្នុងឧបចារភូមិ ១ ក្នុងបដិលាភភូមិ១ ។ បណ្តាភូមិទាំងពីរនោះ ចិត្ត ជាសមាធិ ក្នុងឧបចារភូមិ ដោយការលះបង់នូវនីវរណៈ។ ចិត្ត ជាសមាធិ ក្នុងបដិលាភភូមិ ដោយភាពប្រាកដនៃអង្គ ។ ប៉ុន្តែការធ្វើឲ្យផ្សេងៗគ្នានៃសមាធិទាំងពីរ គឺយ៉ាងដូច្នេះ ក្នុងឧបចារៈ អង្គទាំងឡាយ ជាអង្គដែលមិនទាន់មានកម្លាំង កើតឡើង ។ ព្រោះអង្គទាំងឡាយ មិនទាន់មានកម្លាំងកើតឡើង កាលបើឧបចារសមាធិ កើតឡើងហើយ, ចិត្ត ទើបធ្វើនូវនិមិត្ត ឲ្យជាអារម្មណ៍តាមកាល ក៏ចុះស៊ប់ទៅកាន់ភវង្គ តាមកាល ប្រៀបដូចជាកុមារដែលនៅក្មេងខ្ចី ដែលត្រូវគេលើកឲ្យឈរ តែងដួលទៅលើផែនដី ជារឿយៗយ៉ាងដូច្នោះឯង ។ តែថា ក្នុងអប្បនា អង្គទាំងឡាយជាអង្គមានកម្លាំងកើតហើយ ។ ព្រោះភាវៈនៃអង្គទាំងឡាយ មានកម្លាំងកើតឡើងហើយ កាលបើអប្បនាសមាធិ កើតឡើងហើយ ឈានចិត្ត កាត់ផ្តាច់ភវង្គវារៈអស់វារៈមួយដងហើយ រមែងតាំងនៅ គឺរមែងប្រព្រឹត្តទៅដោយអំណាចនៃលំដាប់ នៃកុសលជវនៈ រហូតទាំងយប់ទាំងថ្ងៃតែម្តង ប្រៀបដូចជាបុរសដែលមានកម្លាំង ក្រោកចាកអាសនៈ គប្បីឈរអស់មួយថ្ងៃបានយ៉ាងនោះឯង ។

ក្នុងសមាធិទាំង ២ យ៉ាងនោះ បដិភាគនិមិត្តនេះឯណា កើតឡើងហើយ មួយអន្លើដោយឧបចារសមាធិ, ឈ្មោះថា ការញ៉ាំងបដិភាគនិមិត្តនោះ ឲ្យកើតឡើង គឺព្រះយោគីធ្វើបាន ដោយកម្រក្រៃពេក ។ ព្រោះហេតុនោះ ថាបើព្រះយោគី អាចធ្វើនិមិត្តនោះ ឲ្យចំរើន(រហូតដល់) បានសម្រេចអប្បនា ដោយភ្លែននោះឯង, ការបាននោះ គឺជាការល្អ, តែបើមិនអាចទេ លំដាប់នោះ ព្រះយោគីនេះ គប្បីជាអ្នកមិនប្រមាទ រក្សា

និមិត្តនោះឲ្យបាន ដូចជាស្ត្រីរក្សាគភ៌ដែលកើតអំពីស្តេចចក្រព័ត្តិ យ៉ាងនោះឯង ។ ព្រោះថា កាលបើព្រះយោគី រក្សានិមិត្តបានយ៉ាងនេះ ការសាបសូន្យចាកឈានដែលខ្លួនបានហើយ មិនមានឡើយ ។ កាលបើការរក្សាមិនមាន, ឈានដែលខ្លួនបានហើយៗ ក៏រមែងសាបសូន្យទៅ ។ នេះ ជាវិធីរក្សា ក្នុងការរក្សានិមិត្តនោះ ។

(វិធីរក្សានិមិត្ត)

(៨៣) ព្រះយោគី គប្បីវៀរចាកហេតុមិនជាទីសប្បាយ ៧ នេះ គឺ : អាវាស ១, គោចរ ១, តិរច្ឆានកថា ១, បុគ្គល ១, ភោជន ១, រដូវ ១, ឥរិយាបថ ១, គប្បីសេពនូវសេចក្តីសប្បាយ ៧ យ៉ាង ព្រោះថា កាលបើព្រះយោគីឯណាមួយ ប្រតិបត្តិបានយ៉ាងនេះ, អប្បនារមែងកើតមាន តាមកាលមិនយឺតយូរឡើយ ។

(អាវាស)

គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបទមាតិកាទាំងនោះ ដូចតទៅនេះ កាលបើព្រះយោគីនោះ នៅក្នុងអាវាសណា, និមិត្ត ដែលមិនទាន់កើតឡើង រមែងមិនកើតឡើងផង និមិត្ត ដែលកើតឡើងហើយ តែងវិនាសទៅវិញផង សតិ ដែលមិនទាន់តាំងនៅហើយ រមែងមិនតាំងនៅស៊ប់ផង, ចិត្ត ដែលមិនតម្កល់នៅមាំហើយ រមែងមិនតម្កល់នៅមាំផង អាវាសនេះ មិនជាទីសប្បាយ ។ កាលបើព្រះយោគីនោះ នៅក្នុងអាវាសណា និមិត្ត រមែងកើតឡើងផង នៅជាប់លាប់ផង សតិ រមែងតាំងនៅស៊ប់ ចិត្ត ជាសមាធិ ដូចជាព្រះបធានិយតិស្សត្ថេរ ដែលនៅអាស្រ័យ ក្នុងនាគបព៌ត,



អាវាសនេះ ជាទីសប្បាយ ។ ព្រោះហេតុនោះ ក្នុងវត្តណា មានអាវាស (ទីនៅ)ច្រើន, ព្រះយោគី ត្រូវនៅក្នុងអាវាសទាំងនោះ អាវាសនីមួយៗ បីៗ ថ្ងៃ, ចិត្ត របស់ព្រះយោគីនោះ ជាធម្មជាតមានអារម្មណ៍តែមួយ ក្នុងអាវាសណា គប្បីនៅក្នុងអាវាសនោះ ។ សេចក្តីថា ភិក្ខុចំនួន ៥០០ ដែលនៅ ក្នុងចូឡនាគគុហា ក្នុងតម្ពបណ្ណិទ្វីប រៀនកម្មដ្ឋាន ក្នុងគុហានោះឯង ក៏បានសម្រេចព្រះអរហត្ត ព្រោះភាវៈនៃអាវាសជាទីសប្បាយមែនពិត ។ ចំណែកព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្ន ជាដើម និង ព្រះអរិយបុគ្គលទាំងឡាយ ដែលបានសម្រេចអរិយភូមិ ក្នុងទីដទៃទៀត ក្នុងគុហាឈ្មោះចូឡនាគនោះ គណនារាប់ពុំបាន ។ សូម្បីក្នុងអាវាសទាំងឡាយដទៃទៀត មានអាវាសឈ្មោះចិត្តលបព៌ត ជាដើម ក៏យ៉ាងដូច្នោះដែរ ។

(គោចរគ្រាម)

ចំណែកគោចរគ្រាមណា មាននៅខាងក្នុង នៃជួរធ្នូ ជាគម្រប់ពីរដោយកន្លះ មិនឆ្ងាយពេក មិនជិតពេក អំពីសេនាសនៈ ដោយទិសខាងជើង ឬ ទិសខាងត្បូងជាគោចរគ្រាមដែលបរិបូរដោយភិក្ខារកបានដោយងាយស្រួល គោចរគ្រាមនោះ ឈ្មោះថា ជាទីសប្បាយ ។ គោចរគ្រាមផ្ទុយអំពីនេះ ឈ្មោះថា មិនជាទីសប្បាយ ។

(តិរច្ឆានកថា)

ពាក្យថា “ភស្សំ” សេចក្តីថា ពាក្យដែលរាប់បញ្ចូលហើយ ក្នុងតិរច្ឆានកថា ៣២ ឈ្មោះថា មិនជាទីសប្បាយ ។ ព្រោះថា ពាក្យតិរច្ឆានកថានោះ រមែងប្រព្រឹត្តទៅ ដើម្បីសាបសូន្យចាកនិមិត្ត របស់ព្រះយោគីនោះ ។ ពាក្យដែលអាស្រ័យកថាវត្ថុ ១០ យ៉ាង ឈ្មោះថា ជាទី

សប្បាយ ។ សូម្បីពាក្យអាស្រ័យកថាវត្ថុ ១០ យ៉ាងនោះ ក៏ព្រះយោគី គប្បីពោលតាមប្រមាណ ។

(បុគ្គល)

សូម្បីបុគ្គលអ្នកមិនពោលតិរច្ឆានកថា បរិបូណ៌ដោយគុណ មានសីលគុណជាដើម ដែលព្រះយោគីបានអាស្រ័យហើយ, ចិត្ត ដែលមិនទាន់តំកល់មាំហើយ រមែងតម្កល់មាំក្តី ចិត្ត ដែលតម្កល់នៅមាំហើយ ជាចិត្តនឹងនខ្ជាប់ខ្ជួនខ្ពស់ឡើងក្តី, បុគ្គលមានសភាពបែបនេះ ឈ្មោះថា ជាទីសប្បាយ ។ ចំណែកបុគ្គលអ្នកដែលពោលតិរច្ឆានកថា ច្រើនដោយសេចក្តីស្ងួនគ្រងនូវកាយ ឈ្មោះថា មិនជាទីសប្បាយ ។ ព្រោះថាបុគ្គលនោះ តែងធ្វើព្រះយោគីនោះ ឲ្យសៅហ្មងតែម្យ៉ាង ដូចជាទឹកជ្រាំ ធ្វើទឹកថ្លាឲ្យក្លាយទៅជាទឹកល្អក់ដូច្នោះ ។ មួយទៀត ព្រោះអាស្រ័យបុគ្គលបែបនោះ សមាបត្តិ រមែងវិនាស ដូចជាសមាបត្តិ នៃភិក្ខុដែលនៅក្នុងវត្តឈ្មោះកោដិបព៌ត យ៉ាងនោះឯង ។ មិនចាំបាច់និយាយថ្វីដល់និមិត្ត ។

(ភោជន និង រដូវ)

ចំណែកភោជន មានរសជាតផ្អែម ចំពោះបុគ្គលពួកខ្លះ មានរសជាតជូរ ចំពោះបុគ្គលពួកខ្លះ ឈ្មោះថា ជាទីសប្បាយ ។ ឯរដូវត្រជាក់ ដល់បុគ្គលពួកខ្លះ ក្តៅដល់បុគ្គលពួកខ្លះ គឺជាទីសប្បាយ ។ ព្រោះហេតុនោះ បើព្រះយោគី សេពភោជនណាក្តី រដូវណាក្តី, សេចក្តីសប្បាយតែងកើតមាន ចិត្ត ដែលមិនទាន់កើតជាសមាធិ តែងកើតជាសមាធិក្តី ចិត្ត ដែលកើតជាសមាធិហើយ រមែងរឹងប៉ឹង ដោយវិសេសក្តី, ភោជននោះ និង រដូវនោះ ទើបជាទីសប្បាយ ។ ភោជនក្រៅអំពីនេះ និង រដូវក្រៅអំពីនេះ មិនជាទីសប្បាយទេ ។



(ឥរិយាបថ)

ក៏ក្នុងឥរិយាបថទាំងឡាយ ទីចង្ក្រមន៍ ជាទីសប្បាយ ដល់ភិក្ខុពួកខ្លះ បណ្តាឥរិយាបថ គឺការដេក ឈរ និង អង្គុយ ឥរិយាបថណាមួយ ជាទីសប្បាយ ដល់ភិក្ខុពួកខ្លះ ។ ហេតុនោះ ព្រះយោគី គប្បីពិចារណាមើល រហូតបី ថ្ងៃ ដូចជាពិចារណាមើលអាវាសនោះ គប្បីជ្រាបថា ក្នុងឥរិយាបថណា ចិត្តដែលមិនទាន់កើតជាសមាធិ រមែងកើតជាសមាធិក្តី ចិត្តដែលកើតជាសមាធិហើយ រមែងរឹងប៉ឹង ដោយវិសេសក្តី ឥរិយាបថនោះ ឈ្មោះថា ជាទីសប្បាយ, ឥរិយាបថក្រៅអំពីនេះ ឈ្មោះថា មិនជាទីសប្បាយទេ ។

បើតាមទំនងនេះ ព្រះយោគីត្រូវវៀរហេតុមិនជាទីសប្បាយទាំង ៧ យ៉ាងនេះ ហើយសេពហេតុជាទីសប្បាយ ។ ព្រោះថា អប្បនា នឹងកើតមាន ដល់ព្រះយោគីពួកខ្លះ ដែលប្រតិបត្តិយ៉ាងនេះ ជាអ្នកច្រើនដោយការសេពនិមិត្ត ដោយកាលមិនយូរឡើយ ។ ប៉ុន្តែកាលបើព្រះយោគីណា ប្រតិបត្តិយ៉ាងដូច្នេះ អប្បនា មិនកើតទេ ។ ព្រះយោគីនោះ ត្រូវញុំាងអប្បនាកោសល ១០ ឲ្យកើតឡើង ។ នេះ គឺជាសេចក្តីពន្យល់ក្នុងអប្បនាកោសលនោះ ។

(មាតិកានៃអប្បនាកោសល)

(៨៤) ព្រះយោគី គប្បីប្រាថ្នាអប្បនាកោសល ដោយអាការៈទាំងឡាយ ១០ យ៉ាង គឺ :

(១) ដោយធ្វើវត្ថុឲ្យក្លៀវក្លា,

(២) ដោយការប្រមូលឥន្ទ្រិយ៍ឲ្យស្មើគ្នា,

(៣) ដោយសេចក្តីឈ្លាសក្នុងនិមិត្ត,

(៤) (ដោយ) ផ្គងចិត្ត ក្នុងសម័យដែលត្រូវផ្គង,

(៥) (ដោយ)សង្កត់សង្កិនចិត្ត ក្នុងសម័យដែលត្រូវសង្កត់សង្កិន,

(៦) (ដោយ)ធ្វើចិត្តឲ្យរីករាយ ក្នុងសម័យដែលគួរធ្វើឲ្យរីករាយ,

(៧) (ដោយ)ធ្វើចិត្តឲ្យស្ពឹងចុះ ក្នុងសម័យដែលត្រូវធ្វើចិត្តឲ្យស្ពឹងចុះ,

(៨) ដោយការវៀរចាកបុគ្គលដែលមិនមានចិត្តជាសមាធិ,

(៩) ដោយការសេពគប់តែបុគ្គលដែលមានចិត្តជាសមាធិ,

(១០) ដោយការបង្អោនចិត្តទៅ ក្នុងសមាធិនោះ ។

### ១- ការធ្វើវត្ថុឲ្យភ្លៀវភ្លា

ក្នុងអាការៈ ១០ នោះ ការធ្វើការៈនៃវត្ថុទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ឲ្យភ្លៀវភ្លា ឈ្មោះថា កិរិយាធ្វើវត្ថុឲ្យភ្លៀវភ្លា ។ ក៏ពេលណា ព្រះយោគីនោះ មានសក់ ក្រចក និង រោមវែង ឬថា រាងកាយមានញើស និង ក្អែលកាន់ហើយ ពេលនោះ វត្ថុខាងក្នុង ឈ្មោះថា មិនស្អាត គឺមិនបរិសុទ្ធ ។ ចំណែកចីវរ របស់ព្រះយោគីនោះ ជាចីវរចាស់ សៅហ្មង មានក្លិនស្អុយ ឬថា សេនាសនៈ ស្មោកគ្រោក ដោយសំរាម ក្នុងពេលណា, វត្ថុខាងក្រៅ ឈ្មោះថា ជាវត្ថុមិនស្អាត គឺមិនបរិសុទ្ធ ក្នុងពេលនោះ ។ ក៏កាលបើវត្ថុទាំងខាងក្នុង ទាំងខាងក្រៅ មិនស្អាត, សូម្បីញាណ ក្នុងចេតសិកទាំងឡាយ ដែលកើតឡើងហើយ ក៏ជាញាណមិនស្អាតផងដែរ ដូចពន្លឺនៃអណ្តាតភ្លើងប្រទីបដែលអាស្រ័យនូវប្រេះ និង ប្រេង ក្នុងអំបែងប្រទីប ដែលមិនស្អាត កើតឡើង ក៏ជារបស់មិនស្អាត យ៉ាងនោះដែរ ។ ក៏កាលបើព្រះយោគី ពិចារណានូវសង្ខារទាំងឡាយដោយញាណដែលមិនបរិសុទ្ធ, សូម្បីសង្ខារទាំងឡាយ ក៏ជាសង្ខារមិនប្រាកដ កាលប្រកបនូវកម្មដ្ឋាន សូម្បីកម្មដ្ឋាន ក៏មិនដល់



នូវការចំរើន លូតលាស់ ទូលំទូលាយដែរ ។ ប៉ុន្តែកាលបើវត្ថុទាំងខាងក្នុងខាងក្រៅស្អាត, សូម្បីញាណ ក្នុងចេតសិកទាំងឡាយដែលកើតឡើងហើយ ក៏ជាញាណស្អាតបរិសុទ្ធផងដែរ ដូចជាពន្លឺនៃអណ្តាតភ្លើងប្រទីបដែលអាស្រ័យប្រេះ និង ប្រេង ក្នុងអំបែងប្រទីបដែលស្អាតកើតឡើង ក៏ជារបស់ស្អាតល្អ យ៉ាងនោះដែរ ។ ក៏កាលបើព្រះយោគី ពិចារណានូវសង្ខារទាំងឡាយ ដោយញាណដ៏បរិសុទ្ធ, សូម្បីសង្ខារទាំងឡាយ ក៏ជាសង្ខារប្រាកដច្បាស់ កាលបើព្រះយោគី ប្រកបនូវកម្មដ្ឋាន សូម្បីកម្មដ្ឋាន ក៏ដល់នូវការចំរើន លូតលាស់ ទូលំទូលាយផងដែរ ។

### ២- ការប្រមូលឥន្ទ្រីយ៍ឲ្យស្មើគ្នា

(៨៥) ការធ្វើនូវភាវៈនៃឥន្ទ្រីយ៍ទាំងឡាយ មានសទ្ធិន្ទ្រីយ៍ជាដើមឲ្យស្មើគ្នា ឈ្មោះថា កិរិយាប្រមូលឥន្ទ្រីយ៍ឲ្យស្មើគ្នា ។ ព្រោះថា ប្រសិនបើសទ្ធិន្ទ្រីយ៍របស់ព្រះយោគីនោះមានកម្លាំង, សទ្ធិន្ទ្រីយ៍ក្រៅអំពីនេះ ទន់ខ្សោយ លំដាប់នោះ វីរិយិន្ទ្រីយ៍ មិនអាចដើម្បីធ្វើនូវកិច្ចគឺការផ្គងចិត្ត, សតិន្ទ្រីយ៍ មិនអាចដើម្បីនឹងធ្វើនូវកិច្ចគឺការថែទាំចិត្ត, សមាធិន្ទ្រីយ៍ មិនអាចដើម្បីនឹងធ្វើកិច្ច គឺការធ្វើចិត្តមិនឲ្យរាយមាយបាន, បញ្ញិន្ទ្រីយ៍ មិនអាចដើម្បីនឹងធ្វើកិច្ច គឺការឃើញ តាមសេចក្តីពិតបាន, ព្រោះហេតុនោះ សទ្ធិន្ទ្រីយ៍ដ៏មានកម្លាំងនោះ ព្រះយោគី គប្បីធ្វើឲ្យបាត់បង់ទៅ ដោយការពិចារណានូវសភាវធម៌ ឬថា ដោយការមិនធ្វើទុកក្នុងចិត្ត ដូចជាកាលបើខ្លួនធ្វើទុកក្នុងចិត្តហើយ សទ្ធិន្ទ្រីយ៍ មានកម្លាំងកើតឡើងបាន ។ មែនពិត រឿងព្រះវក្កលិត្ថេរ ជាតួយ៉ាង ក្នុងសទ្ធិន្ទ្រីយ៍នេះ ។ តែប្រសិនបើវីរិយិន្ទ្រីយ៍ មានកម្លាំងខ្លាំង, គ្រានោះ សទ្ធិន្ទ្រីយ៍ ក៏មិនអាចដើម្បីនឹងធ្វើនូវកិច្ច គឺការចុះចិត្តស៊ប់, ឥន្ទ្រីយ៍ទាំងឡាយក្រៅពីនេះ ក៏មិនអាចដើម្បី

ធ្វើនូវកិរិយាផ្សេងគ្នា នៃកិច្ចក្រៅអំពីនេះ ។ ព្រោះហេតុនោះ វីរិយិន្ទ្រីយ៍ដ៏មានកម្លាំងនោះ ព្រះយោគី គប្បីលះបង់ ដោយការចំរើនសម្ពោជ្ឈង្គមានបស្សទ្ធិជាដើម ។ បណ្ឌិត ត្រូវសំដែងរឿងព្រះសោណត្ថេរ ក្នុងនិទ្ទេសនោះផងដែរ ។ កាលបើភាពមានកម្លាំងនៃឥន្ទ្រីយ៍មួយ កើតមាន បណ្ឌិតគប្បីជ្រាបភាវៈនៃឥន្ទ្រីយ៍ទាំងឡាយក្រៅពីនេះថា គ្មានសមត្ថភាពក្នុងកិច្ចរបស់ខ្លួន សូម្បីក្នុងឥន្ទ្រីយ៍ដ៏សេស ដូចបានពោលមកនេះឯង ។

តែបើពោលដោយវិសេស ក្នុងឥន្ទ្រីយ៍ទាំង ៥ នោះ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម តែងសរសើរភាវៈនៃសទ្ធា និង បញ្ញាទាំងឡាយផង នៃសមាធិ និង វីរិយៈទាំងឡាយផង ថា ជាធម្មជាតស្មើគ្នា ។ ព្រោះថា បុគ្គលមានសទ្ធាខ្លាំងក្លា តែមានបញ្ញាទន់ខ្សោយ ជាអ្នកជ្រះថ្លាក្នុងការពោលអួត រមែងជ្រះថ្លា ក្នុងហេតុដែលមិនមែនជារឿង ។ បុគ្គលអ្នកមានបញ្ញាខ្លាំងក្លា តែមានសទ្ធាទន់ខ្សោយ តែងគប់រកនូវពួកជនអ្នកពោលអួត ជាអ្នកកែខ្លួនមិនបាន ដូចជារោគដែលកើតមកអំពីថ្នាំ រក្សាមិនបាត់ យ៉ាងនោះឯង ។ ព្រោះភាវៈនៃសទ្ធា និង បញ្ញាទាំងពីរ ជាធម្មជាតស្មើគ្នា បុគ្គលទើបជ្រះថ្លា ក្នុងហេតុដែលជារឿងដោយពិត ។ ក៏សេចក្ដីខ្ជិលច្រអូស តែងគ្របសង្កត់នូវបុគ្គលអ្នកមានសមាធិខ្លាំងក្លា តែមានសេចក្ដីព្យាយាមទន់ខ្សោយ ព្រោះភាវៈនៃសមាធិ ជាបក្សពួកនៃសេចក្ដីខ្ជិលច្រអូស ។ សេចក្ដីរាយមាយ តែងគ្របសង្កត់នូវបុគ្គលអ្នកមានសេចក្ដីព្យាយាមខ្លាំងក្លា តែមានសមាធិទន់ខ្សោយ ព្រោះភាវៈនៃសេចក្ដីព្យាយាម ជាបក្សពួកនៃឧទ្ធច្ចៈ ។ តែសមាធិ ដែលវីរិយៈគ្រាំទ្រហើយ មិនបានធ្លាក់ចុះទៅក្នុងកោសជ្ជៈ ។ វីរិយៈ ដែលសមាធិគ្រាំទ្រហើយ មិនបានធ្លាក់ចុះទៅក្នុងឧទ្ធច្ចៈ ។ ព្រោះហេតុនោះ ឥន្ទ្រីយ៍ទាំងពីរ



យ៉ាងនោះ ព្រះយោគីត្រូវធ្វើឲ្យស្មើគ្នា ។ ព្រោះថា អប្បនា រមែងកើតឡើងបាន ព្រោះភាវៈនៃឥន្ទ្រីយ៍ទាំងពីរយ៉ាងនោះស្មើគ្នា ។

ន័យមួយទៀត សទ្ធា សូម្បីមានកម្លាំង ក៏សមគួរដល់ព្រះយោគីដែលបំពេញសមថកម្មដ្ឋាន ។ កាលបើសទ្ធាមានកម្លាំងយ៉ាងនេះ ព្រះយោគីនោះ កាលជឿ គឺថា កាលជឿស៊ប់ នឹងបានដល់នូវអប្បនា ។ ចំណែកក្នុងសមាធិ និង បញ្ញា ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមានកម្លាំង ក៏គួរដល់ព្រះយោគីដែលជាសមាធិកម្មិកៈ ។ ព្រោះថា កាលបើឯកគ្គតាចិត្ត មានកម្លាំងយ៉ាងនេះ ព្រះយោគីនោះ ក៏នឹងបានសម្រេចនូវអប្បនា ។ បញ្ញា ដ៏មានកម្លាំង រមែងគួរដល់ព្រះយោគី ដែលបំពេញវិបស្សនាកម្មដ្ឋាន ។ ព្រោះថា កាលបើបញ្ញា មានកម្លាំង យ៉ាងដូច្នេះ ព្រះយោគីនោះ ក៏នឹងបានសំរេចនូវការចាក់ធ្លុះនូវត្រៃលក្ខណ៍ ។ ព្រោះភាវៈនៃសមាធិ និង បញ្ញាទាំងពីរជាធម្មជាតស្មើគ្នាហ្នឹងឯង ទើបអប្បនាកើតមាន មែនពិត ។

### (សតិចាំបាច់ត្រូវមានក្នុងទីទាំងពួង)

ចំណែកសតិ មានកម្លាំង ក្នុងទីទាំងពួងទើបគួរ ។ ព្រោះថា សតិតែងរក្សានូវចិត្ត ចាកកិរិយាធ្លាក់ចុះកាន់ឧទ្ធច្ចៈ ដោយអំណាចនៃសទ្ធា, វីរិយៈ និង បញ្ញាទាំងឡាយ ដែលជាបក្សពួកនៃឧទ្ធច្ចៈ នឹងរក្សានូវចិត្តចាកកិរិយាធ្លាក់ចុះកាន់កោសជ្ជៈ ព្រោះសមាធិជាបក្សពួកនៃកោសជ្ជៈ ។ ព្រោះហេតុនោះ សតិនោះ គឺព្រះយោគី គប្បីប្រាថ្នា ក្នុងទីទាំងពួង ដូចជាអំបិលប្រឡាក់ ជារបស់ដែលត្រូវប្រាថ្នា ក្នុងម្ហូបគ្រៀមទាំងពួង និង ដូចជាអាមាត្យ អ្នកប្រកបការងារទាំងពួង ជាអ្នកត្រូវគេប្រាថ្នា ក្នុងរាជកិច្ចទាំងពួង យ៉ាងដូច្នោះ ។ ព្រោះហេតុនោះ បានជាព្រះអដ្ឋកថាចារ្យ

ពោលថា "ចំណែកសតិ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាគុណជាតត្រូវប្រាថ្នា ក្នុងទីទាំងពួង, ព្រោះហេតុអ្វី? ព្រោះថា ចិត្តមានសតិ ជាទីរលឹក ឯសតិ មានការរក្សាជាគ្រឿងប្រាកដ, ការផ្គងឡើង និង ការសង្កត់សង្កិនចិត្ត វៀរចាកសតិហើយ មិនកើតទេ" ។

### ៣- ការឈ្លាសក្នុងនិមិត្ត

ភាវៈនៃសេចក្ដីឈ្លាសវៃ ក្នុងកិរិយាធ្វើនិមិត្ត នៃភាវៈនៃចិត្ត មានអារម្មណ៍តែមួយ មានបឋវីកសិណជាដើម ដែលខ្លួនពុំទាន់បានធ្វើហើយ ភាពនៃសេចក្ដីឈ្លាស ក្នុងការចំរើន និង ភាពនៃសេចក្ដីឈ្លាស ក្នុងការរក្សានូវនិមិត្ត ដែលខ្លួនបានហើយ ដោយការចំរើន ឈ្មោះថា ការឈ្លាស ក្នុងនិមិត្ត ។ ក្នុងនិទ្ទេសនេះ លោកបំណងយកការឈ្លាស ក្នុងកិរិយារក្សានោះ ។

### ៤- ផ្គងចិត្តក្នុងសម័យដែលត្រូវផ្គង

(៨៦) សួរថា: តើព្រះយោគី ផ្គងចិត្ត ក្នុងសម័យដែលខ្លួនត្រូវផ្គង យ៉ាងដូចម្ដេច? ។ ឆ្លើយថា: ក្នុងកាលណា ចិត្ត របស់ព្រះយោគីនោះ ជាធម្មជាតរួញរា ព្រោះទោសទាំងឡាយមានភាពនៃសេចក្ដីព្យាយាមបន្ធូបន្ថយហួសពេកជាដើម ក្នុងកាលនោះ ព្រះយោគី កុំចំរើនសម្ពោជ្ឈង្គ ៣ មានបស្សទ្ធិសម្ពោជ្ឈង្គជាដើមហើយ ចំរើនសម្ពោជ្ឈង្គ ៣ មានធម្មវិចយសម្ពោជ្ឈង្គជាដើម ។ មែនពិត ពាក្យនេះ ព្រះមានព្រះភាគត្រាស់ហើយថា "ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាបុរស មានប្រាថ្នានឹងបង្កាត់ភ្លើងតូចឲ្យឆេះឡើង បុរសនោះ ក៏ដាក់នូវស្មៅស្រស់ផង ដាក់អាចម៍គោស្រស់ផង ដាក់ឧសស្រស់ផង ផ្លុំខ្យល់លាយទឹកផង រោយអាចម៍ដីផង ក្នុងភ្លើងតូចនោះ, ម្នាលភិក្ខុទាំងឡាយ តើបុរសនោះ គួរនឹងបង្កាត់ភ្លើង



តូចឲ្យឆេះបានដែរឬទេ?" ។ ភិក្ខុទាំងឡាយក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស មិនគួរនឹងបង្កាត់ឲ្យឆេះបានទេ" ។ ព្រះមានព្រះភាគត្រាស់ទៀតថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងមែនហើយ ចិត្ត ជាធម្មជាតរួញរា ក្នុងសម័យណា, សម័យនោះ ជាកាលមិនគួរនឹងចំរើនបស្សទ្ធិ-សម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនសមាធិសម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនឧបេក្ខាសម្ពោជ្ឈង្គឡើយ, ដំណើរនោះ ព្រោះហេតុដូចម្ដេច?, ម្នាលភិក្ខុទាំងឡាយ ព្រោះថា ចិត្តរួញរាហើយ ចិត្តនោះ ជាធម្មជាតមិនងាយនឹងឲ្យស្ទុះឡើង ដោយធម៌ទាំងឡាយនុ៎ះបានទេ ។ ម្នាលភិក្ខុទាំងឡាយ បើចិត្តជាធម្មជាតរួញរា ក្នុងសម័យណា, សម័យនោះ ជាកាលគួរនឹងចំរើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនវីរិយសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនបីតិសម្ពោជ្ឈង្គ, ដំណើរនោះ ព្រោះហេតុដូចម្ដេច?, ម្នាលភិក្ខុទាំងឡាយ ព្រោះថា ចិត្តរួញរាហើយ ចិត្តនោះ ជាធម្មជាតងាយនឹងឲ្យស្ទុះឡើងបានដោយធម៌ទាំងឡាយនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាបុរសមានប្រាថ្នានឹងបង្កាត់ភ្លើងតូចឲ្យឆេះឡើង បុរសនោះ ក៏ដាក់ស្មៅស្ងួតផង ដាក់អាចម៍គោស្ងួតផង ដាក់ឧសស្ងួតផង ផ្លុំខ្យល់អំពីមាត់ផង មិនរោយអាចម៍ដីផង ក្នុងភ្លើងតូចនោះ ម្នាលភិក្ខុទាំងឡាយ តើបុរសនោះ គួរនឹងបង្កាត់ភ្លើងតូច ឲ្យឆេះបានឬទេ? [១]" ។ ភិក្ខុទាំងឡាយ ក្រាបទូល ថា "សូមទ្រង់ព្រះមេត្តាប្រោស បើយ៉ាងហ្នឹង គួរនឹងបង្កាត់ឲ្យឆេះបាន" ។

(អាហាររបស់ធម្មវិចយសម្ពោជ្ឈង្គ)

ក៏ក្នុងលក្ខណៈ ដែលចិត្តរួញរានេះ បណ្ឌិត គប្បីជ្រាបការចំរើន

១- សុ. សំ. មហាវារ. ភាគទី ៣៧ ទំព័រទី ២៤១ ។

សម្ពោជ្ឈង្គទាំងបី មានធម្មវិចយសម្ពោជ្ឈង្គជាដើម ដោយអំណាចនៃធម៌ដែលជាអាហារសំរាប់ខ្លួន ។ មែនពិត ពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ហើយថា “ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាកុសល និង អកុសល ក៏មាន, ធម៌ទាំងឡាយប្រកបដោយទោស និង មិនមានទោស ក៏មាន, ធម៌ទាំងឡាយ ថោកទាប និង ប្រណីត ក៏មាន, ធម៌ទាំងឡាយមានចំណែកប្រៀបទាំងខ្មៅ ទាំង-ស ក៏មាន, ការធ្វើទុកក្នុងចិត្ត និង ការធ្វើឲ្យច្រើន ក្នុងធម៌ទាំងឡាយនោះមាន, ធម៌នេះ ជាអាហារ ដើម្បីកើតឡើង នៃធម្មវិចយសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងផង ដើម្បីភាព ដ៏ក្រៃលែង ដើម្បីភាពទូលំទូលាយ ដើម្បីការចំរើន ដើម្បីការបរិបូរណ៍នៃធម្មវិចយសម្ពោជ្ឈង្គ ដែលកើតឡើងហើយផង (១) ” ដូច្នេះ ។

(អាហាររបស់វីរិយសម្ពោជ្ឈង្គ)

ន័យដូចគ្នានោះដែរ ព្រះអង្គទ្រង់ត្រាស់ ថា “ម្នាលភិក្ខុទាំងឡាយ! អារម្ភធាតុ (ធាតុគឺការគិតចាប់ផ្ដើម) និក្កមធាតុ (ធាតុគឺការចាប់ផ្ដើមធ្វើ) បរក្កមធាតុ (ធាតុគឺការប្រឹងប្រែងមិនរួញរា) ការធ្វើទុកក្នុងចិត្ត និង ការធ្វើឲ្យច្រើន ក្នុងធម៌ទាំងឡាយនោះ ក៏មាន, ធម៌នេះ ជាអាហារ ដើម្បីកើតឡើង នៃវីរិយសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងផង ដើម្បីភាពដ៏ក្រៃលែង ដើម្បីភាពទូលំទូលាយ ដើម្បីសេចក្ដីចំរើន ដើម្បីភាពបរិបូរណ៍នៃវីរិយសម្ពោជ្ឈង្គ ដែលកើតឡើងហើយផង” ដូច្នេះ ។

(អាហាររបស់បីតិសម្ពោជ្ឈង្គ)

ន័យដូចគ្នានោះដែរ ព្រះអង្គទ្រង់ត្រាស់ ថា “ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គ ក៏មាន, ការធ្វើទុកក្នុងចិត្ត

១- សុ. សំ. មហាវារ. ភាគទី ៣៧ ទំព័រទី ២៨១ ។



និង ការធ្វើឲ្យច្រើន ក្នុងធម៌ទាំងឡាយនោះ ក៏មាន, ធម៌នេះ ជាអាហារ ដើម្បីកើតឡើង នៃបីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងផង ដើម្បីភាពដ៏ក្រៃលែង ដើម្បីភាពទូលំទូលាយ ដើម្បីសេចក្ដីចំរើន ដើម្បីភាពបរិបូណ៌ នៃបីតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយផង” ដូច្នេះ ។

ការធ្វើទុកក្នុងចិត្ត ដែលប្រព្រឹត្តទៅ ដោយអំណាចនៃការចាក់ធ្លុះនូវសភាវលក្ខណៈ និង សាមញ្ញលក្ខណៈ ឈ្មោះថា ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ក្នុងធម៌ទាំងឡាយ មានធម៌ដែលជាកុសល ជាដើម ក្នុងបាលីនោះ ។ ការធ្វើទុកក្នុងចិត្តដែលប្រព្រឹត្តទៅ ដោយអំណាចការញុំាងធាតុទាំងឡាយ មានអារម្ភធាតុជាដើម ឲ្យកើតឡើង ឈ្មោះថា ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ក្នុងធាតុទាំងឡាយ មានអារម្ភធាតុជាដើម ។ ក្នុងធាតុទាំង ៣ នោះ សេចក្ដីព្យាយាមជាបឋម លោកហៅថា “អារម្ភធាតុ” ។ សេចក្ដីព្យាយាម ដែលមានកម្លាំងច្រើនជាងសេចក្ដីព្យាយាមជាបឋមនោះ ព្រោះភាវៈនៃសេចក្ដីព្យាយាមនោះចេញហើយចាកសេចក្ដីខ្ជិលច្រអូស ហៅថា “និក្កមធាតុ” ។ សេចក្ដីព្យាយាមដែលមានកម្លាំងច្រើនជាងនិក្កមធាតុនោះទៅទៀត ព្រោះឈានទៅកាន់ទីកន្លែងដ៏ខ្ពស់ឡើងៗ ហៅថា បរក្កមធាតុ ។ ចំណែកពាក្យថា “ធម៌ទាំងឡាយ ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ” នោះ ជាឈ្មោះ នៃបីតិនោះឯង, កិរិយាធ្វើទុកក្នុងចិត្ត ដែលជាហេតុញុំាងបីតិនោះផងដែរ ឲ្យកើតឡើង ឈ្មោះថា ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ។

ន័យមួយទៀត ធម៌ទាំងឡាយ ៧ គឺ ភាពជាអ្នកសាកសួរ១, ភាពនៃការធ្វើវត្ថុឲ្យស្អាត ១, ការប្រមូលនូវឥន្ទ្រិយ៍ឲ្យស្មើគ្នា ១, ការវៀរស្រឡះចាកបុគ្គលដែលមានប្រាជ្ញាអាក្រក់ ១, ការសេពគប់នូវបុគ្គល

ដែលមានប្រាជ្ញា១, ការពិចារណានូវការប្រព្រឹត្តិ ដោយញាណ ដ៏ជ្រាលជ្រៅ ១, ការបង្អោនចិត្តទៅ ក្នុងធម្មវិចយៈនោះ ១ រមែងប្រព្រឹត្តទៅ ដើម្បីញុំាងធម្មវិចយសម្ពោជ្ឈង្គឲ្យកើតឡើង ។

ធម៌ទាំងឡាយ ១១ គឺ ភាពនៃការពិចារណានូវភ័យ មានអបាយភ័យជាដើម១, ភាពជាអ្នកមានប្រក្រតីឃើញនូវអានិសង្ស គឺការបានសម្រេចនូវគុណវិសេសជាលោកិយៈ និង លោកុត្តរៈ ដែលជាប់ទាក់ទងដោយវីរិយៈ ១, ភាពនៃការពិចារណា នូវផ្លូវដែលជាទីធ្វើដំណើរទៅយ៉ាងដូច្នេះថា “មាគ៌ាដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និង ព្រះមហាសាវកទាំងឡាយបានទៅហើយគឺអាត្មាអញគប្បីទៅ, តែថាមាគ៌ានោះ គឺបុគ្គលអ្នកខ្ជិលច្រអូសមិនអាចដើម្បីនឹងទៅបានឡើយ” ដូច្នេះ ១, សេចក្ដីកោតក្រែងចំពោះការត្រាច់ទៅបិណ្ឌបាត ដោយធ្វើឲ្យជាសក្ការៈមានផលច្រើនដល់ទាយកទាំងឡាយ ១, ការពិចារណាឃើញភាពជាធំ នៃព្រះសាស្ដាយ៉ាងនេះថា “ព្រះសាស្ដារបស់យើង ព្រះអង្គមានប្រក្រតីត្រាស់សរសើរនូវការប្រារព្ធសេចក្ដីព្យាយាម ព្រះអង្គជាអ្នកប្រៀនប្រដៅ គឺបុគ្គលដទៃមិនគប្បីប្រព្រឹត្តកន្លងផង ព្រះអង្គជាអ្នកមានឧបការគុណដ៏ច្រើន ចំពោះយើងទាំងឡាយផង ព្រះអង្គកាលយើងបូជា ដោយសេចក្ដីប្រតិបត្តិ ជាអ្នកគឺយើងបូជាហើយ មិនមែនដោយប្រការដទៃផង (ព្រះអង្គមិនមែនជាបុគ្គល គឺអាត្មាអញបូជាហើយ ដោយអាមិសបូជាក្រៅពីនេះឡើយ)” ដូច្នេះ ១, ការពិចារណាឃើញនូវភាពជាធំនៃមត៌កយ៉ាងដូច្នេះថា “មត៌កដ៏ធំ ពោលគឺព្រះសទ្ធម្ម គឺអាត្មាអញគប្បីទទួលយក, ឯមត៌ក ដ៏ធំនោះ គឺបុគ្គលដែលខ្ជិលច្រអូសមិនអាចទទួលយកបានឡើយ” ដូច្នេះ ១, ការបន្ទោបង់នូវថីនមិទ្ធៈ ដោយសេចក្ដីប្រតិបត្តិទាំងឡាយមានការធ្វើទុកក្នុង



ចិត្ត នូវអាលោកសញ្ញា, ការផ្លាស់ប្ដូរនូវឥរិយាបថ និង ការសេពនូវទីវាលស្រឡះជាដើម ១, ការវៀរស្រឡះចាកបុគ្គលដែលខ្ជិលច្រអូស ១, ការសេពគប់នូវបុគ្គលដែលប្រារព្ធនូវសេចក្ដីព្យាយាម ១, ការពិចារណាឃើញនូវសេចក្ដីព្យាយាមត្រូវ១, ការបង្អោនចិត្តទៅក្នុងសេចក្ដីព្យាយាមនោះ ១ រមែងប្រព្រឹត្តទៅ ដើម្បីញុំាងវីរិយសម្ពោជ្ឈង្គ ឲ្យកើតឡើង ។

ធម៌ទាំងឡាយ ១១ យ៉ាង គឺ : ពុទ្ធានុស្សតិ ១, ធម្មានុស្សតិ ១, សង្ឃានុស្សតិ ១, សីលានុស្សតិ ១, ចាគានុស្សតិ ១, ទេវតានុស្សតិ ១, ឧបសមានុស្សតិ ១, ការវៀរស្រឡះចាកបុគ្គលសៅហ្មង ១, ការសេពគប់នូវបុគ្គលជិតស្និទ្ធ ១, ការពិចារណានូវសេចក្ដីនៃព្រះសូត្រដែលគួរជាទីជ្រះថ្លា ១, កិរិយាបង្អោនចិត្តទៅ ក្នុងបីតិនោះ ១ រមែងប្រព្រឹត្តទៅព្រម ដើម្បីញុំាងបីតិសម្ពោជ្ឈង្គ ឲ្យកើតឡើង ។

ព្រះយោគី កាលញុំាងធម៌ទាំងឡាយនេះ ឲ្យកើតឡើង ដោយអាការៈទាំងឡាយនេះ ដូចបានរៀបរាប់មកហើយនេះ ឈ្មោះថា ធ្វើសម្ពោជ្ឈង្គ ៣ មានធម្មវិចយសម្ពោជ្ឈង្គជាដើមឲ្យចំរើន ។ ព្រះយោគីផ្គងចិត្ត ក្នុងសម័យដែលខ្វនគប្បីផ្គង យ៉ាងនេះឯង ។

### ៥- សង្កត់សង្កិនចិត្ត ក្នុងសម័យដែលគួរសង្កត់សង្កិន

(៨៧) សួរថា: តើព្រះយោគីសង្កត់សង្កិនចិត្ត ក្នុងសម័យ ដែលត្រូវសង្កត់សង្កិន យ៉ាងដូចម្ដេច? ។ ឆ្លើយថា : ពេលណា ចិត្ត របស់ព្រះយោគីនោះ ជាធម្មជាតរាយមាយ ព្រោះហេតុទាំងឡាយ មានភាពជាអ្នកប្រារព្ធសេចក្ដីព្យាយាម ហួសកំរិតជាដើម, ពេលនោះ ព្រះយោគីកុំចំរើនសម្ពោជ្ឈង្គ ៣ មានធម្មវិចយសម្ពោជ្ឈង្គជាដើម ហើយចំរើនសម្ពោជ្ឈង្គ ៣ មានបស្សទ្ធិសម្ពោជ្ឈង្គជាដើម ។ មែនពិត ពាក្យនេះ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយថា “ម្នាលភិក្ខុទាំងឡាយ ឧបមាដូចបុរស ជាអ្នកប្រាថ្នានឹងពន្លត់គំនរភ្លើងដ៏ធំ បុរសនោះ ក៏ដាក់ស្មៅស្ងួតផង ដាក់អាចម៍គោស្ងួតផង ដាក់ឧសស្ងួតផង ផ្លុំខ្យល់អំពីមាត់ផង មិនរោយអាចម៍ដីផង ក្នុងភ្លើងធំនោះ, ម្នាលភិក្ខុទាំងឡាយ! តើបុរសនោះ គួរនឹងពន្លត់គំនរភ្លើងដ៏ធំបានដែរឬទេ?” ។ ភិក្ខុទាំងឡាយក្រាបទូលថា “សូមទ្រង់ព្រះមេត្តាប្រោស បើយ៉ាងហ្នឹង មិនគួរនឹងពន្លត់គំនរភ្លើងធំបានទេ”។ ព្រះមានព្រះភាគត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងមែនហើយ ចិត្ត ជាធម្មជាតរាយមាយ ក្នុងសម័យណា, ក្នុងសម័យនោះ កាលនោះ ជាកាលមិនគួរចំរើនធម្មវិចយសម្ពោជ្ឈង្គ ជាកាលមិនគួរចំរើនវីរិយ-សម្ពោជ្ឈង្គ ជាកាលមិនគួរនឹងចំរើនបីតិសម្ពោជ្ឈង្គ, ដំណើរនោះ ព្រោះហេតុដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ចិត្ត ជាធម្មជាតរួញរា ព្រោះថាចិត្តដែលរួញរានោះ ជាធម្មជាតកម្រនឹងធ្វើឲ្យស្ទូបរម្ងាប់បាន ដោយធម៌ទាំងឡាយនេះ, ម្នាលភិក្ខុទាំងឡាយ ក៏ក្នុងសម័យណា ចិត្តជាធម្មជាតរួញរា, ក្នុងសម័យនោះ កាលនោះ ជាកាលគួរចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនសមាធិសម្ពោជ្ឈង្គ ជាកាលគួរនឹងចំរើនឧបេក្ខាសម្ពោជ្ឈង្គ, ដំណើរនោះ ព្រោះហេតុដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ចិត្ត ជាធម្មជាតរួញរា, ព្រោះថា ចិត្ត ដែលរួញរានោះ ជាធម្មជាតងាយនឹងធ្វើឲ្យស្ងប់រម្ងាប់បាន ដោយធម៌ទាំងឡាយនេះ, ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសអ្នកប្រាថ្នានឹងពន្លត់គំនរភ្លើងដ៏ធំ បុរសនោះ ក៏ដាក់ស្មៅស្រស់ផង ដាក់អាចម៍គោស្រស់ផង ដាក់ឧសស្រស់ផង ផ្លុំខ្យល់លាយទឹកផង រោយអាចម៍ដីផង ក្នុងគំនរភ្លើងធំនោះ, ម្នាលភិក្ខុទាំងឡាយ តើបុរសនោះ គួរនឹងពន្លត់គំនរភ្លើងដ៏ធំ បានដែរឬទេ?” ។ ភិក្ខុទាំងឡាយ ក្រាបទូលថា



“សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ” ។

(អាហាររបស់បស្សទ្ធិសម្ពោជ្ឈង្គ)

ក្នុងបទថា “ក្នុងធម៌ទាំងឡាយនេះ” បណ្ឌិត គប្បីជ្រាបការចំរើនសម្ពោជ្ឈង្គ ៣ មានបស្សទ្ធិសម្ពោជ្ឈង្គជាដើម ដោយអំណាចនៃអាហារសំរាប់ខ្លួន ។ មែនពិត ពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ការស្ងប់កាយ ការស្ងប់ចិត្តមាន, ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា និង ការធ្វើឲ្យច្រើនក្នុងកាយបស្សទ្ធិ និង ចិត្តបស្សទ្ធិនោះ, ធម៌នេះ ជាអាហារ ដើម្បីញ៉ាំងបស្សទ្ធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយឲ្យកើតឡើងផង ដើម្បីភាពក្រៃលែង ភាពទូលំទូលាយភាពចំរើនបរិបូណ៌ នៃបស្សទ្ធិសម្ពោជ្ឈង្គ ដែលកើតឡើងហើយផង” ។

(អាហាររបស់សមាធិសម្ពោជ្ឈង្គ)

ន័យដូចគ្នានោះដែរ ព្រះអង្គទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ និមិត្តស្ងប់ និមិត្ត ដែលអារម្មណ៍មិនប្រាស់ប្រាលក៏មាន, ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា និង ការធ្វើឲ្យច្រើន ក្នុងសមថនិមិត្ត និង អព្យគ្គនិមិត្តនោះ, ធម៌នេះ ជាអាហារ ដើម្បីធ្វើសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ឲ្យកើតឡើងផង ដើម្បីភាពក្រៃលែង ភាពទូលំទូលាយ ភាពចំរើនបរិបូណ៌ នៃសមាធិសម្ពោជ្ឈង្គ ដែលកើតឡើងហើយផង” ។

(អាហាររបស់ឧបេក្ខាសម្ពោជ្ឈង្គ)

ន័យដូចគ្នានោះដែរ ព្រះអង្គទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាទីតាំង នៃឧបេក្ខាសម្ពោជ្ឈង្គក៏មាន, ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា និង ការធ្វើឲ្យច្រើន ក្នុងធម៌ទាំងឡាយនោះ,

ធម៌នេះ ជាអាហារដើម្បីញ៉ាំងឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយឲ្យកើតឡើងផង ដើម្បីភាពក្រៃលែងភាពទូលំទូលាយ ភាពចំរើន ភាពបរិបូណ៌ នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយផង” ដូច្នេះ ។

សម្ពោជ្ឈង្គទាំងឡាយ មានបស្សទ្ធិសម្ពោជ្ឈង្គជាដើម ដែលធ្លាប់កើតឡើងហើយ ដល់ព្រះយោគីនោះ ដោយអាការៈណា, ការធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការប្រព្រឹត្តិទៅ នៃកិរិយាកំណត់អាការៈនោះហើយញ៉ាំងសម្ពោជ្ឈង្គទាំង៣ មានបស្សទ្ធិសម្ពោជ្ឈង្គជាដើមនោះ ឲ្យកើតឡើងនុ៎ះឯង ឈ្មោះថា ការធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ក្នុងបទទាំងឡាយ ៣ ក្នុងបាលីនោះ ។ ឯពាក្យថា “សមថនិមិត្ត” នេះ ជាឈ្មោះនៃសមថៈនុ៎ះឯង ។ មួយទៀត ពាក្យថា “អព្យគ្គនិមិត្ត” នេះ ជាឈ្មោះនៃសមថៈនោះដែរ ដោយសេចក្តីថា មិនរាយមាយ ។

ន័យមួយវិញទៀត ធម៌ទាំងឡាយ ៧ គឺ ការសេពនូវភោជនដ៏ប្រណីត ១, ការសេពនូវរដូវជាសុខ ១, ការសេពនូវឥរិយាបថ ជាសុខ ១, ការប្រកបសេចក្តីព្យាយាមជាកណ្តាល ១, ការវៀរស្រឡះចាកបុគ្គលដែលមានកាយសោប់សេល់ ១, ការសេពគប់ នូវបុគ្គលដែលមានកាយស្ងប់ស្ងាប់ ១, ការបង្អោនចិត្តទៅ ក្នុងបស្សទ្ធិនោះ ១ រមែងប្រព្រឹត្តទៅព្រម ដើម្បីញ៉ាំងបស្សទ្ធិសម្ពោជ្ឈង្គ ឲ្យកើតឡើង ។

ធម៌ទាំងឡាយ ១១ ប្រការ គឺៈ ភាវៈនៃវត្ថុដ៏ក្មៀវក្លា ១, ការឈ្លាសក្នុងនិមិត្ត១, ការប្រមូលឥន្ទ្រីយ៍ឲ្យមានភាពស្មើគ្នា ១, ការសង្កត់សង្កិនចិត្ត ក្នុងសម័យដ៏គួរ ១, ការផ្គងចិត្ត ក្នុងសម័យដ៏គួរ ១, ការធ្វើចិត្តដែលមិនមានសទ្ធាឲ្យរីករាយ ដោយអំណាចនៃជំនឿ និង សេចក្តីតក់ស្លុត ១, ការសំឡឹងជាព្រងើយ ៗ នូវចិត្តដែលប្រព្រឹត្តទៅ ដោយ



ប្រពៃ ១, ការវៀរស្រឡះចាកបុគ្គលដែលមិនមានចិត្តជាសមាធិ ១, ការសេពគប់នូវបុគ្គលដែលមានចិត្តជាសមាធិ ១, ការពិចារណាឈាន និង វិមោក្ខ ១, ការបង្អោនចិត្តទៅក្នុងសមាធិនោះ ១ រមែងប្រព្រឹត្តទៅព្រម ដើម្បីញ៉ាំងសមាធិសម្ពោជ្ឈង្គ ឲ្យកើតឡើង ។

ធម៌ទាំងឡាយ ៥ ប្រការ គឺ ការព្រងើយកន្តើយក្នុងសត្វ ១, ការព្រងើយកន្តើយក្នុងសង្ខារ ១, ការវៀរចាកបុគ្គលដែលជាប់ជំពាក់ ក្នុងសត្វ និង សង្ខារ ១, ការសេពគប់នូវបុគ្គល ដែលព្រងើយកន្តើយ ក្នុងសត្វ និង សង្ខារ ១, ការបង្អោនចិត្តទៅក្នុងឧបេក្ខានោះ ១ រមែងប្រព្រឹត្តទៅព្រម ដើម្បីញ៉ាំងឧបេក្ខាសម្ពោជ្ឈង្គ ឲ្យកើតឡើង ។

ព្រះយោគីកាលញ៉ាំងធម៌ទាំងឡាយនេះឲ្យកើតឡើងដោយអាការៈទាំងឡាយនេះ ដូចបានពោលមកនេះហើយ ឈ្មោះថា ធ្វើសម្ពោជ្ឈង្គ ៣ មានបស្សទ្ធិសម្ពោជ្ឈង្គជាដើមឲ្យចំរើន ។ ព្រះយោគី សង្កត់សង្កិនចិត្តក្នុងសម័យដែលត្រូវសង្កត់សង្កិន យ៉ាងនេះឯង ។

### ៦- ធ្វើចិត្តឲ្យរីករាយ ក្នុងសម័យដែលត្រូវឲ្យរីករាយ

(៨៨) សួរថា : តើព្រះយោគី ញ៉ាំងចិត្តឲ្យរីករាយ ក្នុងសម័យដែលត្រូវឲ្យរីករាយ ដូចម្តេច? ។ ឆ្លើយថា: ក្នុងពេលណា ចិត្ត របស់ព្រះយោគីនោះ ជាធម្មជាតមិនមានសេចក្តីរីករាយ ព្រោះភាវៈនៃសេចក្តីព្យាយាមខាងផ្លូវបញ្ញា ជាធម្មជាតទន់ខ្សោយក្តី ព្រោះមិនបាននូវសេចក្តីសុខដែលកើតអំពីសេចក្តីស្ងប់ក្តី, ក្នុងពេលនោះ ព្រះយោគី ញ៉ាំងចិត្តនោះ ឲ្យតក់ស្លុត ដោយការពិចារណាសង្វេគវត្ថុ ៨ យ៉ាង ។ ឈ្មោះថា សង្វេគវត្ថុ ៨ យ៉ាង (គឺ) ជាតិ, ជរា, ព្យាធិ និង មរណៈ ត្រូវជា ៤, ទុក្ខក្នុងអបាយ ជាគម្រប់ ៥, ទុក្ខ មានវដ្តៈ ជាឫសគល់ ក្នុងអតីត (ជា

គម្រប់ ៦), ទុក្ខ មានវដ្តៈជាឫសគល់ ក្នុងអនាគត (ជាគម្រប់ ៧), ទុក្ខមានការស្វែងរកអាហារ ក្នុងបច្ចុប្បន្ន (ជាគម្រប់ ៨) ។ ព្រះយោគីញ៉ាំងសេចក្ដីជ្រះថ្លាឲ្យកើតឡើងដល់ចិត្តនោះ ដោយការរលឹករឿយៗ នូវគុណព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃផងដែរ ។ ព្រះយោគី ញ៉ាំងចិត្ត ឲ្យរីករាយ ក្នុងសម័យដែលត្រូវធ្វើឲ្យរីករាយ យ៉ាងហ្នឹងឯង ។

### ៧- ធ្វើចិត្តឲ្យស្ងួចចុះក្នុងសម័យដែលគួរឲ្យស្ងួចចុះ

សួរថាៈ តើព្រះយោគី ធ្វើចិត្តឲ្យស្ងួងចុះ ក្នុងសម័យដែលខ្លួនត្រូវធ្វើឲ្យស្ងួងចុះ យ៉ាងដូចម្ដេច? ។ ឆ្លើយថាៈ កាលព្រះយោគីនោះប្រតិបត្តិយ៉ាងនេះ ចិត្ត ជាធម្មជាតមិនរួញរា មិនរាយមាយ មិនត្រេកអរ ប្រព្រឹត្តទៅស្មើ ក្នុងអារម្មណ៍ ដើរទៅកាន់វិថីនៃសមថៈ ក្នុងពេលណា, ក្នុងពេលនោះ ព្រះយោគីនោះ មិនដល់នូវសេចក្ដីខ្វល់ខ្វាយ ក្នុងការផ្គង, ការសង្កត់សង្កិន និង ការធ្វើឲ្យរីករាយ ដូចជានាយសារថី កាលបើសេះទាំងឡាយ បោលទៅស្មើគ្នាហើយ មិនត្រូវខ្វល់ខ្វាយ យ៉ាងនោះឯង ។ ព្រះយោគី តែងធ្វើចិត្តឲ្យស្ងួងចុះ ក្នុងសម័យដែលត្រូវធ្វើឲ្យស្ងួងចុះ យ៉ាងដូច្នេះឯង ។

### ៨- វៀរចាកបុគ្គលដែលមិនមានចិត្តជាសមាធិ

ការលះបង់ឲ្យឆ្ងាយ នូវបុគ្គលទាំងឡាយ ដែលមិនធ្លាប់ឡើងកាន់នេក្ខម្មប្បដិបទា អ្នកមានកិច្ចការច្រើន (តែ) មានការស្ដាប់តិច អ្នកមានចិត្តរាយមាយហើយ ឈ្មោះថា ការវៀរស្រឡះចាកបុគ្គល ដែលមិនមានចិត្តជាសមាធិ ។

### ៩- សេពគប់បុគ្គលដែលមានចិត្តជាសមាធិ

ការចូលទៅរកបុគ្គលទាំងឡាយ អ្នកដើរទៅកាន់នេក្ខម្មប្បដិបទា



អ្នកបាននូវសមាធិ តាមកាលដ៏សមគួរ ឈ្មោះថា ការសេពគប់រកនូវបុគ្គលដែលមានចិត្តជាសមាធិ ។

### ១០- បង្អោនចិត្តទៅក្នុងសមាធិនោះ

ភាពនៃបុគ្គលមានចិត្តបង្អោនទៅក្នុងសមាធិ ឈ្មោះថា ការបង្អោនចិត្តទៅក្នុងសមាធិនោះ ។ សេចក្ដីថាៈ ភាពនៃបុគ្គលអ្នកធ្ងន់ ក្នុងសមាធិ, បន្ទន់ទៅ ក្នុងសមាធិ, ឱនលំទោនទៅ ក្នុងសមាធិ និង ញោចទៅ ក្នុងសមាធិ ។ អប្បនាកោសល្លទាំង ១០ ប្រការនេះ ព្រះយោគី គប្បីឲ្យសម្រេច យ៉ាងដូច្នេះឯង ។

ព្រោះថា កាលព្រះយោគី ញ៉ាំងអប្បនាកោសល្លនេះ ឲ្យសម្រេចយ៉ាងនេះ កាលបើនិមិត្ត គឺខ្លួនបានហើយ អប្បនារមែងប្រព្រឹត្តទៅ ។ ក៏កាលបើព្រះយោគី សូម្បីប្រតិបត្តិយ៉ាងនេះហើយ អប្បនានោះ ក៏នៅតែមិនប្រព្រឹត្តទៅទេ បើទុកជាដូច្នោះ ព្រះយោគី ជាបណ្ឌិត ក៏មិនគួរលះបង់នូវសេចក្ដីព្យាយាមជាគ្រឿងប្រកប ត្រូវប្រឹងប្រែងឲ្យមែនទែន។ ព្រោះថាព្រះយោគីកម្លោះ ឈ្មោះថាលះបង់សេចក្ដីព្យាយាមត្រូវហើយ គប្បីបានសំរេចគុណវិសេស សូម្បីបន្តិចបន្តួច ហេតុនេះ ជាហេតុជាទីតាំងមិនមានឡើយ ។ ព្រោះហេតុនោះ ជនអ្នកត្រាស់ដឹង កាលកំណត់អាការៈនៃការប្រព្រឹត្តិទៅនៃចិត្ត គប្បីប្រកបរឿយៗនូវភាពស្មើគ្នានៃសេចក្ដីព្យាយាមឲ្យបាន។ ព្រះយោគី គប្បីផ្គងចិត្តដែលជាធម្មជាតរួញរានោះសូម្បីបន្តិចបន្តួច គប្បីហាមឃាត់ចិត្តដែលប្រារព្ធសេចក្ដីព្យាយាមក្រៃពេក ហើយញ៉ាំងចិត្ត ឲ្យ

ប្រព្រឹត្តទៅស្មើតែម្យ៉ាង ។ ព្រះយោគី គប្បីរំដោះចិត្តចាក សេចក្តីរួញរា និង សេចក្តីអណ្តែតអណ្តូង ដោយប្រការទាំងពួងហើយ គប្បីញ៉ាំងចិត្តដែលមានមុខឆ្ពោះទៅកាន់និមិត្ត ឲ្យប្រព្រឹត្តទៅ ប្រៀបដូចជាការប្រព្រឹត្តិទៅនៃការកបុគ្គលទាំងឡាយ មានមេឃ្មុំជាដើម ក្នុងលំអងផ្កា ក្នុងស្លឹកនៃឧប្បល ក្នុងសរសៃនៃពីងពាង ក្នុងនាវា ក្នុងនាឡិដែលលោកពណ៌នាហើយ យ៉ាងដូច្នោះ ។

(ឧបមានៃសម្មាវាយាមៈ)

(៨៩) នេះជាការបំភ្លឺសេចក្តី ក្នុងគាថានោះ ។ ឧបមាដូចជាមេឃ្មុំដែលមិនឈ្លាសដឹងថា “ផ្កាឈើលើដើមឈើឯណោះ ផ្កាហើយ” ដូច្នេះ កាលស្ទុះទៅ ដោយសន្ទុះយ៉ាងខ្លាំង ក៏ហួសរំលងនូវផ្កានោះហើយ ទើបត្រឡប់មកដល់វិញ កាលលំអងផ្កាអស់ហើយ, មេឃ្មុំមួយទៀត មិនឈ្លាសវៃ ហើរស្ទុះទៅដោយល្បឿនខ្សោយ, កាលលំអងផ្កាអស់ហើយដូចគ្នា ទើបមកដល់, ចំណែកមេឃ្មុំដែលឆ្លាត ហើរស្ទុះទៅដោយល្បឿនស្មើ ដល់នូវគំនរផ្កា ដោយស្រួល ក្រេបយកនូវលំអងផ្កា តាមសេចក្តីត្រូវការ មកធ្វើជាទឹកឃ្មុំស្រេចហើយ ទើបសោយរសនៃទឹកឃ្មុំ យ៉ាងណាមិញ ។ មួយទៀត ឧបមាដូចជា កាលកូនសិស្ស នៃជាងឆ្មាក់ទាំងឡាយ កាលយកកាំបិតឆ្មាក់ឲ្យដ៏ស្លឹកឈូកដែលបណ្តែតនៅក្នុងអាងទឹក, កូនសិស្សម្នាក់ មិនឈ្លាសពេក កាលដាក់កាំបិត ដោយប្រញាប់ ទើបកាត់ស្លឹកឧប្បលជាពីរខ្ទះ ធ្វើឲ្យស្លឹកឧប្បល ដាច់ធ្លាក់ចុះទៅ ក្នុងទឹកខ្លះ, សិស្សម្នាក់ទៀត មិនឈ្លាស មិនហ៊ានយកកាំបិត មកប៉ះពាល់ទាល់តែ



សោះ ព្រោះភ័យខ្លាចស្លឹកឧប្បលដាច់ និង លិចចុះ, ឯកូនសិស្សដែលឈ្លាសវៃ សំដែងនូវទំហឹងនៃកាំបិត លើស្លឹកឧប្បលនោះ ដោយសេចក្តីព្យាយាមដ៏ស្មើ ជាអ្នកឈ្មោះថា មានសិល្បៈដ៏ផូរផង់ ធ្វើការងារក្នុងទីទាំងពួង មានសភាពបែបនោះ រមែងបាននូវលាភ យ៉ាងណាមិញ ។ មួយទៀត ឧបមាដូចកាលព្រះរាជាទ្រង់ប្រកាស ថា “បុគ្គលណានាំមកនូវសរសៃ នៃពីងពាងប្រមាណ ៤ ព្យាមមកបាន, បុគ្គលនោះ នឹងបានទ្រព្យបួនពាន់កហាបណៈ”ដូច្នេះ, បុរសម្នាក់មិនឈ្លាសពេកទាញសរសៃពីងពាង ដោយប្រញាប់ ក៏ដាច់ក្នុងទីនោះៗ ភ្លាមទៅ, បុរសមិនឈ្លាសដទៃផ្សេងទៀត មិនហ៊ានសូម្បីប៉ះពាល់ដោយដៃឡើយ ព្រោះខ្លាចវាដាច់, ចំណែកបុរសឈ្លាស រុំព័ទ្ធកំណាត់ឈើ ដោយសេចក្តីព្យាយាមដ៏ស្មើ ចាប់តាំងអំពីចុង ហើយនាំមក រមែងបាននូវលាភ យ៉ាងណាមិញ ។ មួយទៀត ឧបមាដូចជាជនអ្នកកាន់ចង្កូត មិនឈ្លាសពេក កាលដំឡើងក្តោង ក្នុងពេលមានខ្យល់ខ្លាំង ធ្វើឲ្យនាវាស្ទុះទៅខុសទិសដៅ, ជនអ្នកកាន់ចង្កូតម្នាក់ទៀត មិនឈ្លាស កាលដាក់ក្តោងចុះ ក្នុងពេលមានខ្យល់ខ្សោយ ឈ្មោះថា សំចតនាវា ក្នុងទីនោះដដែល, ចំណែកជនអ្នកឈ្លាសដំឡើងក្តោងហើយ ក្នុងពេលដែលមានខ្យល់ខ្សោយ ដាក់ក្តោងចុះពាក់កណ្តាល ក្នុងពេលដែលមានខ្យល់ខ្លាំង រមែងទៅដល់ទីកន្លែងដែលខ្លួនប្រាថ្នា ដោយសួស្តី យ៉ាងណាមិញ ។ មួយវិញទៀត ឧបមាដូចជាកាលអាចារ្យ ប្រកាសដល់អន្តេវាសិកទាំងឡាយថា “អ្នកណា មិនធ្វើឲ្យប្រេងកំពប់ ច្រកពេញនាឡិ, អ្នកនោះ នឹងបានលាភ” ដូច្នេះ, សិស្សម្នាក់ មិនឈ្លាសពេក ជាអ្នកជាប់ជំពាក់ក្នុងលាភ ច្រក(ប្រេង) យ៉ាងប្រញាប់ ក៏ធ្វើឲ្យប្រេងកំពប់, សិស្សម្នាក់ទៀតមិនឈ្លាសមិនហ៊ានសូម្បី

តែចាក់ ព្រោះខ្វាចកំពប់ប្រេង, ចំណែកឯសិស្សឈ្មោស ប្រក (ប្រេង) ដោយសេចក្ដីព្យាយាមដ៏ស្មើ រមែងបានលាភ យ៉ាងណា ។ ឧបមេយ្យ ក៏យ៉ាងនោះដែរ, ភិក្ខុមួយរូប កាលនិមិត្តកើតឡើងហើយ គិតថា "អាត្មាអញ នឹងដល់អប្បនា យ៉ាងឆាប់រហ័ស មិនខាន" ដូច្នេះ ទើបធ្វើសេចក្ដីព្យាយាមយ៉ាងខ្លាំង, ចិត្ត របស់ភិក្ខុនោះ ក៏ធ្លាក់ចុះទៅក្នុងឧទ្ធច្ចៈ ព្រោះភាវៈនៃខ្លួនជាអ្នកប្រារព្ធសេចក្ដីព្យាយាមក្រៃពេក, ភិក្ខុនោះ ក៏មិនអាចដល់នូវអប្បនាបានឡើយ, ភិក្ខុ មួយរូបទៀត ឃើញទោស ព្រោះភាវៈនៃខ្លួនប្រារព្ធសេចក្ដីព្យាយាមខ្លាំងពេក ទើបបន្ថយ នូវសេចក្ដីព្យាយាម ដោយគិតថា "ប្រយោជន៍អ្វី ដល់អាត្មាអញ ដោយអប្បនា ក្នុងពេលឥឡូវនេះ" ដូច្នេះ, ចិត្ត របស់ភិក្ខុនោះ រមែងធ្លាក់ចុះទៅ ក្នុងកោសជ្ជៈ ព្រោះភាវៈនៃខ្លួន ជាអ្នកមានសេចក្ដីព្យាយាម ធូរថយហួសពេក, សូម្បីភិក្ខុនោះ ក៏មិនអាចដើម្បីដល់នូវអប្បនាបានដែរ, ឯភិក្ខុរូបណា រំដោះចិត្តដែលរួញរា សូម្បីបន្តិចបន្តួចចាកភាវៈ នៃចិត្តដែលរួញរា ដោះចិត្តដែលរាយមាយ សូម្បីបន្តិចបន្តួចចាកភាវៈនៃចិត្តដែលរាយមាយហើយ ញុំាងចិត្តដែលមានមុខឆ្ពោះទៅកាន់និមិត្ត ឲ្យប្រព្រឹត្តទៅដោយសេចក្ដីព្យាយាមស្មើ, ភិក្ខុនោះទើបបានដល់នូវអប្បនា ។ ព្រះយោគី គប្បីជាអ្នកប្រាកដបែបនោះចុះ ។

ព្រះអដ្ឋកថាចារ្យ សំដៅយកសេចក្ដីនេះ ទើបពោលគាថានេះថា :

ព្រះយោគី គប្បីរំដោះចិត្តចាកសេចក្ដីរួញរា និង សេចក្ដីអណ្ដែតអណ្ដូង ដោយប្រការៈទាំងពួងហើយ គប្បីញុំាងចិត្តដែលមានមុខឆ្ពោះទៅកាន់និមិត្ត ឲ្យប្រព្រឹត្តទៅ ប្រៀបដូចជាការប្រព្រឹត្តិទៅ នៃការកបុគ្គលទាំងឡាយមានមេឃ្មុំ



ជាដើម ក្នុងលំអងផ្កា ក្នុងស្លឹកនៃឧប្បល ក្នុងសរសៃ នៃពីងពាង ក្នុងនាវា ក្នុងនាឡិ ដែលលោកពណ៌នាហើយ យ៉ាងដូច្នោះឯង ។

(៩០) ក៏កាលបើព្រះយោគីនោះ ធ្វើចិត្តដែលមានមុខឆ្ពោះទៅកាន់និមិត្ត ឲ្យប្រព្រឹត្តទៅយ៉ាងនេះ ដោយប្រការដូច្នេះ, ចិត្ត សំរាប់ភាវរកអារម្មណ៍ក្នុងមនោទ្វារ កាត់ផ្ដាច់នូវភវង្គៈ ថា "អប្បនា នឹងសំរេច ក្នុងពេលឥឡូវនេះ" ដូច្នេះហើយ ធ្វើនូវបឋវីកសិណនោះឯង ដែលប្រាកដហើយ ដោយអំណាចនៃកិរិយាប្រកបរឿយៗ ថា "បឋវី បឋវី" ដូច្នេះ ឲ្យជាអារម្មណ៍ទើបកើតឡើង ។ បន្ទាប់អំពីនោះមក ជវនចិត្ត ៤ ឬ ៥ តែងស្ទុះទៅ ក្នុងអារម្មណ៍នោះឯង, ក្នុងទីបំផុត ក្នុងជវនចិត្តទាំងឡាយនោះ ចិត្ត មួយជារូបាវចរ ចិត្ត ដ៏សេសទាំងឡាយជាកាមាវចរ ជាចិត្តមានវិតក្កៈ, វិចារៈ, បីតិ, សុខៈ និង ចិត្តេកគ្គតា ដ៏មានកម្លាំងខ្លាំងវិសេសជាងចិត្តជាប្រក្រតីទាំងឡាយ ដែលលោកហៅថា "បរិកម្មចិត្ត" ព្រោះជាចិត្តតាក់តែងអប្បនាខ្លះ, ហៅថា "ឧបចារចិត្ត" ដូច្នេះខ្លះ ព្រោះជាចិត្តមាននៅ ក្នុងទីជិតអប្បនាផង ព្រោះជាចិត្តប្រព្រឹត្តទៅ ក្នុងទីជិតនៃអប្បនាផង ដូចជាប្រទេសដែលមាននៅក្នុងទីជិត នៃទីទាំងឡាយមានស្រុកជាដើម ក៏លោកហៅថា "ឧបចារនៃស្រុក, ឧបចារនៃក្រុង" យ៉ាងនោះឯង, លោកហៅថា "អនុលោមចិត្ត" ខ្លះ ព្រោះជាចិត្តអនុលោមទៅដល់បរិកម្មចិត្តទាំងឡាយ ក្នុងកាលមុនពីកាលនោះផង ដល់អប្បនាចិត្ត ក្នុងកាលខាងមុខផង ។ មួយទៀត បណ្ដាចិត្តទាំងនោះ ចិត្ត ណាមាននៅក្នុងទីបំផុតនៃចិត្តទាំងពួង ចិត្តនោះ លោកហៅថា "គោត្រភូ" ខ្លះ

ព្រោះគ្របសង្កត់កាមាវចរចិត្តផង ព្រោះអប់រំរូបាវចរចិត្តផង ។

ក៏ដោយលំដាប់នៃជវនចិត្ត ដែលលោកមិនបានចាត់ទុកហើយ ក្នុងជវនចិត្តទាំងនោះ ជវនចិត្តទីមួយ ជាបរិកម្ម, ទីពីរជាឧបចារៈ, ទីបី ជាអនុលោម, ទីបួន ជាគោត្រភូ, ន័យមួយទៀត ជវនចិត្តទីមួយ ជាឧបចារៈ, ទីពីរ ជាអនុលោម, ទីបី ជាគោត្រភូ, ទីបួន ឬ ទីប្រាំ ជាអប្បនាចិត្ត ។ មែនពិត ជវនចិត្តទីបួនទុំះឯង ឬក៏ ទីប្រាំ រមែងដល់នូវអប្បនា ។ ក៏ជវនចិត្តនោះឯង (រមែងដល់នូវអប្បនា) ដោយអំណាចនៃអភិញ្ញាឆាប់ និង អភិញ្ញាយឺតយូរ ។ ជវនចិត្ត បន្ទាប់អំពីនោះមក ជាប្រក្រតី, ជាភវៈនៃភវង្គៈ ។

ឯព្រះគោទត្តត្ថេរ អ្នករៀនព្រះអភិធម្ម ពោលនូវសូត្រនេះ ថា "ធម៌ទាំងឡាយជាកុសល មានក្នុងខាងដើមៗ ជាបច្ច័យ ដោយជាបច្ច័យនៃការសេពនូវធម៌ទាំងឡាយជាកុសល មានក្នុងខាងចុងៗ" ដូច្នេះហើយ ពោលថា "ធម៌ដែលកើតខាងក្រោយៗ ជាធម៌មានកម្លាំង ដោយសារអាសេវនប្បច្ច័យ, ព្រោះហេតុដូច្នោះ អប្បនា រមែងកើត ក្នុងជវនចិត្តទី ៦ ឬ ទី ៧" ដូច្នេះ ។ ពាក្យ របស់ព្រះគោទត្តត្ថេរនោះ លោកពោលបដិសេធហើយ ក្នុងអដ្ឋកថាទាំងឡាយថា "ពាក្យនៃព្រះថេរៈនេះ គ្រាន់តែជាមតិរបស់ខ្លួន" ។ ចំណែកអប្បនា តែងកើត ក្នុងជវនចិត្តទីបួន និង ទីប្រាំតែម្យ៉ាង, ជវនចិត្ត បន្ទាប់មក ឈ្មោះថា ជាធម្មជាតធ្លាក់ចុះហើយ ព្រោះភាវៈនៃជវនៈមានក្នុងទីជិត នៃភវង្គៈ, ពាក្យនោះ ព្រះអដ្ឋកថាចារ្យពោលហើយ ។ ពាក្យរបស់ព្រះអដ្ឋកថាចារ្យនោះ គឺអ្នកណាក៏មិនអាចប្រកែកបានឡើយ ព្រោះជាពាក្យដែលលោកពិចារណា យ៉ាងនេះហើយទើបពោល ។ មែនពិត ចិត្ត តែងមិនអាចដើម្បីនឹងដល់នូវអប្បនា ក្នុង



ជវនៈ ទី ៦ ឬ ទី ៧ បានឡើយ ព្រោះជាធម្មជាតមានក្នុងទីជិតនៃភវង្គៈ ប្រៀបដូចបុរស រត់មានមុខឆ្ពោះទៅកាន់ជ្រោះដែលដាច់ សូម្បីប្រាថ្នាចង់ឈប់ ក៏មិនអាចដាក់ជើងឲ្យឈប់នៅត្រង់ទីប្របេះ (នៃជ្រោះ)បានឡើយ តែងធ្លាក់ចុះទៅ ក្នុងជ្រោះមិនខាន ក៏យ៉ាងនោះដែរ ហេតុនោះ អប្បនា បណ្ឌិតគប្បីជ្រាបថា "តែងកើតក្នុងជវនៈទីបួន និង ទីប្រាំតែប៉ុណ្ណោះ" ។

ក៏អប្បនានោះ ប្រព្រឹត្តទៅក្នុងខណៈ នៃចិត្តមួយប៉ុណ្ណោះ ។ មែនពិត ឈ្មោះថា ការកំណត់កាលដ៏យូរ ក្នុងទីទាំងឡាយ ៧ គឺៈ ក្នុងអប្បនាទីមួយ ១, ក្នុងលោកិយអភិញ្ញាទាំងឡាយ ១, ក្នុងមគ្គបួន ១, ក្នុងផល ដែលជាលំដាប់នៃមគ្គ ១, ក្នុងភវង្គឈាន ក្នុងរូបភព និង អរូបភព ១, ក្នុងនេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យនៃនិរោធ ១, ក្នុងផលសមាបត្តិនៃព្រះយោគីដែលចេញអំពីនិរោធ ១ មិនមានទេ ។ ក្នុងទីទាំង ៧ នោះ ផលជាបន្ទាប់អំពីមគ្គ មិនមាន ក្នុងខាងលើនៃជវនៈទាំង ៣ ទេ ។ នេវសញ្ញានាសញ្ញាយតនៈ ជាបច្ច័យនៃនិរោធ មិនមាន ក្នុងខាងលើនៃជវនៈទាំងឡាយពីរទេ ។ បរិមាណនៃភវង្គឈាន ក្នុងរូបភព និង អរូបភព មិនមានទេ ។ ក្នុងទីដ៏សេសទាំងឡាយ ចិត្ត ជាធម្មជាតមានតែមួយប៉ុណ្ណោះ ។ អប្បនា ប្រព្រឹត្តទៅ ក្នុងខណៈនៃចិត្តតែមួយដូចបានពោលមកនេះឯង ។ បន្ទាប់អំពីអប្បនានោះ (ទើបមាន) ការធ្លាក់ចុះកាន់ភវង្គៈ ។ លំដាប់នោះ អាវជ្ជនចិត្តកាត់ផ្តាច់ភវង្គៈ(កើតឡើង) ដើម្បីប្រយោជន៍ដល់ការពិចារណានូវឈាន ។ បន្ទាប់អំពីនោះមក ការពិចារណានូវឈាន (ទើបកើតឡើង) ដូច្នេះឯង ។

ក៏ដោយលំដាប់នៃការនា មានប្រមាណប៉ុណ្ណោះ ព្រះយោគីទុំះ ឈ្មោះថា ស្ងាត់ចាកកាមទាំងឡាយមែនពិត ស្ងាត់ចាកធម៌ទាំងឡាយ

ជាអកុសល រមែងចូលទៅដល់ផិតឈានទីមួយ មានវិតក្កៈ មានវិចារៈ មានបីតិ និង សុខៈ ដែលកើតអំពីវិវេកហើយនៅ ។ បឋវីកសិណ ហៅថា បឋមជ្ឈាន ដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ មានលំអ ៣ ប្រការ បរិបូណ៌ដោយលក្ខណៈ ១០ ជាឈានដែលព្រះយោគីនោះបាន សម្រេចហើយ ដោយប្រការដូច្នេះ ។

(៩១) បាឋៈថា "ស្ងប់ស្ងាត់ចាកកាមទាំងឡាយ" សេចក្តីថា ស្ងប់ គឺវៀរហើយ គេចចេញហើយចាកកាមទាំងឡាយ ។ ចំណែក ឯវ អក្សរ ណា ក្នុងទីនេះ, ឯវ អក្សរនេះនុ៎ះ បណ្ឌិតគប្បីជ្រាបថា "មានការកំណត់ ជាអត្ថ" ។ ក៏ ឯវ អក្សរ មានការកំណត់ជាអត្ថ ព្រោះហេតុណា, ព្រោះ ហេតុនោះ ឯវ អក្សរនោះ ទើបសំដែងនូវភាវៈនៃកាមទាំងឡាយ សូម្បី មិនមាន ក្នុងសម័យដែលចូលទៅជិតបឋមជ្ឈាននោះហើយនៅ ក៏ជា សត្រូវចំពោះបឋមជ្ឈាននោះផង នូវការបានសម្រេចនូវបឋមជ្ឈាននោះ ព្រោះការលះបង់ នូវកាមទាំងឡាយហ្នឹងឯងផង ។ ដោយប្រការដូច ម្តេច? ។ គឺកាលបើព្រះយោគី ធ្វើការកំណត់ ដោយបាឋៈថា "ស្ងាត់ ចាកកាមទាំងឡាយ មែនពិត" យ៉ាងដូច្នេះ, សេចក្តីថា ពាក្យអធិប្បាយ នេះ បណ្ឌិត ក៏ដឹងជាក់ច្បាស់ថា "កាមទាំងឡាយ ជាសត្រូវដល់ឈាន នោះដោយពិត, កាលបើកាមទាំងឡាយមាន, ឈាននេះ ក៏មិនប្រព្រឹត្ត ទៅដែរ ដូចជាកាលបើមានងងឹត ពន្លឺនៃប្រទីប ក៏មិនមាន យ៉ាងនោះ, មួយទៀត ការបាននូវឈាននោះ កើតមាន ព្រោះការលះបង់កាមទាំង ឡាយនោះប៉ុណ្ណោះ ប្រៀបដូចជាការទៅដល់ត្រើយនាយ រមែងកើតមាន ក៏ព្រោះតែលះបង់នូវត្រើយអាយនុ៎ះឯង ។ ព្រោះហេតុនោះ ឯវ អក្សរ ទើបឈ្មោះថា ធ្វើនូវការកំណត់" ដូច្នេះឯង ។



ក្នុងបាឋៈនោះ គប្បីមានពាក្យសួរថា "ក៏ព្រោះហេតុអ្វី ឯវ អក្សរ នេះ លោកពោលហើយតែក្នុងបទខាងដើម មិនពោលក្នុងបទខាងចុង? ចុះបើទុកជាបុគ្គល មិនស្ងាត់ចាកធម៌ទាំងឡាយ ដែលជាអកុសលហើយ គប្បីចូលទៅកាន់ឈានហើយ នៅបានដែរឬទេ?" ។ មានពាក្យឆ្លើយថា "ក៏ ឯវ អក្សរនេះ លោកពោលហើយ តែក្នុងបទខាងដើម មិនពោល ក្នុងបទខាងចុងនោះ គឺបុគ្គលមិនគប្បីឃើញ យ៉ាងនេះទេ ព្រោះថា ឯវ អក្សរនុ៎ះ គឺលោកពោលហើយ ក្នុងបទខាងដើម ព្រោះឈានរលាស់ ខ្លួនចេញចាកកាមនោះ, មែនពិត ឈាននេះ ឈ្មោះថា ជាគ្រឿងរលាស់ ខ្លួនចេញចាកកាមទាំងឡាយនុ៎ះឯង ព្រោះជាផ្លូវកន្លងនូវកាមធាតុ និង ព្រោះជាសត្រូវដល់កាមរាគៈ សមដូចព្រះសារីបុត្រ ពោលថា "ធម្មជាត នេះជាគ្រឿងរលាស់ចេញចាកកាមទាំងឡាយ ធម្មជាតនេះគឺអ្វី? ធម្មជាត នេះ គឺនេក្ខម្មៈ [១] " ដូច្នេះ ។ ចំណែកខាង ឯវ អក្សរ ក្នុងបាឋៈនេះ គឺ បណ្ឌិតគប្បីពោល សូម្បីក្នុងបទខាងចុងផងដែរ ដូចជា ឯវ អក្សរដែល ព្រះមានព្រះភាគ ទ្រង់នាំមកត្រាស់ទុក ក្នុងបទខាងចុង ក្នុងបាឋៈនេះ ថា "ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ ក្នុងព្រះសាសនានេះឯង សមណ ទី ២ ក្នុងព្រះសាសនានេះ [២] " យ៉ាងនោះឯង, ព្រោះថា ព្រះយោគីមិន អាចដើម្បីមិនស្ងាត់ចាកធម៌ទាំងឡាយជាអកុសល ពោលគឺនីវរណៈ ដទៃទៀត ក្រៅអំពីកាមឆន្ទៈនេះហើយ ចូលទៅកាន់ឈានហើយនៅបាន ឡើយ ព្រោះហេតុនោះ ឯវ អក្សរនោះ បណ្ឌិត គប្បីឃើញ សូម្បីក្នុង បទទាំង ២ យ៉ាងនេះ ថា "ស្ងប់ស្ងាត់មែនពិតចាកកាមទាំងឡាយ ស្ងប់ ស្ងាត់ពិត ចាកធម៌ទាំងឡាយជាអកុសល" ដូច្នេះ ។ ឯវិវេកទាំងឡាយ

១– សុ. ខុ. ភាគ ៧១ ទំព័រ ៣៤៨ ។ ២– សុ. អំ. ភាគ ៤៣ ទំព័រ ២៨៥ ។

ទាំងពួង មានកាយវិវេកជាដើមផង មានចិត្តវិវេកជាដើមផង តែងដល់នូវការរួបរួម ដោយពាក្យជាទូទៅនេះថា "ស្ងប់ស្ងាត់ហើយ"ដូច្នេះ សូម្បីក្នុងបទទាំង ២ ក៏ពិតមែនហើយ តែបើទុកជាដូច្នោះ វិវេកទាំង ៣ ហ្នឹងឯង គឺ : កាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក បណ្ឌិត គប្បីឃើញ ក្នុងឈានកថានេះ ។

ក៏ដោយបទនេះថា "កាមេហិ" វត្ថុកាមទាំងឡាយឯណា ដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងនិទ្ទេស ដោយន័យថា "វត្ថុកាមទាំងឡាយតើដូចម្ដេច? គឺរូបជាទីគាប់ចិត្ត ជាទីស្រឡាញ់ [១] " ដូច្នេះជាដើម និងកិលេសកាមទាំងឡាយឯណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយក្នុងវិភង្គ ក្នុងនិទ្ទេសនោះ ដូចគ្នាដែរ យ៉ាងនេះថា "ឆន្ទៈ ហៅថា កាម, រាគៈ ហៅថា កាម, ឆន្ទរាគៈ ហៅថា កាម, សង្កប្បៈ ហៅថាកាម, ការត្រេកត្រអាល ហៅថា កាម, សង្កប្បរាគៈ ហៅថា កាម, កិលេសទាំងឡាយនេះ ហៅថា កាម" ដូច្នេះ, វត្ថុកាម និង កិលេសកាមទាំងឡាយទាំងពួងនោះ បណ្ឌិត គប្បីឃើញថា លោករួបរួមហើយដូច្នេះមែនពិត ។ ក៏កាលបើមានហេតុយ៉ាងនេះ បាឋៈ ថា "ស្ងាត់ចាកកាមទាំងឡាយមែនពិត" ដូច្នេះនោះ សូម្បីមានសេចក្ដីថា "ស្ងាត់ហើយ ចាកវត្ថុកាមទាំងឡាយមែនពិត" ដូច្នេះ ក៏ប្រើការបាន ។ កាយវិវេក ជាវិវេកដែលលោកពោលហើយ ដោយការស្ងាត់ចាកវត្ថុកាមនោះ ។ បាឋៈថា "ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ" ដូច្នេះ នឹងយកសេចក្ដីថា "ស្ងាត់ហើយចាកកិលេសកាមទាំងឡាយ ឬ ចាកអកុសលទាំងពួងទាំងឡាយ" ដូច្នេះក៏សមគួរ ។ ចិត្តវិវេក ជាវិវេកដែលលោកពោលហើយដោយការស្ងាត់

១- សុ. ខុ. មហា. ភាគទី ៦៨ ទំព័រទី ១ ។



ចាកកិលេសកាមនោះ ។ មួយទៀត បណ្ឌិតគប្បីជ្រាបថា "ក្នុងបាឋៈទាំង ២ នោះ ការលះបង់នូវកាមសុខ គឺលោកសំដែង ឲ្យជាក់ច្បាស់ហើយដោយបាឋៈខាងដើម ព្រោះសំដែងដល់ការស្ងាត់ចាកវត្ថុកាមទាំងឡាយមែនពិត, ការកំណត់យកនូវនេក្ខម្មសុខ គឺលោកសំដែង ឲ្យជាក់ច្បាស់ហើយ ដោយបាឋៈទី២ ព្រោះសំដែងដល់ការស្ងាត់ចាកកិលេសកាមទាំងឡាយ ។ មួយទៀត ព្រោះសំដែងដល់ការស្ងាត់ចាកវត្ថុកាម និងកិលេសកាម ដូចគ្នានោះឯង ការលះបង់នូវកិលេសវត្ថុ គឺលោកសំដែងឲ្យជាក់ច្បាស់ហើយដោយបាឋៈខាងដើម បណ្ដាបាឋៈទាំងពីរនោះ, ការលះបង់នូវសង្កិលេស គឺលោក សំដែងឲ្យជាក់ច្បាស់ហើយ ដោយបាឋៈទី២, ការលះបង់នូវហេតុនៃភាពលោភលន់ គឺលោកសំដែងឲ្យជាក់ច្បាស់ហើយ ដោយបាឋៈទី១, ការលះបង់នូវហេតុនៃភាពល្ងង់ខ្លៅ គឺលោកសំដែង ឲ្យជាក់ច្បាស់ហើយ ដោយបាឋៈទី ២, ឯសេចក្ដីបរិសុទ្ធិដោយការព្យាយាម គឺលោកសំដែង ឲ្យជាក់ច្បាស់ហើយ ដោយបាឋៈទី ១, ការជំរះអធ្យាស្រ័យ គឺលោកសំដែងឲ្យជាក់ច្បាស់ហើយដោយបាឋៈទី២" ។ បណ្ឌិត គប្បីជ្រាបន័យនេះ ក្នុងពួកវត្ថុកាម បណ្ដាកាម ដែលលោកពោលហើយ ក្នុងបទនេះថា "ចាកកាមទាំងឡាយ" ដូច្នេះមុន ។

ចំណែកក្នុងពួកកិលេសកាម សេចក្ដីពេញចិត្ត ក្នុងកាមហ្នឹងឯងមានប្រភេទជាអនេក ដោយឈ្មោះជាអាទិ៍យ៉ាងនេះ ថា "សេចក្ដីពេញចិត្តដូច្នេះផង តម្រេកដូច្នេះផង" គឺលោកបំណងយកហើយថា "កាម" ។ ក៏កាមឆន្ទៈនោះ សូម្បីជាកិលេស ដែលលោករាប់បញ្ចូលហើយ ក្នុងអកុសល ក៏ព្រះមានព្រះភាគទ្រង់ត្រាស់ហើយផ្សេងគ្នា ព្រោះជាសត្រូវចំពោះឈាន ក្នុងវិភង្គ ដោយន័យថា "បណ្ដាកាមជាអកុសលនោះ កាម

ទាំងឡាយ តើដូចម្តេច? គឺ ឆន្ទៈ ឈ្មោះថា កាម” ដូច្នេះជាដើម។ មួយវិញទៀត កាមឆន្ទៈនោះ លោកពោលហើយ ក្នុងបទខាងដើម ព្រោះកាមឆន្ទៈនោះជាកិលេសកាម, គឺលោកពោលហើយ ក្នុងបទទី២ ព្រោះកាមឆន្ទៈនោះ គឺលោករាប់បញ្ចូលហើយ ក្នុងអកុសល ។ ឯពាក្យថា “កាមេហិ” ដូច្នេះ គឺព្រះមានព្រះភាគ មិនបានត្រាស់ហើយ (តែ) ទ្រង់ត្រាស់ថា “កាមេហិ” ដូច្នេះ ព្រោះភាវៈនៃកាមនោះមានច្រើនប្រភេទ ។ មួយទៀត សូម្បីកាលបើភាវៈនៃធម៌ទាំងឡាយដទៃទៀត ជាអកុសលមាន, នីវរណៈទាំងឡាយហ្នឹងឯង គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងវិភង្គ ដោយន័យថា “បណ្តាធម៌ទាំងឡាយនោះ ធម៌ទាំងឡាយជាអកុសល តើដូចម្តេច? គឺកាមឆន្ទៈ” ដូច្នេះជាដើម ព្រោះការសំដែងនូវភាវៈនៃនីវរណធម៌នោះ ជាទំនាស់ និង ជាសត្រូវ ដល់អង្គនៃឈានទាំងឡាយពួកដ៏ខាងលើ ។ មានពាក្យអធិប្បាយថា “ព្រោះថា នីវរណៈទាំងឡាយ ជាសត្រូវដល់អង្គឈាន។ អង្គឈានទាំងឡាយនុ៎ះឯង ជាសត្រូវ គឺជាគ្រឿងកំចាត់ គឺជាគ្រឿងសម្លាប់នូវនីវរណៈទាំងឡាយនោះ” ។ ពិតដូច្នោះមែន ពាក្យនេះ គឺព្រះមហាកច្ចានត្ថេរ ពោលហើយ ក្នុងគម្ពីរបិដកថា “សមាធិ ជាសត្រូវ ដល់កាមឆន្ទៈ, បីតិ ជាសត្រូវ ដល់ព្យាបាទ, វិតក្កៈ ជាសត្រូវ ដល់ថីនមិទ្ធៈ, សុខៈ ជាសត្រូវ ដល់ឧទ្ធច្ចៈ កុក្កុច្ចៈ, វិចារៈ ជាសត្រូវ ដល់វិចិកិច្ឆា” ដូច្នេះ ។ ដោយន័យដែលបានពោលមកនេះ ក្នុងបាឋៈទាំង ២ នោះ សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវកាមឆន្ទៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបាឋៈនេះ ថា “ស្ងប់ស្ងាត់ហើយមែនពិតចាកកាមទាំងឡាយ”ដូច្នេះ, សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិន នូវនីវរណធម៌ទាំងឡាយ ៥ ហ្នឹងឯង គឺព្រះមាន



ព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបាឋៈទី ២ នេះ ថា “ស្ងប់ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ” ដូច្នេះ ។

ចំណែកសេចក្តីអធិប្បាយ បណ្ឌិត គប្បីជ្រាប ដោយស័ព្ទដែលលោកមិនទាន់បានកាន់យកហើយថា “សេចក្តីស្ងប់ស្ងាត់ព្រោះការសង្កត់សង្កិននូវកាមឆន្ទៈ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទទី១, សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវនីវរណៈ ដ៏សេសទាំងឡាយ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយបទទី២, ន័យដូចគ្នានោះដែរ ក្នុងអកុសលមូលទាំងឡាយ ៣ សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវលោភៈ ដែលមានប្រភេទនៃកាមគុណ ៥ ជាអារម្មណ៍ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយបទទី១, សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវទោសៈ និង មោហៈទាំងឡាយ ដែលមានប្រភេទនៃអាឃាតវត្ថុជាដើម ជាអារម្មណ៍ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទទី២, មួយវិញទៀត ក្នុងធម៌ទាំងឡាយ មានឱឃៈជាដើម សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវកាមោឃៈ, កាមយោគៈ, កាមាសវៈ, កាមុបាទាន, អភិជ្ឈាកាយគន្ថៈ និង កាមរាគសំយោជន៍ទាំងឡាយ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទទី១, សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវឱឃៈ, យោគៈ, អាសវៈ, ឧបាទាន, កាយគន្ថៈ និង សំយោជន៍ដ៏សេសទាំងឡាយ គឺព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទ ទី២, ម្យ៉ាងទៀត សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវតណ្ហា និង ពួកធម៌ដែលប្រកបដោយតណ្ហានោះ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយបទទី១, សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវអវិជ្ជា និង ធម៌ទាំងឡាយដែលប្រកបព្រម ដោយអវិជ្ជានោះ គឺព្រះ

មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយបទទី២, ម្យ៉ាងវិញទៀត សេចក្តីស្ងប់ស្ងាត់ ព្រោះការសង្កត់សង្កិននូវចិត្តុប្បាទទាំងឡាយ ៨ ដែលប្រកបព្រមដោយលោភៈ គឺព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដោយបទទី ១, សេចក្តីស្ងប់ស្ងាត់ព្រោះការសង្កត់សង្កិននូវអកុសលចិត្តុប្បាទទាំងឡាយ ៤ ដ៏សេស គឺព្រះមានព្រះភាគ ត្រាស់ហើយ ដោយបទទី២” ដូច្នេះ ។

ពាក្យដែលបានពោលមកនេះ ជាពាក្យសំដែងនូវសេចក្តី ក្នុងឈានបាឋៈនេះថា “ស្ងប់ស្ងាត់ហើយមែនពិត ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ហើយ ចាកអកុសលធម៌ទាំងឡាយ” ដូច្នេះមុន ។

(៩២) ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនូវអង្គជាគ្រឿងលះនៃបឋមជ្ឈាន ដោយបាឋៈមានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ ដើម្បីសំដែងអង្គជាគ្រឿងប្រកប ទើបទ្រង់ត្រាស់ពាក្យនេះ ថា “ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ” ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ សេចក្តីត្រិះរិះ ឈ្មោះថា វិតក្កៈ មានពាក្យអធិប្បាយថាៈ កន្ទុះរា ក្នុងអារម្មណ៍ ។ វិតក្កៈនេះនោះ មានការបន្ទោបង់នូវចិត្ត ក្នុងអារម្មណ៍ជាលក្ខណៈ, មានការដឹកនាំ និង ការទាញមកនូវចិត្តជាកិច្ច ។ ពិតដូច្នោះមែន ដោយអង្គគឺវិតក្កៈនោះ ព្រះយោគាវចរលោកហៅថាៈ ធ្វើនូវអារម្មណ៍ឲ្យជាអារម្មណ៍ គឺ វិតក្កៈនាំមកហើយឲ្យជាអារម្មណ៍ គឺវិតក្កៈ ទាញមកហើយ” ដូច្នេះ ។ វិតក្កៈ មានការនាំមកនូវចិត្ត ក្នុងអារម្មណ៍ ជាផល ។

ការត្រាច់ទៅ ឈ្មោះថា វិចារៈ, មានពាក្យអធិប្បាយថាៈ ការត្រាច់ទៅតាមរឿយៗ។ វិចារៈនេះនោះ មានការតាមស្ទាបអង្អែលនូវអារម្មណ៍ជាលក្ខណៈ, មានការតាមប្រកបនូវសហជាតធម៌ ក្នុងអារម្មណ៍នោះ ជា



កិច្ច, មានការតាមចងនូវចិត្តឲ្យជាប់ ជាផល ។

ក៏កាលបើវិតក្កៈ និង វិចារៈទាំងពីរនោះ សូម្បីមានការប្រាសចាកគ្នាមិនបាន ក្នុងទីណាៗ ក៏ដោយ, វិតក្កៈ ឈ្មោះថា ការដាក់ចិត្តចុះ ជាដំបូង ដូចសំឡេងគោះរគាំង ព្រោះសេចក្តីថា គ្រោតគ្រាត និង ព្រោះសេចក្តីថា មានចិត្តដល់មុន ។ វិចារៈ ឈ្មោះថា ការតាមចងរឹត ដូចជាសូរលាន់នៃរគាំង ព្រោះអត្ថថា ល្អិត និង ព្រោះជាសភាពតាមបបោសអង្អែល ។ ក៏បណ្តាវិតក្កៈ និង វិចារៈទាំង២ នោះ វិតក្កៈ មានការរេ្ជចា នៃចិត្ត ក្នុងកាលកើតឡើងជាលើកដំបូង ព្រោះកិរិយាផ្សាយទៅ នៃចិត្ត ដូចការទទះស្លាបនៃសត្វស្លាប ដែលប្រាថ្នាចង់ហើរឡើងទៅលើអាកាស និង ដូចជាកិរិយាបែរមុខឆ្ពោះទៅរកផ្កាឈូក នៃភមរជាតិ ដែលមានចិត្តក្ជួបជាប់ ក្នុងគ្រឿងក្រអូប យ៉ាងនោះឯង, វិចារៈ មានការប្រព្រឹត្តិស្ងប់ មានភាវៈនៃចិត្តមិនរេ្ជចា ក្រៃពេក ដូចជាការសំកាំងស្លាប នៃសត្វបក្សី ដែលហើរឡើងទៅលើអាកាស និង ដូចជាការហើរធ្មៀលធ្វាត់ នៅខាងលើនៃផ្កាឈូក នៃភមរជាតិ ដែលចុះមកត្រឹបផ្កាឈូក យ៉ាងដូច្នោះឯង។

ចំណែកក្នុងអដ្ឋកថាទុកនិបាត ព្រះអដ្ឋកថាចារ្យ ពោលថា “វិតក្កៈ ដែលប្រព្រឹត្តទៅ ដោយភាវៈនៃការបង្អោនចិត្តចូលទៅក្នុងអារម្មណ៍ ដូចជាកិរិយានៃសត្វស្លាបដ៏ធំ ដែលហើរទៅឰដ៏អាកាស ញុំាងខ្យល់ឲ្យជក់ដោយស្លាបទាំងពីរ សំឡបស្លាបទាំងឡាយហើយ ទើប (ហើរ) ទៅ ក៏យ៉ាងនោះឯង ។ វិចារៈ ដែលប្រព្រឹត្តទៅហើយ ដោយភាវៈ គឺការតាមបបោសអង្អែល ដូចជាកិរិយានៃសត្វស្លាបទទះនូវស្លាបទាំងឡាយ ដើម្បីក្ជួបយកខ្យល់ (ហើរ) ទៅ យ៉ាងនោះឯង ។

ពាក្យក្នុងអដ្ឋកថាទុកនិបាតនោះ ប្រើការបាន តែក្នុងកិរិយាប្រព្រឹត្តិ

ទៅដោយការពាក់ព័ន្ធគ្នាទេ។ ចំណែកសេចក្តីផ្សេងគ្នានៃវិតក្កៈ និងវិចារៈនោះ ជាសេចក្តីប្រាកដហើយក្នុងបឋមជ្ឈាន និងទុតិយជ្ឈានទាំងឡាយ។

មួយវិញទៀត វិតក្កៈ ដូចជាដៃដែលចាប់មាំ វិចារៈ ដូចជាដៃដែលខាត់ នៃបុគ្គលអ្នកចាប់នូវភាជនៈសំរឹត ដែលច្រែះចាប់ហើយ យ៉ាងជាប់ដោយដៃម្ខាង ហើយយកប្រាសកន្ទុយសត្វ ជ្រលក់ប្រេង លាយដោយដីឡេង ដោយដៃម្ខាងទៀត ដូច្នោះឯង ។

ន័យដូចគ្នានោះដែរ វិតក្កៈ ដូចជាដៃដែលជំ, វិចារៈ ដូចជាដៃដែលប្រមុំប្រមូលតុបតែង ខាងនេះផង ខាងនោះផង នៃស្មូនឆ្នាំង ដែលបង្វិលកង់ហើយ ធ្វើភាជនៈ ដោយឈើសំរាប់ជំដូច្នោះ ។

មួយទៀត វិតក្កៈ មានការបង្អោនទៅនូវអារម្មណ៍ ដូចជាដែកស្រួចដែលបុគ្គលដោត ចំកណ្តាលហើយឋិតនៅ, វិចារៈ មានការតាមបបោសអង្អែលនូវអារម្មណ៍ ដូចជាដែកស្រួចដែលបង្វិល ព្ធដ៏ខាងក្រៅ នៃជាងដែលធ្វើនូវវង់មូល ដូច្នោះឯង ។

ឈាននេះ លោកហៅថា “ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ” ព្រោះប្រព្រឹត្តទៅមួយអន្លើដោយវិតក្កៈនេះ និងវិចារៈនេះ ដូចបានពោលមកហើយ ប្រៀបដូចជាដើមឈើ ដែលប្រព្រឹត្តទៅជាមួយផ្កា និង ផ្លែយ៉ាងនោះឯង។ ចំណែកក្នុងគម្ពីរវិភង្គ លោកធ្វើទេសនាជាបុគ្គលាធិដ្ឋានដោយន័យថា “ព្រះយោគី ជាអ្នកចូលដល់ហើយ ជាអ្នកចូលទៅដល់ព្រមហើយ ដោយវិតក្កៈនេះផង ដោយវិចារៈនេះផង” ដូច្នេះជាដើម ។ ចំណែកសេចក្តីអធិប្បាយ សូម្បីក្នុងគម្ពីរវិភង្គបាឋៈនោះ បណ្ឌិត ក៏គប្បីឃើញ យ៉ាងដូច្នេះដែរ ។

(៩៣) បណ្ឌិត គប្បីជ្រាបសេចក្តី ក្នុងបទនេះថា “វិវេកជំ” ដូច្នេះ ។



សេចក្តីស្ងាត់ ឈ្មោះថា វិវេក, អធិប្បាយថាៈ ប្រាសចាកនីវរណធម៌, ន័យមួយទៀត ធម្មជាត ឯណា ស្ងាត់ហើយ ហេតុនោះ ធម្មជាតនោះឈ្មោះថា វិវេក គឺធម៌ដែលស្ងាត់ហើយចាកនីវរណៈ, អធិប្បាយថា កងធម៌ដែលប្រកបព្រមហើយ ដោយឈាន ។ បីតិ និង សុខៈ ឈ្មោះថា វិវេកជៈ ព្រោះកើតហើយអំពីវិវេកនោះ ឬ កើតហើយ ក្នុងវិវេកនោះ ។

បណ្ឌិតគប្បីជ្រាបសេចក្តី ក្នុងបទថា “បីតិសុខំ” នេះ ដូចតទៅ ។ ធម្មជាតិណា ញុំាងកាយ និង ចិត្ត ឲ្យឆ្អែត ហេតុនោះ ធម្មជាតិនោះឈ្មោះថា បីតិ ។ បីតិ នោះ មានកិរិយាប្រព្រឹត្តិស្រឡាញ់ជាលក្ខណៈ, មានការញុំាងកាយ និង ចិត្ត ឲ្យឆ្អែត ជាកិច្ច ឬថា មានការផ្សាយទៅជាកិច្ច, មានការរីករាយជាផល ។ ក៏បីតិ នេះនោះ មាន ៥ យ៉ាង គឺៈ ខុទ្ទកាបីតិ ១, ខណិកាបីតិ ១, ឱក្កន្តិកាបីតិ ១, ឧព្វេង្គាបីតិ ១, ផរណាបីតិ ១ ។ បណ្តាបីតិ ទាំង ៥ យ៉ាងនោះ ខុទ្ទកាបីតិ អាចដើម្បីធ្វើនូវហេតុត្រឹមតែព្រឺរោម ក្នុងរាងកាយប៉ុណ្ណោះ ។ ខណិកាបីតិ រមែងកើតមាន ក្នុងខណៈៗ ដូចជាការកើតឡើងនៃផ្លេកបន្ទោរ ។ ឱក្កន្តិកាបីតិ ខ្ទាំងខ្ទប់ យាងចុះដល់កាយហើយទើបរលាយទៅៗ ដូចជារលកខ្ទាំងខ្ទប់នូវច្រាំងសមុទ្រហើយ ក៏រលាយបាត់ទៅដូច្នោះ ។ ឧព្វេង្គាបីតិ ជាបីតិមានកម្លាំង ដល់នូវការធ្វើកាយ ឲ្យអណ្តែតឡើងហើយ ឲ្យកាយលោតឡើង (ហោះ) ទៅលើអាកាសបាន ។

ពិតដូច្នោះមែន ព្រះមហាតិស្សត្ថេរអ្នកមានកិរិយានៅក្នុងវត្តឈ្មោះបុណ្ណវល្លិកៈជាប្រក្រតី និមន្តទៅព្រះលានចេតិយ ក្នុងពេលល្ងាច ក្នុងថ្ងៃពេញបូណ៌មី ឃើញពន្លឺនៃព្រះច័ន្ទ ជាអ្នកមានមុខឆ្ពោះទៅកាន់មហា-ចេតិយ នឹកគិតថា “ឱហ្ន៎ ក្នុងវេលានេះ បរិស័ទទាំងបួន កំពុងថ្វាយបង្គំ

មហាចេតិយ” ញុំាងឧព្វេង្គាបីតិ មានព្រះពុទ្ធជាអារម្មណ៍ ឲ្យកើតឡើង ដោយអំណាចនៃអារម្មណ៍ ដែលខ្លួនឃើញហើយ តាមប្រក្រតី អណ្តែតឡើងទៅលើអាកាសហើយ ក៏ឋិតនៅចំពោះទីព្រះលាន នៃមហាចេតិយតែម្តង ដូចជាសីស្បែកដ៏វិចិត្រដែលគេកាត់ហើយ បោះលើផ្ទៃនៃថ្មកំបោរ ហើយលោតឡើងទៅ លើអាកាស ដូច្នោះឯង ។ សូម្បីកុលធីតាម្នាក់ ក្នុងវត្តកាលគ្រាម ដែលជាទីចូលទៅអាស្រ័យ នៃវត្តឈ្មោះគិរិគណ្ឌកៈ អណ្តែតឡើងទៅលើអាកាសហើយ ដោយឧព្វេង្គាបីតិ ដែលមានព្រះពុទ្ធជាអារម្មណ៍ដ៏មានកម្លាំង ក៏យ៉ាងនោះដែរ ។

បានឮមកថា មាតាបិតារបស់នាងកុលធីតានោះ កាលទៅវត្តដើម្បីស្តាប់ធម៌ក្នុងពេលល្ងាច ប្រាប់ថា “ម្នាលកូនស្រី នាងមានភារៈដ៏ធ្ងន់មិនអាចទៅ ក្នុងកាលមិនគួរបានទេ, យើងនឹងស្តាប់ធម៌ ឲ្យចំណែកបុណ្យដល់នាង” ដូច្នេះហើយ ទើបបានទៅ ។ នាងកុលធីតានោះ សូម្បីប្រាថ្នាចង់ទៅ តែក៏មិនអាចបំពានពាក្យ របស់មាតាបិតានោះបានឡើយ ក៏ក្រាញនៅក្នុងផ្ទះ កាលឈរនៅលើរានហាលនៃផ្ទះចាស់ហើយ ក្រឡេកមើលព្រះលានចេតិយ តាមអាកាស ក្នុងវត្តឈ្មោះគិរិគណ្ឌកៈ ដោយពន្លឺនៃព្រះច័ន្ទ បានឃើញនូវការបូជាព្រះចេតិយ ដោយប្រទីបបានឃើញបរិស័ទបួន កំពុងធ្វើការបូជាព្រះចេតិយ ដោយសក្ការៈទាំងឡាយមានផ្កាកម្រង និង គ្រឿងក្រអូបជាដើមហើយ ធ្វើប្រទក្សិណ និង បានស្តាប់ឮសំឡេងស្វាធ្យាយជាពួករបស់ភិក្ខុសង្ឃផង។ គ្រានោះ កាលដែលនាងកំពុងតែមើលព្រះចេតិយ ដែលដូចជាគំនរនៃកែវមុក្តា ដោយនឹកគិត ថា “ពួកជនទាំងឡាយនេះ ជាអ្នកមានបុណ្យតើហ្ន៎! ដែលបានទៅវត្តហើយដើរត្រាច់ទៅមកលើលានព្រះចេតិយបែបនេះ និង បានស្តាប់នូវធម្មកថា



ដ៏ពិរោះ មានសភាពបែបនេះ” ដូច្នេះ ឧព្វេង្គាបីតិ ក៏កើតឡើងហើយ ។ នាងកុលធីតានោះ បានលោតឡើងលើអាកាសហើយ ចុះលើទីលានព្រះចេតិយអាកាសមុន ដោយវិសេសជាងមាតាបិតាទៅទៀត ថ្វាយបង្គំព្រះចេតិយហើយ ក៏បានឈរស្តាប់ធម៌ ។ គ្រានោះ មាតាបិតា បានមកសួរនាងថា “នែកូនស្រីឯង មកតាមផ្លូវណា?” ។ នាងបានឆ្លើយថា “នាងខ្ញុំមក តាមអាកាស មិនមែនមកតាមផ្លូវទេ” ដូច្នេះហើយ ត្រូវមាតាបិតាសួរបញ្ជាក់ថា “ម្នាលកូនស្រី! ធម្មតាតាមផ្លូវអាកាស ព្រះខីណាស្រពទាំងឡាយ តែងត្រាច់ទៅ, នាងឯងមក (តាមផ្លូវអាកាស)បាន យ៉ាងដូចម្តេចទៅ?”ដូច្នេះ ទើបប្រាប់ថា “កាលដែលនាងខ្ញុំឈរក្រឡេកមើលព្រះចេតិយដោយពន្លឺព្រះច័ន្ទ បីតិដ៏មានកម្លាំង ដែលមានព្រះពុទ្ធជាអារម្មណ៍កើតឡើងហើយ, គ្រានោះឯង នាងខ្ញុំ ក៏មិនបាន ដឹងនូវភាវៈនៃខ្លួនឈរមិនបានដឹងនូវភាវៈនៃខ្លួនអង្គុយសោះឡើយ ក៏ស្រាប់តែអណ្តែតទៅលើអាកាស ដោយនិមិត្តដែលចិត្តបានកំណត់យកហើយនុ៎ះឯង ហើយក៏មកប្រតិស្ឋាន នៅត្រង់លាននៃព្រះចេតិយតែម្តង” ដូច្នេះ ។

ឧព្វេង្គាបីតិ ជាបីតិ មានកិរិយាអណ្តែតឡើងទៅ លើអាកាស ជាប្រមាណ យ៉ាងដូច្នេះឯង ។

ក៏កាលបើផរណាបីតិ កើតឡើងហើយ, សរីរៈទាំងមូលជាសរីរៈគឺបីតិនោះ គ្របសង្កត់ស្រោចស្រប់ហើយ ឧបមាដូចជាក្រពះបស្សាវៈដែលទឹកបស្សាវៈ ហូរពេញហើយ ពុំនោះសោត ឧបមាដូចជាជ្រោះភ្នំត្រូវទឹកជំនន់ដ៏ធំ ស្រោចស្រប់ហើយ យ៉ាងដូច្នោះឯង ។

ចំណែកបីតិទាំង ៥ នោះឯង កាលកាន់យកនូវផ្ទៃ ដល់នូវការចាស់ពេញបន្ទុក រមែងញុំាងបស្សទ្ធិទាំង ២ យ៉ាង គឺ កាយបស្សទ្ធិ ១,

ចិត្តបស្សទ្ធិ ១ ឲ្យពេញបរិបូរ ។ បស្សទ្ធិ កាលកាន់យកនូវផ្ទៃ ដល់នូវការចាស់ពេញបន្ទុក រមែងញុំាងសេចក្ដីសុខទាំង២ យ៉ាងគឺ កាយិកសុខ ១, ចេតសិកសុខ ១ ឲ្យពេញបរិបូរ ។ សេចក្ដីសុខកាលកាន់យកផ្ទៃ ដល់នូវការចាស់ពេញបន្ទុក រមែងញុំាងសមាធិបីយ៉ាងគឺ ខណិកសមាធិ ១, ឧបចារសមាធិ ១, អប្បនាសមាធិ ១ ឲ្យពេញបរិបូរ ។

បណ្ដាបីតិទាំង ៥ នោះ ផរណាបីតិណា ដែលចំរើនឡើង ជាឫសគល់នៃអប្បនាសមាធិ ដល់នូវការប្រកបដោយសមាធិ, ផរណាបីតិនេះជាបីតិ គឺលោកបំណងយកហើយ ក្នុងសេចក្ដីនេះ ។

ចំណែកបទក្រៅអំពីនេះ (មានអធិប្បាយដូចតទៅនេះ) ។ សេចក្ដីសប្បាយ ឈ្មោះថា សុខ ។ ន័យមួយទៀត ធម្មជាតណា កាត់ គឺជីក គឺកំចាត់ នូវអាពាធដែលប្រព្រឹត្តទៅ ក្នុងកាយ និង ចិត្ត ដោយប្រពៃ ហេតុនោះ ធម្មជាតនោះ ឈ្មោះថា សេចក្ដីសុខ ។ សេចក្ដីសុខនោះ មានការត្រេជាក់ជាលក្ខណៈ, មានការចូលទៅចំរើននូវធម៌ទាំងឡាយ ដែលប្រកបព្រម ដោយសេចក្ដីសុខនោះ ជាកិច្ច, មានការជួយអនុគ្រោះជាផល ។

ក៏សូម្បីកាលបើការមិនប្រាសចាកអំពីគ្នា ក្នុងទីណាៗ នៃបីតិ និង សុខៈនោះមានពិតមែន, បណ្ឌិតគប្បីជ្រាបថាសេចក្ដីត្រេកអរ ព្រោះបាននូវអារម្មណ៍ដែលជាទីប្រាថ្នា ឈ្មោះថា បីតិ, ការសោយនូវរសនៃឥដ្ឋារម្មណ៍ដែលខ្លួនបានហើយ ឈ្មោះថា សុខ ។ បីតិ មានក្នុងទីណា, សុខ រមែងមាន ក្នុងទីនោះ ។ សុខ មានក្នុងទីណា, បីតិ នឹងមាន ក្នុងទីនោះ ដោយមិនបានកំណត់ ។ បីតិ គឺលោកសង្គ្រោះហើយ ក្នុងសង្ខារក្ខន្ធ, សុខ គឺលោកសង្គ្រោះហើយ ដោយវេទនាខន្ធ ។ បីតិ ប្រៀបបីដូចជា



សេចក្ដីត្រេកអរក្នុងការបានឃើញនូវជាយព្រៃ និង ការបានឮដំណឹងថាមានជ្រលងទឹកទាំងឡាយ, សុខ ប្រៀបដូចជាសេចក្ដីសប្បាយរីករាយក្នុងការបានចូលទៅជ្រក ក្នុងម្លប់ព្រៃឈើ និង ការបានបរិភោគ នូវទឹកទាំងឡាយនៃជនអ្នកនឿយហត់ក្នុងផ្លូវឆ្ងាយ ។ ក៏ពាក្យនេះ បណ្ឌិត គប្បីជ្រាបថា : លោក ពោលហើយ ព្រោះបីតិ និង សុខ មានប្រាកដ ក្នុងសម័យនោះ ៗ ។

បីតិនេះផង សុខៈនេះផង ដូចបានរៀបរាប់មកនេះ មានដល់ឈាននោះ ឬថា មានក្នុងឈាននោះ ព្រោះហេតុនោះ ឈាននេះ ទើបលោកហៅថា "មានបីតិ និង សុខ"។ មួយទៀត បីតិផង សុខៈផង ហៅថាបីតិ និង សុខ ដូចជាពាក្យសមាសថា ធម្មវិន័យ ជាដើម ។ បីតិ និង សុខ ដែលកើតអំពីវិវេក មានដល់ឈាននោះ ឬថា មានក្នុងឈាននោះ ហេតុនោះ ឈាននេះ លោកហៅថា មានបីតិ និង សុខ ដែលកើតអំពីវិវេក ដូច្នេះក៏បាន ។ មែនពិត ឈានកើតអំពីវិវេក យ៉ាងណាមិញ, សូម្បីបីតិ និង សុខ ក្នុងឈាននោះ ក៏កើតអំពីវិវេក យ៉ាងនោះដែរ ។ ឯបីតិ និង សុខ ដែលកើតអំពីវិវេកនោះ មានដល់ឈាននោះ ហេតុនោះ ការពោលថា "បីតិ និង សុខ ដែលកើតអំពីវិវេក" រមែងគួរ ដោយបទតែមួយនុ៎ះឯង ។ ចំណែកក្នុងវិភង្គ ព្រះមានព្រះភាគត្រាស់ហើយ ដោយន័យជាអាទិ៍ថា "សុខនេះ ប្រកបដោយបីតិនេះ" ដូច្នេះ។ ប៉ុន្តែសេចក្ដីអធិប្បាយក្នុងវិភង្គនោះ បណ្ឌិតគប្បីឃើញថា យ៉ាងដូច្នេះដែរ ។

ពាក្យថា "ឈានទីមួយ" នេះ នឹងមានប្រាកដខាងមុខ ។ បទថា "ឧបសម្បជ្ជ" ប្រែថា ចូលទៅដល់ហើយ អធិប្បាយថា ដល់ហើយ ឬ ប្រែថា ឲ្យចូលទៅដល់ហើយ, អធិប្បាយថា ឲ្យសំរេចហើយ ។ តែក្នុង

វិភង្គ លោកពោលថា បទថា “ឧបសម្បជ្ជ” គឺការបាន, ការបានចំពោះ, ការដល់, ការដល់ព្រម, ការពាល់ត្រូវ, ការពាល់ត្រូវព្រម, កិរិយាធ្វើឲ្យជាក់ច្បាស់, ការចូលទៅសំរេចនូវឈានទី១ ។ បណ្ឌិត គប្បីឃើញសេចក្ដីអធិប្បាយ សូម្បីនៃវិភង្គបាឋៈនោះដូចនេះដែរ។ បទថា “វិហរតិ” សេចក្ដីថា ព្រះយោគី ជាអ្នកបានឈាន មានប្រការៈដូចបានពោលមកហើយ យ៉ាងនេះ ញុំាងកិរិយាប្រព្រឹត្តិទៅ ញុំាងការប្រព្រឹត្តិ ញុំាងការរក្សា ញុំាងការទៅ ញុំាងការធ្វើដំណើរទៅ ញុំាងការត្រាច់ទៅ ញុំាងការនៅនៃអត្តភាព ឲ្យប្រព្រឹត្តទៅ ដោយធម៌ជាគ្រឿងនៅ ក្នុងឥរិយាបថដ៏សមគួរដល់ឈាននោះ ។ ដូចជាពាក្យដែលលោកពោលហើយ ក្នុងវិភង្គថា: បទថា “វិហរតិ” សេចក្ដីថា រមែងប្រព្រឹត្តទៅ គឺប្រព្រឹត្ត រក្សាទៅ ធ្វើដំណើរទៅ ត្រាច់ទៅ នៅ ព្រោះហេតុនោះ ទើបលោកពោលថា វិហរតិ ។

(៩៤) ចំណែកឯពាក្យណា ដែលខ្ញុំបានពោលហើយថា “បឋមជ្ឈានមានអង្គ៥ លះហើយ ប្រកបព្រមហើយដោយអង្គ ៥” ដូច្នេះ, ក្នុងពាក្យនោះ បណ្ឌិតគប្បីជ្រាបភាវៈនៃបឋមជ្ឈាន លះអង្គ ៥ ដោយអំណាចនៃការលះបង់នូវនីវរណៈទាំង ៥ នេះ គឺ កាមច្ឆន្ទៈ, ព្យាបាទៈ, ថីនមិទ្ធៈ, ឧទ្ធច្ចកុក្កុច្ចៈ, វិចិកិច្ឆា ។ ក៏កាលបើនីវរណៈទាំងឡាយនោះ គឺព្រះយោគីមិនទាន់លះបង់ហើយ ឈាន ក៏កើតឡើងពុំបានឡើយ, ព្រោះហេតុនោះនីវរណៈទាំងនោះ ទើបលោកពោលថា“អង្គជាគ្រឿងលះ” នៃបឋមជ្ឈាននោះ ។ ក៏ធម៌ទាំងឡាយជាអកុសល សូម្បីដទៃទៀត គឺព្រះយោគីតែងលះបង់ ក្នុងខណៈនៃឈាន ក៏ពិតមែនហើយ បើទុកជាដូច្នោះ នីវរណៈទាំង ៥ នេះឯង ជាគ្រឿងធ្វើសេចក្ដីអន្តរាយដល់ឈានដោយវិសេស ។



មែនពិត ចិត្ត ដែលត្រូវកាមច្ឆន្ទៈ លួងលោមហើយ ក្នុងអារម្មណ៍ផ្សេងៗ រមែងមិនតម្កល់នៅមាំ ក្នុងភាពនៃចិត្តមានអារម្មណ៍តែមួយបានឡើយ ។ ន័យមួយទៀត ចិត្ត នោះ គឺកាមច្ឆន្ទៈគ្របសង្កត់ហើយ តែងមិនដើរទៅកាន់ផ្លូវ ដើម្បីលះបង់នូវកាមធាតុ ។ មួយទៀត ចិត្តនោះ កាលត្រូវព្យាបាទៈប៉ះទង្គិច ក្នុងអារម្មណ៍ រមែងប្រព្រឹត្តទៅ អស់កាលជានិច្ចនិរន្តរ៍ពុំបានឡើយ ។ ចិត្ត ដែលត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ ជាចិត្តមិនគួរដល់ការងារឡើយ ។ ចិត្តដែលមានឧទ្ធច្ចកុក្កុច្ចៈជាត្រីមុខ ជាចិត្តមិនស្ងប់រម្ងាប់ឡើយ រមែងវិលវល់។ ចិត្តដែលវិចិកិច្ឆាចូលទៅបៀតបៀនហើយ រមែងមិនឡើងទៅកាន់ផ្លូវ ដែលញុំាងការបានឈាន ឲ្យសំរេចឡើយ ។ នីវរណៈទាំង៥ នេះឯង លោកពោលថា “អង្គដែលត្រូវលះបង់” ព្រោះនីវរណៈទាំង ៥ នោះ ជាហេតុធ្វើឲ្យអន្តរាយដល់ឈាន ដោយវិសេសដូចពោលមកនេះ ។

ក៏វិតក្កៈ ញុំាងចិត្តឲ្យឱនទៅ ក្នុងអារម្មណ៍, វិចារៈ រមែងចងក្រៀកទុក, បីតិ ដែលកើតព្រមដោយបយោគសម្បត្តិ ធ្វើនូវសេចក្ដីឆ្អែត និងសុខ ធ្វើនូវការចូលទៅចំរើន ដល់ចិត្តដែលមានបយោគ គឺវិតក្កៈ និងវិចារៈទាំងនោះ ឲ្យសំរេចហើយ ដោយការមិនរាយមាយ, គ្រានោះ ភាពនៃចិត្តមានអារម្មណ៍តែមួយ គឺការបង្អោនចិត្ត ការចងក្រៀកទុក ការឆ្អែត និង ការចូលទៅចំរើនទាំងឡាយនោះ អនុគ្រោះហើយ រមែងក្ដួចកាន់ នូវចិត្តនោះ ដែលប្រព្រឹត្តទៅមួយអន្លើដោយសម្បយុត្តធម៌ដ៏សេស ដោយស្មើ និង ដោយប្រពៃ ក្នុងឯកត្តារម្មណ៍ ហេតុណា, ហេតុនោះ ភាវៈនៃបឋមជ្ឈាន ប្រកបដោយអង្គ ៥ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃការកើតឡើងនៃអង្គទាំងឡាយ ៥ នេះ គឺ: វិតក្កៈ, វិចារៈ, បីតិ, សុខៈ,

ចិត្តេកគ្គតា ។ ព្រោះថាកាលបើអង្គទាំង៥ នេះ កើតឡើងហើយ ឈាន ជាធម្មជាត ឈ្មោះថា កើតឡើងហើយ ។ ព្រោះហេតុនោះ អង្គទាំង ៥ នោះ ទើបហៅថា អង្គប្រកបព្រមហើយ នៃបឋមជ្ឈាននោះ ។ ព្រោះហេតុនោះ ឈ្មោះថាឈាន ដទៃទៀត ដែលប្រកបព្រមដោយអង្គទាំង ៥ នេះ បណ្ឌិត មិនគួរប្រកាន់ថា មានដូច្នេះទេ ។ ដូចជាសេនា គឺលោកពោលថា ប្រកបដោយអង្គ ៤, តូរ្យតន្ត្រី គឺលោកពោលថាប្រកបដោយអង្គ ៥, មគ្គ គឺលោកពោលថា ប្រកបដោយអង្គ ៨ ដោយអំណាចនៃហេតុត្រឹមតែអង្គប៉ុណ្ណោះឯង យ៉ាងណា, សូម្បីបឋមជ្ឈាននេះ ក៏បណ្ឌិតគប្បីជ្រាបថា "លោកពោលថា មានអង្គ ៥ ឬថា ប្រកបដោយអង្គ ៥ ដោយអំណាចហេតុត្រឹមតែអង្គប៉ុណ្ណោះឯង ក៏យ៉ាងនោះដែរ ។ អង្គទាំង ៥ នេះ មានសូម្បីក្នុងខណៈនៃឧបចារៈ ក៏ពិតមែនហើយ បើទុកជាដូច្នោះ ក្នុងឧបចារៈ អង្គទាំង ៥ នោះ ជាអង្គដែលមានកម្លាំងខ្លាំងជាងចិត្តជាប្រក្រតី ។ ចំណែកក្នុងបឋមជ្ឈាននេះ អង្គទាំង៥ នោះ ដល់នូវលក្ខណៈនៃរូបាវចរៈ ជាអង្គដែលមានកម្លាំងខ្លាំងជាងឧបចារៈទៅទៀត ។ មែនពិត បណ្តាអង្គទាំង ៥ នោះ វិតក្កៈ កាលបង្អោនចិត្តទៅ ក្នុងអារម្មណ៍ ដោយអាការៈ ដ៏ក្បៀវក្លាពេញទី ទើបកើតឡើង ។ វិចារៈ កាលតាមបបោសអង្អែលនូវអារម្មណ៍ យ៉ាងក្រៃលែង ទើបកើតឡើង ។ បីតិ និង សុខ ផ្សព្វផ្សាយទៅកាន់កាយទូទៅទាំងអស់ ទើបកើតឡើង ។ ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា "អវយវៈត្រង់ណាមួយនៃរាងកាយទាំងពួង របស់ព្រះយោគីអ្នកបានបឋមជ្ឈាននោះ គឺបីតិ និងសុខៈដែលកើតពីវិវេក មិនប៉ះពាល់ហើយមិនមានឡើយ" ។ សូម្បីភាវៈនៃចិត្តមានអារម្មណ៍តែ ១ ជាធម្មជាតពាល់ត្រូវ ក្នុងអារម្មណ៍ទាំងឡាយ



កើតឡើង ដូចជាផ្ទៃស្នុកជាន់ខាងលើ ពាល់ត្រូវផ្ទៃស្នុកជាន់ខាងក្រោម ដូច្នោះ ។ នេះជាសេចក្តីវិសេស ជាងកាមាវចរចិត្តទាំងឡាយក្រៅពីនេះ នៃអង្គទាំងឡាយ ៥ នោះ ។

បណ្តាអង្គទាំងឡាយ៥ នោះ ភាពនៃចិត្តមានអារម្មណ៍តែមួយ ព្រះមានព្រះភាគ មិនបានសំដែងចេញហើយ ក្នុងបាលីនេះថា "ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ" ដូច្នេះ ក៏ពិតមែនហើយ បើទុកជាដូច្នោះ ក៏ដោយ ចិត្តេកគ្គតានោះ ក៏ឈ្មោះថា ជាអង្គ ដោយពិត ព្រោះព្រះអង្គត្រាស់ក្នុងវិភង្គ យ៉ាងនេះថាៈ ពាក្យថា "ឈាន គឺៈ វិតក្កៈ, វិចារៈ, បីតិ, សុខៈ, ចិត្តេកគ្គតា" ដូច្នេះ ។ មែនពិត ឧទ្ទេស ព្រះមានព្រះភាគទ្រង់ធ្វើហើយ ដោយសេចក្តីអធិប្បាយណា, សេចក្តីអធិប្បាយនោះឯង ជាសេចក្តីអធិប្បាយ គឺព្រះអង្គទ្រង់បានប្រកាសហើយ ក្នុងវិភង្គនោះ ។

(៩៥) ចំណែកសេចក្តីវិនិច្ឆ័យ ក្នុង ២ បទនេះថា "បឋមជ្ឈានមានលំអ ៣ យ៉ាង ដល់ព្រមដោយលក្ខណៈ ១០" មានដូចតទៅនេះ : បណ្ឌិតគប្បីជ្រាបភាវៈនៃបឋមជ្ឈានមានលំអ ៣ ប្រការ ដោយអំណាចនៃលំអខាងដើម, កណ្តាល និង ខាងចុង, មួយទៀត ភាវៈនៃបឋមជ្ឈាននោះ ដល់ព្រមដោយលក្ខណៈ ១០ ក៏បណ្ឌិត គប្បីជ្រាប ដោយអំណាចលក្ខណៈនៃលំអបទដើម, កណ្តាល និង បទខាងចុងទាំងឡាយនុ៎ះឯង ។ បាលីក្នុងមាតិកានោះ មានដូចតទៅនេះ :

"បដិបទាវិសុទ្ធិ ជាលំអបទខាងដើម នៃបឋមជ្ឈាន, ការរីកចំរើនរឿយៗ នៃឧបេក្ខា ជាលំអបទកណ្តាលនៃបឋមជ្ឈាន, សេចក្តីរីករាយ ជាលំអបទខាងចុង នៃបឋមជ្ឈាន ។

(សួរថា) បដិបទាវិសុទ្ធិ ជាលំអបទខាងដើម នៃបឋមជ្ឈាន,

លក្ខណៈទាំងឡាយ នៃលំអបទខាងដើម មានប៉ុន្មានយ៉ាង? ។

(ឆ្លើយថា) លក្ខណៈទាំងឡាយ នៃលំអបទខាងដើម មាន ៣ គឺៈ សេចក្តីអន្តរាយណានៃបឋមជ្ឈាននោះ, ចិត្ត បរិសុទ្ធចាកសេចក្តីអន្តរាយនោះ ១, ចិត្តដើរទៅកាន់សមថនិមិត្ត ដែលជាផ្លូវកណ្តាល ព្រោះភាវៈនៃចិត្តបរិសុទ្ធហើយ ១, ចិត្ត ស្ទុះទៅ ក្នុងសមថនិមិត្តនោះ ព្រោះភាវៈនៃចិត្តដើរទៅហើយ ១, ការដែលចិត្តបរិសុទ្ធចាកសេចក្តីអន្តរាយក្តី, ការដែលចិត្តដើរទៅកាន់សមថនិមិត្ត ដែលជាផ្លូវកណ្តាល ព្រោះបរិសុទ្ធហើយក្តី, ការដែលចិត្តស្ទុះទៅ ក្នុងសមថនិមិត្តនោះ ព្រោះចិត្តដើរទៅហើយក្តី, នោះ គឺជាបដិបទាវិសុទ្ធិ ជាលំអបទខាងដើម នៃបឋមជ្ឈាន, នេះ ជាលក្ខណៈ ៣ នៃលំអបទខាងដើម, ព្រោះហេតុនោះ ទើបលោកពោលថាៈ បឋមជ្ឈាន ជាឈានមានលំអបទខាងដើមផង ដល់ព្រមដោយលក្ខណៈ ៣ ផង ដូច្នេះ ។

(សួរថា) ការរីកចំរើននៃឧបេក្ខាជាលំអបទកណ្តាលនៃបឋមជ្ឈាន, លក្ខណៈទាំងឡាយ នៃលំអបទកណ្តាល មានប៉ុន្មានយ៉ាង ? ។

(ឆ្លើយថា) លក្ខណៈទាំងឡាយ នៃលំអបទកណ្តាល មាន ៣ គឺ ព្រះយោគី ចូលទៅសំឡឹងមើលនូវចិត្តដែលបរិសុទ្ធហើយ ១, ចូលទៅសំឡឹងមើលនូវចិត្តដែលដើរទៅកាន់សមថៈហើយ ១, ចូលទៅសំឡឹងមើលនូវចិត្តដែលជាទីតាំង នៃអារម្មណ៍តែមួយ ១, ការដែលព្រះយោគីចូលទៅសំឡឹងមើល នូវចិត្តដែលបរិសុទ្ធហើយក្តី, ការដែលព្រះយោគីចូលទៅសំឡឹងមើល នូវចិត្តដែលដើរទៅកាន់សមថៈហើយក្តី, ការដែលព្រះយោគីចូលទៅសំឡឹងមើលនូវចិត្តដែលជាទីតាំង នៃអារម្មណ៍តែមួយក្តី, នោះ ជាកិរិយារីកចំរើននៃឧបេក្ខា ជាលំអបទកណ្តាលនៃបឋមជ្ឈាន,



នេះ ជាលក្ខណៈ ៣ នៃលំអបទកណ្តាល, ព្រោះហេតុនោះ ទើបលោកពោលថា បឋមជ្ឈានមានលំអបទកណ្តាលផង ដល់ព្រមដោយលក្ខណៈ ៣ ផង យ៉ាងដូច្នេះឯង ។

(សួរថា) សេចក្តីរីករាយ ជាលំអបទខាងចុង នៃបឋមជ្ឈាន, លក្ខណៈទាំងឡាយ នៃលំអបទខាងចុង តើមានប៉ុន្មានយ៉ាង? ។

(ឆ្លើយថា) លក្ខណៈទាំងឡាយ នៃលំអបទខាងចុង មាន ៤ គឺ សេចក្តីរីករាយ ដោយសេចក្តីថា មិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតហើយ ក្នុងឈានចិត្តនោះ ១, សេចក្តីរីករាយ ដោយសេចក្តី ថាឥន្ទ្រិយ៍ទាំងឡាយមានរសតែមួយ ១, សេចក្តីរីករាយ ដោយសេចក្តី ថាការបណ្តែតនូវសេចក្តីព្យាយាមដែលចូលទៅដល់ឈាននោះ ១, សេចក្តីរីករាយ ដោយសេចក្តីថា កិរិយាសេពដោយច្រើន ១, ទាំង ៤ យ៉ាងនេះ ជាសេចក្តីរីករាយ ជាលំអបទខាងចុង នៃបឋមជ្ឈាន, នេះ គឺជាលក្ខណៈ ៤ នៃលំអបទខាងចុង, ព្រោះហេតុនោះ ទើបលោកពោលថា “បឋមជ្ឈាន ជាឈានមានលំអបទខាងចុងផង ដល់ព្រមដោយលក្ខណៈ ៤ ផង” ដូច្នេះឯង ។

(៩៦) អាចារ្យមួយក្រុម ពណ៌នា យ៉ាងដូច្នេះថា “ក្នុងធម៌ទាំង ៣ ប្រការនោះ ឧបចារៈ ប្រព្រឹត្តទៅមួយអន្លើដោយសម្ភារៈ ឈ្មោះថា បដិបទាវិសុទ្ធិ, អប្បនា ឈ្មោះថា ការចំរើនដោយឧបេក្ខា, ប្រាជ្ញា ដែលជាគ្រឿងពិចារណាឈ្មោះថា សេចក្តីរីករាយ” ។ ចំណែកក្នុងព្រះបាលី ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ចិត្ត ដែលដល់នូវភាពមានអារម្មណ៍តែមួយ ជាចិត្តស្ទុះទៅកាន់បដិបទាវិសុទ្ធិផង ជាចិត្តគឺឧបេក្ខាឲ្យចំរើនហើយផង ជាចិត្តដែលញាណធ្វើឲ្យរីករាយហើយផង” ដូច្នេះ ព្រោះហេតុណា,

ព្រោះហេតុនោះ បដិបទាវិសុទ្ធិ បណ្ឌិត គប្បីជ្រាប ដោយអំណាចនៃមគ្គជាទីមក នៃពួជ៏ខាងក្នុងអប្បនាទុំះឯង, ការចំរើន ដោយឧបេក្ខា បណ្ឌិតគប្បីជ្រាប ដោយអំណាចកិច្ច នៃតត្រមជ្ឈត្តុបេក្ខា និង សេចក្តីរីករាយ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃកិរិយាសំរេចនូវកិច្ចនៃញាណ ដែលធ្វើឲ្យផូរផង់ ដោយញុំាងភាវៈគឺការមិនប្រព្រឹត្តិកន្លង នូវធម៌ទាំងឡាយជាដើមឲ្យសំរេច។ សួរថា: ពាក្យនេះ មានអធិប្បាយដូចម្តេច?។ ឆ្លើយថា: ក៏អប្បនាកើតឡើង ក្នុងវារៈណា, ក្នុងវារៈនោះ ចិត្ត រមែងបរិសុទ្ធស្អាត ចាកពួកកិលេសពោលគឺនីវរណៈ ដែលជាសេចក្តីអន្តរាយ ដល់ឈាននោះ។ ព្រោះចិត្តបរិសុទ្ធហើយ ចិត្តជាធម្មជាតប្រាសចាកកិលេសជាគ្រឿងរាំង រមែងដើរទៅកាន់សមថនិមិត្ត ដែលជាផ្លូវកណ្តាល ។ អប្បនាសមាធិចិត្ត ដែលប្រព្រឹត្តទៅស្មើទុំះឯង ឈ្មោះថា សមថនិមិត្តជាផ្លូវកណ្តាល ។ ក៏បុរិមចិត្ត ដែលជាអនន្តរបច្ច័យ នៃអប្បនាចិត្តនោះកាលចូលទៅកាន់ភាពនៃចិត្តនឹងធឹង ដោយន័យគឺកិរិយាប្រែប្រួល ចាកសន្តតិ ១ ឈ្មោះថា ដើរទៅកាន់សមថនិមិត្ត ជាផ្លូវកណ្តាល ។ ព្រោះចិត្តនោះដើរទៅហើយ យ៉ាងនេះ ចិត្តទើបឈ្មោះថា ស្ទុះទៅក្នុងសមថៈនោះ ដោយការចូលទៅកាន់ភាពនៃចិត្តនឹងធឹង ។ បណ្ឌិត គប្បីជ្រាបបដិបទាវិសុទ្ធិ ដែលញុំាងអាការៈដែលមានក្នុងបុរិមចិត្តឲ្យសំរេច ដោយអំណាចនៃមគ្គជាទីមក ក្នុងខណៈនៃកិរិយាកើតឡើងនៃបឋមជ្ឈានទុំះឯង ដោយន័យដូចពោលមកនេះ ជាមុនសិន ។

មួយវិញទៀត កាលបើចិត្តនោះ បរិសុទ្ធហើយ យ៉ាងដូច្នេះ ព្រះយោគី កាលមិនធ្វើនូវសេចក្តីខ្វល់ខ្វាយ ក្នុងកិរិយាជម្រះ ព្រោះមិនមានអ្វីដែលត្រូវជម្រះម្តងទៀត ឈ្មោះថា ចូលទៅសំឡឹងមើល នូវចិត្តដែល



បរិសុទ្ធហើយ ។ កាលបើចិត្តដើរទៅកាន់សមថៈហើយ ដោយការចូលទៅកាន់ភាពជាសមថៈ, ព្រះយោគី កាលមិនធ្វើនូវសេចក្តីខ្វល់ខ្វាយ ក្នុងកិរិយាសមាទានម្តងទៀត ឈ្មោះថា ចូលទៅសំឡឹងមើល នូវចិត្តដែលដើរទៅកាន់សមថៈហើយ ។ មួយទៀត កាលដែលចិត្តនោះ លះបង់នូវការជាប់ជំពាក់ ដោយសង្កិលេសហើយ តាំងនៅមាំហើយ ដោយភាពនៃចិត្តមានអារម្មណ៍តែមួយ ព្រោះភាវៈនៃចិត្តដើរទៅហើយកាន់សមថៈហ្នឹងឯង ព្រះយោគី កាលមិនធ្វើសេចក្តីខ្វល់ខ្វាយ ក្នុងការតាំងនៅមាំដោយភាពតែមួយ(នៃចិត្ត) ឈ្មោះថា ចូលទៅសំឡឹងមើលការតាំងនៅមាំ ដោយភាពតែមួយ(នៃចិត្ត) ។ ការចំរើនឡើងនៃឧបេក្ខា បណ្ឌិតគប្បីជ្រាប ដោយអំណាចកិច្ច នៃតត្រមជ្ឈត្តុបេក្ខា ដូចពោលហើយនេះឯង ។

មួយវិញទៀត ធម៌ដែលជាប់គ្នាជាគូទាំងឡាយ បានខាងសមាធិ និង បញ្ញា ដែលកើតហើយ ក្នុងឈានចិត្តនោះ ដែលឧបេក្ខាឲ្យចំរើនហើយយ៉ាងដូច្នេះ នេះឯណា ជាធម៌មិនប្រព្រឹត្តកន្លងនូវគ្នានឹងគ្នា ប្រព្រឹត្តទៅហើយ និង ឥន្ទ្រីយ៍ទាំងឡាយណា មានសទ្ធិន្ទ្រីយ៍ជាដើម ជាឥន្ទ្រីយ៍មានរសតែមួយ ដោយអំណាចវិមុត្តិរស ព្រោះភាវៈនៃឥន្ទ្រីយ៍ទាំងនោះរួចស្រឡះហើយចាកកិលេសទាំងឡាយផ្សេងៗ ប្រព្រឹត្តទៅហើយ, ព្រះយោគីនោះ ញុំាងសេចក្តីព្យាយាមណា ដែលសមគួរដល់ភាវៈនោះ គឺសមគួរដល់ភាវៈ គឺការមិនប្រព្រឹត្តិកន្លងនូវគ្នានឹងគ្នា នៃធម៌ទាំងនោះ និងភាពជាគុណដែលមានរសតែមួយ(នៃឥន្ទ្រីយ៍ទាំងឡាយ) ឲ្យប្រព្រឹត្តទៅ។ ចំណែកការសេពដោយច្រើនណា នៃឈានចិត្តនោះ ប្រព្រឹត្តទៅហើយក្នុងខណៈនោះ, អាការៈទាំងពួងនោះឯង ឈ្មោះថាសំរេចមែនពិត ព្រោះជាអាការៈ គឺព្រះយោគីនោះ ឃើញនូវទោស និង អានិសង្សនោះៗ ក្នុង

*សេចក្តីសៅហ្មង និងសេចក្តីផូរផង់ទាំងឡាយដោយញាណហើយ ញុំាង ចិត្តឲ្យរីករាយ គឺឲ្យបរិសុទ្ធស្អាត ឲ្យផូរផង់ហើយ ដោយអាការៈនោះៗ ហេតុណា, ហេតុនោះ ទើបខ្ញុំពោលថា "សេចក្តីរីករាយ បណ្ឌិតគប្បី ជ្រាប ដោយអំណាចនៃការសំរេចកិច្ចនៃញាណដែលធ្វើឲ្យផូរផង់ ដោយ ការញុំាងភាវៈគឺការមិនប្រព្រឹត្តិកន្លងនូវធម៌ទាំងនោះជាដើមឲ្យសំរេច" ។*

*ញាណជាធម្មជាតប្រាកដ ដោយអំណាចនៃឧបេក្ខា ក្នុងភាវនាចិត្ត នោះ ដូចជាលោកពោលថា "ព្រះយោគី រមែងចូលទៅសំឡឹងមើលនូវ ចិត្តដែលខ្ជួនផ្គងហើយយ៉ាងដូច្នោះ ដោយប្រពៃ, បញ្ញិន្ទ្រីយ៍ ជាឥន្ទ្រីយ៍ មានប្រមាណដ៏ក្រៃលែង ដោយអំណាចនៃឧបេក្ខា និង ដោយអំណាច បញ្ញា, ចិត្ត រមែងរួចស្រឡះចាកកិលេស មានសភាពផ្សេងៗ ដោយ អំណាចនៃឧបេក្ខា, បញ្ញិន្ទ្រីយ៍ ជាឥន្ទ្រីយ៍មានប្រមាណក្រៃលែង ដោយ អំណាចវិមោក្ខ និង ដោយអំណាចបញ្ញា, ធម៌ទាំងឡាយនោះជាធម៌មាន រសតែមួយ ព្រោះចិត្តរួចស្រឡះហើយ, ភាវនា តែងមាន ព្រោះសេចក្តី ថា (ធម៌ទាំងនោះ) មានរសតែមួយ" ដូច្នេះ ព្រោះហេតុណា, ព្រោះ ហេតុនោះ សេចក្តីរីករាយ ដែលជាកិច្ចនៃញាណ ទើបលោកពោលថា "ជាទីបំផុត" ។*

*(៩៧) ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបាឋៈនេះ ថា "ឈានទីមួយ ហៅថា បឋវីកសិណ ជាឈាន គឺព្រះយោគី បាន ហើយ" ដូចតទៅនេះ :*

(បឋមជ្ឈាន)

*ឈាននេះ ឈ្មោះថា បឋម ព្រោះមានលំដាប់នៃការរាប់ ។ ឈាន ណា កើតឡើងហើយជាដំបូង ហេតុនោះ ឈាននោះ ឈ្មោះថា បឋម ។*



*គុណជាតនេះ ឈ្មោះថា ឈាន ព្រោះចូលទៅសំឡឹងនូវអារម្មណ៍ ឬថា ព្រោះដុតបំផ្លាញនូវធម៌ដែលជាសត្រូវ ។ ចំណែកឯមណ្ឌលនៃដី លោក ហៅថា "បឋវីកសិណ" ព្រោះសេចក្តីថា ដីទាំងមូល ។ និមិត្តដែលព្រះ យោគីបានហើយ ព្រោះអាស្រ័យនូវបឋវីមណ្ឌលនោះក្តី ឈានដែល ព្រះយោគីបានហើយ ក្នុងនិមិត្តក្តី លោកហៅថា "បឋវីកសិណ" ។ បណ្តាសេចក្តីនៃបឋវីកសិណទាំង ៣ យ៉ាងនោះ ក្នុងសេចក្តីនេះ បណ្ឌិត គប្បីជ្រាបថា "ឈាន ឈ្មោះថា បឋវីកសិណ" ។ បាលីថា "ឈាន ទី មួយ ហៅថា បឋវីកសិណ ជាឈានគឺព្រះយោគីបានហើយ" ដូច្នេះនោះ គឺលោកពោលហើយ សំដៅយកសេចក្តីនោះ ។*

*ក៏កាលបើព្រះយោគី បានបឋមជ្ឈាន យ៉ាងនេះហើយ, ព្រះយោគី នោះ គប្បីកំណត់យកអាការៈទាំងឡាយ ក្នុងឈាននោះ ដូចជាខ្មាន់ធ្នូ អ្នកបាញ់រោមកន្ទុយ និង ដូចជាអ្នកគ្រួ។ ធម្មតានាយខ្មាន់ធ្នូដែលឈ្លាស វៃល្អ កាលធ្វើកម្ម ដើម្បីបាញ់នូវរោមកន្ទុយ បាញ់ត្រូវរោមកន្ទុយ ក្នុង វារៈណា គប្បីកំណត់យកអាការៈ នៃជំហានដែលខ្ជួនបានជាន់ហើយផង នៃដងធ្នូផង នៃខ្សែធ្នូផង នៃព្រួញផង ក្នុងវារៈនោះថា "អញឈរដោយ អាការៈយ៉ាងនេះ កាន់ដងធ្នូយ៉ាងនេះ កាន់ខ្សែធ្នូយ៉ាងនេះ កាន់នូវព្រួញ យ៉ាងនេះហើយទើបបាញ់រោមកន្ទុយ" ដូច្នេះ ចាប់ដើមអំពីនោះមក ខ្មាន់ ធ្នូនោះ កាលញុំាងអាការៈទាំងនោះ ឲ្យសម្រេច ដោយបការៈដូច្នោះឯង ទើបបាញ់រោមកន្ទុយមិនខុស យ៉ាងណាមិញ, សូម្បីព្រះយោគី ក៏យ៉ាង ដូច្នោះដែរ គប្បីកំណត់យកអាការៈទាំងឡាយ មានភោជនជាទីសប្បាយ ជាដើម ទាំងនេះ ថា "អញ បរិភោគនូវភោជនឈ្មោះនេះ គប់រកបុគ្គល បែបនេះ នៅក្នុងសេនាសនៈបែបនេះ បានសំរេចឈាននេះហើយ ក្នុង*

កាលនេះ ដោយឥរិយាបថ ឈ្មោះនេះ” ដូច្នេះ ។ ព្រោះថាកាលបើព្រះយោគីកំណត់បាន យ៉ាងនេះហើយ, កាលបើបឋមជ្ឈាននោះ បាត់បង់ទៅហើយក្តី, ព្រះយោគីនោះ ក៏អាចដើម្បីញ៉ាំងអាការៈទាំងនោះ ឲ្យសម្រេចហើយញ៉ាំងឈាននោះ ឲ្យកើតឡើងម្តងទៀតបាន កាលធ្វើនូវឈាននោះដែលមិនទាន់ស្ទាត់ឲ្យស្ទាត់ក្តី ក៏អាចដើម្បីឲ្យបានដល់អប្បនាជារឿយៗ។ មួយទៀត ដូចអ្នកគ្រួដែលឈ្លាស កាលអង្គាសចៅហ្វាយនាយ កំណត់ចំណាំនូវអាហារដែលចៅហ្វាយនាយនោះ ចូលចិត្តបរិភោគ ចាប់តាំងពីនោះមក ក៏បង្អោននូវអាហារមានសភាពបែបនោះឯង ទៅឲ្យចៅហ្វាយនាយនោះ រមែងបានលាភ យ៉ាងណាមិញ, សូម្បីព្រះយោគីនេះ ក៏យ៉ាងនោះដែរ កំណត់នូវអាការៈទាំងឡាយ មានភោជនជាដើម ក្នុងខណៈដែលខ្លួនបានសំរេចហើយ ញ៉ាំងអាការៈទាំងនោះឲ្យសម្រេច ទើបជាអ្នកបានអប្បនារឿយៗ ។ ហេតុនោះ ព្រះយោគីនេះ គប្បីកំណត់អាការៈទាំងឡាយ ឲ្យដូចជាអ្នកបាញ់ពេមកន្ទុយ និង អ្នកគ្រួ យ៉ាងដូច្នោះ ។

មែនពិត សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់ពាក្យនេះថា “ម្នាលភិក្ខុទាំងឡាយ អ្នកគ្រួពិសេស ដែលឈ្លាសវាងវៃ ជាអ្នកបម្រើព្រះរាជាខ្លះ មហាអាមាត្យនៃព្រះរាជាខ្លះ ដោយម្ហូបទាំងឡាយ ដែលខ្លួនផ្សំហើយដោយរសជាតផ្សេងៗ គឺ រសជូរខ្លះ រសចត់ខ្លះ រសហឹរខ្លះ រសផ្អែមខ្លះ រសខារខ្លះ រសមិនខារខ្លះ រសប្រៃខ្លះ រសមិនប្រៃខ្លះ, ម្នាលភិក្ខុទាំងឡាយ អ្នកគ្រួពិសេសដែលឈ្លាសវាងវៃនោះឯង រៀនយកនូវការចំណាំនៃចៅហ្វាយនាយ របស់ខ្លួនថា “ថ្ងៃនេះ ម្ហូបនេះ គាប់ចិត្តដល់ចៅហ្វាយនាយរបស់អញផង, ចៅហ្វាយនាយ របស់អញ លូកចំពោះតែម្ហូបនេះផង, ចៅហ្វាយនាយ របស់អញ ចាប់យកច្រើនចំពោះម្ហូបនេះផង, ចៅ



ហ្វាយនាយ របស់អញ ពោលសរសើរចំពោះម្ហូបនេះផង, ថ្ងៃនេះ ម្ហូបមានរសជូរគាប់ចិត្តចំពោះចៅហ្វាយនាយរបស់អញផង, ចៅហ្វាយនាយរបស់អញ លូកចំពោះម្ហូបមានរសជូរផង, ចាប់យកច្រើនចំពោះម្ហូបមានរសជូរផង, ចៅហ្វាយនាយ របស់អញ ពោលសរសើរ ចំពោះម្ហូបមានរសជូរផង ។ល។ ពោលសរសើរចំពោះម្ហូបមិនមានរសប្រៃផង” ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកគ្រួពិសេសដែលឈ្លាស ប្រសប់វាងវៃនោះឯង ជាអ្នកបាននូវគ្រឿងស្លៀកពាក់ ជាអ្នកបានបៀវត្ស និង ជាអ្នកបាននូវរង្វាន់, នោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះថាអ្នកគ្រួវិសេសដែលឈ្លាស ប្រសប់វាងវៃនោះ រៀនយកនូវការចំណាំ នៃចៅហ្វាយនាយរបស់ខ្លួន យ៉ាងណា, ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាបណ្ឌិត ប្រសប់ឈ្លាសវៃ ជាអ្នកមានការពិចារណារឿយៗ នូវកាយ ក្នុងកាយនៅ, អ្នកមានការពិចារណារឿយៗនូវវេទនា ក្នុងវេទនាទាំងឡាយ អ្នកមានការពិចារណារឿយៗ នូវចិត្ត ក្នុងចិត្ត អ្នកមានការពិចារណារឿយៗនូវធម៌ ក្នុងធម៌ទាំងឡាយនៅ ជាអ្នកមានព្យាយាម ជាអ្នកដឹងខ្លួនច្បាស់ មានសតិ គប្បីបន្ទោបង់អភិជ្ឈា និង ទោមនស្ស ក្នុងលោក, កាលបើព្រះយោគីនោះ ពិចារណាឃើញរឿយៗនូវធម៌ ក្នុងធម៌ទាំងឡាយនៅ, ចិត្ត រមែងតាំងនៅមាំ, ឧបកិលេសទាំងឡាយ គឺព្រះយោគីនោះលះបង់បាន, ព្រះយោគីនោះ រៀនយកនូវនិមិត្តនោះ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង ជាបណ្ឌិត ប្រសប់ឈ្លាសវៃ ជាអ្នកបាននូវការនៅជាសុខ ក្នុងបច្ចុប្បន្ននេះផង ជាអ្នកបាននូវសតិ និង សម្បជញ្ញៈផង, រឿងនោះ ព្រោះហេតុអ្វី?, ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុនោះជាបណ្ឌិត ប្រសប់ឈ្លាសវៃ រៀនយកនូវការកំណត់ នៃចិត្តរបស់ខ្លួន

*ក៏យ៉ាងនោះដែរ” ដូច្នេះ ។*

*ក៏កាលបើព្រះយោគីនោះ ញុំាងអាការៈទាំងនោះ ឲ្យដល់ព្រម ម្ដង ទៀត ដោយកិរិយាកាន់យកនូវនិមិត្ត, គុណជាតត្រឹមតែអប្បនាប៉ុណ្ណោះ រមែងសំរេច ។ ទីជាទីតាំងនៅយូរ មិនមានទេ ។ ឯទីជាទីតាំងនៅយូរ តែងមាន ព្រោះភាវៈនៃធម៌ទាំងឡាយ ដែលជាសត្រូវដល់សមាធិ គឺខ្លួន សំអាតល្អហើយ ។ មែនពិត ភិក្ខុណា មិនសង្កត់សង្កិន ដោយប្រពៃនូវ កាមឆន្ទៈ ដោយបច្ចវេក្ខណវិធី មានកិរិយាពិចារណានូវទោសនៃកាម ជាដើម មិនធ្វើសេចក្ដីអាក្រក់ ដោយកាយ ឲ្យស្ងប់រម្ងាប់ ដោយប្រពៃ ដោយអំណាចការស្ងប់រម្ងាប់នៃកាយ មិនបន្ទោបង់ដោយប្រពៃ នូវថីន-មិទ្ធៈ ដោយអំណាចនៃការធ្វើទុកក្នុងចិត្ត នូវអារម្ភធាតុជាដើម មិនធ្វើការ ដកឡើងដោយប្រពៃ នូវឧទ្ធច្ចកុក្កុច្ចៈ ដោយអំណាចនៃមនសិការវិធីមាន ការធ្វើទុកក្នុងចិត្ត នូវសមថនិមិត្តជាដើម មិនជម្រះ ដោយប្រពៃនូវធម៌ ទាំងឡាយដែលជាសត្រូវដល់សមាធិដទៃទៀត ស្រាប់តែចូលនូវឈាន, ភិក្ខុនោះ ចង់ចេញឆាប់ មិនខាន ដូចជាភមរជាតិ ដែលចូលទៅហើយ កាន់ទីជាទីនៅអាស្រ័យ ដែលខ្លួនមិនបានជម្រះហើយ រមែងប្រញាប់ ចេញមកវិញ និង ដូចជាព្រះរាជា ដែលស្ដេចយាងចូលទៅកាន់ឧទ្យាន ដែលមិនបានសំអាតហើយ ក៏ទ្រង់ប្រញាប់យាងចេញមកវិញ យ៉ាង ដូច្នោះដែរ ។ ចំណែកភិក្ខុណា ញុំាងធម៌ទាំងឡាយ ដែលជាសត្រូវដល់ សមាធិ ឲ្យស្អាតដោយប្រពៃហើយ ទើបចូលនូវឈាន ភិក្ខុនោះ ជាអ្នក នៅខាងក្នុងនៃសមាបត្តិ រហូតពេញមួយថ្ងៃក៏បាន ដូចជាភមរជាតិ ដែល ចូលទៅហើយកាន់ទីជាទីនៅអាស្រ័យ ដែលខ្លួនបានជម្រះល្អហើយ (នៅ ក្នុងទីនោះបានយូរ) និង ដូចព្រះរាជា ដែលយាងចូលទៅកាន់ព្រះឧទ្យាន*



*ដែលបានសំអាតហើយ(ស្ដេចនៅក្នុងឧទ្យាននោះបានយូរ)យ៉ាងដូច្នោះ ។*

*ព្រោះហេតុនោះ ទើបុរាណាចារ្យទាំងឡាយ ពោល ថា :*

ព្រះយោគី មានចិត្តធ្វើនូវសេចក្ដីរីករាយទួទៅ ក្នុងវិវេក
គប្បីបន្ទោបង់ នូវសេចក្ដីពេញចិត្ត ក្នុងកាមទាំងឡាយ,
នូវសេចក្ដីថ្នាំងថ្នាក់, នូវឧទ្ធច្ចៈ និង មិទ្ធៈ មានវិចិកិច្ឆា
ជាគម្រប់ប្រាំ ដូចព្រះរាជា ស្ដេចយាងទៅកាន់ព្រះឧទ្យាន
ដ៏ស្អាត ទ្រង់រីករាយ ក្នុងឧទ្យាននោះដូច្នោះ ។

*ព្រោះហេតុនោះ ព្រះយោគី អ្នកមានប្រាថ្នាដើម្បីការតាំងនៅ អស់ កាលដ៏យូរ គប្បីជម្រះធម៌ដែលជាសត្រូវទាំងឡាយ ឲ្យបានស្អាតហើយ ទើបចូលនូវឈាន ។ មួយវិញទៀត ព្រះយោគីគប្បីចំរើនបដិភាគនិមិត្ត ដែលខ្លួនបានហើយយ៉ាងណា ដើម្បីភាពដ៏ទូលាយនៃចិត្តភាវនា ។ ភូមិ នៃការចំរើនបដិភាគនិមិត្តនោះ មាន២ យ៉ាង គឺឧបចារភូមិក្ដី អប្បនាភូមិ ក្ដី ។ មែនពិត ការដែលព្រះយោគី ទោះបីដល់នូវឧបចារៈហើយ នឹង ចំរើនបដិភាគនិមិត្តនោះ ក៏គួរ, តែព្រះយោគី សូម្បីដល់អប្បនាហើយ ក៏គប្បីចំរើន ក្នុងទីមួយ ដោយពិត ។ ព្រោះហេតុនោះ ទើបខ្ញុំពោលថា “ព្រះយោគីគប្បីចំរើនបដិភាគនិមិត្ត ដែលខ្លួនបានហើយយ៉ាងណា” ។*

*(៩៨) នេះជាន័យនៃការចំរើន ក្នុងបដិភាគនិមិត្តនេះ ។ ព្រះយោគី នោះ មិនគប្បីចំរើននិមិត្តនោះ ដោយទំនងនៃការពង្រីកបាត្រ ការពង្រីក នូវនំ, ការពង្រីកបាយ, ការចំរើននៃវល្លិ និង ទំនងនៃការពង្រីកសំពត់ គប្បីកំណត់នូវទំហំនៃនិមិត្ត តាមដែលខ្លួនបានហើយនោះ ត្រឹមតែមួយ ធ្នាប់, ២ ធ្នាប់, ៣ ធ្នាប់ និង ៤ ធ្នាប់ ដោយលំដាប់ ដោយចិត្តហើយ*

គប្បីចំរើន តាមដែលបានកំណត់ទុកមក, តែបើមិនទាន់បានកំណត់ទេ មិនត្រូវចំរើនឡើយ ប្រៀបដូចជាអ្នកស្រែ កំណត់នូវទីដែលខ្លួនត្រូវភ្ជួរ ដោយនង្គ័លហើយ ទើបភ្ជួរព្ធដ៏ខាងក្នុងនៃការកំណត់, មួយទៀត ប្រៀបដូចជាភិក្ខុទាំងឡាយ កាលចងសីមា កំណត់នូវនិមិត្តទាំងឡាយ ជាមុនហើយ ទើបចងក្នុងកាលជាខាងក្រោយដូច្នោះឯង ។ តមក ព្រះយោគីកាលចំរើននិមិត្ត ដោយអំណាចនៃការកំណត់នូវប្រមាណ ១ ចំអាម, ១ហត្ថ, ប៉ុនបរិវេណខាងមុខព្រះវិហារ និង ខេត្តដែន នៃព្រះវិហារទាំងឡាយផង ប៉ុនខេត្តដែននៃស្រុក, និគម, ជនបទ, ខេត្តដែនព្រះរាជា និង ខេត្តដែននៃសមុទ្រទាំងឡាយផង គប្បីកំណត់ ដោយទំហំប៉ុនចក្រវាឡ ឬក៏ ធំជាងចក្រវាឡនោះទៅទៀតក៏បាន ហើយចំរើន ។ ដូចជាកូនសត្វហង្សទាំងឡាយ ចាប់ដើមអំពីកាលដែលរោមស្វាបទាំងឡាយ ដុះឡើងហើយ ចូលទៅកាន់ប្រទេសតូចៗ ធ្វើនូវការប្ញើក(ម៉ាំមួនហើយ) ក៏ហើរទៅកាន់ទីជិតនៃព្រះច័ន្ទ និង ព្រះអាទិត្យទាំងឡាយ ដោយលំដាប់ យ៉ាងណាមិញ, ភិក្ខុ ក៏យ៉ាងដូច្នោះដែរ កាលកំណត់និមិត្តហើយចំរើន ដោយន័យដូចបានពោលហើយ ចំរើនរហូតដល់ទំហំប៉ុនចក្រវាឡ ឬក៏ ធំជាងនោះក៏បាន ។ បន្ទាប់មក និមិត្តនោះ (ជានិមិត្តប្រាកដ) ដល់ព្រះយោគីនោះ ក្នុងទីដែលខ្លួនចំរើនហើយៗ ដូចជាស្បែកនៃគោឧសភៈ ដែលបុគ្គលខ្វារហើយ ដោយកង្វេរមួយរយ នាទីទួល, ទីទំនាប, ជាទឹក, ជាភក់ជ្រៅ, ជាភ្នំ និង ជាទីមិនរាបស្មើនៃផែនដី យ៉ាងនោះឯង ។ តែថាព្រះយោគី ដែលជាអាទិកម្មិកៈ អ្នកបានបឋមជ្ឈានហើយ ក្នុងនិមិត្តនោះ គប្បីជាអ្នកច្រើនដោយកិរិយាចូល(នូវឈាន) មិនត្រូវជាអ្នកច្រើនដោយការពិចារណាឡើយ ។



ព្រោះថា កាលបើព្រះយោគីនោះ ច្រើនដោយការពិចារណា, អង្គឈានទាំងឡាយ ជាអង្គប្រាកដ ដូចជាថ្លៃស និង មានកម្លាំងខ្សោយ ។ គ្រានោះ អង្គឈានទាំងនោះ របស់ព្រះយោគីដែលជាអាទិកម្មិកៈនោះ រមែងមិនសម្រេចជាបច្ច័យ នៃសេចក្តីខ្វល់ខ្វាយ ក្នុងឈាន ព្ធដ៏ខាងលើ ព្រោះអង្គឈានប្រាកដហើយយ៉ាងដូច្នេះ។ ព្រះយោគីដែលជាអាទិកម្មិកៈនោះ កាលខ្វល់ខ្វាយ ក្នុងឈានដែលមិនទាន់ស្ទាត់ជំនាញ រមែងសាបសូន្យចាកបឋមជ្ឈានផង ថែមទាំងមិនអាចដើម្បីបានសម្រេចឈាន ទី២ផង ។ ហេតុនោះ បានជាព្រះមានព្រះភាគត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មេគោដែលត្រាច់រកស៊ីលើខ្នងភ្នំ ជាសត្វល្ងង់ខ្លៅ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ដើម្បីត្រាច់ទៅ លើភ្នំដែលមិនស្មើបាន, មេគោនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា “បើដូច្នោះ មានតែអញទៅកាន់ទីដែលអញមិនធ្លាប់បានទៅផង ទំពាស៊ីស្មៅដែលអញមិនធ្លាប់បានស៊ីផង ផឹកទឹកដែលអញមិនធ្លាប់បានផឹកផង” ដូច្នេះ, មេគោនុ៎ះមិនទាន់បានដាក់ជើងខាងមុខ ឲ្យបានតាំងនៅស៊ប់ល្អហើយ ក៏លើកជើងខាងក្រោយឡើង, មេគោនោះ មិនត្រូវទៅកាន់ទិសដែលវាមិនធ្លាប់ទៅផង មិនត្រូវស៊ីស្មៅដែលវាមិនធ្លាប់ស៊ីផង មិនត្រូវផឹកទឹកដែលវាមិនធ្លាប់ផឹកផង ថែមទាំងមិនគប្បីត្រឡប់មកកាន់ទីកន្លែង ដែលវាឈរត្រិះរិះ យ៉ាងនេះថា “បើដូច្នោះ មានតែអញទៅកាន់ទី ដែលអញមិនធ្លាប់បានទៅផង ។ល។ ផឹកទឹកដែលអញមិនធ្លាប់បានផឹកផង” ដូច្នេះ ដោយសួស្តីនោះបានទេ, រឿងនោះ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះថា មេគោនោះ ជាសត្វត្រាច់រកស៊ីលើខ្នងភ្នំ តែជាសត្វល្ងង់ខ្លៅ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ដើម្បីត្រាច់ទៅ លើភ្នំដែលមិនរាបស្មើបាន មានឧបមា

យ៉ាងណា, ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ក៏មាន ឧបមេយ្យយ៉ាងនោះដែរ ជាអ្នកល្ងង់ខ្លៅ មិនឈ្លាសវៃ មិនស្គាល់ខេត្ត មិនប្រសប់ ដើម្បីស្ងាត់ចាកកាមទាំងឡាយ ។ល។ សម្រេចសម្រាន្តដល់ បឋមជ្ឈាន, ភិក្ខុនោះ មិនសេព មិនចំរើន មិនធ្វើឲ្យច្រើននូវនិមិត្តនោះ ទាំងមិនតម្កល់និមិត្តនោះ ឲ្យតម្កល់នៅល្អហើយផង, ភិក្ខុនោះ ក៏មាន សេចក្តីត្រិះរិះ យ៉ាងដូច្នេះថា "បើដូច្នោះ មានតែអាត្មាអញ គប្បីចូលទៅ កាន់ឈានទីពីរ សម្រេចសម្រាន្តនៅ ។ល។ ព្រោះកិរិយាស្ងប់រម្ងាប់នៃ វិតក្កៈ និង វិចារៈទាំងឡាយ" ដូច្នេះ, ភិក្ខុនោះ មិនអាចដើម្បីចូលទៅ ដល់ឈានទីពីរ ។ល។ ព្រោះវិតក្កៈ និង វិចារៈទាំងឡាយស្ងប់រម្ងាប់ ហើយ សម្រេចសម្រាន្តនៅបានទេ, ភិក្ខុនោះ មានសេចក្តីត្រិះរិះ យ៉ាង នេះថា "បើដូច្នោះ មានតែអាត្មាអញ គប្បីស្ងប់ស្ងាត់ចាកកាមទាំងឡាយ ឲ្យបានហើយ ចូលដល់ឈានទី១ សម្រេចសម្រាន្តនៅ" ដូច្នេះ, ភិក្ខុនោះ ក៏មិនអាចដើម្បីស្ងប់រម្ងាប់ចាកកាមទាំងឡាយ ។ល។ ចូលបឋមជ្ឈាន ហើយសម្រេចសម្រាន្តនៅបានឡើយ, ម្នាលភិក្ខុទាំងឡាយ ភិក្ខុរូបនេះ តថាគតហៅថា ជាអ្នកឃ្លាងហើយ ចាកឈានទាំងពីរ ជាអ្នកសាបសូន្យ ហើយ ចាកឈានទាំងពីរ, ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាមេគោនោះ ជាសត្វត្រាច់រកស៊ីលើខ្នងភ្នំ តែជាសត្វល្ងង់ខ្លៅ មិនឈ្លាសវៃ មិនស្គាល់ ខេត្ត មិនប្រសប់ដើម្បីត្រាច់ទៅលើភ្នំដែលមិនស្មើយ៉ាងនោះឯង" ដូច្នេះ។ ព្រោះហេតុនោះ ព្រះយោគីនោះ គប្បីជាអ្នកមានការស្ទាត់ប្រព្រឹត្តទៅ ដោយអាការៈទាំងឡាយ ៥ ក្នុងបឋមជ្ឈាននោះឯង ជាមុនសិន ។

ក្នុងអាការៈទាំងនោះ វសី (សេចក្តីថ្នឹកទាំងឡាយ) ៥ នេះ គឺ :

(១) **អាវជ្ជនវសី** ថ្នឹកក្នុងការនឹក,



(២) **សមាបជ្ជនវសី** ថ្នឹកក្នុងការចូលឈាន,

(៣) **អធិដ្ឋានវសី** ថ្នឹកក្នុងការទប់ទុកនូវឈាន,

(៤) **វុដ្ឋានវសី** ថ្នឹកក្នុងការចេញ,

(៥) **បច្ចវេក្ខណវសី** ថ្នឹកក្នុងការពិចារណា ។

ព្រះយោគី នឹករកបឋមជ្ឈាន ក្នុងទីកន្លែងដែលប្រាថ្នា ក្នុងពេល ដែលប្រាថ្នា ក្នុងកំណត់ដែលប្រាថ្នា, ភាវៈនៃការយឺតយូរនៃការនឹក មិន មាន ហេតុនោះ អាការៈដូច្នេះ ទើបឈ្មោះថា **អាវជ្ជនវសី** ។ ព្រះយោគី ចូលនូវបឋមជ្ឈាន ត្រឹមតែទីដែលប្រាថ្នា ត្រឹមតែពេលដែលប្រាថ្នា ត្រឹម តែកំណត់ដែលប្រាថ្នា, ភាវៈនៃការយឺតយូរនៃការចូល មិនមាន ព្រោះ ហេតុនោះ អាការៈដូច្នេះ ទើបឈ្មោះថា **សមាបជ្ជនវសី** ។ សូម្បីវសី ដ៏សេស បណ្ឌិត គប្បីពង្រីកសេចក្តី ដូចន័យនេះដែរ ។ នេះ ជាការ ប្រកាសសេចក្តី ក្នុងវសីទាំង ៥ នោះ ។

(៩៩) កាលព្រះយោគី ចេញអំពីបឋមជ្ឈានហើយ នឹកវិតក្កៈ ជា ដំបូង, ជវនៈទាំងឡាយ ៤ ឬ ៥ ដែលមានវិតក្កៈជាអារម្មណ៍ទុំះឯង រមែងស្ទុះទៅ ក្នុងលំដាប់នៃអាវជ្ជនចិត្ត ដែលកាត់ផ្តាច់នូវភវង្គៈហើយ កើតឡើង, បន្ទាប់អំពីនោះមក ភវង្គៈពីរ រមែងកើតឡើង, បន្ទាប់មក អាវជ្ជនចិត្តដែលមានវិចារៈជាអារម្មណ៍ តែងកើតឡើងម្តងទៀត, ជវនៈ ទាំងឡាយ រមែងស្ទុះទៅ តាមន័យដែលបានពោលមកហើយទុំះឯង ហេតុនោះ ព្រះយោគី អាចដើម្បីបញ្ជូននូវចិត្ត មិនឲ្យមានចន្លោះ ក្នុងអង្គ ឈានទាំង ៥ យ៉ាង ដូច្នេះ ក្នុងកាលណា, ក្នុងកាលនោះ អាវជ្ជនវសី ជាគុណជាតសំរេចហើយដល់ព្រះយោគីនោះ ។ ចំណែក វសីនេះ ដល់ នូវទីបំផុត គឺព្រះយោគីបាន ក្នុងយមកប្បាដិហារ នៃព្រះមានព្រះភាគ ឬ

ក្នុងកាលមានសភាពបែបនេះ នៃព្រះសាវ័កទាំងឡាយឯទៀត ។ ធម្មតាការថ្មីក ក្នុងការនឹកដែលឆាប់រហ័ស ដោយវិសេសជាងនេះទៅទៀត មិនមានទេ ។ ចំណែកភាពជាអ្នកអាចក្នុងការចូល (ឈាន) បានយ៉ាងឆាប់ដូចជាការចូល ក្នុងកាលជាទីទូន្មានស្តេចនាគ ឈ្មោះ នន្ទោបនន្ទ នៃព្រះមហាមោគ្គល្លានដ៏មានអាយុ ដូច្នោះ ឈ្មោះថា សមាបជ្ជនវសី ។ ភាពនៃបុគ្គលជាអ្នកអាចដើម្បីទប់ (នូវឈាន) បាន អស់កាលតែមួយរំពេចត្រឹមតែផ្ទាត់ម្រាមដៃម្តង ឬ ត្រឹមតែផ្ទាត់ម្រាមដៃ ១០ ដង ឈ្មោះថា អធិដ្ឋានវសី ។ ភាពនៃបុគ្គលជាអ្នកអាចដើម្បីចេញ (ចាកឈាន) បានឆាប់រហ័ស យ៉ាងដូច្នោះដែរ ឈ្មោះថា វុដ្ឋានវសី ។

ដើម្បីសំដែង នូវអធិដ្ឋានវសី និង វុដ្ឋានវសីទាំង ២ យ៉ាង នោះគួរសំដែងរឿងព្រះពុទ្ធរក្ខិតត្ថេរ ។

សេចក្តីដំណាលថា លោកដ៏មានអាយុអង្គនោះ (បួស) បាន ៨ វស្សា តាំងអំពីឧបសម្បទមក គង់នៅត្រង់កណ្តាល នៃពួកភិក្ខុអ្នកមានឫទ្ធិទាំងឡាយ ចំនួនបីម៉ឺនអង្គ ដែលមកហើយកាន់ទីព្យាបាលជំងឺ របស់ព្រះមហារោហណគុត្តត្ថេរ ក្នុងវិហារឈ្មោះថេរម្ពត្ថលៈ ឃើញនូវស្តេចគ្រុឌ កំពុងធាបចុះមកអំពីអាកាស (ដោយបំណង) ថា "អញនឹង ចាប់ស្តេចនាគ ជាអ្នកបម្រើដែលកំពុងតែប្រគេនបបរ ដល់ព្រះថេរៈ" ដូច្នេះក៏និមិត្តនូវភ្នំហើយ យកដើមដៃឱបចាប់ស្តេចនាគឲ្យចូលទៅ ក្នុងភ្នំនោះក្នុងខណៈនោះឯង។ ស្តេចគ្រុឌឲ្យនូវការប្រហារព្ធដ៏ភ្នំហើយ ក៏គេចទៅ។ ព្រះមហាថេរៈបានពោលថា "ម្នាលអាវុសោ ប្រសិនបើព្រះពុទ្ធរក្ខិត នឹងមិនមានទេ, សមយើងទាំងអស់គ្នា ជាបុគ្គលគឺគេគប្បីតិះដៀលបាន" ។

ចំណែកបច្ចវេក្ខណវសី គឺខ្ញុំពោលហើយ ក្នុងអាវជ្ជនវសីនុ៎ះឯង ។



ព្រោះថា ជវនៈទាំងឡាយ ដែលជាលំដាប់អំពីអាវជ្ជនៈ ក្នុងអាវជ្ជនវសីនោះ គឺជវនៈ ក្នុងបច្ចវេក្ខណៈហ្នឹងឯង ។

(ទុតិយជ្ឈាន)

ក៏ព្រះយោគី អ្នកបំពេញវសី ក្នុងវសីទាំង ៥ ចេញអំពីឈាន ទី១ ដែលស្ទាត់ហើយ ឃើញទោស ក្នុងបឋមជ្ឈាននោះថា "សម្បត្តិនេះមានសត្រូវគឺនីវរណៈ ក្នុងទីជិតផង, សម្បត្តិនេះ មានអង្គមានកម្លាំងថយ ព្រោះភាវៈនៃវិតក្កៈ និង វិចារៈ ជាធម្មជាត ដ៏គ្រោកគ្រាកផង" ដូច្នេះហើយ ធ្វើទុកក្នុងចិត្ត នូវទុតិយជ្ឈាន ដោយថា ជាធម៌ដ៏ប្រណីតលើកលះនូវសេចក្តីពេញចិត្ត ក្នុងបឋមជ្ឈានហើយ គប្បីធ្វើសេចក្តីព្យាយាម ដើម្បីបានសម្រេចនូវទុតិយជ្ឈាន ។

លំដាប់នោះ កាលព្រះយោគីនោះ ចេញអំពីបឋមជ្ឈានហើយ ជាអ្នកមានសតិ ដឹងច្បាស់ ពិចារណាអង្គឈានទាំងឡាយ, វិតក្កៈ និង វិចារៈទាំងឡាយ រមែងកើតឡើងប្រាកដ ដោយភាវៈជាអង្គគ្រោកគ្រាក, បីតិ និង សុខៈផង ភាពនៃចិត្តមានអារម្មណ៍តែមួយផង រមែងប្រាកដឡើង ដោយភាពជាអង្គដ៏ស្ងប់ ក្នុងកាលណា, ក្នុងកាលនោះ កាលព្រះយោគីនោះ ធ្វើទុកក្នុងចិត្តរឿយៗ នូវនិមិត្តនោះឯង ដោយបរិកម្ម ថា "បឋវី បឋវី" ដូច្នេះ ដើម្បីលះនូវអង្គដែលគ្រោកគ្រាក និង ដើម្បីបានចំពោះនូវអង្គដែលស្ងប់, មនោទ្វារាវជ្ជនចិត្ត កាត់ផ្តាច់នូវភវង្គៈ (ដោយគិត)ថា "ទុតិយជ្ឈាន រមែងកើតឡើង ក្នុងកាលឥឡូវនេះ" ហើយធ្វើបឋវីកសិណនោះឯង ឲ្យជាអារម្មណ៍ ទើបកើតឡើង ។ បន្ទាប់អំពីនោះ ជវន ១ ជារូបាវចរចិត្ត ប្រកបដោយទុតិយជ្ឈាន ក្នុងទីបំផុតនៃជវនទាំងឡាយណា, ជវនទាំងឡាយនោះ ៤ ឬ ៥ រមែងស្ទុះទៅ ក្នុងអារម្មណ៍

នោះឯង, ជវន ដ៏សេសជាកាមាវចរចិត្ត មានបការៈដូចខ្ញុំបានពោលមកហើយនុ៎ះឯង ។

ក៏ដោយហេតុមានប្រមាណប៉ុណ្ណោះ ព្រះយោគីនោះ ឈ្មោះថា ចូលទៅសម្រេចសម្រាន្តនៅឈានទី២ ដែលមានការជ្រះថ្លាព្រម ព្វដ៏ខាងក្នុង មានភាពនៃចិត្តព្រោងឡើងតែមួយ មិនមានវិតក្កៈ មិនមានវិចារៈ ព្រោះវិតក្កៈ និង វិចារៈស្ងប់រម្ងាប់ មានតែបីតិ និង សុខៈ ដែលកើតអំពីសមាធិ ។ ទុតិយជ្ឈាន ជាបឋវីកសិណ ដែលលះអង្គ ២ ប្រកបព្រមដោយអង្គ ៣ មានលំអ ៣ យ៉ាង ដល់ព្រមដោយលក្ខណៈ ១០ ជាឈាន គឺព្រះយោគីនោះបានហើយ យ៉ាងនេះឯង ។

(១០០) បណ្ដាបាឋៈទាំងឡាយនោះ បាឋៈថា "ព្រោះវិតក្កៈ និង វិចារៈ ស្ងប់រម្ងាប់" ដូច្នេះ សេចក្ដីថាៈ ព្រោះការស្ងប់រម្ងាប់ គឺ ព្រោះការកន្លង នូវអង្គទាំង ២ នេះ គឺ វិតក្កៈ ១ វិចារៈ ១ ។ មានពាក្យអធិប្បាយថាៈ ព្រោះភាវៈនៃអង្គទាំង ២ នោះ មិនប្រាកដ ក្នុងខណៈនៃទុតិយជ្ឈាន ។ ធម៌ក្នុងបឋមជ្ឈាន សូម្បីទាំងអស់ មិនមាន ក្នុងទុតិយជ្ឈាន, មែនពិត ធម៌ទាំងឡាយ មានផស្សៈជាដើម ក្នុងបឋមជ្ឈានជាធម៌ផ្សេងមែនពិត, ក្នុងទុតិយជ្ឈាននេះ ជាធម៌ផ្សេង ក៏ពិតមែនហើយ ទោះបីជាដូច្នោះក៏ដោយ ក្នុងទុតិយជ្ឈាន បាឋៈនោះ បណ្ឌិត គប្បីជ្រាបថាៈ ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា "ព្រោះវិតក្កៈ និង វិចារៈ ស្ងប់រម្ងាប់" ដូច្នេះ ដើម្បីសំដែងថា "ព្រោះការប្រព្រឹត្តិកន្លងនូវអង្គ ដែលគ្រោតគ្រាតៗ កិរិយាបាននូវឈានទាំងឡាយ ដទៃអំពីបឋមជ្ឈាន មានទុតិយជ្ឈានជាដើម រមែងមាន" ដូច្នេះ ។

បទថា "អជ្ឈត្តំ" ក្នុងទីនេះ លោកបំណងយកពាក្យខាងក្នុងខ្លួន ។



ចំណែកក្នុងវិភង្គ លោកពោលពាក្យមានប្រមាណប៉ុណ្ណោះ ថា "អជ្ឈត្តំ គឺចំពោះខ្លួន" ដូច្នេះវិញ ។ ក៏ព្រោះលោកបំណងយកពាក្យខាងក្នុងខ្លួន ព្រោះហេតុនោះ ក្នុងបទថា "អជ្ឈត្តំ" នេះ ទើបមានសេចក្ដីអធិប្បាយយ៉ាងនេះ ថា "កើតដល់ខ្លួន ឬ កើតក្នុងខ្លួន កើតក្នុងសន្ដានរបស់ខ្លួន" ។

បទថា "សម្បសាទនំ" មានវិនិច្ឆ័យថាៈ សទ្ធា លោកហៅថា សេចក្ដីជ្រះថ្លាស៊ប់ ។ សូម្បីឈាន ក៏លោកហៅថា សេចក្ដីជ្រះថ្លាស៊ប់ ព្រោះប្រកបដោយសេចក្ដីជ្រះថ្លាស៊ប់ ដូចជាសំពត់ មានពណ៌ខៀវ ក៏ព្រោះប្រកបដោយពណ៌ខៀវដូច្នោះ។ មួយទៀត ឈាននោះញុំាងចិត្តឲ្យជ្រះថ្លាស៊ប់ ព្រោះឈាននោះប្រកបដោយសេចក្ដីជ្រះថ្លាស៊ប់ផង ព្រោះចូលទៅរម្ងាប់នូវសេចក្ដីកំរើកនៃវិតក្កៈ និង វិចារៈទាំងឡាយផង ព្រោះហេតុណា, ព្រោះហេតុនោះឯង បានជាលោកហៅថា "គ្រឿងញុំាងចិត្តឲ្យជ្រះថ្លាស៊ប់" ។ ក៏ក្នុងអត្ថវិកប្បនេះ បណ្ឌិតគប្បីជ្រាបបទសម្ព័ន្ធយ៉ាងដូច្នេះ ថា "ទុតិយជ្ឈាន ជាគ្រឿងញុំាងចិត្តឲ្យជ្រះថ្លាស៊ប់" ដូច្នេះ។ ប៉ុន្តែក្នុងអត្ថវិកប្បខាងដើម បទថា "ចេតសោ" នុ៎ះ បណ្ឌិត គប្បីប្រកបជាមួយនឹងឯកោទិភាវស័ព្ទ ។

នេះ ជាការប្រកបសេចក្ដី ក្នុងឯកោទិភាវស័ព្ទនោះ ។ ធម៌ឯណាព្រោងឡើងតែមួយ ហេតុនោះ ធម៌នោះ ឈ្មោះថា ព្រោងឡើងតែមួយ, អធិប្បាយថាៈ ជាធម៌ប្រសើរ គឺប្រសើរបំផុត ព្រោងឡើង ព្រោះភាវៈនៃធម៌នោះ គឺវិតក្កៈ និង វិចារៈទាំងឡាយ ដុះឡើងគ្របសង្កត់មិនបាន។ មែនពិត សូម្បីបុគ្គលប្រសើរបំផុត ក៏លោកហៅថា "ជាបុគ្គលឯក ក្នុងលោក" ។ ឬ នឹងហៅថា "បុគ្គលដែលប្រាសចាកវិតក្កៈ និង វិចារៈហើយ ជាបុគ្គលឯក គឺ មិនមានសំឡាញ់" ដូច្នេះ ក៏គួរ ។ មួយទៀត

ធម៌ណា ញុំាងសម្បយុត្តធម៌ទាំងឡាយ ឲ្យព្រោងឡើង ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា ឧទិ, អធិប្បាយថា ញុំាងសម្បយុត្តធម៌ទាំងឡាយ ឲ្យតាំងឡើង ។ ធម៌នោះ ឈ្មោះថា ជាធម៌ឯក ព្រោះអត្ថថា ប្រសើរបំផុតផង ជាឧទិផង ហេតុនោះ ទើបឈ្មោះថា ឯកោទិ ។ ពាក្យថា "ឯកោទិ" នេះ ជាឈ្មោះនៃសមាធិ ។ ឈាន ទី២ នេះ ញុំាងសមាធិដែលញុំាងសម្បយុត្តធម៌ ឲ្យព្រោងឡើងតែមួយនេះ ឲ្យកើតឡើង គឺឲ្យចំរើនឡើង ហេតុនោះ ទុតិយជ្ឈាននេះ ទើបឈ្មោះថា ឯកោទិភាព ដូចរៀបរាប់មកនេះឯង ។ មួយទៀត សមាធិ ដែលឈ្មោះថា ឯកោទិនេះនោះ ជាការព្រោងឡើងនៃចិត្ត មិនមែនជាការព្រោងឡើងនៃសត្វ មិនមែនជាការព្រោងឡើងនៃជីវៈ ព្រោះហេតុណា ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា "ចេតសោ ឯកោទិភាវំ" ដូច្នេះ ។

សួរថា: ក៏សទ្ធានេះ និង សមាធិដែលឈ្មោះថា ឯកោទិ នេះ មានក្នុងបឋមជ្ឈានផង មិនមែនទេឬ? កាលបើដូច្នោះ ព្រោះហេតុអ្វីបានជាព្រះមានព្រះភាគទ្រង់ត្រាស់តែទុតិយជ្ឈាននេះថា "ជាសេចក្តីជ្រះថ្លាស៊ប់ និង ថា ជាការព្រោងឡើងតែមួយនៃចិត្ត ?" ។

ឆ្លើយថា: បណ្ឌិត គប្បីជ្រាបថា "ព្រោះបឋមជ្ឈាន ឯណោះ ជាធម្មជាត មិនទាន់ថ្លាល្អ ព្រោះមានការកំរើក ដោយវិតក្កៈ និង វិចារៈនៅឡើយ ដូចទឹកដែលល្អក់ដោយរលក និង រលកខ្វាំង យ៉ាងនោះឯង, ហេតុនោះ សូម្បីកាលបើមានសទ្ធា, ក៏លោកមិនពោលថា "ជាសេចក្តីជ្រះថ្លាស៊ប់" ដូច្នេះទេ, ក៏សូម្បីសមាធិ ក្នុងបឋមជ្ឈាននេះ ក៏មិនប្រាកដច្បាស់ ដោយប្រពៃផងដែរ ព្រោះសទ្ធាហ្នឹងឯង មិនបានថ្លាល្អ, ព្រោះហេតុនោះ បានជាព្រះមានព្រះភាគមិនហៅថា "ឯកោទិភាវៈ" ដូច្នេះផង។



តែក្នុងឈាននេះ សទ្ធា មានឱកាសបានហើយ ព្រោះមិនមានសេចក្តីកង្វល់ ដោយវិតក្កៈ និង វិចារៈ ទើបមានកម្លាំង, ចំណែកសមាធិវិញរមែងប្រាកដច្បាស់ ព្រោះបាននូវសទ្ធាដ៏មានកម្លាំងជាគ្នានុ៎ះឯង ព្រោះហេតុនោះ ទើបលោកពោលតែទុតិយជ្ឈាននេះប៉ុណ្ណោះថា យ៉ាងនេះឯង" ដូច្នេះ ។

ចំណែកក្នុងវិភង្គ លោកពោលតែពាក្យមានប្រមាណប៉ុណ្ណេះ ថា "សទ្ធាឯណា, សេចក្តីជឿ, ការចុះចិត្ត, សេចក្តីជ្រះថ្លាក្រៃលែង ឯណា, សទ្ធានោះ ឈ្មោះថា សេចក្តីជ្រះថ្លាស៊ប់, ការតាំងនៅនៃចិត្តណា ។ល។ សម្មាសមាធិឯណា, សម្មាសមាធិនោះឈ្មោះថា ភាពនៃការព្រោងឡើងតែមួយនៃចិត្ត" ដូច្នេះ ។ ចំណែកអដ្ឋកថាជាគ្រឿងពណ៌នាសេចក្តីនេះព្រមទាំងបាលី ក្នុងវិភង្គនេះ ដែលយើងបានពោលហើយយ៉ាងនេះ មិនខុសគ្នា ប្រៀបធៀបគ្នាបាន និង សមគ្នា ដោយពិត យ៉ាងណា, បណ្ឌិតគប្បីជ្រាប យ៉ាងនោះចុះ ។

បទថា "អវិតក្កំ អវិចារំ" អធិប្បាយថា: សេចក្តីត្រិះរិះ មិនមានក្នុងទុតិយជ្ឈាននេះ ឬថា ដល់ទុតិយជ្ឈាននោះ ព្រោះវិតក្កៈ គឺព្រះយោគីលះបានហើយ ដោយភាវនា ព្រោះហេតុនោះ ទុតិយជ្ឈាននោះ ទើបឈ្មោះថា មិនមានវិតក្កៈ ។ ទុតិយជ្ឈាន ដែលឈ្មោះថា មិនមានវិចារៈ បណ្ឌិតគប្បីជ្រាប ដោយន័យនេះឯង ។ សូម្បីក្នុងវិភង្គ ក៏លោកពោលហើយថា "ទាំងវិតក្កៈ ទាំងវិចារៈនេះ ជាធម៌ស្ងប់រម្ងាប់ហើយ ជាធម៌រម្ងាប់ហើយ ជាធម៌ចូលទៅស្ងប់ហើយ ជាធម៌តាំងនៅមិនបាន ជាធម៌សាបសូន្យហើយ ជាធម៌មិនផុសផុរ ជាធម៌មិនកំរើកជាធម៌ក្រៀមហើយ ជាធម៌ក្រៀមស្ងួតហើយ ជាធម៌ធ្វើឲ្យអស់រលីងហើយ ដោយបការដូច្នេះ

ហេតុនោះ ឈាននេះ ទើបឈ្មោះថា មិនមានវិតក្កៈ មិនមានវិចារៈ” ។

ក្នុងអធិការនេះ អាចារ្យអ្នកចោទសួរថា: “ក៏សេចក្តីអធិប្បាយនេះ សម្រេចហើយ ដោយពាក្យនេះឯងថា “ព្រោះវិតក្កៈ និង វិចារៈ ស្ងប់រម្ងាប់” ដូច្នេះ មិនមែនទេឬ, កាលបើដូច្នោះ ព្រោះហេតុអ្វីទៅ បានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា: មិនមានវិតក្កៈ មិនមានវិចារៈ ដូច្នេះម្តងទៀត ?” ។

ឆ្លើយថា: “សេចក្តីអធិប្បាយនេះ សម្រេចហើយ យ៉ាងដូច្នេះឯងមែនពិត, តែពាក្យថា “វិតក្កវិចារានំ វូបសមា” នោះ មិនមែនជាពាក្យសំដែងនូវសេចក្តីពោលនោះទេ, ក្រែងយើងបានពោលមកហើយថា: ក៏ពាក្យថា “ព្រោះវិតក្កៈ និង វិចារៈ ស្ងប់រម្ងាប់” នេះ គឺព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះ ដើម្បីសំដែងថា “ព្រោះប្រព្រឹត្តកន្លងនូវអង្គជ្រោកជ្រាកៗ ការសម្រេចនូវឈានទាំងឡាយដទៃ អំពីបឋមជ្ឈាន មានទុតិយជ្ឈានជាដើម រមែងមាន” ដូច្នេះ មិនមែនទេឬ?, ន័យមួយទៀត ពាក្យថា “វិតក្កវិចារានំ វូបសមា” នេះ ជាពាក្យសំដែង នូវហេតុនៃទុតិយជ្ឈាននោះ ជាសម្បសាទនៈ និងជាឯកោទិភាព យ៉ាងនេះថា “ឈាននេះជាសម្បសាទនៈ ព្រោះចូលទៅរម្ងាប់នូវវិតក្កៈ និង វិចារៈទាំងឡាយ, មិនមែនព្រោះការចូលទៅរម្ងាប់ នៃកិលេសដែលដុះឡើង តាមកាលទេ និង ជាឯកោទិភាព ក៏ព្រោះកិរិយាស្ងប់រម្ងាប់ទៅនៃវិតក្កៈ និង វិចារៈទាំងឡាយ, មិនមែនព្រោះការលះបង់នូវនីវរណៈ ដូចជាឧបចារជ្ឈានទេ និង មិនមែនព្រោះកិរិយាប្រាកដនៃអង្គ ដូចជាបឋមជ្ឈានទេ” ដូច្នេះផង, មួយទៀត ពាក្យនោះ ជាពាក្យសំដែងនូវហេតុនៃទុតិយជ្ឈាននោះ ជាអវិតក្កៈ និង ជាអវិចារៈ យ៉ាងនេះថា “ឈាននេះ ឈ្មោះថា អវិតក្កៈ អវិចារៈ



ព្រោះការស្ងប់រម្ងាប់ទៅ នៃវិតក្កៈ និង វិចារៈទាំងឡាយ, មិនមែនព្រោះកិរិយាមិនមាននៃវិតក្កៈ និង វិចារៈ ដូចជាតតិយជ្ឈាន និង ចតុត្ថជ្ឈានទាំងឡាយ និង ដូចជាវិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណ ជាដើមទេ” ដូច្នេះផង, មិនមែនជាពាក្យសំដែងត្រឹមតែកិរិយាមិនមាននៃវិតក្កៈ និង វិចារៈប៉ុណ្ណោះទេ, ចំណែកពាក្យថា “អវិតក្កំ អវិចារំ” នេះ ជាពាក្យសំដែងត្រឹមតែការមិនមាននៃវិតក្កៈ និង វិចារៈប៉ុណ្ណោះឯង ព្រោះហេតុនោះ ពាក្យថា “អវិតក្កំ អវិចារំ” នោះ សូម្បីព្រះមានព្រះភាគត្រាស់មុនហើយក៏ដោយ ក៏គួរតែត្រាស់មែនពិត ។

(១០១) បទថា “សមាធិជំ” សេចក្តីថា (បីតិ និង សុខៈ) កើតហើយអំពីសមាធិ ក្នុងបឋមជ្ឈាន ឬ អំពីសម្បយុត្តសមាធិ ។ បណ្តាសមាធិទាំងពីរនោះ សូម្បីបឋមជ្ឈាន ក៏កើតអំពីសម្បយុត្តសមាធិ ក៏ពិតមែនហើយ បើទុកជាដូច្នោះ សមាធិនេះឯង គួរនូវភាពដែលបុគ្គលគប្បីហៅថា “សមាធិ” ព្រោះមិនកំរើកញាប់ញ័រផង ព្រោះថ្លាស្អាតល្អក្រៃលែងផង ព្រោះការប្រាសចាកការកំរើក នៃវិតក្កៈ និង វិចារៈ ។ ព្រោះហេតុនោះ ដើម្បីសរសើរនូវសមាធិនេះ ទើបព្រះមានព្រះភាគ ត្រាស់តែទុតិយជ្ឈាននេះប៉ុណ្ណោះ ថា “កើតអំពីសមាធិ” ។

បទថា “បីតិសុខំ” នេះ មានន័យដូចបានពោលមកហើយនុ៎ះឯង។

បទថា “ទុតិយំ” គឺ ឈាននេះ ឈ្មោះថា ជាទីពីរ ព្រោះមានលំដាប់នៃចំនួន ។ ឈាននេះ ឈ្មោះថា ជាទីពីរ ព្រោះព្រះយោគី ចូលនូវឈាននេះទីពីរ ។

ចំណែកពាក្យណា ដែលយើងពោលហើយថា “ទុតិយជ្ឈាន លះអង្គ ២ ប្រកបដោយអង្គ ៣” ដូច្នេះ, បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុង

ពាក្យនោះ (តទៅ) ។ ភាវៈនៃឈាននេះ លះអង្គ ២ បណ្ឌិតគប្បីជ្រាប ដោយអំណាចការលះវិតក្កៈ និង វិចារៈទាំងឡាយ ។ ចំណែកនីវរណៈទាំងឡាយ គឺព្រះយោគីលះបង់ ក្នុងខណៈនៃឧបចារៈ នៃបឋមជ្ឈាន យ៉ាងណា, វិតក្កៈ និង វិចារៈទាំងឡាយ គឺព្រះយោគីលះបង់ ក្នុងខណៈនៃទុតិយជ្ឈាននេះ យ៉ាងនោះ មិនបានឡើយ ។ តែក្នុងខណៈនៃអប្បនាឈាននេះ រមែងកើតឡើង វៀរហើយចាកវិតក្កៈ និង វិចារៈទាំងឡាយនោះមែនពិត ។ ព្រោះហេតុនោះ វិតក្កៈ និង វិចារៈទាំងនោះ ទើបលោកហៅថា “ជាអង្គដែលសម្រាប់លះនៃទុតិយជ្ឈាននោះ” ។ ចំណែកភាវៈនៃឈាននេះ ប្រកបព្រមដោយអង្គ ៣ បណ្ឌិត គប្បីជ្រាប ដោយអំណាចការកើតឡើងនៃអង្គទាំង ៣ នេះ គឺៈ បីតិ, សុខៈ ចិត្តេកគ្គតា ។ ព្រោះហេតុនោះ ពាក្យឯណា ដែលលោកពោលហើយ ក្នុងវិភង្គ ថា “សេចក្ដីជ្រះថ្លាស៊ប់ បីតិ សុខៈ ភាពនៃចិត្តមានអារម្មណ៍តែ១ ឈ្មោះថាឈាន” ដូច្នេះ, ពាក្យនោះ គឺលោកពោលហើយដោយបរិយាយ ដើម្បីសំដែងនូវឈាន ព្រមទាំងបរិក្ខារ ។ តែបើលើកលែងសេចក្ដីជ្រះថ្លាស៊ប់ហើយ ទុតិយជ្ឈាននេះ មានអង្គ ៣ ប៉ុណ្ណោះ ដោយអំណាចនៃអង្គទាំងឡាយដែលដល់នូវលក្ខណៈនៃការចូលទៅសំឡឹង ដោយនិប្បរិយាយ ។ សមដូចជាពាក្យដែលលោកពោលថា “សួរថាៈ ក្នុងសម័យនោះ ឈានប្រកបដោយអង្គ ៣ តើដូចម្ដេច?, ឆ្លើយថាៈ ឈានប្រកបដោយអង្គ ៣ គឺ ៈ បីតិ, សុខៈ, ភាពនៃចិត្តមានអារម្មណ៍តែមួយ” ដូច្នេះ ។ ពាក្យដ៏សេស មានន័យគឺលោកពោលហើយ ក្នុងបឋមជ្ឈានទុំះឯង ។

(តតិយជ្ឈាន)

ក៏កាលបើព្រះយោគី បានទុតិយជ្ឈាននោះ យ៉ាងដូច្នេះហើយ, ព្រះ



យោគី ត្រូវមានសេចក្ដីប្រព្រឹត្តិឲ្យស្ទាត់ ដោយអាការៈទាំងឡាយ ៥ តាមន័យដែលបានពោលមកហើយទុំះឯង ចេញចាកទុតិយជ្ឈាន ដែលស្ទាត់ហើយ ឃើញទោស ក្នុងទុតិយជ្ឈាននោះថា “សម្បត្តិនេះ មានវិតក្កៈ និង វិចារៈ ជាសត្រូវនៅជិត” ដូច្នេះផង ថា “សម្បត្តិនេះ ជាធម្មជាតិមានកម្លាំងខ្សោយ” ព្រោះភាវៈនៃបីតិដែលលោកពោលហើយថា “ការសប្បាយរីករាយនៃចិត្តដែលទៅហើយ ក្នុងបីតិ ក្នុងទុតិយជ្ឈាននោះឯណាទុំះឯង, ព្រោះការសប្បាយរីករាយនៃចិត្តនោះ ទុតិយជ្ឈាននោះ ទើបលោកហៅថា ជាអង្គដ៏ជ្រោកជ្រាក” ដូច្នេះ ជាធម្មជាត ដ៏គ្រោតគ្រាត” ដូច្នេះផង ហើយធ្វើទុកក្នុងចិត្តនូវតតិយជ្ឈាន ដោយថាជាធម៌ល្អិត គប្បីគ្របសង្កត់នូវសេចក្ដីពេញចិត្ត ក្នុងទុតិយជ្ឈាន ហើយធ្វើសេចក្ដីព្យាយាម ដើម្បីបានតតិយជ្ឈាន ។

លំដាប់នោះឯង កាលបើព្រះយោគីនោះ ចេញចាកទុតិយជ្ឈាន ហើយ មានសតិ ដឹងច្បាស់ ពិចារណាអង្គឈានទាំងឡាយ, បីតិ រមែងតាំងឡើងប្រាកដ ដោយថាជាធម្មជាតដ៏គ្រោតគ្រាត, សុខៈ និង ឯកគ្គតា រមែងតាំងឡើងប្រាកដ ដោយថាជាធម្មជាតដែលល្អិត ក្នុងកាលណា, ក្នុងកាលនោះ កាលព្រះយោគីនោះ ធ្វើទុកក្នុងចិត្តរឿយៗ នូវនិមិត្តនោះឯង ដោយបរិកម្ម ថា “បឋវី បឋវី” ដូច្នេះ ដើម្បីលះបង់នូវអង្គដែលគ្រោតគ្រាត និង ដើម្បីបានចំពោះនូវអង្គដ៏ល្អិត, មនោទ្វារាវជ្ជនចិត្ត កាត់ផ្ដាច់នូវភវង្គៈ (ដោយគិត) ថា “តតិយជ្ឈាន រមែងកើតឡើង ក្នុងកាលឥឡូវនេះ” ហើយធ្វើនូវបឋវីកសិណនោះឯង ឲ្យជាអារម្មណ៍ ទើបកើតឡើង ។ បន្ទាប់ពីនោះមក ជវនមួយ ជារូបាវចរចិត្ត ប្រកបដោយតតិយជ្ឈាន ក្នុងទីបំផុតនៃជវនទាំងឡាយណា, ជវនទាំងឡាយនោះ ៤

ឬ ៥ តែងស្ទុះទៅ ក្នុងអារម្មណ៍នោះឯង, ជវនដ៏សេស ជាកាមាវចរ-ចិត្ត តាមន័យដែលខ្ញុំបានពោលមកហើយនុ៎ះឯង ដោយប្រការដូច្នេះ ។

ក៏ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះយោគីនោះ ព្រោះនឿយណាយចាកបីតិផង ជាអ្នកមានចិត្តព្រងើយផង មានសតិផង ជាអ្នកដឹងច្បាស់ផង គង់នៅ ថែមទាំងសោយនូវសេចក្តីសុខ ដោយកាយផង ឈ្មោះថា ចូលទៅសម្រេចសម្រាន្តនៅឈានទី៣ នោះ ដែលព្រះអរិយៈទាំងឡាយ ពោល (សរសើរ) ថា "(ព្រះយោគីនោះ) ជាអ្នកមានចិត្តព្រងើយ មានសតិ ជាអ្នកមានប្រក្រតីនៅជាសុខ" ដូច្នេះ ។ តតិយជ្ឈានជាបឋវីកសិណ ដែលលះអង្គមួយ ប្រកបដោយអង្គ ២ មានលំអ ៣ យ៉ាង បរិបូណ៌ដោយលក្ខណៈ១០ ជាឈានគឺព្រះយោគីនោះបានហើយយ៉ាងដូច្នេះឯង ។

ក្នុងបាឋៈទាំងនោះ បាឋៈ ថា "ព្រោះនឿយណាយ ចាកបីតិផង" ដូច្នេះ មានវិនិច្ឆ័យថាៈ ការនឿយណាយក្តី ការប្រព្រឹត្តិកន្លងក្តី នូវបីតិមានប្រការដូចពោលមកហើយ ឈ្មោះថា វិរាគៈ ។ ក៏ ច សព្ទ ក្នុងចន្លោះ នៃបទទាំង ២ មានសេចក្តីថា ប្រមូលមក ។ ច សព្ទនោះប្រមូលមក នូវការចូលទៅស្ងប់រម្ងាប់ ឬ នូវការចូលទៅស្ងប់រម្ងាប់នៃវិតក្កៈ និង វិចារៈ ។ ក្នុងសេចក្តីទាំង ២ នោះ ច សព្ទប្រមូលមកនូវការចូលទៅស្ងប់រម្ងាប់តែម្យ៉ាង ក្នុងកាលណា, ក្នុងកាលនោះ បណ្ឌិតគប្បីជ្រាបសេចក្តីប្រកប យ៉ាងនេះថា "ព្រោះការនឿយណាយ ចាកបីតិផង ព្រោះការចូលទៅស្ងប់រម្ងាប់ក្រៃលែង នូវកិលេសតិចតួចផង" ។ ក៏ វិរាគសព្ទ ក្នុងសេចក្តីប្រកបនេះ មានសេចក្តីថា នឿយណាយ ។ ព្រោះហេតុនោះ បណ្ឌិត គប្បីឃើញសេចក្តីអធិប្បាយនេះថា "ព្រោះ



នឿយណាយចាកបីតិផង ព្រោះចូលទៅស្ងប់រម្ងាប់បីតិផង" ។ តែថា ច សព្ទ ប្រមូលមកនូវការចូលទៅស្ងប់រម្ងាប់នូវវិតក្កៈ និង វិចារៈ ក្នុងកាលណា, ក្នុងកាលនោះ បណ្ឌិត គប្បីជ្រាបសេចក្តីប្រកប យ៉ាងនេះថា "ព្រោះការនឿយណាយចាកបីតិផង ព្រោះការចូលទៅស្ងប់រម្ងាប់នូវវិតក្កៈ និង វិចារៈទាំងឡាយ ដោយក្រៃលែង តិចតួចទៀតផង" ។ ក៏ វិរាគសព្ទ ក្នុងសេចក្តីប្រកបនេះ មានសេចក្តីថា ប្រព្រឹត្តកន្លង ។ ព្រោះហេតុនោះ បណ្ឌិត គប្បីឃើញសេចក្តីអធិប្បាយនេះ ថា "ព្រោះការប្រព្រឹត្តិកន្លងបីតិផង ព្រោះការចូលទៅស្ងប់រម្ងាប់ នូវវិតក្កៈ និង វិចារៈទាំងឡាយផង" ដូច្នេះ ។

វិតក្កៈ និង វិចារៈទាំងឡាយនេះ ចូលទៅស្ងប់រម្ងាប់ហើយ ក្នុងទុតិយជ្ឈាននុ៎ះឯង ក៏ពិតមែនហើយ ក៏ប៉ុន្តែពាក្យថាៈ វិតក្កៈ និង វិចារៈនេះ លោកពោលហើយ ដើម្បីសំដែង នូវមគ្គនៃឈាននេះផង ដើម្បីពោលសរសើរ នូវឈាននេះផង ។ មែនពិត កាលបើលោក ពោលថា "ព្រោះចូលទៅស្ងប់រម្ងាប់នូវវិតក្កៈ និង វិចារៈទាំងឡាយផង" ដូច្នេះ, ពាក្យនេះថា "ការចូលទៅស្ងប់រម្ងាប់នូវវិតក្កៈ និង វិចារៈ ជាមគ្គនៃឈាននេះ ដោយពិត" ដូច្នេះ រមែងប្រាកដ ។ ក៏ការលះបង់ ដែលលោកពោល យ៉ាងនេះថា "ព្រោះការលះបង់នូវសំយោជនៈទាំងឡាយ ៥ ដែលជាចំណែកខាងក្រោមមានសក្កាយទិដ្ឋិជាដើម សូម្បីមិនទាន់បានលះបង់ហើយ ក្នុងអរិយមគ្គទី៣" ដូច្នេះ ក៏ជាការពោលសរសើរគុណជាគ្រឿងញុំាងសេចក្តីខ្មីឃ្មាត ឲ្យកើតឡើង ដល់ព្រះយោគីទាំងឡាយអ្នកមានសេចក្តីខ្វល់ខ្វាយខ្នះខ្នែង ដើម្បីបានសំរេច នូវតតិយមគ្គនោះយ៉ាងណា, កាលលោកពោលការចូលទៅរម្ងាប់នូវវិតក្កៈ និង វិចារៈ

ទាំងឡាយ សូម្បីមិនទាន់ចូលស្ងប់រម្ងាប់ ក្នុងតតិយជ្ឈាននេះ ក៏ចាត់ថាជាការពោលសរសើរ (នូវតតិយជ្ឈាន នោះ) យ៉ាងដូច្នោះដែរ ។ ព្រោះហេតុនោះ ទើបលោកពោលសេចក្តីអធិប្បាយនេះថា "ព្រោះប្រព្រឹត្តកន្លង នូវបីតិផង ព្រោះចូលទៅស្ងប់រម្ងាប់ នូវវិតក្កៈ និង វិចារៈ ទាំងឡាយផង" ដូច្នេះ ។

(១០២) បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបាលីនេះ ថា "ឧបេក្ខកោ ច វិហរតិ" ដូច្នេះ តទៅ ។ ធម្មជាតឯណា ឃើញអំពីការចូលទៅកើត ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា ឧបេក្ខា មានអធិប្បាយថា: ឃើញដ៏ស្មើ គឺឃើញមិនធ្លាក់ចុះទៅ ក្នុងបក្សពួក ។ បុគ្គលអ្នកប្រកបព្រម ដោយតតិយជ្ឈាន លោកហៅថា ជាអ្នកព្រងើយ ព្រោះប្រកបព្រមដោយឧបេក្ខានោះ ដែលភ្លៀវភ្លាទូលាយ មានកម្លាំង ។ ក៏ឧបេក្ខា មាន ១០ យ៉ាង គឺ : ឆឡង្គុបេក្ខា, ព្រហ្មវិហារុបេក្ខា, ពោជ្ឈង្គុបេក្ខា, វីរិយុបេក្ខា, សង្ខារុបេក្ខា, វេទនូបេក្ខា, វិបស្សនូបេក្ខា, តត្រមជ្ឈត្តុបេក្ខា, ឈានុបេក្ខា, បរិសុទ្ធុបេក្ខា ។

បណ្តាឧបេក្ខាទាំង ១០ នោះ ឧបេក្ខាណា មានអាការៈ ជាហេតុមិនលះបង់នូវប្រក្រតីភាពដ៏បរិសុទ្ធ ក្នុងគន្លងនៃអារម្មណ៍ទាំង ៦ ដែលជាទីប្រាថ្នា និង មិនជាទីប្រាថ្នា ក្នុងទ្វារទាំង ៦ របស់ព្រះខីណាស្រព ដែលមកហើយ យ៉ាងនេះថា "ភិក្ខុ ជាព្រះខីណាស្រព ក្នុងសាសនានេះ ឃើញរូប ដោយចក្ខុ ជាអ្នកមិនមានចិត្តត្រេកអរ មិនអាក់អន់ចិត្ត សោះឡើយ និង ជាអ្នកមានសតិ ដឹងខ្លួនច្បាស់ នៅជាព្រងើយៗ" ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា ឆឡង្គុបេក្ខា ។

ចំណែកឯឧបេក្ខាណា មានអាការៈ មានភាពជាកណ្តាល ក្នុង



សត្វទាំងឡាយ ដែលមកហើយ យ៉ាងដូច្នេះថា "ភិក្ខុ មានចិត្តប្រកបព្រមដោយឧបេក្ខា ផ្សាយទៅកាន់ទិសមួយ គង់នៅ" ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា ព្រហ្មវិហារុបេក្ខា ។

ឧបេក្ខាណា មានអាការៈមានភាពជាកណ្តាល ដល់សហជាតធម៌ទាំងឡាយ ដែលមកហើយ យ៉ាងនេះថា "ភិក្ខុ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ" ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា ពោជ្ឈង្គុបេក្ខា ។

ចំណែកឧបេក្ខាណា ពោលគឺសេចក្តីព្យាយាម ដែលបុគ្គលបានប្រារព្ធហើយ មិនតឹងពេក មិនធូរពេក ដែលមកហើយ យ៉ាងនេះថា "ភិក្ខុ ធ្វើទុកក្នុងចិត្ត នូវឧបេក្ខានិមិត្ត អស់កាលតាមកាល" ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា វីរិយុបេក្ខា ។

ឧបេក្ខាណា គឺវិបស្សនាបញ្ញា ដែលពិចារណានូវបាបធម៌ និងអង្គដែលត្រូវលះបង់ មាននីវរណៈជាដើម ហើយតាំងចិត្តស៊ប់ មានភាពជាកណ្តាល ក្នុងការប្រកាន់យក ដែលមកហើយ យ៉ាងនេះថា "សួរថា: សង្ខារុបេក្ខា មានប៉ុន្មាន តែងកើតឡើង ដោយអំណាចសមាធិ, សង្ខារុបេក្ខា មានប៉ុន្មាន តែងកើតឡើង ដោយអំណាច នៃវិបស្សនា?, ឆ្លើយថា: សង្ខារុបេក្ខា ៨ តែងកើតឡើង ដោយអំណាចនៃសមាធិ, សង្ខារុបេក្ខា ១០ តែងកើតឡើង ដោយអំណាចនៃវិបស្សនា" ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា សង្ខារុបេក្ខា ។

ចំណែកឧបេក្ខាណា ដែលមានការសំគាល់ថា មិនជាទុក្ខ មិនជាសុខ ដែលមកហើយ យ៉ាងនេះថា "ចិត្តជាកាមាវចរកុសល ជាចិត្តកើតឡើងហើយ ប្រកបដោយឧបេក្ខា ក្នុងសម័យណា" ដូច្នេះ, ឧបេក្ខានេះ

ឈ្មោះថា វេទនូបេក្ខា ។

ឯឧបេក្ខាណា មានភាពជាព្រងើយៗ ក្នុងការពិចារណា ដែលមកហើយ យ៉ាងនេះថា “វត្ថុណា មាន, វត្ថុណា កើតហើយ, ព្រះយោគីលះបង់ នូវវត្ថុនោះ រមែងបានចំពោះ នូវឧបេក្ខា” ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា វិបស្សនូបេក្ខា ។

ចំណែកឧបេក្ខាណា ជាធម៌គ្រប់គ្រងសហជាតធម៌ទាំងឡាយ ឲ្យមានភាពស្មើគ្នា ដែលមកហើយ ក្នុងយេវាបនកធម៌ទាំងឡាយ មានឆន្ទាគតិជាដើម, ឧបេក្ខានេះ ឈ្មោះថា តត្រមជ្ឈត្តុបេក្ខា ។

ឧបេក្ខាណា មិនញ៉ាំងការធ្លាក់ចុះទៅ ក្នុងធម៌ដែលជាបក្សពួក ឲ្យកើតឡើង ក្នុងតតិយជ្ឈាននោះ សូម្បីដែលមានសុខជាទីបំផុត ដ៏លើស ដែលមកហើយ យ៉ាងនេះថា “ព្រះយោគី ជាអ្នកព្រងើយៗ គង់នៅផង” ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា ឈានុបេក្ខា ។

ឯឧបេក្ខាណា បរិសុទ្ធស្អាតចាកធម៌ ដែលជាសត្រូវទាំងពួង មានអាការៈមិនខ្វល់ខ្វាយ សូម្បីក្នុងការរម្ងាប់នូវធម៌ដែលជាសត្រូវ ដែលមកហើយ យ៉ាងនេះថា “(ភិក្ខុចូលដល់) ចតុត្ថជ្ឈាន ដែលមានសេចក្ដីបរិសុទ្ធិនៃសតិ ដែលកើតអំពីឧបេក្ខា” ដូច្នេះ, ឧបេក្ខានេះ ឈ្មោះថា បរិសុទ្ធុបេក្ខា ។

បណ្ដាឧបេក្ខាទាំង ១០ នោះ ឆឡង្គុបេក្ខា ក្ដី, ព្រហ្មវិហារុបេក្ខា ក្ដី, ពោជ្ឈង្គុបេក្ខាក្ដី, តត្រមជ្ឈត្តុបេក្ខាក្ដី, ឈានុបេក្ខាក្ដី, បរិសុទ្ធុបេក្ខាក្ដី ដោយសេចក្ដី បានដល់ តត្រមជ្ឈត្តុបេក្ខាតែ១ ប៉ុណ្ណោះឯង។ ឯសេចក្ដីផ្សេងគ្នានេះ នៃឧបេក្ខាទ៊ុះ ដោយកិរិយាផ្សេងគ្នា ដែលមិនបានកំណត់នោះៗ ដូចជាការផ្សេងគ្នា នៃសត្វសូម្បីមានតែម្នាក់ ដោយអំណាច នៃ



ពាក្យ មានពាក្យថា ក្មេងប្រុស, កម្លោះ, ចាស់, សេនាបតី និង ព្រះរាជាជាដើម, ព្រោះហេតុនោះ ក្នុងឧបេក្ខាទាំង ៦ នោះ បណ្ឌិតគប្បីជ្រាបថា “ឆឡង្គុបេក្ខា មានក្នុងទីណា, ឧបេក្ខាទាំងឡាយ(៥) មានពោជ្ឈង្គុបេក្ខាជាដើម មិនមាន ក្នុងទីនោះទេ, ឬថា ពោជ្ឈង្គុបេក្ខា មានក្នុងទីណា, ឧបេក្ខាទាំងឡាយ (៥) មានឆឡង្គុបេក្ខាជាដើម មិនមាន ក្នុងទីនោះទេ” ដូច្នេះ ។ ក៏ភាពនៃឧបេក្ខាទាំង ៦ នោះ ជាឧបេក្ខាតែមួយដោយសេចក្ដីយ៉ាងណា, សូម្បីភាវៈនៃសង្ខារុបេក្ខា និង វិបស្សនូបេក្ខាទាំងឡាយ ជាឧបេក្ខាតែ១ ដោយសេចក្ដី ក៏យ៉ាងនោះដែរ ។ ពិតមែនហើយ ឧបេក្ខាទាំង ២ នោះ គឺបញ្ញាហ្នឹងឯង តែផ្សេងគ្នា ដោយចំណែកពីរ ដោយអំណាចនៃកិច្ច ។ ប្រៀបដូចជាកាលបុរសកាន់យកកំណាត់ឈើ មានសណ្ឋានដូចជើងពពែ (ឈើចម្ពាម) ស្វែងរកពស់ ដែលបានលូនចូលផ្ទះ ក្នុងវេលាល្ងាច ដល់ឃើញពស់នោះអែបនៅក្នុងជង្រុកអង្កាមហើយ ឈ្ងោកមើល ដោយគិតថា “ពស់ ឬក៏ មិនមែនពស់ទេ” លុះឃើញផ្ទត់-ក ៣ ជាន់ហើយ ក៏មិនមានសេចក្ដីសង្ស័យ ភាពនៃចិត្តជាកណ្ដាល ក្នុងការពិចារណាថា “ពស់ ឬក៏ មិនមែនជាពស់” រមែងមាន យ៉ាងណាមិញ, កាលបើឃើញលក្ខណៈ ៣ ដោយវិបស្សនាញាណហើយ ភាពនៃចិត្តព្រងើយឯណា ក្នុងការពិចារណា នូវភាវៈនៃសង្ខារទាំងឡាយ ថា ជារបស់ទៀង ឬក៏ មិនទៀងជាដើម រមែងកើតឡើងដល់ព្រះយោគី ដែលបានបំពេញវិបស្សនាហើយ ក៏យ៉ាងដូច្នោះដែរ, ភាពព្រងើយនេះ ឈ្មោះថា វិបស្សនូបេក្ខា ។

តែកាលដែលបុរសនោះ យកឈើចម្ពាម ចាប់ពស់បានជាប់ហើយ ក៏ស្វែងរកអាការៈ ដើម្បីនឹងលែងទ៊ុះឯង ថា “អញ មិនបៀតបៀនពស់

នេះផង មិនឲ្យពស់នេះវាចឹកខ្លួនអញផង លែងវាទៅ តើដូចម្ដេចហ្ន៎” ដូច្នេះ, ភាពនៃចិត្តព្រងើយ ក្នុងការកាន់យក រមែងមាន យ៉ាងណាមិញ, កាលបើព្រះយោគីឃើញនូវភព ៣ ហាក់ដូចជាត្រូវភ្លើងឆេះសព្វហើយ ព្រោះលក្ខណៈ ៣ ជាធម្មជាត គឺខ្លួនបានឃើញរូបហើយ ភាពនៃចិត្តព្រងើយ ក្នុងការប្រកាន់យកនូវសង្ខារណា រមែងមាន ក៏យ៉ាងនោះដែរ, ភាពនៃចិត្តព្រងើយនេះ ឈ្មោះថា សង្ខារុបេក្ខា ។

បើតាមទំនងនេះ កាលបើវិបស្សនូបេក្ខា សម្រេចហើយ, សូម្បីសង្ខារុបេក្ខា ក៏ជាធម្មជាតសម្រេចហើយ មែនពិត ។ ក៏ឧបេក្ខានេះផ្សេងគ្នាដោយចំណែកពីរ ដោយកិច្ច ពោលគឺភាពជាកណ្ដាល ក្នុងការពិចារណា និង កិរិយាប្រកាន់មាំ (នូវសង្ខារ)នេះ យ៉ាងដូច្នេះ ។

ចំណែកវីរិយុបេក្ខា និង វេទនូបេក្ខា ប្លែកផ្សេងអំពីគ្នានឹងគ្នាផង ដោយសេចក្ដី ក៏ប្លែកផ្សេងគ្នាអំពីឧបេក្ខាទាំងឡាយ ដ៏សេសផង មែនពិត យ៉ាងដូច្នេះឯង ។

បណ្ដាឧបេក្ខាទាំងនេះ ឈានុបេក្ខា គឺព្រះដ៏មានព្រះភាគ ទ្រង់បំណងយកហើយ ក្នុងទីនេះ ដោយបការៈដូច្នេះ ។ ឈានុបេក្ខានោះ មានភាពព្រងើយ ជាលក្ខណៈ មានការមិនចងចិត្ត ជាកិច្ច មានការមិនខ្វល់ខ្វាយ ជាផល មានការនឿយណាយចាកបីតិ ជាហេតុ ។

អាចារ្យអ្នកចោទ ពោល ក្នុងអធិការនេះ ថា “ចុះឈានុបេក្ខានេះដោយសេចក្ដីគឺតត្រមជ្ឈត្តុបេក្ខាហ្នឹងឯង មួយវិញទៀត តត្រមជ្ឈត្តុបេក្ខានោះ មានក្នុងបឋមជ្ឈាន និង ទុតិយជ្ឈាន មិនមែនទេឬ? ព្រោះហេតុនោះ ឧបេក្ខានេះ ជាឧបេក្ខាដែលព្រះមានព្រះភាគ គប្បីត្រាស់យ៉ាងនេះថា “ក៏ព្រះយោគី ជាអ្នកព្រងើយ គង់នៅ” ដូច្នេះ ក្នុងបឋមជ្ឈាន និង



ទុតិយជ្ឈាននោះផងដែរ, ព្រោះហេតុអ្វី បានជាព្រះអង្គមិនត្រាស់ឧបេក្ខានោះ ? ” ដូច្នេះ ។

អាចារ្យអ្នកឆ្លើយ ឆ្លើយថា “ព្រោះឧបេក្ខា ក្នុងឈានទាំង២ នោះ មានកិច្ចមិនទាន់ច្បាស់លាស់នៅឡើយ ។ មែនពិត កិច្ចនៃឧបេក្ខានោះ ក្នុងឈានទាំង ២ នោះ ជាកិច្ចមិនទាន់ច្បាស់លាស់ ព្រោះត្រូវធម៌ទាំងឡាយដែលជាសត្រូវមានវិតក្កៈជាដើម គ្របសង្កត់ហើយ ។ ចំណែកឧបេក្ខានេះ ក្នុងតតិយជ្ឈាននេះ ជាឧបេក្ខា ដូចជាមានក្បាលងើបឡើងហើយ ជាធម្មជាតមានកិច្ចច្បាស់លាស់កើតហើយ ព្រោះភាវៈនៃឧបេក្ខានោះ គឺវិតក្កៈ, វិចារៈ និង បីតិ គ្របសង្កត់មិនបាន, ព្រោះហេតុនោះ ព្រះមានព្រះភាគ ត្រាស់ឧបេក្ខានោះ” ដូច្នេះ ។

អដ្ឋកថា ជាគ្រឿងពណ៌នាសេចក្ដីដោយសព្វគ្រប់ នៃបាលីនេះថា “ឧបេក្ខកោ ច វិហរតិ”ដូច្នេះ ចប់ហើយ ។

(១០៣) ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងបាលីនេះថា “សតោ ច សម្បជានោ” ដូច្នេះ (តទៅ) ។ ភិក្ខុណា រលឹក ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា អ្នករលឹក ។ ភិក្ខុណា ដឹងច្បាស់ដោយប្រពៃ ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា អ្នកដឹងច្បាស់ដោយប្រពៃ ។ សតិ និង សម្បជញ្ញៈ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយបុគ្គល ។ បណ្ដាសតិ និង សម្បជញ្ញៈទាំង ២ នោះ សតិ មានការរលឹក ជាលក្ខណៈ មានការមិនភ្លេចជាកិច្ច មានការរក្សាជាផល ។ សម្បជញ្ញៈ មានការមិនវង្វេងជាលក្ខណៈ មានការពិចារណាជាកិច្ច មានការជ្រើសរើសជាផល ។

ក្នុងឈានទាំងនោះ សតិ និង សម្បជញ្ញៈនេះ មានសូម្បីក្នុងឈាន

ដែលមានខាងដើម ក៏ពិតមែនហើយ ព្រោះថាគុណជាតត្រឹមតែឧបចារៈ ក៏មិនសម្រេចដល់កិច្ចដែលភ្លេចភ្លាំងសតិ អ្នកមិនដឹងច្បាស់, មិនចាំបាច់ពោលថ្វីដល់អប្បនា តែព្រោះឈានទាំងឡាយនោះ ជាធម្មជាតគ្រោតគ្រាត ដំណើរនៃចិត្តជាដំណើរសុខ ដូចជាដំណើរ របស់បុរសដែលដើរលើភូមិ(ផ្ទៃរាប) ជាការស្រួលយ៉ាងនុ៎ះឯង, កិច្ចនៃសតិ និង សម្បជញ្ញៈ ក្នុងឈានទាំងនោះ ទើបមិនបានច្បាស់លាស់, តែព្រោះភាវៈនៃឈាននេះ ជាឈានដ៏ល្អិត ព្រោះលះបង់នូវអង្គដែលគ្រោតគ្រាតបាន ព្រះយោគីត្រូវប្រាថ្នាដំណើរនៃចិត្ត ដែលកិច្ចនៃសតិ និង សម្បជញ្ញៈ ផ្គងហើយតែម្យ៉ាង ប្រៀបដូចជាបុរសធ្វើដំណើរលើមុខកាំបិតកោរ យ៉ាងនោះឯង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះ (សតោ សម្បជានោ) តែក្នុងតតិយជ្ឈាននេះប៉ុណ្ណោះ ។

បណ្ឌិត គប្បីជ្រាបសេចក្តីអធិប្បាយ ដោយក្រៃលែងបន្តិចទៀត ។ កូនគោកំពុងបៅដោះមេ ត្រូវបុគ្គលនាំចេញពីមេហើយ មិនមានអ្នករក្សា ក៏រមែងចូលទៅរកមេគោម្តងទៀត យ៉ាងណា, សុខ ក្នុងតតិយជ្ឈាននេះ ត្រូវព្រះយោគីបម្រះចេញហើយអំពីបីតិ, សេចក្តីសុខនោះ គឺព្រះយោគីមិនបានរក្សា ដោយគ្រឿងរក្សាគឺសតិ និង សម្បជញ្ញៈ គប្បីចូលទៅរកបីតិម្តងទៀតដោយពិត ជាឈានប្រកបដោយបីតិវិញ ក៏យ៉ាងនោះដែរ ។ មួយទៀត បណ្ឌិតគប្បីជ្រាបថា ពាក្យថា "សតោ សម្បជានោ" នេះ គឺព្រះមានព្រះភាគត្រាស់ហើយ តែក្នុងតតិយជ្ឈាននេះ ដើម្បីទ្រង់សំដែងនូវសេចក្តីដ៏វិសេសនេះទៀតថា "សូម្បីសត្វទាំងឡាយ តែងរីករាយ ក្នុងសេចក្តីសុខផង, សេចក្តីសុខនេះ ក៏មានរសឆ្ងាញ់ក្រៃលែងផង ព្រោះមិនមានសុខដទៃក្រៃលែង ជាងសេចក្តីសុខ ក្នុងតតិយជ្ឈាននោះ, តែថា



ការមិនជាប់ចិត្ត ក្នុងសេចក្តីសុខ ក្នុងតតិយជ្ឈាននេះ រមែងមាន ដោយអានុភាពនៃសតិ និង សម្បជញ្ញៈ មិនមែនមាន ដោយប្រការៈដទៃឡើយ" ដូច្នេះឯង ។

(១០៤) ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបាលី ថា "សុខញ្ច កាយេន បដិសំវេទេតិ" នេះ (តទៅ) ។ ការចងចិត្ត ដោយការសោយនូវសេចក្តីសុខ មិនមានដល់ព្រះយោគីដែលបានតតិយជ្ឈាន ក៏ពិតមែនហើយ, កាលបើមានហេតុយ៉ាងនេះ សេចក្តីសុខដែលប្រកបដោយនាមកាយ របស់ព្រះយោគីនោះ ជាសេចក្តីសុខ ដែលប្រកបព្រមដោយនាមកាយ តាមដែលបាន ព្រោះហេតុណា, រូបកាយ របស់ព្រះយោគីនោះ ដែលរូបដ៏ប្រណីតក្រៃពេក តាំងឡើង ព្រមដោយនាមកាយនោះ ពាល់ត្រូវហើយ ព្រោះភាវៈនៃព្រះយោគីនោះ ជាបុគ្គលគឺសេចក្តីសុខឯណា ពាល់ត្រូវហើយ សូម្បីព្រះយោគីនោះចេញចាកឈានហើយ ក៏គប្បីសោយនូវសេចក្តីសុខ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សំដែង នូវសេចក្តីនេះ ទើបទ្រង់ត្រាស់ថា "សុខញ្ច កាយេន បដិសំវេទេតិ" ដូច្នេះ ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបាលីនេះថា "យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី " ដូច្នេះ ដូចតទៅនេះ បណ្ឌិតគប្បីជ្រាបដីកាជាគ្រឿងប្រកប ក្នុងតតិយជ្ឈាននេះ យ៉ាងនេះថា "ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់ប្រាប់ សំដែង បញ្ញត្តិ តែងតាំង បើកបង្ហាញ បែងចែក ធ្វើឲ្យរាក់ មានអធិប្បាយថា "ប្រកាសសរសើរ នូវបុគ្គលអ្នកបាននូវតតិយជ្ឈាននោះ ព្រោះហេតុនៃឈានណា ព្រោះដំណើរនៃឈានណា" ដូច្នេះ, សួរថា "ទ្រង់សរសើរ យ៉ាងដូច

ម្ដេច?” ។ ឆ្លើយថា: ទ្រង់ត្រាស់សរសើរថា “ព្រះយោគីជាអ្នកព្រងើយកន្តើយ មានសតិ មានប្រក្រតីនៅជាសុខ” ។ ព្រះយោគី ចូលទៅកាន់តតិយជ្ឈានទោះ ហើយគង់នៅ” ដូច្នេះ ។

សួរថា “ក៏ព្រោះហេតុអ្វី ទើបព្រះអរិយៈទាំងនោះ សរសើរនូវបុគ្គលដែលបានតតិយជ្ឈាននោះ យ៉ាងនេះ?” ។

ឆ្លើយថា “ព្រោះគួរដល់ការសរសើរ ។ មែនពិត បុគ្គលអ្នកបាននូវតតិយជ្ឈាននេះ ជាអ្នកព្រងើយ ក្នុងតតិយជ្ឈាន ដែលជាសុខ មានរសផ្អែមក្រៃពេក សូម្បីមិនទាន់ដល់នូវគុណជាត ជាគ្រឿងដល់ត្រើយនៃសេចក្ដីសុខក៏ដោយ ក៏ត្រូវគ្រឿងជាប់ជំពាក់ ដោយសេចក្ដីសុខ ក្នុងតតិយជ្ឈាននោះ ទាញមកមិនបាន ព្រោះហេតុណា, ព្រះយោគីនោះឈ្មោះថា ជាអ្នកមានសតិ ព្រោះភាវៈជាអ្នកមានសតិតាំងនៅមាំ រហូតដល់បីតិកើតឡើងមិនបាន និង រមែងសោយនូវសេចក្ដីសុខ ដែលមិនសៅហ្មង ជាសេចក្ដីសុខដែលព្រះអរិយៈប៉ងប្រាថ្នាហើយផង ជាសេចក្ដីសុខ ដែលព្រះអរិយៈសេពហើយពិតផង ដោយនាមកាយ ព្រោះហេតុណា, ព្រោះហេតុនោះ បុគ្គលអ្នកបាននូវតតិយជ្ឈាននោះ ទើបជាអ្នកគួរដល់ការសរសើរ ។ បណ្ឌិតគប្បីជ្រាបថា: ព្រោះគួរដល់ការសរសើរ ដូចបានពោលមកនេះ ព្រះអរិយៈទាំងនោះ កាលប្រកាសនូវគុណដែលជាហេតុគួរសរសើរ យ៉ាងនេះ ទើបសរសើរបុគ្គលអ្នកបានតតិយជ្ឈាននោះ យ៉ាងនេះថា “ជាអ្នកព្រងើយ មានសតិ មានប្រក្រតីនៅជាសុខ” ។

បទថា “តតិយំ” គឺ ឈាននេះ ជាឈាន ទី៣ ព្រោះមានលំដាប់នៃចំនួន ។ ឈាននេះ ឈ្មោះថា ជាឈាន ទី៣ ព្រោះព្រះយោគី ចូលឈាននេះ ជាទី៣ ដូច្នេះក៏បាន ។



ចំណែកពាក្យណា ដែលយើងពោលហើយថា “តតិយជ្ឈាន លះអង្គ១ ប្រកបព្រមដោយអង្គ២” ដូច្នេះ, បណ្ឌិតគប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងពាក្យនោះ (ដូចតទៅនេះ) ។ ភាពនៃតតិយជ្ឈាននោះ លះអង្គ ១ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃការលះនូវបីតិ ។ ក៏បីតិនេះនោះ គឺព្រះយោគីលះបង់ ក្នុងខណៈនៃអប្បនាទុំះឯង ដូចជាវិតក្កៈ និង វិចារៈ គឺព្រះយោគីលះបង់ ក្នុងខណៈនៃអប្បនា នៃទុតិយជ្ឈាន យ៉ាងនោះដែរ, ព្រោះហេតុនោះ បីតិនោះ ទើបលោក ពោលថា: ជាអង្គសម្រាប់លះនូវវិតក្កៈ និង វិចារៈនោះ ។ ចំណែកឯ តតិយជ្ឈាននោះ ជាឈានប្រកបដោយអង្គ ២ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃការកើតឡើង នៃអង្គទាំងឡាយ២ នេះ គឺ: សុខៈ ចិត្តេកគ្គតា ។ ព្រោះហេតុនោះ ពាក្យណាដែលយើងពោលហើយក្នុងវិភង្គថា “ឧបេក្ខា, សតិ និង សម្បជញ្ញៈ, សុខៈ, ភាពនៃចិត្តមានអារម្មណ៍តែ ១ ឈ្មោះថា ឈាន” ដូច្នេះ, ពាក្យនោះ គឺព្រះមានព្រះភាគត្រាស់ហើយ ដោយបរិយាយ ដើម្បីសំដែងនូវឈាននោះ ព្រមទាំងបរិក្ខារ ។ ចំណែក ឈានទី ៣ នេះ លើកលែងតែឧបេក្ខា សតិ និង សម្បជញ្ញៈ ចេញហើយ ជាឈានមានអង្គ ២ មែនពិត ដោយអំណាចអង្គទាំងឡាយ ដែលដល់នូវឧបនិជ្ឈានលក្ខណៈ ដោយនិប្បរិយាយ ។ សមដូចជាព្រះមានព្រះភាគ ត្រាស់ថា: សួរថា “ក្នុងសម័យនោះ ឈានប្រកបដោយអង្គ ២ គឺអ្វីខ្លះ?” ។ ឆ្លើយថា “គឺសុខៈ, ភាពនៃចិត្តមានអារម្មណ៍តែមួយ” ដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចយើងពោលមកហើយ ក្នុងបឋមជ្ឈានទុំះឯង ។

(ចតុត្ថជ្ឈាន)

(១០៥) លុះដល់ព្រះយោគី បានសម្រេចតតិយជ្ឈាននោះ យ៉ាង

នេះហើយ, ព្រះយោគីត្រូវមានសេចក្ដីប្រព្រឹត្តិឲ្យស្ទាត់ដោយអាការៈទាំងឡាយ ៥ តាមន័យដែលបានពោលមកហើយនុ៎ះឯង ចេញពីតតិយជ្ឈានដែលស្ទាត់ហើយ ឃើញនូវទោស ក្នុងតតិយជ្ឈាននោះ ថា “សម្បត្តិនេះមានសត្រូវគឺបីតិនៅជិត” ដូច្នេះផងថា “សម្បត្តិនេះ ឈ្មោះថាជាធម្មជាតមានកម្លាំងខ្សោយ” ព្រោះភាវៈនៃសុខៈដែលលោកពោលហើយ យ៉ាងនេះថា “ការចងចិត្តថាៈ សេចក្ដីសុខ ក្នុងតតិយជ្ឈាននោះឯណានុ៎ះឯង, ព្រោះការចងចិត្តនោះ តតិយជ្ឈាននោះ ទើបលោកហៅថា ជាអង្គ ដ៏គ្រោតគ្រាត ជាធម្មជាតដ៏គ្រោតគ្រាត” ដូច្នេះផង ហើយធ្វើទុកក្នុងចិត្តនូវចតុត្ថជ្ឈាន ថា ជាធម៌ល្អិត គប្បីគ្របសង្កត់នូវសេចក្ដីពេញចិត្ត ក្នុងតតិយជ្ឈានហើយ ធ្វើសេចក្ដីព្យាយាម ជាគ្រឿងប្រកប ដើម្បីបាននូវចតុត្ថជ្ឈាន ។

គ្រានោះ កាលព្រះយោគីនោះ ចេញចាកតតិយជ្ឈានហើយ មានសតិ ដឹងច្បាស់ ពិចារណានូវអង្គឈានទាំងឡាយ, សេចក្ដីសុខពោលគឺសោមនស្សដែលជាចេតសិកសុខ រមែងតាំងឡើងប្រាកដថា ជាធម្មជាតដ៏គ្រោតគ្រាត, ឧបេក្ខាវេទនា និង ចិត្តេកគ្គតា រមែងតាំងឡើង ប្រាកដថា ជាធម្មជាតដ៏ល្អិត ក្នុងកាលណា, ក្នុងកាលនោះ កាលព្រះយោគីនោះធ្វើទុកក្នុងចិត្តរឿយៗ នូវនិមិត្តនោះឯង ដោយបរិកម្ម ថា “បឋវី បឋវី” ដូច្នេះ ដើម្បីលះនូវអង្គដ៏គ្រោតគ្រាត និង ដើម្បីបានចំពោះនូវអង្គដ៏ល្អិត, មនោទ្វារាវជ្ជនចិត្ត កាត់ផ្ដាច់នូវភវង្គៈ (ដោយគិត) ថា “ចតុត្ថជ្ឈាន នឹងកើតឡើង ក្នុងកាលឥឡូវនេះ” ដូច្នេះហើយ ធ្វើបឋវីកសិណនោះឯងឲ្យជាអារម្មណ៍ ទើបកើតឡើង ។ បន្ទាប់ពីនោះ ជវនមួយ ជារូបាវចរចិត្តប្រកបដោយចតុត្ថជ្ឈាន ក្នុងទីបំផុត នៃជវនទាំងឡាយណា, ជវនទាំង



ឡាយនោះ ៤ ឬ ៥ រមែងកើតឡើង ក្នុងអារម្មណ៍នោះឯង, ជវន ដ៏សេស ជាកាមាវចរចិត្ត មានប្រការគឺយើងពោលហើយនុ៎ះឯង ។ ប៉ុន្តែបណ្ឌិត គប្បីជ្រាបសេចក្ដីផ្សេងគ្នានេះថា “សុខវេទនា មិនមែនជាបច្ច័យដោយអាសេវនប្បច្ច័យនៃអទុក្ខមសុខវេទនាទេ, អទុក្ខមសុខវេទនា គប្បីកើតឡើង ក្នុងចតុត្ថជ្ឈាននុ៎ះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ជវនក្នុងអប្បនាវិថីទាំងនោះ ជាជវនសម្បយុត្តហើយ ដោយឧបេក្ខាវេទនា, ក៏ព្រោះភាវៈនៃអប្បនាជវន ដ៏សម្បយុត្តហើយ ដោយឧបេក្ខានុ៎ះឯងសូម្បីបីតិក្នុងឈាននេះ ក៏រមែងសាបសូន្យទៅ ដោយប្រការដូច្នេះ ។

ក៏ដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រះយោគីនោះ ឈ្មោះថា ចូលដល់ឈាន ទី៤ ដែលមិនមានទុក្ខ មិនមានសុខ មានសេចក្ដីបរិសុទ្ធិនៃសតិដែលកើតអំពីឧបេក្ខាហើយនៅ ព្រោះលះបង់នូវសុខផង ព្រោះលះបង់ទុក្ខផង ព្រោះសោមនស្ស និង ទោមនស្សទាំងឡាយ រលត់អស់ក្នុងកាលមុនតែម្ដង ។ ចតុត្ថជ្ឈាន ជាបឋវីកសិណដែលលះអង្គ ១ ប្រកបដោយអង្គ ២ មានលំអ ៣ យ៉ាង បរិបូរដោយលក្ខណៈ ១០ ជាឈាន គឺព្រះយោគីនោះ បានសម្រេចហើយ យ៉ាងដូច្នេះឯង ។

(១០៦) ក្នុងបាឋៈទាំងនោះ បាឋៈថា “សុខស្ស ច បហានា ទុក្ខស្ស ច បហានា” នោះ គឺ ព្រោះការលះនូវសេចក្ដីសុខដែលប្រព្រឹត្តទៅ ក្នុងកាយផង នូវសេចក្ដីទុក្ខដែលប្រព្រឹត្តទៅក្នុងកាយផង ។ បទថា “បុព្វេវ” សេចក្ដីថា ក៏ការលះនុ៎ះឯង មានមកក្នុងកាលមុនពិត មិនមែនមាន ក្នុងខណៈនៃចតុត្ថជ្ឈានទេ ។ ពាក្យថា “ព្រោះសោមនស្ស និង ទោមនស្ស រលត់អស់” នោះ សេចក្ដីថា ព្រោះធម៌ទាំងឡាយ ២ នេះ គឺចេតសិក-សុខ និង ចេតសិកទុក្ខ តាំងនៅមិនបាន, អធិប្បាយថាៈ ព្រោះលះបង់

ក្នុងកាលមុនមែនពិត ។ សួរថា “ក៏ការលះបង់ នូវធម៌ទាំង ២ យ៉ាងនោះ មានក្នុងកាលណា?” ។ ឆ្លើយថា “មាននៅក្នុងខណៈនៃឧបចារៈនៃឈានទាំង៤ ” ។ មែនពិត ព្រះយោគីលះបង់សោមនស្ស ក្នុងខណៈនៃឧបចារៈ នៃចតុត្ថជ្ឈាននុ៎ះឯង ។ ទុក្ខ, ទោមនស្ស និង សុខ គឺព្រះយោគីលះបង់ ក្នុងខណៈនៃឧបចារៈ នៃបឋមជ្ឈាន, ទុតិយជ្ឈាន និង តតិយជ្ឈាន ។ ការលះបង់នូវសុខ, ទុក្ខ, សោមនស្ស និង ទោមនស្ស ក្នុងចតុត្ថជ្ឈានបាឋៈនេះឯង សូម្បីព្រះមានព្រះភាគ មិនបានត្រាស់ហើយ តាមលំដាប់នៃការលះនូវសុខ, ទុក្ខ, សោមនស្ស និង ទោមនស្សទាំងនោះក៏ដោយ តែព្រះអង្គត្រាស់ហើយ ដោយលំដាប់នៃឧទ្ទេស នៃឥន្ទ្រិយ៍ទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គ បណ្ឌិតគប្បីជ្រាប ដូចពោលមកនេះឯង ។

សួរថា “ថាបើអង្គទាំងឡាយនោះ គឺព្រះយោគីលះបង់ ក្នុងខណៈនៃឧបចារៈនៃឈាននោះៗ ឯង កាលបើដូច្នោះ ព្រោះហេតុអ្វី? បានជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់និរោធ តែក្នុងឈានហ្នឹងឯងយ៉ាងនេះ ថា: ក៏ទុក្ខិន្ទ្រិយ៍ ដែលកើតឡើងហើយ រមែងរលត់ទៅវិញ ដោយមិនសេសសល់ ក្នុងទីណា?, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ ស្ងប់ស្ងាត់មែនពិត ចាកកាមទាំងឡាយ ។ល។ រមែងចូលដល់ឈានទីមួយហើយនៅ, ទុក្ខិន្ទ្រិយ៍ ដែលកើតឡើងហើយ រមែងរលត់ទៅ ដោយមិនសេសសល់ ក្នុងទីនេះ, ក៏ទោមនស្សិន្ទ្រិយ៍, សុខិន្ទ្រិយ៍, សោមនស្សិន្ទ្រិយ៍ ដែលកើតឡើងហើយ រមែងរលត់ទៅ ដោយមិនសេសសល់ ក្នុងទីណា?, ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ ព្រោះលះនូវសុខផង ។ល។ ចូលដល់ឈានទី៤ ហើយនៅ, សោមនស្សិន្ទ្រិយ៍ កើតឡើងហើយ តែងរលត់ទៅ មិនមានសេសសល់ក្នុងទីនេះ” ដូច្នេះ ។



ឆ្លើយថា “ព្រោះនិរោធ ក្នុងឈាននោះៗ រលត់ដោយខ្លួនឯង ក្រៃពេក ។ ពិតមែន ការរលត់នៃអង្គឈានទាំងឡាយនោះ ក្នុងឈានទាំងឡាយមានបឋមជ្ឈានជាដើមជាអតិសយនិរោធ មិនមែនជានិរោធធម្មតានុ៎ះទេ ។ ចំណែកការរលត់ ក្នុងខណៈនៃឧបចារៈ ជានិរោធធម្មតា មិនមែនជាអតិសយនិរោធទេ ។ ពិតដូច្នោះមែន ការកើតឡើង នៃទុក្ខិន្ទ្រិយ៍ សូម្បីរលត់ហើយ ក្នុងឧបចារៈ នៃបឋមជ្ឈាន ក្នុងអាវជ្ជនចិត្តផ្សេងៗ គប្បីមាន ដោយសារមានសម្ផស្សនៃសត្វ មានរបោម និង មូសជាដើម ឬ ដោយសារការស្អុះស្អាប់ ព្រោះអាសនៈ មិនស្មើ ។ តែការកើតឡើង មិនគប្បីមាន ខាងក្នុងនៃអប្បនាទេ ។ ម្យ៉ាងទៀត ទុក្ខិន្ទ្រិយ៍នេះ សូម្បីរលត់ ក្នុងឧបចារៈហើយ ក៏មិនមែនឈ្មោះថា រលត់ហើយ ដោយប្រពៃទេ ព្រោះភាវៈនៃទុក្ខិន្ទ្រិយ៍នោះ ជាធម្មជាតគឺធម៌ដែលជាសត្រូវ មិនទាន់កំចាត់បង់ ។ តែខាងក្នុង នៃអប្បនា កាយទាំងមូល ជាកាយឈ្មោះថាយាងចុះកាន់សេចក្ដីសុខហើយ ព្រោះការផ្សព្វផ្សាយទៅនៃបីតិ ។ ក៏ទុក្ខិន្ទ្រិយ៍ របស់បុគ្គលអ្នកមានកាយយាងចុះកាន់សេចក្ដីសុខហើយ ជាធម្មជាត ឈ្មោះថា រលត់ហើយដោយប្រពៃ ព្រោះភាវៈនៃទុក្ខិន្ទ្រិយ៍នោះ គឺធម៌ដែលជាសត្រូវកំចាត់បង់ហើយ ។ ម្យ៉ាងវិញទៀត ការកើតឡើង នៃទោមនស្សិន្ទ្រិយ៍ សូម្បីព្រះយោគីលះបង់បានហើយ ក្នុងឧបចារៈ នៃទុតិយជ្ឈាន ក្នុងអាវជ្ជនចិត្តផ្សេងៗ គប្បីមាន ។ ព្រោះហេតុដែលទុក្ខិន្ទ្រិយ៍នោះ កាលបើមានការលំបាកកាយ និង ការចង្អៀតចិត្ត សូម្បីមានវិតក្កៈនិង វិចារៈ ជាបច្ច័យក៏ដោយ, ក៏រមែងកើតឡើងបាន, ប៉ុន្តែកាលបើមិនមានវិតក្កៈ និង វិចារៈទេ វាក៏កើតឡើងមិនបានឡើយ ។ ប៉ុន្តែទោមនស្សិន្ទ្រិយ៍ រមែងកើតឡើង ក្នុងទីណា, កាលបើមានវិតក្កៈ

*និង វិចារៈ ក្នុងទីនោះ, វិតក្កៈ និង វិចារៈ ក្នុងឧបចារៈនៃទុតិយជ្ឈាន គឺព្រះយោគីមិនទាន់លះបង់បានដោយពិត ព្រោះហេតុនោះ ការកើតឡើងនៃទោមនស្សិន្ទ្រិយ៍នោះ គប្បីមាន ក្នុងឧបចារៈនៃទុតិយជ្ឈាននោះ ។ តែក្នុងទុតិយជ្ឈានមិនគប្បីមាន ព្រោះភាវៈនៃបច្ច័យគឺព្រះយោគីលះបង់បានហើយ ។ ន័យដូចគ្នានោះដែរ ការកើតឡើង នៃសុខិន្ទ្រិយ៍ សូម្បីគឺព្រះយោគីលះបង់បានហើយ ក្នុងឧបចារៈនៃតតិយជ្ឈាន ក៏គប្បីមានដល់ព្រះយោគីអ្នកមានកាយ គឺរូបដែលប្រណីត មានបីតិជាសមុដ្ឋាន ពាល់ត្រូវហើយ, តែមិនគប្បីមាន ក្នុងតតិយជ្ឈានឡើយ ។ ព្រោះថា ក្នុងតតិយជ្ឈាន បីតិ ដែលជាបច្ច័យនៃសុខៈ រលត់ទៅហើយ ដោយប្រការទាំងពួង ។ម្យ៉ាងវិញទៀត ការកើតឡើង នៃសោមនស្សិន្ទ្រិយ៍ សូម្បីព្រះយោគី លះបង់បានហើយ ក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏គប្បីមាន ព្រោះសោមនស្សិន្ទ្រិយ៍នោះ នៅជិតផង ព្រោះមិនទាន់កន្លងហើយ ដោយត្រឹមត្រូវ ព្រោះមិនមានឧបេក្ខាដែលដល់នូវអប្បនាផង ។ តែក្នុងចតុត្ថជ្ឈានមិនគប្បីមានទេ ។ ក៏ព្រោះហេតុដូច្នោះ ការកាន់យក ដោយមិនសេសសល់ គឺព្រះមានព្រះភាគទ្រង់ធ្វើហើយក្នុងព្រះបាលីនោះៗថា "ទុក្ខិន្ទ្រិយ៍ដែលកើតឡើងហើយ រមែងរលត់ទៅ ដោយមិនសេសសល់ ក្នុងទីនេះ ដូច្នេះជាដើម ដោយប្រការដូច្នេះឯង" ។*

*ក្នុងអធិការ នៃចតុត្ថជ្ឈាននេះ អាចារ្យអ្នកចោទ បានពោល ថា : "កាលបើដូច្នោះ, វេទនាទាំងនោះ សូម្បីព្រះយោគីលះបង់ហើយ ក្នុងឧបចារៈនៃឈាននោះៗ, ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគ ទ្រង់នាំមកហើយ ក្នុងទីនេះ?" ដូច្នេះ ។*

*ឆ្លើយថា "ដើម្បីកំណត់យកស្រួល ។ ព្រោះអទុក្ខមសុខវេទនា*



*នេះឯណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ក្នុងបាឋៈនេះថា* "អទុក្ខមសុខំ" *ដូច្នេះ, អទុក្ខមសុខវេទនានោះ ជាធម្មជាតដ៏ល្អិតសុខុមដឹងបានដោយកម្រ គឺព្រះយោគីមិនអាចដើម្បីទទួលយកបាន ដោយស្រួលឡើយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់នាំមកនូវអទុក្ខមសុខវេទនាទាំងអស់នោះ ដើម្បីកំណត់យកស្រួល ប្រៀបដូចជាអ្នករក្សាគោ គៀងគោទាំងអស់ ចូលក្នុងក្រោលមួយ ដើម្បីចាប់បានដោយស្រួល នូវគោដែលកាច គឺបុគ្គលមិនអាចចូលទៅរក តាមតែបានហើយចាប់យក, កាលបើដូច្នេះ អ្នករក្សាគោ ក៏លែងគោចេញម្ដងមួយៗ ទើបឲ្យបុគ្គលចាប់គោនោះឯង ដែលដើរមកហើយ តាមលំដាប់ ដោយពាក្យថា "នេះគឺគោនោះ អ្នកទាំងឡាយ ចូរចាប់វា" ដូច្នេះ យ៉ាងនោះឯង ។ ព្រោះថា ព្រះមានព្រះភាគ លុះទ្រង់សំដែងនូវវេទនា ដែលព្រះអង្គទ្រង់នាំមក យ៉ាងនេះហើយ ក៏ទ្រង់អាចញុំាងព្រះយោគី ឲ្យកាន់យកអទុក្ខមសុខវេទនានោះ ថា "ធម្មជាតណា ដែលមិនមែនជាសុខ មិនមែនជាទុក្ខ មិនមែនជាសោមនស្ស មិនមែនជាទោមនស្ស, ធម្មជាតនេះ ឈ្មោះថាអទុក្ខមសុខវេទនា" ដូច្នេះ ។*

*ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបវេទនាទាំងនោះថា "ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ដើម្បីសំដែងនូវបច្ច័យនៃចេតោវិមុត្តិ ដែលជាអទុក្ខមសុខវេទនា" ដូច្នេះផងក៏បាន ។ មែនពិត ឧបាយទាំងឡាយមានការលះទុក្ខជាដើម ជាបច្ច័យនៃចេតោវិមុត្តិ ដែលជាអទុក្ខមសុខវេទនានោះ ។ សមដូចជាព្រះធម្មទិន្នាថេរី ពោលថា "ម្នាលអាវុសោ បច្ច័យនៃចេតោវិមុត្តិសមាបត្តិ ដែលជាអទុក្ខមសុខវេទនា មាន៤ យ៉ាងហ្នឹងឯង, ម្នាលអាវុសោ ភិក្ខុ ក្នុងព្រះធម្មវិន័យនេះ ព្រោះលះបង់នូវសុខៈផង ។ល។*

ចូលដល់ចតុត្ថជ្ឈានហើយនៅ, ម្នាលអាវុសោ បច្ច័យបួន នៃចេតោ-វិមុត្តិសមាបត្តិ ដែលជាអទុក្ខមសុខវេទនា យ៉ាងនេះឯង” ដូច្នេះ ។

ម្យ៉ាងទៀត បណ្ឌិត គប្បីជ្រាបថា “សំយោជនកិលេសទាំងឡាយ មានសក្កាយទិដ្ឋិជាដើម សូម្បីព្រះយោគីលះបង់ហើយ ក្នុងមគ្គដទៃ តែព្រះមានព្រះភាគទ្រង់ត្រាស់ថា “ព្រះយោគីលះបង់ហើយ ក្នុងតតិយមគ្គនោះ ដើម្បីត្រាស់សរសើរនូវតតិយមគ្គ យ៉ាងណា, វេទនាទាំងនោះ ព្រះមានព្រះភាគត្រាស់ហើយ ក្នុងចតុត្ថជ្ឈានេះ ដើម្បីទ្រង់ត្រាស់សរសើរនូវឈាននោះឯង ក៏យ៉ាងនោះដែរ” ។

មួយវិញទៀត បណ្ឌិត គប្បីជ្រាបថា “ព្រះអង្គត្រាស់វេទនាទាំងនោះ ដើម្បីទ្រង់សំដែងនូវភាវៈនៃរាគៈ និង ទោសៈទាំងឡាយជាធម្មជាតឆ្ងាយក្រៃពេក ក្នុងចតុត្ថជ្ឈាននោះ ព្រោះកំចាត់បង់ចោលនូវបច្ច័យ” ។ មែនពិត ក្នុងវេទនាទាំងនោះ សុខៈជាបច្ច័យនៃសោមនស្ស, សោមនស្សជាបច្ច័យនៃរាគៈ, ទុក្ខៈ ជាបច្ច័យនៃទោមនស្ស, ទោមនស្ស ជាបច្ច័យនៃទោសៈ, ក៏ព្រោះឈាននោះ សម្លាប់នូវវេទនា មានសុខវេទនាជាដើម រាគៈ និង ទោសៈ ព្រមទាំងបច្ច័យ គឺឈាននោះសម្លាប់ហើយ ហេតុនោះ រាគៈ និង ទោសៈ នោះ ទើបឈ្មោះថា មាននៅក្នុងទីឆ្ងាយក្រៃពេក យ៉ាងដូច្នេះឯង ។

(១០៧) បាលីថា “អទុក្ខមសុខំ” មានវិនិច្ឆ័យថាៈ ឈាននេះ ឈ្មោះថា អទុក្ខៈ ព្រោះមិនមានទុក្ខ, ឈ្មោះថា អសុខៈ ព្រោះមិនមានសុខ ។ ព្រះមានព្រះភាគ សំដែងនូវវេទនា ទី៣ ដែលជាសត្រូវនៃទុក្ខ និង សុខ ក្នុងចតុត្ថជ្ឈាននោះ ដោយពាក្យនេះ មិនមែនទ្រង់សំដែងត្រឹមតែការមិនមានទុក្ខ និង សុខទេ ។ វេទនា ទី៣ លោកហៅថា អទុក្ខម-



សុខវេទនាខ្លះ ហៅថាឧបេក្ខាវេទនាខ្លះ ។ វេទនា ទី៣ នោះ បណ្ឌិតគប្បីជ្រាបថា មានការសោយអារម្មណ៍ផ្ទុយអំពីឥដ្ឋារម្មណ៍ និង អនិដ្ឋារម្មណ៍ ជាលក្ខណៈ មានភាពជាព្រងើយជាកិច្ច មានការមិនកើតប្រាកដជាផល មានការរំលត់សុខជាហេតុ ។

បាឋៈ ថា “ឧបេក្ខាសតិបារិសុទ្ធី” ប្រែថា មានសេចក្តីបរិសុទ្ធិនៃសតិ គឺឧបេក្ខាឲ្យកើតហើយ ។ ព្រោះថាសតិ ក្នុងឈាននេះ បរិសុទ្ធល្អ ។ ក៏សេចក្តីបរិសុទ្ធិណានៃសតិនោះ, សេចក្តីបរិសុទ្ធិនោះ គឺឧបេក្ខាធ្វើហើយ, មិនមែនសភាវៈដទៃធ្វើទេ ។ ហេតុនោះ ឈាននេះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា “មានសេចក្តីបរិសុទ្ធិនៃសតិ គឺឧបេក្ខាឲ្យកើតហើយ” ។ សូម្បីក្នុងវិភង្គក៏លោកពោលថា “សតិនេះជាធម្មជាតិបើកហើយ ជាធម្មជាតិបរិសុទ្ធផូរផង់ ព្រោះឧបេក្ខានេះ ហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “មានសេចក្តីបរិសុទ្ធិនៃសតិ ព្រោះឧបេក្ខា” ។ ក៏សេចក្តីបរិសុទ្ធិនៃសតិ ក្នុងឈាននេះ រមែងមាន ព្រោះឧបេក្ខាណា, ឧបេក្ខានោះ បណ្ឌិតគប្បីជ្រាបថា ដោយសេចក្តី គឺតត្រមជ្ឈត្តតា ។ មិនមែនតែសតិម្យ៉ាងប៉ុណ្ណោះទេដែលបរិសុទ្ធ ព្រោះឧបេក្ខានោះ ក្នុងឈានទី ៤ នេះ, តាមពិត សម្បយុត្តធម៌ទាំងពួងក៏បរិសុទ្ធដែរ ។ តែទ្រង់ត្រាស់ទេសនា ដោយលើកយកសតិ មកជាប្រធាន ។ ក្នុងឈានទាំងនោះ ឧបេក្ខានេះ មានក្នុងឈានទាំងឡាយ ៣ ពួដ៏ខាងក្រោមហ្នឹងឯង ក៏ពិតមែនហើយ ប៉ុន្តែថា ប្រៀបដូចជាស្នាមនៃព្រះច័ន្ទ សូម្បីមាន ក្នុងវេលាថ្ងៃ ក៏ជាធម្មជាតិមិនបរិសុទ្ធ មិនផូរផង់ ព្រោះត្រូវពន្លឺព្រះអាទិត្យ ក្នុងវេលាថ្ងៃ គ្របសង្កត់ផង ព្រោះមិនបាននូវរាត្រី ដែលមានចំណែកស្មើគ្នាផង ដោយភាពនៃខ្លួនជាព្រះច័ន្ទ និង ដោយភាវៈនៃរាត្រី ជាអ្នកទំនុក

បំរុងខ្លួនផង យ៉ាងណាមិញ, សូម្បីស្នាមនៃព្រះច័ន្ទ គឺតត្រមជ្ឈត្តុបេក្ខា នេះឯង ក៏យ៉ាងនោះដែរ សូម្បីជាមាន ក៏ជាធម្មជាតិមិនបរិសុទ្ធ ក្នុងប្រភេទនៃឈាន មានបឋមជ្ឈានជាដើម ព្រោះត្រូវតេជះនៃធម៌ដែលជាសត្រូវមានវិតក្កៈជាដើម គ្របសង្កត់ផង ព្រោះមិនបាននូវរាត្រីគឺឧបេក្ខា-វេទនា ដែលមានចំណែកស្មើគ្នាផង ។ ក៏កាលបើឧបេក្ខាវេទនានោះ មិនបរិសុទ្ធហើយ, សូម្បីសហជាតធម៌ទាំងឡាយ មានសតិជាដើម ក៏ជាធម្មជាតមិនបរិសុទ្ធផងដែរ ដូចជាពន្លឺនៃស្នាមព្រះច័ន្ទ ដែលមិនបរិសុទ្ធក្នុងវេលាថ្ងៃ ក៏មិនភ្លឺច្បាស់ យ៉ាងដូច្នោះដែរ ។ ហេតុនោះ បណ្ដាឈានទាំង៣ ពួដ៏ខាងក្រោមនោះ សូម្បីឈាន១ ក៏ព្រះមានព្រះភាគ មិនត្រាស់ថា “ឧបេក្ខាសតិបារិសុទ្ធិ” ដូច្នេះទេ ។ តែក្នុងចតុត្ថជ្ឈាននេះ ច័ន្ទលេខាគឺតត្រមជ្ឈត្តុបេក្ខានេះ ជាធម្មជាតដ៏បរិសុទ្ធក្រៃពេក ព្រោះមិនមានតេជះនៃធម៌ដែលជាសត្រូវមានវិតក្កៈជាដើមគ្របសង្កត់ផង ព្រោះបាននូវរាត្រីគឺឧបេក្ខាវេទនា ដែលមានចំណែកស្មើគ្នាផង ។ ព្រោះភាវៈនៃឧបេក្ខានោះ បរិសុទ្ធហើយ សូម្បីសហជាតធម៌ទាំងឡាយមានសតិជាដើម ក៏ជាធម្មជាតបរិសុទ្ធផូរផង់ផងដែរ ដូចជាពន្លឺនៃស្នាមព្រះច័ន្ទ ដែលបរិសុទ្ធយ៉ាងនោះឯង ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា ចតុត្ថជ្ឈាននេះប៉ុណ្ណោះ គឺព្រះមានព្រះភាគត្រាស់ថា “ឧបេក្ខាសតិបារិសុទ្ធិ” ដូច្នេះ ។

បទថា “ចតុត្ថំ” គឺឈាននេះ ជាឈាន ទី៤ ព្រោះមានលំដាប់នៃចំនួន ។ ឈាននេះ ឈ្មោះថា ទី ៤ ព្រោះព្រះយោគីចូលឈាននេះជាទី ៤ ដូច្នេះ ក៏បាន ។

ចំណែកពាក្យណា ដែលយើងពោលហើយថា “ចតុត្ថជ្ឈាន លះអង្គ ១ ប្រកបព្រមដោយអង្គ ២” ដូច្នេះ, បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ ក្នុង



ពាក្យនោះ (តទៅ) ។ ភាវៈនៃចតុត្ថជ្ឈាន លះអង្គ ១ បណ្ឌិតគប្បីជ្រាបដោយអំណាចការលះសោមនស្ស។ ក៏សោមនស្សនោះ ព្រះយោគី លះបង់បានតែក្នុងជវនខាងដើមទាំងឡាយ ក្នុងវិថីតែមួយទេ ។ ហេតុនោះ សោមនស្សនោះ ទើបព្រះមានព្រះភាគត្រាស់ ថា “ជាអង្គ សម្រាប់លះ” របស់ចតុត្ថជ្ឈាននោះ ។ ចំណែកភាវៈនៃចតុត្ថជ្ឈាននោះ ប្រកបព្រមដោយអង្គ ២ បណ្ឌិតគប្បីជ្រាប ដោយអំណាចការកើតឡើងនៃអង្គទាំង ២ នេះ គឺឧបេក្ខាវេទនា (និង) ចិត្តេកគ្គតា ។ ពាក្យដ៏សេស មានន័យដូចយើងពោលមកហើយ ក្នុងបឋមជ្ឈាននុ៎ះឯង ។ ន័យក្នុងចតុត្ថជ្ឈាននេះ មានត្រឹមតែប៉ុណ្ណោះឯង ។

(បញ្ចកជ្ឈាន)

លុះព្រះយោគី អ្នកញ៉ាំងឈាន ទី៥ ឲ្យកើតឡើង ចេញចាកបឋមជ្ឈានដ៏ស្ទាត់រួចហើយឃើញទោស ក្នុងបឋមជ្ឈាននោះថា “សម្បត្តិនេះ មានសត្រូវ គឺនីវរណៈនៅជិត” ដូច្នេះ និង ថា “សម្បត្តិនេះ ឈ្មោះថាជាអង្គដែលមានកម្លាំងខ្សោយ ព្រោះភាវៈនៃវិតក្កៈជាអង្គគ្រោកគ្រាក” ដូច្នេះហើយ គប្បីធ្វើទុកក្នុងចិត្ត នូវទុតិយជ្ឈាន ដោយថាជាធម៌ដ៏ល្អិតគ្របសង្កត់នូវសេចក្ដីគ្រោតអរ ក្នុងបឋមជ្ឈានហើយ ធ្វើសេចក្ដីព្យាយាមជាគ្រឿងប្រកប ដើម្បីបានសម្រេចដល់ទុតិយជ្ឈាន ។ គ្រានោះ កាលព្រះយោគីនោះ ចេញចាកបឋមជ្ឈានហើយ មានសតិ មានសេចក្ដីដឹងខ្លួន ពិចារណានូវអង្គឈានទាំងឡាយ, អង្គត្រឹមតែវិតក្កៈ រមែងតាំងឡើងប្រាកដ ដោយថា ជាអង្គគ្រោកគ្រាក, អង្គទាំងឡាយ មានវិចារៈជាដើម រមែងតាំងឡើងប្រាកដ ដោយថា ជាអង្គដ៏ល្អិត ក្នុងកាលណា, ក្នុងកាលនោះ កាលបើព្រះយោគីនោះ ធ្វើទុកក្នុងចិត្តរឿយៗ នូវនិមិត្តនុ៎ះ

ឯង ដោយបរិកម្មថា “បឋវី បឋវី” ដូច្នេះ ដើម្បីលះនូវអង្គដ៏គ្រោតគ្រាត ផង ដើម្បីបានចំពោះនូវអង្គដ៏ល្អិតផង, ទុតិយជ្ឈាន រមែងកើតឡើង តាមន័យដែលបានពោលមកហើយនុ៎ះឯង ។ អង្គត្រឹមតែវិតក្កៈប៉ុណ្ណោះ ជាអង្គសម្រាប់លះបង់នូវទុតិយជ្ឈាននោះ, អង្គទាំងឡាយ ៤ មានវិចារៈ ជាដើម ជាអង្គសម្រាប់ប្រកប ។ ពាក្យដ៏សេស មានប្រការៈដូចពោល មកហើយនុ៎ះឯង ។

លុះដល់ទុតិយជ្ឈាននេះឯង គឺព្រះយោគីបានហើយយ៉ាងនេះ, ព្រះ យោគី ជាអ្នកមានសេចក្ដីប្រព្រឹត្តិស្ទាត់ ដោយអាការៈទាំងឡាយ៥ តាម ន័យដែលបានពោលមកហើយនុ៎ះឯង ចេញចាកទុតិយជ្ឈាន ដែលស្ទាត់ ហើយ ឃើញទោស ក្នុងទុតិយជ្ឈាននោះថា “សម្បត្តិនេះមានសត្រូវ គឺ វិតក្កៈនៅជិត” ដូច្នេះ និង ថា “សម្បត្តិនេះ ឈ្មោះថា ជាអង្គមានកម្លាំង ខ្សោយ ព្រោះភាវៈនៃវិចារៈ ជាអង្គគ្រោតគ្រាត” ដូច្នេះហើយ ធ្វើទុកក្នុង ចិត្ត នូវតតិយជ្ឈាន ថា ជាធម៌ល្អិត គ្របសង្កត់នូវសេចក្ដីត្រេកអរ ក្នុង ទុតិយជ្ឈានហើយ ធ្វើសេចក្ដីព្យាយាមជាគ្រឿងប្រកប ដើម្បីបានសំរេច តតិយជ្ឈាន ។ គ្រានោះ កាលព្រះយោគីនោះ ចេញចាកទុតិយជ្ឈាន ហើយ មានសតិ មានសេចក្ដីដឹងខ្លួន ពិចារណានូវអង្គឈានទាំងឡាយ, អង្គត្រឹមតែវិចារៈរមែងតាំងឡើងប្រាកដថា ជាអង្គគ្រោកគ្រាក, អង្គទាំង ឡាយ មានបីតិជាដើម រមែងតាំងឡើងប្រាកដ ថា ជាអង្គដ៏ល្អិត ក្នុង កាលណា, ក្នុងកាលនោះ កាលបើព្រះយោគីនោះ ធ្វើទុកក្នុងចិត្តរឿយៗ នូវនិមិត្តនុ៎ះឯង ដោយបរិកម្ម ថា “បឋវី បឋវី” ដូច្នេះ ដើម្បីលះបង់នូវ អង្គ ដ៏គ្រោតគ្រាតផង ដើម្បីបានចំពោះនូវអង្គដ៏ល្អិតផង, តតិយជ្ឈាន រមែងកើតឡើង តាមន័យដូចបានពោលមកហើយនុ៎ះឯង ។ អង្គត្រឹមតែ



វិចារៈប៉ុណ្ណោះ ជាអង្គសម្រាប់លះ នៃតតិយជ្ឈាននោះ, អង្គទាំងឡាយ៣ មានបីតិជាដើមជាអង្គសម្រាប់ប្រកប ដូចក្នុងទុតិយជ្ឈាននៃចតុក្កន័យ ។ ពាក្យដ៏សេស មានន័យដូចបានពោលមកហើយនុ៎ះឯង ។

ឈានណា ជាឈាន ទី២ ក្នុងចតុក្កន័យ, ឈាននោះ ចែកចេញ ជា ២ មានទុតិយជ្ឈានផង តតិយជ្ឈានផង ក្នុងបញ្ចកន័យ, ឯឈាន ទាំងឡាយណា ជាឈាន ទី៣ និង ទី៤ ក្នុងចតុក្កន័យនោះ ឈាន ទាំងឡាយនោះ ជាឈាន ទី៤ និង ទី៥, ឈាន ទី១ គឺជាឈាន ទី១ តែម្យ៉ាង ដោយប្រការៈដូច្នេះឯង ។

បរិច្ឆេទ ទី៤ ឈ្មោះ បឋវីកសិណនិទ្ទេស
ក្នុងអធិការនៃសមាធិភាវនា ក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គ
ដែលខ្ញុំរៀបរៀងហើយ
ដើម្បីប្រយោជន៍ដល់កិរិយាញ៉ាំងសាធុជនឲ្យរីករាយចប់ហើយ
ដោយប្រការដូច្នេះ ។

♣ ♣ ♣

រៀបរៀងចប់បរិបូរ
ថ្ងៃអាទិត្យ ៣ កើត ខែបុស្ស ឆ្នាំជូត អដ្ឋស័ក ព.ស. ២៥៤០
ត្រូវនឹងថ្ងៃទី ៩ កុម្ភៈ ១៩៩៧
វេលាល្ងាច

(អាបោកសិណ)

(១០៨) ឥឡូវនេះ ជាកថា ដោយពិស្តារ ក្នុងអាបោកសិណ ក្នុងលំដាប់នៃបឋវីកសិណ ។ មែនពិត ព្រះយោគី អ្នកប្រាថ្នាដើម្បីចំរើនអាបោកសិណ ត្រូវអង្គុយឲ្យស្រួល ហើយរៀនយកនូវនិមិត្ត ក្នុងទឹក ដូចជាអ្នកចំរើនបឋវីកសិណ យ៉ាងនោះដែរ ។ បទទាំងពួងថា “និមិត្តដែលព្រះយោគីធ្វើហើយក្តី មិនទាន់ធ្វើហើយក្តី” ដូច្នេះជាដើម បណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារ ។ ឯបទទាំងពួងនោះ បណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារក្នុងអាបោកសិណនេះ យ៉ាងណា, ក្នុងកសិណទាំងពួង ក៏ត្រូវ (សំដែង) ឲ្យពិស្តារ យ៉ាងនោះដែរ ។ ព្រោះថា បន្ទាប់អំពីនេះទៅ យើងនឹងមិនពោលពាក្យមានប្រមាណប៉ុណ្ណោះទៀតទេ ពោលត្រឹមតែសេចក្តីដែលប្លែកគ្នាប៉ុណ្ណោះឯង ។

សូម្បីក្នុងអាបោកសិណនេះ និមិត្តក្នុងទឹក ដែលព្រះយោគីមិនបានធ្វើហើយ គឺក្នុងស្រះបោក្ខរណីក្តី ក្នុងត្រពាំងក្តី ក្នុងទន្លេ(ទឹកប្រៃ)ក្តី ក្នុងសមុទ្រក្តី រមែងកើតឡើង ដល់ព្រះយោគី អ្នកមានបុណ្យ មានការកសាងធ្វើទុកហើយ ក្នុងកាលមុនមែនពិត ដូចជានិមិត្តកើតឡើង ដល់ព្រះចូឡសិវត្ថេរ យ៉ាងនោះឯង។ បានឮមកថា កាលលោកដ៏មានអាយុអង្គនោះ លះបង់នូវលាភសក្ការៈ គិតថា “អញ នឹងនៅ នៅយ៉ាងស្ងប់ស្ងាត់” ដូច្នេះ ក៏ឡើងជិះទូក នាកំពង់ដ៏ធំហើយ ទៅកាន់ជម្ពូទ្វីប ក្រឡេកមើលមហាសមុទ្រ ក្នុងចន្លោះ, កសិណនិមិត្ត ដែលមានចំណែកប្រៀបដូចមហាសមុទ្រនោះ បានកើតឡើងហើយ ។ ព្រះយោគីអ្នកមិនបានធ្វើការកសាងទុកហើយ ជៀសវាងនូវទោស នៃកសិណទាំងឡាយ ៤ កុំអាលកាន់យកទឹក មានពណ៌ណាមួយ ក្នុងចំណោមពណ៌ខៀវ, លឿង,



ក្រហម និង ពណ៌-ស, តែទឹកណា ដែលមិនទាន់ធ្លាក់ដល់ផែនដីនៅឡើយ គឺបុគ្គលត្រងហើយ ដោយសំពត់ដ៏ស្អាត លើអាកាស ឬថា ទឹកដទៃដែលថ្លាស្អាត មិនល្អក់ មានសភាពដូច្នោះក៏បាន, ត្រូវប្រេកទឹកនោះឲ្យពេញបាត្រ ឬ កុណ្ឌី ស្មើត្រឹមកណ្តាប់មាត់ហើយ តម្កល់ទុក នៅក្នុងឱកាសដែលខ្លួនបានកំណត់ទុកហើយមានប្រការដូចពោលហើយ អង្គុយឲ្យស្រួល ក្នុងទីបំផុតនៃវត្ត មិនគប្បីពិចារណាពណ៌ (នៃទឹក)ទេ ។ ព្រះយោគីមិនត្រូវធ្វើទុកក្នុងចិត្តដល់លក្ខណៈទេ ។ គប្បីធ្វើទឹកនោះ ឲ្យមានពណ៌ស្មើដោយទីអាស្រ័យមែនពិត តម្កល់ចិត្ត ក្នុងបណ្ណត្តិធម៌ ដោយអំណាចនៃពាក្យដែលប្រើមកច្រើន ហើយចំរើន ថា “អាបោ អាបោ” ដូច្នេះ ដោយអំណាចនៃឈ្មោះដែលប្រាកដមែនពិត ក្នុងចណ្តាមឈ្មោះនៃទឹកទាំងឡាយមាន “អម្ពុ, ឧទកៈ, វារី, សលិលៈ” ដូច្នេះជាដើម ។ កាលព្រះយោគីនោះ ចំរើនយ៉ាងនេះ, និមិត្តទាំង ២ រមែងកើតឡើងតាមន័យដែលលោកពោលហើយ ដោយលំដាប់នុ៎ះឯង ។ តែថា ក្នុងអាបោកសិណនេះ ឧគ្គហនិមិត្ត រមែងប្រាកដដូចជាញាប់ញ័រ ។ ថាបើទឹកនោះ ជាទឹកដែលលាយដោយពុំពពុះទឹក, ឧគ្គហនិមិត្ត ក៏នឹងប្រាកដឡើង យ៉ាងដូច្នោះដែរ ។ ទោសនៃកសិណ រមែងប្រាកដ ។ ចំណែកឯបដិភាគនិមិត្ត មិនញាប់ញ័រ ប្រាកដឡើង ហាក់ដូចជាផ្ចិតស្លឹកត្នោត ជាវិការៈនៃកែវមណី ដែលបុគ្គលតម្កល់ទុកហើយ ឰដ៏អាកាសផង ហាក់បីដូចជាមណ្ឌល នៃកញ្ចក់កែវមណីផង ។ ព្រះយោគីនោះ រមែងបានសម្រេចនូវឧបចារជ្ឈាន, ចតុត្ថជ្ឈាន និង បញ្ចកជ្ឈាន មួយអន្លើដោយការប្រាកដឡើង នៃបដិភាគនិមិត្តនោះឯង តាមន័យដែលបានពោលមកហើយមែនពិត ។ អាបោកសិណ ចប់ហើយ ។

(តេជោកសិណ)

(១០៩) ឯព្រះយោគីអ្នកមានប្រាថ្នាដើម្បីចំរើនតេជោកសិណ ត្រូវរៀនយកនិមិត្ត ក្នុងភ្លើង ។ ក្នុងតេជោកសិណានោះ និមិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានបុណ្យ មានការកសាងបានធ្វើទុកហើយ កាលរៀនយកនិមិត្ត ក្នុងភ្លើងដែលខ្លួនមិនទាន់ធ្វើហើយ ក្រឡេកមើលអណ្ដាតភ្លើង ក្នុងចង្កៀង, ក្នុងជើងក្រាន, ក្នុងកន្លែងដុតបាត្រ ឬ ក្នុងភ្លើងដែលឆេះព្រៃ ក្នុងទីណាមួយក៏ដោយ ដូចជានិមិត្តកើតឡើង ដល់ព្រះចិត្តគុត្តត្ថេរយ៉ាងនោះឯង ។ សេចក្ដីដំណាលថាៈ កាលលោកដ៏មានអាយុអង្គនោះ ចូលទៅកាន់រោងឧបោសថ ក្នុងថ្ងៃជាទីស្ដាប់ធម៌ហើយ ក្រឡេកមើលអណ្ដាតភ្លើងប្រទីបប៉ុណ្ណោះ និមិត្ត ក៏កើតឡើង ។

ឯព្រះយោគី ក្រៅអំពីនេះ គប្បីធ្វើ (កសិណនិមិត្ត) ។ នេះជាវិធីសម្រាប់ធ្វើ ក្នុងកសិណនិមិត្តនោះ ។ ព្រះយោគី ត្រូវពុះឧសដែលមានខ្លឹម មានសាច់ដ៏ជិត ហាលឧសទាំងនោះឲ្យបានស្ងួត ធ្វើឲ្យជាកំណាត់ៗហើយ ទៅកាន់គល់ឈើ ឬក៏ មណ្ឌលដែលសមគួរធ្វើជាគំនរ ដោយអាការៈដូចជាដុតបាត្រ ហើយដុតភ្លើង ធ្វើជាប្រហោងមានប្រមាណមួយចំអាម បួនធ្នាប់ ឰដ៏កន្ទេលរំបេក ឬ ស្បែក ឬក៏ ផ្ទាំងសំពត់ ក៏បាន ។ ព្រះយោគី គប្បីដាក់កន្ទេលរំបេក, ស្បែក ឬ ផ្ទាំងសំពត់នោះ ចំខាងមុខហើយអង្គុយ តាមន័យដែលលោកពោលហើយនុ៎ះឯង កុំធ្វើទុកក្នុងចិត្តនូវស្មៅ និង ឧស ឰដ៏ខាងក្រោម ឬក៏ នូវផ្សែង និង អណ្ដាតភ្លើង ឰដ៏ខាងលើហើយ គប្បីរៀនយកនិមិត្តឰដ៏អណ្ដាតភ្លើងជាដុំត្រង់កណ្ដាល ។ ព្រះយោគី មិនត្រូវពិចារណាពណ៌ ដោយអំណាចពណ៌ មានជាអាទិ៍ថា "ពណ៌ខៀវ ឬក៏ ពណ៌លឿង" ដូច្នេះឡើយ ។ មិនគប្បីធ្វើទុកក្នុងចិត្ត



ដល់លក្ខណៈ ដោយថា ជារបស់ក្ដៅ ។ គប្បីធ្វើភ្លើងនោះ ឲ្យមានពណ៌ស្មើគ្នាដោយទីអាស្រ័យនុ៎ះឯង តម្កល់ចិត្តក្នុងបណ្ណត្តិធម៌ ដោយអំណាចពាក្យដែលប្រើមកច្រើន ហើយចំរើនថា "តេជោ តេជោ" ដូច្នេះ ដោយអំណាចនៃឈ្មោះដែលប្រាកដមែនពិត ក្នុងចំណោមឈ្មោះ របស់ភ្លើងទាំងឡាយ ដូចជា "បាវកោ, កណ្ហវត្តនិ, ជាតវេទោ, ហុតាសនោ" យ៉ាងនេះជាដើម ។ កាលព្រះយោគីនោះចំរើនយ៉ាងដូច្នេះ, និមិត្តទាំង ២ រមែងកើតឡើងដោយលំដាប់ តាមន័យដែលបានពោលហើយមិនខាន ។ ឧគ្គហនិមិត្ត ក្នុងតេជោកសិណានោះ រមែងប្រាកដ ដូចជាអណ្ដាតភ្លើងដាច់ហើយធ្លាក់ចុះៗ យ៉ាងនោះឯង ។ ចំណែកទោសនៃកសិណ រមែងប្រាកដ ដល់ព្រះយោគីអ្នករៀនយកនិមិត្ត ក្នុងភ្លើងដែលខ្លួនមិនបានធ្វើហើយ ។ អង្កត់ឧស ដែលភ្លើងមិនឆេះផង ដុំនៃរងើកភ្លើងផង ផេះផងផ្សែងផង រមែងប្រាកដ ។ បដិភាគនិមិត្តនឹងថ្កល់ ប្រាកដឡើង ហាក់បីដូចជាកំណាត់សំពត់កម្ពលពណ៌ក្រហម ដែលគេតម្កល់ទុកហើយ ឰដ៏អាកាស ដូចជាផ្ចិតស្លឹកត្នោតពណ៌ដូចមាស និង ហាក់បីដូចជាសសរមាស យ៉ាងនោះឯង ។ ព្រះយោគីនោះ រមែងបាននូវឧបចារជ្ឈានផងនូវចតុត្ថជ្ឈាន និង បញ្ចកជ្ឈានផង មួយអន្លើដោយការប្រាកដឡើង នៃបដិភាគនិមិត្តនោះឯង តាមន័យដែលបានពោលមកហើយមែនពិត ។

តេជោកសិណ ចប់ហើយ ។

(១១០) ឯព្រះយោគីអ្នកមានប្រាថ្នាដើម្បីចំរើនវាយោកសិណ ត្រូវរៀនយកនិមិត្ត ក្នុងខ្យល់ ។ ក៏និមិត្តក្នុងខ្យល់នោះ គឺព្រះយោគីគប្បីរៀនយក ដោយអំណាចនៃខ្យល់ដែលខ្លួនឃើញហើយ ឬក៏ ដោយអំណាចនៃខ្យល់ដែលខ្លួនពាល់ត្រូវហើយ ។ មែនពិត ពាក្យនេះ គឺលោកពោល

ហើយ ក្នុងអដ្ឋកថាទាំងឡាយថា “ព្រះយោគី កាលរៀនយកនូវវាយោកសិណ តែងរៀនយកនូវនិមិត្ត ក្នុងខ្យល់ គឺតែងចូលទៅកំណត់នូវចុងអំពៅដែលត្រូវខ្យល់បក់ទៅបក់មក ឬ កំណត់នូវចុងឫស្សី ចុងឈើ ឬក៏ ចុងសក់ ដែលត្រូវខ្យល់បក់ទៅមក ក៏បាន កំណត់ខ្យល់ ដែលមកពាល់ត្រូវ ក្នុងកាយក៏បាន” ដូច្នេះ ។ ហេតុនោះ ព្រះយោគី ឃើញដើមអំពៅក្តី ឫស្សីក្តី ដើមឈើក្តី ដែលមានស្លឹកដុះជិតឋិតនៅស្មើត្រឹមក្បាល ឬ នូវក្បាលនៃបុរស ដែលមានសក់ក្រាស់ ប្រមាណបួនធ្នាប់ ដែលខ្យល់បក់ត្រូវហើយ គប្បីតាំងស្មារតីថា “ខ្យល់នេះបក់ ក្នុងទីនេះ” ដូច្នេះ ពុំនោះសោត គប្បីតាំងស្មារតី ក្នុងខ្យល់ដែលចូលទៅហើយ តាមចន្លោះបង្អួចក្តី តាមចន្លោះជញ្ជាំងក្តី ហើយបក់មកត្រូវកាយប្បទេស របស់ព្រះយោគីនោះ ហើយចំរើនថា “វាតោ វាតោ” ដូច្នេះ ដោយអំណាចឈ្មោះប្រាកដមែនពិត ក្នុងចំណោមឈ្មោះ នៃខ្យល់ទាំងឡាយ មានជាអាទិ៍ថា “វាតៈ, មាលិតៈ, អនិលៈ” ដូច្នេះ ។ ឧគ្គហនិមិត្ត ក្នុងវាយោកសិណនេះ ប្រាកដដូចជានិមិត្តញាប់ញ័រ ប្រាកដស្មើដោយខ្នាញ់នៃចំហាយបាយបាយាស ដែលបុគ្គលទើបតែនឹងដាក់ចុះអំពីជើងក្រាន ។ បដិភាគនិមិត្ត ជានិមិត្តស្ងប់ស្ងាត់នឹងថ្កល់ ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយនុ៎ះឯង ។ វាយោកសិណ ចប់ហើយ ។

(នីលកសិណ)

(១១) ក៏បន្ទាប់អំពីវាយោកសិណនោះមក ព្រោះបាលីថា “ព្រះយោគី កាលរៀនយកនីលកសិណ រមែងរៀនយកនិមិត្ត ក្នុងវត្ថុមានពណ៌ខៀវ ជាផ្កាក្តី ជាសំពត់ក្តី ជាធាតុមានពណ៌ក្តី” ដូច្នេះ និមិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានបុណ្យ មានការកសាងធ្វើទុកហើយ



ព្រោះគ្រាន់តែឃើញគុំនរផ្កាកម្រង ឬ កម្រាលផ្កាដែលមានពណ៌ដូច្នោះ ក្នុងទីសម្រាប់បូជា ឬក៏ នូវវត្ថុណាមួយ ក្នុងចំណោមសំពត់ពណ៌ខៀវ និង កែវពណ៌ខៀវជាមុន ។ ព្រះយោគីក្រៅនេះ គប្បីកាន់យកផ្កាទាំងឡាយមានផ្កាឧប្បលខៀវ និង ផ្កាកណ្ណិកាភ្នំជាដើម មកក្រាលឲ្យពេញផ្ទៃប្រអប់ ឬក៏ ផ្ទៃហិបឲ្យបានស្មើត្រឹមកណ្តាប់មាត់ ដោយស្លឹកឈើទាំងឡាយនុ៎ះឯង ដោយវិធីដែលកេសរ ឬក៏ ទង មិនប្រាកដ ។ មួយទៀត ព្រះយោគីគប្បីយកសំពត់ពណ៌ខៀវមកចងជាបង្វិចហើយ ប្រេកឲ្យពេញក៏បាន ។ មា្យ៉ងវិញទៀត ព្រះយោគី គប្បីយកសំពត់ពណ៌ខៀវនោះពាសត្រង់កណ្តាប់មាត់នៃបង្វិចនោះ ឲ្យដូចជាផ្ទៃនៃស្គរ ក៏បាន ។ ព្រះយោគី គប្បីយកធាតុណាមួយ ក្នុងចំណោមធាតុ មានពណ៌ខៀវ ដូចជាសំរឹទ្ធ ខៀវដូចជាស្លឹកឈើ និង ខៀវដូចជាផ្កាអញ្ជ័ន មកធ្វើជាមណ្ឌលកសិណ ឲ្យជារបស់ដែលខ្លួននាំយកទៅបាន ដោយន័យដែលលោកពោលមកហើយ ក្នុងបឋវីកសិណ ឬក៏ ត្រង់ជញ្ជាំងតែម្តងក៏បាន ហើយកាត់ជុំវិញ តាមពណ៌ដែលមានចំណែកមិនស្មើគ្នា ។ បន្ទាប់ពីនោះ ព្រះយោគីគប្បីញុំាងការធ្វើទុកក្នុងចិត្ត ឲ្យប្រព្រឹត្តទៅថា “នីលំ នីលំ” ដូច្នេះ តាមន័យដែលលោកពោលហើយ ក្នុងបឋវីកសិណ ។ សូម្បីក្នុងនីលកសិណនេះ ទោសនៃកសិណក៏ប្រាកដ ក្នុងឧគ្គហនិមិត្ត ។ វត្ថុទាំងឡាយមានកេសរ, ទង និង ចន្លោះនៃត្របកជាដើម រមែងប្រាកដឡើង។ បដិភាគនិមិត្ត របូតហើយអំពីមណ្ឌលនៃកសិណ ប្រាកដដូចជាទង នៃត្នោត ជាវិការៈនៃកែវ ឰដ៏អាកាស ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាប តាមន័យដែលលោកពោលហើយនុ៎ះឯង ។

នីលកសិណ ចប់ហើយ ។

(បីតកក្ខសិណ)

*(១១២) សូម្បីក្នុងបីតកក្កសិណ ក៏ន័យដូចគ្នានេះដែរ ។ តាមពិតពាក្យនេះ ព្រះអដ្ឋកថាចារ្យពោលហើយថា "ព្រះយោគី កាលរៀនយកនូវបីតកក្កសិណ រមែងរៀនយកនូវនិមិត្ត ក្នុងពណ៌លឿង គឺក្នុងផ្កាខ្លះ ក្នុងសំពត់ខ្លះ ក្នុងធាតុមានពណ៌ខ្លះ" ដូច្នេះ ។ ព្រោះហេតុនោះ សូម្បីក្នុងបីតកក្កសិណនេះ និមិត្ត រមែងកើតឡើង ដល់ព្រះយោគី អ្នកមានបុណ្យមានការកសាងធ្វើទុកហើយ ព្រោះគ្រាន់តែបានឃើញគំនរផ្កាកម្រង ឬ កម្រាលផ្កាដែលមានពណ៌ដូច្នោះ ឬក៏ នូវវត្ថុណាមួយក្នុងចំណោមសំពត់មានពណ៌លឿង និង ធាតុពណ៌លឿង ដូចជានិមិត្ត កើតឡើង ដល់ព្រះចិត្តគុត្តត្ថេរ យ៉ាងនោះឯង ។ បានឮមកថា: កាលលោកដ៏មានអាយុអង្គនោះ ឃើញនូវគ្រឿងបូជាលើអាសនៈ ដែលគេធ្វើហើយ ដោយផ្កាចន្ទន៍ក្រហមទាំងឡាយ ក្នុងចិត្តបព៌តវិហារ, និមិត្តប៉ុនអាសនៈ បានកើតឡើងហើយ ព្រមជាមួយនឹងការឃើញតែម្តង ។ ចំណែកព្រះយោគីក្រៅនេះ គប្បីយកផ្កាទាំងឡាយមានផ្កាកណ្ណិកាជាដើម ឬ សំពត់ពណ៌លឿង ឬក៏ ធាតុ (ពណ៌លឿង) មកធ្វើជាកសិណ តាមន័យដែលលោកពោលហើយ ក្នុងនីលកសិណនុ៎ះឯង ហើយញុំាងមនសិការ ឲ្យប្រព្រឹត្តទៅ ថា "បីតកំ បីតកំ" ដូច្នេះ ។ ពាក្យដ៏សេស ដូចគ្នាហ្នឹងឯង ។*

*បីតកក្កសិណ ចប់ហើយ ។*

(លោហិតក្ខសិណ)

*(១១៣) សូម្បីក្នុងលោហិតកក្កសិណ ក៏មានន័យដូចគ្នានេះដែរ ។ មែនពិត ពាក្យនេះ ព្រះអដ្ឋកថាចារ្យពោលហើយថា "ព្រះយោគីកាលរៀនយកនូវលោហិតកក្កសិណ រមែងរៀនយកនូវនិមិត្ត ក្នុងវត្ថុមានពណ៌*



*ក្រហម គឺក្នុងផ្កាខ្លះ ក្នុងសំពត់ខ្លះ ក្នុងធាតុមានពណ៌ខ្លះ" ដូច្នេះ។ ព្រោះហេតុនោះ សូម្បីក្នុងលោហិតកក្កសិណនេះ និមិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានបុណ្យ មានការកសាងធ្វើទុកហើយ ព្រោះគ្រាន់តែឃើញគំនរនៃផ្កាកម្រង មានផ្កាសិរមាន់ជាដើម ឬ កម្រាលផ្កាដែលមានពណ៌ដូច្នោះ ឬក៏ នូវវត្ថុណាមួយ ក្នុងចំណោមសំពត់ពណ៌ក្រហម, កែវពណ៌ក្រហម និង ធាតុពណ៌ក្រហម ។ ចំណែកព្រះយោគីក្រៅនេះ គប្បីយកផ្កាទាំងឡាយមានផ្កាចបា, ផ្កាសិរមាន់ និង ផ្កាស្មៅកន្ទុយដំរីក្រហម ជាដើម ឬ សំពត់ក្រហម ឬក៏ ធាតុ (ពណ៌ក្រហម) មកធ្វើជាកសិណ តាមន័យដូចបានពោលមកហើយហ្នឹងឯង ក្នុងនីលកក្កសិណ ហើយញុំាងមនសិការ ឲ្យប្រព្រឹត្តទៅ ថា "លោហិតកំ លោហិតកំ" ដូច្នេះ ។ ពាក្យដ៏សេស ក៏ដូចគ្នានោះដែរ ។ លោហិតកក្កសិណ ចប់ហើយ ។*

(ឱទាតក្ខសិណ)

*(១១៤) បណ្ឌិត គប្បីជ្រាបវិនិច្ឆ័យ ក្នុងឱទាតកក្កសិណផងដែរ ។ ព្រោះបាលីថា "ព្រះយោគី កាលរៀនយកឱទាតកក្កសិណ រមែងរៀនយកនូវនិមិត្ត ក្នុងពណ៌-ស គឺក្នុងផ្កាខ្លះ ក្នុងសំពត់ខ្លះ ក្នុងធាតុមានពណ៌ខ្លះ" ដូច្នេះ, និមិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានបុណ្យ មានការកសាងធ្វើហើយមុន ព្រោះគ្រាន់តែឃើញគំនរផ្កាកម្រង ឬ កម្រាលផ្កានួនស្រី និង ផ្កាម្លិះជាដើម ឬ គំនរផ្កាព្រលិត-ស និង ផ្កាឈូកជាដើម ឬក៏ សំពត់ពណ៌-ស និង ធាតុពណ៌-ស ទាំងឡាយ របស់ណាមួយ ។ សូម្បីក្នុងមណ្ឌលនៃសំណ មណ្ឌលប្រាក់ មណ្ឌលនៃព្រះច័ន្ទទាំងឡាយ និមិត្ត ក៏កើតឡើងដូចគ្នាដែរ ។ ព្រះយោគី ក្រៅពីនេះ គប្បីយកផ្កា-ស ទាំងឡាយ ឬ សំពត់ពណ៌-ស ឬក៏ ធាតុពណ៌-ស មកធ្វើជាកសិណ*

តាមន័យដែលពោលមកហើយ ក្នុងនីលកសិណហ្នឹងឯង ហើយញ៉ាំង មនសិការ ឲ្យប្រព្រឹត្តទៅថា "ឱទាតំ ឱទាតំ" ដូច្នេះ ។ ពាក្យដ៏សេស ក៏ដូចគ្នានុ៎ះដែរ ។ ឱទាតកសិណ ចប់ ។

(អាលោកកសិណ)

(១១៥) ឯក្នុងអាលោកកសិណ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ(ដូចតទៅ) ព្រោះបាលីថា "ព្រះយោគី កាលរៀនយកអាលោកកសិណ រមែងរៀនយកនូវនិមិត្ត ក្នុងពន្លឺ គឺ ក្នុងប្រហោងជញ្ជាំងខ្លះ ក្នុងប្រហោងស្លឹកត្នោតខ្លះ ក្នុងចន្លោះបង្អួចខ្លះ" ដូច្នេះ, និមិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានបុណ្យមានការកសាងធ្វើទុកហើយជាដំបូង ព្រោះគ្រាន់តែឃើញពន្លឺព្រះអាទិត្យ ឬ ពន្លឺព្រះច័ន្ទដែលចូលទៅតាមប្រហោងទាំងឡាយមានប្រហោងជញ្ជាំងជាដើម ប្រហោងណាមួយ ហើយញ៉ាំងមណ្ឌល ឲ្យកើតឡើង ពួដ៏ជញ្ជាំង ឬ លើផែនដី ពុំនោះសោត ចេញតាមចន្លោះនៃមែកឈើ ដែលមានស្លឹកក្រាស់ ឬ តាមប្រឡោះ នៃមណ្ឌលមែកឈើដែលក្រាស់ ហើយញ៉ាំងមណ្ឌល ឲ្យកើតឡើង លើផែនដីនុ៎ះឯង ក៏បានដែរ ។ ឯព្រះយោគីក្រៅនេះ គប្បីចំរើនមណ្ឌលនៃពន្លឺ មានប្រការដូចបានពោលហើយនោះឯងថា "ឱភាសោ ឱភាសោ" ឬថា "អាលោកោ អាលោកោ" ដូច្នេះ ក៏បាន ។ ព្រះយោគី កាលមិនអាច(ធ្វើ)ដូច្នោះបានទេ គប្បីអុជប្រទីប ក្នុងក្អម បិទមាត់ក្អម ធ្វើប្រហោងក្នុងក្អមហើយ ដាក់ឲ្យមានមុខទៅរកជញ្ជាំង ។ ពន្លឺប្រទីប ចេញតាមប្រហោងនោះហើយ ធ្វើឲ្យទៅជាមណ្ឌលត្រង់ជញ្ជាំង ។ ព្រះយោគី គប្បីចំរើនមណ្ឌលនោះ ថា : "អាលោកោ អាលោកោ" ដូច្នេះ។ មណ្ឌលនៃពន្លឺនេះ ជាពន្លឺឋិតនៅបានយូរជាងពន្លឺក្រៅអំពីនេះ ។ ឧគ្គហនិមិត្ត ក្នុងអាលោកកសិណនេះ ជា



និមិត្តប្រាកដស្មើ ដោយមណ្ឌលដែលតាំងឡើងហើយពួដ៏ជញ្ជាំង ឬ លើផែនដីនុ៎ះឯង ។ បដិភាគនិមិត្តជានិមិត្តក្រាស់ និង ថ្លា ប្រាកដស្មើដោយគំនរនៃពន្លឺ ។ ពាក្យដ៏សេសក៏ដូចគ្នានោះដែរ ។ អាលោកកសិណចប់ ។

(បរិច្ឆិន្នាកាសកសិណ)

(១១៦) បណ្ឌិត គប្បីជ្រាបសេចក្ដីវិនិច្ឆ័យ ក្នុងអាកាសកសិណ ដែលលោកកំណត់ហើយផងដែរ, ព្រោះបាលីថា "ព្រះយោគី កាលរៀនយកនូវអាកាសកសិណ រមែងរៀនយកនូវនិមិត្ត ក្នុងអាកាស គឺ ត្រង់ប្រហោងជញ្ជាំងក្ដី ត្រង់ប្រហោងស្លឹកត្នោតក្ដី ត្រង់ចន្លោះបង្អួចក្ដី" ដូច្នេះ, និមិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានបុណ្យ មានការកសាងធ្វើទុកហើយជាមុន ព្រោះគ្រាន់តែឃើញប្រហោងណាមួយ ក្នុងចំណោមប្រហោងទាំងឡាយ មានប្រហោងជញ្ជាំងជាដើមប៉ុណ្ណោះ ។ ព្រះយោគីក្រៅនេះ គប្បីធ្វើប្រហោងឲ្យមានប្រមាណ១ ចំអាម ៤ ធ្នាប់ ពួដ៏មណ្ឌប ដែលបុគ្គលប្រក់ជិតល្អហើយ ឬ ពួដ៏កំណាត់ឯណាមួយ បណ្ដាកំណាត់ទាំងឡាយ មានកំណាត់ស្បែក និង កន្ទេលរំចេកជាដើម ហើយចំរើនប្រហោងនោះឯង ដែលមានប្រហោងនៃជញ្ជាំងជាដើម ជាប្រភេទ ថា "អាកាសោ អាកាសោ" ដូច្នេះ ។ ឧគ្គហនិមិត្ត ក្នុងអាកាសកសិណនេះ ជានិមិត្ត ប្រាកដស្មើនឹងប្រហោង ព្រមទាំងទីទាំងឡាយ មានទីបំផុត នៃជញ្ជាំងជាដើមនុ៎ះឯង សូម្បីព្រះយោគីចំរើន ក៏មិនចំរើនដែរ ។ បដិភាគ-និមិត្ត ដូចជាមណ្ឌលនៃអាកាសមែនពិត រមែងប្រាកដឡើងផង កាលព្រះយោគីចំរើន ក៏រមែងចំរើនបានផង ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងបឋវីកសិណនុ៎ះឯង ។

បរិច្ឆិន្នាកាសកសិណ ចប់ហើយ ។

ព្រះទសពល ព្រះអង្គទ្រង់ឃើញ នូវធម៌គ្រប់យ៉ាង បាន ត្រាស់ហើយនូវកសិណទាំងឡាយ ១០ ឯណា កសិណទាំងឡាយនោះ ជាហេតុនៃចតុក្កជ្ឈាន និង បញ្ចកជ្ឈាន ក្នុងថ្នាក់រូបាវចរ ដូចពណ៌នាមកនេះ ។ បណ្ឌិត បានដឹងច្បាស់នូវកសិណទាំងឡាយ ១០ នោះ និង ន័យនៃការចំរើននូវកសិណទាំង ១០ នោះនេះ យ៉ាងនេះហើយ គប្បីដឹងច្បាស់បកិណ្ណកកថានេះ ដោយក្រៃលែង ក្នុងកសិណទាំងនោះផងចុះ ។

(បកិណ្ណកកថា)

*(១១៧) ក៏ឫទ្ធិទាំងឡាយមានជាអាទិ៍យ៉ាងនេះ គឺ ភាពនៃឫទ្ធិ មានជាដើមដូច្នេះ គឺ បុគ្គលសូម្បីម្នាក់បណ្ដាលទៅជាបុគ្គលច្រើននាក់ក៏បាន, និម្មិតផែនដី លើអាកាស ឬ លើទឹក ហើយដើរទៅ ដោយជើង ក៏បាន ឬក៏ សំរេចឥរិយាបថ មានការឈរ និង ការអង្គុយជាដើមក៏បាន, បានចំពោះនូវអភិភាយតនៈ គឺហេតុជាគ្រឿងគ្របសង្កត់ ដោយន័យតិចតួច និង ន័យមិនមានប្រមាណ រមែងសំរេចបាន ដោយអំណាចបឋវីកសិណ ក្នុងចំណោម នៃកសិណទាំងឡាយនេះ ។*

*ឫទ្ធិទាំងឡាយមានជាអាទិ៍ យ៉ាងនេះ គឺ ងើបឡើង និង មុជចុះក្នុងផែនដីបាន, ធ្វើតំណក់ទឹក (ភ្លៀង) ឲ្យកើតឡើងបាន, និម្មិត នូវទឹកមានស្ទឹង និង សមុទ្របាន, ធ្វើផែនដី, ភ្នំ និង ប្រាសាទជាដើម ឲ្យកម្រើក ក៏បានដូច្នេះ រមែងសម្រេចដោយអំណាចអាបោកសិណ ។*

*ឫទ្ធិទាំងឡាយ មានជាអាទិ៍ យ៉ាងនេះ គឺ : ការបន្ទុយផ្សែងបាន,*



*ការធ្វើភ្លើងឲ្យឆេះបាន, ការធ្វើភ្លៀងរងើកភ្លើង ឲ្យកើតឡើងបាន, យកភ្លើងទៅរំលត់ភ្លើងបាន, ជាអ្នកអាចនឹងដុតវត្ថុ ដែលខ្លួនត្រូវការនោះបាន មែនពិត, ធ្វើនូវពន្លឺដើម្បីប្រយោជន៍ ដល់ការមើលរូបឃើញ ដោយទិព្វចក្ខុបាន, ធ្វើសរីរៈឲ្យឆេះ ដោយតេជោធាតុ ក្នុងសម័យបរិនិព្វានបាន ដូច្នេះ រមែងសម្រេច ដោយអំណាច នៃតេជោកសិណ ។*

*ឫទ្ធិទាំងឡាយ មានជាអាទិ៍យ៉ាងនេះ គឺៈ ដើរទៅ ដូចជាដំណើរនៃខ្យល់ព្យុះ, ធ្វើគ្រាប់ភ្លៀងជាវិការៈនៃខ្យល់ ឲ្យកើតឡើងបាន ដូច្នេះ រមែងសម្រេចបាន ដោយអំណាចនៃវាយោកសិណ ។*

*ឫទ្ធិទាំងឡាយមានជាអាទិ៍យ៉ាងនេះ គឺ និម្មិតរូបមានពណ៌ខៀវបានផង, ធ្វើឲ្យងងឹតបានផង, បានចំពោះនូវអភិភាយតនៈ គឺជាគ្រឿងគ្របសង្កត់ ដោយន័យមានសម្បុរល្អ និងសម្បុរអាក្រក់បានផង, បានសំរេចដល់សុភវិមោក្ខផង ដូច្នេះ រមែងសំរេចបានដោយអំណាចនីលកសិណ។*

*ឫទ្ធិទាំងឡាយ មានជាអាទិ៍ យ៉ាងនេះ គឺៈ និម្មិតនូវរូបមានពណ៌លឿងបាន, ផ្សងបានថាៈ វត្ថុនេះ ចូរកើតទៅជាមាសក៏បាន, បានចំពោះនូវអភិភាយតនៈ តាមន័យដែលលោកពោលមកហើយនុ៎ះឯង និង បានលុះនូវសុភវិមោក្ខបានផង ដូច្នេះ រមែងសម្រេចបាន ដោយអំណាច នៃបីតកសិណ ។*

*ឫទ្ធិទាំងឡាយ មានជាអាទិ៍ យ៉ាងនេះ គឺៈ និម្មិតនូវរូបមានពណ៌ក្រហមបាន, បានចំពោះនូវអភិភាយតនៈ និង បានលុះសុភវិមោក្ខបានផង តាមន័យដែលលោកពោលមកហើយនុ៎ះឯងដូច្នេះ រមែងសំរេចបាន ដោយអំណាចនៃលោហិតកសិណ ។*

*ឫទ្ធិទាំងឡាយ មានជាអាទិ៍យ៉ាងនេះ គឺៈ និម្មិតនូវរូបមានពណ៌-ស*

បាន, ធ្វើនូវបីនមិទ្ទៈ ឲ្យនៅឆ្ងាយបាន, កំចាត់បង់នូវងងឹតក៏បាន, ធ្វើពន្លឺដើម្បីប្រយោជន៍ដល់ការឃើញរូប ដោយទិព្វចក្ខុក៏បាន ដូច្នេះ រមែងសម្រេចបាន ដោយអំណាចឱទាតកសិណ ។

ឫទ្ធិទាំងឡាយ មានជាអាទិ៍ យ៉ាងនេះ គឺៈ និម្មិតនូវរូប មានពន្លឺល្អបាន, ធ្វើនូវបីនមិទ្ទៈ ឲ្យនៅក្នុងទីឆ្ងាយបាន, កំចាត់បង់នូវងងឹតក៏បាន, ធ្វើពន្លឺដើម្បីប្រយោជន៍ ដល់ការឃើញរូប ដោយទិព្វចក្ខុ ក៏បាន ដូច្នេះ រមែងសម្រេចបាន ដោយអំណាចអាលោកកសិណ ។

ឫទ្ធិទាំងឡាយ មានជាអាទិ៍យ៉ាងនេះ គឺៈ និម្មិតនូវរបស់ទាំងឡាយ ដែលកំបាំងជិត ឲ្យបើកមក និម្មិតនូវអាកាស (ទីចំហ) សូម្បីក្នុងទីទាំងឡាយមានខាងក្នុងផែនដី និង ភ្នំជាដើម ហើយសំរេចនូវឥរិយាបថបាន, ដើរទៅមិនទើសទាក់ ក្នុងទីទាំងឡាយ មានខាងក្រៅជញ្ជាំងជាដើមក៏បាន ដូច្នេះ រមែងសម្រេចបាន ដោយអំណាចនៃអាកាសកសិណ ។

(ការប្លែកគ្នានៃកសិណ)

កសិណទាំងអស់ហ្នឹងឯង តែងបាននូវសេចក្តីប្លែកគ្នានេះ គឺៈ ខាងលើ, ខាងក្រោម, ទទឹង, មិនមានពីរ, មិនមានប្រមាណ” ។ មែនពិត ព្រះមានព្រះភាគ ទ្រង់បានត្រាស់ពាក្យនេះ ថា “បុគ្គលពួកខ្លះ កំណត់នូវបឋវីកសិណ ខាងលើ, ពួកខ្លះកំណត់ ខាងក្រោម, ពួកខ្លះ កំណត់ទទឹង, មិនមានពីរ, មិនមានប្រមាណ” ដូច្នេះជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យថា “ឧទ្ធំ” គឺ មានមុខឆ្ពោះទៅកាន់ផ្ទៃនៃអាកាសខាងលើ ។ ពាក្យថា “អធោ” គឺ មានមុខឆ្ពោះទៅកាន់ផែនដីខាងក្រោម ។ ពាក្យថា “តិរិយំ” គឺ កំណត់ហើយ ដោយជុំវិញ ឲ្យដូចជាមណ្ឌលនៃស្រែ ។ មែនពិត ព្រះយោគីពួកខ្លះចំរើនកសិណ តែ



ខាងលើម្យ៉ាង, ពួកខ្លះ ចំរើនកសិណខាងក្រោម, ពួកខ្លះ ចំរើនកសិណដោយជុំវិញ ឬក៏ ផ្សព្វផ្សាយទៅ យ៉ាងដូច្នេះ ដោយហេតុនោះៗ ដូចជាបុគ្គលអ្នកប្រាថ្នាចង់ឃើញរូបដោយចក្ខុទិព្វ ផ្សាយពន្លឺទៅយ៉ាងដូច្នោះ ។ ព្រោះហេតុដូច្នោះ បានជាព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា “ឧទ្ធំ អធោ តិរិយំ” ដូច្នេះ ។

ចំណែកពាក្យថា “អទ្វយំ” នេះ ជាពាក្យដែលព្រះអង្គត្រាស់ហើយ ដើម្បីភាវៈនៃកសិណមួយ មិនចូលទៅកាន់កសិណមួយទៀតបាន។ ដូចជាកាលបុគ្គលចុះទឹកហើយ, មានតែទឹកម្យ៉ាងប៉ុណ្ណោះឯង ក្នុងទិសទាំងពួង, វត្ថុដទៃមិនមានឡើយ យ៉ាងណា, បឋវីកសិណ ក៏ជាបឋវីកសិណតែម្យ៉ាង, ការប្របល់គ្នានឹងកសិណដទៃ មិនមាន ដល់បឋវីកសិណនោះឡើយ យ៉ាងនោះដែរ, ន័យនេះ បណ្ឌិតគប្បីជ្រាប ក្នុងកសិណទាំងពួងដូច្នេះឯង ។

ពាក្យថា “អប្បមាណំ” នេះ ព្រះអង្គត្រាស់ហើយ ដោយអំណាចការផ្សាយទៅ នៃកសិណនោះមិនមានប្រមាណ ។ មែនពិត ព្រះយោគីកាលផ្សាយកសិណនោះ ដោយចិត្ត រមែងផ្សាយទៅទាំងអស់តែម្តង ។ មិនប្រកាន់ប្រមាណថា “ទីនេះជាខាងដើម, ទីនេះជាកណ្តាលនៃកសិណនោះ” ដូច្នេះឡើយ ។

ក៏សត្វទាំងឡាយនោះឯណា ដែលព្រះដ៏មានព្រះភាគត្រាស់ហើយថា “ជាអ្នកប្រកបព្រមហើយ ដោយសភាវៈជាគ្រឿងរារាំង គឺកម្ម ក្តី, ជាអ្នកប្រកបព្រមហើយ ដោយសភាវៈជាគ្រឿងរារាំងគឺកិលេស ក្តី, ជាអ្នកប្រកបព្រមហើយ ដោយសភាវៈជាគ្រឿងរារាំង គឺវិបាក ក្តី, ជាអ្នកមិនមានសទ្ធា, មិនមានឆន្ទៈ, ឥតប្រាជ្ញា, ជាមនុស្សមិនគួរ ដើម្បីចុះចិត្ត

កាន់នូវនិយាម គឺអរិយមគ្គដែលជាផ្លូវត្រឹមត្រូវ ក្នុងធម៌ទាំងឡាយ ដែលជាកុសល” ដូច្នេះ, ការចំរើន សូម្បីក្នុងកសិណមួយ ក៏មិនបានសម្រេចដល់បណ្ដាសត្វទាំងឡាយនោះ សូម្បីតែសត្វមួយឡើយ ។

បណ្ដាបទទាំងនោះ បទថា “កម្មាវរណេន សមន្នាគតា” គឺ ប្រកបព្រមហើយ ដោយអនន្តរិយកម្ម ។ បទថា “កិលេសាវរណេន សមន្នាគតា” គឺប្រកបហើយដោយនិយតមិច្ឆាទិដ្ឋិផង ជាឧភតោព្យញ្ជនកៈ និងជាខ្ទើយផង ។ ពាក្យថា “វិបាកាវរណេន សមន្នាគតា” គឺ ជាអ្នកមានបដិសន្ធិជាអហេតុកៈ និងជាទ្វិហេតុកៈ ។ ពាក្យថា “អស្សទ្ធា” គឺប្រាសចាកសទ្ធា ក្នុងព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ។ ពាក្យថា “អច្ឆន្ទិកា” គឺ ប្រាសចាកឆន្ទៈ ក្នុងបដិបទា ដែលមិនមែនជាសត្រូវ ។ ពាក្យថា “ទុប្បញ្ញា” គឺ ប្រាសចាកសម្មាទិដ្ឋិ ដែលជាលោកិយៈ និងលោកុត្តរៈ ។ ពាក្យថា “អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ” នោះ សេចក្ដីថា ជាអ្នកមិនគួរ ដើម្បីចុះចិត្តស៊ប់កាន់អរិយមគ្គ ពោលគឺសេចក្ដីទៀងទាត់ផង ពោលគឺផ្លូវដ៏ត្រឹមត្រូវផង ក្នុងធម៌ទាំងឡាយដែលជាកុសល ។

មួយវិញទៀត មិនមែនតែក្នុងកសិណប៉ុណ្ណោះទេ ការចំរើន សូម្បីក្នុងកម្មដ្ឋានទាំងឡាយដទៃទៀត ក៏មិនសម្រេចបាន ដល់សត្វទាំងឡាយនោះ សូម្បីសត្វមួយ ។ ព្រោះហេតុនោះ កុលបុត្រ សូម្បីប្រាសចាកវិបាកាវរណៈហើយ គប្បីវៀរស្រឡះនូវកម្មាវរណៈ និងកិលេសាវរណៈឲ្យបានឆ្ងាយ ញុំាងសទ្ធា, ឆន្ទៈ និង បញ្ញា ឲ្យចំរើន ដោយវុឌ្ឍិធម៌ទាំងឡាយ មានការស្ដាប់ធម៌ របស់សប្បុរស និង កិរិយាចូលទៅផ្ដេកផ្ដិត



ជាមួយនឹងសប្បុរសជាដើម ហើយធ្វើសេចក្ដីព្យាយាមក្នុងកិរិយាប្រកបរឿយៗ នូវកម្មដ្ឋាន ដូចបានរៀបរាប់មកនេះឯង ។

បរិច្ឆេទ ទី៥ ឈ្មោះសេសកសិណនិទ្ទេស
ក្នុងអធិការនៃសមាធិភាវនា ក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គ
ដែលខ្ញុំរៀបរៀងហើយ
ដើម្បីប្រយោជន៍ដល់កិរិយាញុំាងសាធុជនឲ្យរីករាយ
ចប់ហើយ ដោយប្រការដូច្នេះ ។

❃ ❦ ❃

សៀវភៅ **វិសុទ្ធិមគ្គប្រែ** ភាគទី២ និង ភាគទី៣
នឹងបោះពុម្ពផ្សាយចែកជាធម្មទាន នៅពេលខាងមុខនេះ
សូមពុទ្ធបរិស័ទជួយឧបត្ថម្ភ ក្នុងកិច្ចការធម្មទាននេះ
តាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន
សូមទាក់ទង: **ភិក្ខុ មហាយិន-នឿន** (៧១៤) ៧៤៤-២៨៣៤
**ភិក្ខុ ប្រាក់-ផល្លី** ០៩២-៩៤-៦៧-៨៧

សូមអរគុណ

*(១១៨) ក៏ក្នុងអសុភៈ ដែលមិនមានវិញ្ញាណទាំង ១០ គឺ :* ឧទ្ធុមាតកអសុភ, វិនីលកអសុភ, វិបុព្វកអសុភ, វិច្ឆិទ្ទកអសុភ, វិក្ខាយិតកអសុភ, វិក្ខិត្តកអសុភ, ហតវិក្ខិត្តកអសុភ, លោហិតកអសុភ, បុឡុវកអសុភ, អដ្ឋិកអសុភ *ដែលលោកសំដែងចេញហើយ ក្នុងលំដាប់នៃកសិណ,*

(ឧទ្ធុមាតកអសុភ)

*អសុភ ដែលឈ្មោះថា ឧទ្ធុមាតៈ ព្រោះជាសាកសពនៃសរីរៈដែលហើមប៉ោងឡើង តាមលំដាប់អំពីការអស់ទៅនៃជីវិត ដូចជាគេយកស្នប់សប់ ។ អសុភហើមប៉ោងឡើងហ្នឹងឯង ហៅថា* ឧទ្ធុមាតកអសុភ *។ មួយទៀត ឧទ្ធុមាតកអសុភ ឈ្មោះថា ជាអសុភដែលគេគួរខ្ពើម ព្រោះជារបស់ដែលគួរខ្ពើមរអើម ព្រោះហេតុនោះ ទើបឈ្មោះថា ឧទ្ធុមាតក-អសុភ ដែលគួរខ្ពើម ។ ពាក្យថា "អសុភដែលហើមឡើង" នេះ ជាឈ្មោះសរីរៈនៃសាកសពដែលមានសភាពដូច្នោះ ។*

(វិនីលកអសុភ)

*អសុភ ដែលមានពណ៌ខៀវ លាយហើយ ដោយពណ៌ផ្សេងៗ ហៅថា អសុភមានពណ៌ខៀវ ។ អសុភ ដែលមានពណ៌ខៀវហ្នឹងឯង ឈ្មោះថា* វិនីលកអសុភ *។ ន័យមួយទៀត វិនីលកអសុភ ឈ្មោះថា ជាអសុភដែលគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះហេតុនោះ ទើបឈ្មោះថា វិនីលកអសុភ ដែលគួរខ្ពើម ។ ពាក្យថា "អសុភមានពណ៌ខៀវ" នេះ ជាឈ្មោះសរីរៈនៃសាកសពស្រស់ ដែលមានពណ៌ក្រហមក្នុងទីដែលមានសាច់ក្រាស់ទាំងឡាយ មានពណ៌-ស ក្នុងទីដែលមានខ្ទុះ*



*ទៅកកហើយ តែភាគច្រើន មានពណ៌ខៀវ ក្នុងទីដែលមានពណ៌ខៀវដូចជារុំហើយ ដោយសំពត់សាដកមានពណ៌ខៀវ យ៉ាងនេះឯង ។*

(វិបុព្វកអសុភ)

*អសុភ ដែលមានទឹកខ្ទុះហូរចេញមក ក្នុងទីដែលប្រេះបែកទាំងឡាយ ឈ្មោះថា អសុភមានខ្ទុះហូរចេញ ។ វិបុព្វៈហ្នឹងឯង ឈ្មោះថា* វិបុព្វកអសុភ *។ មួយទៀត វិបុព្វកអសុភ ឈ្មោះថា ជាអសុភដែលគួរខ្ពើម ព្រោះជារបស់ដែលគេគួរខ្ពើម ព្រោះហេតុនោះ ទើបឈ្មោះថា វិបុព្វកអសុភ ។ ពាក្យថា "*វិបុព្វកៈ*" នេះ គឺជាឈ្មោះនៃសរីរៈនៃសាកសពដែលមានពណ៌យ៉ាងដូច្នោះ ។*

(វិច្ឆិទ្ទកអសុភ)

*អសុភ ដែលបែកដាច់ចេញ ដោយ ២ ចំណែក លោកហៅថា វិច្ឆិទ្ទកៈ ។ វិច្ឆិទ្ទកៈហ្នឹងឯង ឈ្មោះថា* វិច្ឆិទ្ទកអសុភ *។ មួយទៀត វិច្ឆិទ្ទកអសុភ ឈ្មោះថា ជាអសុភដែលគេគួរខ្ពើម ព្រោះជារបស់ដែលគេគួរខ្ពើម ព្រោះហេតុនោះ ទើបឈ្មោះថា វិច្ឆិទ្ទកអសុភ ។ ពាក្យថា* "វិច្ឆិទ្ទកៈ" *នេះ ជាឈ្មោះនៃសរីរៈ នៃសាកសពស្រស់ ដែលគេកាត់ហើយត្រង់កណ្តាល ។*

(វិក្ខាយិតកអសុភ)

*អសុភឯណា ដែលសត្វទាំងឡាយ មានស្វាន និង ចចកជាដើម ខាំទំពាស៊ីហើយ ដោយអាការៈផ្សេងៗ គ្នា ខាងនេះខ្វះ ខាងនោះខ្វះ ហេតុនោះ អសុភនោះ ឈ្មោះថា* វិក្ខាយិតកអសុភ *។ អសុភដែលមានសត្វស្វាន និងចចកហែកស៊ីហ្នឹងឯង ឈ្មោះថា វិក្ខាយិតកអសុភ ។ មួយវិញទៀត វិក្ខាយិតកអសុភ ឈ្មោះថា ជាអសុភដែលគេគួរខ្ពើម*

ព្រោះជារបស់ដែលគេគួរខ្ពើម ព្រោះហេតុនោះ ទើបឈ្មោះថា វិក្ខាយិតកអសុភ ។ ពាក្យថា "វិក្ខាយិតកៈ" នេះ ជាឈ្មោះ នៃសរីរៈ នៃសាកសពស្រស់ ដែលមានសភាពបែបនោះ ។

(វិក្ខិត្តកអសុភ)

អសុភ ដែលគេចោលរាត់រាយហើយ ឈ្មោះថា វិក្ខិត្តកអសុភ ។ អសុភ ដែលគេចោលរាត់រាយទុំះឯង ឈ្មោះថា វិក្ខិត្តកអសុភ ។ មួយទៀត វិក្ខិត្តកអសុភ ឈ្មោះថា ជាអសុភដែលគេគួរខ្ពើម ព្រោះជារបស់ដែលគួរខ្ពើម ព្រោះហេតុនោះ ទើបឈ្មោះថា វិក្ខិត្តកអសុភ ។ ពាក្យថា "វិក្ខិត្តកៈ" នេះ គឺជាឈ្មោះនៃសរីរៈនៃសាកសពដែលគេបោះចោលហើយ ក្នុងទីនោះៗ យ៉ាងនេះ គឺៈ ដៃទៅដោយផ្សេង, ជើងទៅដោយផ្សេង, ក្បាលទៅដោយផ្សេង ដូច្នេះជាដើម ។

(ហតវិក្ខិត្តកអសុភ)

អសុភនោះ ត្រូវគេចិញ្ច្រាំហើយផង ត្រូវគេបោះចោលរាត់រាយហើយ ដោយន័យមុនទុំះឯងផង ព្រោះហេតុនោះ អសុភនោះ ឈ្មោះថា ហតវិក្ខិត្តកអសុភ ។ ពាក្យថា "ហតវិក្ខិត្តកៈ" នេះ គឺជាឈ្មោះនៃសរីរៈនៃសាកសព ដែលគេចិញ្ច្រាំនឹងកាំបិត ត្រង់អវយវៈតូច-ធំ ទាំងឡាយ ដោយអាការៈដូចជាជើងក្អែកហើយ បោះចោលរាត់រាយ ដោយន័យដែលបានពោលហើយទុំះឯង ។

(លោហិតកអសុភ)

អសុភ ដែលឈ្មោះថា លោហិតកៈ ព្រោះមានលោហិតរាត់រាយខ្ចាត់ខ្ចាយ ហូរចេញមកអំពីខាងនេះផង ខាងនោះផង ។ ពាក្យថា "លោហិតកៈ" នេះ ជាឈ្មោះនៃសរីរៈនៃសាកសពដែលស្រស់ ប្រឡាក់



ដោយឈាមដែលហូរចេញមក ។

(បុឡុវកអសុភ)

ដង្កូវទាំងឡាយ ឈ្មោះថា បុឡុវៈ ។ ដង្កូវទាំងឡាយ រវើករវាមក្នុងអសុភនោះ ព្រោះហេតុនោះ អសុភនោះ ទើបបានឈ្មោះថា បុឡុវកអសុភ (ជាទីចោះនៃដង្កូវ) ។ ពាក្យថា "បុឡុវកៈ" នេះ ជាឈ្មោះនៃសរីរៈនៃសាកសពស្រស់ ដែលពោរពេញហើយដោយដង្កូវ ។

(អដ្ឋិកអសុភ)

ឆ្អឹងហ្នឹងឯង ឈ្មោះថា អដ្ឋិកៈ ។ មួយទៀត ឆ្អឹង ឈ្មោះថា ជារបស់ដែលគួរខ្ពើម ព្រោះជារបស់ដែលគេគួរខ្ពើម ព្រោះហេតុនោះ ទើបឈ្មោះថា អដ្ឋិកអសុភ ។ ពាក្យថា "អដ្ឋិកៈ" នេះ គឺជាឈ្មោះនៃរាងឆ្អឹង ក៏បាន នៃឆ្អឹងមួយដុំ ក៏បាន ។

ក៏ពាក្យទាំងឡាយ មានពាក្យថា ឧទ្ធុមាតកៈ នេះឯង ជាឈ្មោះនៃនិមិត្ត ដែលអាស្រ័យនូវអសុភ មានឧទ្ធុមាតកអសុភជាដើមនេះហើយកើតឡើងក៏បាន ជាឈ្មោះ នៃឈានដែលព្រះយោគី បានចំពោះហើយក្នុងនិមិត្តទាំងឡាយក៏បាន ដូច្នេះឯង ។

(វិធីរៀនឧទ្ធុមាតកអសុភកម្មដ្ឋាន)

(១១៩) ក្នុងអសុភទាំង ១០ នោះ ព្រះយោគី ប្រាថ្នាដើម្បីនឹងញ៉ាំងឧទ្ធុមាតកនិមិត្ត ក្នុងសរីរៈដែលហើមប៉ោង ឲ្យកើតឡើងហើយ ចំរើនឈាន ពោលគឺឧទ្ធុមាតកអសុភ គប្បីចូលទៅរកអាចារ្យ មានប្រការដូចបានពោលហើយ ហើយរៀនយកកម្មដ្ឋាន តាមន័យដែលបានពោលមកហើយ ក្នុងបឋវីកសិណហ្នឹងឯង ។ អាចារ្យនោះ កាលសំដែងនូវកម្មដ្ឋាន ដល់ព្រះយោគីនោះ គប្បីសំដែងនូវវិធីការទាំងអស់ មាន

អប្បនាវិធីជាទីបំផុត យ៉ាងនេះ គឺៈ វិធីនៃការទៅដើម្បីប្រយោជន៍ ដល់អសុភនិមិត្ត, ការកំណត់នូវនិមិត្ត ដោយជុំវិញ, ការរៀនយកនូវនិមិត្ត ដោយអាការៈ ១១ យ៉ាង, ការពិចារណានូវផ្លូវទៅ-មក ។ ចំណែកព្រះយោគីនោះ រៀនយកវិធីទាំងអស់ បានស្រួលបួលហើយ កាលចូលទៅកាន់ទីសេនាសនៈមានប្រការដូចពោលមកហើយ ក្នុងកាលមុនហើយ គប្បីស្វែងរកឧទ្ធុមាតកនិមិត្តនៅចុះ ។

ក៏ព្រះយោគី កាលនៅយ៉ាងនេះ ទុកជាឮនូវពាក្យ របស់ជនទាំងឡាយ ដែលកំពុងតែនិយាយគ្នាថា "សាកសពហើមប៉ោង គឺបុគ្គលទុកហើយ ក្នុងមាត់ផ្លូវ នៃស្រុកឈ្មោះឯណោះក្តី, ត្រង់មាត់ជងព្រៃឈ្មោះឯណោះក្តី, ត្រង់ផ្លូវឈ្មោះឯណោះក្តី, ក្បែរជើងភ្នំឈ្មោះឯណោះក្តី, ក្បែរគល់ឈើ ឈ្មោះឯណោះក្តី, ក្នុងព្រៃស្មសាន ឈ្មោះឯណោះក្តី" ដូច្នេះហើយ ក៏មិនគួរទៅ ក្នុងខណៈនោះភ្លាមទេ ដូចជាបុគ្គល ស្ទុះទៅតាមកន្លែងដែលមិនមែនជាកំពង់នោះឡើយ ។ សួរថាៈ ព្រោះហេតុអ្វី? ។ ឆ្លើយថាៈ ព្រោះថា ធម្មតាអសុភនោះ ជាសាកសពដែលម្រឹគពាឡស្លួនគ្រងហើយផង អមនុស្សស្លួនគ្រងហើយផង ។ សេចក្តីអន្តរាយ ដល់ជីវិត គប្បីមានដល់ព្រះយោគីនោះ ក្នុងទីនៃអសុភនោះមិនខាន ។ ម្យ៉ាងវិញទៀត ផ្លូវដែលទៅ ក្នុងទីនៃអសុភនោះ តែងមាន តាមផ្លូវទ្វារចូលស្រុកខ្លះ, តាមកំពង់ងូតទឹកខ្លះ, តាមទីបំផុតនៃភ្លឺស្រែខ្លះ ។ រូបដែលជាទំនាស់ ក្នុងទីទាំងឡាយនោះ រមែងមកកាន់រង្វង់ចក្ខុ ។ ពុំនោះសោតសរីរៈនោះឯង ជាទំនាស់ ។ មែនពិត សរីរៈ របស់ស្ត្រី ជាវិសភាគដល់បុរស ។ ចំណែកសរីរៈរបស់បុរស ក៏ជាវិសភាគ ដល់ស្ត្រីដែរ ។ សរីរៈនោះទុំះដែលស្លាប់ហើយភ្លាមៗ រមែងប្រាកដថា ជារបស់ល្អពិត ។



សេចក្តីអន្តរាយ នៃព្រហ្មចរិយៈ គប្បីមាន ដល់ព្រះយោគីនោះ ព្រោះអសុភនោះមែនពិត ។ ក៏បើព្រះយោគី ត្រិះរិះនឹងខ្លួនថា "ហេតុនេះ មិនមែនជារឿងធ្ងន់ ដល់ភិក្ខុអ្នកប្រាកដដូចជាអាត្មាអញឡើយ" ដូច្នេះ, ព្រះយោគី អ្នកត្រិះរិះ (នឹងខ្លួន) យ៉ាងនេះ គួរទៅចុះ ។

ក៏ព្រះយោគីនោះ កាលនឹងទៅគប្បីប្រាប់ដល់ព្រះសង្ឃត្ថេរ ឬ ភិក្ខុអ្នកចេះដឹងច្បាស់ដទៃហើយសឹមទៅ ។ ព្រោះហេតុអ្វី? ។ ព្រោះថា បើព្រះយោគីនោះ ត្រូវអនិដ្ឋារម្មណ៍ មានរូប និង សំឡេងជាដើម នៃសត្រូវទាំងឡាយ មានអមនុស្ស, សីហៈ និង ខ្លា ជាដើម ក្នុងព្រៃស្មសាន គ្របសង្កត់ហើយ, អវយវៈតូច-ធំ ទាំងឡាយ ញ័រចំប្រប់ផង, ភោជនដែលឆាន់ហើយតាំងនៅមិនបានផង, អាពាធផ្សេងទៀត ក៏កើតមានផង ។ កាលបើដូច្នោះ ភិក្ខុ មានព្រះសង្ឃត្ថេរជាដើមនោះ នឹងធ្វើនូវបាត្រ និង ចីពរ របស់ព្រះយោគីនោះ ឲ្យទៅជារបស់ដែលទុកដាក់យ៉ាងល្អ ក្នុងវិហារ ហើយបញ្ជូនពួកភិក្ខុកម្លោះ ឬ ពួកសាមណេរទៅមម្រើភិក្ខុនោះ ។ មួយទៀត ពួកចោរដែលមានកម្ម ធ្វើហើយក្តី មិនទាន់ធ្វើហើយក្តី សម្គាល់ថា "ឈ្មោះថា ព្រៃស្មសាន ជាទីគ្មានរង្កៀស" ដូច្នេះ រមែងមកប្រជុំគ្នា ។ ចោរទាំងនោះ ត្រូវពួកមនុស្ស ដេញតាមហើយ ក៏ចោលនូវបង្វិចទ្រព្យ ក្នុងទីជិតនៃភិក្ខុ ហើយរត់ទៅ ក៏មាន ។ មនុស្សទាំងឡាយ ចាប់ភិក្ខុបានហើយ ក៏នឹងបៀតបៀន (ដោយគិត) ថា "ពួកយើងបានឃើញចោរហើយ ព្រមទាំងទ្រព្យជាគ្រឿងធ្វើឲ្យជនវង្វេង (ភស្តុតាង)" ដូច្នេះ។ គ្រានោះ ភិក្ខុមានព្រះសង្ឃត្ថេរជាដើមនោះ របស់ភិក្ខុនោះ នឹងប្រាប់មនុស្សទាំងនោះ ឲ្យបានដឹងថា "អ្នកទាំងឡាយ ចូរកុំបៀតបៀននូវភិក្ខុនេះឡើយ, ភិក្ខុរូបនេះ ប្រាប់ដល់អាត្មាហើយ ទើបទៅ

ដោយកម្មឈ្មោះនេះ” ដូច្នេះហើយ នឹងធ្វើនូវសេចក្ដីសួស្ដី (ដល់ភិក្ខុនោះ) ។ នេះគឺជាអានិសង្ស ក្នុងការប្រាប់ហើយបានទៅ ។

(វិធីនៅពិចារណាអសុភ)

ព្រោះហេតុនោះ ព្រះយោគី បានប្រាប់ដល់ភិក្ខុ មានប្រការដូចបានពោលមកហើយ មានសេចក្ដីពេញចិត្តកើតឡើង ក្នុងការឃើញនូវអសុភនិមិត្ត គប្បីញ៉ាំងបីតិ និង សោមនស្ស ឲ្យកើតឡើងហើយ ទៅតាមវិធីដែលលោកពោលហើយក្នុងអដ្ឋកថាទាំងឡាយ ឈ្មោះថាប្រៀបដូចជាក្សត្រ មានបីតិ និង សោមនស្សកើតហើយ ស្ដេចយាងទៅកាន់ទីអភិសេក, ដូចជាបុគ្គលដែលបូជាយញ្ញ មានបីតិ និង សោមនស្សកើតហើយ តែងទៅកាន់ទីបូជាយញ្ញ, ពុំនោះសោត ដូចជាបុគ្គលអ្នកឥតទ្រព្យ មានបីតិ និង សោមនស្ស កើតហើយ តែងទៅកាន់ទីកំណប់ទ្រព្យ យ៉ាងនោះឯង។ មែនពិត ពាក្យនេះ លោកពោលហើយថា “ព្រះយោគីកាលរៀនយកអសុភនិមិត្ត ដែលជាអសុភហើមប៉ោង ទៅតែម្នាក់ឯង មិនមានបុគ្គលជាគម្រប់ពីរ មានសតិតាំងនៅមាំ មិនវង្វេងវង្វាន់ មានឥន្ទ្រីយ៍ទាំងឡាយ ទៅជាប់នឹងខ្លួន មានចិត្តមិនទៅខាងក្រៅ កាលពិចារណានូវផ្លូវដែលទៅ និង ផ្លូវដែលមក, អសុភនិមិត្ត ដែលជាអសុភហើមប៉ោង ជានិមិត្តដែលគេទុកហើយ ក្នុងប្រទេសណា, ព្រះយោគី ធ្វើដុំថ្មក្ដី, ដំបូកក្ដី, ដើមឈើក្ដី, គុម្ពឈើក្ដី, វល្លិក្ដី ក្នុងប្រទេសនោះ ឲ្យប្រព្រឹត្តទៅជាមួយនឹងនិមិត្ត ធ្វើឲ្យប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍, លុះធ្វើឲ្យប្រព្រឹត្តទៅជាមួយនឹងនិមិត្ត លុះធ្វើឲ្យប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍រួចហើយ ទើបចូលទៅកំណត់ នូវឧទ្ធុមាតកអសុភនិមិត្ត ដោយសភាវៈធម្មតា ដោយពណ៌សម្បុរខ្លះ ដោយភេទខ្លះ ដោយទ្រង់ទ្រាយខ្លះ



ដោយទិសខ្លះ ដោយឱកាសខ្លះ ដោយបរិច្ឆេទខ្លះ ដោយទី-ត ដោយចន្លោះ ដោយទីទំនាប ដោយទីទួល ដោយជុំវិញ, ព្រះយោគីនោះ ធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកល្អហើយ ចាំនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្លួនចាំបានល្អហើយ កំណត់យកនូវនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្លួនកំណត់បានល្អហើយ, ព្រះយោគីនោះ លុះធ្វើនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកាន់យកបានល្អហើយ លុះចាំនូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនចាំបានល្អហើយ លុះកំណត់នូវនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនកំណត់បានល្អហើយ ទៅតែម្នាក់ឯង មិនមានសំឡាញ់, មានសតិតាំងនៅមាំ មិនវង្វេងវង្វាន់ មានឥន្ទ្រីយ៍ទាំងឡាយ ទៅជាប់នឹងខ្លួន មានចិត្តមិនទៅខាងក្រៅ កាលពិចារណាផ្លូវទៅ-មក, ព្រះយោគីនោះ សូម្បីកាលចង្រ្កម តែងអធិដ្ឋានទីចង្រ្កមន៍ ឲ្យប្រព្រឹត្តទៅ ក្នុងចំណែកនៃអសុភនិមិត្តនោះ តែប៉ុណ្ណោះ សូម្បីអង្គុយ ក៏តែងក្រាលអាសនៈ ឲ្យប្រព្រឹត្តទៅ ក្នុងចំណែកនៃអសុភនិមិត្តនោះតែម្យ៉ាង ។

សួរថា “កិរិយាចូលទៅកំណត់ នូវនិមិត្ត ដោយជុំវិញ តើមានប្រយោជន៍ ដូចម្ដេច?, មានអានិសង្ស ដូចម្ដេច?” ។

ឆ្លើយថា “ការចូលទៅកំណត់នូវនិមិត្ត ដោយជុំវិញ មានការមិនភ្លេចភ្លាំង ជាប្រយោជន៍, មានការមិនភ្លេចភ្លាំង ជាអានិសង្ស” ។

សួរថា “ការកាន់យកនូវនិមិត្ត ដោយវិធី ១១ យ៉ាង តើមានប្រយោជន៍ ដូចម្ដេច?, មានអានិសង្ស ដូចម្ដេច?” ។

ឆ្លើយថា “ការកាន់យកនិមិត្ត ដោយវិធី១១ យ៉ាង មានការចងក្រៀកចិត្តទុកជាប្រយោជន៍, មានការចងក្រៀកចិត្តទុក ជាអានិសង្ស” ។

សួរថា “ការពិចារណានូវផ្លូវទៅ-មក តើមានប្រយោជន៍ដូចម្ដេច?,

មានអានិសង្ស ដូចម្ដេ?” ។ ឆ្លើយថា “ការពិចារណា នូវផ្លូវទៅ-មក មានការញ៉ាំងកម្មដ្ឋាន ឲ្យដើរទៅកាន់វិថី ជាប្រយោជន៍, មានការញ៉ាំងកម្មដ្ឋាន ឲ្យដើរទៅកាន់វិថី ជាអានិសង្ស” ។

ព្រះយោគីនោះ ជាអ្នកឃើញនូវអានិសង្សជាប្រក្រតី ជាអ្នកមានសេចក្ដីសម្គាល់(នូវអសុភ) ថា ដូចជារតនៈញ៉ាំងសេចក្ដីកោតក្រែង ឲ្យតាំងឡើងប្រាកដហើយ ប្រព្រឹត្តស្រឡាញ់ រមែងចងក្រៀក នូវចិត្តទុកក្នុងអារម្មណ៍នោះ ថា “អាត្មាអញ នឹងរួចចាកជរា និង មរណៈ ដោយបដិបទានេះ ពិតប្រាកដ” ដូច្នេះ, ព្រះយោគីនោះ ស្ងាត់ហើយមែនពិតចាកកាមទាំងឡាយ ។ល។ ចូលដល់ឈានទីមួយហើយនៅ, ឈានទីមួយជារូបាវចរៈ ជាឈានគឺព្រះយោគីនោះ បានលុះហើយ, កិរិយានៅជាទិព្វផង បុញ្ញកិរិយាវត្ថុ ដែលសម្រេចមកអំពីភាវនាផង ក៏ព្រះយោគីនោះ បានលុះហើយ ដូច្នេះឯង ។

(ធំនៀមក្នុងការមើលអសុភ)

ព្រោះហេតុនោះ ព្រះយោគីណា ទៅកាន់ទីកន្លែងពិចារណាសាកសព (ទីស្មសាន) ដើម្បីប្រយោជន៍ដល់ការញ៉ាំងចិត្តឲ្យយល់ព្រម, ព្រះយោគីនោះ ចូរគោះរគាំង ញ៉ាំងពួកឲ្យប្រជុំគ្នាហើយសឹមទៅចុះ ។ ប៉ុន្តែព្រះយោគី កាលទៅ ដោយធម៌ជាប្រធានគឺកម្មដ្ឋាន គប្បីជាបុគ្គលម្នាក់ឯង មិនមានសំឡាញ់ មិនលះបង់នូវមូលកម្មដ្ឋាន ធ្វើទុកក្នុងចិត្តនូវមូលកម្មដ្ឋាននោះរឿយៗ ហើយកាន់យកនូវឈើច្រត់ ឬក៏ លំពង់ឈើ ដើម្បីទប់ទល់នឹងសេចក្ដីអន្តរាយ ដែលកើតអំពីសត្វសាហាវ មានស្វានជាដើម ក្នុងទីស្មសាន ធ្វើសតិកុំឲ្យភ្លេចភ្លាំង ដោយញ៉ាំងភាពជាអ្នកនឹងធឹងល្អ ឲ្យដល់ព្រមផង ជាអ្នកមានចិត្តមិនទៅខាងក្រៅ ដោយញ៉ាំងការៈ



នៃឥន្ទ្រីយ៍ទាំងឡាយ ដែលមានចិត្ត ជាគម្រប់ ៦ ឲ្យទៅជាប់នឹងខ្លួន ឲ្យសម្រេចផង ហើយសឹមទៅ ។

ព្រះយោគី កំពុងចេញពីវត្តនៅឡើយ គប្បីកំណត់ទ្វារ ថា “អាត្មាអញជាអ្នកចេញមកហើយ តាមទ្វារឯណោះ ក្នុងទិសឯណោះ” ដូច្នេះ ។ តពីនោះ ព្រះយោគីនោះ មកតាមផ្លូវណា គប្បីកំណត់ផ្លូវនោះ ថា “ផ្លូវនេះ ទៅឆ្ពោះទៅរកទិសខាងកើត ឬ ទៅឆ្ពោះទៅរកទិសខាងលិច, ទិសខាងជើង និង ទិសខាងត្បូង ឬក៏ ទៅឆ្ពោះទៅរកទិសផ្សេងៗ” ដូច្នេះ ។ មួយទៀត ព្រះយោគី កាលកំណត់ផ្លូវជាទីទៅ យ៉ាងនេះ ថា “ក្នុងទីនេះ ផ្លូវទៅខាងឆ្វេង, ក្នុងទីនេះ ផ្លូវទៅខាងស្ដាំ និង ក្នុងទីនៃអសុភនោះ ក្នុងទីនេះ មានថ្ម, ក្នុងទីនេះ មានដំបូក, ក្នុងទីនេះ មានដើមឈើ, ក្នុងទីនេះ មានវល្លិ” ដូច្នេះ គប្បីទៅកាន់ទីដែលនិមិត្តតាំងនៅ ។ មួយវិញទៀត ព្រះយោគី មិនត្រូវទៅកាន់ទីប្រាសខ្យល់ជាដាច់ខាត ។ ព្រោះថា កាលព្រះយោគីទៅកាន់ទីប្រាសខ្យល់, ក្លិននៃសាកសព គប្បីប៉ះច្រមុះហើយធ្វើឲ្យខួរក្នុងក្បាលកម្រើក ឬ គប្បីញ៉ាំងអាហារ ឲ្យក្អួតចេញមក ឬក៏ធ្វើឲ្យកើតសេចក្ដីស្ដាយក្រោយ ថា “អាត្មាអញ ជាអ្នកមកហើយកាន់ទីនៃសាកសព ឈ្មោះថា មានសភាពបែបនេះ” ដូច្នេះ, ព្រោះហេតុនោះ ព្រះយោគី គប្បីវៀរនូវទីប្រាសខ្យល់ហើយ ទៅកាន់ទីបណ្ដោយខ្យល់ ។ ថាបើព្រះយោគី មិនអាចទៅតាមទីបណ្ដោយខ្យល់បានទេ, ភ្នំក្ដី, ជ្រោះក្ដី, ថ្មក្ដី, របងក្ដី, ទីមានបន្លាក្ដី, ទឹកក្ដី, ទីមានរអិលក្ដី មានក្នុងចន្លោះ ។ ព្រះយោគី គប្បីយកជាយចីវរ បិទច្រមុះ ហើយសឹមទៅចុះ ។ នេះ ជាគមនវត្ត (វត្តក្នុងការទៅ) របស់ព្រះយោគីនោះ ។

(វត្ត ក្នុងពេលទៅដល់អសុភ)

ក៏ព្រះយោគី អ្នកទៅដល់យ៉ាងនេះហើយ មិនគួរក្រឡេកមើលអសុភនិមិត្ត ជាមុនទេ ។ ត្រូវកំណត់ទិសទាំងឡាយសិន ។ ព្រោះថា កាលព្រះយោគីឈរនៅ ក្នុងចំណែកនៃទិសមួយ, អារម្មណ៍ មិនច្បាស់ រមែងប្រាកដ និង ចិត្ត ជាធម្មជាតមិនគួរដល់ការងារ, ព្រោះហេតុនោះ ព្រះយោគីគប្បីវៀរនូវចំណែកនៃទិសនោះ, កាលព្រះយោគី ឈរនៅក្នុងទីណា អារម្មណ៍ រមែងប្រាកដជាក់ច្បាស់ និង ចិត្ត ជាធម្មជាតគួរដល់ការងារ ហើយឈរនៅ ក្នុងទីនោះចុះ ។

មួយទៀត ព្រះយោគីគប្បីលះបង់ទីប្រាសខ្យល់ និង ទីបណ្ដោយខ្យល់ ។ ព្រោះថា កាលព្រះយោគី ឋិតនៅ ក្នុងទីប្រាសខ្យល់ ត្រូវក្លិននៃសាកសពបៀតបៀនហើយ, ចិត្ត រមែងប្រាស់ប្រាល ។ ថាបើ កាលព្រះយោគី ឋិតនៅ ក្នុងទីបណ្ដោយខ្យល់, តែងមានអមនុស្សអាស្រ័យនៅក្នុងទីនោះ, អមនុស្សទាំងនោះ ខឹងហើយ តែងធ្វើនូវសេចក្ដីអន្តរាយ, ព្រោះហេតុនោះ ព្រះយោគី ត្រូវចុះសន្សឹមៗ ហើយមិនគួរឋិតនៅ ក្នុងទីបណ្ដោយខ្យល់ពេកទេ ។

សូម្បីព្រះយោគី ឋិតនៅ យ៉ាងនេះ ក៏មិនត្រូវឋិតនៅ ក្នុងទីឆ្ងាយពេក ក្នុងទីជិតពេក មិនត្រូវឋិតនៅអស់ទីបណ្ដោយជើង មិនត្រូវឋិតនៅ អស់ទីបណ្ដោយក្បាល ។ ព្រោះថា កាលព្រះយោគី ឋិតនៅ ក្នុងទីឆ្ងាយពេក, អារម្មណ៍ ជាអារម្មណ៍មិនច្បាស់, កាលព្រះយោគី ឋិតនៅក្នុងទីជិតពេក ភ័យនឹងកើតឡើង, កាលព្រះយោគី ឋិតនៅ អស់ទីបណ្ដោយជើង ឬ អស់ទីបណ្ដោយក្បាល, អសុភទាំងអស់ នឹងមិនប្រាកដស្មើគ្នាឡើយ ព្រោះហេតុនោះ ព្រះយោគី ត្រូវឋិតនៅត្រង់ពាក់កណ្ដាលនៃសរីរៈ មិនឲ្យឆ្ងាយពេក មិនឲ្យជិតពេក ដែលជាទីសប្បាយ



ដល់បុគ្គលអ្នកសំឡឹងមើល (អសុភ) ។

(វិធីកំណត់និមិត្តក្នុងអសុភ)

ព្រះយោគី អ្នកឋិតនៅ យ៉ាងនេះហើយ គប្បីចូលទៅកំណត់និមិត្តទាំងឡាយ ដោយជុំវិញ ដែលលោកពោលហើយ យ៉ាងនេះ ថា “ព្រះយោគី ធ្វើនូវដុំថ្មក្ដី ។ល។ វល្លិក្ដី ក្នុងទីនោះ ឲ្យប្រព្រឹត្តទៅជាមួយនឹងនិមិត្ត” ។ នេះគឺជាវិធីនៃការកំណត់ ក្នុងអសុភនោះ ។

ថាបើ ដោយជុំវិញ នៃនិមិត្តនោះ មានថ្មនៅ ក្នុងវង្វង់នៃចក្ខុ, ព្រះយោគី គប្បីកំណត់ថ្មនោះ ថា “ដុំថ្មនេះ ខ្ពស់ ឬ ទាប តូច ឬ ធំ ខ្មៅ ឬ ស វែង ឬក៏ មូល” ដូច្នេះ ។ បន្ទាប់មក ព្រះយោគី គប្បីកំណត់ថា “ក្នុងឱកាស ឈ្មោះនេះ នេះ ជាដុំថ្ម, នេះ ជាអសុភនិមិត្ត, នេះ ជាអសុភនិមិត្ត, នេះ ជាដុំថ្ម” ដូច្នេះ ។

ថាបើ មានដំបូក, សូម្បីដំបូកនោះ ក៏ព្រះយោគី គប្បីកំណត់ ថា “ដំបូកនេះ ខ្ពស់ ឬ ទាប តូច ឬ ធំ មានពណ៌ក្រហម ឬ ខ្មៅ ឬក៏មានពណ៌-ស ខ្វី ឬ វែង ឬក៏ មូល” ដូច្នេះ ។ បន្ទាប់មក ព្រះយោគី គប្បីកំណត់ ថា “ក្នុងឱកាសឈ្មោះនេះ នេះ ជាដំបូក, នេះ ជាអសុភ-និមិត្ត (នេះ ជាអសុភនិមិត្ត, នេះ ជាដំបូក)” ដូច្នេះ ។

ថាបើ មានដើមឈើ, សូម្បីដើមឈើនោះ ក៏ព្រះយោគី គប្បីកំណត់ថា “ដើមឈើនេះ គឺដើមពោធិ៍បាយ ឬ ដើមជ្រៃ, ដើមជ្រៃលៀប ឬ ដើមខ្វិត, ខ្ពស់ ឬ ទាប តូច ឬ ធំ ខ្មៅ ឬក៏ ស” ។ បន្ទាប់មក ព្រះយោគី គប្បីកំណត់ថា “ក្នុងឱកាសឈ្មោះនេះ នេះ ជាដើមឈើ, នេះ ជាអសុភនិមិត្ត, (នេះ ជាអសុភនិមិត្ត, នេះ ជាដើមឈើ)” ដូច្នេះ ។

ថាបើ មានគុម្ពឈើ, សូម្បីគុម្ពឈើនោះ ក៏ព្រះយោគី គប្បីកំណត់

ថា “គុម្ពឈើនេះជាគុម្ពផ្កាវ ឬ ជាគុម្ពសង្ស៊ែរ គុម្ពស្មៅអណ្ដាស ឬ គុម្ពស្មៅកន្ទុយដំរី, ជាគុម្ពខ្ពស់ ឬ ទាប, តូច ឬក៏ ធំ” ដូច្នេះ ។ បន្ទាប់មក ព្រះយោគីគប្បីកំណត់ថា “ក្នុងឱកាសឈ្មោះនេះ នេះ ជាគុម្ពឈើ, នេះ ជាអសុភនិមិត្ត, (នេះ ជាអសុភនិមិត្ត, នេះ ជាគុម្ពឈើ)” ដូច្នេះ ។

ថាបើ មានវល្លិ, សូម្បីវល្លិនោះ ក៏ព្រះយោគី គប្បីកំណត់ថា “វល្លិនេះ ជាវល្លិឃ្លោក ឬ ជាវល្លិត្រឡាច, វល្លិបាស ឬ វល្លិប្រេង ឬក៏ វល្លិផោម” ដូច្នេះ ។ បន្ទាប់មក ព្រះយោគី គប្បីកំណត់ថា “ក្នុងឱកាសឈ្មោះនេះ នេះជាវល្លិ, នេះជាអសុភនិមិត្ត, នេះជាអសុភនិមិត្ត, នេះជាវល្លិ” ដូច្នេះ ។

ចំណែកពាក្យណា ដែលលោកពោលហើយថា “ព្រះយោគី ធ្វើឲ្យប្រព្រឹត្តទៅជាមួយនឹងនិមិត្ត ធ្វើឲ្យប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍”ដូច្នេះ, ពាក្យនោះ ក៏យាងចុះមកព្ធដ៏ខាងក្នុង ក្នុងពាក្យថា កំណត់និមិត្ត ដោយជុំវិញនេះឯង ។ ព្រោះថា ព្រះយោគី កាលកំណត់រឿយៗ ឈ្មោះថា ធ្វើឲ្យប្រព្រឹត្តទៅជាមួយនឹងនិមិត្ត ។

ព្រះយោគី កាលកំណត់បំព្រួញៗ នូវការកំណត់ទាំង ២ យ៉ាងនេះ ថា “នេះ ជាដុំថ្ម, នេះ ជាអសុភនិមិត្ត, នេះ ជាអសុភនិមិត្ត, នេះ ជាដុំថ្ម” ដូច្នេះ ឈ្មោះថា ធ្វើឲ្យប្រព្រឹត្តទៅជាមួយអារម្មណ៍ ។ លុះព្រះយោគីធ្វើ (អសុភ) ឲ្យប្រព្រឹត្តទៅជាមួយនិមិត្ត និង ឲ្យប្រព្រឹត្តទៅជាមួយអារម្មណ៍ យ៉ាងនេះហើយ គប្បីធ្វើទុកក្នុងចិត្ត ដោយសភាវៈនោះ ដែលភាវៈនៃអសុភនោះ ជាសភាវៈរបស់វា ជាសភាវៈមិនទូទៅ ដល់អសុភ ឯទៀត ជាសភាវៈរបស់ខ្លួនវា គឺភាវៈនៃអសុភនោះ ជារបស់ហើមប៉ោង ព្រោះភាវៈនៃពាក្យដែលលោកពោលហើយថា “ព្រះយោគី



កំណត់ ដោយភាពជាសភាវៈរបស់វា” ដូច្នេះ ។ សេចក្ដីថា ព្រះយោគីគប្បីកំណត់ តាមសភាវៈរបស់វា គឺ តាមកិច្ចរបស់ខ្លួនវា យ៉ាងនេះ ថា “អសុភហើមប៉ោង គួរឲ្យខ្ពើម” ដូច្នេះ ។

(កាន់យកនិមិត្តដោយប្រការ ៦)

ព្រះយោគី លុះកំណត់ យ៉ាងនេះហើយ គប្បីកាន់យកនិមិត្ត ដោយប្រការ ៦ យ៉ាង គឺ: ដោយពណ៌សម្បុរខ្លះ, ដោយភេទខ្លះ, ដោយទ្រង់ទ្រាយខ្លះ, ដោយទិសខ្លះ, ដោយឱកាសខ្លះ, ដោយការកំណត់ខ្លះ ។ សួរថា “កាន់យកដោយប្រការដូចម្ដេច?” ។ ឆ្លើយថា “ក៏ព្រះយោគីនោះ គប្បីកំណត់ ដោយពណ៌សម្បុរថា: សរីរៈនេះ ជាសរីរៈ របស់មនុស្សមានសម្បុរខ្មៅ ឬ របស់មនុស្សមានសម្បុរ-ស ឬក៏ របស់មនុស្សមានសម្បុរសណ្ដែកបាយ” ដូច្នេះ ។

ចំណែកដោយភេទ ព្រះយោគី មិនត្រូវកំណត់ថា “ជាភេទស្ត្រី ឬ ភេទបុរស” ដូច្នេះទេ គប្បីកំណត់ថា “នេះ ជាសរីរៈ របស់បុគ្គលដែលឋិតនៅ ក្នុងបឋមវ័យ ឬ ក្នុងមជ្ឈិមវ័យ ឬក៏ ក្នុងបច្ឆិមវ័យ” ដូច្នេះ ។

ព្រះយោគី គប្បីកំណត់ ដោយទ្រង់ទ្រាយ ដោយអំណាចនៃទ្រង់ទ្រាយដែលហើមប៉ោងប៉ុណ្ណោះថា “នេះ ជាទ្រង់ទ្រាយនៃក្បាល, នេះ ជាទ្រង់ទ្រាយនៃ-ក, នេះ ជាទ្រង់ទ្រាយនៃដៃ, នេះ ជាទ្រង់ទ្រាយនៃពោះ, នេះ ជាទ្រង់ទ្រាយនៃផ្ចិត, នេះ ជាទ្រង់ទ្រាយនៃចង្កេះ, នេះជាទ្រង់ទ្រាយនៃភ្លៅ, នេះ ជាទ្រង់ទ្រាយនៃស្មង, នេះ ជាទ្រង់ទ្រាយនៃជើង របស់សាកសពនោះ” ដូច្នេះ ។

ចំណែកដោយទិស ព្រះយោគីត្រូវកំណត់ ថា “ក្នុងសរីរៈនេះ មានទិស ២ គឺ: ក្រោមផ្ចិតចុះមក ជាទិសខាងក្រោម, លើផ្ចិតឡើងទៅ ជា

ទិសខាងលើ” ដូច្នេះ ។ មួយទៀត ព្រះយោគី គប្បីកំណត់ថា “អាត្មាអញ ឋិតនៅ ក្នុងទិសនេះ, អសុភនិមិត្ត ឋិតនៅ ក្នុងទិសនេះ” ។

ចំណែកដោយឱកាស ព្រះយោគី ត្រូវកំណត់ថា “ដៃទាំងឡាយ ឋិតនៅ ក្នុងឱកាសឈ្មោះនេះ, ជើងទាំងឡាយ ឋិតនៅ ក្នុងឱកាសនេះ, ក្បាលឋិតនៅ ក្នុងឱកាសនេះ, ពាក់កណ្ដាលកាយ ឋិតនៅ ក្នុងឱកាសនេះ” ។ មួយទៀត ព្រះយោគី គប្បីកំណត់ថា “អាត្មាអញ ឋិតនៅ ក្នុងឱកាសនេះ, អសុភនិមិត្ត ឋិតនៅ ក្នុងឱកាសនេះ” ដូច្នេះ ។

ដោយការកំណត់ ព្រះយោគី គប្បីកំណត់ថា “សរីរៈនេះ ខាងក្រោម គឺអញកំណត់ហើយ ដោយផ្ទៃនៃជើង, ខាងលើ កំណត់ហើយ ដោយចុងនៃសក់, ខាងទទឹង កំណត់ហើយ ដោយក្រចក និង ក្នុងទីតាមដែលបានកំណត់ហើយ សរីរៈនេះ ពេញប្រៀបហើយ ដោយសាកសព ៣២ មែនពិត” ដូច្នេះ ។ មួយទៀត ព្រះយោគី គប្បីកំណត់ ថា “នេះ ជាការកំណត់នៃដៃ, នេះ ជាការកំណត់នៃជើង, នេះ ជាការកំណត់នៃក្បាល, នេះ ជាការកំណត់ នៃពាក់កណ្ដាលកាយ នៃអសុភនេះ” ដូច្នេះ ។ ម្យ៉ាងទៀត ព្រះយោគី កាន់យកអស់ទី មានប្រមាណត្រឹមណា, ក៏គប្បីកំណត់យកទី មានប្រមាណត្រឹមណោះឯងថា “នេះ ជាអសុភហើមប៉ោងបែបនេះឯង” ។ ប៉ុន្តែសរីរៈនៃស្ត្រី មិនគួរដល់បុរស ឬ សរីរៈនៃបុរស មិនគួរដល់ស្ត្រី ។ អារម្មណ៍ ក្នុងសរីរៈ ដែលជាវិសភាគ មិនប្រាកដ, រមែងជាបច្ច័យ នៃកិរិយាឃ្វីងឃ្វាង នៃចិត្តថែមទៀត ។ ព្រោះថា ក្នុងអដ្ឋកថា មជ្ឈិមនិកាយ លោកពោល ថា “ស្ត្រីទុកជាហើមប៉ោងហើយ ក៏រមែងគ្របសង្កត់ចិត្តនៃបុរសហើយឋិតនៅ” ។ ព្រោះហេតុនោះ ព្រះយោគី គប្បីកាន់យកនិមិត្ត ដោយប្រការ ៦ យ៉ាង



នេះ តែក្នុងសរីរៈ មានចំណែកស្មើគ្នាប៉ុណ្ណោះ ។

(កាន់យកនិមិត្តដោយប្រការ ៥)

ឯកុលបុត្រណា មានកម្មដ្ឋានសេពហើយ ក្នុងសំណាក់នៃព្រះពុទ្ធមានក្នុងកាលមុនទាំងឡាយ មានធុតង្គរក្សាហើយ មានមហាភូតរូប ញ៉ាំញីហើយ មានសង្ខារកំណត់ហើយ មាននាមរូបកំណត់ហើយ មានសេចក្ដីសម្គាល់ក្នុងសត្វដកឡើងហើយ មានសមណធម៌ធ្វើហើយ មានវាសនាធ្លាប់អប់រំហើយ មានភាវនាចំរើនហើយ មានពូជ មានញាណដ៏លើស មានកិលេសតិច, បដិភាគនិមិត្ត រមែងប្រាកដ ដល់កុលបុត្រនោះ ក្នុងទីដែលខ្លួនក្រឡេកមើលហើយ និង ក្រឡេកមើលហើយនុ៎ះឯង, ថាបើ បដិភាគនិមិត្ត មិនប្រាកដយ៉ាងនេះទេ, កាលបើដូច្នោះ កាលកុលបុត្រនោះ កាន់យកនិមិត្ត ដោយប្រការ ៦ យ៉ាង ដូចបានពោលមកហើយនេះ, បដិភាគនិមិត្ត រមែងប្រាកដ ។ តែថា កាលបើធ្វើដោយប្រការ ៦ យ៉ាង ដូចពោលមកហើយនេះ ក៏នៅតែមិនប្រាកដ ដល់កុលបុត្រណា, កុលបុត្រនោះ គប្បីកាន់យកនិមិត្ត ដោយប្រការ៥ យ៉ាងថ្មីម្ដងទៀត គឺៈ ដោយទី-ត, ដោយចន្លោះ, ដោយទីទំនាប, ដោយទីទួល, ដោយទីជុំវិញ ។

បណ្ដាវិធានទាំង ៥ យ៉ាងនោះ ត្រង់បទ ថា “**ដោយទី-ត**” បានដល់ ដោយទី-ត ១៨០ ។ (សួរថា) តើព្រះយោគី នឹងកំណត់នូវទី-ត ១៨០ ក្នុងឧទ្ធុមាតកអសុភ យ៉ាងដូចម្ដេច? ។ (ឆ្លើយថា) ហេតុនោះ ព្រះយោគីនោះ គប្បីកំណត់ ដោយទី-ត ដោយអំណាចនៃទី-ត ជំ ១៤ យ៉ាង ដូច្នេះ គឺ ទី-ត នៃដៃស្ដាំ ៣, ទី-ត នៃដៃឆ្វេង ៣, ទី-ត នៃជើងស្ដាំ ៣, ទី-ត នៃជើងឆ្វេង ៣, ទី-ត នៃ-ក ១, ទី-ត នៃចង្កេះ ១ ។

បទថា “ដោយចន្លោះ” គឺ ចន្លោះដៃ, ចន្លោះជើង, ចន្លោះពោះ, ចន្លោះត្រចៀក ឈ្មោះថា ចន្លោះ ព្រោះហេតុនោះ ព្រះយោគី គប្បីកំណត់ ដោយចន្លោះ យ៉ាងដូច្នេះចុះ ។ ព្រះយោគី គប្បីកំណត់ភាពនៃភ្នែកទាំងឡាយ ដែលខ្លួនធ្មេចហើយក្តី, ភាពនៃភ្នែកទាំងឡាយដែលខ្លួនបើកហើយក្តី, ភាពនៃមាត់ដែលខ្លួនបិទហើយក្តី, ភាពនៃមាត់ដែលខ្លួនបើកហើយក្តី ។

បទថា “ដោយទីទំនាប” បានដល់ អវយវៈឯណា ជាកន្លែងទាបក្នុងសរីរៈ គឺជាអណ្តូងនៃភ្នែកក្តី ខាងក្នុងនៃមាត់ក្តី គន្ទាក់នៃ-កក្តី, ព្រះយោគី គប្បីកំណត់អវយវៈនោះ ។ មួយទៀត ព្រះយោគី គប្បីកំណត់ថា “អាត្មាអញ ឋិតនៅ ក្នុងទីទំនាប, សរីរៈ ឋិតនៅលើទីទួល” ដូច្នេះ ។

បទថា “ដោយទីទួល” បានដល់ អវយវៈឯណា ជាកន្លែងខ្ពស់ក្នុងសរីរៈ គឺក្បាលជង្គង់ក្តី ទ្រូងក្តី លលាដ៍ក្បាលក្តី, ព្រះយោគី គប្បីកំណត់អវយវៈនោះ ។ មួយទៀត ព្រះយោគី គប្បីកំណត់ថា “អាត្មាអញ ឋិតនៅលើទីទួល, សរីរៈ ឋិតនៅក្នុងទីទំនាប” ដូច្នេះ ។

បទថា “ដោយជុំវិញ” គឺ ព្រះយោគី គប្បីកំណត់សរីរៈទាំងអស់ដោយជុំវិញ ។ គឺព្រះយោគី គប្បីញ៉ាំងញាណឲ្យត្រាច់ទៅ ក្នុងសរីរៈទាំងមូល, ទីណា ជាទីច្បាស់លាស់ រមែងប្រាកដឡើង, គប្បីតម្កល់ចិត្ត (បរិកម្ម)ថា “ឧទ្ធុមាតកំ ឧទ្ធុមាតកំ” ដូច្នេះ ក្នុងទីនោះ ។ បើព្រះយោគី កំណត់ ដោយអាការៈ យ៉ាងនេះហើយ, ឧទ្ធុមាតកអសុភ ក៏នៅតែមិនប្រាកដឡើង, (សរីរៈខាងលើ) ជាទីបំផុតនៃពោះ រមែងហើមប៉ោងឡើងក្រៃពេក, គប្បីតម្កល់ចិត្ត បរិកម្ម ក្នុងសរីរៈនោះថា “អសុភ ហើមប៉ោង អសុភ ហើមប៉ោង” ។



(១២០) ឥឡូវនេះ នេះ ជាវិនិច្ឆ័យកថា ក្នុងអដ្ឋកថាបាឋៈទាំងឡាយ ថា “ព្រះយោគីនោះ ធ្វើនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្លួនកាន់យកល្អហើយ” ដូច្នេះជាដើម ។ ព្រះយោគីនោះ គប្បីកាន់និមិត្ត ដោយប្រពៃក្នុងសរីរៈនោះ ដោយអំណាចនៃការកាន់យកនិមិត្ត តាមដែលបានពោលមកហើយ ។ ព្រះយោគី គប្បីធ្វើសតិឲ្យឋិតនៅ ដោយល្អហើយ សឹមនឹក ។ ព្រះយោគីកាលធ្វើជារឿយៗយ៉ាងដូច្នេះ គប្បីចងចាំ និង គប្បីកំណត់អសុភ ឲ្យបានស្រួលបួលផងមែនពិត ។ ព្រះយោគី ឈរក្តីអង្គុយក្តី ក្នុងទីមិនឆ្ងាយពេក មិនជិតពេក អំពីសរីរៈ គប្បីបើកភ្នែកក្រឡេកមើលហើយកាន់យកនិមិត្ត ។ ព្រះយោគី គប្បីបើកភ្នែកហើយក្រឡេកមើល អស់វារៈ ១០០ដង អស់វារៈ ១០០០ដង (ដោយបរិកម្ម) ថា “អសុភ ហើមប៉ោង ជារបស់បដិកូល អសុភ ហើមប៉ោង ជារបស់បដិកូល” ដូច្នេះ ។ ព្រះយោគី គប្បីធ្មេចភ្នែកហើយ រំពឹងមើល ។ កាលព្រះយោគី ធ្វើរឿយៗ យ៉ាងនេះ, ឧគ្គហនិមិត្ត ជានិមិត្តគឺខ្លួនកាន់យកល្អហើយ ។

សួរថា “ឧគ្គហនិមិត្ត ជានិមិត្ត គឺព្រះយោគីកាន់យកល្អហើយ ក្នុងកាលណា?” ដូច្នេះ ។ ឆ្លើយថា “កាលព្រះយោគី បើកភ្នែកមើលក្តី, ធ្មេចភ្នែក នឹករំពឹងមើលក្តី ក្នុងកាលណា, និមិត្ត ជានិមិត្តប្រាកដស្មើតែមួយ មកកាន់វង្វង់ចក្ខុ, ក្នុងកាលនោះ ឧគ្គហនិមិត្ត ឈ្មោះថា ជានិមិត្តគឺព្រះយោគីកាន់យកល្អហើយ ។

ព្រះយោគីនោះ លុះធ្វើនិមិត្តនោះ ឲ្យជានិមិត្ត គឺខ្លួនកាន់យកល្អហើយ លុះពិចារណា ឲ្យជានិមិត្ត គឺខ្លួនពិចារណាល្អហើយ លុះកំណត់ឲ្យជានិមិត្ត គឺខ្លួនកំណត់ល្អហើយយ៉ាងនេះ ប្រសិនបើមិនអាចដើម្បីដល់

នូវទីបំផុតនៃការទៅ ក្នុងទីនោះបានទេ, កាលបើយ៉ាងដូច្នោះ ព្រះយោគីនេះ ជាបុគ្គលម្នាក់ឯង មិនមានសំឡាញ់ ធ្វើទុកក្នុងចិត្ត នូវកម្មដ្ឋាននោះឯង ធ្វើសតិឲ្យតាំងនៅ ដោយប្រពៃ មានឥន្ទ្រីយ៍ទាំងឡាយទៅជាប់នឹងខ្លួន មានសេចក្ដីគិតមិនទៅខាងក្រៅខ្លួន តាមន័យដែលបានពោលមកហើយ ក្នុងវេលាជាទីមកនោះឯង ហើយទៅកាន់ទីសេនាសនៈ របស់ខ្លួនវិញ ។ មួយវិញទៀត ព្រះយោគីកាលចេញពីព្រៃស្មសានទុំះឯង គប្បីកំណត់ផ្លូវជាទីមក ថា "អាត្មាអញ ជាអ្នកចេញមកតាមផ្លូវណា, ផ្លូវនេះជាផ្លូវត្រង់ទៅរកទិសខាងកើត ឬ ជាផ្លូវត្រង់ទៅរកទិសខាងលិច ទិសខាងជើង និង ទិសខាងត្បូង ឬ ជាផ្លូវត្រង់ទៅរកទិសតូច (ទិសឈៀង) ឬក៏ ក្នុងទីនេះ ទៅតាមទិសខាងឆ្វេង, ក្នុងទីនេះ ទៅតាមទិសខាងស្ដាំ, ក្នុងទីនេះ មានដុំថ្ម, ក្នុងទីនេះ មានដំបូក, ក្នុងទីនេះ មានដើមឈើ, ក្នុងទីនេះ មានគុម្ពឈើ, ក្នុងទីនេះ មានវល្លិ" ដូច្នេះ ។ ព្រះយោគី កំណត់នូវផ្លូវជាទីមក យ៉ាងនេះហើយ មក សូម្បីចង្ក្រម ក៏គប្បីអធិដ្ឋានទីចង្ក្រម ដែលជាចំណែកនៃអសុភនិមិត្តនុ៎ះតែប៉ុណ្ណោះ ។ សេចក្ដីថា "ព្រះយោគីគប្បីចង្ក្រម ក្នុងប្រទេសនៃផែនដី ដែលមានមុខឆ្ពោះទៅរកទិសនៃអសុភនិមិត្ត" ។ ព្រះយោគី សូម្បីអង្គុយ ក៏ត្រូវក្រាលអាសនៈ ឲ្យប្រព្រឹត្តទៅក្នុងចំណែកនៃអសុភនិមិត្តនោះផងដែរ ។ តែថាប្រសិនបើ ក្នុងទិសនោះ មានបឹងធំក្ដី, ជ្រោះក្ដី, ដើមឈើក្ដី, របងក្ដី, ភក់ក្ដី, ព្រះយោគីមិនអាចដើម្បីចង្ក្រម ក្នុងប្រទេសនៃផែនដី ដែលមានមុខឆ្ពោះទៅរកទិសនោះ, សូម្បីអាសនៈ ក៏ព្រះយោគី មិនអាចក្រាលបាន ព្រោះមិនមានឱកាស, ព្រះយោគី មិនបាច់ក្រឡេកមើលទិសនោះទេ ត្រូវចង្ក្រម និង អង្គុយ ក្នុងទីដែលសមគួរ ដល់ឱកាសក៏បាន, តែថា គប្បីធ្វើចិត្តឲ្យមានមុខឆ្ពោះ



ទៅកាន់ទិសនោះតែប៉ុណ្ណោះ ។

(១២១) ឥឡូវនេះ នេះ ជាសេចក្ដីអធិប្បាយ ក្នុងការដោះស្រាយ មានជាអាទិ៍ថា "មានការមិនវង្វេងជាប្រយោជន៍" នៃបញ្ហាទាំងឡាយ ថា "ការចូលទៅកំណត់និមិត្ត ដោយជុំវិញ មានប្រយោជន៍ យ៉ាងដូចម្ដេច?" ដូច្នេះជាដើម ។

ក៏កាលព្រះយោគីណា ទៅកាន់កន្លែងនៃនិមិត្ត ដែលហើមប៉ោងឡើង ក្នុងកាលខុស ធ្វើការកំណត់និមិត្ត សូម្បីដោយជុំវិញហើយ បើកភ្នែកមើលនុ៎ះឯង ដើម្បីកាន់យកនូវនិមិត្ត, សរីរៈនោះ រមែងប្រាកដហាក់ដូចជាក្រោកឈរឡើង ហាក់ដូចជាចាប់សង្គ្រុបយក និង ហាក់ដូចជាដេញតាមផង ។ ព្រះយោគីនោះ ឃើញសាកសពនោះ ដែលបុគ្គលគួរខ្ពើម ជាអារម្មណ៍គួរឲ្យស្ញែងហើយ ជាអ្នកមានចិត្តអណ្ដែតអណ្ដូង ហាក់ដូចជាឆ្កួត តែងដល់នូវសេចក្ដីភ័យខ្លាច នូវភាពនៃការស្រៀវសាច់ការព្រឺរោម ។ មែនពិត បណ្ដាអារម្មណ៍ ៣៨ ដែលព្រះសង្គីតិកាចារ្យចែកហើយ ក្នុងបាលី រូបដទៃមែនពិត ឈ្មោះថា ជាអារម្មណ៍គួរឲ្យស្ញែងមិនមានទេ ។ ព្រោះថា ក្នុងកម្មដ្ឋាននេះ ព្រះយោគី ឈ្មោះថា ជាអ្នកវិលវក់ ព្រោះឈានក៏មាន ។ ព្រោះហេតុអ្វី? ។ ព្រោះភាវៈនៃកម្មដ្ឋានជាធម្មជាតគួរស្ញើមក្រៃពេក ។ ព្រោះហេតុនោះ ព្រះយោគីនោះ គប្បីប្រឹងទ្រាំ ធ្វើសតិឲ្យតាំងនៅបានល្អហើយ បន្ទោបង់នូវសេចក្ដីតក់ស្លុតថា "សរីរៈដែលស្លាប់ទៅហើយ ឈ្មោះថាក្រោកឡើង ដេញតាមមិនមានទេ, ក៏ប្រសិនបើ ថ្មនោះ ឬ វល្លិនោះ ដែលឋិតនៅ ក្បែរនៃសរីរៈស្លាប់នោះគប្បីមក, សូម្បីសរីរៈ ក៏គប្បីមកដែរ, ប៉ុន្តែ ថ្មនោះក្ដី វល្លិនោះក្ដី មកមិនបានទេ យ៉ាងណាមិញ, ឯសរីរៈ ក៏មកមិនបាន យ៉ាងនោះដែរ, ក៏

អាការៈដែលប្រាកដ ដល់អ្នកនេះ ជាអាការៈកើតអំពីសញ្ញា មានសញ្ញាជាដែនកើត, កម្មដ្ឋាន ប្រាកដដល់អ្នក ក្នុងថ្ងៃនេះហើយ, ម្នាលភិក្ខុ អ្នកកុំខ្វាចឡើយ” ដូច្នេះ ញ៉ាំងសេចក្ដីរីករាយ ឲ្យកើតឡើងហើយ គប្បីញ៉ាំងចិត្តឲ្យត្រាច់ទៅ ក្នុងនិមិត្តនោះ ។ ព្រះយោគី រមែងបាននូវគុណវិសេស យ៉ាងនេះ ។ ពាក្យថា “ការចូលទៅកំណត់ នូវនិមិត្ត ដោយជុំវិញ មានការមិនវង្វេងជាប្រយោជន៍” នេះ គឺលោកពោលហើយ សំដៅយកការបាននូវគុណវិសេសនេះឯង ។

ក៏ព្រះយោគី កាលញ៉ាំងការកាន់យកនិមិត្ត ដោយប្រការ១១ យ៉ាងឲ្យសម្រេច ទើបឈ្មោះថា ចងក្រៀកទុកនូវកម្មដ្ឋានបាន ។ ព្រោះថា ឧគ្គហនិមិត្ត រមែងកើតឡើង ដល់ព្រះយោគីនោះ ព្រោះការបើកភ្នែកមើលជាបច្ច័យ ។ កាលព្រះយោគី ញ៉ាំងចិត្តឲ្យត្រាច់ទៅ ក្នុងឧគ្គហនិមិត្តនោះ, បដិភាគនិមិត្ត ទើបកើតឡើង ។ ព្រះយោគី កាលញ៉ាំងចិត្ត ឲ្យប្រព្រឹត្តទៅ ក្នុងឧគ្គហនិមិត្តនោះ ទើបបាននូវអប្បនា ។ ព្រះយោគីឋិតនៅ ក្នុងអប្បនា ចំរើនវិបស្សនាហើយ ទើបធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន ។ ហេតុនោះ ទើបលោកពោលថា “ការកាន់យកនូវនិមិត្តដោយអាការៈ ១១ យ៉ាង មានការចងក្រៀកទុកជាប្រយោជន៍” ដូច្នេះ ។

(១២២) ក៏ក្នុងបទថា “ការពិចារណា នូវផ្លូវជាទីទៅ និង ជាទីមក មានការញ៉ាំងកម្មដ្ឋាន ឲ្យដើរទៅកាន់វិថីជាប្រយោជន៍” ដូច្នេះ នោះ មានសេចក្ដីថា: ការពិចារណា នូវផ្លូវជាទីទៅផង នូវផ្លូវជាទីមកផង ដែលលោកពោលហើយ, ការពិចារណានោះ មានការញ៉ាំងកម្មដ្ឋាន ឲ្យដើរទៅ តាមវិថីនៃកម្មដ្ឋានជាប្រយោជន៍ ។ សេចក្ដីពិស្ដារថា ប្រសិនបើជនពួកខ្លះ សួរនូវថ្ងៃ ចំពោះភិក្ខុនេះ អ្នករៀនកម្មដ្ឋានហើយមក ក្នុងចន្លោះ



ផ្លូវ ថា “បពិត្រលោកម្ចាស់ដ៏ចំរើន ថ្ងៃនេះជាតិថីទីប៉ុន្មាន?” ដូច្នេះក្ដី សួរនូវប្រស្នាក្ដី ធ្វើនូវបដិសណ្ឋារៈក្ដី ។ ការដែលព្រះយោគី ជាអ្នកស្ងៀមហើយដើរទៅ ដោយគិតថា “អាត្មាអញ ជាអ្នករៀននូវកម្មដ្ឋាន” ដូច្នេះមិនគួរទេ ។ ព្រះយោគី គប្បីប្រាប់ថ្ងៃ ។ គប្បីដោះស្រាយប្រស្នា ។ បើព្រះយោគី មិនដឹង, ត្រូវប្រាប់ថា “អាត្មា មិនដឹងទេ” ។ ព្រះយោគីគប្បីធ្វើបដិសណ្ឋារៈ ដែលប្រកបដោយធម៌ ។ កាលព្រះយោគីនោះ ធ្វើយ៉ាងនេះ, និមិត្តនៅខ្ចី ដែលខ្លួនរៀនហើយ នឹងបាត់បង់ទៅវិញ ។ សូម្បីនិមិត្តនៅខ្ចីនោះ កំពុងបាត់បង់ទៅ, ព្រះយោគី ត្រូវពួកជនសួរថ្ងៃហើយក៏ត្រូវតែប្រាប់កុំខាន ។ កាលមិនចេះប្រស្នា ក៏ត្រូវប្រាប់ថា “អាត្មា មិនចេះទេ” ។ ព្រះយោគីចេះ សូម្បីប្រាប់ ដោយឯកទេសក៏គួរ ។ គប្បីធ្វើបដិសណ្ឋារៈថែមទៀត ។ មួយទៀត ព្រះយោគី ឃើញភិក្ខុអាគន្តុកៈហើយ គប្បីធ្វើបដិសណ្ឋារៈ ដល់អាគន្តុកៈកុំខាន ។ ខន្ធកវត្តទាំងឡាយទាំងពួងសូម្បីដ៏សេសមានចេតិយង្គណវត្ត,ពោធិយង្គណវត្ត, ឧបោសថាគារវត្ត, ភោជនសាលាវត្ត, ជន្តាឃរវត្ត, អាចារិយវត្ត, ឧបជ្ឈាយវត្ត, អាគន្តុកវត្ត និង គមិកវត្តជាដើម ក៏ព្រះយោគី ត្រូវបំពេញកុំខាន ។ កាលព្រះយោគីនោះ កំពុងតែបំពេញវត្តទាំងនោះឯង, និមិត្តនៅខ្ចីនោះក៏នឹងបាត់បង់ទៅ ។ សូម្បីព្រះយោគីនោះ ជាអ្នកប្រាថ្នានឹងទៅ ដោយគិតថា “អាត្មាអញ នឹងទៅហើយ រៀនយកនិមិត្តម្ដងទៀត” ដូច្នេះ ក៏មិនអាចដើម្បីនឹងទៅកាន់ទីស្មសានបានឡើយ ព្រោះត្រូវអមនុស្ស ឬ សត្វសាហាវទាំងឡាយ ឋិតនៅហើយផង និមិត្ត ក៏បាត់បង់ទៅផង ។ មែនពិត ឧទ្ធុមាតកអសុភ ឋិតនៅ អស់មួយថ្ងៃ ឬ ពីរថ្ងៃប៉ុណ្ណោះ ក៏ដល់នូវភាពនៃអសុភ មាននីលកអសុភជាដើម ។ បណ្ដាកម្មដ្ឋានទាំងអស់

ឈ្មោះថា កម្មដ្ឋាន ដែលបានដោយកម្រ ស្មើនឹងឧទ្ធុមាតកអសុភនោះ
មិនមានទេ ។ ព្រោះហេតុនោះ កាលបើនិមិត្ត បាត់បង់ហើយយ៉ាងនេះ,
ភិក្ខុនោះ គប្បីអង្គុយ ក្នុងទីជាទីនៅ ក្នុងវេលាយប់ ឬ ក្នុងទីជាទីនៅ ក្នុង
វេលាថ្ងៃ ហើយពិចារណាផ្លូវជាទីទៅ និង ជាទីមក ដរាបដល់ទីដែលខ្លួន
អង្គុយពត់ភ្នែន យ៉ាងនេះថា “អាត្មាអញ ចេញអំពីវត្ត តាមទ្វារឈ្មោះ
នេះ ដើរទៅកាន់ផ្លូវ មានមុខត្រង់ទៅរកទិសឯណោះ ហើយកាន់យកនូវ
ផ្លូវខាងឆ្វេង ក្នុងទីឈ្មោះឯណោះ កាន់យកផ្លូវខាងស្តាំ ក្នុងទីឈ្មោះឯ
ណោះ, ក្នុងទីនៃអសុភនោះ ដុំថ្មមាន ក្នុងទីឯណោះ, បណ្តាដំបូក, ដើម
ឈើ, គុម្ពឈើ និង វល្លិ វត្ថុណាមួយមានក្នុងទីឯណោះ, អាត្មាអញនោះ
ទៅតាមផ្លូវនោះ ទើបបានឃើញនូវអសុភ ក្នុងផ្លូវឈ្មោះឯណោះ, ក្នុង
ទីនោះ អាត្មាអញ ឈរមានមុខឆ្ពោះទៅរកទិសឈ្មោះឯណោះ ហើយ
កំណត់ នូវនិមិត្តទាំងឡាយ ដោយជុំវិញ យ៉ាងនេះផងៗ រៀនយកនូវ
អសុភនិមិត្ត យ៉ាងនេះហើយ ចេញអំពីទីស្មសាន ក្នុងទិសឯណោះ ធ្វើ
កម្មនេះផងៗ តាមផ្លូវឈ្មោះមានសភាពបែបនេះ ជាអ្នកមកហើយ
អង្គុយក្នុងទីនេះ” ដូច្នេះ ។ កាលព្រះយោគីនោះ ពិចារណា យ៉ាងនេះ,
និមិត្តនោះ ជានិមិត្តប្រាកដ ។ គឺនិមិត្តនោះ រមែងឋិតនៅ ដូចជាវត្ថុដែល
គេតម្កល់ទុក ក្នុងទីខាងមុខ, កម្មដ្ឋាន រមែងដើរទៅកាន់វិថី តាមអាការៈ
ដែលមាន ក្នុងកាលមុនទុំះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា
“ការពិចារណានូវផ្លូវជាទីទៅ និង ជាទីមក មានការញ៉ាំងកម្មដ្ឋាន ឲ្យដើរ
ទៅកាន់វិថី ជាប្រយោជន៍” ។

ឥឡូវនេះ បណ្ឌិតគប្បីជ្រាបសេចក្តីអធិប្បាយ ក្នុងអដ្ឋកថាបាឋៈ
នេះថា “ព្រះយោគី ជាអ្នកឃើញអានិសង្សជាប្រក្រតី ជាអ្នកមានសេចក្តី



សម្គាល់ (ក្នុងអសុភ) ថា ដូចជារតនៈ ញ៉ាំងសេចក្តីគោរពឲ្យតាំងឡើង
ប្រាកដហើយ ប្រព្រឹត្តស្រឡាញ់ រមែងចងក្រៀកទុកនូវចិត្តក្នុងអារម្មណ៍
នោះ” ដូច្នេះ (តទៅ) ។ ព្រះយោគី ញ៉ាំងចិត្ត ឲ្យកើតឡើង ក្នុងអសុភ
ហើមប៉ោង ដែលបុគ្គលគួរខ្ពើម ញ៉ាំងឈាន ឲ្យកើតឡើងហើយ ចំរើន
វិបស្សនា មានឈានជាទីតាំង គប្បីជាអ្នកមានប្រក្រតីឃើញ អានិសង្ស
យ៉ាងនេះ ថា “អាត្មាអញ នឹងរួចចាក ជរា និង មរណៈ ដោយបដិបទា
នេះដោយពិត” ។ ដូចជាទុគតបុរស បានរតនៈ គឺកែវមណី ដ៏មានតម្លៃ
ច្រើន គិតថា “ឱហ្ន៎ ទ្រព្យគឺបុគ្គលរកបានដោយកម្រ គឺអញបានហើយ”
ដូច្នេះហើយ គប្បីជាអ្នកមានសេចក្តីសម្គាល់ ក្នុងកែវមណីនោះ ថា ជា
រតនៈ ញ៉ាំងសេចក្តីគោរពឲ្យកើតហើយ ប្រព្រឹត្តស្រឡាញ់ដោយសេចក្តី
ស្រឡាញ់ដ៏ធំទូលាយ រក្សានូវកែវមណី ដ៏មានតម្លៃច្រើននោះ យ៉ាងណា
មិញ, ព្រះយោគី ក៏យ៉ាងដូច្នោះដែរ ត្រេកអរ ថា “កម្មដ្ឋាននេះ ដែល
គេបានដោយកម្រ គឺអញបានហើយ ដែលប្រាកដស្មើ ដោយកែវមណី
មានតម្លៃច្រើនរបស់ទុគតបុរស, ព្រោះថា ព្រះយោគីអ្នកបំពេញកម្មដ្ឋាន
ក្នុងធាតុ ៤ រមែងកំណត់ នូវមហាភូតរូប ៤ របស់ខ្លួន, អ្នកបំពេញ
អានាបានកម្មដ្ឋាន រមែងកំណត់នូវខ្យល់ ក្នុងច្រមុះរបស់ខ្លួន, អ្នកបំពេញ
កសិណកម្មដ្ឋាន រមែងធ្វើកសិណហើយ ចំរើនគួរតាមសេចក្តីសប្បាយ,
កម្មដ្ឋានទាំងឡាយក្រៅអំពីនេះ ព្រះយោគី បានដោយងាយ យ៉ាងនេះ,
តែឧទ្ធុមាតកអសុភកម្មដ្ឋាននេះ ឋិតនៅ អស់ ១ ថ្ងៃ ឬ ២ ថ្ងៃតែប៉ុណ្ណោះ
បន្ទាប់អំពីនោះទៅ រមែងដល់នូវភាពជាអសុភ មានអសុភពណ៌ខៀវ ជា
ដើម ព្រោះហេតុនោះ កម្មដ្ឋានដែលបុគ្គលបានដោយកម្រជាងឧទ្ធុមាតក
អសុភកម្មដ្ឋាននេះទើបមិនមានឡើយ” ដូច្នេះ ជាអ្នកមានសេចក្តីសម្គាល់

ក្នុងឧទ្ធុមាតកអសុភនោះ ថា ដូចជារតនៈ គប្បីញ៉ាំងសេចក្ដីគោរពកោតក្រែង ឲ្យតាំងឡើងប្រាកដហើយ ប្រព្រឹត្តស្រឡាញ់ រក្សានិមិត្តនោះ ។ ព្រះយោគី គប្បីចងក្រៀកចិត្តទុករឿយៗ ក្នុងឧទ្ធុមាតកអសុភនោះ ថា "អសុភ ហើមប៉ោងឡើង គឺបុគ្គលគួរខ្ពើម, អសុភហើមប៉ោងឡើង គឺបុគ្គលគួរខ្ពើម ទាំងក្នុងទីជាទីនៅក្នុងវេលាយប់ ទាំងក្នុងទីជាទីនៅ ក្នុងវេលាថ្ងៃ" ដូច្នេះ ។ ព្រះយោគីគប្បីនឹករំពឹង គប្បីធ្វើទុកក្នុងចិត្តនូវនិមិត្តនោះរឿយៗ ។ ព្រះយោគីគប្បីធ្វើនិមិត្តនោះ ឲ្យជានិមិត្តគឺខ្លួនត្រិះរិះបានមក នឹករំពឹងបានមក ។

កាលព្រះយោគីនោះធ្វើយ៉ាងនេះ, បដិភាគនិមិត្ត រមែងកើតឡើងៗ នេះ គឺជាសេចក្ដីផ្សេងគ្នា នៃនិមិត្តទាំង ២ ក្នុងឧទ្ធុមាតកអសុភនោះ ។ ឧគ្គហនិមិត្ត រមែងប្រាកដ ដូចជាមានរូបប្លែក មានរូបគួរខ្ពើម មានការឃើញគួរខ្លាច ។ ឯបដិភាគនិមិត្ត រមែងប្រាកដ ដូចបុរសមានអវយវៈតូច-ធំ ធាត់ បរិភោគ (អាហារ) ដរាបដល់ឆ្អែតហើយដេក ។

ព្រះយោគីនោះ លះបង់កាមច្ឆន្ទៈ ដោយអំណាចការសង្កត់សង្កិន (វិក្ខម្ភនបហានៈ) ព្រោះមិនធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ព្ធដ៏ខាងក្រៅ ព្រមទាំងការដែលបានចំពោះ នូវបដិភាគនិមិត្តនុ៎ះឯង, មួយទៀត ព្រះយោគីនោះ លះបង់ព្យាបាទ ព្រោះលះបង់នូវសេចក្ដីត្រេកអរហ្នឹងឯង ដូចជាខ្ទុះ ដែលជនលះបង់បាន ក៏ព្រោះលះបង់នូវឈាមយ៉ាងនោះឯង, ន័យដូចគ្នានោះដែរ ព្រះយោគីលះបង់ថីនមិទ្ធៈបាន ព្រោះភាវៈនៃខ្លួនជាអ្នកមានសេចក្ដីព្យាយាមប្រារព្ធហើយ, លះបង់ឧទ្ធច្ចកុក្កុច្ចៈបាន ដោយអំណាចនៃការប្រកបជារឿយៗ នូវធម៌ស្ងប់ ដែលធ្វើនូវសេចក្ដីមិនក្ដៅក្រហាយស្ដាយក្រោយ, សេចក្ដីសង្ស័យ ចំពោះព្រះសាស្ដា ជាអ្នក



សំដែងសេចក្ដីប្រតិបត្តិ ចំពោះសេចក្ដីប្រតិបត្តិ និងចំពោះផលនៃសេចក្ដីប្រតិបត្តិ, ក៏ព្រះយោគីនោះ លះបង់បាន ព្រោះភាវៈនៃគុណវិសេស ដែលខ្លួនបានហើយ ជាគុណវិសេសដ៏ជាក់ច្បាស់, នីវរណៈទាំង ៥ គឺ ព្រះយោគី លះបង់បាន ដូចរៀបរាប់មកនេះឯង, មួយទៀត អង្គឈានទាំងឡាយ គឺៈ វិតក្កៈ មានការបង្អោនទៅនូវចិត្ត ក្នុងនិមិត្តនុ៎ះឯង ជាលក្ខណៈ, វិចារៈ ដែលញ៉ាំងកិច្ច គឺការបបោសអង្អែល នូវនិមិត្ត ឲ្យសំរេច, បីតិ ជាបច្ច័យនៃកិរិយាបាននូវគុណវិសេសដែលខ្លួនបានចំពោះហើយ, សុខៈ ដែលឈ្មោះថា មានសេចក្ដីស្ងប់ជាហេតុ ព្រោះសេចក្ដីស្ងប់កើតព្រម ដល់ព្រះយោគី ដែលជាអ្នកមានចិត្តប្រកបដោយបីតិ និងឯកគ្គតាចិត្ត ដែលឈ្មោះថា មានសេចក្ដីសុខជាហេតុ ព្រោះកិរិយាតាំងនៅខ្ជាប់នៃចិត្ត កើតមាន ដល់ព្រះយោគី អ្នកដល់ហើយនូវសេចក្ដីសុខ រមែងកើតប្រាកដ ។ សូម្បីឧបចារជ្ឈាន ដែលកើតជារូបប្រៀប នៃបឋមជ្ឈាន រមែងកើត ដល់ព្រះយោគីនោះ ក្នុងខណៈនោះដូចគ្នា យ៉ាងនេះឯង ។ បន្ទាប់អំពីឧបចារជ្ឈាននោះទៅ បណ្ឌិត គប្បីជ្រាបវិធានទាំងអស់ ដរាបដល់អប្បនា និង ការបានដល់វសី នៃបឋមជ្ឈាន តាមន័យដែលលោកបានពោលហើយ ក្នុងបឋវីកសិណនុ៎ះឯង ។

## ២- វិនីលកអសុភកម្មដ្ឋាន

(១២៣) ក៏សូម្បីក្នុងកម្មដ្ឋានទាំងឡាយ មានវិនីលកអសុភកម្មដ្ឋានជាដើម ដទៃអំពីឧទ្ធុមាតកអសុភកម្មដ្ឋាននេះទៅ លក្ខណៈនោះឯណា គឺព្រះអដ្ឋកថាចារ្យ ពោលហើយ ចាប់តាំងអំពីការដើរទៅ(មើលអសុភ)ជាដើម ដោយន័យថា "ព្រះយោគី កាលរៀនយកនូវអសុភនិមិត្ត ដែលជាអសុភ ហើមប៉ោង រមែងដើរទៅតែម្នាក់ឯង មិនមានសំឡាញ់ មាន

សតិតាំងនៅមាំ” ដូច្នេះជាដើម, លក្ខណៈទាំងអស់នោះ បណ្ឌិតគប្បីប្រែ (ផ្លាស់) នៅត្រឹមតែបទថា “ឧទ្ធុមាតកៈ” ក្នុងទីនោះៗ ដោយអំណាចនៃអសុភនោះៗ យ៉ាងនេះថា “ព្រះយោគី កាលរៀនយកនូវអសុភនិមិត្ត ដែលមានពណ៌ខៀវ... ព្រះយោគី កាលរៀនយកនូវអសុភនិមិត្ត ដែលមានខ្ទុះប្រែក...” ដូច្នេះហើយ គប្បីជ្រាបព្រមទាំងវិនិច្ឆ័យ និង សេចក្តីអធិប្បាយតាមន័យដែលបានពោលហើយនុ៎ះឯង ។ ចំណែកសេចក្តីនេះជាសេចក្តីផ្សេងគ្នា ។

ព្រះយោគី គប្បីញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ក្នុងវិនីលកអសុភថា “វិនីលកអសុភ គឺបុគ្គលគួរខ្ពើម, វិនីលកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ក៏ឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ រមែងប្រាកដដូចជាអសុភ មានសម្បុរពពាលពព្រុះ ។ ចំណែកបដិភាគនិមិត្ត រមែងប្រាកដ ដោយអំណាចនៃពណ៌ដ៏ក្រាស់ ។

## ៣- វិបុព្វកអសុភកម្មដ្ឋាន

ព្រះយោគី គប្បីញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅ ក្នុងវិបុព្វកអសុភថា “វិបុព្វកអសុភ គឺបុគ្គលគួរខ្ពើម, វិបុព្វកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ចំណែកឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ រមែងប្រាកដ ហាក់ដូចជាកំពុងហូរចេញ ។ បដិភាគនិមិត្ត នៅនឹងថ្កល់ ជានិមិត្តស្ងប់ស្ងាត់ រមែងប្រាកដឡើង ។

## ៤- វិច្ឆិទ្ទកអសុភកម្មដ្ឋាន

វិច្ឆិទ្ទកអសុភ ព្រះយោគី តែងបាន ក្នុងយុទ្ធមណ្ឌលខ្លះ ក្នុងដងព្រៃជាទីស្នាក់នៅនៃចោរខ្លះ ក្នុងទីសុសាន ជាទីដែលព្រះរាជាទ្រង់ញ៉ាំងរាជបុរស ឲ្យកាប់ពួកចោរខ្លះ, ពុំនោះសោតទេ ក្នុងព្រៃត្រង់កន្លែងដែល



បុរសត្រូវសីហៈ និង ខ្លាធំទាំងឡាយខាំស៊ី, ព្រោះហេតុនោះ ព្រះយោគីទៅកាន់ទីមានសភាពដូច្នោះហើយ បើអសុភនោះ សូម្បីធ្លាក់ចុះហើយក្នុងទិសផ្សេងៗ មកកាន់វង្វង់នៃចក្ខុ ដោយកិរិយាទឹករំពឹងតែម្តង, ការមកបានយ៉ាងនេះ នេះ ជាការប្រពៃ, ថាបើអសុភនោះ មិនមកទេ, ក៏មិនត្រូវស្ទាបអង្អែល ដោយដៃខ្លួនឡើយ ។ ព្រោះថា ព្រះយោគីកាលស្ទាបអង្អែល រមែងដល់នូវសេចក្តីស្និទ្ធស្នាល ហេតុនោះ ព្រះយោគីគប្បីប្រើញោមវត្ត, សាមណេរគ្រោង ឬក៏ អ្នកណាមួយផ្សេងទៀត ឲ្យធ្វើត្រង់កន្លែងតែមួយ ។ ព្រះយោគី កាលមិនបាន គប្បីយកឈើប្រត់ចាស់ ឬក៏ កំណាត់ឈើ បង្អោនចូលទៅ ធ្វើទុកចន្លោះនៃម្រាមដៃមួយ ។ ព្រះយោគី លុះបង្អោនចូលទៅជិត យ៉ាងនេះហើយ គប្បីញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ថា “អសុភ ដាច់ចេញផ្សេងៗ គឺបុគ្គលគួរខ្ពើម, អសុភដាច់ចេញផ្សេងៗ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ឧគ្គហនិមិត្ត ហាក់ដូចជាដាច់ហើយ ត្រង់ពាក់កណ្តាល រមែងប្រាកដក្នុងកម្មដ្ឋាននោះ ។ ចំណែកបដិភាគនិមិត្ត ជានិមិត្តដ៏បរិបូណ៌ ពេញលេញ រមែងប្រាកដឡើង ។

## ៥- វិក្ខាយិតកអសុភកម្មដ្ឋាន

ក្នុងវិក្ខាយិតកអសុភ ព្រះយោគី គប្បីញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅថា “វិក្ខាយិតកអសុភ គឺបុគ្គលគួរខ្ពើម, វិក្ខាយិតកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ចំណែកឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ រមែងប្រាកដឡើង ដូចជាត្រូវសត្វជជែងគ្នាស៊ី ក្នុងទីនោះៗឯង ។ បដិភាគនិមិត្ត ជានិមិត្តពេញបរិបូណ៌ តែងប្រាកដឡើងមែនពិត ។

## ៦- វិក្ខិត្តកអសុភកម្មដ្ឋាន

ព្រះយោគី គប្បីប្រើឲ្យបុគ្គលធ្វើ ឬក៏ ធ្វើដោយខ្លួនឯង សូម្បីនូវ

*វិក្ខិត្តកអសុភ (អសុភកាត់រាយ) ឲ្យមានចន្លោះ មួយម្រាមដៃៗ តាមន័យដែលពោលហើយ ក្នុងវិច្ឆិទ្ទកអសុភនុ៎ះឯង ហើយគប្បីញ៉ាំងការធ្វើទុកក្នុងចិត ឲ្យប្រព្រឹត្តទៅថា “វិក្ខិត្តកអសុភ គឺបុគ្គលគួរខ្ពើម, វិក្ខិត្តកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ រមែងប្រាកដឡើង ដូចជាមានចន្លោះប្រាកដ ។ ចំណែកខាង បដិភាគនិមិត្ត ជានិមិត្តពេញលេញមែនពិត រមែងប្រាកដឡើង ។*

## ៧- ហតវិក្ខិត្តកអសុភកម្មដ្ឋាន

*សូម្បីហតវិក្ខិតកអសុភ (អសុភ រាត់រាយដែលគេចិញ្ច្រាំហើយ) ក៏ព្រះយោគី បានក្នុងទីទាំងឡាយ មានបការៈគឺលោកពោលហើយ ក្នុងវិច្ឆិទ្ទកអសុភនុ៎ះឯង ។ ព្រោះហេតុនោះ ព្រះយោគី គប្បីទៅ ក្នុងទីទាំងនោះ ហើយប្រើឲ្យគេធ្វើ ឬក៏ ធ្វើដោយខ្លួនឯង ឲ្យមានចន្លោះមួយម្រាមដៃៗ តាមន័យដែលពោលហើយនុ៎ះឯង ហើយគប្បីញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅ ថា “ហតវិក្ខិត្តកអសុភ គឺបុគ្គលគួរខ្ពើម, ហតវិក្ខិត្តកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ចំណែកឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ ប្រាកដហាក់បីដូចជាមុខរបួស ។ បដិភាគនិមិត្ត ជានិមិត្តពេញលេញមែនពិត រមែងប្រាកដឡើង ។*

## ៨- លោហិតកអសុភកម្មដ្ឋាន

*លោហិតកអសុភ ព្រះយោគីតែងបាន ក្នុងអវយវៈទាំងឡាយមានដៃ និង ជើងជាដើម នៃមនុស្សទាំងឡាយដែលបាននូវការប្រហារ ក្នុងទីទាំងឡាយ មានយុទ្ធមណ្ឌលជាដើម ដាច់ហើយ ឬក៏ ក្នុងកាលដែលលោហិតហូរចេញអំពីមាត់ នៃសាកសពទាំងឡាយ ដែលមានពក និង រលកកែវ បែកធ្លាយហើយជាដើម ។ ហេតុនោះ ព្រះយោគី ឃើញនូវ*



*លោហិតនោះហើយ គប្បីញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅថា “លោហិតកអសុភ គឺបុគ្គលគួរខ្ពើម, លោហិតកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ ឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ មានអាការៈកំរើក រមែងប្រាកដ ហាក់ដូចជាផ្ទាំង នៃសំពត់ក្រហម ដែលត្រូវខ្យល់បក់បោកហើយ ។ ចំណែកឯបដិភាគនិមិត្ត ជានិមិត្តស្ងប់ស្ងាត់ រមែងប្រាកដឡើង ។*

## ៩- បុឡុវកអសុភកម្មដ្ឋាន

*បុឡុវកអសុភ រមែងមាន ក្នុងពេលដែលហ្វូងដង្កូវ ចេញអំពីមុខដំបៅទាំង ៩ នៃសាកសព ដោយកន្លងទៅបាន ២ ឬ ៣ ថ្ងៃ ។ មួយទៀត បុឡុវកអសុភនោះ មានប្រមាណប៉ុនសរីរៈ នៃសត្វទាំងឡាយមានស្វាន, ចចក, មនុស្ស, គោ, ក្របី, ដំរី, សេះ និង ពស់ថ្លាន់ ជាដើម បិតនៅ ដូចជាគំនរបាយនៃស្រូវសាលី ។ ព្រះយោគី គប្បីញ៉ាំងមនសិការ ឲ្យប្រព្រឹត្តទៅ ក្នុងសាកសពទាំងឡាយនោះ សាកសពណាមួយ ថា “បុឡុវកអសុភ គឺបុគ្គលគួរខ្ពើម, បុឡុវកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ។ មែនពិត និមិត្ត ក្នុងសាកសពដំរីខាងក្នុងនៃបឹងឈ្មោះកាឡទីឃវាបី កើតឡើងប្រាកដ ដល់ព្រះថេរៈឈ្មោះ ចូឡបិណ្ឌបាតិកតិស្សៈ ។ ចំណែកឧគ្គហនិមិត្ត ក្នុងកម្មដ្ឋាននេះ រមែងប្រាកដ ហាក់ដូចជានៅកម្រើកញាប់ញ័រ ។ បដិភាគនិមិត្ត ជានិមិត្តស្ងប់ស្ងាត់រមែងប្រាកដឡើង ហាក់បីដូចជាដុំនៃស្រូវសាលី ។*

## ១០- អដ្ឋិកអសុភកម្មដ្ឋាន

*អដ្ឋិកអសុភ ព្រះមានព្រះភាគ ត្រាស់ហើយ ដោយប្រការផ្សេងៗ ដោយន័យថា “ព្រះយោគីនោះគប្បីឃើញនូវសរីរៈដែលគេចោលហើយ ក្នុងព្រៃខ្មោច ជារាងឆ្អឹង ដែលមានសាច់ និង ឈាម មានសរសៃចង*

ភ្ជាប់” ដូច្នេះជាដើម ។ ព្រោះហេតុនោះ រាងឆ្អឹងនោះ ជារបស់ដែលគេទុកហើយ ក្នុងទីណា, ព្រះយោគីគប្បីទៅ ក្នុងទីនោះ តាមន័យខាងដើមនុ៎ះឯង ធ្វើនូវរាងឆ្អឹងនោះ ឲ្យប្រព្រឹត្តទៅជាមួយនិមិត្ត ឲ្យប្រព្រឹត្តទៅជាមួយអារម្មណ៍ ដោយអំណាចនៃវត្ថុទាំងឡាយ មានថ្មជាដើម ដោយជុំវិញ កំណត់ដោយសភាវៈធម្មតាថា “របស់នេះ ជាឆ្អឹង” ដូច្នេះហើយរៀនយកនិមិត្ត ដោយអាការៈទាំង១១ ដោយអាការៈមានពណ៌ជាដើម ។ តែអដ្ឋិកអសុភនោះ, កាលព្រះយោគី ក្រឡេកមើល ដោយពណ៌ថា “ជាពណ៌-ស” ដូច្នេះ រមែងមិនប្រាកដឡើង, ការប្រឡំ ដោយកសិណ មានពណ៌-ស តែងមាន ។ ហេតុនោះ ព្រះយោគី គប្បីក្រឡេកមើល ថា “ឆ្អឹង” ដោយអំណាចឆ្អឹង គឺបុគ្គលគួរខ្ពើមតែម្យ៉ាង ។ ពាក្យថា “ភេទ” ក្នុងអសុភនេះ ជាឈ្មោះនៃអវយវៈ ទាំងឡាយមានដៃជាដើម ។ ព្រោះហេតុនោះ ព្រះយោគីគប្បីកំណត់ ដោយភេទ ដោយអំណាច(អវយវៈ) គឺដៃ, ជើង, ក្បាល, ទ្រូង, ដើមដៃ, ចង្កេះ, ភ្លៅ និង ជង្គង់ទាំងឡាយ ។ ចំណែកដោយទ្រង់ទ្រាយ ព្រះយោគី គប្បីកំណត់ ដោយអំណាចនៃការវែង និង ខ្លី, មូល និង បួនជ្រុង, តូច និង ធំ ។ ទិស និង ឱកាស មានន័យដូចបានពោលមកហើយហ្នឹងឯង ។ ចំណែកដោយបរិច្ឆេទ ព្រះយោគី គប្បីកំណត់ ដោយអំណាចនៃទីបំផុត(ជុំវិញ)នៃឆ្អឹងនោះៗ, ក្នុងរាងឆ្អឹងទាំងនោះ និមិត្តឆ្អឹងឯណា ជានិមិត្តច្បាស់ រមែងប្រាកដ, គប្បីកាន់យកនូវនិមិត្តនោះ(រហូត)បានដល់អប្បនា ។ ចំណែក ដោយទីទាប និង ទីទួល ព្រះយោគី គប្បីកំណត់ ដោយអំណាចទីទាប និង ទីទួលនៃឆ្អឹងនោះៗ ។ មួយទៀត ព្រះយោគីគប្បីកំណត់ ដោយអំណាចនៃទីកន្លែង ថា “អាត្មាអញ បិនៅ ក្នុងទីទាប, ឆ្អឹង បិតនៅ ក្នុងទីទួល ឬថា



អាត្មាអញ បិតនៅ លើទីទួល, ឆ្អឹង បិតនៅ ក្នុងទីទាប” ដូច្នេះក៏បាន ។ ចំណែកដោយទី-ត ព្រះយោគី គប្បីកំណត់ ដោយអំណាចនៃទីដែលឆ្អឹងទាំង ២ កំណាត់ ប៉ះទង្គិចគ្នាហើយៗ ។ ដោយចន្លោះ ព្រះយោគី គប្បីកំណត់ ដោយអំណាចចន្លោះនៃឆ្អឹងទាំងឡាយនុ៎ះឯង ។ ចំណែកដោយជុំវិញ ព្រះយោគី គប្បីញ៉ាំងញាណ ឲ្យប្រព្រឹត្តទៅ ក្នុងឆ្អឹងទាំងអស់ហ្នឹងឯងហើយ កំណត់ថា “ក្នុងទីនេះ មានឆ្អឹងនេះ” ដូច្នេះ ។ កាលបើនិមិត្ត មិនប្រាកដ ដោយការនាវិធីយ៉ាងនេះទេ, ព្រះយោគី គប្បីញ៉ាំងចិត្ត ឲ្យបិតនៅត្រង់ឆ្អឹងលលាដ៍ ។ ក៏ការកាន់យកនិមិត្ត ដោយអាការៈ ១១ យ៉ាងនេះ ក្នុងអដ្ឋិកអសុភនេះ យ៉ាងណា, សូម្បីក្នុងអសុភទាំងឡាយ ដែលមានខាងដើម អំពីអដ្ឋិកអសុភនេះ មានបុឡុវកអសុភ ជាដើម ក៏ព្រះយោគី គប្បីកំណត់ ដោយអំណាចនៃអាការៈដែលសមគួរយ៉ាងនោះដែរ ។

ក៏ព្រោះកម្មដ្ឋាននេះ រមែងសម្រេច ក្នុងរាងឆ្អឹងទាំងមូលក៏បាន ក្នុងឆ្អឹងតែមួយក៏បាន ព្រោះហេតុនោះ ព្រះយោគីគប្បីកាន់យកនិមិត្ត ដោយអាការៈ ១១ យ៉ាង ក្នុងរាងឆ្អឹង ឬ ឆ្អឹងទាំងឡាយនោះ របស់ណាមួយហើយ ញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅថា “អដ្ឋិកអសុភ គឺបុគ្គលគួរខ្ពើម, អដ្ឋិកអសុភ គឺបុគ្គលគួរខ្ពើម” ។

ព្រះអដ្ឋកថា បានពោលថា “ឧគ្គហនិមិត្តក្តី បដិភាគនិមិត្តក្តី ក្នុងកម្មដ្ឋាននេះ ជានិមិត្តដូចគ្នាតែមួយនុ៎ះឯង” ។ ពាក្យនោះ សមគួរហើយ ក្នុងឆ្អឹងតែមួយ ។ តែក្នុងរាងឆ្អឹង ភាពនៃរាងឆ្អឹងមានចន្លោះ ប្រាកដ ក្នុងឧគ្គហនិមិត្ត ភាពនៃរាងឆ្អឹងពេញបរិបូណ៌ ក្នុងបដិភាគនិមិត្ត ទើបគួរ ។ មួយទៀត សូម្បីក្នុងឆ្អឹងតែមួយ ឧគ្គហនិមិត្ត គប្បីជារូបគួរខ្ពើម គួរឲ្យ

ភ័យខ្លាច, តែបដិភាគនិមិត្ត គប្បីជារូបញុំាងបីតិ និង សោមនស្ស ឲ្យកើត ព្រោះជានិមិត្តដែលនាំឧបចារៈមក ។ តែថា ក្នុងឱកាសនេះ ពាក្យណា ដែលព្រះអដ្ឋកថាចារ្យពោលហើយ ក្នុងអដ្ឋកថាទាំងឡាយ, ពាក្យនោះ លោកពោលឲ្យផ្លូវហើយដូចគ្នា ។ ពិតដូច្នោះមែន ក្នុងអដ្ឋកថានោះ សូម្បីពោលថា “ក្នុងព្រហ្មវិហារទាំង ៤ និង ក្នុងអសុភទាំង ១០ បដិភាគនិមិត្ត មិនមានទេ ។ ព្រោះក្នុងព្រហ្មវិហារទាំងឡាយ ការប្រឡូកប្រឡុំគ្នានៃខេត្តដែននុ៎ះឯង គឺជានិមិត្ត និង ក្នុងអសុភទាំង ១០ កាលបើភាពជារបស់គួរខ្ពើម គឺព្រះយោគី ធ្វើមិនឲ្យមានវិកប្ប ឃើញហើយនុ៎ះឯង ទើបឈ្មោះថា ជានិមិត្ត” ដូច្នេះហើយ ពោលពាក្យមិនឲ្យមានចន្លោះម្តងទៀតនុ៎ះឯង ថា “និមិត្ត ក្នុងអសុភនេះមាន ២ យ៉ាង គឺ ឧគ្គហនិមិត្ត បដិភាគនិមិត្ត, ឧគ្គហនិមិត្តជានិមិត្តមានរូបប្លែកគួរឲ្យខ្ពើម មានអារម្មណ៍គួរឲ្យព្រឺ គួរឲ្យភ័យខ្លាច ប្រាកដឡើង” ដូច្នេះជាដើម។ ព្រោះហេតុនោះ យើងទាំងឡាយបានពិចារណាហើយ ពោលនូវពាក្យណា, ពាក្យនេះឯងគួរហើយ ក្នុងឱកាសនេះ ។ មួយទៀត ឯរឿងទាំងឡាយ មានរឿងនៃសរីរៈ របស់ស្ត្រីទាំងមូល ប្រាកដ ជារាងឆ្អឹង ដល់ព្រះមហាតិស្សត្ថេរ ព្រោះក្រឡេកមើលត្រឹមតែធ្មេញ ជានិទស្សនៈ ក្នុងអដ្ឋិកកម្មដ្ឋាននេះ ដោយប្រការដូច្នេះឯង ។

ព្រះទសពល ទ្រង់មានព្រះកិត្តិគុណ គឺលោកទសសតលោចនៈ ពោលសរសើរហើយ ទ្រង់មានព្រះគុណដ៏ល្អ បានត្រាស់ហើយ នូវអសុភទាំងឡាយឯណា ដែលជាហេតុ នៃឈានមួយៗ ដោយប្រការដូច្នេះ, បណ្ឌិត



ជ្រាប នូវអសុភទាំងឡាយនោះ និង ភាវនាន័យនេះ នៃអសុភទាំងឡាយនោះផង យ៉ាងនេះហើយ គប្បីជ្រាបបកិណ្ណកកថា ក្នុងអសុភទាំងនោះឯង ដោយក្រៃលែងថែមទៀត ដូចតទៅនេះ ។

(បកិណ្ណកកថា)

(១២៤) មែនពិត ព្រះយោគី អ្នកដែលបានសម្រេចឈាន ក្នុងអសុភកម្មដ្ឋានទាំងឡាយនោះ អសុភកម្មដ្ឋានណាមួយ ជាអ្នកមិនមានសេចក្តីប្រព្រឹត្តិលោភលន់ ដូចជាអ្នកដែលមានរាគៈ ទៅប្រាសហើយ ព្រោះភាវៈជាអ្នកសង្កត់សង្កិនរាគៈបានល្អហើយ ។ កាលបើមានហេតុយ៉ាងដូច្នេះ, ប្រភេទអសុភនេះឯណា ដែលលោកពោលហើយ, ប្រភេទនៃអសុភនោះ បណ្ឌិតគប្បីជ្រាបថា “លោកពោលហើយ ដោយអំណាចនៃការដល់នូវភាពជាធម្មតានៃសរីរៈ និង ដោយអំណាចនៃការផ្សេងគ្នានៃបុគ្គលដែលជារាគចរិត” ដូច្នេះ ។

ព្រោះថា សរីរៈស្រស់ កាលដល់នូវភាពជារបស់បដិកូល ក៏គប្បីជាសាកសព ដល់នូវសភាពនៃឧទ្ធុមាតកអសុភខ្លះ ដល់នូវសភាព នៃសាកសពណាមួយ បណ្តាសាកសពទាំងឡាយ មានវិនីលកអសុភ ជាដើម ។ ព្រោះហេតុនោះ ព្រះយោគី ជាអ្នកអាចដើម្បីបាននូវអសុភបែបណាៗ, ក៏គប្បីកាន់យកនិមិត្ត ក្នុងអសុភបែបនោះៗ យ៉ាងនេះ ថា “ឧទ្ធុមាតកអសុភ គឺបុគ្គលគួរខ្ពើម, វិនីលកអសុភ គឺបុគ្គលគួរខ្ពើម” ដូច្នេះ ប្រភេទនៃអសុភ បណ្ឌិត គប្បីជ្រាបថា “លោកពោលហើយ ១០ យ៉ាង ដោយអំណាចនៃការដល់សភាពនៃសរីរៈ យ៉ាងដូច្នេះឯង” ។

តែដោយសេចក្ដីផ្សេងគ្នា ក្នុងអសុភទាំងឡាយនេះ បណ្ឌិត គប្បីជ្រាបថា "ប្រភេទនៃអសុភលោកពោលហើយ១០ យ៉ាង ដោយអំណាចការផ្សេងគ្នា នៃបុគ្គលដែលជារាគចរិត មួយផ្សេងទៀត យ៉ាងដូច្នេះ គឺៈ

(១) ឧទ្ធុមាតកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងទ្រង់ទ្រាយ ព្រោះសំដែងនូវវិបត្តិទ្រង់ទ្រាយនៃសរីរៈ,

(២) វិនីលកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងសម្បុរនៃសរីរៈ ព្រោះសំដែងវិបត្តិ នៃតម្រេកក្នុងស្បែក,

(៣) វិបុព្វកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងក្លិននៃសរីរៈ ដែលតាក់តែងហើយ ដោយអំណាចនៃគ្រឿងស្អិតស្អាងមានផ្កាកម្រង និង គ្រឿងក្រអូបជាដើម ព្រោះសំដែងនូវភាវៈនៃរបស់ដែលជាប់ដោយកាយ និង ពណ៌សម្បុរដែលជារបស់ស្អុយ,

(៤) វិច្ឆិទ្ទកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងភាពដែលក្រាស់ណែន ក្នុងសរីរៈ ព្រោះសំដែងនូវភាពដែលជាប្រហោង ព្ធដ៏ខាងក្នុង,

(៥) វិក្ខាយិតកអសុភ ជាទីសប្បាយនៃបុគ្គលដែលត្រេកត្រអាលក្នុងការទុលឡើងនៃសាច់ ក្នុងទីផ្សេងៗនៃសរីរៈ មានដោះជាដើម ព្រោះសំដែងការខូចខាតនៃសម្បត្តិនៃការទុលឡើងនៃសាច់,

(៦) វិក្ខិត្តកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងលីលា នៃអវយវៈតូច-ធំ ព្រោះសំដែងនូវការរាត់រាយ នៃអវយវៈតូច-ធំទាំងឡាយ,

(៧) ហតវិក្ខិត្តកអសុភ ជាទីសប្បាយនៃបុគ្គលដែលត្រេកត្រអាលក្នុងសម្បត្តិ នៃទ្រង់ទ្រាយរបស់សរីរៈ ព្រោះសំដែងនូវការពិការ ដោយ



សេចក្ដីខុសផ្សេងគ្នា នៃទ្រង់ទ្រាយរបស់សរីរៈ,

(៨) លោហិតកអសុភ ជាទីសប្បាយនៃបុគ្គលដែលត្រេកត្រអាលក្នុងសេចក្ដីល្អដែលគ្រឿងប្រដាប់ឲ្យកើត ព្រោះសំដែងនូវភាពជារបស់បដិកូល ដោយមានលោហិតប្រឡាក់,

(៩) បុឡុវកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងកាយដោយសេចក្ដីសម្គាល់ ថា "ជារបស់ខ្លួន" ព្រោះសំដែងនូវភាវៈនៃកាយដែលជារបស់ទូទៅដល់ហ្វូងដង្កូវជាច្រើន,

(១០) អដ្ឋិកអសុភ ជាទីសប្បាយ នៃបុគ្គលដែលត្រេកត្រអាលក្នុងសម្បត្តិ របស់ធ្មេញ ព្រោះសំដែងនូវភាវៈនៃឆ្អឹងសរីរៈទាំងឡាយ ជារបស់បដិកូល" ដូច្នេះ ។

មួយទៀត ក្នុងអសុភទាំង ១០ យ៉ាងនោះ ចិត្ត នឹងឋិតនៅ មានអារម្មណ៍តែមួយបាន ក៏ព្រោះកម្លាំងនៃវិតក្កៈប៉ុណ្ណោះ ប្រាសចាកវិតក្កៈហើយ មិនអាចឋិតនៅបានទេ ព្រោះភាវៈនៃអារម្មណ៍ មានកម្លាំងខ្សោយប្រៀបដូចជាក្នុងទន្លេដែលមានទឹកហូរទៅ មិនចេះឈប់ មានខ្សែទឹកហូរលឿន ទូកចតនៅបាន ក៏ព្រោះតែយុថ្កា ប្រាសចាកយុថ្កាហើយ មិនអាចចតនៅបានឡើយ យ៉ាងនោះឯង ព្រោះហេតុណា, ព្រោះហេតុនោះ ក្នុងអសុភកម្មដ្ឋាននេះ ទើបមានតែបឋមជ្ឈានប៉ុណ្ណោះ, ឈានទាំងឡាយមានទុតិយជ្ឈានជាដើម មិនមានឡើយ ។ មួយទៀត ក្នុងអារម្មណ៍នោះសូម្បីបដិកូល បីតិ និង សោមនស្ស ក៏រមែងកើតឡើងបាន ព្រោះព្រះយោគីឃើញនូវអានិសង្ស យ៉ាងនេះ ថា "អាត្មាអញ នឹងរួចផុតចាកជរា និង មរណៈ ដោយបដិបទានេះ ដោយពិត" ដូច្នេះផង ព្រោះលះបង់នូវគ្រឿងក្ដៅ គឺនីវរណៈបានផង ដូចក្នុងគំនរលាមក បីតិ និង សោមនស្ស

ក៏រមែងកើតឡើង បានដល់ បុគ្គលអ្នកចោលសម្រាម ដែលឃើញអានិសង្សថា “ឥឡូវនេះ អាត្មាអញ នឹងបាននូវថ្លៃឈ្នួលច្រើន” ដូច្នេះ និង ប្រៀបដូចជាក្នុងការប្រព្រឹត្តិ ទៅនៃការក្អួត និង ការបញ្ចុះចេញមក បីតិ និង សោមនស្ស ក៏រមែងកើតឡើង បានដល់ បុគ្គលដែលមានរោគ អ្នកមានព្យាធិទុក្ខ ដ៏ធ្ងន់ធ្ងរ យ៉ាងនោះឯង ។

(អសុភ ១០ មានលក្ខណៈតែមួយ)

មួយទៀត អសុភទាំង ១០ នេះ ដោយលក្ខណៈ មានតែមួយប៉ុណ្ណោះ ។ មែនពិត ភាពជារបស់បដិកូល គឺមិនស្អាត, មានក្លិនស្អុយ និង គួរឲ្យខ្ពើមទុ៎ះឯង ជាលក្ខណៈ របស់អសុភទាំង ១០ យ៉ាងនោះ ។ អសុភនេះនោះ មិនមែនប្រាកដ ដោយលក្ខណៈនេះ តែក្នុងសរីរៈរបស់មនុស្សស្លាប់ម្យ៉ាងទេ, តែរមែងប្រាកដ សូម្បីក្នុងសរីរៈ របស់មនុស្សដែលមានជីវិតរស់នៅផងដែរ ដូចជាអសុភដែលប្រាកដ ដល់ព្រះមហាតិស្សត្ថេរ អ្នកមានប្រក្រតីនៅ ក្នុងចេតិយបព៌ត ដែលឃើញនូវធ្មេញនៃធ្មេញ និង ដូចជាអសុភដែលប្រាកដ ដល់សាមណេរ ដែលជាឧបដ្ឋាករបស់ព្រះសង្ឃរក្ខិតត្ថេរ អ្នកក្រឡេកមើលព្រះរាជាស្តេចទ្រង់គង់លើ-កដំរី យ៉ាងនោះ ។ ព្រោះថា សរីរៈ របស់មនុស្សដែលស្លាប់ហើយ ជារបស់អសុភ យ៉ាងណា, សូម្បីសរីរៈ របស់មនុស្សដែលនៅរស់ ក៏ជារបស់អសុភ យ៉ាងនោះដែរ ។ ប៉ុន្តែលក្ខណៈនៃអសុភ ក្នុងសរីរៈរបស់មនុស្សដែលនៅរស់នោះ រមែងមិនប្រាកដ ព្រោះត្រូវគ្រឿងអលង្ការដែលជាអាគន្តុកៈបិទបាំងហើយ ។ ក៏តាមប្រក្រតី ធម្មតាសរីរៈនេះមានឆ្អឹង ៣០០ កំណាត់ ដោយក្រៃលែងៗ តាំងឡើងហើយ ជាប់រាងមានតំណតជាប់គ្នា ១៨០ ចងភ្ជាប់ហើយ ដោយសរសៃ ៩០០ បូកហើយដោយ



សាច់ ៩០០ ដុំ រុំព័ទ្ធហើយដោយស្បែកស្រស់ស្តើងៗ បិទហើយដោយស្បែកមានប្រហោងតូច-ធំ មានខ្លាញ់ហូរចេញហើយ ទាំងខាងលើ ទាំងខាងក្រោមជានិច្ច ដូចជាក្រឡនៃខ្លាញ់ខាប់ ជាទីនៅអាស្រ័យនៃហ្វូងដង្កូវ ជាទីកើតឡើង នៃរោគទាំងឡាយ ជាជំរកនៃទុក្ខធម៌ទាំងឡាយ ជាកន្ទួលហូរចេញជាប់ជានិច្ច តាមមុខដំបៅទាំង ៩ ដូចជាបូសដែលចាស់បែបធ្លាយហើយ គឺជាសរីរៈដែលមានអាចម៍ភ្នែកហូរចេញ តាមភ្នែកទាំងពីរ មានអាចម៍ត្រចៀកហូរចេញ តាមរន្ធត្រចៀកទាំងពីរ មានទឹកសម្បោរហូរចេញ តាមរន្ធច្រមុះទាំងពីរ មានអាហារ, ទឹកប្រមាត់, ស្លេស្ម៍ និង ឈាម ហូរចេញមក តាមមាត់ មានឧច្ចារៈ និង បស្សាវៈ ហូរចេញមកតាមទ្វារក្រោមទាំងឡាយ មានតំណក់ញើសដែលមិនស្អាតហូរចេញមកតាមរណ្តៅនៃរោមទាំង ៩៩,០០០ រណ្តៅ មានសត្វទាំងឡាយ មានរុយក្បាលខៀវជាដើម រោមព័ទ្ធជុំជិត, បុគ្គលមិនសំអាតហើយនូវសរីរៈណាដោយសរីរកិច្ចទាំងឡាយ មានដុសធ្មេញ, លាងមាត់ កក់សក់, ងូតទឹក និង ស្លៀកពាក់ជាដើម ជាមនុស្សតាមកំណើតមកហើយទុ៎ះឯង មានសក់អាក្រក់កន្ទ្រើងរើង ត្រាច់អំពីស្រុកមួយ ទៅស្រុកមួយ ទោះជាព្រះរាជាក្តី ជាបុគ្គលណាមួយ ក្នុងបណ្តាបុគ្គលថ្នាក់ទាប មានអ្នកស៊ីឈ្នួលចោលសំរាម និង មនុស្សចណ្ឌាលជាដើមក្តី ក៏មិនមានការខុសប្លែកផ្សេងអំពីគ្នាឡើយ ព្រោះភាវៈនៃសរីរៈជារបស់បដិកូលស្មើគ្នា ។ ឈ្មោះថាសេចក្តីផ្សេងគ្នា ក្នុងសរីរៈ នៃព្រះរាជាក្តី នៃមនុស្សចណ្ឌាលក្តី មិនមានឡើយ ព្រោះភាវៈនៃសរីរៈ ជារបស់មិនស្អាត, មានក្លិនស្អុយ, គួរឲ្យខ្ពើម និង ជារបស់បដិកូល យ៉ាងនេះឯង ។ ក៏ប៉ុន្តែបុគ្គលទាំងឡាយដុសខាត់មន្ទិលទាំងឡាយ មានមន្ទិលនៃធ្មេញជាដើម ក្នុងសរីរៈនេះ

*ដោយសរីរកិច្ចទាំងឡាយ មានដុសធ្មេញ និងលាងមាត់ជាដើម បិទបាំងអវយវៈ ដែលញុំាងសេចក្តីអៀនខ្មាស ឲ្យកំរើក ដោយសំពត់មានពណ៌ផ្សេងៗ លាបដោយគ្រឿងលាប ដែលក្រអូប ឈ្ងុយឈ្ងប់ ស្អិតស្អាងដោយគ្រឿងស្អិតស្អាងទាំងឡាយ មានផ្កា និង គ្រឿងអាភរណៈជាដើម ហើយ ធ្វើឲ្យដល់នូវអាការៈដែលគួរប្រកាន់មាំ ថា “អញ” ថា “របស់អញ” ដូច្នេះ ។ បន្ទាប់ពីនោះ បុគ្គលទាំងឡាយនោះ ក៏ចាំនូវលក្ខណៈនៃអសុភ ដែលជាសភាវៈពិតប្រាកដ យ៉ាងណា របស់វានោះ មិនបាន ព្រោះលក្ខណៈនៃអសុភនោះ ត្រូវបិទបាំង ដោយគ្រឿងអលង្ការដែលជាអាគន្តុកៈនេះ ពួកបុរស ក៏ធ្វើនូវសេចក្តីត្រេកអរ ចំពោះស្ត្រីទាំងឡាយ, ឯពួកស្ត្រី ក៏ធ្វើសេចក្តីត្រេកអរ ចំពោះបុរសទាំងឡាយដែរ ។ តែដោយបរមត្ថ ឈ្មោះថា កន្លែងដែលគួរ ដល់ការដែលគួរឲ្យត្រេកត្រអាល ក្នុងសរីរៈនេះ សូម្បីតែបន្តិចបន្តួច ក៏មិនមានឡើយ ។ ពិតមែនដូច្នោះ សត្វទាំងឡាយ តែងមិនប្រាថ្នាសូម្បីប៉ះពាល់ ដោយដៃ តែងនឿយណាយអៀនខ្មាសខ្ពើម ក្នុងបណ្តាចំណែកទាំងឡាយ មានសក់, រោម, ក្រចក, ធ្មេញ, ទឹកមាត់, ទឹក សម្បោរ, ឧច្ចារៈ និង បស្សាវៈជាដើម សូម្បីចំណែកមួយដែលធ្លាក់ហើយពួដ៏ខាងក្រៅនៃសរីរៈ, តែថាចំណែកណាៗជារបស់មាននៅសេសសល់ ក្នុងសរីរៈនោះ, បុគ្គលទាំងឡាយនោះ ត្រូវសេចក្តីងងឹតគឺអវិជ្ជារុំព័ទ្ធហើយ ត្រេកត្រអាលហើយ ដោយរាគៈពោលគឺសេចក្តីស្នេហាក្នុងខ្លួន រមែងកាន់យកនូវចំណែកនោះៗ សូម្បីជារបស់បដិកូល យ៉ាងនេះថា “ជារបស់គួរប្រាថ្នា គួរត្រេកអរ ជារបស់ទៀង ជាសុខ ជាខ្លួន” ដូច្នេះ ។ បុគ្គលទាំងឡាយនោះ កាលប្រកាន់ យ៉ាងនេះ ឈ្មោះថា ដល់នូវភាពស្មើគ្នា ដោយសត្វចចកចាស់ ដែលឃើញនូវដើម*



*រលួសបាយ ក្នុងព្រៃ ហើយក្តៅក្រហាយនឹងផ្កា ដែលមិនទាន់ជ្រុះធ្លាក់អំពីដើមឈើ ថា “នេះ ជាដុំសាច់, នោះ ជាដុំសាច់” ដូច្នេះនុ៎ះឯង ។ ព្រោះហេតុដូច្នោះ*

សត្វចចក ឃើញនូវផ្ការលួសបាយ ដែលរីកហើយ ក្នុងព្រៃ សម្គាល់ថា “អញបានដើមសាច់ហើយ” ក៏ប្រញាប់ប្រញាល់បោលទៅហើយ ត្របាក់ផ្កាដែលធ្លាក់ហើយៗ ជាសត្វលោភលន់ ដ៏ក្រៃលែង ដឹងថា “នេះ មិនមែនជាសាច់” រមែងប្រកាន់ថា “វត្ថុណា ដែលមាន លើដើមឈើ វត្ថុនោះ ជាសាច់” ដូច្នេះ យ៉ាងណាមិញ, អ្នកប្រាជ្ញមិនត្រូវកាន់យក នូវចំណែកដែលធ្លាក់ហើយប៉ុណ្ណោះ ថា “ជាអសុភ” យ៉ាងដូច្នោះ ហើយគប្បីកាន់យកនូវចំណែកនោះ សូម្បីមាននៅ ក្នុងសរីរៈថា ជាអសុភ យ៉ាងដូច្នោះ, ព្រោះបុគ្គលពាលទាំងឡាយ ប្រកាន់យកនូវរាងកាយនេះថា ជារបស់ស្អាត ហើយជាអ្នកឈ្លក់វង្វេង ក្នុងរាងកាយនោះ ធ្វើនូវអំពើអាក្រក់ទាំងឡាយ រមែងមិនរួចផុត អំពីសេចក្តីទុក្ខ, ព្រោះហេតុនោះ អ្នកមានប្រាជ្ញា គប្បីឃើញនូវសភាវៈនៃរាងកាយដែលស្អុយ ទោះជារស់នៅក្តី ស្លាប់ហើយក្តី ថា ជារបស់ប្រាសហើយចាកភាវៈជារបស់ល្អ ។

*មែនពិត ពាក្យនេះ ព្រះបុរាណាចារ្យ ពោលហើយ ថា :*

កាយ ជារបស់មិនស្អាតមានក្លិនស្អុយ ប្រៀបដូចជាសាកសព ប្រៀបដូចជារណ្តៅលាមក ជាកាយដែលអ្នកមាន

ចក្ខុទាំងឡាយ តិះដៀលហើយ (ប៉ុន្តែ) ជាកាយ គឺបុគ្គលពាលត្រេកអរខ្លាំងណាស់, កាយឯណា បិទបាំងហើយ ដោយស្បែកស្រស់ មានដំបៅធំ ៩ រណ្ដៅ ជាកាយមិនស្អាត មានក្លិនស្អុយ ហូរចេញ ដោយជុំវិញ, ប្រសិនបើខាងក្នុង នៃកាយនេះ គប្បីជារបស់ខាងក្រៅ, បុគ្គល គប្បីកាន់ដំបងហើយ ហាមឃាត់ នូវក្អែក និងសុនខ បានដោយពិត ។

*ព្រោះហេតុនោះ ភិក្ខុដែលជាទព្វជាតិ ទុកជាសរីរៈ ដែលនៅរស់ក្ដី សរីរៈដែលស្លាប់ហើយក្ដី, អាការៈនៃអសុភ រមែងប្រាកដ ក្នុងសរីរៈណាៗ, គប្បីកាន់យកនិមិត្ត ក្នុងសរីរៈនោះៗ ឯង ហើយបំពេញកម្មដ្ឋានឲ្យដល់អប្បនា ដោយប្រការដូច្នេះ ។*

*បរិច្ឆេទ ទី៦ ឈ្មោះ អសុភកម្មដ្ឋាននិទ្ទេស*
*ក្នុងអធិការនៃសមាធិភាវនា ក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គ*
*ដែលខ្ញុំរៀបរៀងហើយ*
*ដើម្បីប្រយោជន៍ដល់កិរិយាញុំាងសាធុជនឲ្យរីករាយ*
*ចប់ហើយ ដោយប្រការដូច្នេះ ។*

❋ ❋ ❋

រៀបរៀងចប់ បរិបូណ៌
ថ្ងៃច័ន្ទ ៣ រោច ខែមាឃ ឆ្នាំជូត អដ្ឋស័ក ព.ស. ២៥៤០
២៣ កុម្ភៈ ១៩៩៧



*(១២៥) ក៏ក្នុងអនុស្សតិ ១០ ដែលលោកសំដែងហើយ ក្នុងលំដាប់នៃអសុភ, សតិហ្នឹងឯង ឈ្មោះថា អនុស្សតិ ព្រោះកើតឡើងរឿយៗ ។ សតិ ឈ្មោះថា អនុស្សតិ ព្រោះជាសេចក្ដីរលឹកដែលសមគួរដល់កុលបុត្រ អ្នកបួសហើយ ដោយសទ្ធា ព្រោះឲ្យប្រព្រឹត្តទៅ ក្នុងឋានៈដែលគួរឲ្យប្រព្រឹត្តទៅនុ៎ះឯង ដូច្នេះ ក៏បានដែរ ។*

*អនុស្សតិ ដែលប្រារព្ធនូវព្រះពុទ្ធហើយ កើតឡើង ឈ្មោះថា* ពុទ្ធានុស្សតិ *។ ពាក្យថា* “ពុទ្ធានុស្សតិ” *នុ៎ះ គឺជាឈ្មោះនៃសតិ ដែលមានព្រះពុទ្ធគុណ ជាអារម្មណ៍ ។*

*អនុស្សតិ ដែលប្រារព្ធនូវព្រះធម៌ហើយ កើតឡើង ឈ្មោះថា* ធម្មានុស្សតិ *។ ពាក្យថា* “ធម្មានុស្សតិ” *នុ៎ះ គឺជាឈ្មោះនៃសតិ ដែលមានព្រះធម្មគុណ មានស្វាក្ខាតធម៌ជាដើម ជាអារម្មណ៍ ។*

*អនុស្សតិ ដែលប្រារព្ធនូវព្រះសង្ឃហើយ កើតឡើង ឈ្មោះថា* សង្ឃានុស្សតិ *។ ពាក្យថា* “សង្ឃានុស្សតិ” *នុ៎ះគឺជាឈ្មោះនៃសតិដែលមានព្រះសង្ឃគុណ មានភាវៈជាអ្នកប្រតិបត្តិល្អជាដើម ជាអារម្មណ៍ ។*

*អនុស្សតិ ដែលប្រារព្ធនូវសីលហើយ កើតឡើង ឈ្មោះថា* សីលានុស្សតិ *។ ពាក្យថា* “សីលានុស្សតិ” *នុ៎ះ គឺជាឈ្មោះនៃសតិ ដែលមានសីលគុណ មានភាវៈជាសីលមិនដាច់ជាដើម ជាអារម្មណ៍ ។*

*អនុស្សតិ ដែលប្រារព្ធនូវការលះបង់ហើយ កើតឡើង ឈ្មោះថា* ចាគានុស្សតិ *។ ពាក្យថា* “ចាគានុស្សតិ” *នុ៎ះ គឺជាឈ្មោះ នៃសតិ ដែលមានចាគគុណ មានភាពជាអ្នកមានចាគៈ លះបង់រួចហើយជាដើម ជាអារម្មណ៍ ។*

អនុស្សតិ ដែលប្រារព្ធនូវទេវតាហើយ កើតឡើង ឈ្មោះថា ទេវតានុស្សតិ ។ ពាក្យថា "ទេវតានុស្សតិ" នុ៎ះ គឺជាឈ្មោះនៃសតិ ដែលមានគុណ មានសទ្ធាជាដើម របស់ខ្លួន លើកយកទេវតាទុក ក្នុងឋានៈជាសាក្សី ជាអារម្មណ៍ ។

អនុស្សតិ ដែលប្រារព្ធនូវសេចក្ដីស្លាប់ហើយ កើតឡើង ឈ្មោះថា មរណានុស្សតិ ។ ពាក្យថា "មរណានុស្សតិ" នុ៎ះ គឺជាឈ្មោះ នៃសតិ ដែលមានការចូលទៅកាត់ផ្ដាច់នូវជីវិតិន្ទ្រិយ៍ ជាអារម្មណ៍ ។

សតិទៅហើយ កាន់រូបកាយ ដែលផ្សេងដោយចំណែក មានសក់ជាដើម ឬថា ទៅហើយ ក្នុងកាយ ព្រោះហេតុនោះ សតិនោះ ទើបឈ្មោះថា កាយគតា ។ កាលបើគួរពោលថា "សតិនោះផង ទៅហើយ ក្នុងកាយផង ព្រោះហេតុនោះ ទើបឈ្មោះថា កាយគតស្សតិ" ដូច្នេះ, តែលោកមិនធ្វើរស្សៈ ពោលថា "កាយគតាសតិ" ដូច្នេះ ។ ពាក្យថា "កាយគតាសតិ" នុ៎ះ គឺជាឈ្មោះនៃសតិដែលមាននិមិត្ត ក្នុងចំណែកនៃកាយមានសក់ជាដើម ជាអារម្មណ៍ ។

សតិ ដែលប្រារព្ធនូវខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញហើយ កើតឡើង ឈ្មោះថា អានាបានស្សតិ ។ ពាក្យថា "អានាបានស្សតិ" នុ៎ះ គឺជាឈ្មោះ នៃសតិដែលមាននិមិត្ត ក្នុងខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ជាអារម្មណ៍ ។

អនុស្សតិ ដែលប្រារព្ធនូវសេចក្ដីស្ងប់ហើយ កើតឡើង ឈ្មោះថា ឧបសមានុស្សតិ ។ ពាក្យថា "ឧបសមានុស្សតិ" នុ៎ះ ជាឈ្មោះ នៃសតិ ដែលមានព្រះនិព្វាន ជាទីរម្ងាប់នូវទុក្ខទាំងពួង ជាអារម្មណ៍ ។



## (វិធីចំរើនពុទ្ធានុស្សតិ)

ក្នុងអនុស្សតិ ១០ នេះ ដូចពោលមកហើយនេះ ព្រះយោគីអ្នកប្រកបព្រមហើយ ដោយសេចក្ដីជ្រះថ្លាក្រៃលែង ប្រាថ្នានឹងចំរើនពុទ្ធានុស្សតិ ជាដំបូង គប្បីជាអ្នកទៅ ក្នុងទីស្ងាត់ ពួនសម្ងំនៅ ក្នុងទីសេនាសនៈដ៏សមគួរហើយ រលឹកដល់គុណ របស់ព្រះដ៏មានព្រះភាគព្រះពុទ្ធជាម្ចាស់ ជារឿយៗ យ៉ាងនេះថា "ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា" ដូច្នេះ ។ នេះ ជាន័យក្នុងការរលឹករឿយៗ ក្នុងព្រះពុទ្ធគុណទាំងឡាយនោះ ។ បុគ្គលរលឹករឿយៗថា "សោ ភគវា ឥតិបិ អរហំ ឥតិបិ សម្មាសម្ពុទ្ធោ ។ល។ សោ ភគវា ឥតិបិ ភគវា" ដូច្នេះ ។ មានពាក្យអធិប្បាយថា "ព្រោះហេតុនេះផង នេះផង" ដូច្នេះ ។

បុគ្គល រលឹករឿយៗ ថា "ក្នុងបទទាំងនោះ ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះហេតុទាំងឡាយនេះជាមុន គឺ អារកត្តា ព្រោះភាពជាអ្នកឆ្ងាយ, អរីនំ អរានញ្ច ហតត្តា ព្រោះភាវៈនៃសឹកសត្រូវទាំងឡាយ គឺព្រះអង្គទ្រង់កំចាត់បានហើយ និង ព្រោះភាវៈនៃកាំទាំងឡាយ គឺព្រះអង្គទ្រង់បានទម្លាយចោលអស់ហើយ, បច្ចយាទីនំ អរហត្តា ព្រោះភាវៈនៃព្រះអង្គជាអ្នកគួរ ដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម, បាបករណេ រហាភាវា ព្រោះមិនមានសេចក្ដីស្ងាត់កំបាំង ក្នុងការធ្វើបាប ។

មែនពិត ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ជាអ្នកឆ្ងាយ គឺទ្រង់ឋិតនៅ ក្នុងទីឆ្ងាយសែនឆ្ងាយបំផុត ចាកកិលេសទាំងពួងទាំង

ឡាយ ព្រោះភាវៈនៃកិលេសទាំងឡាយ ព្រមទាំងវាសនា គឺព្រះអង្គទ្រង់កំចាត់បានហើយ ដោយមគ្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គជាអ្នកឆ្ងាយ ។

> ព្រះដ៏មានព្រះភាគ អង្គឯណា ទ្រង់មិនមានការជាប់ជំពាក់ ដោយកិលេសណា និង ព្រះអង្គមិនទ្រង់ប្រកបដោយទោសទាំងឡាយណា, ព្រះមានព្រះភាគព្រះអង្គនោះ ព្រះអង្គជានាថៈ ទ្រង់ព្រះនាមថា ជាអ្នកឆ្ងាយ ចាកកិលេស និង ទោសទាំងនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ។

មួយទៀត សត្រូវគឺកិលេសទាំងឡាយនោះ គឺព្រះមានព្រះភាគអង្គនោះ ទ្រង់កំចាត់បង់បានហើយ ដោយមគ្គ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា អរហំ ព្រោះទ្រង់កំចាត់បង់សត្រូវទាំងឡាយបានហើយមែនពិត ។

> សត្រូវទាំងឡាយ ពោលគឺកិលេស មានរាគៈជាដើម សូម្បីទាំងពួង គឺព្រះដ៏មានព្រះភាគ ព្រះអង្គជានាថៈ ទ្រង់កំចាត់បង់បានហើយ ដោយសស្ត្រា ពោលគឺបញ្ញា ព្រោះហេតុណា, ព្រោះហេតុនោះឯង ព្រះអង្គនោះ ទើបទ្រង់ព្រះនាមថា អរហំ ។

(១២៦) មួយទៀត សំសារចក្រ ដែលមានដុំសម្រេចហើយ ដោយអវិជ្ជា និង ភវតណ្ហា អភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម ជាកាំ



មានជរា និង មរណៈ ជាកង់ ប្រកហើយ ដោយភ្ញៅ ដែលធ្វើដោយអាសវសមុទយៈ ប្រកបព្រមហើយ ក្នុងរថ គឺត្រៃភព វិលទៅហើយ រហូតវេលា រកទីដើមមិនមានទ្រុំ ឯណា, កាំទាំងឡាយទាំងពួង នៃសំសារចក្រនោះ គឺព្រះមានព្រះភាគអង្គនោះ ព្រះអង្គទ្រង់ឋិតនៅ លើផែនដីគឺសីល ដោយព្រះបាទ គឺវីរិយៈហើយ ទ្រង់យកព្រះហស្ត គឺសទ្ធា ចាប់នូវកាំបិតព្រា គឺព្រះញាណ ដែលធ្វើនូវការអស់ទៅនៃកម្ម ទ្រង់បានកំចាត់បង់អស់ហើយ ក្បែរពោធិមណ្ឌល ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា អរហំ ព្រោះទ្រង់កំចាត់បង់កាំ (គឺសង្ខារ) ទាំងឡាយបានហើយហ្នឹងឯង ។

មួយវិញទៀត សំសារវដ្ដ មានទីបំផុតខាងដើម គឺបុគ្គលមិនដឹងហើយ ឈ្មោះថា សំសារចក្រ ។ ក៏អវិជ្ជា ជាដុំ នៃសំសារចក្រនោះ ព្រោះជាដើមហេតុ, ជរា និង មរណៈ ជាកង់ ព្រោះជាខាងចុង, ធម៌ទាំងឡាយ ១០ ដ៏សេស ជាកាំ ព្រោះមានអវិជ្ជានៅខាងដើម និង ព្រោះមានជរា និង មរណៈនៅខាងចុង ។ ក្នុងធម៌ទាំងឡាយនោះ ការមិនដឹង ក្នុងអរិយសច្ចទាំងឡាយ មានទុក្ខជាដើម ឈ្មោះថា អវិជ្ជា ។ មួយទៀត អវិជ្ជា ក្នុងកាមភព ជាបច្ច័យនៃសង្ខារទាំងឡាយ ក្នុងកាមភព ។ អវិជ្ជា ក្នុងរូបភព ជាបច្ច័យនៃសង្ខារទាំងឡាយ ក្នុងរូបភព ។ អវិជ្ជា ក្នុងអរូបភព ជាបច្ច័យនៃសង្ខារទាំងឡាយ ក្នុងអរូបភព ។

សង្ខារទាំងឡាយ ក្នុងកាមភព ជាបច្ច័យនៃបដិសន្ធិវិញ្ញាណ ក្នុងកាមភព ។ ក្នុងភពទាំងឡាយក្រៅអំពីនេះ ក៏ន័យដូចគ្នានេះដែរ ។

បដិសន្ធិវិញ្ញាណ ក្នុងកាមភព ជាបច្ច័យ នៃនាម និង រូប ក្នុងកាមភព ។ ក្នុងរូបភព ក៏យ៉ាងដូច្នោះដែរ ។ (តែ) បដិសន្ធិវិញ្ញាណ

ក្នុងអរូបភព ជាបច្ច័យនៃនាមតែម្យ៉ាង ។

នាមរូប ក្នុងកាមភព ជាបច្ច័យ នៃសឡាយតនៈ ក្នុងកាមភព ។ នាមរូប ក្នុងរូបភព ជាបច្ច័យ នៃអាយតនៈទាំង ៣ ក្នុងរូបភព ។ នាម ក្នុងអរូបភព ជាបច្ច័យ នៃអាយតនៈ ១ ក្នុងអរូបភព ។

អាយតនៈ ៦ ក្នុងកាមភព ជាបច្ច័យ នៃផស្សៈទាំង ៦ ក្នុងកាមភព ។ អាយតនៈទាំងឡាយ ៣ ក្នុងរូបភព ជាបច្ច័យ នៃផស្សៈទាំងឡាយ ៣ ក្នុងរូបភព ។ អាយតនៈ ១ ក្នុងអរូបភព ជាបច្ច័យ នៃផស្សៈ ១ ក្នុងអរូបភព ។

ផស្សៈទាំងឡាយ ៦ ក្នុងកាមភព ជាបច្ច័យនៃវេទនាទាំងឡាយ ៦ ក្នុងកាមភព ។ ផស្សៈ ៣ ក្នុងរូបភព ជាបច្ច័យ នៃវេទនា ៣ ក្នុងរូបភពនោះដូចគ្នា ។ ផស្សៈ ១ ក្នុងអរូបភព ជាបច្ច័យ នៃវេទនា ១ ក្នុងអរូបភពនោះដូចគ្នា ។

វេទនាទាំងឡាយ ៦ ក្នុងកាមភព ជាបច្ច័យ នៃកងនៃតណ្ហាទាំងឡាយ ៦ ក្នុងកាមភព ។ វេទនា ៣ ក្នុងរូបភព ជាបច្ច័យ នៃកងនៃតណ្ហា ៣ ក្នុងរូបភពនោះដូចគ្នា ។ វេទនា ១ ក្នុងអរូបភព ជាបច្ច័យនៃកងនៃតណ្ហា ១ ក្នុងអរូបភព ។

តណ្ហានោះ ៗ ក្នុងភពនោះ ៗ ជាបច្ច័យ នៃឧបាទាននោះ ៗ ។ ធម៌ដ៏សេសទាំងឡាយ មានឧបាទានជាដើម ជាបច្ច័យនៃធម៌ទាំងឡាយ មានភពជាដើម។ សួរថា “រឿងនោះតើដូចម្តេច?” ។ ឆ្លើយថា “បុគ្គលពួកខ្លះ ក្នុងលោកនេះ គិតថា អញនឹងបរិភោគនូវកាមទាំងឡាយហើយ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ព្រោះការប្រកាន់មាំ ក្នុងកាម ជាបច្ច័យ ។ ព្រោះការពេញ



បរិបូណ៌នៃទុច្ចរិត បុគ្គលនោះ ក៏រមែងទៅកើត ក្នុងអបាយ ។ កម្មដែលជាហេតុនៃការកើតឡើង ក្នុងអបាយ នៃបុគ្គលនោះ ជាកម្មភព ។ ខន្ធទាំងឡាយដែលកើតឡើងហើយ ព្រោះកម្ម ឈ្មោះថា ឧបបត្តិភព ។ ការកើតឡើងនៃខន្ធទាំងឡាយ ជាជាតិ, ការចាស់ ដោយជុំវិញ នៃខន្ធទាំងឡាយ ជាជរា, ការបែកធ្លាយ នៃខន្ធទាំងឡាយ ជាមរណៈ ។

បុគ្គលមួយទៀត ប្រាថ្នា ថា “អញ នឹងសោយ នូវសម្បត្តិ ក្នុងឋានសួគ៌” ដូច្នេះហើយ ប្រព្រឹត្តសុចរិត ព្រោះកាមុបាទានជាបច្ច័យយ៉ាងដូច្នោះដែរ ព្រោះការពេញបរិបូរណ៍នៃសុចរិត បុគ្គលនោះ ក៏រមែងទៅកើត ក្នុងឋានសួគ៌ ។ ន័យ ក៏ជាន័យដូចគ្នានោះឯង គឺ កម្មដែលជាហេតុនៃការកើតឡើង ក្នុងឋានសួគ៌នោះ របស់បុគ្គលនោះ ជាកម្មភព ដូច្នេះជាដើម ។

ចំណែកបុគ្គលមួយទៀត ប្រាថ្នាថា “អញ នឹងសោយ នូវសម្បត្តិ ក្នុងព្រហ្មលោក” ហើយចំរើនមេត្តា ចំរើនករុណា មុទិតា ឧបេក្ខា ព្រោះកាមុបាទានជាបច្ច័យដូចគ្នាដែរ, ព្រោះការពេញបរិបូរណ៍ នៃការចំរើនភាវនា បុគ្គលនោះ ក៏រមែងទៅកើត ក្នុងព្រហ្មលោក ។ ន័យ ក៏ជាន័យដូចគ្នានោះឯង គឺកម្មដែលជាហេតុនៃការកើតឡើង ក្នុងព្រហ្មលោកនោះ របស់បុគ្គលនោះ ជាកម្មភព ដូច្នេះជាដើម ។

បុគ្គលមួយទៀត ប្រាថ្នា ថា “អញ នឹងសោយ នូវសម្បត្តិ ក្នុងអរូបភព” ដូច្នេះហើយ ចំរើនសមាបត្តិ មានអាកាសានញ្ចាយតនៈ ជាដើម ព្រោះកាមុបាទានជាបច្ច័យ ក៏យ៉ាងដូច្នោះដែរ, ព្រោះការពេញបរិបូណ៌នៃភាវនា បុគ្គលនោះ ក៏រមែងទៅកើត ក្នុងអរូបភពនោះៗ ។ កម្មដែលជាហេតុ នៃការកើតឡើង ក្នុងអរូបភពនោះ របស់បុគ្គលនោះ

ជាកម្មភព ។ ខន្ធទាំងឡាយ ដែលកើតហើយព្រោះកម្ម ជាឧបបត្តិភព ។ ការកើត នៃខន្ធទាំងឡាយ ជាជាតិ, ការចាស់ ដោយជុំវិញ នៃខន្ធទាំងឡាយ ជាជរា, ការបែកធ្លាយ នៃខន្ធទាំងឡាយ ជាមរណៈ” ដូច្នេះឯង ។ ន័យសូម្បីក្នុងការប្រកបទាំងឡាយ មានឧបាទាន ដ៏សេស ជាដើមហេតុ ក៏មានន័យដូចនេះដែរ ។

បញ្ញា ក្នុងការកំណត់បច្ច័យ ថា “អវិជ្ជា ជាហេតុ, សង្ខារ កើតឡើងហើយអំពីហេតុ, អវិជ្ជា និង សង្ខារទាំងពីរនោះ កើតឡើងហើយអំពីហេតុដូចគ្នាដែរ” ដូច្នេះ នេះ ឈ្មោះថា ធម្មដ្ឋិតិញាណ, បញ្ញា ក្នុងការកំណត់បច្ច័យ ថា “អវិជ្ជា ជាហេតុ, សង្ខារ កើតឡើងហើយអំពីហេតុ, អវិជ្ជា និង សង្ខារទាំងពីរនោះ កើតឡើងហើយអំពីហេតុដូចគ្នា ទាំងក្នុងអតីតកាល ទាំងក្នុងអនាគតកាល” ដូច្នេះ ឈ្មោះថា ធម្មដ្ឋិតិញាណ ដោយប្រការដូច្នេះឯង ។ បណ្ឌិតគប្បីពង្រីកបទទាំងពួងឲ្យបានពិស្តារ ដោយន័យនេះ ។

ក្នុងធម៌ទាំងនោះ អវិជ្ជា និង សង្ខារ ជាសង្ខេប ១, វិញ្ញាណ, នាមរូប, សឡាយតនៈ, ផស្សៈ និង វេទនា ជាសង្ខេប ១, តណ្ហា, ឧបាទាន និង ភព ជាសង្ខេប ១, ជាតិ, ជរា និង មរណៈ ជាសង្ខេប ១ ។ មួយទៀត ក្នុងសង្ខេបទាំង ៤ នោះ សង្ខេបខាងដើម ជាអតីតកាល, សង្ខេបកណ្តាល ២ ជាបច្ចុប្បន្នកាល, ជាតិ, ជរា និង មរណៈ ជាអនាគតកាល, មួយទៀត ក្នុងធម៌ទាំងនោះ តណ្ហា, ឧបាទាន និង ភព ឈ្មោះថា ជាធម៌គឺលោកប្រកាន់យកហើយមែនពិត ព្រោះការប្រកាន់យកអវិជ្ជា និង សង្ខារ ព្រោះហេតុនោះ ធម៌ទាំងឡាយ ៥ យ៉ាងនេះ ទើបឈ្មោះថា ជាកម្មវដ្ត ក្នុងអតីតកាល ។ ធម៌ទាំង ៥ មានវិញ្ញាណ



ជាដើម ជាវិបាកវដ្ត ក្នុងកាលឥឡូវនេះ ។ ព្រោះការប្រកាន់យកតណ្ហា, ឧបាទាន និង ភព ទើបបានឈ្មោះថា ប្រកាន់យកអវិជ្ជាសង្ខារផងដែរ ព្រោះហេតុនោះ ធម៌ទាំងឡាយ ៥ យ៉ាងនេះ ទើបឈ្មោះថា ជាកម្មវដ្ត ក្នុងកាលឥឡូវនេះ ។ ធម៌ទាំងឡាយ៥ យ៉ាងនេះ ឈ្មោះថា ជាវិបាកវដ្ត ក្នុងកាលតទៅ ព្រោះធម៌ទាំងឡាយ ៥ មានវិញ្ញាណជាដើម គឺលោកសំដែងហើយ ដោយការសំដែងនូវជាតិ, ជរា និង មរណៈ ។ ធម៌ទាំងនោះ មាន ២០ យ៉ាង ដោយអាការៈ ។ ក្នុងធម៌ទាំងនោះ ក្នុងចន្លោះនៃសង្ខារ និង វិញ្ញាណ មានសន្ធិ ១, ក្នុងចន្លោះនៃវេទនា និង តណ្ហា មានសន្ធិ ១, ក្នុងចន្លោះនៃភព និង ជាតិ មានសន្ធិ ១ យ៉ាងនេះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ គឺទ្រង់ដឹង ទ្រង់ចាក់ធ្លុះនូវបដិច្ចសមុប្បាទដែលមានសង្ខេប ៤ អទ្ធា ៣ អាការៈ ២០ សន្ធិ ៣ នោះ ដោយអាការៈទាំងពួង ដូចពោលមកនេះឯង ។

ការដឹងនោះ ឈ្មោះថា ញាណ ព្រោះសេចក្តីថា ដឹង, ឈ្មោះថា បញ្ញា ព្រោះសេចក្តីថា ដឹងជាក់ច្បាស់ ។ ហេតុនោះ ទើបលោកពោលថា “បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញាណ” ដូច្នេះ ។

ព្រះមានព្រះភាគ កាលទ្រង់ជ្រាប នូវធម៌ទាំងនោះ តាមសេចក្តីពិត ដោយធម្មដ្ឋិតិញាណនេះហើយ ទ្រង់នឿយណាយ ទ្រង់ធុញទ្រាន់ ទ្រង់រួចផុតស្រឡះ ក្នុងធម៌ទាំងឡាយនោះ ឈ្មោះថា ទ្រង់សម្លាប់ គឺទ្រង់សម្លាប់ ដោយវិសេស ទ្រង់កំចាត់ នូវកាំទាំងឡាយ នៃសំសារចក្រនេះ មានប្រការដូចបានពោលមកហើយ ។ ព្រោះព្រះអង្គ ទ្រង់កំចាត់កាំទាំងឡាយបានយ៉ាងនេះហើយ ព្រះមានព្រះភាគអង្គនោះ ទើបទ្រង់ព្រះនាមថា អរហំ ។

កាំទាំងឡាយនៃសំសារចក្រ គឺព្រះលោកនាថ ទ្រង់បាន
កំចាត់ចោលហើយ ដោយតបៈ គឺព្រះញាណ ព្រោះ
ហេតុណា, ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ
ទើបទ្រង់ព្រះនាមថា អរហំ ។

(១២៧) មួយទៀត ព្រះមានព្រះភាគអង្គនោះ គួរនូវបច្ច័យទាំងឡាយមានចីវរបច្ច័យជាដើម និង នូវការបូជាដ៏វិសេស ព្រោះភាវៈនៃព្រះអង្គជាអគ្គទក្ខិណេយ្យបុគ្គល, ក៏ព្រោះហេតុនោះហ្នឹងឯង កាលបើព្រះតថាគត ទ្រង់ស្ដេចកើតឡើងហើយ, បុគ្គលទាំងឡាយពួកខ្លះ ជាអ្នកមានសក្តិធំ ទាំងទេវតា ទាំងមនុស្ស, បុគ្គលទាំងឡាយនោះ មិនធ្វើនូវការបូជា ក្នុងទីដទៃឡើយ ។ ពិតមែនដូច្នោះ សហម្បតីព្រហ្ម បូជាហើយនូវព្រះតថាគត ដោយកម្រងនៃរតនៈប៉ុនភ្នំព្រះសុមេរុ ។ មួយទៀត ទេវតា និង មនុស្សទាំងឡាយដទៃទៀត មានព្រះបាទពិម្ពិសារ និង ព្រះបាទកោសលជាដើមក៏បានបូជាព្រះតថាគតហើយតាមកម្លាំង ។ ម្យ៉ាងវិញទៀត ព្រះបាទអសោកមហារាជ ទ្រង់លះបង់ព្រះរាជទ្រព្យមានចំនួន ៩៦ កោដិ ទ្រង់ត្រាស់ឲ្យកសាងព្រះវិហារ ៨៤,០០០ ខ្នង ក្នុងសកលជម្ពូទ្វីប ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគ សូម្បីទ្រង់បរិនិព្វានទៅហើយក្តី ។ នឹងចាំបាច់ពោលថ្វី ដល់ការបូជាដ៏វិសេសដទៃទៀត ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គជាអ្នកគួរ ដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម មែនពិត ។

ព្រោះហេតុដែលព្រះលោកនាថ ព្រះអង្គនេះ ទ្រង់គួរ
នូវការបូជាដ៏វិសេស ព្រមទាំងបច្ច័យទាំងឡាយ ព្រោះ



ហេតុនោះ ព្រះលោកនាថអង្គនោះ ទើបទ្រង់ជាអ្នកឈ្មោះ
ទ្រង់គួរនូវព្រះនាមនោះ គឺថា ជាអរហំ ក្នុងលោក ដែល
សមគួរដល់សេចក្តី ។

មួយទៀត បុគ្គលពាលទាំងឡាយពួកខ្លះសម្គាល់ថា ខ្លួនជាបណ្ឌិតក្នុងលោក រមែងធ្វើអំពើបាប ក្នុងទីកំបាំង ព្រោះភ័យខ្លួចដល់កេរ្តិ៍ឈ្មោះយ៉ាងណា, ព្រះមានព្រះភាគអង្គនោះ ទ្រង់មិនធ្វើនូវបាប ក្នុងទីស្ងាត់កំបាំង ក្នុងទីណាៗ យ៉ាងដូច្នោះទេ ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ទើបទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គមិនមានទីស្ងាត់កំបាំងក្នុងការធ្វើបាប មែនពិត ។

ឈ្មោះថា ការស្ងាត់កំបាំង ក្នុងកិរិយាធ្វើបាបទាំងឡាយ
រមែងមិនមាន ដល់ព្រះតថាគត ជាអ្នកប្រាកដដូច្នោះ
ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះមានព្រះភាគអង្គ
នោះ ទើបទ្រង់ប្រាកដព្រះនាមថា អរហំ ព្រោះមិន
មានការស្ងាត់កំបាំង ។

ព្រះមុនីព្រះអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះ
ព្រះអង្គទ្រង់ឆ្ងាយ ចាកកិលេស ១ ព្រោះទ្រង់កំចាត់
សត្រូវ ពោលគឺកិលេសទាំងឡាយ ១ ព្រះអង្គជាអ្នក
កំចាត់នូវកាំ នៃសំសារចក្រ ១ ជាអ្នកសមគួរ ដល់
ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម ១ មិនទ្រង់
ធ្វើបាបទាំងឡាយ ក្នុងទីស្ងាត់កំបាំង១ ព្រោះហេតុនោះ
ទើបទ្រង់ព្រះនាមថា អរហំ

ដោយប្រការទាំងពួង ដូចបានពណ៌នាមកនេះឯង ។

(១២៨) ចំណែកព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ព្រះនាម ថា សម្មាសម្ពុទ្ធោ ព្រោះទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងទាំងឡាយ ដោយប្រពៃផង ដោយព្រះអង្គឯងផង ។ ពិតដូច្នោះមែន ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងទាំងឡាយ ដោយប្រពៃផង ដោយព្រះអង្គឯងផង គឺទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយ ដែលជាអភិញ្ញេយ្យៈ ព្រោះភាវៈជាធម៌ គឺបុគ្គលគប្បីដឹង ដោយក្រៃលែង ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយ ដែលជាបរិញ្ញេយ្យៈ ព្រោះភាវៈជាធម៌ គឺបុគ្គលគប្បីកំណត់ដឹង ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយ ដែលជាបហាតព្វៈ ព្រោះភាវៈជាធម៌គឺបុគ្គលគប្បីលះបង់ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយ ដែលជាសច្ឆិកាតព្វៈ ព្រោះភាវៈជាធម៌ គឺបុគ្គលគប្បីធ្វើឲ្យជាក់ច្បាស់ ទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយ ដែលជាភាវេតព្វៈ ព្រោះភាវៈជាធម៌គឺបុគ្គលគប្បីធ្វើឲ្យចំរើន ។

ក៏ព្រោះហេតុដូច្នេះឯង ទើបព្រះអង្គទ្រង់ត្រាស់ ថា :

> របស់ដែលបុគ្គលគប្បីដឹង ដោយក្រៃលែង គឺតថាគតដឹងចំពោះហើយ និង របស់ដែលបុគ្គលគប្បីចំរើន គឺតថាគតបានចំរើនហើយ របស់ដែលបុគ្គលគប្បីលះបង់ គឺតថាគតលះបង់បានហើយ, ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ តថាគត ទើបបានជាអ្នកត្រាស់ដឹង [១] ។

ន័យមួយទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងនូវធម៌ទាំង

១- សុ ខុ. ភាគទី ៥៨ ទំព័រទី ១៩៧ ។



ពួងទាំងឡាយ ដោយប្រពៃផង ដោយព្រះអង្គឯងផង ដោយលើកឡើងនូវបទមួយៗ យ៉ាងនេះថា “ចក្ខុ ជាទុក្ខសច្ចៈ, តណ្ហា ដែលមានមកអំពីភពមុន ជាហេតុឲ្យកើត ព្រោះភាវៈជាតួហេតុ ដែលជាឫសគល់នៃចក្ខុនោះ ជាសមុទយសច្ចៈ, ការមិនប្រព្រឹត្តិទៅនៃចក្ខុ និង ចក្ខុសមុទយទាំងពីរ ជានិរោធសច្ចៈ, បដិបទា ដែលជាហេតុដឹងច្បាស់នូវនិរោធ ជាមគ្គសច្ចៈ” ដូច្នេះ ក៏បាន ។ ក្នុងសោតៈ, ឃានៈ, ជិវ្ហា, កាយ និង ចិត្ត ក៏ន័យដូចគ្នានេះដែរ ។ អាយតនៈទាំងឡាយ ៦ មានរូបជាដើម, កងវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម, ផស្សៈ ៦ មានចក្ខុសម្ផស្ស ជាដើម, វេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម, សញ្ញា ៦ មានរូបសញ្ញាជាដើម, ចេតនា ៦ មានរូបសញ្ចេតនាជាដើម, កងនៃតណ្ហា ៦ មានរូបតណ្ហាជាដើម, វិតក្កៈ ៦ មានរូបវិតក្កៈជាដើម, វិចារៈ ៦ មានរូបវិចារៈជាដើម, ខន្ធ ៥ មានរូបក្ខន្ធជាដើម, កសិណ ១០, អនុស្សតិ ១០, សញ្ញា ១០ ដោយអំណាចនៃឧទ្ធុមាតកសញ្ញាជាដើម, អាការៈ ៣២ មានសក់ជាដើម, អាយតនៈ ១២, ធាតុ ១៨, ភព ៩ មានកាមភពជាដើម, ឈាន ៤ មានបឋមជ្ឈានជាដើម, អប្បមញ្ញា ៤ មានមេត្តាភាវនាជាដើម, រូបសមាបត្តិ ៤ និង អង្គនៃបដិច្ចសមុប្បាទ ដោយបដិលោម មានជរា និង មរណៈជាដើម ដោយអនុលោម មានអវិជ្ជាជាដើម បណ្ឌិតគប្បីប្រកប ដោយន័យនេះផងដែរ ។

នេះ ជាការប្រកបបទ ១ ក្នុងធម៌ទាំងឡាយនោះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹង គឺទ្រង់ត្រាស់ដឹង ដោយអនុលោម ទ្រង់ត្រាស់ដឹង ដោយបដិលោម នូវធម៌ទាំងពួងទាំងឡាយ ដោយប្រពៃផង ដោយព្រះអង្គឯងផង ដោយលើកយកបទមួយៗ យ៉ាងនេះថា “ជរា និង មរណៈ

ជាទុក្ខសច្ចៈ, ជាតិ ជាសមុទយសច្ចៈ, ការរលាស់ចេញនូវទុក្ខ និង សមុទយៈទាំងពីរ ជានិរោធសច្ចៈ, បដិបទា ដែលជាហេតុឲ្យដឹងច្បាស់នូវនិរោធ ជាមគ្គសច្ចៈ” ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា “ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ក៏ព្រោះទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងទាំងឡាយ ដោយប្រពៃផង ដោយព្រះអង្គឯងផង” ដូច្នេះ ។

(១២៩) ចំណែកព្រះមានព្រះភាគ ទ្រង់ព្រះនាម ថា វិជ្ជាចរណ-សម្បន្នោ ព្រោះទ្រង់ប្រកបព្រម ដោយវិជ្ជាទាំងឡាយ និង ចរណៈ ។ បណ្ដាបទទាំងនោះ បទថា “វិជ្ជា” បានទាំងវិជ្ជា ៣ ទាំងវិជ្ជា ៨ ។ វិជ្ជា ៣ បណ្ឌិតគប្បីជ្រាប តាមន័យដូចបានពោលហើយ ក្នុងភយភេរវសូត្រនុ៎ះឯង ។ វិជ្ជា ៨ បណ្ឌិត គប្បីជ្រាប តាមន័យដែលបានពោលហើយ ក្នុងអម្ពដ្ឋសូត្រ ។ ក៏ក្នុងអម្ពដ្ឋសូត្រនោះ ព្រះមានព្រះភាគ ទ្រង់កំណត់យកអភិញ្ញា ៦ ព្រមទាំងវិបស្សនាញាណ និង មនោមយិទ្ធិ ហើយទ្រង់ត្រាស់វិជ្ជា ៨ ។

ធម៌ទាំង ១៥ យ៉ាងនេះឯង គឺៈ ការសង្រួម ក្នុងសីល, ការគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រីយ៍ទាំងឡាយ, ការស្គាល់ប្រមាណ ក្នុងភោជន, ការប្រកបរឿយៗ នូវភាពជាអ្នកភ្ញាក់រឭក, សទ្ធម្ម ៧, រូបាវចរឈាន ៤ បណ្ឌិត គប្បីជ្រាបថា ឈ្មោះថា ចរណៈ ។ មែនពិត ធម៌ទាំង ១៥ យ៉ាងនេះឯង លោកហៅថា ចរណៈ ព្រោះជាផ្លូវដើរទៅដល់ទិសដែលមិនស្លាប់ នៃព្រះអរិយសាវក ។ សមដូចជាព្រះអានន្ទត្ថេរ ពោលថា “ម្នាលមហានាម ព្រះអរិយសាវក ក្នុងព្រះធម្មវិន័យនេះ [១] ជាអ្នកមាន

១- សុ. ម. ម. ភាគទី ២៣ ទំព័រទី ៤៣ ។



សីល” ដូច្នេះជាដើម ។ ពាក្យរបស់ព្រះអានន្ទត្ថេរទាំងអស់ បណ្ឌិតគប្បីជ្រាប តាមន័យដែលពោលហើយ ក្នុងគម្ពីរមជ្ឈិមបណ្ណាសកៈនុ៎ះឯង ។

ព្រះមានព្រះភាគ ទ្រង់ប្រកបព្រមហើយ ដោយវិជ្ជាទាំងឡាយនេះ និង ដោយចរណៈនេះ ហេតុនោះ ទើបទ្រង់ព្រះនាម ថា វិជ្ជាចរណ-សម្បន្នោ ទ្រង់ប្រកបព្រមហើយ ដោយវិជ្ជា និង ចរណៈ ។

ក្នុងការដល់ព្រមទាំង ២ យ៉ាងនោះ ការដល់ព្រមដោយវិជ្ជា ញ៉ាំងសព្វញ្ញុតញ្ញាណ នៃព្រះមានព្រះភាគ ឲ្យពេញបរិបូរហើយឋិតនៅ, ការដល់ព្រមដោយចរណៈ ញ៉ាំងភាវៈជាអ្នកប្រកប ដោយព្រះមហាករុណា នៃព្រះមានព្រះភាគ ឲ្យពេញបរិបូរហើយឋិតនៅ, ព្រះមានព្រះភាគអង្គនោះ ទ្រង់ដឹងនូវរបស់ដែលមានប្រយោជន៍ និង របស់ដែលមិនមានប្រយោជន៍ ដោយសព្វញ្ញុតញ្ញាណ ហើយទ្រង់ជៀសវាងរបស់ដែលឥតប្រយោជន៍ ទ្រង់ប្រកបតែក្នុងរបស់ដែលជាប្រយោជន៍ ដោយភាពជាអ្នកប្រកប ដោយព្រះមហាករុណា ដល់សត្វទាំងពួង ដូចជាបុគ្គលអ្នកដល់ព្រមដោយវិជ្ជា និង ចរណៈ ។ ព្រោះហេតុនោះ ព្រះសាវកទាំងឡាយរបស់ព្រះអង្គ ជាអ្នកប្រតិបត្តិល្អ មិនមែនជាអ្នកប្រតិបត្តិអាក្រក់ ដូចជាពួកសាវក របស់គ្រូទាំងឡាយ ដែលប្រាសចាកវិជ្ជា និង ចរណៈ ជាបុគ្គលធ្វើខ្លួនឲ្យក្ដៅក្រហាយដូច្នោះទេ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានផ្លូវស្ដេចយាងទៅល្អ ១ ព្រោះព្រះអង្គស្ដេចយាងទៅហើយកាន់ទីកន្លែងដែលល្អ ១ ព្រោះព្រះអង្គស្ដេចយាងទៅហើយ ដោយប្រពៃ ១ ព្រោះព្រះអង្គទ្រង់ត្រាស់ហើយ ដោយប្រពៃ ១ ។

ព្រោះថាសូម្បីការទៅ(គមនៈ) ក៏ហៅថា “គតៈ” ។ ក៏ការទៅនោះ

របស់ព្រះមានព្រះភាគអង្គនោះ ជាការទៅល្អ គឺជាដំណើរទៅ យ៉ាងបរិសុទ្ធ មិនមានទោស ។ សួរថា “ក៏ការទៅនោះគឺអ្វី?” ។ ឆ្លើយថា “គឺអរិយមគ្គ” ។ មែនពិត ព្រះមានព្រះភាគអង្គនោះទ្រង់មិនជាប់ជំពាក់ ស្តេចយាងទៅកាន់ទិសដ៏ក្សេមបាន ក៏ព្រោះការទៅនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាម ថា សុគតោ ព្រោះព្រះអង្គជាអ្នកមានផ្លូវស្តេចយាងទៅយ៉ាងល្អ ។

មួយទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់ស្តេចយាងទៅកាន់ទីកន្លែងដ៏ល្អ គឺអមតនិព្វាន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គស្តេចយាងទៅហើយកាន់ទីកន្លែងដែលល្អប្រការ ១ ។

ម្យ៉ាងទៀត ព្រះអង្គស្តេចយាងទៅហើយ ដោយប្រពៃ គឺមិនទ្រង់វិលត្រឡប់មកកាន់កិលេសទាំងឡាយ ដែលព្រះអង្គទ្រង់លះបង់បានហើយ ដោយមគ្គនោះៗ ជាថ្មីម្តងទៀត ។ សមដូចជាព្រះអង្គត្រាស់ថា “កិលេសទាំងឡាយណា ដែលព្រះអង្គទ្រង់លះបានហើយ ដោយសោតាបត្តិមគ្គ, ព្រះអង្គ មិនមក មិនវិលមក មិនវិលត្រឡប់មកកាន់កិលេសទាំងឡាយនោះទេ ព្រោះហេតុដូច្នោះ ព្រះអង្គទើបទ្រង់ព្រះនាមថា សុគតោ ។ល។ កិលេសទាំងឡាយណា ដែលព្រះអង្គទ្រង់លះបានហើយ ដោយអរហត្តមគ្គ, ព្រះអង្គ មិនមក មិនវិលមក មិនវិលត្រឡប់មកកាន់កិលេសទាំងឡាយនោះទេ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា សុគតោ ” ដូច្នេះ ។

ម្យ៉ាងទៀត ព្រះអង្គស្តេចយាងទៅហើយ ដោយប្រពៃ គឺទ្រង់ធ្វើតែប្រយោជន៍ និង សេចក្តីសុខ ដល់លោកទាំងពួង ដោយសម្មាបដិបត្តិ ព្រោះទ្រង់បានបំពេញព្រះបារមី ៣០ ចាប់ដើមតាំងអំពីព្រះបាទមូល នៃ



ព្រះពុទ្ធព្រះនាមទីបង្ករ ដរាបដល់កាលដែលព្រះពោធិញ្ញាណជាក់ច្បាស់ និង ស្តេចយាងទៅហើយ មិនចូលទៅជិតអន្តធម៌ទាំងនេះ គឺសស្សតៈ ឧច្ឆេទៈ កាមសុខៈ អត្តកិលមថៈ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គស្តេចយាងទៅហើយ ដោយប្រពៃប្រការ ១ ។

មួយទៀត ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ត្រាស់ ដោយប្រពៃ គឺទ្រង់ត្រាស់តែព្រះតម្រាស់ដ៏សមគួរ ក្នុងឋានៈដែលសមគួរ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គទ្រង់ត្រាស់ ដោយប្រពៃប្រការ ១ ។

នេះ ជាសូត្រសំរាប់ជាឧទាហរណ៍ ក្នុងសេចក្តីនោះ គឺ :

(១) ព្រះតថាគត ទ្រង់ជ្រាប នូវព្រះវាចាណា ដែលជាព្រះវាចាមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ និង វាចានោះ ជាវាចាមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត ដល់ពួកជនដទៃផង, ព្រះតថាគតមិនត្រាស់នូវព្រះវាចានោះទេ ។

(២) ព្រះតថាគត សូម្បីទ្រង់ជ្រាប នូវព្រះវាចាណា ដែលជាព្រះវាចាពិត ទៀង (តែ) មិនប្រកបដោយប្រយោជន៍ និង វាចានោះ ជាវាចាមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត ដល់ពួកជនដទៃផង, ព្រះតថាគត ក៏មិនទ្រង់ត្រាស់ នូវព្រះវាចានោះដែរ ។

(៣) ចំណែកព្រះវាចាណា ព្រះតថាគត ទ្រង់ជ្រាបថា ជាវាចាពិតទៀង ប្រកបដោយប្រយោជន៍ និង វាចានោះ ជាវាចាមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត ដល់ពួកជនដទៃផង, ក្នុងដំណើរនោះ ព្រះតថាគតជាអ្នកជ្រាបនូវកាល ដើម្បីព្យាករនូវព្រះវាចានោះ ។

(៤) ព្រះតថាគត ទ្រង់ជ្រាបនូវព្រះវាចាណា ដែលជាព្រះវាចាមិន

ពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ទោះជាវាចានោះ ជាវាចាជាទីស្រឡាញ់ ជាទីពេញចិត្ត ដល់ពួកជនដទៃ, ព្រះតថាគតក៏មិនទ្រង់ត្រាស់នូវព្រះវាចានោះដែរ ។

(៥) សូម្បីវាចាណា ព្រះតថាគតជ្រាបថា ជាវាចាពិត ទៀង (តែ) មិនប្រកបដោយប្រយោជន៍, ទោះបីវាចានោះ ជាវាចាជាទីស្រឡាញ់ ជាទីពេញចិត្ត ដល់ពួកជនដទៃ, សូម្បីវាចានោះ ក៏ព្រះតថាគត មិនទ្រង់ត្រាស់ដែរ ។

(៦) ចំណែកវាចាណា ព្រះតថាគតទ្រង់ជ្រាបថា ជាវាចាពិត ទៀង ប្រកបដោយប្រយោជន៍ និង វាចានោះ ជាវាចាជាទីស្រឡាញ់ជាទីពេញចិត្ត ដល់ពួកជនដទៃផង, ក្នុងដំណើរនោះ ព្រះតថាគត ជាអ្នកជ្រាបនូវកាល ដើម្បីព្យាករព្រះវាចានោះ [១] ” ដូច្នេះ ។

ព្រះមានព្រះភាគអង្គនោះ បណ្ឌិត គប្បីជ្រាបថា “ទ្រង់ព្រះនាមថា សុគតោ” ព្រោះព្រះអង្គទ្រង់ត្រាស់ ដោយប្រពៃ ដូចបានពណ៌នាមកនេះឯង ប្រការ ១ ។

(១៣០) ក៏ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា លោកវិទូ ក៏ព្រោះព្រះអង្គទ្រង់ជ្រាបលោក ដោយប្រការទាំងពួងពិត ។ មែនពិត ព្រះមានព្រះភាគអង្គនោះ ទ្រង់បានជ្រាប គឺទ្រង់បានយល់ ទ្រង់បានជ្រាបច្បាស់នូវលោក ដោយប្រការទាំងពួង គឺៈ ដោយសភាវៈ, ដោយសមុទយៈ, ដោយនិរោធៈ, ដោយឧបាយនៃនិរោធ សមដូចព្រះអង្គត្រាស់ថាៈ ម្នាលអាវុសោ បុគ្គលមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនបដិសន្ធិក្នុងទីបំផុតនៃលោកណា, តថាគត មិនពោលនូវទីបំផុតនៃលោកនោះ ថា

---

១- សុ. ម. ភាគទី ២៣ ទំព័រទី ១៥៦-១៥៧ ។



គឺបុគ្គលគប្បីដឹង គប្បីឃើញ គប្បីដល់ ដោយការដើរទៅ ដូច្នេះឡើយ, ម្នាលអាវុសោ! មួយទៀត បើតថាគត មិនបានដល់នូវទីបំផុតនៃលោកហើយ ក៏មិនពោលនូវការធ្វើទីបំផុតនៃទុក្ខឡើយ, ម្នាលអាវុសោ មួយវិញទៀត តថាគត បញ្ញត្ត នូវលោក គឺទុក្ខផង លោកសមុទយៈផង លោកនិរោធផង លោកនិរោធគាមិនីបដិបទាផង ក្នុងអត្តភាពប្រមាណមួយព្យាមនេះឯង ដែលប្រកបដោយសញ្ញាផង ប្រកបដោយចិត្តផង ។

ទីបំផុតនៃលោក បុគ្គលមិនគប្បីដល់ ដោយការដើរទៅ
(ដោយជើង) ក្នុងកាលណាម្តងឡើយ, មួយទៀត ការ
មិនទាន់បានដល់នូវទីបំផុតនៃលោក ឈ្មោះថា មិនបាន
រួចចាកទុក្ខឡើយ, ព្រោះហេតុនោះឯង ព្រះដ៏មានព្រះ
ភាគទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់មានបញ្ញាល្អ ទ្រង់
ដល់នូវទីបំផុតនៃលោក ទ្រង់ប្រព្រឹត្តចប់ព្រហ្មចរិយៈ
ហើយ ទ្រង់មានបាបរម្ងាប់បង់ហើយ ទ្រង់ជ្រាបច្បាស់
នូវទីបំផុត នៃលោក ទ្រង់មិនប្រាថ្នា នូវលោកនេះ និង
លោកខាងមុខឡើយ [១] ។

ន័យមួយទៀត លោកមាន ៣ គឺ ៈ សង្ខារលោក, សត្វលោក, ឱកាសលោក ។ ក្នុងលោកទាំង ៣ នោះ សង្ខារលោក បណ្ឌិត គប្បីជ្រាប ក្នុងអាគតដ្ឋាន ថា “លោកមួយ គឺ សត្វទាំងឡាយទាំងពួង តាំងនៅបាន ដោយសារអាហារ [២] ” ។ សត្វលោក បណ្ឌិត គប្បីជ្រាប ក្នុងអាគតដ្ឋាន ថា “លោកទៀង” ខ្លះ ថា “លោកមិនទៀង [៣] ” ខ្លះ ។

---

១-សុ. ភាគ៤២ ទំព័រ១១៧។ ២-សុ. ភាគ៦៩ ទំព័រ២៧៥។ ៣-ភាគ២៨ ទំព័រ៨ ។

*ឱកាសលោក បណ្ឌិតគប្បីជ្រាប ក្នុងអាគតដ្ឋាន ថា :*

ព្រះច័ន្ទ និង ព្រះអាទិត្យទាំងឡាយ ដើរក្រឡឹងជុំវិញភ្នំ
សុមេរុ, ទិសទាំងឡាយ តែងភ្លឺស្វាងរុងរឿង រហូតទីមាន
កំណត់ត្រឹមណា, លោក មានមួយពាន់ចំណែក រហូតទី
មានកំណត់ត្រឹមនោះ, អំណាចរបស់ព្រះអង្គ តែងប្រព្រឹត្ត
ទៅ ក្នុងលោកទាំងឡាយនោះ [១] ។

*ព្រះមានព្រះភាគ ទ្រង់បានជ្រាបនូវលោកទាំង ៣ នោះឯង ដោយប្រការទាំងពួង ។ ពិតមែនដូច្នោះ សូម្បីសង្ខារលោកនេះ គឺលោកមួយ គឺសត្វទាំងឡាយទាំងពួង តាំងនៅបាន ដោយសារអាហារ, លោក ២ គឺនាម ១ រូប ១, លោក ៣ គឺវេទនា ៣, លោក ៤ គឺអាហារ ៤, លោក ៥ គឺឧបាទានក្ខន្ធ ៥, លោក ៦ គឺអាយតនៈខាងក្នុង ៦, លោក ៧ គឺវិញ្ញាណដ្ឋិតិ ៧, លោក ៨ គឺលោកធម៌ ៨, លោក ៩ គឺសត្តាវាស ៩, លោក ១០ គឺ អាយតនៈ ១០, លោក ១២ គឺអាយតនៈ ១២, លោក ១៨ គឺធាតុ ១៨ គឺព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបហើយ ដោយប្រការទាំងពួង [២] ។ មួយទៀត ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់ជ្រាបនូវអាសយៈ (ឆន្ទៈជាទីដេកនៃចិត្ត) ទ្រង់ជ្រាបនូវអនុសយៈ (កិលេសជាគ្រឿងដេកនៅរឿយៗ) ទ្រង់ជ្រាបនូវចរិត ទ្រង់ជ្រាបនូវអធិមុត្តិ (ការបង្អោនចិត្តចូលទៅ) នៃសត្វទាំងឡាយទាំងពួង ទ្រង់ជ្រាបនូវសត្វទាំងឡាយ ដែលមានកិលេសដូចជាធូលីក្នុងភ្នែកតិច ដែលមានកិលេសដូចជាធូលីក្នុងភ្នែកច្រើន ដែលមានឥន្ទ្រិយ៍ចាស់ក្លា ដែលមាន*

*១- សុ. ខុ. ភាគទី ២២ ទំព័រ ៣៦៨ ។ ២- សុ. ខុ. ភាគ ៦៩ ទំព័រ ២៧៥ ។*



*ឥន្ទ្រិយ៍ទន់ខ្សោយ មានអាការៈល្អ មានអាការៈអាក្រក់ ដែលគប្បីឲ្យដឹងបាន ដោយងាយ ដែលគប្បីឲ្យដឹងបានដោយលំបាក ជាសត្វគួរ ជាសត្វអភ័ព ព្រោះហេតុណា, ព្រោះហេតុនោះ សូម្បីសត្វលោក ក៏ព្រះអង្គទ្រង់បានជ្រាបហើយ ដោយប្រការទាំងពួង ។ មួយទៀត សត្វលោក គឺព្រះអង្គទ្រង់ជ្រាបហើយ យ៉ាងណា, សូម្បីឱកាសលោក ក៏ព្រះអង្គទ្រង់ជ្រាបហើយ យ៉ាងនោះដែរ ។*

(ទំហំនៃចក្កវាឡ)

*ពិតដូច្នោះមែន ចក្កវាឡមួយនេះ ដោយបណ្តោយ ដោយទទឹង មានប្រមាណ ១,២០៣,៤៥០ យោជន៍ ។ តែដោយជុំវិញ*

បរិមណ្ឌលទាំងអស់ (នៃចក្កវាឡនោះ) មានប្រមាណ
៣,៦១០,៣៥០ យោជន៍,

(កម្រាស់នៃផែនដី)

*ក្នុងចក្កវាឡនោះ*

ផែនដីនេះ ពោលដោយកម្រាស់ មានប្រមាណប៉ុណ្ណេះ
គឺ ២៤០,០០០ យោជន៍,

(កម្រាស់នៃទឹកទ្រផែនដី)

*គ្រឿងសម្រាប់ទ្រនូវផែនដីនោះឯង គឺ*

ទឹកឋិតនៅលើខ្យល់ ដោយកម្រាស់ មានប្រមាណ
ប៉ុណ្ណេះ គឺ ៤៨០,០០០ យោជន៍,

*គ្រឿងសម្រាប់ទ្រនូវទឹកនោះឯង គឺ :*

ខ្យល់ដែលរសាត់ទៅ លើពពក មានប្រមាណ
៩៦០,០០០ យោជន៍, នេះជាការតាំងនៅព្រមនៃលោក,

(ទំហំនៃភ្នំព្រះសុមេរុ)

*មួយទៀត ក្នុងចក្កវាឡដែលតាំងនៅព្រម យ៉ាងនេះនោះ មាន*

ភ្នំព្រះសុមេរុ ជាភ្នំដែលមានកំពស់ខ្ពស់បំផុត ជ្រៅចុះទៅ ក្នុងមហាសមុទ្រ ៨៤,០០០ យោជន៍, ខ្ពស់ឡើងទៅលើ ក៏មានប្រមាណប៉ុណ្ណោះដែរ,

ភ្នំធំទាំងឡាយ គឺ ភ្នំយុគន្ធរ ភ្នំឥសិន្ធរៈ ភ្នំករវីកៈ ភ្នំសុទស្សនៈ ភ្នំនិមិន្ធរៈ ភ្នំវិនតកៈ ភ្នំអស្សកណ្ណៈ ដែលវិចិត្រហើយ ដោយរតនៈផ្សេងៗ ប្រៀបដូចជាភ្នំទិព្វ ជ្រៅចុះទៅក្រោម និង ឡើងខ្ពស់ទៅលើ ដោយប្រមាណពាក់កណ្ដាលៗ អំពីប្រមាណ នៃភ្នំព្រះសុមេរុនោះ ទៅតាមលំដាប់,

ភ្នំធំទាំង ៧ នោះ (ឋិតនៅ) ដោយជុំវិញ នៃភ្នំព្រះសុមេរុ ជាទីអាស្រ័យនៅ របស់មហារាជ ជាទីដែលទេវតា និង យក្សអាស្រ័យនៅ,

ភ្នំហិមវា ខ្ពស់ ៥០០ យោជន៍ ដោយបណ្ដោយ និងទទឹង ៣,០០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤,០០០,

ដើមជម្ពូ ឈ្មោះនគៈ ដោយជុំវិញដើម មាន ១៥ យោជន៍ មានដើមខ្ពស់ ៥០ យោជន៍ និង មែក ៥០ យោជន៍ លាតសន្ធឹងទៅ មានប្រវែង ១០០ យោជន៍ ដោយជុំវិញ និង កំពស់ឡើងទៅលើ ក៏ប្រវែងដូចគ្នានោះដែរ, ដោយអានុភាពនៃដើមជម្ពូឯណា, ទ្វីបនេះ ទើបលោកប្រកាសឈ្មោះថា ជម្ពូទ្វីប,



*ក៏ទំហំនៃដើមជម្ពូនេះឯណា, ទំហំនេះនុ៎ះឯង ជាទំហំនៃដើម ចិត្របាដលី (ប្រទៀង) របស់អសុរទាំងឡាយ ដើមគរ របស់គ្រុឌទាំងឡាយ ដើមកទម្ព (ក្ទម្ព) ក្នុងអបរគោយានទ្វីប ដើមកប្បព្រឹក្ស ក្នុងឧត្តរកុរុទ្វីប ដើមប្រេស ក្នុងបុព្វវិទេហទ្វីប ដើមរលួសផ្អុង ក្នុងឋានតាវត្តិង្ស ព្រោះហេតុនោះ ទើបបុរាណាចារ្យ ពោលថា :*

ដើមច្រនៀង ដើមគរ ដើមជម្ពូ ដើមរលួសផ្អុង របស់ពួកទេវតា ដើមក្ទម្ព ដើមកប្បព្រឹក្ស និង ដើមទី ៧ គឺ ដើមប្រេស ដូច្នេះ,

(ទំហំនៃភ្នំចក្កវាឡ)

ភ្នំចក្កវាឡ ជ្រៅចុះទៅ ក្នុងមហាសមុទ្រ ៨២,០០០ យោជន៍ ខ្ពស់ឡើងទៅលើ ក៏ប្រមាណប៉ុនណោះដែរ, ភ្នំចក្កវាឡនេះ ឋិតនៅព័ទ្ធជុំវិញលោកធាតុទាំងអស់នោះ,

(ទំហំនៃវិមាននិងទ្វីប)

*ក្នុងលោកធាតុនោះ មណ្ឌល នៃព្រះច័ន្ទ មានប្រមាណ ៤៩ យោជន៍, មណ្ឌល នៃព្រះអាទិត្យមានប្រមាណ ៥០ យោជន៍, វិមានតាវត្តិង្សមាន ១០,០០០ យោជន៍, វិមានអសុរ, មហាអវីចិនរក, ជម្ពូទ្វីប ក៏មានទំហំប៉ុនគ្នានោះដែរ, អបរគោយានទ្វីប មាន ៧,០០០ យោជន៍, បុព្វវិទេហទ្វីប ក៏មានទំហំដូចគ្នានោះដែរ, ឧត្តរកុរុទ្វីប មានប្រមាណ ៨,០០០ យោជន៍, មួយទៀត ក្នុងលោកធាតុនោះ ទ្វីបធំ ទ្វីបមួយៗ មានទ្វីបដែលតូចៗ ជាបរិវារទ្វីបមួយៗ ៥០០ ៗ របស់ទាំងអស់នោះ ជាចក្កវាឡ ១ ឈ្មោះថា លោកធាតុ ១, ក្នុងចន្លោះ នៃលោកធាតុទាំង*

ឡាយ មានលោកន្តរិយនរក ១ ។

ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាប គឺទ្រង់យល់ ទ្រង់ជ្រាបច្បាស់នូវអនន្តចក្កវាឡ អនន្តលោកធាតុទាំងឡាយ មានប្រការដូចពោលមកហើយ ដោយព្រះអនន្តពុទ្ធញ្ញាណ ។ សូម្បីឱកាសលោក ក៏ព្រះអង្គទ្រង់ជ្រាប ដោយប្រការទាំងពួង ដូចបានរៀបរាប់មកនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គទ្រង់ជ្រាបលោកដោយប្រការទាំងពួង យ៉ាងនេះឯង ប្រការ ១ ។

(១៣១) ក៏បុគ្គលដែលក្រៃលែង ជាងព្រះដ៏មានព្រះភាគអង្គនោះមិនមាន ព្រោះមិនមានអ្នកណាម្នាក់ វិសេសជាងព្រះអង្គ ដោយគុណទាំងឡាយ ព្រោះហេតុនោះ ទើបទ្រង់បានព្រះនាមថា អនុត្តរោ ។ ពិតមែនដូច្នោះ ព្រះមានព្រះភាគអង្គនោះ តែងគ្របសង្កត់នូវលោកទាំងពួងដោយសីលគុណផង ដោយសមាធិគុណ, បញ្ញាគុណ, វិមុត្តិគុណ និងវិមុត្តិញ្ញាណទស្សនគុណផង, ព្រះអង្គ មិនមានបុគ្គលស្មើ ស្មើដោយព្រះអង្គ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបស្មើ មិនមានចំណែកប្រៀប មិនមានបុគ្គលប្រៀបដូច ដោយសីលគុណផង ។ល។ ដោយវិមុត្តិញ្ញាណទស្សនគុណផង ។ សមដូចព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគត មិនពិចារណាឃើញនូវសមណៈ ឬ ព្រាហ្មណ៍ដែលដល់ព្រមដោយសីល ក្រៃលែងជាងតថាគត ក្នុងលោក ព្រមទាំងមារលោក ព្រហ្មលោក ។ល។ ក្នុងពួកសត្វ ព្រមទាំងទេវតា និងមនុស្សនេះឡើយ [១] " ដូច្នេះជាដើម ។ បណ្ឌិត គប្បីជ្រាបសេចក្តីពិស្តារ ។ សូត្រទាំងឡាយ មានអគ្គប្បសាទសូត្រជាដើម និង គាថាទាំង

១- សុ. សំ. សគ. ភាគទី ៣០ ទំព័រទី ៣១ ។



ឡាយ មានជាអាទិ៍ថា "អាចារ្យ របស់ខ្ញុំ មិនមាន [១] " ដូច្នេះ បណ្ឌិតគប្បីធ្វើឲ្យពិស្តារ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះទ្រង់ញ៉ាំងបុគ្គលដែលគួរទូន្មានទាំងឡាយឲ្យរលឹក ។ អធិប្បាយថា "ទ្រង់ហ្វឹកគឺទ្រង់នាំទៅដោយវិសេស" ។ បុគ្គលទាំងឡាយដែលមិនទាន់បានហ្វឹកតែគួរដើម្បីនឹងទូន្មានបាន ទោះជាសត្វតិរច្ឆានឈ្មោលក្តី ជាមនុស្សប្រុសក្តី ជាអមនុស្សប្រុសក្តី ឈ្មោះថា បុរសដែលគួរទូន្មានបាន ក្នុងបទថា "បុរិសទម្មសារថិ" នោះ ។ ពិតមែនដូច្នោះ សូម្បីសត្វតិរច្ឆានឈ្មោលទាំងឡាយ ដូចអបលាលនាគរាជ ចូឡោទរនាគរាជ មហោទរនាគរាជ អគ្គិសិខនាគរាជ ធូមសិខនាគរាជ អាលវាឡនាគរាជ ដំរីឈ្មោះធនបាលដូច្នេះជាដើម គឺព្រះមានព្រះភាគទ្រង់ហ្វឹកហើយ គឺទ្រង់ធ្វើឲ្យអស់ពិសហើយ ទ្រង់ឲ្យឋិតនៅចំពោះហើយ ក្នុងសរណៈ និង សីលទាំងឡាយ, សូម្បីមនុស្សប្រុសទាំងឡាយ មានសច្ចកនិគ្រន្ថបុត្រ អម្ពដ្ឋមាណពពោក្ខរសាតិព្រាហ្មណ៍ សោណទណ្ឌព្រាហ្មណ៍ កូដទណ្ឌព្រាហ្មណ៍ ជាដើម សូម្បីអមនុស្សប្រុសទាំងឡាយ មានអាឡវកយក្ស សូចិលោម-យក្ស ខរលោមយក្ស និង សក្កទេវរាជជាដើម ក៏ព្រះអង្គទ្រង់ទូន្មានបានហើយ គឺទ្រង់ណែនាំបានហើយ ដោយឧបាយគ្រឿងណែនាំទាំងឡាយដ៏វិចិត្រ ។ មួយទៀត ក្នុងសេចក្តីនេះ ព្រះសូត្រនេះថា "ម្នាលកេសីតថាគត រមែងណែនាំ នូវបុរសដែលគួរទូន្មានទាំងឡាយ ដោយល្អខ្លះដោយអាក្រក់ខ្លះ រមែងណែនាំដោយល្អ និង ដោយអាក្រក់ខ្លះ [២] " ដូច្នេះជាដើម បណ្ឌិតគប្បី(សំដែង) ឲ្យពិស្តារ ។ មួយវិញទៀត ព្រះ

១- សុ. ម. ភាគទី ២១ ទំព័រ ១៥៤ ។ ២- សុ. អំ. ភាគទី ៤២ ទំព័រទី ២៨៣ ។

មានព្រះភាគ កាលទ្រង់ត្រាស់ពន្យល់ នូវគុណវិសេស មានបឋមជ្ឈានជាដើម ដល់បុគ្គលទាំងឡាយ មានបុគ្គលអ្នកមានសីលបរិសុទ្ធជាដើម និង ទ្រង់ត្រាស់ពន្យល់ នូវបដិបទាមគ្គ ដែលប្រសើរខ្ពង់ខ្ពស់ ដល់ព្រះអរិយបុគ្គលទាំងឡាយ មានសោតាបន្នជាដើម ក៏ឈ្មោះថា ទ្រង់ទូន្មាននូវបុគ្គលដែលទូន្មានហើយមែនពិត ។

ម្យ៉ាងវិញទៀត ២ បទថា “អនុត្តរោ បុរិសទម្មសារថិ” នេះ ជាបទសំដែងសេចក្តីតែមួយទុំះឯង ។ ព្រោះថា ព្រះមានព្រះភាគ ទ្រង់ណែនាំនូវបុរសដែលគួរទូន្មានទាំងឡាយ ដូចជាបុគ្គលទាំងឡាយអង្គុយធ្វើសមាធិ ក្នុងទីតែមួយទុំះឯង ស្ទុះទៅបាន ៨ ទិស មិនជាប់ជំពាក់យ៉ាងដូច្នោះ ព្រោះហេតុនោះ ទើបបណ្ឌិត ថ្វាយព្រះនាមថា “ទ្រង់ណែនាំ នូវបុរសដែលគួរទូន្មានបាន មិនមានបុគ្គលក្រៃលែងជាង” ដូច្នេះ ។ មួយទៀត ក្នុងសេចក្តីនេះ ព្រះសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ដំរីដែលគួរហ្វឹក គឺបុគ្គលអ្នកហ្វឹកដំរី បរទៅហើយ រមែងស្ទុះទៅកាន់ទិសតែមួយទេ [១]” ដូច្នេះជាដើម បណ្ឌិតគប្បី (សំដែង) ឲ្យពិស្តារ ។

(១៣២) ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា “សត្ថា” ព្រោះទ្រង់ប្រៀនប្រដៅរឿយៗ ដោយប្រយោជន៍ ក្នុងលោកនេះ, ប្រយោជន៍ ក្នុងលោកខាងមុខ និង ប្រយោជន៍ដ៏ខ្ពង់ខ្ពស់ តាមសមគួរ ។ មួយទៀត ទ្រង់ព្រះនាមថា “សត្ថា” បានន័យថាព្រះមានព្រះភាគទ្រង់ជាអ្នកនាំពួក, សេចក្តីអធិប្បាយ ក្នុងរឿងនោះ បណ្ឌិតគប្បីជ្រាបតាមន័យបាលីនិទ្ទេសមានជាអាទិ៍ថា “អ្នកនាំពួកញុំាងពួកឲ្យឆ្លងផ្លូវលំបាក គឺឲ្យឆ្លងផ្លូវលំបាកគឺចោរ ឲ្យឆ្លងផ្លូវលំបាកគឺសត្វសាហាវ ឲ្យឆ្លងផ្លូវលំបាកគឺទុរ្ភិក្ស ឲ្យ

១- សុ. ម. ឧ. ភាគទី ២៨ ទំព័រទី ១១៨ ។



ឆ្លង ឲ្យឆ្លងឡើង ឲ្យឆ្លងចៀសចេញ អំពីផ្លូវលំបាកគឺមិនមានទឹក ឲ្យដល់ភូមិផែនដី ដ៏ក្សេមក្សាន្ត យ៉ាងណា, ព្រះមានព្រះភាគ ទ្រង់ជាព្រះសាស្តា ទ្រង់ជាអ្នកនាំពួក ទ្រង់ញុំាងសត្វ ឲ្យឆ្លងផ្លូវលំបាកគឺភព ឲ្យឆ្លងផ្លូវលំបាក គឺជាតិ [១] ” ដូច្នេះជាដើម ក៏យ៉ាងនោះដែរ ។

ពាក្យថា “ទេវមនុស្សានំ” បានដល់ នៃទេវតាទាំងឡាយផង នៃមនុស្សទាំងឡាយផង ។ ពាក្យថា “ទេវមនុស្សានំ” នេះ ព្រះអង្គត្រាស់ហើយ ដោយអំណាចនៃការកំណត់វេនេយ្យសត្វថ្នាក់ឧក្រិដ្ឋ និង ដោយអំណាចការកំណត់យកវេនេយ្យសត្វដែលជាភព្វបុគ្គល ។ តែតាមពិតព្រះមានព្រះភាគ ទ្រង់ជាព្រះសាស្តា នៃសត្វតិរច្ឆានទាំងឡាយផងដែរ ដោយការប្រទាននូវព្រះអនុសាសនី ។ មែនពិត សត្វតិរច្ឆានទាំងឡាយនោះឯង បានដល់ឧបនិស្ស័យសម្បត្តិ ក៏ដោយសារតែការស្តាប់នូវព្រះធម៌ របស់ព្រះមានព្រះភាគហើយ ជាអ្នកមានចំណែកនៃមគ្គផល ក្នុងអត្តភាពទី២ ឬ ទី៣ ព្រោះការដល់ព្រមនៃឧបនិស្ស័យនោះឯង ។ ក៏ក្នុងសេចក្តីនោះ អ្នកដែលបាននូវឧបនិស្ស័យសម្បត្តិ ព្រោះកិរិយាស្តាប់នូវធម៌ មានមណ្ឌូកទេវបុត្រជាដើម ជាឧទាហរណ៍ ។

បានឮមកថា កាលព្រះមានព្រះភាគទ្រង់សំដែងធម៌ ដល់ប្រជាជនដែលនៅក្នុងទីក្រុងចម្បា ក្បែរមាត់ច្រាំងនៃស្រះបោក្ខរណី ឈ្មោះគគ្គរា, សត្វកង្កែបមួយ បានកាន់យកនូវនិមិត្ត ក្នុងសំឡេង របស់ព្រះមានព្រះភាគ ។ បុរសចិញ្ចឹមកូនគោម្នាក់ កាលដាក់ឈើច្រត់ចុះ ក៏បានឈរច្រត់នៅចំក្បាលសត្វកង្កែបនោះជាប់ ។ សត្វកង្កែបនោះស្លាប់ ក្នុងខណៈនោះភ្លាមហើយ បានទៅកើត ក្នុងវិមានមាស កំពស់ ១២ យោជន៍ ក្នុង

១- សុ. ខុ. ចូ. ភាគទី ៦៨ ទំព័រទី ១៨៤ ។

កពតាវត្តិង្ស ប្រៀបដូចជាលក់ទៅហើយ ភ្ញាក់ឡើងវិញ ឃើញខ្លួនមានពួកនាងទេព្ធអប្សរចោមរោម ក្នុងវិមាននោះ ក៏ពិចារណាថា “អើហ្ន៎! អាត្មាអញ មកកើត ក្នុងទីនេះហើយតើ!, អាត្មាអញ បានធ្វើកម្មអ្វីហ្ន៎?” ដូច្នេះ មិនបានឃើញកម្មអ្វីមួយដទៃក្រៅអំពីការកាន់យកនូវនិមិត្ត ក្នុងសំឡេង របស់ព្រះមានព្រះភាគឡើយ ។ ក្នុងខណៈនោះឯង មណ្ឌូកទេវបុត្រនោះ មក ថ្វាយបង្គំព្រះបាទទាំងឡាយ របស់ព្រះមានព្រះភាគ ព្រមទាំងវិមាន ។

ព្រះមានព្រះភាគ ទ្រង់ជ្រាបពិត តែទ្រង់ត្រាស់សួរថា :

> អ្នកណាហ្ន៎ រុងរឿង ដោយឫទ្ធិ ដោយយស មានពណ៌
> សម្បុរល្អស្អាត ញ៉ាំងទិសទាំងពួង ឲ្យភ្លឺស្វាង ថ្វាយបង្គំ
> ជើងទាំងឡាយ របស់តថាគត ។

មណ្ឌូកទេវបុត្រនោះ ក្រាបទូលព្រះមានព្រះភាគ ថា :

> ក្នុងជាតិមុន ទូលព្រះបង្គំ កើតជាសត្វកង្កែប ជាសត្វត្រាច់
> រកស៊ីនៅតាមទឹក ក្នុងទឹក, កាលទូលព្រះបង្គំ កំពុងតែ
> ស្តាប់ធម៌ របស់ព្រះដ៏មានព្រះភាគ, បុរសអ្នកចិញ្ចឹមកូន
> គោ បានសម្លាប់ នូវទូលព្រះបង្គំ ។

ព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ ដល់មណ្ឌូកទេវបុត្រនោះ ។ ការត្រាស់ដឹងធម៌ បានមានហើយដល់សត្វ ៨៤,០០០ ។ ចំណែកឯទេវបុត្រ ឋិតនៅក្នុងសោតាបត្តិផល ធ្វើការសើចហើយចៀសចេញទៅ។

ចំណែកវត្ថុគ្រប់បែបយ៉ាង ដែលឈ្មោះថា បុគ្គលគប្បីដឹង ក៏មាន,



ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះទ្រង់ជ្រាបវត្ថុទាំងអស់នោះឯង ដោយអំណាចនៃព្រះញាណដែលកើត ក្នុងទីបំផុតនៃវិមោក្ខ ។ មួយទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹងនូវសច្ចៈទាំង ៤ ដោយព្រះអង្គឯងផង ទ្រង់ញ៉ាំងសត្វទាំងឡាយដទៃទៀត ឲ្យត្រាស់ដឹងផង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះហេតុទាំងឡាយ ដូចបានពោលមកហើយនេះឯងជាដើម ។ ក៏ដើម្បីឲ្យដឹងច្បាស់នូវសេចក្តីនេះ ន័យ ក្នុងបាលីនិទ្ទេសក្តី ន័យ ក្នុងបាលីបដិសម្ភិទាក្តី ទាំងអស់ដែលប្រព្រឹត្តទៅហើយ យ៉ាងនេះថា “ព្រះមានព្រះភាគទ្រង់ព្រះនាមថា “ពុទ្ធោ” ព្រោះទ្រង់ត្រាស់ដឹង នូវសច្ចទាំងឡាយ, ទ្រង់ព្រះនាមថា “ពុទ្ធោ” ព្រោះទ្រង់ញ៉ាំងពួកសត្វឲ្យត្រាស់ដឹង [១] ” ដូច្នេះជាដើម បណ្ឌិតគប្បី (សំដែង) ឲ្យបានពិស្តារ ។

(១៣៣) ចំណែកពាក្យថា “ភគវា” នេះ ជាពាក្យហៅព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គវិសេសដោយគុណ, ជាអ្នកប្រសើរបំផុត និងជាគ្រូ ដោយសេចក្តីគោរព ។

ព្រោះហេតុនោះ ទើបបុរាណាចារ្យ ពោលហើយ ថា :

> ពាក្យថា “ភគវា” ជាពាក្យប្រសើរ, ពាក្យថា “ភគវា”
> ជាពាក្យប្រសើរបំផុត, ព្រះមានព្រះភាគអង្គនោះ ទ្រង់ជា
> គ្រូ ទ្រង់ប្រកបដោយគុណធម៌របស់គ្រូ ព្រោះហេតុនោះ
> ទើបទ្រង់ព្រះនាមថា “ភគវា” ។

ម្យ៉ាងវិញទៀត នាម មាន ៤ យ៉ាង គឺ អាវត្ថិកនាម (នាមដែល

---

១- សុ. ខុ. ចូ. ខុ. ប. ភាគទី ៦៨ ទំព័រទី ១០៧ ។

ហៅទៅតាមកាលសម័យ) លិង្គិកនាម (នាមដែលហៅទៅតាមភេទ) នេមិត្តិកនាម (នាមដែលជានិមិត្ត) អធិច្ចសមុប្បន្ននាម (នាមដែលតាំងឡើងធម្មតាៗ) ។ មានពាក្យអធិប្បាយថា “នាមដែលតាំងឡើង តាមសេចក្តីប្រាថ្នាតាមវោហាររបស់លោក ឈ្មោះថា អធិច្ចសមុប្បន្ននាម” ។

ក្នុងនាមទាំង ៤ នោះ នាមដូចជា “វច្ឆោ កូនគោ, ទម្មោ គោដែលគេហ្វឹក, ពលិពទ្ទោ គោប្រើ” ដូច្នេះជាដើម ឈ្មោះថា អាវត្ថិកនាម ។ នាមដូចជា “ទណ្ឌី មនុស្សមានឈើច្រត់, ឆត្តី មនុស្សមានឆ័ត្រ, សិខី សត្វមានសិរ, ករី សត្វមានប្រមោយ” យ៉ាងដូច្នេះជាដើម ឈ្មោះថា លិង្គិកនាម ។ នាមដូចជា “តេវិជ្ជោ អ្នកមានវិជ្ជា ៣, ឆឡភិញ្ញោ អ្នកបានអភិញ្ញា ៦” ដូច្នេះជាដើម ឈ្មោះថា នេមិត្តិកនាម ។ នាមដែលតាំងឡើង មិនគិតដល់សេចក្តីនៃពាក្យ ដូចជា “សិរីវឌ្ឍកោ អ្នកចំរើនដោយសិរី, ធនវឌ្ឍកោ អ្នកចំរើនដោយទ្រព្យ” យ៉ាងដូច្នេះជាដើម ឈ្មោះថា អធិច្ចសមុប្បន្ននាម ។

ចំណែកព្រះនាមថា “ភគវា” នេះជានេមិត្តិកនាម, ព្រះនាងមហាមាយា មិនបានតាំងថ្វាយ, ព្រះបាទសុទ្ធោទនមហារាជ មិនបានតាំងថ្វាយ, ព្រះញាតិ ៨៤,០០០ ក៏មិនបានតាំងថ្វាយ, ទេវតា វិសេសទាំងឡាយ មានសក្កទេវរាជ និង សន្តុសិតទេវបុត្រជាដើម ក៏មិនបានតាំងថ្វាយ ។ មែនពិត ពាក្យនេះ ព្រះធម្មសេនាបតី បានពោលហើយថា “ព្រះនាមថា ភគវា នោះ ព្រះមាតាមិនបានតាំងថ្វាយ ។ល។ ព្រះនាមនោះ ជាវិមោក្ខន្តិកនាម ព្រះនាមដែលកើត ក្នុងទីបំផុតនៃវិមោក្ខ ព្រមទាំងការបាននូវសព្វញ្ញុតញ្ញាណ ក្រោមដើមពោធិព្រឹក្ស នៃព្រះដ៏មានព្រះភាគ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ, ព្រះនាមនោះ ជាសច្ឆិកាបញ្ញត្តិ



តាំងឡើងព្រោះត្រាស់ដឹងធម៌ជាក់ច្បាស់, ព្រះនាមនេះគឺអ្វី ?, ព្រះនាមនេះ គឺ ភគវា [១] ” ដូច្នេះ ។

ក៏ព្រះនាមនោះ មានគុណណាជានិមិត្ត, ដើម្បីសំដែងនូវគុណទាំងឡាយនោះ ព្រះសង្គីតិកាចារ្យទាំងឡាយ ពោលនូវគាថានេះ ថា :

> ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា ភគវា ព្រោះជាភគី អ្នកមានជោគ, ព្រោះជាភជី អ្នកសេព, ព្រោះជាភាគី អ្នកមានចំណែក, ព្រោះជាវិភត្តវា អ្នកចំណែក, ព្រោះបានធ្វើនូវការបំបាក់ នូវកិលេស, ព្រោះជាគ្រូ, ព្រោះមានភាគ្យៈ អ្នកមានបុណ្យបារមី, ព្រោះជាសុភាវិតត្តនោ ទ្រង់អប់រំព្រះអង្គល្អហើយ ដោយញាណទាំងឡាយដ៏ច្រើន, ព្រោះជាភវន្តគៈ អ្នកដល់ទីបំផុតនៃភព ។

ក៏សេចក្តីអធិប្បាយ នៃបទទាំងឡាយនោះៗ ក្នុងគាថានោះ បណ្ឌិតគប្បីឃើញ តាមន័យដែលបានពោលមកហើយ ក្នុងនិទ្ទេសនោះឯង ។ ចំណែកន័យនេះ ជាន័យមួយផ្សេងទៀត គឺ :

> ព្រះមានព្រះភាគ ព្រះអង្គជាអ្នកមានភាគ្យៈ ជាអ្នកកាច់បំបាក់ ជាអ្នកប្រកប ដោយភគធម៌ទាំងឡាយ ជាអ្នកចំណែក ជាអ្នកសេព ជាអ្នកកំចាត់នូវការត្រាច់ទៅ ក្នុងភពទាំងឡាយ ព្រោះហេតុនោះ ទ្រង់ព្រះនាម ថា ភគវា ។

---

១- សុ. ខុ. ចូ. ភាគទី ៦៧ ទំព័រទី ១៦ ។

បណ្តាបទទាំងនោះ បណ្ឌិត គប្បីជ្រាបថា : លោកកាន់យកនូវនិរុត្តិលក្ខណៈ មានលក្ខណៈ ជាអាទិ៍ថា “វណ្ណាគមោ ចុះតួអក្សរថ្មី, វណ្ណវិបរិយាយោ ផ្លាស់តួអក្សរ” ដូច្នេះ ឬក៏ កាន់យកនូវលក្ខណៈ គឺការរួមបញ្ចូល ក្នុងស័ព្ទមានបិសោទរស័ព្ទជាដើម ដោយន័យ នៃស័ព្ទសាស្ត្រ, ព្រះមានព្រះភាគអង្គនោះ ទ្រង់មានភាគ្យៈ គឺព្រះបារមី មានទានបារមី និង សីលបារមីជាដើម ដែលប្រសើរខ្ពង់ខ្ពស់ អាចញ៉ាំងសេចក្តីសុខដែលជាលោកិយៈ និង លោកុត្តរៈ ឲ្យកើតឡើងបាន ព្រោះហេតុណា, ព្រោះហេតុនោះ កាលបើត្រូវពោលថា “ភាគ្យវា” ក៏ពោលថា “ភគវា” ដូច្នេះ ។

មួយទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់កាច់បំបាក់កិលេសដែលធ្វើសេចក្តីក្រវល់ក្រវាយ និង សេចក្តីក្តៅក្រហាយទាំងពួង បានរាប់សែនយ៉ាង គឺ ប្រភេទលោភៈ, ទោសៈ, មោហៈ, ការធ្វើទុកក្នុងចិត្តវិបរិត្ត, អហិរិកៈ, អនោត្តប្បៈ, កោធៈ, ឧបនាហៈ, មក្ខៈ, បលាសៈ, ឥស្សា, មច្ឆរិយៈ, មាយា, សាថេយ្យៈ, ថម្ភៈ, សារម្ភៈ, មានះ, អតិមានះ, មទៈ, បមាទៈ, តណ្ហា, អវិជ្ជា, អកុសលមូល ៣, ទុច្ចរិត ៣, សង្កិលេស ៣, មលៈ ៣, វិសមៈ ៣, សញ្ញា ៣, វិតក្កៈ ៣, បបញ្ច ៣, វិបរិយេសៈ ៤, អាសវៈ ៤, គណ្ឋៈ ៤, ឱឃៈ ៤, យោគៈ ៤, អគតិ ៤, តណ្ហុបាទាន ៤, ចេតោខីលៈ ៥, វិនិពន្ធៈ ៥, នីវរណៈ ៥, អភិនន្ទៈ ៥, វិវាទមូល ៦, កងនៃតណ្ហា ៦, អនុសយៈ ៧, មិច្ឆត្តៈ ៨, តណ្ហាមូលកៈ ៩, អកុសលកម្មបថ ១០, ទិដ្ឋិគតៈ ៦២, តណ្ហាវិបរិត្ត ១០៨ ឬថា ដោយសង្ខេប ទ្រង់កាច់បំបាក់ នូវមារទាំង ៥ គឺ កិលេសមារ, ខន្ធមារ, អភិសង្ខារមារ, ទេវបុត្តមារ និង មច្ចុមារ ព្រោះហេតុណា,



ព្រោះហេតុនោះ កាលបើត្រូវពោលថា “ភគ្គវា” ព្រោះទ្រង់កាច់បំបាក់អន្តរាយទាំងឡាយនោះអស់ហើយ តែពោលថា “ភគវា” ដូច្នេះ ។

មែនពិត ក្នុងសេចក្តីនេះ លោកពោលថា :

> ព្រះមានព្រះភាគ ទ្រង់ជាអ្នកកាច់បំបាក់រាគៈ ជាអ្នកកាច់បំបាក់ទោសៈ ជាអ្នកកាច់បំបាក់មោហៈ ជាអ្នកមិនមានអាសវៈ ជាអ្នកកាច់បំបាក់បាបធម៌ទាំងឡាយបានហើយ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា “ភគវា” ។

ក៏ការដល់ព្រមនៃព្រះរូបកាយ របស់ព្រះមានព្រះភាគអង្គនោះ ដែលទ្រទ្រង់នូវបុញ្ញលក្ខណៈ ១០០ គឺលោកសំដែងហើយ ដោយភាវៈនៃព្រះអង្គជាអ្នកមានបុណ្យបារមី, ការដល់ព្រមនៃធម្មកាយ គឺលោកសំដែងហើយ ដោយភាវៈនៃព្រះអង្គ ជាអ្នកបំបាក់ទោសៈបានហើយ, ភាពនៃព្រះអង្គ ជាអ្នកគឺមនុស្ស ក្នុងលោក និង មនុស្សជិតខាងទាំងឡាយ ស្គាល់ជាច្រើនក្តី ភាពនៃព្រះអង្គ ជាអ្នកគឺពួកគ្រហស្ថ និង បព្វជិត គប្បីទៅរកក្តី ភាពជាអ្នកអង់អាច ក្នុងការជួយកំចាត់សេចក្តីទុក្ខខាងផ្លូវកាយ និង ផ្លូវចិត្ត របស់ពួកជនទាំងឡាយនោះ ដែលទៅរកហើយក្តី ភាពជាអ្នកធ្វើឧបការៈ ដល់ពួកជនទាំងនោះ ដោយអាមិសទាន និង ធម្មទានទាំងឡាយក្តី និង ភាពជាអ្នកអាចក្នុងការញ៉ាំងជនទាំងនោះ ឲ្យប្រកបព្រមដោយសេចក្តីសុខជាលោកិយៈ និង សេចក្តីសុខដែលជាលោកុត្តរៈ គឺលោកសំដែងហើយដោយគុណសម្បត្តិទាំង ២ នោះដែរ ។

មួយទៀត ភគៈ ស័ព្ទ ក្នុងលោក រមែងប្រព្រឹត្តទៅ ក្នុងធម៌ទាំង ៦ យ៉ាង គឺៈ ភាពជាធំ, ធម៌, យស, សិរី, កាម និង សេចក្តីព្យាយាម ។

ក៏ភាពជាធំ ក្នុងព្រះហឫទ័យ របស់ខ្លួនព្រះអង្គឯង នៃព្រះមានព្រះភាគនោះ ដ៏ប្រសើរក៏មាន ឬក៏ ភាពជាធំ ដែលលោកសន្មតហើយ មានការធ្វើកាយឲ្យរួញតូច និង ការធ្វើកាយឲ្យស្រាលជាដើម ដែលពេញបរិបូរ ដោយអាការៈគ្រប់យ៉ាង របស់ព្រះមានព្រះភាគអង្គនោះ ក៏មាន, ដោយន័យដូចគ្នានោះដែរ ព្រះធម៌ដែលជាលោកុត្តរៈ របស់ព្រះអង្គ ក៏មាន, ព្រះយស របស់ព្រះអង្គ ប្រាកដច្បាស់ ក្នុងលោកទាំង ៣ ជាព្រះយសដែលព្រះអង្គបានហើយ ដោយព្រះគុណតាមសេចក្ដីពិត ជាព្រះយសស្អាតបរិសុទ្ធដ៏ក្រៃលែង ក៏មាន, ព្រះសិរីនៃព្រះអវយវៈតូច-ធំ ទាំងពួងបរិបូរ ដោយអាការៈគ្រប់យ៉ាង អាចញ៉ាំងសេចក្ដីជ្រះថ្លា ក្នុងភ្នែក និង ចិត្ត ឲ្យកើតឡើង ដល់ជនអ្នកខ្វល់ខ្វាយ ក្នុងការមើលនូវព្រះរូបកាយក៏មាន, កាមៈ (សេចក្ដីប្រាថ្នា) ដែលសម្គាល់ថា សេចក្ដីសម្រេច នៃប្រយោជន៍ ដែលទ្រង់ប្រាថ្នាហើយក៏មាន ព្រោះប្រយោជន៍ណាៗ ដែលព្រះអង្គប្រាថ្នាហើយ ត្រូវការហើយ ទោះជាប្រយោជន៍ផ្ទាល់ព្រះអង្គក្ដី ប្រយោជន៍នៃជនដទៃក្ដី ប្រយោជន៍នោះៗ ក៏បានសម្រេចសម តាមព្រះបំណងទាំងនោះហើយ និង សេចក្ដីព្យាយាម ពោលគឺសម្មាវាយាមៈ ដែលជាហេតុឲ្យកើតឡើង នៃភាពជាគ្រូនៃលោកទាំងពួង ក៏មាន ព្រោះហេតុណា, ព្រោះហេតុនោះ ទើបអ្នកប្រាជ្ញ ថ្វាយព្រះនាមថា “**ភគវា**” ព្រោះអត្ថនេះថា “ព្រះអង្គ ទ្រង់មានភគធម៌” ព្រោះទ្រង់ប្រកប ដោយភគធម៌ទាំងឡាយនេះ ដូច្នេះប្រការ ១ ។

មួយទៀត ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **វិភត្តវា** មានពាក្យអធិប្បាយថា ទ្រង់ចំណែក ទ្រង់បើក ទ្រង់សំដែងនូវធម៌ទាំងពួង ដោយប្រភេទទាំងឡាយ មានកុសលជាដើម ឬ នូវធម៌ មានកុសលជាដើម



ដោយប្រភេទទាំងឡាយមានខន្ធ, អាយតនៈ, ធាតុ, សច្ចៈ, ឥន្ទ្រិយ៍ និង បដិច្ចសមុប្បាទ ឬ នូវអរិយសច្ច គឺទុក្ខ ដោយអត្ថ គឺ បៀតបៀន, ត្រូវបច្ច័យតាក់តែង, ដុតរោល និង ប្រែប្រួល, នូវអរិយសច្ច គឺសមុទយៈ ដោយអត្ថ គឺប្រមូលមក (នូវទុក្ខ) ជាហេតុ (នៃទុក្ខ) ចងភ្ជាប់ (ជាមួយទុក្ខ) និង សេចក្ដីកង្វល់ (មិនឲ្យបានដល់មគ្គ) នូវអរិយសច្ច គឺនិរោធ ដោយអត្ថ គឺ រលាស់ខ្លួនចេញ (ចាកទុក្ខ) ស្ងប់ស្ងាត់ (ចាកទុក្ខ) គ្មានបច្ច័យតាក់តែង ជាធម្មជាតមិនស្លាប់ នូវអរិយសច្ច គឺមគ្គ ដោយអត្ថ គឺ នាំចេញ (ចាកទុក្ខ) ជាហេតុនៃនិរោធ ជាគ្រឿងឃើញព្រះនិព្វាន ជាធំក្នុងការឃើញអរិយសច្ច ព្រោះហេតុណា, ព្រោះហេតុនោះ កាលបើត្រូវពោលថា “**វិភត្តវា**” តែពោលថា “**ភគវា**” ដូច្នេះ ។

មួយទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់គប់ គឺទ្រង់សេព ទ្រង់ធ្វើឲ្យច្រើននូវធម៌ដែលជាទិព្វវិហារ ព្រហ្មវិហារ និង អរិយវិហារ នូវកាយវិវេក ចិត្តវិវេក និង ឧបធិវិវេក នូវសុញ្ញតវិមោក្ខ អប្បណិហិត-វិមោក្ខ និង អនិមិត្តវិមោក្ខ និង នូវឧត្តរិមនុស្សធម៌ទាំងឡាយ ដែលជាលោកិយៈ និង លោកុត្តរៈដទៃទៀត ព្រោះហេតុណា, ព្រោះហេតុនោះ កាលបើត្រូវពោលថា “**ភត្តវា**” តែពោលថា “**ភគវា**” ដូច្នេះ ។

មួយវិញទៀត ព្រោះការទៅ ពោលគឺតណ្ហា ក្នុងភពទាំង ៣ គឺព្រះអង្គទ្រង់ខ្ជាក់ចោលហើយ ហេតុនោះ កាលបើត្រូវពោលថា “**ភវេសុ វន្តគមនោ**” តែលោកយក **ភ** អក្សរ អំពី **ភវ** សព្ទ **គ** អក្សរ អំពី **គមន** សព្ទ និង **វ** អក្សរ អំពី **វន្ត** សព្ទ ធ្វើឲ្យទៅជាទីឃៈ ហើយពោលថា “**ភគវា**” ដូច្នេះ ប្រៀបដូចជាក្នុងផ្លូវលោក កាលបើត្រូវពោលថា “**មេហនស្ស ខស្ស មាលា** (មាលា នៃឱកាសដែលជាទីកំបាំង)” ដូច្នេះ

តែអ្នកប្រាជ្ញ (យក មេ អំពី មេហនស្ស, ខ អំពី ខស្ស, លា អំពី មាលា ហើយ) ពោលថា “មេខលា” យ៉ាងនោះឯង ។

(១៣៤) កាលបើព្រះយោគីនោះ រលឹកនូវគុណ របស់ព្រះពុទ្ធ ថា “ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះ អរហំ ព្រោះហេតុនេះផង ព្រោះហេតុនេះផង ។បេ។ ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះ ភគវា ព្រោះហេតុនេះផង” ដូច្នេះ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តដែលរាគៈ រួបរឹតមិនបាន ជាចិត្តដែលទោសៈ រួបរឹតមិនបាន ជាចិត្តដែលមោហៈ រួបរឹតមិនបានមែនពិត, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តដែលដើរទៅត្រង់ មែនពិត ប្រារព្ធនូវព្រះតថាគត ។ កាលបើព្រះយោគីនោះ សង្កត់សង្កិននីវរណធម៌បានហើយ ដោយការមិនមានបរិយុដ្ឋានកិលេស មានរាគៈជាដើម យ៉ាងដូច្នេះហើយ ឈ្មោះថាមានចិត្តដើរទៅត្រង់ ព្រោះភាវៈជាអ្នកមានចិត្តឆ្ពោះទៅរកកម្មដ្ឋាន, វិតក្កៈ និង វិចារៈ ដែលបង្អោនទៅរកគុណព្រះពុទ្ធ រមែងប្រព្រឹត្តទៅ យ៉ាងនេះឯង ។ កាលបើព្រះយោគីនោះ ត្រិះរិះ ពិចារណារឿយៗ នូវគុណព្រះពុទ្ធ, បីតិ រមែងកើតឡើង ។ សេចក្តីក្រវល់ក្រវាយខាងផ្លូវកាយ និង ចិត្ត របស់ព្រះយោគី អ្នកមានចិត្តប្រកប ដោយបីតិ រមែងស្ងប់រម្ងាប់ ព្រោះសេចក្តីស្ងប់រម្ងាប់ ដែលមានបីតិ ជាបទដ្ឋាន ។ សេចក្តីសុខដែលប្រព្រឹត្តទៅ ទាំងខាងផ្លូវកាយ ទាំងខាងផ្លូវចិត្ត រមែងកើតឡើង ដល់ព្រះយោគីអ្នកមានសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ហើយ ។ ចិត្ត របស់ព្រះយោគីអ្នកមានសេចក្តីសុខ ជាចិត្តមានគុណ របស់ព្រះពុទ្ធជាអារម្មណ៍ រមែងតាំងនៅមាំ, អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈតែមួយ ដោយលំដាប់ ដូចបានពណ៌នាមកនេះ ។ តែឈាននេះ ឈ្មោះថា



ជាឈានមិនដល់អប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ ព្រោះភាវៈនៃព្រះពុទ្ធគុណទាំងឡាយ ជាអារម្មណ៍ដែលជ្រាលជ្រៅ ឬ ព្រោះភាវៈនៃចិត្តបង្អោនទៅក្នុងការរលឹករឿយៗនូវព្រះគុណមានប្រការផ្សេងៗ ។ ឈាននោះនុ៎ះ រមែងដល់នូវការរាប់ ថា “ពុទ្ធានុស្សតិ” ហ្នឹងឯង ព្រោះជាឈាន ដែលកើតឡើង ដោយអំណាចនៃការរលឹករឿយៗ ដល់គុណរបស់ព្រះពុទ្ធ ។

(អានិសង្សចំរើនពុទ្ធានុស្សតិ)

ក៏ភិក្ខុអ្នកប្រកបរឿយៗ នូវពុទ្ធានុស្សតិនេះ ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែងចំពោះព្រះសាស្តា រមែងបានចំពោះនូវការពេញបរិបូណ៌នៃសទ្ធា ការពេញបរិបូណ៌នៃសតិ ការពេញបរិបូណ៌នៃបញ្ញា និង ការពេញបរិបូណ៌នៃបុណ្យ ជាអ្នកច្រើនទៅ ដោយបីតិ និង បាមោជ្ជៈ អត់ធន់ចំពោះភ័យ និង ហេតុដែលគួរឲ្យខ្លាច ជាអ្នកអាចអត់សង្កត់សេចក្តីទុក្ខ រមែងបានចំពោះនូវសេចក្តីសម្គាល់ថា ដូចជាបាននៅរួមជាមួយនឹងព្រះសាស្តា ។

មួយទៀត សូម្បីសរីរៈ របស់ភិក្ខុនោះ ដែលការរលឹករឿយៗ នូវគុណរបស់ព្រះពុទ្ធ គ្រប់គ្រងហើយ ជាកាយដែលគួរដល់ការបូជា ដូចជាផ្ទះនៃចេតិយ ។ ចិត្ត រមែងបង្អោនចូលទៅក្នុងពុទ្ធភូមិ ។ មួយវិញទៀត កាលបើមានការជួបប្រសប់នឹងវត្ថុដែលគួរប្រព្រឹត្តល្មើស ហិរិ និង ឱត្តប្បៈ រមែងប្រាកដដល់ភិក្ខុនោះ ដូចជាឃើញព្រះសាស្តា នៅចំពោះមុខ ។ មួយទៀត ភិក្ខុ កាលមិនទាន់ចាក់ធ្លុះនូវគុណធម៌ខ្ពង់ខ្ពស់ រមែងជាអ្នកមានសុគតិនៅខាងមុខ ។

ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើនូវ

សេចក្ដីមិនប្រមាទ ក្នុងពុទ្ធានុស្សតិ ដែលមាន
អានុភាពច្រើន យ៉ាងនេះ គ្រប់ៗ កាល ។

*នេះជាកថាមុខ យ៉ាងពិស្ដារ ក្នុងពុទ្ធានុស្សតិ ជាបឋម ។*

❈ ❈ ❈

**(ការចំរើនធម្មានុស្សតិ)**

*(១៣៥) សូម្បីព្រះយោគី មានប្រាថ្នានឹងចំរើនធម្មានុស្សតិ ក៏គប្បីជាអ្នកទៅក្នុងទីស្ងាត់ គេចចេញអំពីពួក ពួនសម្ងំនៅហើយ រលឹកគុណទាំងឡាយ នៃព្រះបរិយត្តិធម៌ និង ព្រះលោកុត្តរធម៌ ៩ ប្រការ យ៉ាងនេះថា* “ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ” *ដូច្នេះ ។*

*ក៏ក្នុងបទថា* “ស្វាក្ខាតោ” *នេះ សូម្បីព្រះបរិយត្តិធម៌ ក៏ដល់នូវការសង្គ្រោះផងដែរ, ក្នុងបទទាំងឡាយក្រៅអំពីនេះ បានដល់ លោកុត្តរធម៌តែម្យ៉ាង ។ បណ្ដាធម៌ទាំង ២ យ៉ាងនោះ ដំបូង ព្រះបរិយត្តិធម៌ ឈ្មោះថា* ស្វាក្ខាតៈ *ព្រោះភាវៈជាធម៌មានលំអបទដើម មានលំអបទកណ្ដាល មានលំអបទចុង និង ព្រោះភាវៈជាធម៌ប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ។*

*មែនពិត ព្រះមានព្រះភាគ ទ្រង់ដំដែងនូវព្រះគាថាណា សូម្បីមួយបទ, ព្រះគាថានោះ ជាគាថាមានលំអបទដើម ដោយបទជាបឋម មានលំអបទកណ្ដាល ដោយបទ ទី២ និង បទ ទី៣ មានលំអបទចុង ដោយបទខាងចុង ព្រោះភាវៈនៃព្រះធម៌ មានសេចក្ដីល្អនៅជុំវិញ ។*

*ព្រះសូត្រដែលមានអនុសន្ធិមួយ ជាសូត្រមានលំអបទដើម ដោយ*



*និទានវចនៈ មានលំអបទចុង ដោយនិគមវចនៈ មានលំអបទកណ្ដាល ដោយពាក្យដ៏សេសៗ ព្រះសូត្រដែលមានអនុសន្ធិផ្សេងៗ ជាសូត្រមានលំអបទដើម ដោយអនុសន្ធិជាបឋម មានលំអបទចុង ដោយអនុសន្ធិខាងចុង មានលំអបទកណ្ដាល ដោយអនុសន្ធិ ដ៏សេសទាំងឡាយ ។ មួយវិញទៀត ព្រះសូត្រនោះ ឈ្មោះថា មានលំអបទដើម ព្រោះជាព្រះសូត្រ ដែលមានទាំងនិទាន មានទាំងហេតុដែលកើតឡើង ឈ្មោះថា មានលំអបទកណ្ដាល ព្រោះមានសេចក្ដីមិនវិបរិត្ត និង ព្រោះប្រកបដោយហេតុ និង ឧទាហរណ៍ តាមសមគួរដល់វេនេយ្យសត្វទាំងឡាយ និង ឈ្មោះថា មានលំអបទចុង ព្រោះពាក្យនិគមវចនៈ ដែលញ៉ាំងការបានចំពោះនូវសទ្ធា ឲ្យកើតឡើង ដល់ពួកអ្នកស្ដាប់ ។*

*សាសនធម៌ទាំងអស់ ឈ្មោះថា ជាធម៌មានលំអបទដើម ព្រោះសីលដែលជាប្រយោជន៍ របស់ខ្លួន, ឈ្មោះថា មានលំអបទកណ្ដាល ព្រោះសមថៈ វិបស្សនា មគ្គ និង ផលទាំងឡាយ, ឈ្មោះថា មានលំអបទចុង ព្រោះព្រះនិព្វានក៏បាន ។ មួយទៀត សាសនធម៌ ឈ្មោះថា មានលំអបទដើម ព្រោះសីល និង សមាធិ, ឈ្មោះថា មានលំអបទកណ្ដាល ព្រោះវិបស្សនា និង មគ្គ, ឈ្មោះថា មានលំអបទចុង ព្រោះផល និង និព្វាន ។ សាសនធម៌ ឈ្មោះថា មានលំអបទដើម ព្រោះការត្រាស់ដឹងដោយប្រពៃ របស់ព្រះពុទ្ធ, មានលំអបទកណ្ដាល ព្រោះភាវៈនៃព្រះធម៌ជាធម៌ដែលល្អប្រពៃ មានលំអបទចុង ព្រោះការប្រតិបត្តិល្អ របស់ព្រះសង្ឃ ។ ឬក៏ សាសនធម៌ ឈ្មោះថា មានលំអបទដើម ព្រោះប្រាជ្ញាគ្រឿងត្រាស់ដឹង ដ៏ក្រៃលែង មានលំអបទកណ្ដាល ព្រោះប្រាជ្ញាគ្រឿងត្រាស់ដឹង ដោយចំណែកមួយ មានលំអបទខាងចុង ព្រោះ*

ប្រាជ្ញាគ្រឿងត្រាស់ដឹងនៃសាវក ដែលបុគ្គលអ្នកបានស្តាប់នូវសាសនធម៌នោះហើយប្រតិបត្តិដើម្បីការត្រាស់ដឹងយ៉ាងដូច្នោះ គប្បីបានសំរេចៗម្យ៉ាងទៀត សាសនធម៌នោះ គឺបុគ្គលកំពុងស្តាប់ រមែងនាំមកនូវសេចក្តីល្អ ដោយពិត សូម្បីដោយការស្តាប់ ព្រោះគ្របសង្កត់នីវរណធម៌បានហើយ ព្រោះហេតុនោះ ទើបឈ្មោះថា មានលំអបទដើម, បុគ្គល កាលប្រតិបត្តិ រមែងនាំមកនូវសេចក្តីល្អ សូម្បីដោយការប្រតិបត្តិ ព្រោះនាំសេចក្តីសុខ ក្នុងសមថៈ និង សេចក្តីសុខ ក្នុងវិបស្សនា មកឲ្យ ព្រោះហេតុនោះ ទើបឈ្មោះថា មានលំអបទកណ្តាល និង បុគ្គល ប្រតិបត្តិហើយយ៉ាងដូច្នោះ, កាលបើផល នៃការប្រតិបត្តិ សម្រេចហើយ, ក៏រមែងនាំមកនូវសេចក្តីល្អ សូម្បីដោយផលនៃការប្រតិបត្តិ ព្រោះនាំនូវភាពជាអ្នកនឹងធឹងមកឲ្យ ព្រោះហេតុនោះ ទើបឈ្មោះថា មានលំអបទចុង ដោយប្រការដូច្នេះ ។ សាសនធម៌នោះ ឈ្មោះថា ជាធម៌គឺព្រះមានព្រះភាគ ត្រាស់សំដែងហើយដោយល្អ ព្រោះជាធម៌មានលំអបទដើម, មានលំអបទកណ្តាល និង មានលំអបទចុង ដូចពណ៌នាមកនេះឯង ។

មួយទៀត ព្រះដ៏មានព្រះភាគអង្គនោះកាលទ្រង់សំដែងធម៌ រមែងប្រកាស គឺសំដែងដោយន័យផ្សេងៗ នូវសាសនព្រហ្មចរិយធម៌ និង មគ្គព្រហ្មចរិយធម៌ឯណា, សាសនព្រហ្មចរិយធម៌ និង មគ្គព្រហ្មចរិយធម៌នោះ ឈ្មោះថា សាត្ថៈ ព្រោះដល់ព្រម ដោយអត្ថ ឈ្មោះថា សព្យញ្ជនៈ ព្រោះដល់ព្រមដោយព្យញ្ជនៈ តាមសមគួរ ។

ឈ្មោះថា សាត្ថៈ ព្រោះប្រកបព្រមដោយអត្ថបទ គឺសំដែងសេចក្តីដោយសង្ខេប, ផ្តើមប្រកាស, ពង្រីកសេចក្តី, ចំណែកសេចក្តី, ធ្វើសេចក្តីឲ្យរាក់ និង បញ្ញត្តិ, ឈ្មោះថា សព្យញ្ជនៈ ព្រោះការដល់ព្រម



ដោយអក្ខរៈ, បទ, ព្យញ្ជនៈ, អាការៈ, និរុត្តិ និង និទ្ទេស ។

ឈ្មោះថា សាត្ថៈ ព្រោះភាវៈជាធម៌ជ្រាលជ្រៅ ដោយអត្ថ និង ព្រោះភាវៈជាធម៌ជ្រាលជ្រៅដោយបដិវេធ, ឈ្មោះថា សព្យញ្ជនៈ ព្រោះជ្រាលជៅដោយធម៌ និង ព្រោះជ្រាលជ្រៅដោយទេសនា ។

ឈ្មោះថា សាត្ថៈ ព្រោះជាវិស័យ នៃអត្ថប្បដិសម្ភិទា និង បដិភាណប្បដិសម្ភិទា, ឈ្មោះថា សព្យញ្ជនៈ ព្រោះជាវិស័យ នៃធម្មប្បដិសម្ភិទា និង និរុត្តិបដិសម្ភិទា ។

ឈ្មោះថា សាត្ថៈ ព្រោះវិគ្រោះថា ញ៉ាំងបរិក្ខកជនឲ្យជ្រះថ្លា ព្រោះជាធម៌ គឺអ្នកប្រាជ្ញគប្បីដឹង, ឈ្មោះថា សព្យញ្ជនៈ ព្រោះវិគ្រោះថា ជាគុណញ៉ាំងលោកិយជនឲ្យជ្រះថ្លា ព្រោះសទ្ធេយ្យធម៌ ។

ឈ្មោះថា សាត្ថៈ ព្រោះមានសេចក្តីអធិប្បាយជ្រាលជ្រៅ, ឈ្មោះថា សព្យញ្ជនៈ ព្រោះមានបទរាក់ ។

ឈ្មោះថា ដ៏ពេញបរិបូណ៌ទាំងអស់ ព្រោះភាវៈជាធម៌ពេញលេញបរិបូណ៌គ្រប់ទាំងអស់ ព្រោះមិនមានសេចក្តីដែលត្រូវបន្ថែមចូលទៅ ។ ឈ្មោះថា បរិសុទ្ធ ព្រោះភាវៈជាធម៌មិនមានទោស ព្រោះមិនមានសេចក្តីដែលត្រូវនាំយកចេញ ។

ន័យមួយទៀត ឈ្មោះថា សាត្ថៈ ព្រោះឈ្វាសវៃ ក្នុងអធិគមដោយសេចក្តីប្រតិបត្តិ, ឈ្មោះថា សព្យញ្ជនៈ ព្រោះឈ្វាសវៃក្នុងអាគមដោយបរិយត្តិ, ឈ្មោះថា ពេញបរិបូណ៌ទាំងអស់ ព្រោះប្រកបដោយធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម, ឈ្មោះថា បរិសុទ្ធ ព្រោះមិនមានឧបក្កិលេស ព្រោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់ការរលាស់ចេញ

និង ព្រោះមិនមានការជាប់ជំពាក់ ក្នុងលោកាមិស ព្រោះហេតុនោះ ព្រះបរិយត្តិធម៌នោះ ឈ្មោះថា ស្វាក្ខាតធម៌ ព្រោះប្រកាសព្រហ្មចរិយៈព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ពេញលេញបរិបូណ៌ បរិសុទ្ធទាំងអស់ដោយប្រការដូច្នេះឯង ។

មួយទៀត បរិយត្តិធម៌នោះ ឈ្មោះថា ស្វាក្ខាតធម៌ ព្រោះព្រះមានព្រះភាគត្រាស់ហើយដោយល្អ ព្រោះមិនមានការវិបល្លាសចាកសេចក្តីដូចជាសេចក្តីនៃធម៌ របស់ពួកអន្យតិរ្ថិយ រមែងដល់នូវសេចក្តីវិបល្លាស ព្រោះភាវៈនៃធម៌ ដែលលោកពោល ថា “ជាធម៌ធ្វើនូវសេចក្តីអន្តរាយទាំងឡាយ” ដូច្នេះ មិនមានភាពជាធម៌ធ្វើនូវសេចក្តីអន្តរាយឡើយ និងព្រោះភាវៈជាធម៌ ដែលលោកពោល ថា “ជានិយ្យានិកធម៌” ក៏មិនមានភាពជាធម៌នាំចេញចាកទុក្ខដែរ ហេតុនោះ អន្យតិរ្ថិយទាំងឡាយនោះ ឈ្មោះថា ជាអ្នកមានធម៌សំដែងហើយមិនល្អមែនពិត យ៉ាងណាមិញ, សេចក្តីនៃធម៌របស់ព្រះមានព្រះភាគ មិនដល់នូវសេចក្តីវិបល្លាស យ៉ាងដូច្នោះឡើយ ព្រោះធម៌ដែលព្រះអង្គត្រាស់ហើយ យ៉ាងនេះថា “ធម៌ទាំងឡាយនេះ ជាធម៌ធ្វើនូវសេចក្តីអន្តរាយ, ធម៌ទាំងឡាយនេះ ជាធម៌នាំឲ្យចេញចាកទុក្ខ” ដូច្នេះហើយ មិនប្រព្រឹត្តកន្លងនូវភាពយ៉ាងដូច្នោះឡើយ។

ព្រះបរិយត្តិធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ដូចបានពណ៌នាមកនេះឯង ជាដំបូង ។

ចំណែកលោកុត្តរធម៌ ឈ្មោះថា ស្វាក្ខាតធម៌ ព្រោះទ្រង់ត្រាស់សេចក្តីប្រតិបត្តិ ដែលសមគួរដល់ព្រះនិព្វាន និង ព្រោះទ្រង់ត្រាស់ព្រះនិព្វាន ដែលសមគួរដល់សេចក្តីប្រតិបត្តិ ។ ប្រៀបដូចជាសក្កទេវរាជពោលថា “ក៏បដិបទា ជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គ



នោះ ទ្រង់បញ្ញត្តហើយ ដោយប្រពៃ ដល់ព្រះសាវកទាំងឡាយ, ព្រះនិព្វាន និង សេចក្តីប្រតិបត្តិ រមែងប្រៀបធៀបគ្នាបាន ឧបមាដូចជាទឹកក្នុងទន្លេគង្គា រមែងប្រៀបធៀបគ្នាបាន រមែងចូលគ្នាបានជាមួយនឹងទឹកក្នុងទន្លេយមុនា យ៉ាងណាមិញ, ក៏សេចក្តីប្រតិបត្តិ ដែលឲ្យដល់ព្រះនិព្វាន គឺព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តហើយ ដោយប្រពៃ ដល់ព្រះសាវកទាំងឡាយ, ព្រះនិព្វាន និង សេចក្តីប្រតិបត្តិ រមែងប្រៀបធៀបនឹងគ្នាបាន ក៏យ៉ាងដូច្នោះដែរ [១] ” ដូច្នេះ ។

មួយវិញទៀត ក្នុងលោកុត្តរធម៌នោះ អរិយមគ្គ ជាផ្លូវកណ្តាលមិនចូលទៅជិតអន្តធម៌ទាំង ២ យ៉ាងនុ៎ះឯង ឈ្មោះថា ជាធម៌គឺព្រះអង្គទ្រង់ត្រាស់ហើយដោយល្អ ព្រោះអរិយមគ្គនោះ ព្រះអង្គត្រាស់ហើយថា “ជាមជ្ឈិមាបដិបទា” ។ សាមញ្ញផលទាំងឡាយ ដែលមានកិលេសស្ងប់រម្ងាប់ហើយនុ៎ះឯង ឈ្មោះថា ស្វាក្ខាតធម៌ ព្រោះសាមញ្ញផលនោះឯង ព្រះអង្គទ្រង់ត្រាស់ហើយ ថា “ជាធម្មជាត មានកិលេសស្ងប់រម្ងាប់ហើយ” ដូច្នេះ ។ ព្រះនិព្វាន ដែលជាសភាវៈទៀង សភាវៈមិនស្លាប់ សភាវៈជាទីពឹង និង សភាវៈជាទីជ្រកកោនហ្នឹងឯង ឈ្មោះថា ស្វាក្ខាត-ធម៌ ព្រោះព្រះនិព្វាននោះឯង ព្រះអង្គទ្រង់ត្រាស់ហើយ ដោយអំណាចនៃភាវៈជាធម៌ទៀងជាដើម ។ សូម្បីលោកុត្តរធម៌ ក៏ឈ្មោះថា ជាធម៌គឺព្រះអង្គទ្រង់ត្រាស់សំដែងហើយដោយប្រពៃ ដូចបានពោលមកនេះឯង។

ចំណែកសេចក្តីវិនិច្ឆ័យ ក្នុងបទថា “សន្ទិដ្ឋិកោ” នេះ បណ្ឌិតគប្បីជ្រាបដូចតទៅ ។ ជាបឋម អរិយមគ្គ ឈ្មោះថា សន្ទិដ្ឋិកោ ព្រោះជាធម៌ គឺព្រះអរិយបុគ្គល អ្នកធ្វើនូវការមិនមានកិលេស មានរាគៈជាដើម

---

១- សុ. ទី មហា. ភាគទី ១៧ ទំព័រទី ១១០ ។

ក្នុងសន្តានរបស់ខ្លួន គប្បីឃើញដោយខ្លួនឯង ។

សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរ ដែលរាគៈគ្របសង្កត់ហើយ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និង អ្នកដទៃទាំង ២ ខ្លះ រមែងរងទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅ ក្នុងចិត្តខ្លះ, កាលបើលះបង់រាគៈបានហើយ, បុគ្គល រមែងមិនគិត ដើម្បីបៀតបៀនខ្លួនឯងផង មិនគិត ដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និង អ្នកដទៃទាំង២ ផង, រមែងមិនរងទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត, ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង [១] ” ។

ម្យ៉ាងវិញទៀត សូម្បីលោកុត្តរធម៌ទាំង ៩ ក៏ឈ្មោះថា ជាធម៌គឺបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ព្រោះជាធម៌ដែលបុគ្គលណា ៗ បានសម្រេចហើយ, បុគ្គលនោះៗ គប្បីលះបង់នូវភាវៈដែលបុគ្គលគប្បីដល់ដោយសេចក្ដីជឿ របស់បុគ្គលដទៃហើយ ឃើញដោយខ្លួនឯង ដោយបច្ចវេក្ខណញ្ញាណ ។

មួយទៀត ទិដ្ឋិ ដែលព្រះអរិយសរសើរហើយ ឈ្មោះថា សន្ទិដ្ឋិ លោកុត្តរធម៌ រមែងឈ្នះ ដោយសន្ទិដ្ឋិ ព្រោះហេតុនោះ ទើបឈ្មោះថា សន្ទិដ្ឋិកធម៌ ។ ពិតដូច្នោះ ក្នុងលោកុត្តរធម៌នោះ អរិយមគ្គ រមែងឈ្នះនូវកិលេសទាំងឡាយ ដោយសន្ទិដ្ឋិ ដែលសម្បយុត្តហើយ, អរិយផល រមែងឈ្នះនូវកិលេសទាំងឡាយ ដោយសន្ទិដ្ឋិ ដែលជាហេតុ, ព្រះនិព្វាន រមែងឈ្នះនូវកិលេសទាំងឡាយ ដោយសន្ទិដ្ឋិ ដែលជាអារម្មណ៍ របស់

១- សុ. អំ. តិ. ភាគទី ៤១ ទំព័រទី ១៣៦ ។



ខ្លួន ហេតុនោះ លោកុត្តរធម៌ទាំង ៩ យ៉ាង ទើបឈ្មោះថា សន្ទិដ្ឋិកធម៌ ព្រោះឈ្នះ(នូវកិលេស) ដោយសន្ទិដ្ឋិ ប្រៀបដូចជាអ្នកច្បាំង ឈ្មោះថា រថិកៈ ព្រោះឈ្នះដោយរថ យ៉ាងនោះឯង ។

មួយទៀត ការឃើញ ឈ្មោះថា ទិដ្ឋៈ ។ ទិដ្ឋៈហ្នឹងឯង ជាសន្ទិដ្ឋៈ មានសេចក្ដីថា ការឃើញ ។ លោកុត្តរធម៌ រមែងគួរនូវសន្ទិដ្ឋៈ ហេតុនោះ ឈ្មោះថា សន្ទិដ្ឋិកៈ ។ ព្រោះថាលោកុត្តរធម៌ កាលបុគ្គលឃើញដោយអំណាចនៃការនាកិសម័យ និង ដោយអំណាចនៃសច្ឆិកិរិយា-កិសម័យទុំះឯង រមែងញ៉ាំងភ័យគឺវដ្ដៈ ឲ្យវិលត្រឡប់ ព្រោះហេតុនោះ លោកុត្តរធម៌នោះ ទើបឈ្មោះថា សន្ទិដ្ឋិកៈ ព្រោះគួរនូវសន្ទិដ្ឋៈ គឺការឃើញ ប្រៀបដូចជាបុគ្គលដែលឈ្មោះថា វត្ថិកៈ ព្រោះគួរនូវវត្ថៈ (សំពត់) យ៉ាងនោះឯង ។

ធម៌នោះ សំដៅយកនូវការឲ្យផល របស់ខ្លួន មិនមានកាល ហេតុនោះ ធម៌នោះ ទើបឈ្មោះថា អកាលោ (ឲ្យផលរបស់ខ្លួន មិនមានកាល) ។ អកាលោ ហ្នឹងឯង ឈ្មោះថា អកាលិកោ (ឲ្យផលមិនរង់ចាំកាល) ។ អធិប្បាយថា “ធម៌នោះ មិនបានរង់ចាំកាលមានប្រភេទគឺការកំណត់មាន ៥ ថ្ងៃ និង ៧ ថ្ងៃជាដើមហើយ ឲ្យផលឡើយ តែរមែងឲ្យផល ក្នុងលំដាប់ស្មើគ្នា ព្រមទាំងការប្រព្រឹត្តិទៅ របស់ខ្លួនហ្នឹងឯង” ។

មួយទៀត កាល ក្នុងការឲ្យផលរបស់ខ្លួននៃអរិយមគ្គនោះ ចៀសចេញហើយ ដល់ហើយ ហេតុនោះ ទើបឈ្មោះថា កាលិកោ ប្រកបដោយកាល ។ សួរថា “ធម៌នោះ គឺអ្វី?” ។ ឆ្លើយថា “ធម៌នោះ គឺកុសលធម៌ ដែលជាលោកិយៈ” ។ ឯលោកុត្តរធម៌នេះ មិនប្រកបដោយកាល ព្រោះភាវៈជាធម៌មានផលជាលំដាប់ស្មើគ្នា ព្រោះហេតុនោះ ទើប

ឈ្មោះថា អកាលិកោ មិនប្រកបដោយកាល ។ ពាក្យថា “អកាលិកោ” នេះ ព្រះអង្គត្រាស់ហើយសំដៅយកនូវមគ្គតែម្យ៉ាង ។

លោកុត្តរធម៌នោះ គួរនូវឯហិបស្សវិធី ដែលប្រព្រឹត្តទៅ យ៉ាងនេះថា “អ្នកចូរមក! អ្នកចូរមើលនូវធម៌នេះ” ដូច្នេះ ហេតុនោះ លោកុត្តរ-ធម៌នោះ ទើបឈ្មោះថា ឯហិបស្សិកោ (ធម៌គួរនូវឯហិបស្សវិធី) ។ សួរថា “ក៏ព្រោះហេតុអ្វី លោកុត្តរធម៌នោះ ទើបគួរនូវវិធីនោះ?” ។ ឆ្លើយថា “ព្រោះភាវៈនៃលោកុត្តរធម៌នោះ ជាសភាវៈមានផង ព្រោះភាវៈនៃលោកុត្តរធម៌នោះជាសភាវៈបរិសុទ្ធផង ។ មែនពិត អ្នកណាមួយ បើទុកជាពោលថា “ប្រាក់ ឬក៏ មាស មានក្នុងកណ្តាប់ដៃទទេ” ដូច្នេះ ក៏មិនអាចដើម្បីពោលថា “អ្នកចូរមក! អ្នកចូរមើលនូវប្រាក់ ឬ មាសនេះ” ដូច្នេះបានឡើយ។ ព្រោះហេតុអ្វី? ។ ព្រោះភាវៈនៃប្រាក់ ឬ មាសនោះមិនមាន ។ ឯលាមកក្តី ទឹកមូត្រក្តី សូម្បីមាន អ្នកណាក៏មិនអាចដើម្បីពោលថា “អ្នកចូរមក អ្នកចូរមើលនូវលាមក ឬ ទឹកមូត្រនេះ ដើម្បីញុំាងចិត្តឲ្យរីករាយ”ដូច្នេះ ដោយប្រកាសនូវភាវៈនៃលាមក ឬ ទឹកមូត្រនោះថា ជាទីគាប់ចិត្តបានឡើយ។ ឬថា ម្យ៉ាងទៀត លាមកក្តី ទឹកមូត្រក្តី ជារបស់ដែលបុគ្គលត្រូវបិទបាំង ដោយស្មៅទាំងឡាយ ឬ ដោយស្លឹកឈើទាំងឡាយមែនពិត ។ ព្រោះហេតុអ្វី? ។ ព្រោះលាមក និងទឹកមូត្រនោះ ជារបស់មិនស្អាត ។ តែលោកុត្តរធម៌ទាំង ៩ នេះវិញដោយសភាពជាធម៌មានផង ជាធម៌បរិសុទ្ធ ដូចជាមណ្ឌល នៃព្រះច័ន្ទពេញវង់ ពួដ៏អាកាស ដែលមានពពកទៅប្រាសហើយផង ដូចជាកែវមណី អំពីកំណើត ដែលបុគ្គលដាក់លើសំពត់កម្ពល មានពណ៌លឿងផង ព្រោះហេតុនោះ លោកុត្តរធម៌នោះ ទើបឈ្មោះថា ឯហិបស្សិកោ



ព្រោះគួរនូវឯហិបស្សវិធី ព្រោះភាវៈនៃលោកុត្តរធម៌នោះជាសភាវៈមានផង ព្រោះភាវៈនៃលោកុត្តរធម៌នោះ ជាសភាវៈបរិសុទ្ធផង ។

លោកុត្តរធម៌ណា គឺការកបុគ្គល គប្បីនាំចូលទៅជិត ព្រោះហេតុនោះ លោកុត្តរធម៌នោះ ឈ្មោះថា ឱបនយិកោ (លោកុត្តរធម៌ គឺការកបុគ្គលគប្បីនាំចូលទៅជិត) ។ ក៏នេះជាសេចក្តីវិនិច្ឆ័យ ក្នុងបទថា “ឱបនយិកោ” នេះ ។ ការនាំចូលមក ឈ្មោះថា ឧបនយៈ (ការនាំចូលមក) ។ បុគ្គលសូម្បីសំឡឹងមើលនូវសំពត់ក្តី នូវក្បាលក្តី ដែលភ្លើងឆេះសព្វហើយ គួរដើម្បីដល់នូវការបង្អោនចូលមកជិត ក្នុងចិត្តនៃខ្លួនៗ ដោយអំណាចនៃភាវនា ព្រោះហេតុនោះ ទើបឈ្មោះថា ឧបនយិកោ (បុគ្គលគួរបង្អោនចូលមកទុកក្នុងចិត្តនៃខ្លួនៗ ដោយអំណាចនៃភាវនា) ។ លោកុត្តរធម៌ គឺឧបនយិកៈហ្នឹងឯង ឈ្មោះថា ឱបនយិកោ ។ ពាក្យថា “ឱបនយិកោ” នេះ គួរក្នុងលោកុត្តរធម៌ ដែលជាសង្ខតធម៌ ។ ចំណែកក្នុងលោកុត្តរធម៌ដែលជាអសង្ខតធម៌ ធម៌នោះ គួរដើម្បីដល់នូវការនាំចូលមក តាមចិត្តនៃខ្លួន ហេតុនោះ ធម៌នោះ ឈ្មោះថា ឱបនយិកោ (ធម៌គួរនូវការនាំចូលមកតាមចិត្តនៃខ្លួន) អធិប្បាយថា “គួរនូវការជាប់ស្អិតនៅ ដោយអំណាចការធ្វើឲ្យជាក់ច្បាស់”។ មួយទៀត លោកុត្តរធម៌នោះ ញុំាងព្រះអរិយបុគ្គល ឲ្យចូលទៅកាន់ព្រះនិព្វាន ព្រោះហេតុនោះ ធម៌ គឺអរិយមគ្គ ឈ្មោះថា ឱបនេយ្យៈ (ញុំាងព្រះអរិយបុគ្គលឲ្យចូលទៅកាន់ព្រះនិព្វាន) ។ ធម៌ គឺផល និង ព្រះនិព្វាន ឈ្មោះថា ឧបនេយ្យៈ ព្រោះជាធម៌ គឺអរិយបុគ្គលគប្បីនាំចូលទៅកាន់ភាវៈនៃអរិយមគ្គ ដែលខ្លួនគប្បីធ្វើឲ្យជាក់ច្បាស់ ។ ឧបនេយ្យៈ ហ្នឹងឯង ឈ្មោះថា ឱបនយិកោ ។

បទថា "បច្ចត្តំវេទិតព្វោ វិញ្ញូហិ" សេចក្ដីថា (លោកុត្តរធម៌) គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម សូម្បីទាំងពួង គប្បីជ្រាបក្នុងខ្លួនៗថា "មគ្គ គឺអាត្មាអញបានចំរើនហើយ, ផល គឺអាត្មាអញបានត្រាស់ដឹងហើយ, ធម៌ជាគ្រឿងរំលត់ទុក្ខ គឺអាត្មាអញ ធ្វើឲ្យជាក់ច្បាស់ហើយ" ដូច្នេះ ។ ពិតមែនហើយ កិលេសទាំងឡាយ របស់សទ្ធិវិហារិក មិនមែនលះបង់ ដោយមគ្គដែលព្រះឧបជ្ឈាយ៍ចំរើនហើយបានទេ, សទ្ធិ-វិហារិកនោះ នឹងនៅជាសុខសប្បាយ ដោយផលសមាបត្តិ របស់ព្រះឧបជ្ឈាយ៍នោះ ក៏មិនបាន, នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលព្រះឧបជ្ឈាយ៍នោះ ធ្វើឲ្យជាក់ច្បាស់ហើយ ក៏មិនបានដែរ ។ ព្រោះហេតុនោះ ទើបមានពាក្យអធិប្បាយថា "លោកុត្តរធម៌នុ៎ះ មិនមែនគឺបុគ្គលគប្បីឃើញ ដូចជាគ្រឿងអាភរណៈ លើក្បាលនៃជនដទៃទេ, តែថាជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ គប្បីឃើញ គប្បីសោយ ក្នុងចិត្តនៃខ្លួនតែម្យ៉ាង" ។ មែនពិត លោកុត្តរធម៌នោះ មិនមែនជាវិស័យ របស់ពួកជនពាលទេ ។ ន័យមួយទៀត ធម៌នេះ គឺព្រះមានព្រះភាគទ្រង់ប្រាប់ហើយដោយប្រពៃ។ ព្រោះហេតុអ្វី? ។ ព្រោះភាវៈនៃធម៌នោះ គឺព្រះអរិយបុគ្គលឃើញដោយខ្លួនឯង។ លោកុត្តរធម៌នេះ ឈ្មោះថា សន្ទិដ្ឋិកធម៌ ព្រោះភាវៈនៃធម៌នោះ មិនប្រកបដោយកាល ។ លោកុត្តរធម៌នេះ ហៅថា អកាលិកោ (មិនប្រកបដោយកាល) ព្រោះភាវៈនៃធម៌នោះជាធម៌គួរដល់ឯហិបស្សវិធី ។ មួយទៀត ធម៌ណា ឈ្មោះថា គួរដល់ឯហិបស្សវិធី, ធម៌នោះ ឈ្មោះថា គួរដើម្បីបង្អោនចូលមកទុកក្នុងចិត្តនៃខ្លួន ដោយអំណាចនៃភាវនា ។ កាលបើព្រះយោគីនោះ រលឹករឿយៗ នូវគុណនៃព្រះធម៌ទាំងឡាយផ្សេងដោយគុណ មានគុណថា ស្វាក្ខាតៈ ជាដើម ដូចពណ៌នាមកនេះ,



ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះឯង មិនមែនជាចិត្ត គឺរាគៈជិះជាន់បានទេ, មិនមែនជាចិត្ត គឺទោសៈជិះជាន់បានទេ ។ល។ មិនមែនជាចិត្ត គឺមោហៈជិះជាន់បានទេ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តទៅត្រង់ ប្រារព្ធនូវធម៌តែម្យ៉ាង ព្រោះហេតុនោះ អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈជាមួយគ្នា ដល់ព្រះយោគីនោះអ្នកមាននីវរណធម៌ស្ងប់រម្ងាប់ហើយតាមន័យដែលមានហើយ ក្នុងកាលមុននុ៎ះឯង ។ តែឈានមិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះតែងកើត ព្រោះភាវៈនៃធម្មគុណទាំងឡាយ ជាអារម្មណ៍ដ៏ជ្រាលជ្រៅផង ព្រោះភាវៈនៃចិត្តបង្អោនចូលទៅក្នុងការរលឹករឿយៗនូវគុណមានប្រការផ្សេងៗ ផង ។ ឈាននេះនោះ តែងដល់នូវការរាប់ថា "ធម្មានុស្សតិ" ហ្នឹងឯង ព្រោះភាវៈនៃឈាននោះ កើតឡើងហើយ ដោយអំណាចនៃការរលឹករឿយៗ នូវធម្មគុណ ។

(អានិសង្សចំរើនធម្មានុស្សតិ)

ចំណែកឯភិក្ខុប្រកបរឿយៗ នូវធម្មានុស្សតិនេះ ជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែង ក្នុងព្រះសាស្ដា ជាអ្នកធ្វើសេចក្ដីគោរពក្នុងព្រះធម៌ ដោយការរលឹករឿយៗនូវព្រះធម្មគុណ យ៉ាងនេះថា "យើងពិចារណារកមើលនូវគ្រូ ដែលជាអ្នកសំដែងនូវធម៌ គួរបង្អោនចូលមកទុកក្នុងចិត្តបាន យ៉ាងនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានដែរ (១) " ដូច្នេះ រមែងបាននូវភាពធំទូលាយ ដោយគុណមានសទ្ធាជាដើម, ជាអ្នក

---

១- សុ. ទី. មហា. ភាគទី ១៧ ទំព័រទី ១០៩ ។

*ច្រើនដោយបីតិ និង បាមោជ្ជៈ ជាអ្នកអត់សង្កត់នូវភ័យដ៏ពន្លឹក ជាអ្នកអាចអត់សង្កត់នូវសេចក្ដីទុក្ខ រមែងបានចំពោះនូវសេចក្ដីសម្គាល់ ក្នុងការនៅរួមដោយធម៌ ។ ក៏សូម្បីសរីរៈ របស់ព្រះយោគីនោះ ដែលការរលឹករឿយៗនូវធម្មគុណគ្រប់គ្រងហើយ ជាសរីរៈ គួរដល់ការបូជា ដូចជាផ្ទះដែលបុគ្គលគប្បីបូជា, ចិត្ត របស់ព្រះយោគីនោះ រមែងបង្អោនទៅដើម្បីការត្រាស់ដឹងនូវអនុត្តរធម៌, ឯហិរិ និង ឱត្តប្បៈ រមែងតាំងឡើងប្រាកដ ដល់ព្រះយោគីនោះ ដែលរលឹករឿយៗ នូវភាវៈនៃធម៌ជាធម៌ល្អ កាលបើមានការប្រកបព្រម ក្នុងវត្ថុ ដែលបុគ្គលគប្បីប្រព្រឹត្តកន្លង ។ មួយទៀត ព្រះយោគីនោះកាលមិនទាន់ចាក់ធ្លុះចំពោះនូវគុណដ៏ក្រៃលែងទេ គង់បានជាអ្នកមានស្ថានសួគ៌ ប្រព្រឹត្តទៅក្នុងកាលខាងមុខ ។*

ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញាល្អគប្បីធ្វើនូវសេចក្ដី
មិនប្រមាទ ក្នុងធម្មានុស្សតិ ដែលមានអានុភាពច្រើន
យ៉ាងនេះ សព្វ ៗ កាល ។

*នេះជាកថាមុខ ដោយពិស្ដារ ក្នុងធម្មានុស្សតិ ។*

♣ ♣ ♣

(ការចំរើនសង្ឃានុស្សតិ)

*(១៣៦) ឯព្រះយោគីអ្នកមានប្រាថ្នាដើម្បីចំរើនសង្ឃានុស្សតិ គប្បីជាអ្នកទៅក្នុងទីស្ងាត់ ចេញចាកពួកហើយ សម្ងំនៅ ក្នុងកម្មដ្ឋានហើយ រឭករឿយៗ ដល់គុណព្រះអរិយសង្ឃ យ៉ាងដូច្នេះថា* "សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ



សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស" *ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* "សុប្បដិបន្នោ" *ប្រែថា ប្រតិបត្តិហើយដោយប្រពៃ, អធិប្បាយថាៈ ប្រតិបត្តិហើយនូវសេចក្ដីប្រតិបត្តិ ដ៏ត្រឹមត្រូវ ជាសេចក្ដីប្រតិបត្តិមិនត្រឡប់វិញ ជាសេចក្ដីប្រតិបត្តិ ដ៏សមគួរដល់ព្រះនិព្វាន ជាសេចក្ដីប្រតិបត្តិនូវធម៌មិនមែនជាសត្រូវ(ដល់ធម៌ និងបុគ្គល) ជាសេចក្ដីប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។*

*បុគ្គលទាំងឡាយណា ស្ដាប់នូវពាក្យប្រៀនប្រដៅ ដែលជាឱវាទរបស់ព្រះមានព្រះភាគ ដោយគោរព ហេតុនោះ បុគ្គលទាំងឡាយនោះ ឈ្មោះថា* សាវកា *។ ប្រជុំនៃសាវកទាំងឡាយ ឈ្មោះថា* សាវកសង្ឃោ *(ប្រជុំនៃសាវក) ។ អធិប្បាយថា ប្រជុំនៃសាវកដែលដល់ហើយនូវការត្រូវរបៀបគ្នា ព្រោះភាពជាអ្នកស្មើគ្នា ដោយសីល និង ទិដ្ឋិ ។*

*ក៏សម្មាបដិបទានោះ ជាបដិបទាដ៏ត្រង់ គឺមិនវៀច មិនកោង មិនល្អៀង, មួយទៀត បដិបទានោះ លោកហៅថា "ជាធម៌ គឺបុគ្គលគប្បីដឹងដ៏ប្រសើរ" ដូច្នេះក៏បាន, និង រមែងដល់នូវការរាប់ថា "ជាសេចក្ដីកោតក្រែង ព្រោះបដិបទានោះ ជាបដិបទាដ៏សមគួរ" ដូច្នេះផង ក៏បាន ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះអរិយសង្ឃ ដែលប្រតិបត្តិហើយនូវសម្មាបដិបទានោះ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅថា "ប្រតិបត្តិដោយត្រង់ផង ប្រតិបត្តិដ៏សមគួរ ដល់ញាយធម៌ផង ប្រតិបត្តិដ៏សមគួរដល់សាមីចិកម្មផង" ដូច្នេះ ។*

*ក៏ក្នុងបទថា* "សុប្បដិបន្នោ" *ជាដើមនោះ បណ្ឌិត គប្បីជ្រាប ថា*

“ព្រះអរិយបុគ្គលទាំងឡាយណា ជាអ្នកតាំងនៅហើយ ក្នុងមគ្គ, ព្រះអរិយបុគ្គលទាំងឡាយនោះ ឈ្មោះថា ប្រតិបត្តិហើយដោយល្អ ព្រោះភាវៈនៃលោកជាអ្នកព្រមព្រៀងហើយ ដោយសេចក្តីប្រតិបត្តិ ដោយប្រពៃ, ព្រះអរិយបុគ្គលទាំងឡាយណា ជាអ្នកតាំងនៅហើយ ក្នុងផល, ព្រះអរិយបុគ្គលទាំងឡាយនោះ ក៏ឈ្មោះថា ប្រតិបត្តិហើយ ដោយប្រពៃ ព្រោះចូលទៅកាន់យក នូវសេចក្តីប្រតិបត្តិដែលកន្លងទៅហើយ ព្រោះភាវៈនៃលោកទាំងនោះ បានត្រាស់ដឹងហើយ នូវធម៌ដែលបុគ្គលគប្បីត្រាស់ដឹង ដោយសម្មាបដិបទា” ដូច្នេះ ។

ន័យមួយទៀត ព្រះសង្ឃជាសាវ័ក ឈ្មោះថា ប្រតិបត្តិដោយប្រពៃ ព្រោះភាវៈនៃលោកប្រតិបត្តិហើយ តាមសមគួរដល់ពាក្យប្រៀនប្រដៅក៏បាន ព្រោះភាវៈនៃលោកប្រតិបត្តិហើយ នូវសេចក្តីប្រតិបត្តិមិនខុសក៏បាន ក្នុងព្រះធម្មវិន័យ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ, ឈ្មោះថា ប្រតិបត្តិដោយត្រង់ ព្រោះលោកជាអ្នកប្រតិបត្តិដោយមជ្ឈិមាបដិបទា មិនប៉ះពាល់នូវប្រជុំពីរនៃធម៌អមខាងផង ព្រោះលោកជាអ្នកប្រតិបត្តិ ដើម្បីលះបង់នូវទោស គឺសេចក្តីវៀចកោង និងសេចក្តីល្អៀង នៃកាយ, វាចា និង ចិត្ត, ព្រះនិព្វាន ព្រះមានព្រះភាគត្រាស់ហៅថា ជាធម៌គឺបុគ្គលគប្បីដឹង, ព្រះសង្ឃ ជាសាវ័ក ឈ្មោះថា ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រោះភាវៈនៃលោកជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ ដល់ព្រះនិព្វាននោះ, ព្រះសង្ឃ ជាសាវ័ក ឈ្មោះថា ប្រតិបត្តិដ៏សមគួរ ដល់សាមីចិកម្ម ព្រោះភាវៈនៃលោកជាអ្នកប្រតិបត្តិហើយ ដោយប្រការដែលជនទាំងឡាយប្រតិបត្តិហើយ ជាអ្នកសមគួរដល់កម្ម គឺសេចក្តីកោតក្រែង ។



បទថា “យទិទំ” គឺថា យានិ ឥមានិ ប្រែថា នេះឯណា ។ ពាក្យថា “ចត្តារិ បុរិសយុគានិ” សេចក្តីថា ដោយអំណាចនៃគូ នៃបុរស មាន ៤ គូ គឺព្រះអរិយបុគ្គល ដែលឋិតនៅ ក្នុងមគ្គទីមួយ, ព្រះអរិយបុគ្គលអ្នកឋិតនៅ ក្នុងផល, នេះជាគូ ១ យ៉ាងនេះជាដើម ។ ពាក្យថា “អដ្ឋ បុរិសបុគ្គលា” សេចក្តីថា ដោយអំណាចនៃបុរសបុគ្គល មានបុរស-បុគ្គល ៨ ពួកគត់ តាមន័យនេះ គឺព្រះអរិយបុគ្គលដែលឋិតនៅ ក្នុងមគ្គទី១ ជាពួកមួយ, ព្រះអរិយបុគ្គលដែលឋិតនៅ ក្នុងផល (ទី១) ជាពួកមួយដូច្នេះជាដើម ។ ក៏ក្នុងបទថា “អដ្ឋ បុរិសបុគ្គលា” នោះ បទទាំងឡាយនេះថា “បុរស ឬ ឬថា បុគ្គល” ដូច្នេះ ជាបទមានសេចក្តីតែមួយ ។ តែពាក្យថា “បុរសបុគ្គល” នេះ ព្រះអង្គត្រាស់ហើយ ដោយអំណាចនៃសត្វដែលព្រះអង្គគប្បីទូន្មានបាន ។ ពាក្យថា “ឯស ភគវតោ សាវកសង្ឃោ” សេចក្តីថា ដោយអំណាចនៃគូនៃបុរសទាំងឡាយ ៤ គូ, ដោយឡែកពីគ្នា បុរសបុគ្គលទាំងឡាយ ៨ នេះឯណា, ព្រះសង្ឃទាំងនេះ ជាព្រះសង្ឃសាវ័ក នៃព្រះដ៏មានព្រះភាគ ។

បណ្ឌិត គប្បីជ្រាបសេចក្តីវិនិច្ឆ័យ ក្នុងបទទាំងឡាយ មានបទថា “អាហុនេយ្យោ” ដូច្នេះជាដើម(តទៅ) ។ វត្ថុណា ដែលជនទាំងឡាយគប្បីនាំមកហើយបូជា ព្រោះហេតុនោះ វត្ថុនោះ ឈ្មោះថា អាហុនៈ (វត្ថុដែលជនគប្បីនាំមកបូជា), អធិប្បាយថា: វត្ថុដែលជនគប្បីនាំមកសូម្បីអំពីចម្ងាយហើយ ឲ្យចំពោះអ្នកមានសីលទាំងឡាយ ។ ពាក្យថា “អាហុនំ” នេះ ជាឈ្មោះ នៃបច្ច័យទាំងឡាយបួន ។ ព្រះសង្ឃ ជាសាវ័ក គួរដើម្បីទទួល នូវវត្ថុដែលជនទាំងឡាយ គប្បីនាំមកអំពីចម្ងាយ

ហើយបូជានោះ ព្រោះធ្វើនូវវត្ថុដែលជនទាំងឡាយ គប្បីនាំមកនោះ ឲ្យមានផលច្រើន ព្រោះហេតុនោះ ព្រះសង្ឃជាសាវកនោះ ទើបឈ្មោះថា អាហុនេយ្យោ (ជាអ្នកគួរដើម្បីទទួល នូវវត្ថុដែលជនទាំងឡាយ គប្បីនាំមកហើយបូជា) ។

ន័យមួយទៀត សូម្បីសម្បត្តិទាំងអស់ ដែលបុគ្គលមកហើយ អំពីចម្ងាយ គប្បីបូជា ក្នុងសង្ឃជាសាវកនោះ ហេតុនោះ ព្រះសង្ឃសាវកនោះ ទើបឈ្មោះថា អាហវនីយោ (ជាអ្នកគឺបុគ្គលគួរមកហើយបូជា) ។ ឬថា ព្រះសង្ឃសាវកឯណា តែងគួរនូវវត្ថុ គឺជនគប្បីនាំមក សូម្បីរបស់ទេវតាទាំងឡាយមានសក្កទេវរាជជាដើម ហេតុនោះ ព្រះសង្ឃជាសាវកនោះ ទើបឈ្មោះថា អាហវនីយោ (ជាអ្នកគួរនូវវត្ថុដែលជនគប្បីនាំមកបូជា នៃទេវតាមានសក្កទេវរាជ ជាដើម) ។

មួយទៀត ភ្លើងឯណានេះ ដែលមានឈ្មោះថា អាហវនីយៈ របស់ព្រាហ្មណ៍ទាំងឡាយ, លទ្ធិ របស់ពួកព្រាហ្មណ៍ទាំងឡាយនោះថា "វត្ថុដែលព្រាហ្មណ៍បូជាហើយ ចំពោះភ្លើងឯណា ជារបស់មានផលដ៏ច្រើន" ដូច្នេះ, បើភ្លើងនោះ ឈ្មោះថា អាហវនីយៈ ព្រោះភាវៈនៃវត្ថុដែលបុគ្គលបូជាហើយ ជារបស់មានផលច្រើន, ព្រះសង្ឃទុំះឯង ឈ្មោះថា អាហវនីយៈ, ព្រោះថា វត្ថុដែលបុគ្គលបូជាហើយ ក្នុងព្រះសង្ឃ ជារបស់មានផលច្រើន ។

សមដូចជាព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ ថា :

ក៏ជនណាគប្បីបម្រើភ្លើង ក្នុងព្រៃ អស់១០០ ឆ្នាំ, ចំណែកបុគ្គលណា បូជានូវព្រះអរិយបុគ្គលមួយអង្គ ដែលមានខ្លួន



អប់រំហើយ សូម្បីតែមួយរំពេច, ការបូជា របស់បុគ្គលនោះឯង ប្រសើរបំផុត, ការបូជា អស់ ១០០ ឆ្នាំ របស់ជននោះ ពុំប្រសើរឡើយ [១] ។

បទថា "អាហវនីយោ" នេះនោះ ក្នុងនិកាយដទៃ ដោយសេចក្ដីជាបទត្រូវគ្នា ដោយបទនេះ ថា "អាហុនេយ្យោ" ក្នុងពាក្យដែលយើងកំពុងពោលនេះ, តែបើពោលដោយព្យញ្ជនៈ មានសេចក្ដីផ្សេងគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ ក្នុងបទទាំង ២ នេះ ។ ព្រះសង្ឃ ជាសាវក ជាអាហុនេយ្យៈ ដូចបានរៀបរាប់មកនេះឯង ។

ឯក្នុងបទថា "បាហុនេយ្យោ" នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យ (ដូចតទៅនេះ) ។ អាគន្តុកទាន ដែលគេចាត់ចែងហើយ ដោយសក្ការៈ ដើម្បីប្រយោជន៍ដល់ញាតិ និង មិត្តទាំងឡាយជាទីស្រឡាញ់ និង ជាទីគាប់ចិត្ត ដែលមកហើយអំពីទិសធំ និង ទិសតូច លោកហៅថា ទានសំរាប់ទទួលភ្ញៀវ, សូម្បីទានសំរាប់ទទួលភ្ញៀវនោះ ក៏គួរដើម្បីប្រគេនដល់ព្រះសង្ឃទុំះឯង លើកលែងតែញាតិ និង មិត្តដែលជាទីស្រឡាញ់ជាទីគាប់ចិត្តទាំងនោះ និង ភ្ញៀវទាំងឡាយដែលមានសភាពដូច្នោះ, មានតែព្រះសង្ឃទេ ដែលគួរដើម្បីទទួលអាគន្តុកទាននោះ ។ ព្រោះថា ភ្ញៀវប្រាកដស្មើដោយព្រះសង្ឃ មិនមានទេ ។ ពិតដូច្នោះមែន ព្រះសង្ឃទុំះរមែងប្រាកដ ក្នុងចន្លោះនៃព្រះពុទ្ធមួយព្រះអង្គផង និង ជាអ្នកប្រកបព្រម ដោយធម៌ទាំងឡាយ ដែលធ្វើនូវភាពនៃសេចក្ដីស្រឡាញ់ និងសេចក្ដីពេញចិត្ត មិនប្រឡូកប្រឡល់ផង ។ ទានដែលបុគ្គលនាំមក ដើម្បី

---

១- សុ. ខុ. ធ. ភាគទី ៥២ ទំព័រទី ១៤ ។

ញាតិ និង មិត្ត ដែលទើបមកដល់ថ្មី គួរដើម្បីប្រគេន ដល់ព្រះសង្ឃនេះ យ៉ាងនេះ ថែមទាំងព្រះសង្ឃ ក៏គួរដើម្បីនឹងទទួលនូវទានដែលគេនាំមក ដើម្បីភ្ញៀវផង ហេតុនោះ ព្រះសង្ឃនោះ ទើបឈ្មោះថា បាហុនេយ្យោ (ព្រះសង្ឃ) គួរដើម្បីទទួលនូវអាគន្តុកទាន (គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និង មិត្តដែលទើបមកដល់ថ្មី) ។

ចំណែកឯ បាលី ថា "បាហវនីយោ" របស់និកាយទាំងឡាយ ឯណា, បាលី របស់និកាយទាំងឡាយនោះ (សំដែង) ថា "ព្រះសង្ឃ គួរដើម្បីទទួលនូវបុព្វការៈ ព្រោះហេតុណា, ព្រោះហេតុនោះ ទានវត្ថុ ជាដំបូងបង្អស់ គឺបុគ្គលគប្បីនាំមកបូជា ចំពោះព្រះសង្ឃនេះ ហេតុនោះ ព្រះសង្ឃនោះ ឈ្មោះថា បាហវនីយោ (ព្រះសង្ឃ) ជាអ្នកគួរដែលបុគ្គលគប្បីនាំយកនូវរបស់មកបូជា ជាដំបូងបង្អស់ ឬថា ព្រះសង្ឃ គួរនូវការនាំមកបូជា ដោយប្រការទាំងពួង ព្រោះហេតុនោះ ព្រះសង្ឃនោះ ឈ្មោះថា បាហវនីយោ (អ្នកគួរនូវការនាំមកបូជា ដោយប្រការទាំងពួង) ។ សព្ទថា "បាហវនីយោ" នេះនោះ ក្នុងទីនេះ លោកពោលថា "បាហុនេយ្យោ" តាមសេចក្តីនោះវិញ ។

ក៏ទានដែលបុគ្គលជឿនូវបរលោកហើយគប្បីឲ្យ ព្រះមានព្រះភាគ ត្រាស់ថា "ទក្ខិណា" ។ ព្រះសង្ឃ គួរនូវទក្ខិណាទាននោះ ឬថា ព្រះសង្ឃ មានប្រយោជន៍ចំពោះទក្ខិណាទាន ព្រះសង្ឃ ញ៉ាំងទក្ខិណាទាននោះ ឲ្យស្អាតបរិសុទ្ធ ព្រោះភាវៈគឺការធ្វើទក្ខិណាទាននោះ ឲ្យមានផលច្រើន ហេតុណា, ហេតុនោះ ព្រះសង្ឃនោះ ឈ្មោះថា ទក្ខិណេយ្យោ (អ្នកគួរនូវទក្ខិណាទាន ឬ អ្នកមានប្រយោជន៍ដល់ទក្ខិណាទាន) ។

ព្រះសង្ឃ គួរនូវអញ្ជលីកម្ម ដែលមនុស្សលោកទាំងពួងធ្វើដៃទាំង



ពីរ ដាក់លើសិរសា ព្រោះហេតុនោះ ព្រះសង្ឃនោះ ទើបឈ្មោះថា អញ្ជលិករណីយោ (អ្នកគួរនូវការធ្វើអញ្ជលីកម្ម) ។

បទថា "អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស" សេចក្តីថា ព្រះសង្ឃ ជាទីដុះឡើងនៃបុណ្យ របស់សត្វលោក មិនមានទីដទៃប្រាកដស្មើ ។ ដូចជាទីដែលជាទីដុះឡើង នៃស្រូវខ្សាយទាំងឡាយ ឬ នៃស្រូវដំណើបទាំងឡាយ របស់ស្តេចក្តី របស់អាមាត្យក្តី បណ្ឌិត ហៅថា ស្រែ នៃស្រូវខ្សាយរបស់ស្តេច, ថា ស្រែនៃស្រូវដំណើបរបស់ស្តេច យ៉ាងណាមិញ, ព្រះសង្ឃ ជាទីដុះឡើងនៃបុណ្យទាំងឡាយ របស់សត្វលោកទាំងពួង ក៏យ៉ាងនោះដែរ ។ មែនពិត បុណ្យទាំងឡាយ ប្រព្រឹត្តទៅព្រម ដើម្បីប្រយោជន៍ និង សេចក្តីសុខមានប្រការផ្សេងៗ រមែងដុះឡើង ដល់សត្វលោក ព្រោះអាស្រ័យព្រះសង្ឃ, ព្រោះហេតុនោះ ព្រះសង្ឃ ឈ្មោះថា ជាស្រែបុណ្យរបស់សត្វលោករកស្រែបុណ្យដទៃឲ្យក្រៃលែងជាងគ្មាន ។

កាលបើព្រះយោគីនោះ រលឹករឿយៗ នូវគុណនៃព្រះសង្ឃទាំងឡាយ ផ្សេងដោយគុណមានភាវៈជាអ្នកប្រតិបត្តិ ដោយប្រពៃជាដើម ដូចបានពណ៌នាមកនេះឯង, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគី នោះឯង មិនមែនជាចិត្ត គឺរាគៈ ជិះជាន់បានទេ, មិនមែនជាចិត្ត គឺទោសៈ ជិះជាន់បានទេ ។ល។ មិនមែនជាចិត្ត គឺមោហៈជិះជាន់បានទេ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តទៅត្រង់ ប្រារព្ធនូវព្រះសង្ឃ តែម្យ៉ាង ព្រោះហេតុនោះ អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈជាមួយគ្នា ដល់ព្រះយោគីនោះ អ្នកមាននីវរណធម៌ស្ងប់រម្ងាប់ហើយ តាមន័យដែលមានហើយ ក្នុងកាលមុននុ៎ះឯង ។ តែឈាន មិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ ព្រោះភាវៈនៃគុណរបស់ព្រះសង្ឃ

ទាំងឡាយជាអារម្មណ៍ដ៏ជ្រាលជ្រៅផង ព្រោះភាវៈនៃចិត្តបង្អោនចូលទៅក្នុងការរលឹករឿយៗ នូវគុណមានប្រការផ្សេងៗផង ។ ឈាននេះនោះតែងដល់នូវការរាប់ ថា "សង្ឃានុស្សតិ" មែនពិត ព្រោះភាវៈនៃឈានកើតឡើងហើយ ដោយអំណាចនៃការរលឹករឿយៗ នូវសង្ឃគុណ ។

(អានិសង្សចំរើនសង្ឃានុស្សតិ)

ចំណែកឯ ភិក្ខុ អ្នកប្រកបរឿយៗ នូវសង្ឃានុស្សតិនេះ ជាអ្នកមានសេចក្តីគោរព មានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃ រមែងបានសម្រេចនូវភាពដ៏ធំទូលាយ ដោយគុណមានសទ្ធាជាដើម, ជាអ្នកច្រើនដោយបីតិ និង បាមោជ្ជៈ ជាអ្នកអត់សង្កត់នូវភ័យដ៏ពន្លឹក ជាអ្នកអាចអត់សង្កត់នូវសេចក្តីទុក្ខ រមែងបាននូវសេចក្តីសម្គាល់ ក្នុងកិរិយានៅរួមជាមួយនឹងព្រះសង្ឃ ។ ក៏សូម្បីសរីរៈ របស់ព្រះយោគីនោះ ដែលការរលឹករឿយៗ នូវគុណរបស់ព្រះសង្ឃគ្រប់គ្រងហើយ ជាសរីរៈ គួរដល់នូវការបូជា ដូចជារោងនៃឧបោសថ ដែលព្រះសង្ឃប្រជុំគ្នាហើយ, ចិត្តរបស់ព្រះយោគីនោះ រមែងបង្អោនទៅ ក្នុងកិរិយាបានដល់នូវសង្ឃគុណ, ឯហិរិ និង ឱត្តប្បៈ រមែងតាំងឡើងប្រាកដ ដល់ព្រះយោគីនោះ ដែលហាក់ដូចជាឃើញនូវព្រះសង្ឃ ក្នុងទីចំពោះមុខ ក្នុងកាលជាទីចួបប្រទះនូវវត្ថុដែលបុគ្គលគប្បីប្រព្រឹត្តល្មើស ។ មួយទៀត ព្រះយោគីនោះកាលមិនទាន់ចាក់ធ្លុះ ចំពោះនូវគុណដ៏ក្រៃលែងទេ គង់បានជាអ្នកមានស្ថានសួគ៌ប្រព្រឹត្តទៅ ក្នុងកាលខាងមុខ ។

ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តី
មិនប្រមាទ ក្នុងសង្ឃានុស្សតិ ដែលមានអានុភាពច្រើន
យ៉ាងនេះ សព្វ ៗ កាល ។



នេះជាកថាមុខ ដោយពិស្តារ ក្នុងសង្ឃានុស្សតិ ។

♣ ♣ ♣

(ការចំរើនសីលានុស្សតិ)

(១៣៧) ឯព្រះយោគីអ្នកមានប្រាថ្នាដើម្បីចំរើនសីលានុស្សតិ គប្បីជាអ្នកទៅក្នុងទីស្ងាត់ ចេញចាកពួកហើយ សម្ងំនៅ ក្នុងកម្មដ្ឋានហើយរឭករឿយៗ ដល់សីលរបស់ខ្លួន ដោយអំណាចនៃគុណ មានសីលមិនដាច់ជាដើម យ៉ាងនេះថា "ឱហ្ន៎! សីលទាំងឡាយ របស់អញ មិនដាច់, មិនធ្លុះ, មិនពពាល, មិនពព្រុស, ជាសីលរួចខ្លួន, គឺអ្នកប្រាជ្ញសរសើរហើយ, គឺតណ្ហា និង ទិដ្ឋិ មិនបានពាល់ត្រូវហើយ, ជាសីលប្រព្រឹត្តទៅព្រមដើម្បីសមាធិអ្វីម៉្លេះទេ" ។ ឯសីលទាំងឡាយនោះ គ្រហស្ថគប្បីរលឹកសីលរបស់គ្រហស្ថ, បព្វជិត ក៏គប្បីរលឹកសីល របស់បព្វជិត ។ ទោះជាសីលរបស់គ្រហស្ថក្តី សីលរបស់បព្វជិតក្តី ចូរលើកទុកសិនចុះ។ សូម្បីសិក្ខាបទមួយ ក្នុងខាងដើមក្តី ក្នុងខាងចុងក្តី របស់សីលទាំងឡាយណា មិនធ្លាយហើយ, សីលទាំងឡាយនោះ ជាសីលមិនដាច់ ដូចជាសំពត់សាដកដែលដាច់ហើយត្រង់ជាយ ព្រោះហេតុនោះ សីលទាំងនោះទើបឈ្មោះថា សីលមិនដាច់ ។

សូម្បីសិក្ខាបទ ១ ក្នុងទីពាក់កណ្តាល របស់សីលទាំងឡាយណាមិនបែកធ្លាយហើយ, សីលទាំងឡាយនោះ ជាសីលមិនធ្លុះហើយ ដូចជាសំពត់សាដកធ្លុះ ត្រង់ទីពាក់កណ្តាល ព្រោះហេតុនោះ សីលទាំងនោះទើបឈ្មោះថា សីលមិនធ្លុះ ។

សូម្បីសិក្ខាបទ ២ ឬ ៣ តាមលំដាប់ និង លំដាប់ របស់សីលទាំងឡាយណា មិនធ្លាយហើយ, សីលទាំងឡាយនោះ ជាសីលមិន

ពពាល ដូចមេគោដែលមានសម្បុរនៃសរីរៈ មានសម្បុរខ្មៅ និង សម្បុរក្រហមជាដើម សម្បុរណាមួយ ដោយសម្បុរផ្សេងគ្នា មានសណ្ឋានវែង និង មូលជាដើម ដែលតាំងឡើង ត្រង់ខ្នងក្តី ត្រង់ពោះក្តី ព្រោះហេតុនោះ សីលទាំងនោះ ទើបឈ្មោះថា ជាសីលមិនពពាល ។

សីលទាំងឡាយណា មិនធ្លាយហើយ ក្នុងចន្លោះៗ, សីលទាំងឡាយនោះ ឈ្មោះថា ជាសីលមិនពព្រុស ដូចមេគោដែលវិចិត្រហើយ ដោយកំណត់មានចំណែកស្មើប្រាស ព្រោះហេតុនោះ សីលទាំងនោះ ទើបឈ្មោះថា ជាសីលមិនពព្រុស ។

មួយទៀត ដោយអត្ថ ដែលមិនប្លែកគ្នា សីលទាំងអស់ហ្នឹងឯង ឈ្មោះថា សីលមិនដាច់, មិនធ្លុះ, មិនពពាល, មិនពព្រុស ព្រោះភាវៈនៃសីលនោះជាគុណជាត គឺមេថុនសំយោគ ៧ ប្រការ និងបាបធម៌ទាំងឡាយមានកោធៈ និង ឧបនាហៈជាដើម មិនចូលទៅបៀតបៀនហើយ ។

សីលទាំងនោះឯង ហៅថា សីលរួចខ្លួន ព្រោះរួចផុតចាកភាពនៃខ្លួនជាខ្ញុំនៃតណ្ហា ហើយធ្វើនូវភាពជាសីលរួចខ្លួន ។

សីលទាំងនោះ ឈ្មោះថា គឺអ្នកប្រាជ្ញសរសើរហើយ ព្រោះភាវៈនៃសីលនោះ គឺអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ទ្រង់បានត្រាស់សរសើរហើយ ។

សីលទាំងនោះឯង ហៅថា សីលមិនប៉ះពាល់ ព្រោះភាវៈនៃសីលនោះ គឺតណ្ហា និង ទិដ្ឋិ ប៉ះពាល់មិនបានហើយ ឬថា ព្រោះភាវៈនៃសីលនោះ គឺអ្នកណាមួយ មិនអាចដើម្បីពាល់ត្រូវ យ៉ាងនេះថា “នេះជាទោសក្នុងសីលទាំងឡាយរបស់អ្នក” ដូច្នេះ ។

សីលទាំងនោះឯង ឈ្មោះថា ជាសីលប្រព្រឹត្តទៅព្រម ដើម្បី



សមាធិ ព្រោះញ៉ាំងឧបចារសមាធិ ឬ អប្បនាសមាធិឲ្យប្រព្រឹត្តទៅព្រម ពុំនោះសោត ញ៉ាំងមគ្គសមាធិទាំងផលសមាធិផងឲ្យប្រព្រឹត្តទៅព្រម ។

កាលបើព្រះយោគីនោះ រលឹករឿយៗ នូវសីលទាំងឡាយ របស់ខ្លួន ដោយអំណាចនៃគុណ មានភាវៈនៃសីលមិនដាច់ជាដើម ដូចបានពណ៌នាមកនេះឯង, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះឯង មិនមែនជាចិត្ត គឺរាគៈជិះជាន់បានទេ, មិនមែនជាចិត្ត គឺទោសៈ ជិះជាន់បានទេ ។ល។ មិនមែនជាចិត្ត គឺមោហៈ ជិះជាន់បានទេ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តទៅត្រង់ ប្រារព្ធនូវសីលតែម្យ៉ាង ព្រោះហេតុនោះ អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈជាមួយគ្នា ដល់ព្រះយោគីនោះ អ្នកមាននីវរណធម៌ស្ងប់រម្ងាប់ហើយ តាមន័យដែលមានហើយ ក្នុងកាលមុននុ៎ះឯង ។ តែឈាន មិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ តែងកើត ព្រោះភាវៈនៃគុណ របស់សីលទាំងឡាយជាអារម្មណ៍ដ៏ជ្រាលជ្រៅផង ព្រោះភាវៈនៃចិត្តបង្អោនចូលទៅ ក្នុងការរលឹករឿយៗ នូវគុណមានប្រការផ្សេងៗផង ។ ឈាននេះនោះ តែងដល់នូវការរាប់ ថា “សីលានុស្សតិ” មែនពិត ព្រោះភាវៈនៃឈាននោះ កើតឡើងហើយ ដោយអំណាចការរឭករឿយៗ នូវសីលគុណ ។

### (អានិសង្សចំរើនសីលានុស្សតិ)

ចំណែក ភិក្ខុ អ្នកប្រកបរឿយៗ នូវសីលានុស្សតិនេះ ជាអ្នកមានសេចក្តីគោរព ក្នុងសិក្ខា ជាអ្នកមានសេចក្តីប្រព្រឹត្តិ ដោយចំណែកដ៏ស្មើ មិនប្រមាទ ក្នុងបដិសណ្ឋារៈ ប្រាសហើយចាកភ័យ មានភ័យអំពីកិរិយាតិះដៀលខ្លួនបានជាដើម មានកិរិយាឃើញនូវភ័យជាប្រក្រតី ក្នុងទោសទាំងឡាយមានប្រមាណតូច រមែងបាននូវភាពទូលាយ ដោយគុណមាន

សទ្ធាជាដើម ជាអ្នកច្រើនដោយបីតិ និង បាមោជ្ជៈ ។ មួយទៀត ព្រះយោគីនោះ បើទុកជាមិនទាន់ចាក់ធ្លុះនូវគុណដ៏ក្រៃលែងទេ ក៏គង់បានជាអ្នកមានសុគតិប្រព្រឹត្តទៅ ក្នុងកាលខាងមុខដែរ ។

ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តី
មិនប្រមាទ ក្នុងសីលានុស្សតិ ដែលមានអានុភាពច្រើន
យ៉ាងនេះ សព្វ ៗ កាល ។

*នេះជាកថាមុខ ដោយពិស្តារ ក្នុងសីលានុស្សតិ ។*

(ការចំរើនចាគានុស្សតិ)

*(១៣៨) ព្រះយោគី អ្នកមានប្រាថ្នាចំរើនចាគានុស្សតិ គប្បីជាអ្នកមានចិត្តបង្អោនចូលទៅ ក្នុងចាគៈ តាមប្រក្រតី គប្បីជាអ្នកមានការចែកចំណែកទានឲ្យប្រព្រឹត្តទៅ អស់កាលជានិច្ច, មួយវិញទៀត ព្រះយោគីកាលប្រារព្ធនូវការចំរើន ត្រូវធ្វើការសមាទាន ថា "ឥឡូវនេះ ចាប់ផ្តើមអំពីថ្ងៃនេះតទៅ កាលបើមានបដិគាហកៈ, អាត្មាអញ បើមិនទាន់ឲ្យនូវទានទេ ដោយហោចទៅ សូម្បីត្រឹមតែមួយពំនូត នឹងមិនបរិភោគឡើយ" ដូច្នេះហើយឲ្យទាន តាមសមគួរដល់ស្មារតី តាមសមគួរដល់កម្លាំង ក្នុងបដិគាហកៈទាំងឡាយ ដ៏ប្រសើរវិសេសដោយគុណ ក្នុងថ្ងៃនោះ ហើយកាន់យកនិមិត្ត ក្នុងទាននោះ ទៅក្នុងទីស្ងាត់ បេញចាកពួកហើយ សម្ងំនៅ ក្នុងកម្មដ្ឋានហើយ គប្បីរលឹករឿយៗ ដល់ចាគៈ របស់ខ្លួន ដោយអំណាចនៃគុណមានការៈ នៃមន្ទិល និង សេចក្តីកំណាញ់ជាដើម ទៅប្រាសហើយ យ៉ាងនេះថា "ឱហ្ន៎! ជាលាភទាំងឡាយ របស់អាត្មាអញ,*



*សាសនា និង ភាពនៃខ្លួនជាមនុស្សនេះ គឺអញបានហើយ ដោយល្អហ្ន៎!, អាត្មាអញ មានចិត្តប្រាសចាកសេចក្តីកំណាញ់ ដែលជាតួមន្ទិលហើយ ក្នុងពួកសត្វដែលមានមន្ទិល គឺសេចក្តីកំណាញ់រួបរឹតហើយ ជាអ្នកមានការលះបង់រួចស្រឡះហើយ មានបាតដៃលាងរួចហើយ ត្រេកអរហើយ ក្នុងការលះ គួរដល់ការសូម ត្រេកអរក្នុងការឲ្យ និង ការចំណែកហើយនៅ" ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា* "លាភា វត មេ" *នោះ គឺ* មយ្ហំ វត លាភា *ឱហ្ន៎! លាភទាំងឡាយរបស់អញ ។ អធិប្បាយថា "លាភទាំងឡាយនេះឯណា របស់ទាយក គឺព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរហើយ ដោយន័យទាំងឡាយមានន័យជាអាទិ៍ យ៉ាងនេះ ថា "ចំណែកឯទាយកនោះ លុះឲ្យអាយុហើយ ជាអ្នកមានចំណែកនៃអាយុ ដែលជាទិព្វខ្លះ ជារបស់នៃមនុស្សខ្លះ [១] " ដូច្នេះជាដើមផង, ថា "ទាយក អ្នកឲ្យ(ទាន) រមែងជាទីស្រឡាញ់, ជនទាំងឡាយដ៏ច្រើន រមែងគប់រកនូវទាយកនោះ [២] " ដូច្នេះជាដើមផង, ថា "ទាយក កាលធ្វើដំណើរទៅតាមធម៌ របស់ពួកសប្បុរស ឲ្យ(ទាន) រមែងជាទីស្រឡាញ់ [៣] " ដូច្នេះផង, លាភទាំងឡាយនោះ ជាចំណែក របស់អាត្មាអញ ដោយពិតប្រាកដ" ដូច្នេះ ។*

*ពាក្យថា* "សុលទ្ធំ វត មេ" *សេចក្តីថា សាសនា នេះឯណា ឬភាពជាមនុស្ស នេះឯណា ដែលអញបានហើយ, សាសនា និង ភាពជាមនុស្សនោះ គឺអញបានហើយដោយល្អណាស់ហ្ន៎ ។ ព្រោះហេតុអ្វី? ។ ព្រោះកាលបើពួកសត្វ ត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹតហើយ, អាត្មា*

*១- សុ អំ. ភាគ ៤៤ ទំព័រ ៨២ ។ ២- ភាគ ៤៤ ទំព័រ ៧៨ ។ ៣- ទំព័រ ៨១ ។*

អញ ជាអ្នកមានចិត្តប្រាសចាកអំពីមន្ទិល គឺសេចក្តីកំណាញ់ ។ល។ ត្រេកអរហើយ ក្នុងការឲ្យ និង ការចែករំលែក ។

បណ្តាបទទាំងនោះ បទថា "មច្ឆេរមលបរិយុដ្ឋិតាយ" មានសេចក្តីថា ត្រូវមន្ទិលគឺសេចក្តីកំណាញ់គ្របសង្កត់ហើយ ។ បទថា "បជាយ" សេចក្តីថា សត្វទាំងឡាយ លោកហៅថា "បជា" ដោយអំណាចនៃការកើត, ព្រោះហេតុនោះ ក្នុងបទថា "បជាយ" នេះ ទើបមានសេចក្តីអធិប្បាយនេះថា "កាលបើសត្វទាំងឡាយដែលមន្ទិលគឺសេចក្តីកំណាញ់ ដែលមានការមិនអត់ធន់នូវភាវៈនៃសម្បត្តិទាំងឡាយ របស់ខ្លួន ជាទូទៅដល់ជនទាំងឡាយដទៃ ជាលក្ខណៈ គឺធម៌ខ្មៅទាំងឡាយ ដែលជាគ្រឿងប្រទូស្តនូវភាវៈនៃចិត្ត ជាដែនផ្សាយចេញនូវពន្លឺ ឯណាមួយ គ្របសង្កត់ហើយ" ដូច្នេះ ។

បទថា "វិគតមលមច្ឆេរេន" សេចក្តីថា ឈ្មោះថា មានមន្ទិល និង សេចក្តីកំណាញ់ ទៅប្រាសហើយ ព្រោះភាវៈនៃមន្ទិលទាំងឡាយ សូម្បីដទៃ មានមន្ទិលគឺរាគៈ និង ទោសៈជាដើម ទៅប្រាសហើយផង ព្រោះភាវៈនៃសេចក្តីកំណាញ់ ទៅប្រាសហើយផង ។ បទថា "ចេតសា វិហរាមិ" សេចក្តីថា អាត្មាអញជាអ្នកមានចិត្ត មានប្រការដូចបានពោលមកហើយនៅ ។ ចំណែកក្នុងព្រះសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "អាត្មាអញ នៅគ្រប់គ្រងផ្ទះ [១] " ព្រោះភាវៈនៃពាក្យនោះ កាលបើសក្យព្រះមហានាម ដែលជាព្រះសោតាបន្ន ទូលសួរនូវធម៌ជាគ្រឿងនៅដោយនិស្ស័យ ក៏ទ្រង់សំដែងហើយ ដោយអំណាចនៃធម៌ជាគ្រឿងនៅដោយនិស្ស័យនុ៎ះឯង ។ សេចក្តីក្នុងបទ ថា "អាត្មាអញ នៅគ្រប់គ្រង

១- សុ. អំ. ឆ. ភាគទី ៤៦ ទំព័រទី ១៦ ។



ផ្ទះ" នោះ គឺអាត្មាអញ គ្របសង្កត់នៅហើយ ។

បទថា "មុត្តចាគោ" ប្រែថា មានការលះ រួចស្រឡះហើយ ។ បទថា "បយតបាណិ" ប្រែថា មានដៃលាងហើយ ។ មានសេចក្តីអធិប្បាយថា មានដៃលាងស្អាតហើយហ្នឹងឯង សព្វៗ កាល ដើម្បីឲ្យនូវទេយ្យធម៌ ដោយដៃខ្លួនឯង ដោយសេចក្តីគោរព ។

បទថា "វោស្សគ្គរតោ" សេចក្តីថា ការលះបង់ឈ្មោះថា វោស្សគ្គៈ អធិប្បាយថា បរិច្ចាគ ។ បុគ្គលត្រេកអរហើយ ក្នុងកិរិយាលះបង់នោះ ដោយអំណាចនៃការប្រកបក្រៃលែងទៀងទាត់ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា អ្នកត្រេកអរ ក្នុងការលះ ។

បទថា "យាចយោគោ" អធិប្បាយថា ជាអ្នកគួរ ដល់ការសូម ព្រោះបុគ្គលទាំងឡាយដទៃសូមវត្ថុណាៗ ក៏ឲ្យនូវវត្ថុនោះៗ ។ បាលីថា "យាជយោគោ" ដូច្នេះក៏មាន ។ អធិប្បាយថា អ្នកប្រកបហើយ ដោយយាជៈ ពោលគឺការបូជា ។

បទថា "ទានសំវិភាគរតោ" ប្រែថា ត្រេកអរហើយ ក្នុងការឲ្យផង ក្នុងការចែករំលែកផង ។ អធិប្បាយថា ព្រះយោគី រមែងរលឹករឿយៗ យ៉ាងនេះថា "មែនពិត អាត្មាអញ ឲ្យទានផង, ធ្វើនូវការចែករំលែកអំពីវត្ថុ ដែលខ្លួនគប្បីបរិភោគផង, ថែមទាំងត្រេកអរហើយ ក្នុងការឲ្យ និង ការចែករំលែកទាំង ២ យ៉ាងនេះផង" ។

កាលព្រះយោគីនោះ រលឹករឿយៗ នូវចាគៈ របស់ខ្លួន ដោយអំណាចនៃគុណ មានភាពជាអ្នកមានមន្ទិលគឺសេចក្តីកំណាញ់ ទៅប្រាសហើយជាដើមយ៉ាងនេះ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះឯង មិនមែនជាចិត្ត គឺរាគៈជិះជាន់បានទេ, មិនមែនជាចិត្ត គឺទោសៈជិះជាន់

បានទេ ។ល។ មិនមែនជាចិត្ត គឺមោហៈ ជិះជាន់បានទេ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តទៅត្រង់ ប្រារព្ធនូវចាគៈតែម្យ៉ាង ព្រោះហេតុនោះ អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈជាមួយគ្នា ដល់ព្រះយោគីនោះ អ្នកមាននីវរណធម៌ស្ងប់រម្ងាប់ហើយ តាមន័យដែលមានហើយ ក្នុងកាលមុនទុំះឯង ។ តែឈាន មិនដល់នូវអប្បនាដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ តែងកើត ព្រោះភាវៈនៃចាគគុណទាំងឡាយជាអារម្មណ៍ដ៏ជ្រាលជ្រៅផង ព្រោះភាវៈនៃចិត្តបង្អោនចូលទៅ ក្នុងការរលឹករឿយៗ នូវចាគគុណមានប្រការផ្សេងៗផង ។ ឈាននេះនោះតែងដល់នូវការរាប់ ថា "ចាគានុស្សតិ" មែនពិត ព្រោះភាវៈនៃឈាននោះ កើតឡើងហើយ ដោយអំណាចនៃការរលឹករឿយៗនូវចាគគុណ ។

(អានិសង្សចំរើនចាគានុស្សតិ)

ចំណែកឯ ភិក្ខុ អ្នកប្រកបរឿយៗ នូវចាគានុស្សតិនេះ ជាអ្នកមានចិត្តបង្អោនទៅហើយកាន់ចាគៈ ដោយប្រមាណដ៏ក្រៃលែង ជាអ្នកមានអជ្ឈាស្រ័យ មិនប្រកបដោយលោភៈ ជាអ្នកធ្វើសមគួរដល់មេត្តា ជាប្រក្រតី ជាអ្នកក្លៀវក្លា ជាអ្នកច្រើនទៅដោយបីតិ និង បាមោជ្ជៈ ។ មួយទៀត ព្រះយោគីនោះ កាលមិនទាន់បានចាក់ធ្លុះចំពោះនូវគុណ ដ៏ក្រៃលែងទេ ក៏គង់បានជាអ្នកមានសុគតិប្រព្រឹត្តទៅ ក្នុងកាលខាងមុខ ។

ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តី
មិនប្រមាទ ក្នុងចាគានុស្សតិ ដែលមានអានុភាពច្រើន
យ៉ាងនេះ សព្វៗ កាល ។

នេះជាកថាមុខដោយពិស្តារ ក្នុងចាគានុស្សតិ ។



(ការចំរើនទេវតានុស្សតិ)

(១៣៩) ចំណែកព្រះយោគីអ្នកមានប្រាថ្នាចំរើនទេវតានុស្សតិ គប្បីជាអ្នកប្រកបហើយ ដោយគុណទាំងឡាយមានសទ្ធាជាដើម ដែលដល់ព្រមហើយ ដោយអំណាចនៃអរិយមគ្គ ។ បន្ទាប់អំពីនោះ ព្រះយោគីនោះ គប្បីទៅក្នុងទីស្ងាត់ គេចចេញអំពីពួកហើយ សម្ងំនៅ ក្នុងកម្មដ្ឋានហើយ តាំងទុកនូវទេវតាទាំងឡាយ ក្នុងទីដែលជាបន្ទាល់ហើយ រលឹករឿយៗ ដល់គុណទាំងឡាយ មានសទ្ធាជាដើម របស់ខ្លួន យ៉ាងនេះថា "ពួកទេវតាជាន់ចាតុម្មហារាជិកា ក៏មាន, ពួកទេវតាទាំងឡាយជាន់តាវត្តិង្សក៏មាន, ជាន់យាមា, ជាន់តុសិត, ជាន់និម្មានរតី, ជាន់បរនិម្មិត្ត-វសវត្តី ក៏មាន, ពួកទេវតាដែលរាប់បញ្ចូល ក្នុងពួកព្រហ្ម ក៏មាន, ពួកទេវតាទាំងឡាយជាន់ខ្ពស់ឡើងទៅទៀត ជាងពួកទេវតាជាន់ព្រហ្ម-កាយិកានោះ ក៏មាន, ទេវតាទាំងអម្បាលនោះ ប្រកបព្រមដោយសទ្ធាមានសភាពបែបណា, ទេវតាទាំងអម្បាលនោះ ច្យុត ចាកអត្តភាពនេះហើយ ទើបបានទៅកើត ក្នុងជាន់ទាំងឡាយ មានជាន់ចាតុម្មហារាជិកាជាដើមនោះ, សទ្ធា ដែលមានសភាពបែបនោះ របស់អាត្មាអញ ក៏មានផងដែរ, ពួកទេវតាទាំងឡាយនោះ ប្រកបព្រមហើយដោយសីល មានសភាពបែបណា, ដោយសុតៈ មានសភាពបែបណា, ដោយចាគៈ មានសភាពបែបណា, ដោយបញ្ញា មានសភាពបែបណា, ច្យុតហើយ ចាកអត្តភាពនេះ ទើបបានទៅកើត ក្នុងភពនោះៗ, បញ្ញា ដែលមានសភាពបែបនោះ របស់អាត្មាអញ ក៏មានផងដែរ [១] " ដូច្នេះ ។ តែក្នុងព្រះសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ ថា "ម្នាលមហានាម ក្នុងសម័យណា ព្រះអរិយសាវករលឹក [២] រឿយៗ នូវសទ្ធាផង, សីលផង, សុតៈផង,

១- សុ. អំ. ភាគទី ៤១ ទំព័រ ២៧៣ ។ ២- សុ. អំ. ភាគទី ៤៦ ទំព័រទី ១៨ ។

ចាគៈផង, បញ្ញាផង របស់ខ្លួន និង របស់ទេវតាទាំងឡាយ, ក្នុងសម័យនោះ ចិត្ត របស់ព្រះអរិយសាវកនោះឯង មិនមែនជាចិត្ត ដែលត្រូវរាគៈរួបរឹតបានទេ...” ដូច្នេះជាដើម ។

ព្រះពុទ្ធដីកានុ៎ះ គឺព្រះអង្គត្រាស់ហើយ ក៏ពិតមែន ។ ក៏ប៉ុន្តែថា បណ្ឌិត គប្បីជ្រាបថា “ពាក្យនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ដើម្បីទ្រង់សំដែងគុណ របស់ទេវតាទាំងឡាយ ដែលគប្បីទុក ក្នុងទីជាបន្ទាល់ស្មើគ្នា ដោយគុណទាំងឡាយមានសទ្ធាជាដើមរបស់ខ្លួន” ដូច្នេះ។

ព្រោះថា ក្នុងអដ្ឋកថា ព្រះអដ្ឋកថាចារ្យ ពោលហើយធ្វើឲ្យមាំ ថា “ព្រះយោគី តាំងទុកនូវទេវតាទាំងឡាយ ក្នុងទីជាសាក្សីហើយ រលឹករឿយៗ នូវគុណទាំងឡាយរបស់ខ្លួន” ដូច្នេះ ។

ព្រោះហេតុនោះ កាលបើព្រះយោគីនោះ សូម្បីរលឹករឿយៗ នូវគុណទាំងឡាយនៃពួកទេវតា ក្នុងចំណែកខាងដើមហើយ រលឹករឿយៗ នូវគុណទាំងឡាយ មានសទ្ធាជាដើម របស់ខ្លួន ដែលមាន ក្នុងកាលជាខាងក្រោយ, ក៏ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះឯង មិនមែនជាចិត្ត គឺរាគៈ ជិះជាន់បានទេ, មិនមែនជាចិត្ត គឺទោសៈ ជិះជាន់បានទេ ។ល។ មិនមែនជាចិត្ត គឺមោហៈជិះជាន់បានទេ, ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះ ជាចិត្តទៅត្រង់ ប្រារព្ធនូវទេវតាតែម្យ៉ាង ព្រោះហេតុនោះ អង្គឈានទាំងឡាយ រមែងកើតឡើង ក្នុងខណៈជាមួយគ្នា ដល់ព្រះយោគីនោះ អ្នកមាននីវរណធម៌ស្ងប់ហើយ តាមន័យដែលមានហើយ ក្នុងកាលមុននុ៎ះឯង ។ តែឈាន មិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ រមែងកើត ព្រោះភាវៈនៃគុណទាំងឡាយ មានសទ្ធាជាដើម ជាអារម្មណ៍ដ៏ជ្រាលជ្រៅផង ព្រោះភាវៈនៃចិត្តបង្អោនចូលទៅ



ក្នុងការរលឹករឿយៗ នូវគុណមានប្រការផ្សេងៗផង ។ ឈាននេះនោះ តែងដល់នូវការរាប់ថា “ទេវតានុស្សតិ” មែនពិត ព្រោះភាវៈនៃឈាននោះ កើតឡើងហើយ ដោយអំណាចនៃកិរិយារលឹករឿយៗ នូវគុណមានសទ្ធាជាដើម ដែលស្មើដោយគុណ របស់ពួកទេវតា ។

(អានិសង្សចំរើនទេវតានុស្សតិ)

ចំណែក ភិក្ខុ អ្នកប្រកបរឿយៗ នូវទេវតានុស្សតិនេះ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតាទាំងឡាយ រមែងបាននូវភាពដ៏ទូលាយដោយគុណមានសទ្ធាជាដើម ដោយប្រមាណដ៏ក្រៃលែង ជាអ្នកច្រើនដោយបីតិ និង បាមោជ្ជៈនៅ ។ មួយទៀត ព្រះយោគីនោះ កាលមិនទាន់បានចាក់ធ្លុះចំពោះនូវគុណដ៏ក្រៃលែងទេ ក៏គង់បានជាអ្នកមានសុគតិប្រព្រឹត្តទៅ ក្នុងកាលខាងមុខ ។

ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញាល្អ គប្បីធ្វើនូវសេចក្តី
មិនប្រមាទ ក្នុងទេវតានុស្សតិ ដែលមានអានុភាពច្រើន
យ៉ាងនេះ សព្វ ៗ កាល ។

នេះជាកថាមុខ ដោយពិស្តារ ក្នុងទេវតានុស្សតិ ។

(១៤០) ក៏ព្រះពុទ្ធវចនៈឯណា ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះពុទ្ធដីកាទាំងឡាយ មានជាអាទិ៍ថា “ក្នុងសម័យនោះ ចិត្ត របស់ព្រះយោគីនោះឯង ជាចិត្តទៅត្រង់ ប្រារព្ធព្រះតថាគត” ដូច្នេះ ដើម្បីសំដែងនូវអនុស្សតិទាំង ៦ នោះ ឲ្យបានពិស្តារហើយ ទ្រង់ត្រាស់ថា “ម្នាលមហានាម ! ក៏អរិយសាវក អ្នកមានចិត្តទៅត្រង់ហើយហ្នឹងឯង

រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវបាមោជ្ជៈដែលប្រកបហើយដោយធម៌, បីតិ រមែងកើតដល់អរិយសាវកនោះ អ្នកមានចិត្តត្រេកអរទូទៅហើយ” ដូច្នេះ, ក្នុងព្រះពុទ្ធវចនៈទាំងនោះ បណ្ឌិតគប្បីជ្រាប ថា “ព្រះពុទ្ធវចនៈថា: ព្រះអរិយសាវក បាននូវការដឹងនូវអត្ថ” ដូច្នេះ ព្រះអង្គត្រាស់ហើយ សំដៅយកសេចក្ដីត្រេកអរ ដែលកើតឡើងហើយ ព្រោះអាស្រ័យនូវអត្ថ នៃពុទ្ធគុណទាំងឡាយថា “ឥតិបិ សោ ភគវា” ដូច្នេះជាដើម, ព្រះពុទ្ធវចនៈ ថា “ព្រះអរិយសាវក បាននូវការដឹងនូវធម៌” ដូច្នេះ ព្រះអង្គត្រាស់ហើយសំដៅយកសេចក្ដីត្រេកអរដែលកើតឡើងហើយ ព្រោះអាស្រ័យនូវបាលី, ព្រះពុទ្ធវចនៈថា “ព្រះអរិយសាវក រមែងបាននូវបាមោជ្ជៈ ដែលប្រកបហើយដោយធម៌” ដូច្នេះ ទ្រង់ត្រាស់ហើយ ដោយអំណាចសេចក្ដីត្រេកអរទាំង ២ យ៉ាង” ។

ចំណែកព្រះពុទ្ធដីកា ឯណា ដែលព្រះអង្គទ្រង់ត្រាស់ហើយ ក្នុងទេវតានុស្សតិ ថា “ប្រារព្ធនូវទេវតាទាំងឡាយ” ដូច្នេះ, ព្រះពុទ្ធដីកានោះ បណ្ឌិតគប្បីជ្រាបថា “គឺព្រះអង្គត្រាស់ហើយ ដោយអំណាចនៃចិត្តដែលប្រារព្ធនូវទេវតាទាំងឡាយហើយ ប្រព្រឹត្តទៅ ឬ ដោយអំណាចនៃចិត្តដែលប្រារព្ធគុណទាំងឡាយ ដែលញ៉ាំងភាវៈនៃសត្វជាទេវតា ឲ្យសំរេចប្រាកដស្មើដោយគុណនៃទេវតាហើយប្រព្រឹត្តទៅ ក្នុងកាលខាងដើម” ។

ក៏អនុស្សតិទាំង ៦ នេះ រមែងសំរេច ដល់អរិយសាវកទាំងឡាយតែម្យ៉ាង ។ ព្រោះថា គុណ របស់ព្រះពុទ្ធ, ព្រះធម៌ និង ព្រះសង្ឃទាំងឡាយ ជាគុណប្រាកដច្បាស់ ដល់អរិយសាវកទាំងឡាយនោះ ។ ទាំងអរិយសាវកទាំងនោះ ក៏ប្រកបព្រមហើយ ដោយសីលទាំងឡាយ មានគុណមានភាវៈ នៃសីលមិនដាច់ជាដើម ដោយចាគៈ ដែលមានមន្ទិល



និង សេចក្ដីកំណាញ់ ទៅប្រាសហើយ និង ដោយគុណទាំងឡាយ មានសទ្ធាជាដើម ដែលប្រាកដស្មើ ដោយគុណនៃទេវតាទាំងឡាយដែលមានអានុភាពច្រើនផង ។

ក៏ក្នុងមហានាមសូត្រ ព្រះមានព្រះភាគ ដែលសក្យៈមហានាមទូលសួរនូវធម៌ជាគ្រឿងនៅ ដោយនិស្ស័យ នៃព្រះសោតាបន្ន ទ្រង់សំដែងអនុស្សតិទាំង ៦ នេះ ដោយពិស្ដារ ដើម្បីទ្រង់ពន្យល់នូវធម៌ជាគ្រឿងនៅនៃព្រះសោតាបន្នបុគ្គលហ្នឹងឯង ។

សូម្បីក្នុងគេធសូត្រ ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់(អនុស្សតិទាំង ៦) ដើម្បីប្រយោជន៍ដល់ការញ៉ាំងចិត្ត របស់អរិយសាវក ឲ្យស្អាតល្អ ដោយអនុស្សតិហើយ បានសំរេចនូវសេចក្ដីបរិសុទ្ធិ ដែលមានអត្ថយ៉ាងក្រៃលែងប្រសើរខ្ពង់ខ្ពស់យ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងព្រះធម្មវិន័យនេះ រលឹករឿយៗ នូវតថាគតថា: ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះហេតុនេះៗ ។ល។ ក្នុងសម័យនោះ ចិត្ត របស់អរិយសាវកនោះ ជាចិត្តទៅត្រង់ មែនពិត ជាចិត្តចេញហើយ ជាចិត្តរួចហើយ ជាចិត្តរួចផុតហើយចាកតម្រេក, ម្នាលភិក្ខុទាំងឡាយ ពាក្យថា “គេធៈ” ហ្នឹងឯង ជាឈ្មោះនៃកាមគុណទាំង៥, ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ធ្វើនូវអនុស្សតិនេះ ឲ្យជាអារម្មណ៍ហើយរមែងបរិសុទ្ធ យ៉ាងនេះប្រការមួយ [១]” ដូច្នេះជាដើម ។

សូម្បីក្នុងសម្ពាធោកាសសូត្រ ដែលព្រះមហាកច្ចាយនៈ ដ៏មានអាយុ សំដែងហើយ ក៏ព្រះធម្មសង្គាហកាចារ្យទាំងឡាយ សំដែងអនុស្សតិទាំង ៦ នេះ ដោយអំណាចនៃការបាននូវឱកាស ដើម្បីភាវៈ

---

១- សុ. អំ. ឆ. ភាគទី ៤៦ ទំព័រទី ៦៨ ។

ជាអ្នកមានធម៌ដ៏បរិសុទ្ធ មានអត្ថយ៉ាងក្រៃលែង នៃព្រះអរិយសាវកហ្នឹងឯង យ៉ាងនេះថា “ម្នាលលោកដ៏មានអាយុ ហេតុគួរឲ្យអស្ចារ្យ, ម្នាលលោកដ៏មានអាយុ ហេតុមិនធ្លាប់កើត ក៏កើតឡើងបាន ព្រោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់ដឹងនូវធម៌ដែលជាគ្រឿងបាននូវឱកាស ក្នុងសេចក្តីចង្អៀត ដើម្បីសេចក្តីបរិសុទ្ធិ នៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន, ធម៌ជាគ្រឿងបាននូវឱកាស ក្នុងទីចង្អៀតនេះ គឺអ្វី?, គឺហេតុជាទីតាំងនៃអនុស្សតិទាំង ៦, អនុស្សតិដ្ឋានទាំង ៦ តើដូចម្តេច?, ម្នាលលោកដ៏មានអាយុ ព្រះអរិយសាវក ក្នុងព្រះធម្មវិន័យនេះ រលឹករឿយៗនូវព្រះតថាគត ។ល។ សត្វទាំងឡាយពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីស្អាតជាធម្មតា យ៉ាងនេះ ប្រការមួយ [១] ” ដូច្នេះជាដើម ។

សូម្បីក្នុងឧបោសថសូត្រ ក៏ព្រះដ៏មានព្រះភាគ ទ្រង់សំដែងអនុស្សតិទាំង ៦ ដើម្បីទ្រង់សំដែងនូវភាវៈនៃឧបោសថ ជាគុណជាតមានផលច្រើន ដោយអំណាចនៃកម្មដ្ឋាន ដែលជាគ្រឿងជម្រះចិត្តនៃព្រះអរិយសាវក អ្នករក្សាឧបោសថហ្នឹងឯង យ៉ាងនេះថា “ម្នាលនាងវិសាខា អរិយុបោសថ តើយ៉ាងដូចម្តេច?, ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម, ម្នាលនាងវិសាខា ក៏ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើយ៉ាងដូចម្តេច?, ម្នាលនាងវិសាខា ព្រះអរិយសាវក ក្នុងសាសនានេះ រលឹករឿយៗ នូវតថាគត...[២]” ដូច្នេះ ។

សូម្បីក្នុងឯកាទសនិបាត ក៏ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែង

១- សុ. អំ. ភាគ ៤៦ ទំព័រ ៧២ ។ ២- សុ. អំ. ភាគ ៤១ ទំព័រ ២៦២ ។



នូវអនុស្សតិទាំង ៦ នេះ ដល់សក្យៈមហានាមដែលទូលសួរថា “បពិត្រព្រះអង្គដ៏ចំរើន កាលយើងខ្ញុំព្រះអង្គនោះនៅ ដោយធម៌ជាគ្រឿងនៅផ្សេងៗ, តើយើងខ្ញុំព្រះអង្គ គប្បីនៅដោយធម៌ជាគ្រឿងនៅ ដូចម្តេច?” ដូច្នេះ ដើម្បីពន្យល់នូវធម៌ជាគ្រឿងនៅនៃអរិយសាវកហ្នឹងឯង យ៉ាងនេះថា “ម្នាលមហានាម បុគ្គលអ្នកមានសទ្ធា ជាអ្នកធ្វើឲ្យសម្រេចបាន, ម្នាលមហានាម បុគ្គលអ្នកមិនមានសទ្ធា មិនមែនជាអ្នកធ្វើឲ្យសំរេចបានទេ, បុគ្គលអ្នកមានព្យាយាមប្រារព្ធហើយ មានសតិខ្ជាប់ខ្ជួន មានចិត្តតាំងនៅមាំហើយ មានបញ្ញា ជាអ្នកធ្វើឲ្យសម្រេចបាន, បុគ្គលអ្នកខ្ជិលប្រអូស អ្នកភ្លេចភ្លាំងសតិ អ្នកមានចិត្តមិនតាំងនៅមាំ មានបញ្ញាមិនល្អមិនមែនជាអ្នកធ្វើឲ្យសម្រេចបានទេ, ម្នាលមហានាម ចូរអ្នកតាំងនៅក្នុងធម៌ទាំង ៥ នេះឯងហើយ ចំរើនធម៌ទាំង ៦ តទៅទៀត, ម្នាលមហានាម ក្នុងការចំរើនធម៌ទាំង៦ នេះ អ្នកគប្បីរលឹករឿយៗនូវតថាគតថា “ព្រះដ៏មានព្រះភាគអង្គនោះ ព្រោះហេតុនេះ...[១]” ដូច្នេះជាដើម ។

កាលបើមានហេតុយ៉ាងនេះ អនុស្សតិទាំង ៦ នេះ សូម្បីបុថុជ្ជនអ្នកប្រកបព្រមដោយគុណមានសីលបរិសុទ្ធជាដើម ក៏គួរធ្វើទុកក្នុងចិត្ត។ ព្រោះថា សូម្បីដោយអំណាចនៃការរលឹករឿយៗ ចិត្ត របស់បុគ្គលអ្នករលឹករឿយៗ នូវគុណទាំងឡាយនៃអរិយទាំងឡាយ មានព្រះពុទ្ធជាដើម រមែងជ្រះថ្លាមែនពិត, ដោយអានុភាពនៃសេចក្តីជ្រះថ្លាឯណា ព្រះយោគីនោះ គប្បីសង្កត់សង្កិននូវនីវរណៈទាំងឡាយហើយ ជាអ្នកមានបាមោជ្ជៈដ៏លើសលុប ប្រារព្ធវិបស្សនាហើយ ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តមែនពិតដូចជាព្រះបុស្សទេវត្ថេរ អ្នកមានប្រក្រតីនៅ ក្នុងវិហារឈ្មោះ

១- សុ. អំ. ឯក. ភាគទី ៥១ ទំព័រទី ២៦៤ ។

កម្ពុអន្ធការ យ៉ាងដូច្នោះឯង ។

បានឮមកថា លោកដ៏មានអាយុអង្គនោះ ឃើញព្រះពុទ្ធរូបដែលមារនិម្មិតហើយ បានចំពោះនូវបីតិដែលមានព្រះពុទ្ធជាអារម្មណ៍ ដោយគិតថា “មារនេះមានរាគៈ, ទោសៈ និង មោហៈនៅឡើយ រមែងស្អាតដល់ម៉្លេះទៅហើយ, ចុះព្រះមានព្រះភាគ ជាអ្នកមានរាគៈ, ទោសៈ និង មោហៈ ទៅប្រាសហើយ ដោយប្រការទាំងពួង តើល្អដូចម្ដេចទៅហ៎?” ដូច្នេះហើយ ចំរើនវិបស្សនា ក៏បានសំរេចនូវព្រះអរហត្ត ។

បរិច្ឆេទ ទី៧ ឈ្មោះ ឆអនុស្សតិនិទ្ទេស
ក្នុងអធិការនៃសមាធិភាវនា ក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គ
ដែលខ្ញុំរៀបរៀងហើយ
ដើម្បីប្រយោជន៍ដល់កិរិយាញុំាងសាធុជនឲ្យរីករាយ
ចប់ហើយ ដោយប្រការដូច្នេះ ។

♣ ♣ ♣

**ចប់**

**បករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គប្រែ**

**ភាគ ទី១**

*រៀបរៀងចប់សព្វគ្រប់*
*នៅថ្ងៃច័ន្ទ ៣ កើត ខែផល្គុន អដ្ឋស័ក ព.ស. ២៥៤០*
*ត្រូវនឹងថ្ងៃទី ១០ ខែមិនា ១៩៩៧ ។*
*វេលា ម៉ោង ២:៥៩ ល្ងាច*



## អវសានកថា

ដោយអានិសង្សនៃធម្មទាននេះ ខ្ញុំសូមតាំងចិត្តប្រាថ្នាឲ្យបានអស់ទៅនៃអាសវក្កិលេស ក្នុងអនាគតកាលកុំបីខានឡើយ ។

មួយទៀត ខ្ញុំសូមឧទ្ទិសនូវអានិសង្សដែលកើតអំពីធម្មទាននេះ ជូនដល់លោកអ្នកដ៏មានគុណទាំងទ្វេគឺ បិតានាម **យិន-យឿម** មាតានាម **ហឹង-អម** សូមលោកអ្នកដ៏មានគុណទាំងពីរបានទទួលនូវបុណ្យកុសលនេះ តាមសមគួរដល់សេចក្ដីប្រាថ្នាទៅហោង ។

♣ ♣ ♣

សូមសិក្សានូវភាគទី២-ទី៣ បន្តទៀត

## រាយនាមពុទ្ធបរិស័ទ ជួយឧបត្ថម្ភ ក្នុងធម្មទាននេះមានៈ

| | |
|---|---|
| លោក ឡូ-ប៊ុនឡេង អ្នកស្រីអឿប-ឆៃគីម | ២,៦៥០ដុ |
| ធម្មបូជា បុណ្យចំរើនព្រះជន្ម ព្រះភិក្ខុ សែម-សុឃឿន | ១,៧៥០ដុ |
| ឧបាសិកា អឿប-ឆៃហុង | ១,០០០ដុ |
| ឧបាសិកាឈឹម-គីមស្រ៊ុន និង កូនចៅ ព្រមទាំងញាតិមិត្រ | ១,០០០ដុ |
| ឧបាសិកា នួន-វណ្ណា | ៩០០ដុ |
| លោក វង់-ម៉ៅ អ្នកស្រីឆាន់-កាន់ដួង | ៨៥០ដុ |
| អ្នកស្រី ឆាន់-ហៃគឹង | ៥០០ដុ |
| វត្តមិនីសុតារាម | ៥០០ដុ |
| ឧបាសិកា វ៉េន-ល្វន់ (សុខ-រស់) និង កូនចៅ | ៤៥០ដុ |
| ពុទ្ធបរិស័ទវត្តសាន់តាអាណា ថ្ងៃសីល | ៤២០ដុ |
| បុណ្យឧបាសិកា លី-ឡាំងជាង និង កូនចៅ | ៤០០ដុ |
| ភិក្ខុ អាំង-យុង ឧបាសិកា តាន់-គីមថាន់ បុត្រធីតា និង ចៅ | ៤០០ដុ |
| លោកតែ-ទាសៀ អ្នកស្រីលឹម-ណៃហ៊ួង ព្រមទាំងញាតិមិត្រ | ៤០០ដុ |
| បុណ្យលោកតា អ៊ាប-ភាវ | ៣៣០ដុ |
| ព្រះតេជះគុណប្រកប វត្តជម្ពូរុក្ខាវនារាម | ៣១៥ដុ |
| ភិក្ខុវិនយធរោ មហាឃិន-នឿន | ៣០០ដុ |
| ឧបាសក នង-ហាក់ ព្រមទាំងគ្រួសារ កូនចៅ | ៣០០ដុ |
| លោកគ្រូរក្ខិតធម្មោ គង់-សូផាន | ៣០០ដុ |
| លោកអាចារ្យ អ៊ុង-អ៊ិន ព្រមទាំងគ្រួសារ និង កូនចៅ | ៣០០ដុ |
| លោកសុជាតតោ-សំលឿង អ្នកស្រីស៊ុម-សាឡាត់ | ៣០០ដុ |
| អ្នកស្រី RATH KIM & BILL CHHAY | ២៦០ដុ |
| ពុទ្ធបរិស័ទ វត្តខ្មែរបាលិលេយ្យ | ២៦០ដុ |
| ឧបាសិកា សៅ-យ៉ៃ ព្រមទាំងកូនចៅ | ២៥០ដុ |
| ព្រះតេជះព្រះគុណធម្មថេរោ (សៅ-ឃន) | ២៥០ដុ |
| ឧបាសក ចេក-ឃាន ឧបាសិកា ច័ន្ទ-ឈួម ព្រមទាំងកូនចៅ | ២៥០ដុ |
| អ្នកស្រី ធីរ៉ា RICHARCH (GA) | ២២០ដុ |
| លោកអាចារ្យ ភាគ-ឈួន គ្រួសារ និង កូនចៅ | ២២០ដុ |
| ឧបាសិកា លឹម-គាមទី និង បុត្រធីតា | ២២០ដុ |
| ញោម សារុន និង កូន | ២១៧ដុ |
| លោក រិទ្ធិ-ស៊ាន អ្នកស្រីស៊ីវ-ង៉ោ,សុផានី, លីនដា, សោភ័ណ | ២១០ដុ |
| កេតុ-ថូ | ២០០ដុ |
| ឧបាសិកា លឹម-ណៃស្រីម កូនចៅ | ២០០ដុ |



| | |
|---|---|
| អ្នកស្រីស៊ូ-ហាច និង កូនចៅ | ២០០ដុ |
| លោកឈាន-សារឿន អ្នកស្រី ឡឹង-គីមស្រាន | ២០០ដុ |
| អាចារ្យប្រាក់-ភាច ឧបាសិកា សុខ-ភឿន | ២០០ដុ |
| ឧត្តមធម្មឃោសាចារ្យ កុត-កុសល កែវ-សុធម្មា ឡៃ-យ៉ុន | ២០០ដុ |
| លោក តាំង-ចឺ អ្នកស្រី ឡេា-គីមឡេង | ២០០ដុ |
| លោក ឡាំ-រឿង ព្រមទាំងក្រុមគ្រួសារ | ២០០ដុ |
| Mrs NAMTYHUY, Mr, & Mrs. KEIW LEE, TINATH LEE | ២០០ដុ |
| ឧបាសិកា អ៊ឹង-សាយទាវ នាង អ៊ឹង-គិមអេង | ២០០ដុ |
| ព្រះតេជះគុណ ថុន-សុផុន | ២០០ដុ |
| លោកវោហា-ជួន អ្នកស្រីណាត្រី-ជួន | ២០០ដុ |
| ពុទ្ធិកសមាគម វត្តធម្មរង្សី | ២០០ដុ |
| លោក ឯក-ឆាលី អ្នកស្រី អោម-ខុន | ២០០ដុ |
| ឧបាសក ជូ-មី ឧបាសិកា ឯក-បូលីន និង កូនចៅ | ១៨៥ដុ |
| អ្នកស្រី កុត-កណ្ណិកា សោម៉ា(សុជាតា) ស្វាមី និង បុត្រ | ១៧៥ដុ |
| លោកតាអ៊ឹម-ពន្លក និង ឧបាសិកាដួង-សុខុម | ១៧៥ដុ |
| ភិក្ខុ ប្រាជ្ញ-សារ៉ាន់ | ១៦៦ដុ |
| DARA HENG | ១៥០ដុ |
| ឧបាសិកា អ៊ុន-ហេង និង កូនចៅ | ១៥០ដុ |
| ឧបាសិកា រេន | ១៥០ដុ |
| ភិក្ខុ ម៉ែន-សុខ | ១៤០ដុ |
| ភិក្ខុ និង សាមណេរ វត្តអែរ៉ាប់ | ១៣០ដុ |
| ឧបាសក ជ្រូក-រួន ឧបាសិកា ម៉ែន-ផាត កូនចៅ | ១២០ដុ |
| ឧបាសិកា យឹម-លឹម ព្រមទាំងកូនចៅ | ១២០ដុ |
| ភិក្ខុ មហាប៊ុន-ឈឺន | ១១០ដុ |
| ភិក្ខុ ប៉ាន-សំម៉ាយ និង ពុទ្ធបរិស័ទ វត្តច័ន្ទស៊ីសាមគ្គីធម៌ | ១១០ដុ |
| ឧបាសិកា ញ៉ែម-នីម និងកូនចៅ | ១១០ដុ |
| ភិក្ខុ សោម-សុភា (ធម្មធរោ) | ១០៧ដុ |
| ភិក្ខុ ឫទ្ធិពល នាថបណ្ឌិតោ | ១០៥ដុ |
| CHHAY SEREI CHAN | ១០៥ដុ |
| អ្នកស្រី ជា-តោ | ១០៥ដុ |
| ភិក្ខុ ឃុន-ទុយ | ១០៥ដុ |
| លោក ញិន-ផុន អ្នកស្រី សុខ-សារ៉េត កញ្ញា ញិន-រ័ត្ន | ១០១ដុ |
| លោក អឿ-សៅ, ឧបាសកប៊ូ-ហោនាង, | |
| ឧបាសិកា អ៊ឹង-រិទ្ធានី, ឧបាសិកាលី-ប៉ូលីន ស៊ីម-ប៉ូ | ១០០ដុ |

| | |
|---|---|
| លោក តាំង-ហាំងសាយ អ្នកស្រីជីវ-សុខមួយ និង កូនចៅ | ១០០ដុ |
| លោកអាចារ្យ ឡុង ឧបាសិកា ឈាង-សាមិន | ១០០ដុ |
| លោក សារិន អ្នកស្រី គឹម-លាង | ១០០ដុ |
| ឧបាសិកា សុខ-សាមឿន តាន់-សម្បត្តិ | ១០០ដុ |
| ឧបាសិកា អ៊ឹម-ណូយ | ១០០ដុ |
| **MOLANIE, ALLAN, LONIS & MADELYN LIM** | ១០០ដុ |
| អាចារ្យ វិសុទ្ធិ-ឱម ឧបាសិកា សូត-សាខន | ១០០ដុ |
| អ្នកស្រី កែវ-បុប្ផទិព្វ | ១០០ដុ |
| ឧបាសិកា កង-សាលី និង កូនចៅ | ១០០ដុ |
| **TAING KIM LEAANG** | ១០០ដុ |
| ឧបាសិកា ថោង-មុំ | ១០០ដុ |
| អ្នកស្រី ប៊ុត-សុផានី | ១០០ដុ |
| ឧបាសិកា គាន-សរ | ១០០ដុ |
| លោក តាន់-កៅ អ្នកស្រី តាន់-សារឿន | ១០០ដុ |
| ឧបាសិកា ង៉ោ-ស៊ូអេង | ១០០ដុ |
| ព្រះវិភទ្ទញ្ញាណ (ព្រហ្ម-ខៀន) វត្តសុវណ្ណគិរី | ១០០ដុ |
| ភិក្ខុ ប៊ុន-ស្លៀន ធម្មវរោ | ១០០ដុ |
| ភិក្ខុ សឹម-សៀម ធម្មរក្ខិតោ | ១០០ដុ |
| ភិក្ខុ អឿ-សៅ | ១០០ដុ |
| ព្រះតេជះគុណមាស-គឹមអេង | ១០០ដុ |
| ភិក្ខុ យិន-សាគុណ | ១០០ដុ |
| ព្រះតេជះគុណ ម៉ី-រស | ១០០ដុ |
| ភិក្ខុ ឡាយ-រិន | ១០០ដុ |
| ភិក្ខុ មហាមុនី-រត្ន | ១០០ដុ |
| ភិក្ខុ គង់-សុទ្ធី | ១០០ដុ |
| សាមណេរ ជិម-មាល័យ | ១០០ដុ |
| លោកអាចារ្យ ថាច់-សុង ហុង-គិមហ៊ន់ | ១០០ដុ |
| អ្នកស្រី ឆាន់-ហ្វុង | ១០០ដុ |
| លោកអាចារ្យស៊ឺន-ជុង ឧបាសិកា ឡុង-ប៉ែន | ១០០ដុ |
| ឧបាសក លន់-ធន់ | ១០០ដុ |
| ឧបាសក ជិក-វិញ និង ឧបាសិកា គិម-ថាញ់ | ១០០ដុ |
| ឧបាសិកា ផាវ-សារៀប និង កូនចៅ | ១០០ដុ |
| អ្នកស្រី ឈុន-យ៉េន | ១០០ដុ |
| ឧបាសក ហ៊ឹម-ម៉ៅ ភរិយា និង បុត្រធីតា | ១០០ដុ |



| | |
|---|---|
| លោក ផង់-វ៉េម អ្នកស្រី វ៉ែន-អឿន | ១០០ដុ |
| ឧបាសិកា សាន-អឿន ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា សួស-ណៃទៀង ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា ជិង-សាយ ថ ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា ណាវ៉េត-អ៊ូ | ១០០ដុ |
| ឧបាសក ថ្លាង-សាវន ឧបាសិកា យិន-សំណាង | ១០០ដុ |
| ឧបាសិកា កាក់-កួយ | ១០០ដុ |
| ឧបាសក ស៊ិន-ផូ លោកយាយពុំ | ១០០ដុ |
| ឧបាសិកា ឌុច-សាមីន | ១០០ដុ |
| បណ្ឌិត តូច-ផលមាន និង គ្រួសារ | ១០០ដុ |
| កម្លោះ ពៅ វីឌៀល សម្បូរ | ១០០ដុ |
| ផ្លួក-សុទ្ធី | ១១០ដុ |
| ឧបាសិកា កុល-យន់ យាយសម្មា | ១០០ដុ |
| ឧបាសិកា ឈា លោកតា ហេន | ១០០ដុ |
| ឧបាសិកា ញ៉ែម-ឡាង និង បុត្រ | ១០០ដុ |
| ឧបាសិកា កាក់-គីគង់ និង បុត្រធីតា | ១០០ដុ |
| **LAKHANA SAR (BONG LEAK)** កូនយាយរេន | ១០០ដុ |
| លោក ប៉ុក-ប៊ុនរិទ្ធ ព្រមទាំងគ្រួសារ និង កូនចៅ | ១០០ដុ |
| ឧបាសិកា ទិត-សាត ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា អ៊ុក-ទូរ៉េត | ១០០ដុ |
| ម៉ន-ស៊ិងហេង ភរិយា ឡាយ-សុខគា | ១០០ដុ |
| ស៊ុម-រ៉ាត់ ភរិយា យិន-ឃីម និង បុត្រធីតា | ១០០ដុ |
| ឧបាសិកា ឱម-សង្វ៉ាន លោកនេត្រ-ហេង និងកូនចៅ | ១០០ដុ |
| លោកគ្រូ ឆាយ-យស ឧបាសិកា ចាប-សំអៀន | ១០០ដុ |
| ឧបាសិកា កុត-សាខន និង បុត្រធិតា | ១០០ដុ |
| ភិក្ខុ អ៊ុន-វ៉ុន | ១០០ដុ |
| លោក ជា-ព្រហម៉ន នាង ផ្លាសារ៉េត | ១០០ដុ |
| នាង ព្រហ្ម-ច័ន្ទ សូវ៉ន និង កូនលក្ខណា | ១០០ដុ |
| លោកអាចារ្យ កែវ-ប៉ុន ឧបាសិកា ហាច-សួង | ១០០ដុ |
| លោកអាចារ្យ ដោក-សុន ឧបាសិកា អ៊ូ-អ៊ូច និង កូនចៅ | ១០០ដុ |
| ភិក្ខុ សុខ-ភាតរ: | ១០០ដុ |
| អ្នកស្រី សំបូ-រ័ត្ន (ហៅហ៊ីង-ស៊ុនថា) | ១០០ដុ |
| ភិក្ខុ គឹម-បាន | ១០០ដុ |
| ភិក្ខុ ទិម-ញូល (តិណកាមោ) | ១០០ដុ |

| | |
|---|---|
| ឧបាសិកា ហ៊ីង-ប៊ូ | ១០០ដុ |
| អ្នកស្រី គួយ-រ៉ាន់ | ១០០ដុ |
| ឧបាសិកា ភន-ស៊ាងហៃ និង បុត្រធីតា | ១០០ដុ |
| ឧបាសិកា យិន-ហ៊ុន ឧបាសក យិន-សឿន | ១០០ដុ |
| ឧបាសិកា យូ-ស្រ៊ន | ១០០ដុ |
| លោកអាចារ្យ ហេង អ្នកស្រី ហ៊ុន-គីមសាយ | ១០០ដុ |
| ឧបាសក ឈុំ-កុសល ឧបាសិកា ហេង-យិន និង បុត្រធីតា | ១០០ដុ |
| ឧបាសិកា គីម-សី លោក ប្រៀន-គាង និង ភរិយា | ១០០ដុ |
| ឧបាសិកា ជា-លីមអេង | ១០០ដុ |
| ឧបាសិកាផាវ-សារៀប អ្នកស្រីសក់-សាលឿន គ្រួសារ | ១០០ដុ |
| លោក ស៊ីសុវណ្ណ-ណាយ និង ភរិយា | ១០០ដុ |
| ឧបាសិកា ប៉ាន-សារិទ្ធ ព្រមទាំងកូនចៅ | ១០០ដុ |
| ឧបាសិកា ផាន់-ឡាន និង បុត្រធីតា | ១០០ដុ |
| អ្នកស្រី លីម-ចាន់ណា | ១០០ដុ |
| បុណ្យឧបាសក សឹន-អឿង ឧបាសិកា គិម-ថីសី | ១០០ដុ |
| **PHNOM PENP EXPRESS** | ៩០ដុ |
| **LOEUNG NINA** | ៩០ដុ |
| អ្នកស្រី សន-លីណា ហៅ អាភាព កូនខ្ញុំ | ៩០ដុ |
| លោក តាំង-ហាំងឆាយ អ្នកស្រីជីវ-សុខម៉ួយ | ៩០ដុ |
| ឧបាសិកា លីម-មួយជូ | ៩០ដុ |
| ភិក្ខុ ជា-ហឿង ឧបាសិកា អ៊ូច-សូត្រ | ៩០ដុ |
| បូជាព្រះធម៌ទេសនា វត្តសាន់តាអាណា | ៨៨ដុ |
| ឧបាសក ជូ-មី ឧបាសិកា បូលីន កូនចៅ | ៨៥ដុ |
| ឧបាសិកា ទិត្យ-យ៉ាន ប៉ុក-សំអាន | ៨០ដុ |
| អ្នកស្រី សឿន-សុឃួន ព្រមទាំងគ្រួសារ | ៨០ដុ |
| ឧបាសក ទៀង ឧបាសិកា រួម និងកូនចៅ | ៧០ដុ |
| លោក ចាន់-យឿន អ្នកស្រី ងួន-ខន, អ្នកស្រី ងួន-ដកច័ន្ទ, ព្រមទាំងបុត្រធីតា | ៧០ដុ |
| អ្នកស្រី គីម-សារុន និង លោក គីរី | ៧០ដុ |
| នាង គ្រួ | ៦០ដុ |
| ឧបាសិកា លីម-អាង | ៦០ដុ |
| ឧបាសិកា ចេង-ប៉ោយ | ៦០ដុ |
| ឧបាសិកា ងី-ឆេ កូនចៅ | ៦០ដុ |
| លោក ឡេង-ឆាយ និង សុខ-ម៉ួយជាវ | ៦០ដុ |



| | |
|---|---|
| យាយ អ៊ឹង-ហ៊្គិច គ្រី-ម៉េងលាង គ្រី-ជិនណាំ | ៦០ដុ |
| ឧបាសក ឡឹម-ម៉ាតធីតា ឧបាសិកា តាំង-ធីយន | ៦០ដុ |
| ភិក្ខុ សន-សែន (វត្តព្រះពុទ្ធ) | ៦០ដុ |
| ឧបាសក តេង-ខាំសន ឧបាសិកា ធុយ-ប៊ុនម៉ា | ៦០ដុ |
| ក្រុមវេន គ្រួសារតាម៉ាន និង ញាតិមិត្រ នៅសៅមុនី | ៥៦ដុ |
| អ្នកស្រី ឡាច-រ៉ាន់ និង គ្រួសារ | ៥៥ដុ |
| **ROSS CHANTY** | ៥៥ដុ |
| តៅ-ច្រិក និង កូនចៅ | ៥៣ដុ |
| អ្នកស្រី ចាន់-កូឡាប, សេក-គ្រិច, សេក-ទី | ៥៣ដុ |
| ឧបាសក ប៉ែន-ញ៉ឹម ឧបាសិកា តូ-សារិ | ៥០ដុ |
| ឧបាសិកា ប៉ោ-សែគ្គិច | ៥០ដុ |
| ភិក្ខុ ច័ន្ទ-សុខា វត្តពោធិសុវណ្ណារាម | ៥០ដុ |
| អាចារ្យ ប៉េ-រី ឧបាសិកា ញ៉ឹង | ៥០ដុ |
| ឧបាសិកា ស៊ិន-ង៉ែត | ៥០ដុ |
| កញ្ញា យុត | ៥០ដុ |
| ឧបាសិកា ឆាយ-ទន | ៥០ដុ |
| ភិក្ខុ អ៊ុយ-ហេង | ៥០ដុ |
| ឧបាសិកា ផលី | ៥០ដុ |
| លោក អាចារ្យ ទិក-យី | ៥០ដុ |
| ឧបាសិកា សីល-ចាន់លន់ | ៥០ដុ |
| អ្នកស្រី អៀ-ប៊ុរ និង កូនចៅ | ៥០ដុ |
| **DARIN & SAROM SOK** | ៥០ដុ |
| អ្នកស្រី ហេង-ឈាប | ៥០ដុ |
| ឧបាសិកា ស៊ុម-រដ្ឋ ព្រមទាំងកូនចៅ | ៥០ដុ |
| អ្នកស៊ន-យ៉ាន គ្រួសារ និង កូនចៅ | ៥០ដុ |
| លោកម៉ៅ គ្រួសារតាចិន | ៥០ដុ |
| **AMY CHEA** | ៥០ដុ |
| លោក ទ្រី-គិមម៉េង អ្នកស្រី សៀក-អ៊ាមគុយ | ៥០ដុ |
| ឧបាសិកា ង៉ូវ-ស៊ីលាន ព្រមទាំងកូនចៅ | ៥០ដុ |
| លោក អ៊ឹង-ង៉ួនហាវ អ្នកស្រី អ៊ឹង-សាយឃីម | ៥០ដុ |
| **HOUT SOU PHALLY KHUTH** | ៥០ដុ |
| អ្នកស្រី បាន-ជាហួ និង បុត្រធីតា | ៥០ដុ |
| ឧបាសិកា ដួង-យ៉ាន | ៥០ដុ |
| លោក ដុះ-ឆីយ | ៥០ដុ |

| | |
|---|---|
| អ្នកស្រី ម៉ឹង-ទៀ្ប | ៥០ដុ |
| អ្នកស្រី បាន-ជាផិចជូ គ្រួសារ និង បុត្រ | ៥០ដុ |
| ឧបាសិកា អៀង-គីមហួយ | ៥០ដុ |
| ម៉ិល-យ៉ែម | ៥០ដុ |
| កញ្ញា ឆាយ-យុផល | ៥០ដុ |
| ឧបាសក ស៊ុន-ជាង ឧបាសិកា លី-ឡាំងជាង | ៥០ដុ |
| ភិក្ខុ ស៊ិន-ថោង ធម្មសុវណ្ណោ | ៥០ដុ |
| ភិក្ខុ បណ្ឌិតោ ជីក-ព្រហ្ម | ៥០ដុ |
| ឧបាសិកា ឈា-ហ៊ន | ៥០ដុ |
| ឧបាសិកា ចេង-ឆៃមាន | ៥០ដុ |
| ឧបាសិកា គ្រី-សេងលី | ៥០ដុ |
| ភិក្ខុ ស៊ិន-សុវត្ថា | ៥០ដុ |
| លោក ឌួង-ប៉ុន អ្នកស្រី ភី-រិន | ៥០ដុ |
| ឧបាសិកា យូ-ឡេា | ៥០ដុ |
| ភិក្ខុ ប្រាក់-ឈន | ៥០ដុ |
| ភិក្ខុ សុបណ្ណោ ហៀប-ឈាន | ៥០ដុ |
| អ្នកស្រី ប៉ុក-សុគន្ធមាលី លោកខៀវ-សំអាត បុត្រ | ៥០ដុ |
| ភិក្ខុ ឌឿ-ឧត្តម | ៥០ដុ |
| ឧបាសិកា ពីជ | ៥០ដុ |
| លោក នូ-ច័ន្ទប៊ុននី និង ភរិយា | ៥០ដុ |
| ឧបាសិកា គង់-សូភន | ៥០ដុ |
| ឧបាសិកាអៀង-គីមហួយ កូនចៅ, ឧបាសកភោគ-ឈុំ អ៊ឹង-ស៊ីណា | ៥០ដុ |
| គឹម-សេង | ៥០ដុ |
| រាជ-រតនៈ, ចេង ហ៊ុយ ផេង ភរិយា និង បុត្រ, | |
| ឡាយ-នាង ជា-សុគុំ ភរិយា និង បុត្រ | ៥០ដុ |
| ឧបាសិកា នេត-ដានី (រ៉ើម) | ៥០ដុ |
| ភិក្ខុ សុវណ្ណបញ្ញោ សោ-អ៊ូន | ៥០ដុ |
| អ្នកស្រី ស៊ូ-នឿន | ៥០ដុ |
| ឧបាសិកា ម៉ារ-បូរី (ផល) | ៥០ដុ |
| អ្នកស្រី គីមលី-ផ្លុង | ៥០ដុ |
| ឧបាសិកា ឌុច-សាខន | ៥០ដុ |
| ឧបាសិកា ថាប់-ថូ | ៥០ដុ |
| លោក ឈុន-គីមអៀត និង ភរិយា | ៥០ដុ |
| ឧបាសិកា តាំង-គីមលាង | ៥០ដុ |



| | |
|---|---|
| អ្នកស្រី ទៀ្ប-សៀង គ្រួសារ | ៥០ដុ |
| អ្នកស្រី សុខ-គាង | ៥០ដុ |
| មុនី-ឡាំ និង គ្រួសារ | ៥០ដុ |
| ម្តាយសាមណេរចេក | ៥០ដុ |
| លោក គង់-វុត អ្នកស្រី អ៊ុក-ស៊ិនហ៊ា | ៥០ដុ |
| ភិក្ខុ ធីង យីម ( វត្តធម្មនិការាម ) | ៥០ដុ |
| លោកយាយ ជិ ប៉ុនឡុង និង ប៊ូ រ៉ាស៊ី | ៥០ដុ |
| លោក វេង ណាំ និង សក់ សាន់នី | ៥០ដុ |
| ព្រះគ្រូចៅអធិការ ទេព-សៀង វត្តត្រៃរតនារាម ប្រទេសបារាំង | ៥០E |
| យុវជន ដារ៉ា-ហេង | ៥០ដុ |
| ឧបាសិកា ទូច-ឈុន ឧបាសក ឡាច | ៨៥ដុ |
| ឧបាសិកា ឡូ-ប៊ុនហ៊ាង ឧបាសក អោ-ឈីន | ៨៥ដុ |
| អ្នកស្រី សុខ-មួយលាង | ៨៥ដុ |
| ភិក្ខុ បញ្ញាទីបោ ភួង-ប៊ុនហ៊ីម | ៨៥ដុ |
| ឧបាសិកា គិម-ចេងស្រ៊ុន | ៨៥ដុ |
| ឧបាសក ហួន-ជូលាង | ៨៥ដុ |
| ឧបាសិកា ស៊ីវ-យក់លុយ | ៨៥ដុ |
| ណាតាលី និង ឌីណា | ៨៥ដុ |
| ឧបាសិកា រឿម | ៨៥ដុ |
| ជា-វួចលាង | ៨៥ដុ |
| ឧបាសិកា យឹម-សារ៉ន | ៨៥ដុ |
| អ៊ឹង-លាងគង់, ទាឡាង មួយ | ៨៥ដុ |
| ឧបាសិកា នុប-រស់ | ៨៥ដុ |
| ឧបាសិកា ម៉ម-អុន | ៨៥ដុ |
| ឧបាសិកា ទេស-ស៊ីថា | ៨៥ដុ |
| ឧបាសក ជា-ហេង ឧបាសិកា អែម-មុំ | ៨៥ដុ |
| ឧបាសិកា ឈុន-គីមស្រ៊ី និង បុត្រធីតា | ៨៥ដុ |
| ឧបាសិកា ជា-លាងហ៊ី និង បុត្រធីតា | ៨៥ដុ |
| អ្នកស្រី ថាច, លោកមុត-ឆុត ភរិយា និង បុត្រធីតា | ៨៥ដុ |
| ធម្មាចារ្យ ថាច់-សៅ អាចារ្យវិបស្សនា | ៨៥ដុ |
| មហាឧបាសិកា កែវ-ពេជ្រ ច័ន្ទ-ស៊ីថុល | ៨៨ដុ |
| ឧបាសក លាក់-ផន ឧបាសិកា ចុន-អេត | ៨៨ដុ |
| ឧបាសក គ្រូ តោ-ស្វាង | ៨៨ដុ |
| ឧបាសិកា ឈួន-ង៉ន | ៨៨ដុ |

| | |
|---|---|
| អ្នកស្រីសេក-ណារី សេក-មាធិន សេក-មុនីរតនា គីម-បុប្ផជនណា | ៨៨ដុ |
| លោក អាំង-សូវ៉ាន់ និង ហែម-ច័ន្ទសុផល | ៨២ដុ |
| អ្នកស្រី វាំង-សុហ្វីនី, អ្នកស្រី វាំង-សុណាន្តា | ៨២ដុ |
| លោក សុនន-សុខ និហ ហែម-ចន្ទី | ៨២ដុ |
| ឧបាសិកា លឿម-ឡម | ៨០ដុ |
| ឧបាសិកា តាំង-ក្លួយ | ៨០ដុ |
| លោក ឆាយ-ទ្រី និង អ្នកស្រី លី-អៀវឆេង | ៨០ដុ |
| ឧបាសិកា ឃុត-សុត, អ្នកស្រីវាំង-ផុន, ទុំ-ណារិទ្ធ សេង-ដានេត្រ និង បុត្រធីត | ៨០ដុ |
| ឧបាសិកា ឈូ-ច្រែង | ៨០ដុ |
| ភិក្ខុ ទឹម-ញ៉ុល | ៨០ដុ |
| លោក **FRANK LY** | ៨០ដុ |
| ឧបាសកថេត-រិន,ឧបាសិកាម៉ៅ-ខាត់, ថេត-កូ, អ៊ឹម-កឿត, រិន-កុសល, រិន-ចំរើន, ស៊ីវ-វិរៈ, ឫទ្ធិ-រតនៈ | ៨០ដុ |
| ឧបាសិកា ចាន់-ញឹម | ៨០ដុ |
| រឿន | ៨០ដុ |
| យុវជន លី-សុរិចិត្រ (បូរ៉ា) | ៨០ដុ |
| ពុត-សុគន្ធវារី | ៨០ដុ |
| អ្នកមីង សន-ឡេន | ៨០ដុ |
| **NARY** | ៨០ដុ |
| អកស្រី ឌី-វណ្ណៈ និង គ្រួសារ | ៨០ដុ |
| ឧបាសិកា ជុំ-ឃន ឧបាសក ព្រុំ-រិត និង បុត្រ | ៨០ដុ |
| អ្នកស្រី វណ្ណារី និង គ្រួសារ | ៨០ដុ |
| គ្រួសារ សេង-គីម និង ភរិយា | ៨០ដុ |
| **MARY DY** | ៨០ដុ |
| ប៉ាន់-សុខហេង ភរិយា ប៉ាន់-សុខុន | ៨០ដុ |
| ឧបាសកគួយ-ធុន ឧបាសិកា ធូរ-មុំ | ៨០ដុ |
| អ្នកស្រី តូច-សារី | ៨០ដុ |
| ភិក្ខុ ចាប-ញ៉ម | ៨០ដុ |
| លោក កាំង-ហេង អ្នកស្រីតាន់-អាយគួន | ៣៥ដុ |
| អ្នកស្រី ង៉ួន-គីមសេង | ៣៥ដុ |
| គួ-ហ៊ីង និង កូនចៅ | ៣៥ដុ |
| គង់-សូ និង កូនចៅ | ៣៥ដុ |
| អែម-ដើង និង កូនចៅ | ៣៥ដុ |



| | |
|---|---|
| អៀវ-ថាញ់ និង កូនចៅ | ៣៥ដុ |
| យ៉ង់-មាលី | ៣៥ដុ |
| ទាន់-សាយ ទីវ-វ៉េម និង កូនចៅ | ៣៥ដុ |
| ត្រាំង-ដែន និង កូនចៅ | ៣៥ដុ |
| យូ-គុណវុត ភរិយា និង កញ្ញា យូ-មុនីរ័ត្ន | ៣៥ដុ |
| យក់-ព្រីដា កញ្ជនា និង កូន | ៣៥ដុ |
| លឹម-ប៊ុនធឿន មិន-សាវ៉ាន់ និង កុន | ៣៥ដុ |
| លោក ពៅ-កុច អ្នកស្រី ទេស-ហ៊ន | ៣៥ដុ |
| ឧបាសិកា ថៃ-តាំង | ៣៥ដុ |
| លោក ព្រុំ-ឡាយ និង ភរិយា | ៣៥ដុ |
| លោក ជីន-សុគន្ធ អ្នកស្រី ហេង-ស៊ីហ៊ាង | ៣៥ដុ |
| ឧបាសិកា ហ៊ុន-ពត ព្រមទាំងបុត្រធីតា | ៣៥ដុ |
| ឧបាសិកា អ៊ិត-ឡម | ៣៥ដុ |
| ឧបាសិកា កាន់-ឆន | ៣៥ដុ |
| ភិក្ខុ ពេជ្រ-សុធីរ | ៣៥ដុ |
| ភិក្ខុ សឹម-យឹម | ៣៥ដុ |
| លោក រូឡង់-ឌី ពែក-សុផាន | ៣៥ដុ |
| លោក រូ-សាមលី ព្រមទាំងបុត្រ | ៣៥ដុ |
| លោក ញឹម-ពែក មុំ-សារឿន | ៣៥ដុ |
| លោក គួយ-សុថុន អ្នកស្រី លន់-ស៊ីនួន | ៣៥ដុ |
| លោក គួយ-សុវណ្ណារិទ្ធិ អ្នកស្រី ប៊ុត-រ័ត្ន | ៣៥ដុ |
| ឧបាសក យ៉ម-ដែង ឧ:សិកា ហេង-វ៉ាន់ឌី | ៣៥ដុ |
| កញ្ញា យ៉ម-ចិន្តា, កញ្ញា យ៉ម-ផលា, កញ្ញា យ៉ម-ច័ន្ទរ៉ុង | ៣៥ដុ |
| លោកស្រី ស៊ុយ-ផល្លី កុមារា អាឡិចសិនដា កុមារី អញ្ជលី | ៣៥ដុ |
| លោក យ៉ម-គីរីវ៉ាន់ អ្នកស្រី គឹម-សុភាព កុមារា យ៉ម-វ៉េនឌី កុមារី យ៉ម-យាលី ឧបាសិកា ចេង-ស្រ៊ុន | ៣៥ដុ |
| ឧបាសក ម៉ី-សារ៉ន ឧបាសិកា ឡាំង-ជាង | ៣៥ដុ |
| ឧបាសិកា ហៀន-សូងម | ៣៥ដុ |
| អ្នកស្រី ថង-ចួប | ៣៥ដុ |
| លោក អ៊ួង-គាងហេង អ្នកស្រី ហៅ-ម៉េង និង បុត្រធីតា | ៣៥ដុ |
| ឧបាសក ឌួង-ឆែម ឧបាសិកា អ៊ុយ-អ៊ាត | ៣៥ដុ |
| លោក បេង-ជុត អ្នកស្រី ស៊ីវ-ហេង និង បុត្រធីតា | ៣៥ដុ |
| ឧបាសិកា រឿន-រាជ ឧបាសក ឆ-ភោគ និង បុត្រធីតា | ៣៥ដុ |
| ឧបាសិកា អ៊ុន-ផូវ និង បុត្រធីតា | ៣៥ដុ |

| | |
|---|---|
| ឧបាសិកា ប៉ិល-សាគុណ និង បុត្រធីតា | ៣៥ដុ |
| អ្នកស្រី តាន់-ឆេងស៊ីម និង បុត្រធីតា | ៣៥ដុ |
| លោក ប៉ែន-សុខន អ្នកស្រី យិវ-សេដ្ឋា | ៣៥ដុ |
| លោក គូ-ប៊ុនកាន អ្នកស្រី សេង-ថង | ៣៥ដុ |
| លោក ផន-វី អ្នកស្រី លន-ឡេង | ៣៥ដុ |
| ឧបាសក អុន-លន ឧបាសិកា ហេង-លន់ | ៣៥ដុ |
| លោក អៀម-ឃុនណារុធ អ្នកស្រី ណៃ-យុំ | ៣៥ដុ |
| ឧបាសក សេង-សួត ឧបាសិកា សុន្ទរ៍-ធីង | ៣២ដុ |
| ឧបាសក ឆុង-ញិប ឧបាសិកា សរិត-សួម | ៣២ដុ |
| ថាន សូផុន និង ធឿនយ៉ាវ | ៣២ដុ |
| នាង ផាន់-ណា | ៣០ដុ |
| លោកអាចារ្យ ប៉ុក-ធឿន ឧបាសិកា ញាណ-ឈឿម | ៣០ដុ |
| ឧបាសិកា លីម-ឈួន | ៣០ដុ |
| លោក គីម-កន អ្នកស្រី គីម-ណារិន និង បុត្រ | ៣០ដុ |
| ឧបាសិកា ប្រាក់-ហាន | ៣០ដុ |
| ឧបាសក កែម-សាន | ៣០ដុ |
| ឧបាសិកា សេង-គីមហ៊ន | ៣០ដុ |
| ឧបាសិកា អ៊ាក-គីម | ៣០ដុ |
| ឧបាសិកា ប៊ិត-ថងខាំ | ៣០ដុ |
| លោកអាចារ្យ នេត្រ-គឿន | ៣០ដុ |
| ឧបាសក សួគ៌-ស្រ៊ុន | ៣០ដុ |
| អ្នកស្រី សុផន-ខេន | ៣០ដុ |
| ឧបាសិកា ជិន-ស៊ីវអេង | ៣០ដុ |
| ឧបាសិកា អ៊ុន-យុន | ៣០ដុ |
| ភិក្ខុ សន្តិបាលត្ថេរ ឈន-អូន | ៣០ដុ |
| ភិក្ខុ ធម្មវិនយោ ទូច-ផន | ៣០ដុ |
| ភិក្ខុ យីម-វិចិត្រ | ៣០ដុ |
| ភិក្ខុ ខេមិយោ អឿន-ហ៊ាង | ៣០ដុ |
| ភិក្ខុ ស៊ិមហាក-ហេង | ៣០ដុ |
| ឧបាសិកា សរ-យុត | ៣០ដុ |
| លោក ភោ-សុផាត អ្នកស្រីសុខ-យី | ៣០ដុ |
| **TOUCH & SIMONE** | ៣០ដុ |
| ឧបាសិកា វ៉ាន់-ដា | ៣០ដុ |
| លោក ងិក-លី លក្ខិណា-លី និង ក្រុមគ្រួសារ | ៣០ដុ |



| | |
|---|---|
| ឧបាសិកា អ៊ុក-លឿប | ៣០ដុ |
| ឧបាសិកា សូ-សៀន ហៅ សូផន-សូ | ៣០ដុ |
| ក្រុមគ្រួសារ កូនចៅ ញោម អ៊ិន-សរ | ៣០ដុ |
| **YAN SIM** | ៣០ដុ |
| ឧបាសិកា អ៊ាត-អេង | ៣០ដុ |
| នាង ឆាត-ឆោម និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា ប៊ិត-ថងខាំ | ៣០ដុ |
| លី-វ៉ានី វិត្ថារា-តាន់ | ៣០ដុ |
| ឧបាសិកា ប៉ោ-យេង និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា ទន-យិន | ៣០ដុ |
| ឧបាសិកា ចាន់-គីមហ៊្វយ | ៣០ដុ |
| លោក ឌី-សូផល អ្នកស្រី ហួយ-សាត | ៣០ដុ |
| លោក គ្រី-ជិនលាង និង សុខា | ៣០ដុ |
| ឧបាសិកា សឿង-លឿង ឧបាសិកា យាន | ៣០ដុ |
| អ្នកស្រី ប៉ុក-សុគន្ធារុធ | ៣០ដុ |
| អ្នកស្រី ឡាយ-គុយអេង ព្រមទាំងបុត្រ | ៣០ដុ |
| លោក សំបូ-ចាន់ អ្នកស្រី អ៊ីន-ញ៉ី | ៣០ដុ |
| ឧបាសិកា មុំ-គីមឆេង | ៣០ដុ |
| ឧបាសក ជុំ-ហេង | ៣០ដុ |
| ឧបាសិកា គីម-ហូ | ៣០ដុ |
| **LIHOUR PROM** | ៣០ដុ |
| អ្នកស្រី រស់-សៅវ៉ាន | ៣០ដុ |
| លោក មាស-គង់ អ្នកស្រី មាស-ទូច | ៣០ដុ |
| ឧបាសក ព្រម-ផន ឧបាសិកា ពោធិ-ពាជ | ៣០ដុ |
| ឧបាសិកា មួង-ច័ន្ទ និង បុត្រធីតា | ៣០ដុ |
| ឧបាសិកា អ៊ូ-យុត្ថានី ឡេង ចាន់ រស្មី | ៣០ដុ |
| ឧបាសិកា **SENG SEANG LIM** | ៣០ដុ |
| ឧបាសិកា ខែត-យី | ៣០ដុ |
| ឧបាសិកា អ៊ីម-សាវ | ៣០ដុ |
| ឧបាសកសៀក-ស្រ៊ុន ឧបាសិកា គិត-ស្រ៊ុន | ៣០ដុ |
| លោក ឃួន ណុន និង សក់ ស៊ីនួន | ៣០ដុ |
| លោក ចាន់-សាម៉ន់ អ្នកស្រី ផល្លី | ៣០ដុ |
| លោក ហឿត-មឿន អ្នកស្រី ជីវ៉ា | ៣០ដុ |
| ឧបាសក គាត-ជ្រឹម ហៅ សារី | ៣០ដុ |

ឧបាសិកា ខាត់ ឧបាសិកា នឿយ-ខៀម ៣០ដុ
ឧបាសិកា ជី ឧបាសក ប៉ូន ៣០ដុ
ភិក្ខុ ពិសិដ្ឋ-កំសាន្ត ៣០ដុ
ភិក្ខុ គល-ស៊ីនួន ៣០ដុ
ឧបាសិកា វ៉ាយ-រុន ២៧ដុ
លោកអាចារ្យ ធូរ-ម៉ៅ ឧបាសិកា យ៉ឹយ-យ៉ាង ២៧ដុ
ឧបាសក យិម-ហ៊ីរិ និង ភរិយា ស៊ុម-ពេត ២៧ដុ
អ្នកស្រី និន-ឌិន ២៥ដុ
អ៊ឹម-ចាន់ ២៥ដុ
ប្រាក់-អាត់ ២៥ដុ
**IM KIMCHHORN** ២៥ដុ
ឧបាសិកា តាត-មុនី ២៥ដុ
ឧបាសក សេ ឧបាសិកា សុង ២៥ដុ
**NCHIN & CHAI EATON** ២៥ដុ
អ្នកស្រី ឯម-ពៅ ២៥ដុ
លោក បិន-កាន់ អ្នកស្រី វ័ត្ត-ថន កាន់-ធឿន កាន់-សុខា
គាន់-ដា កាន់-សុធា ២៤ដុ
អ្នកស្រី **TONG TIBET** ២៤ដុ
ឧបាសិកា សរ-យុត និង បុត្រធីតា ២២ដុ
បច្ច័បំសុកូល នៅវត្តសាន់តាអាណា ២២ដុ
អ្នកស្រី សារុំ និង កូនចៅ ២២ដុ
ឧបាសិកា ខេម-ច្រែស ២២ដុ
បងស្រី សារុម-ប៊ិច ២២ដុ
លោក សំរ៉ាន-វណ្ណដា អ្នកស្រី យិន-យ៉ាន កញ្ញា យិន-វន់ ២១ដុ
ឧបាសក យ៉ាំង-ស៊ីង ឧបាសិកា ថង-ស៊យ ២១ដុ
សេង-នី និង កូនចៅ ២១ដុ
ប៉ុក-គួន និង កូនចៅ ២១ដុ
លោក ហុង-ឯក អ្នកស្រី ផាត-ញ៉ិប ២១ដុ
ឧបាសិកា សុខ-ហួង ២១ដុ
លោក ថាច់-ប៊ុនធី អ្នកស្រី ឡឿង-សារ៉ាត ២១ដុ
អ្នកស្រី កែវ-ចន្ទី និង បុត្រ ២១ដុ
ឧបាសិកា ប៊ិច-សុខុម និង បុត្រ ២១ដុ
លោក ឈិម-អឿង អ្នកស្រី ឈឹម-វណ្ណា ២១ដុ



លោក ឈឹម-សាខន អ្នកស្រី ឡាច-សារឿន ២១ដុ
លោក កៅ-ជិន អ្នកស្រី កែវ-លួន ២១ដុ
អ្នកស្រី ម៉ុន-រ៉ាម៉ី ២១ដុ
អ្នកស្រី ម៉ុន-សូផន ២១ដុ
អ្នកស្រី ណុប-ណុំ ២០ដុ
ឧបាសិកា ជុក-សឿន ២០ដុ
អ្នកស្រី ប៉ូ-ណាន ២០ដុ
ឧបាសក ឈីន-ប៊ុនលីត និង ភរិយា ២០ដុ
ឧបាសិកា សយ-ប៊ុន ២០ដុ
ឧបាសិកា សៀក-សៀន ២០ដុ
ឧបាសិកា លីម-យ៉ុម ហៅ សាលី ២០ដុ
កញ្ញា យិន-ចាន់ណារា ២០ដុ
ឧបាសិក ថាច់-រ៉េង ២០ដុ
ជា-កែវបូរ៉ុន សាន-សុខា ២០ដុ
លោក តូច-ឧប្បាលា (ឆឹត) ២០ដុ
**SAORAN LATOUR** ២០ដុ
**BIN VETH** ២០ដុ
**BIN TOUCH** ២០ដុ
**BIN ARTH** ២០ដុ
**BIN RITH** ២០ដុ
**BIN BO** ២០ដុ
អ្នកស្រី ស៊ុម-បុប្ផា និង បុត្រ ២០ដុ
អ្នកស្រី ហំ-សំអាត និង បុត្រ ២០ដុ
មុត-សុផល ភោ-សូរឿន ២០ដុ
លោក អ៊ាប-ហាំងឃុន អ្នកស្រី អ៊ឹង-លីគាង ២០ដុ
ឧបាសិកា ស្តើង-មុយ ២០ដុ
អ្នកស្រី ធឿន លោកម៉ៅ បុត្រធីតា ២០ដុ
លោក ស៊ុម-វណ្ណៈ អ្នកស្រី វណ្ណី បុត្រធីតា ២០ដុ
ឧបាសិកា ហែម-ឃឹម ២០ដុ
សាមណេរ ចែម-សារ៉ាត ឧបាសិកា ស៊ុម-ស៊ុក ២០ដុ
យុវជន ថាច់-ចននី ២០ដុ
អ្នកស្រី សុភក្ត្រ-ឡឿង ២០ដុ
អ៊ឹម-សាលី ២០ដុ

| | |
|---|---|
| ឧបាសិកា លេង | ២០ដុ |
| ហុង (HONG) | ២០ដុ |
| អ្នកស្រី លី-គឹមស៊ី | ២០ដុ |
| វ៉ែន-សារឿន | ២០ដុ |
| ឧបាសក ចេក-ឃាន | ២០ដុ |
| ឧបាសក ឈុន-ម៉ៅ | ២០ដុ |
| លោក ជា-ហ៊្វង អ្នកស្រី តូ-សុផាន់ណា | ២០ដុ |
| អ្នកស្រី ផា-ឆាយ៉ាស៊ី | ២០ដុ |
| អ្នកស្រី គឹម-ហាន | ២០ដុ |
| អ្នកស្រី គឹម-ហេង | ២០ដុ |
| អ្នកស្រី ម៉ី-សុធារ | ២០ដុ |
| SEAK CHEA | ២០ដុ |
| ឈិន-លី (CHIN LEE) | ២០ដុ |
| ឧបាសិកា តូច-ឃុនណាង | ២០ដុ |
| BOU SAMY | ២០ដុ |
| ឧបាសិកា ងី-ឆេ | ២០ដុ |
| លោក ហ៊ិន-សុវណ្ណ នាង អ៊ឹង-មួយហ៊ាង | ២០ដុ |
| អ្នកស្រី លឹម-បុប្ផ | ២០ដុ |
| អ្នកស្រី លី-ង៉ែត លោកកូវ-គិហ្វលង់ | ២០ដុ |
| អ្នកស្រី ចាន់-លី | ២០ដុ |
| អ្នកស្រី ស៊ីម-សារ៉ន និងគ្រួសារ បុប្ផ-ស៊ីម | ២០ដុ |
| ឧបាសិកា ស៊ី-លេន | ២០ដុ |
| ជា-កែវបូរុន សាន-សុខា | ២០ដុ |
| តូច-ឧប្បាលា (ឆើត) | ២០ដុ |
| វ៉ាតធិរៈ | ២០ដុ |
| ឧបាសិកា មួង-សឿន និង បុត្រ | ២០ដុ |
| អ្នកស្រី ម៉ៅ-ហៀង | ២០ដុ |
| លោក ផូ-ចយ អ្នកស្រី យី | ២០ដុ |
| ឧបាសិកា អ៊ុន-អ៊ន | ២០ដុ |
| ឧបាសិកា ពេជ្រ-សួន | ២០ដុ |
| លោក កង-ជួន អ្នកស្រីទូច-រ៉េន | ២០ដុ |
| សុខុម, លោករ័ត្ន-វ៉ុន, ឌី-យ៉ានី, រូសាលីន, រូសានីណារា | ២០ដុ |
| ឧបាសក គឹម-សាំង ឧបាសិកា សួស | ២០ដុ |
| លោក មេ-ប៉ុង | ២០ដុ |



| | |
|---|---|
| លោក ថាំង-ចេវ ព្រមទាំងគ្រួសារ | ២០ដុ |
| ឧបាសិកា មិល-ម៉ាលី | ២០ដុ |
| លោក ថាច់-ថេង អ្នកស្រី ប្រាក់-សាម | ២០ដុ |
| កញ្ញា លី-ថុងសូលីដា | ២០ដុ |
| កញ្ញា លី-សូលីណា | ២០ដុ |
| ឧបាសក លី-ថុង ឧបាសិកា មាឃ-គឹមសាន | ២០ដុ |
| YONG SITHON | ២០ដុ |
| ឧបាសិកា អ៊្វ-ឆេង និង កូនស្រី លីដា | ២០ដុ |
| លោក សារឿត-រិត និង គ្រួសារ | ២០ដុ |
| ឧបាសក សួន-សារិ ឧបាសិកា ទឹម-ញ៉ | ២០ដុ |
| ឧបាសិកា ញាណ-សុំ | ២០ដុ |
| ឧបាសិកា ណាយ-ប៊ុនម៉ា | ២០ដុ |
| លោក ហួយ-យ៉ុង អ្នកស្រី ហ៊ុន-សារ៉ុម និង បុត្រ | ២០ដុ |
| ភិក្ខុ សុធម្មប្បញ្ញោ ចន្ទ-ស៊ី, ឧបាសិកា ស៊ុយ-សាង | ២០ដុ |
| លោកគ្រូសូត្រ ផល | ២០ដុ |
| លឹម-ញ៉ុល ពិន-អ៊ិត និង កូនចៅ | ២០ដុ |
| ស៊ូ-ឡុង ណៃ-យឹម | ២០ដុ |
| ឧបាសិកា គង់-សុគន្ធា និង បុត្រធីតា | ២០ដុ |
| ឧបាសិកា ឡុង-ស៊ីនួន | ២០ដុ |
| លោក សន-ណាត និង គ្រួសារ | ២០ដុ |
| លោក ខៀវ-ដារារ័ត្ន អ្នកស្រី ងួន-ច័ន្ទថា | ២០ដុ |
| លោក សំ-សារឿន អ្នកស្រី មឿន-យ៉ឹង | ២០ដុ |
| Mr. CHM KHOUN | ២០ដុ |
| លឹម-ស៊ីវបី និង បុត្រក្មួយ អ៊ឹង-ប៊ុន-ម៉ៅ ពិសី-ជៀវ បុត្រធីតា | ២០ដុ |
| PHATH RTH | ២០ដុ |
| ឈិត-ដាវ សុជាតា លោក លី-សុខខែន ឆី-ម៉ាលីណា | ២០ដុ |
| ឧបាសិកា សយ-ប៊ុន | ២០ដុ |
| ឧបាសិកា សៀក-សៀន | ២០ដុ |
| ឧបាសិកា លឹម-យ៉ុម ហៅ សាលី | ២០ដុ |
| កញ្ញា យិន-ចាន់ណារា | ២០ដុ |
| ឧបាសិកា ថាច់-រ៉េង | ២០ដុ |
| លោក ខៀវ-សារឿន និង គ្រួសារ | ២០ដុ |
| លោក ឌុក-ប៊ុនភិត និង ណាម-រិត | ២០ដុ |
| សុខ-នីន នាង ជឹម-កញ្ញា | ២០ដុ |

| | |
|---|---|
| អ្នកស្រី ហ៊ីម-ឡុង | ២០ដុ |
| អ្នកស្រី នី-ផា និង ភ្វាមី | ២០ដុ |
| អ្នកស្រី សួន-វី និង ស្វាមី | ២០ដុ |
| អ្នកស្រី វ៉ាន់-គៀ | ២០ដុ |
| ឧបាសិកា ញ៉ក់-ហួ ព្រមទាំងបុត្រ | ២០ដុ |
| អ្នកមីង ម៉ៅ-សារុន | ២០ដុ |
| អ្នកស្រី នុន-រិត និង គ្រួសារ | ២០ដុ |
| លោក ប្រាក់-ភន អ្នកស្រី ភិន-វ៉ាន់ណាន | ២០ដុ |
| លោក ប៉ុក-សុគន្ធាណា | ២០ដុ |
| អ្នកស្រី ស៊ីម-សាវ៉ែន លោក ផេង-ហួត និង បុត្រ | ២០ដុ |
| ឧបាសិកា ឈឺ-ស៊ីវហ៊ាង | ២០ដុ |
| ទូច-លីមសេង ម៉ែន-សុខឿន | ២០ដុ |
| ឧបាសិកា មាស-ដា | ២០ដុ |
| ឧបាសិកា ចាន់-សូផាត | ២០ដុ |
| ទាយិកា ពិសី | ២០ដុ |
| ឧបាសិកា ខាន់-ហួយ | ២០ដុ |
| ឈិត-ដាវ ច័ន្ទសិតា កែវ-សុវណ្ណ | ២០ដុ |
| ឧបាសក ឃុន-ម៉េហាវ ឧបាសិកា សៀវ-ឆេង | ២០ដុ |
| ឧបាសិកា គង់-យ៉េន | ២០ដុ |
| **SOPHAN TAN** | ២០ដុ |
| លោក សុខ-មឿត អ្នកស្រី ហេង-វ៉ាន់ | ២០ដុ |
| លោក ស៊ូ-ស៊ីម អ្នកស្រី គិន-សំបូរ | ២០ដុ |
| ព្រហ្ម-មាស សុវណ្ណ | ២០ដុ |
| ឧបាសិកា យស-ម៉ន | ២០ដុ |
| លោក ឡាំង-គិមឆេង | ២០ដុ |
| ទាយក សុផល | ២០ដុ |
| លោកអាចារ្យ ថាច់-ងុក ជា-គិមតាក | ២០ដុ |
| ឧបាសិកា ហង្ស-សំអុល | ២០ដុ |
| លោក សុយុទ្ធ-ចេឡា អ្នកស្រី ជ្រក-បាច | ២០ដុ |
| ហ៊ុន-គីមហេង | ២០ដុ |
| លោក ជា-ស៊ីវត្ថនា អ្នកស្រីឃុន-សូនីម៉ា និង បុត្រ | ២០ដុ |
| ឧបាសិកា ហ-ស៊ុន | ២០ដុ |
| អ្នកស្រីសក់-សំនៀង និង គ្រួសារ | ២០ដុ |
| អាចារ្យនាង-ណាត | ២០ដុ |



| | |
|---|---|
| ឧបាសក កែវ-ឆាត ឧបាសិកា នង-រុន | ១៨ដុ |
| ឧបាសក កៅ-លីសេង ឧបាសិកា ចាប់-ម៉ានី | ១៨ដុ |
| ស្រី-ហឿន និង កូន | ១៨ដុ |
| ស៊ីម-វេងគាវ និង កូន | ១៨ដុ |
| ឧបាសិកា អ៊ុន-ផៃ ហៅស៊ីថា | ១៨ដុ |
| លោក សួត-តេង អ្នកស្រី ហ៊យ-សៀន និង បុត្រធីតា | ១៨ដុ |
| លោក ស៊ីម-សារិត អ្នកស្រី ហ៊យ-សែន និង បុត្រធីតា | ១៨ដុ |
| លោក លឹម-ទិត អ្នកស្រី សែម-សុខុន | ១៨ដុ |
| លោក ហ៊យ-សុថាន អ្នកស្រី ស៊ុម-ម៉ាច និង បុត្រ | ១៨ដុ |
| អ្នកឥតមានឈ្មោះ | ១៧ដុ |
| ឧបាសិកា អ៊ាវ-ប៊ួយ និង បុត្រធីតា | ១៧ដុ |
| លោក សារួន និង គ្រួសារ | ១៥ដុ |
| អ្នកស្រី តាំង-ដាវណ្ណៈ | ១៥ដុ |
| អាចារ្យ អ៊ុក-សែម ឧបាសិកា ហង់-ជីម | ១៥ដុ |
| ឧបាសិកា សាត់-ចាន់ | ១៥ដុ |
| លោក ប្រាក់-ផន អ្នកស្រី ភិន-បាណាន | ១៥ដុ |
| លោក គីម-សារុន អ្នកស្រី រូ-គីរី | ១៥ដុ |
| ឧបាសិកា ឆែម-ឡាប និង បុត្រធីតា | ១៥ដុ |
| **SOUPHAPHONE KEOVONGKOT** | ១៥ដុ |
| អ្នកស្រី វ៉ានី លោក ពុទ្ធជន និង បុត្រធីតា | ១៥ដុ |
| លោកសៀវ-គីមរួច និង ភរិយា | ១៥ដុ |
| លោក ទូច-ទិព អ្នកស្រី ខេម-ភាព | ១៥ដុ |
| លោក សៀន អ្នកស្រី ចរិយា | ១៥ដុ |
| លោក ពើង-យឿម | ១៥ដុ |
| អ្នកស្រី ពើង-សុខុម | ១៥ដុ |
| ពើង-ចិរតេជ | ១៥ដុ |
| ពើង-ចិរវណ្ណ | ១៥ដុ |
| យាំង-វិន្នា | ១៥ដុ |
| នាង លក្ខិណា | ១៤ដុ |
| លោក សួង-សុភាព អ្នកស្រី សួង-មាលី | ១៤ដុ |
| ឧបាសិកា ទេស-សុន និង កូនចៅ | ១៤ដុ |
| លោក សុខ-ហេង ឧបាសិកា សឿង-អេង | ១៤ដុ |
| លោក ថាច់-ឈួង អ្នកស្រី យ៉ែម-ចន្ធូ និង បុត្រធីតា | ១៤ដុ |
| អ្នកស្រី មឿន-រស្មី និង បុត្រធីតា | ១៣ដុ |

| | |
|---|---|
| យ៉ាំង-ដាំ | ១២ដុ |
| ឧបាសិកា ចាប-ឃិន | ១១ដុ |
| ឧបាសិកា ម៉ៃ-សារ៉េត | ១១ដុ |
| ឧបាសិកា ផាន់-សួង | ១១ដុ |
| កញ្ញា ហុង-ភានី | ១១ដុ |
| លោក សេង-សុត អ្នកស្រី ហ៊ាយ-ពៅ | ១១ដុ |
| លោក សេង-ស៊ិន និង កូន សេង-សាលីណា | ១១ដុ |
| លោក សេង-ស៊ីម អ្នកស្រី ញ៉ែម-គឿន | ១១ដុ |
| កញ្ញា សេង-រតនា | ១១ដុ |
| អ្នកស្រី ឡាច-សុផល | ១១ដុ |
| ឧបាសិកា ង៉ែត-ហួយ | ១១ដុ |
| អ្នកស្រី ស៊ីសុវត្ថិ ច័ន្ទ វល្លក្ខិណា | ១១ដុ |
| លោក សេក-អាង | ១១ដុ |
| លោក ហ៊ាយ-សុខា អ្នកស្រី ចន្ធី និង បុត្រធីតា | ១១ដុ |
| នាង ឡាច-សុផាន | ១១ដុ |
| លោក ពែក-សំអៀត កុត-អ៊ៃ | ១១ដុ |
| លោក កែវ-កែន ពែក-សុភា | ១១ដុ |
| លោក ពែក-សំណាង ស្រី អែម | ១១ដុ |
| លោក ពែក-សម្ភស្ស | ១១ដុ |
| នុត-ស៊ីម | ១០ដុ |
| អ៊ុ-ស៊ីន | ១០ដុ |
| អ្នកស្រី ពុំ-សូភី លោក មួង-សំអាត | ១០ដុ |
| ឧបាសិកា ម៉ុម-រី | ១០ដុ |
| លោក ប៊ុន-លឿង និង ភរិយា | ១០ដុ |
| ឧបាសិកា ហេង-ស៊ីវទៀង និង បុត្រធីតា | ១០ដុ |
| ឧបាសិកា លី-សារី | ១០ដុ |
| ឧបាសិកា ពៅ-យឺន ឧបាសក អ៊ឹម-យន | ១០ដុ |
| នាង បាយ-អូន និង ក្រុមគ្រួសារ | ១០ដុ |
| លោក សារ៉ាត-រិត និង គ្រួសារ | ១០ដុ |
| ឧបាសិកា ចឹក-ង៉ឿន | ១០ដុ |
| ភិក្ខុ ព្រុំ-សៀន | ១០ដុ |
| អ្នកស្រី ហេង-ឈាប | ១០ដុ |
| អ្នកស្រី ស-សុខា | ១០ដុ |
| អ្នកស្រី សួន-សុខុម | ១០ដុ |



| | |
|---|---|
| សាន-ស៊ីយន | ១០ដុ |
| សាន-ស៊ុំផិត សុខ-ជា | ១០ដុ |
| សាន-សុខយន យស់-សុវណ្ណ | ១០ដុ |
| ភិក្ខុ យ៉ែម-ណាក បស្សន្នោ | ១០ដុ |
| **TI CHHOR** | ១០ដុ |
| អ៊ាក-តាំង | ១០ដុ |
| អ្នកស្រី សុខ-សំ | ១០ដុ |
| អ្នកស្រី គួច-ឃីម | ១០ដុ |
| ឧបាសិកា អ៊ុម-ថុល | ១០ដុ |
| ឧបាសិកា ហ៊ុយ-ភន | ១០ដុ |
| លោក សុវណ្ណ-ឈុន ឧបាសិកា ប៉ែន | ១០ដុ |
| អ្នកស្រី សីម-គាវ | ១០ដុ |
| លោក ឃីម-សេង អ្នកស្រីសឿន | ១០ដុ |
| អ្នកស្រី ប៊ុន-ហេង | ១០ដុ |
| កញ្ញា យ៉ែម-ស្រីមុំ | ១០ដុ |
| កញ្ញា យ៉ែម-ស្រីអូន | ១០ដុ |
| លោក ប៊ឹក-ឈាង អ្នកស្រី ហែម-ឆេងប៉ៅ | ១០ដុ |
| ឧបាសកា នួន-សេង ឧបាសិកា គង់-ណារ៉ាន់ | ១០ដុ |
| ឧបាសិកា ង៉ែត-ខុន | ១០ដុ |
| លោកអាចារ្យ សាម-គុណ ឧបាសិកា រ័ត្ន-រី | ១០ដុ |
| ឧបាសិកា រិន លោកតា ជឿម កូនចៅ | ១០ដុ |
| ឧបាសិកា លី-សាយជូ | ១០ដុ |
| ឧបាសិកា បេ-យ៉េន | ១០ដុ |
| ដន្លងឧបាសិកាឆាន់-កាន់ជួង | ១០ដុ |
| ផេង-នាង | ១០ដុ |
| ប៊ុត-សុខា | ១០ដុ |
| ឧបាសក សារឿន ឧបាសិកា ប៉ុក-មិន | ១០ដុ |
| លោក អ៊ុម-សុផល អ្នកស្រី ឡុង-ភា | ១០ដុ |
| លោក សានី អ្នកស្រី ភិរុន និងបុត្រធីតា | ១០ដុ |
| លោក មាស-សាំង | ១០ដុ |
| ឧបាសិកា ចាន់-ឡុង និង កូនចាន់-លី | ១០ដុ |
| អ្នកស្រី ឌុង-បភាវត្តី ស្វាមី និង បុត្រ | ១០ដុ |
| អ្នកស្រី ព្រីន-រ៉ាន់ | ១០ដុ |
| អ្នកស្រី នួន-សុភី | ១០ដុ |

| | |
|---|---|
| អ្នកស្រី ញឹក-លី | ១០ដុ |
| កញ្ញា មៀច-មករា | ១០ដុ |
| លោក កែវ-កុសល | ១០ដុ |
| KAO CHANDANY | ១០ដុ |
| អ្នកស្រី ជាម-ហ្វីង | ១០ដុ |
| លោក អ៊ុក-ស៊ុម អ្នកស្រី អ៊ុក-ផេងឡេង | ១០ដុ |
| លោក អ៊ិញ-សិញ អ្នកស្រី ជុយ-ណៃអ៊ិញ | ១០ដុ |
| អាភា | ១០ដុ |
| លោក មូត្រ-វិចិត្រ អ្នកស្រីកែ-សឿន | ១០ដុ |
| ឆាន់-ជន | ១០ដុ |
| លីម-សុខជូ | ១០ដុ |
| អ្នកស្រី តែ-ស៊ីវលាង | ១០ដុ |
| អ្នកស្រី អ៊ី-យឹក អែម-មី-យាំ | ១០ដុ |
| លោកជួង-ប៉ាន នាង ញ៉ិល-មាលិះ និង ញ៉ិល-ឥន្ទ្រីយ៍ | ១០ដុ |
| នាង KIM ROS | ១០ដុ |
| CHAYA DARY និង កូនទាំង ២ | ១០ដុ |
| ឧបាសិកា ឡុង-អ៊ី | ១០ដុ |
| ឧបាសិកា ទូច-យ៉ុន | ១០ដុ |
| ឧបាសិកា ប៊ិន-រ៉ា | ១០ដុ |
| ឧបាសិកា ព្រះ-ឈាង | ១០ដុ |
| នាង លី-ឆៃ | ១០ដុ |
| អ្នកស្រី ផាន់-សារឹម | ១០ដុ |
| ឧបាសក ថាច់-សូផាត អ្នកស្រី យង-វន្នី | ១០ដុ |
| លោកយាយ តាន់-ប៉ាវ | ១០ដុ |
| ដារី-រិត | ១០ដុ |
| ឧបាសិកា ប្រីយ-យ៉ុម | ១០ដុ |
| ឧបាសិកា អ៊ូ-នង | ១០ដុ |
| លោក ធឿម អ្នកស្រី ណៃប | ១០ដុ |
| លោក ប៊ូ-យើន និង សុមាលី | ១០ដុ |
| អ្នកស្រី ញឹប | ១០ដុ |
| អ្នកស្រី យ៉ង់-ម៉ៅ | ១០ដុ |
| លោក ភូ-តេង អ្នកស្រី ធី | ១០ដុ |
| លោកស្រី ម៉ា-សុទ្ធ | ១០ដុ |
| អ្នកស្រី អ៊ាង-ដាវ | ១០ដុ |



| | |
|---|---|
| ទាយក ថន | ១០ដុ |
| ញោម សៀង-លិម | ១០ដុ |
| លោកស៊ី-សំបាន និង គ្រួសារ | ១០ដុ |
| ឧបាសិកា សុខ-យ៉ាន | ១០ដុ |
| លោក យ៉ាវ-នាង នាងសុខា | ១០ដុ |
| ឧបាសិកា អ៊ឹម-អឿន | ១០ដុ |
| ញោម លីណា | ១០ដុ |
| ឧបាសិកា ម៉ិល-ប៊ិច | ១០ដុ |
| ឧបាសិកា តឹក-អុន | ១០ដុ |
| ឧបាសិកា អែម-ទេត | ១០ដុ |
| ឧបាសក សេក-ម៉ុន ឧបាសិកា កែវ-អ៊ិន | ១០ដុ |
| ឧបាសិកា អ៊ាប-ច័ន្ទលី | ១០ដុ |
| ឧបាសិកា យិន-កែម | ១០ដុ |
| ឧបាសិកា ម៉ឹង-លន់ | ១០ដុ |
| អ្នកស្រី អឿន-សារី | ១០ដុ |
| មែឡូ-ថានោកា | ១០ដុ |
| ឈិត-ដាវគុណទ្រី | ១០ដុ |
| ឈិត-ដាវចិត្រា | ១០ដុ |
| ឈិត-ដាវសៅ-រ៉ាន្នី | ១០ដុ |
| លោក ទេស-សាមិត | ១០ដុ |
| ឧបាសិកា អឿង | ១០ដុ |
| ទាយិកា ចន្ទ | ១០ដុ |
| ឧបាសិកា ផាន-ឡុង | ៩ដុ |
| យ៉ាំង-សគុណា | ៩ដុ |
| ហ៊ុយ-សវេត | ៩ដុ |
| យ៉ាំង-ស៊ីវុត | ៩ដុ |
| យ៉ាំង-សវេត | ៩ដុ |
| ឧបាសិកា ជា-គួរ | ៧ដុ |
| អ្នកស្រី ជិន-វីរ៉ា និង ស្វាមី | ៧ដុ |
| លោក ជិន-ប៉ៀល្លី និង ស្រី នុត | ៧ដុ |
| លោក សួន-ច័ន្ទី អ្នកស្រី គីម-លី | ៧ដុ |
| លោក ប៉េង-លី និង សុរតន៍ | ៧ដុ |
| លោក ប៉ិល-អៀត អ្នកស្រី ស៊ីណា | ៧ដុ |
| អ្នកស្រី កែវ-វ៉េត | ៧ដុ |

| | |
|---|---|
| ឧបាសិកា ឈឿម-វ៉ាន់ | ៧ដុ |
| អ្នកស្រី ហង់-គីមយ៉ាន | ៧ដុ |
| ឧបាសិកា ឡាង | ៧ដុ |
| ឧបាសិកា សំ-យិន | ៧ដុ |
| ឧបាសិកា ឌួង-ច័ន្ទបុប្ផា និង បុត្រ | ៧ដុ |
| លោក វ៉េម-អួន | ៧ដុ |
| ឧបាសិកា ម៉ែន-ស៊ិម | ៧ដុ |
| ឧបាសិកា ឡាង | ៧ដុ |
| អ៊ូច-រឿន | ៧ដុ |
| ឧបាសិកា ស៊ុន-ឡាយ | ៧ដុ |
| អ្នកស្រី ជីច-ណាង និង អ៊ី-ខ្វាន់នី | ៧ដុ |
| លោកតា អៀ-សឿន លោកយាយ គិម-ឈុន | ៧ដុ |
| ឧបាសិកា វង-ហ៊្វីង និង កូន ថូ-សាឡៅ | ៧ដុ |
| លោក ថូ-ច័ន្ទតារា និង គ្រួសារ | ៧ដុ |
| អ្នកស្រី ថូ-វ៉ាន់ឌី និង គ្រួសារ | ៧ដុ |
| អ្នកស្រី ថូ-និកា និង គ្រួសារ | ៧ដុ |
| លោក ថូ-សុខវ៉ាន់ និង គ្រួសារ | ៧ដុ |
| លោក ស្ទីម-សាម៉ុន អ្នកស្រី សំសុខន | ៧ដុ |
| ណោន-សុខជា | ៧ដុ |
| សូង-សុភ័ណ | ៧ដុ |
| សូង-ផែមម៉ាឡា | ៧ដុ |
| លោក លីម-តៅខេង អ្នកស្រី ហេង-ស៊ីហាន | ៧ដុ |
| សូង-សុភា | ៧ដុ |
| ហ៊ុយ-ប្រេសសិណា | ៦ដុ |
| ហ៊ុយ-ប្រេសតូន | ៦ដុ |
| ឧបាសិកា សុត-ទេព | ៦ដុ |
| ឈិត-ដាវសុខានី | ៥ដុ |
| លោក មាន-អានី | ៥ដុ |
| ឧបាសិកា រស់-ស៊ុំ | ៥ដុ |
| លោកយាយ ល នាង-ប៉ុក | ៥ដុ |
| ញ៉ែម-សារ៉េត | ៥ដុ |
| សិន-ឌី | ៥ដុ |
| អចារ្យ ជូ-មី ឧបាសិកា បូលីន កូន | ៥ដុ |
| ឧបាសិកា ប៊ូ-ឡាយ | ៥ដុ |



| | |
|---|---|
| ឧបាសកា ឈាន | ៥ដុ |
| ឧបាសិកា ឆេង-យាន | ៥ដុ |
| ឧបាសិកា អ៊ុំ-ម៉ច | ៥ដុ |
| ឧបាសិកា ទូច-សំបូរ | ៥ដុ |
| **SAMNANG TOUCH & SOKHEUN** | ៥ដុ |
| អ្នកស្រី ភិន-នី | ៥ដុ |
| ឧបាសិកា ហេង-ហេង | ៥ដុ |
| **CHOY PHANIXAY** | ៥ដុ |
| លោក ភួង-នេនៅ និង ភរិយា | ៥ដុ |
| ឧបាសិកា អ៊ុំម-ម៉ុន | ៥ដុ |
| ឧបាសិកា ឃួន-ខាំ | ៥ដុ |
| លោក ប្រម-គ្រួច និង ភរិយា | ៥ដុ |
| លោក អាត់ អ្នកស្រី យិន-យិ | ៥ដុ |
| លោក មែក-សាខន អ្នកស្រី លី-ឡុង | ៥ដុ |
| លោកតា ជុំ-សុន | ៥ដុ |
| ឧបាសិកា ទិត្យ-លេន | ៥ដុ |
| លោក ទេស-ហ៊ាន | ៥ដុ |
| ឧបាសិកា ឌី-ប៊ុនឆាន | ៥ដុ |
| អ្នកស្រី សេង-ផល្លិ | ៥ដុ |
| **CHOUK PHEUN** | ៥ដុ |
| **BUNHANG KON** | ៥ដុ |
| លោក កែវ-ចាន់ អ្នកស្រី ឃឹម-អេង | ៥ដុ |
| ហ៊ាយ-គ្រីស្ទហ្វឺ | ៨ដុ |
| ហ៊ាយ-គ្រីស្ទីណា | ៨ដុ |
| ណោន-សាម៉េត | ៨ដុ |
| ណោន-សាមុត | ៨ដុ |
| ណោន-សុអេង | ៨ដុ |
| ណោន-ផាន់ណាត | ៨ដុ |
| លោក ញ៉ែម-សារឹម | ៨ដុ |
| ឧបាសិកា ណែម | ៨ដុ |
| លោក ថង-ឈុត | ៨ដុ |
| ឧបាសិកា នី-វ៉ាន់ | ៨ដុ |
| លោក ហូ អ្នកស្រី ប៊ុង | ៨ដុ |
| ឧបាសិកា ខឹម-រុន | ៨ដុ |

| | |
|---|---|
| អ្នកស្រី សុខ-វណ្ណា | ៥ដុ |
| អ្នកស្រី រី-លីនអ៊ុប | ៥ដុ |
| អ្នកស្រី សុជាតិ និង គ្រួសារ | ៥ដុ |
| ឧបាសិកា ហេង-ស៊ីន | ៣ដុ |
| ឧបាសិកា គុណ | ២ដុ |
| អ្នកស្រី ណូ-នីឡា | ២ដុ |

## កំហុសតែងមានជាធម្មតា

ខ្ញុំសូមខន្តីអភ័យទោសអំពីសំណាក់ព្រះតេជះព្រះ
គុណព្រះថេរានុថេរៈ និង ពុទ្ធបរិស័ទទាំងអស់
កាលបើមានការបាត់ឈ្មោះ ឬ ខុសឈ្មោះ
និង
កាលបើមានការខុសឆ្គងដោយប្រការផ្សេងៗ
ទៀតនោះ សូមព្រះតេជះព្រះគុណ និង
ពុទ្ធបរិស័ទទាំងអស់ អនុគ្រោះផងចុះ ។
សូមអរព្រះគុណ និង អរគុណទុកជាមុន !

សូមប្រគេនពរ និង ជូនពរ

♣ ♣ ♣



សូមពុទ្ធបរិស័ទរង់ចាំសិក្សាសៀវភៅ
**វិសុទ្ធិមគ្គប្រែ ភាគទី២ និង ភាគទី៣**
ដែលនឹងបោះពុម្ពផ្សាយជាធម្មទាន
នៅពេលខាងមុខនេះជាបន្តទៀត ។

សូមពុទ្ធបរិស័ទជួយឧបត្ថម្ភ ក្នុងកិច្ចការធម្មទាននេះ
តាមកម្លាំងសទ្ធាជ្រះថ្លារៀងៗ ខ្លួន

សូមទាក់ទង : ភិក្ខុវិនយធរោ មហាយិន-នឿន
វត្តខ្មែរសាន់តាអាណា
2630 N. Grand Ave. Santa Ana, CA 92705
(714) 744-2844
**U.S.A**

ទាក់ទង: ភិក្ខុ យ៉ាន-សារុន
**វត្តទួនមុនីរាម (ហៅវត្តថាន់) ភ្នំពេញ**
០២២-៨៧-៣០-០៩

និង

ទាក់ទង: ភិក្ខុប្រាក់-ផល្លី
**វត្តបទុមវតី ភ្នំពេញ**
០៩២-៩៤-៦៧-៨៧